# បរមត្ថជោតិកា

## អដ្ឋកថា-ខុទ្ទកបាឋ

រចនាដោយព្រះពុទ្ធឃោសាចារ្យ

ពុទ្ធសករាជ ២៥៥៤

# បរមត្ថជោតិកា

## ខុទ្ទកបាឋ-អដ្ឋកថា

## សុត្តន្តបិដក ខុទ្ទកនិកាយ

## លេខ ៥២

ប្រែជាខេមរភាសា

បោះពុម្ពលើកទី ១

ចំនួន ៣.០០០ ច្បាប់

**ការផ្សាយរបស់ព្រះសង្ឃវត្តបាការនិវេសន៍ កំផែង**

**ព.ស ២៥៥៤**

# PARAMATTHAJOTIKĀ

## (Commentary)

## SUTTA-PIṬAKA

Khuddaka-nikāya

Khuddakapatha

**Translated from Pali to Khmer**

**1st Edition 3.000 Copies**

**A publication**

**Of**

**Wat PĀKĀRAKNIVESANĀRĀM KAMPHENG'S MONK**

**B.E 2554**

# អារម្ភកថា

## សុខា សទ្ធម្មទេសនា

ការសម្ដែងឡើងនូវធម៌របស់សប្បុរសជាហេតុបាននូវសេចក្ដីសុខ

អស់រយៈកាលជាង ២៥០០ ឆ្នាំមកហើយ ដែលព្រះអនាវរណញ្ញាណ បានប្រកាសសម្ដែងនូវព្រះសទ្ធម្មរបស់ព្រះអង្គ។ព្រះធម៌ ដែលជាពុទ្ធវចនៈបានប្រសូត ចេញពីព្រះឱស្ឋនៃព្រះសម្ពុទ្ធ ។ ការប្រកាសនូវព្រះធម្មចក្កប្បវត្តនសូត្រ របស់ព្រះអង្គ ក្នុងថ្ងៃ ១៥ កើត ខែ អាសាឍ ឆ្នាំ រកា បានញ៉ាំងឱ្យព្រះអញ្ញាកោណ្ឌញ្ញ និងព្រហ្មចំនួន ១៨ កោដិ តាំងនៅក្នុងអរិយសម្បត្តិ នេះជាប្រវត្តិដំបូងនៃប្រវត្តិសាស្ត្រមនុស្សជាតិ ដែលបានស្គាល់ព្រះពុទ្ធសាសនា ។ បន្ទាប់ពីប្រកាសសម្ដែងព្រះធម៌នេះមក ព្រះមានព្រះភាគជាម្ចាស់ បានចំណាយពេលខាងចុងនៃវដ្ដសង្សាររបស់ព្រះអង្គ ដើម្បីប្រកាសសម្ដែងព្រះធម៌ ក្នុងគោលបំណងបង្ហាញផ្លូវឆ្ពោះទៅកាន់សន្តិវរបទ គឺព្រះនិព្វាន ដល់វេនេយ្យសត្វ។មានពេលខ្លះ ការសម្ដែងព្រះធម៌របស់ព្រះអង្គ បានញ៉ាំងឱ្យសត្វលោក បានត្រាស់ដឹងរាប់ចំនួនមិនបាន ដូចព្រះថេរៈមានព្រះនាមថា ព្រះសារីបុត្ត ជនជាតិស្រីលង្កា (ព.ស ១៦៩៦)[១] ជាព្រះដីកាចារ្យ ដ៏ប្រសើរបានរចនា គម្ពីរសារត្ថទីបនីដីកា ដីកាព្រះវិន័យ ត្រង់វេរញ្ជកណ្ឌវណ្ណនា មានសេចក្ដីថា "ព្រះមានព្រះភាគ ព្រះអង្គឧប្បត្តិឡើងក្នុងលោក ដើម្បីអនុគ្រោះដល់លោក ។ តើព្រះអង្គបានអនុគ្រោះយ៉ាងណា? បុគ្គលឯណា កាលស្ដាប់ព្រះធម្មវិសេសទេសនា របស់ព្រះតថាគត បានផឹកនូវទឹកអម្រឹតចាក់ផ្លុះនូវព្រះធម៌ ព្រះមានព្រះភាគតែងអនុគ្រោះដល់បុគ្គលពួកនោះ ។ មែនពិត នាកាលព្រះភគវន្តមុនី ព្រះអង្គបានញ៉ាំងពេលឱ្យកន្លងទៅ ៧ សប្ដាហ៍ នា

---

១-ព្រះសារីបុត្តត្ថេរ ជាបិដកធរ មានព្រះជន្មក្នុងរាជ្យព្រះបាទបរក្កមពាហុ ។ វណ្ណកម្មរបស់ព្រះថេរៈអង្គនេះ មានវិនយសង្គហ ឬវិនយវិនិច្ឆ័យ ជាគម្ពីរដែលបរិយាយយ៉ាងសង្ខេបពីព្រះវិន័យ, សារត្ថទីបនី ជាដីការបស់គម្ពីរសមន្តប្បាសាទិកា,គម្ពីរសារត្ថមញ្ជូសា ជាដីការបស់គម្ពីរអដ្ឋសាលិនី, នីលដ្ឋប្បកាសិនី ជាគម្ពីរដីការបស់គម្ពីរបបញ្ចសូទនី ។ លោកមានកូនសិស្សឆ្នើមៗជាច្រើនអង្គ ដូចជាសង្ឃរក្ខិត, សុមង្គល, ពុទ្ធនាគ និងវាចិស្សរជាដើម ។

Dictionary of Pali Proper Names,By G.P.MALALASEKERA,1974 .

ពោធិមណ្ឌល ព្រះអង្គបានយាងចេញពីពោធិមណ្ឌល ទៅកាន់ព្រៃឥសិបតនមិគ-ទាយវ័ន ដើម្បីប្រកាសសម្តែងព្រះធម្មចក្កប្បវត្តនសូត្រ ដោយន័យជាដើមយ៉ាងនេះថា **ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា** ម្នាលភិក្ខុទាំងឡាយ អន្តធម៌ទាំងឡាយពីរយ៉ាងនេះឯង ភិក្ខុមិនគួរសេពឡើយ ដូច្នេះ ព្រះអញ្ញា-កោណ្ឌញ្ញត្ថេរដ៏មានអាយុ មួយអន្លើដោយព្រហ្ម ១៨ កោដិ បានផឹកនូវទឹកអម្រឹត ។ ក្នុងថ្ងៃទីប្រាំ បន្ទាប់ពីប្រកាសធម្មចក្កប្បវត្តនសូត្រមក ព្រះដ៏មានព្រះភាគបានសម្តែងនូវអនត្តលក្ខណសូត្រ ក្នុងទីបំផុតនៃព្រះសូត្រ បញ្ចវគ្គិយភិក្ខុ បានតាំងនៅក្នុងព្រះអរហត្ត ។ ក្រោយមក ព្រះអង្គបានញុំាំងបុរស ៥៥ រូប មានយសកុលបុត្រ ជាប្រមុខឱ្យតាំងក្នុងព្រះអរហត្ត ហើយនៅឯដងព្រៃកប្បាសិកវ័នញុំាំងភទ្ទវគ្គិយ ៣០ រូប ឱ្យតាំងនៅក្នុងមគ្គ ៣ ផល ៣ ។ បន្ទាប់ពីនោះមកទៀត ព្រះបរមលោកនាថ បានញុំាំងជដិល ១០០០ រូប នៅឯគយាសីសប្រទេស ឱ្យតាំងនៅក្នុងព្រះអរហត្ត ក្នុងទីបំផុតនៃអាទិត្តបរិយាយសូត្រ ចំណែកឯក្នុងព្រៃលដ្ឋិវ័ន ព្រាហ្មណ៍ និងគហបតិ ចំនួន ១១ ម៉ឺននាក់ មានព្រះបាទពិម្ពិសាររាជជាប្រមុខ ក្រោយពីបានស្តាប់ព្រះធម្មទេសនា បានតាំងក្នុងសោតាបត្តិផល, ហើយចំនួន ១ ម៉ឺន នាក់ទៀត បានតាំងនៅក្នុងសរណគមន៍ ។ ក្នុងទីបំផុតនៃការអនុមោទនាតិរោកុឌ្ឌសូត្រ សត្វចំនួន ៨៤.០០០ បានផឹកនូវទឹកអម្រឹត ។ សត្វ ៨៤.០០០ រូប ក្នុងការប្រជុំនៃសុមនមាលាការក្តី សត្វ ១០.០០០ រូប ក្នុងសមាគមធនបាលក្តី ៨៤.០០០ រូប ក្នុងសមាគមខទិរង្គារជាតកក្តី សត្វ ៨៤.០០០ រូប ក្នុងសមាគមជម្ពុកាជីវកក្តី សត្វ ៨៤.០០០ រូប ក្នុងសមាគម-អានន្ទសេដ្ឋីក្តី សុទ្ធតែបានផឹកនូវទឹកអម្រឹត ។ ក្នុងថ្ងៃ ដែលព្រះសម្ពុទ្ធ សម្តែងបារាយនសូត្រ នាបាសាណកចេតិយ សត្វ ១៤ កោដិ បានផឹកនូវទឹកអម្រឹត ។ សត្វ ២០ កោដិ ក្នុងថ្ងៃ ដែលព្រះពុទ្ធជាម្ចាស់សម្តែងយមកបាដិហារិយក្តី សត្វ ៨០ កោដិ ក្នុងសម័យដែលមកស្តាប់ការសម្តែងព្រះអភិធម្មរបស់ព្រះសម្ពុទ្ធ ដែលព្រះអង្គសម្តែងដើម្បីប្រោសព្រះមាតា ទៀបមណ្ឌលបណ្ឌុកម្ពលសិលា នាស្ថាន

តាវតិង្សក្ដី សត្វ ៣០ កោដិ ក្នុងកាលព្រះសម្ពុទ្ធសម្ដែងរឿងទេវោរោហណក្ដី ទេវតា៨០.០០០ រូប ក្នុងកាលព្រះពុទ្ធសម្ដែងសក្កបញ្ហាក្ដី សុទ្ធតែបានផឹកទឹកអម្រឹត ។ មិនមានការកំណត់ចំនួននៃសត្វសម្រេចធម៌ ក្នុងឋានៈ(ការសម្ដែង) បួននេះគឺ ក្នុងកាលសម្ដែងមហាសមយសូត្រ ១ កាលសម្ដែងមង្គលសូត្រ ១ កាលសម្ដែងចូឡរាហុលោវាទសូត្រ ១ កាលសម្ដែងសមចិត្តបដិបទា ១ ។ នេះគ្រាន់តែជាចំនួនខ្លះ ដែលយើងបានដឹងតាមរយៈ ព្រះគន្ថរចនាចារ្យ ឬព្រះធម្មសង្គាហកាចារ្យប៉ុណ្ណោះ ។ នៅមានចំនួនសត្វ ដែលដង្ហែព្រះមានព្រះភាគយាង និងនិមន្តទៅព្រះនិព្វាន រាប់ចំនួនមិនបាន ប្រមាណមិនអស់ទៀតផង ។ ហើយនៅសម័យក្រោយមក ដូចជាក្នុងការផ្សព្វផ្សាយព្រះពុទ្ធសាសនារបស់ព្រះថេរៈទាំងឡាយជាសង្ឃទូត ដែលនិមន្តទៅកន្លែងផ្សេងៗ តាមថេរបញ្ជារបស់ព្រះមោគ្គល្លិបុត្តតិស្សត្ថេរ និងដោយមានរាជូបត្ថម្ភនៃព្រះបាទធម្មាសោក មានសត្វបានស្ដាប់ និងសម្រេចធម៌យ៉ាងច្រើនអនេក ។ ដូចមានក្នុងគម្ពីរសមន្តប្បាសាទិកា របស់ព្រះពុទ្ធឃោសាចារ្យ គម្ពីរសារត្ថទីបនីដីកា របស់ព្រះសារីបុត្តត្ថេរ, និងគម្ពីរសាសនវង្ស របស់ព្រះថេរៈព្រះនាមបញ្ញាសាមិត្ថេរ បានសម្ដែងថា ក្រោយពីការធ្វើ តតិយសង្គាយនាហើយ ព្រះមោគ្គល្លិបុត្តតិស្សត្ថេរ បានរំពឹងមើលនូវការតាំងនៅនៃសាសនា ថាតើសាសនានឹងតាំងមាំនៅក្នុងទីណា? ពេលដឹងថាសាសនានឹងតាំងមាំនៅ ក្នុងបច្ចន្តប្រទេស ព្រះថេរៈបានបញ្ជូននូវព្រះសង្ឃទូត ទៅផ្សព្វផ្សាយសាសនាក្នុងទីផ្សេងៗ មានៈ

| | | |
|---|---|---|
| ១-ព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ | និមន្តទៅកាន់ | ដែនដីសុវណ្ណភូមិ |
| ២-ព្រះមហារក្ខិតត្ថេរ | និមន្តទៅកាន់ | យោនកបុរី |
| ៣-ព្រះរក្ខិតត្ថេរ | និមន្តទៅកាន់ | វនវាសីប្រទេស |
| ៤-ព្រះយោនកធម្មរក្ខិតត្ថេរ | និមន្តទៅកាន់ | អបរន្តកប្រទេស |
| ៥-ព្រះមជ្ឈន្តិកត្ថេរ | និមន្តទៅកាន់ | កស្មីរគន្ធារប្រទេស |
| ៦-ព្រះមហាទេវត្ថេរ | និមន្តទៅកាន់ | មហិសករដ្ឋ |
| ៧-ព្រះមហាធម្មរក្ខិតត្ថេរ | និមន្តទៅកាន់ | មហារដ្ឋប្រទេស |
| ៨-ព្រះមជ្ឈិមត្ថេរ | និមន្តទៅកាន់ | ចីនប្រទេស |
| ៩-ព្រះមហាមហិន្ទត្ថេរ | និមន្តទៅកាន់ | កោះសីហឡ ។ |

ផ្លូវនីមួយៗ តែងមានគណៈសង្ឃប្រាំៗព្រះអង្គទៀត ដើម្បីងាយស្រួលក្នុងការបំពេញឧបសម្បទា ដល់កុលបុត្រក្នុងបច្ចន្តជនបទ ។

បានឮមកថា កាលព្រះថេរៈ ព្រះនាមឧត្តរៈ និងព្រះនាមសោណៈ បាននិមន្តទៅដល់ដែនដីសុវណ្ណភូមិហើយ បានផ្ចាញ់នាងអារក្សទឹក ដែលតែងតែមកចាប់កូនអ្នកស្រុកទំពាស៊ី ។ ក្រោយពីបានផ្ចាញ់នាងអារក្សទឹកហើយ ព្រះថេរៈទាំងពីរព្រះអង្គ បានប្រមូលមនុស្សទាំងឡាយឱ្យមកជួបជុំគ្នា រួចប្រកាសនូវព្រហ្មជាលសូត្រ ។ ធម្មាភិសម័យ មានដល់សត្វប្រមាណ ៦ ម៉ឺននាក់ ក្នុងសន្និបាតនោះ ។ ពួកក្មេងអ្នកស្រុកទាំងឡាយចំនួន ៣.៥០០ នាក់ និងកុលធីតាប្រមាណ ១.៥០០ នាក់ បានបួសហើយ ។

នៅឯយោនកបុរី ព្រះមហារក្ខិតត្ថេរ បានសម្ដែងកាឡការាមសូត្រ ជនប្រមាណ ១៣៧.០០០ នាក់ បានសម្រេចមគ្គ និងផល ហើយពួកមនុស្សប្រមាណ ១០.០០០ នាក់ បានបួសក្នុងសម្នាក់របស់ព្រះថេរៈ ។ ព្រះពុទ្ធសាសនាបានតាំងនៅមាំក្នុងរដ្ឋយោនកៈនោះ ដោយប្រការដូច្នេះ ។

ព្រះថេរៈព្រះនាម រក្ខិតត្ថេរ បាននិមន្តទៅកាន់វនវាសីប្រទេស បានញ៉ាំងជនទាំងឡាយ ក្នុងទីនោះឱ្យជ្រះថ្លា ដោយការសម្ដែងអនមតគ្គិយបរិយាយកថា ។ ក្នុងទីបំផុតនៃកថា ធម្មាភិសម័យ បានសម្រេចដល់សត្វ ៦០.០០០ នាក់ ។ ពួកមនុស្សប្រមាណ ៣៧.០០០ នាក់ បានបួសក្នុងព្រះពុទ្ធសាសនា ព្រះវិហារ ៥០០ ខ្នង បានកសាងដើម្បីឧទ្ទិសដល់ព្រះពុទ្ធសាសនា ។

ចំណែកឯព្រះយោនកធម្មរក្ខិតត្ថេរ បាននិមន្តទៅកាន់អបរន្តកជនបទ បានញ៉ាំងជនអ្នកនៅក្នុងអបរន្តកជនបទនោះ ឱ្យជ្រះថ្លា ដោយការសម្ដែងអគ្គិក្ខន្ធូបមសូត្រ ។ សត្វប្រមាណ ៣៧.០០០ រូប ឱ្យផឹកអមតធម៌ ។ បុរសក្នុងត្រកូលក្សត្រ ប្រមាណ ១.០០០ នាក់ និង ស្ត្រី ៦.០០០ រូប បានបព្វជ្ជា ។

រីឯព្រះមជ្ឈន្តិកត្ថេរ ជាអ្នកប្រាជ្ញ បាននិមន្តទៅកាន់ដែន កស្មីរគន្ធារៈ ញ៉ាំងពួកនាគទាំងឡាយ ប្រមាណ ៨៤.០០០ នាគ ជាសត្វកាចសហាវឱ្យតាំង នៅក្នុង

សរណៈ ៣ និង សីល ៥ ។ ធ្វើឱ្យបញ្ចកយក្ខ និងនាងយក្សហារិតីយក្ខិនី ព្រមទាំងកូនប្រមាណ ៥០០ រូប ឱ្យតាំងនៅក្នុងបឋមផល ។ លោកបាន ប្រកាសសម្តែងអសិវិសូបមសូត្រ ញ៉ាំងសត្វ ៨០.០០០ រូប បានសម្រេចធម៌ និង មានត្រកូល ១០០.០០០ រូប បានបួស ។

ព្រះមហាទេវត្ថេរ និមន្តទៅកាន់មហិសករដ្ឋ ប្រកាសសម្តែង ទេវទូតសូត្រ ក្នុងទីបំផុតនៃព្រះសូត្រ សត្វប្រមាណ ៤០.០០០ រូប បាននូវធម្មចក្ខុ ។ កុលបុត្រចំនួន ៤០.០០០ រូប បានចេញបួស ។

ព្រះមហាធម្មរក្ខិតត្ថេរ និមន្តទៅកាន់មហារដ្ឋជនបទ បានញ៉ាំងជនទាំង ឡាយឱ្យជ្រះថ្លា ដោយការសម្តែងមហានារទកស្សបជាតក សត្វប្រមាណ ៨៤.០០០ រូប បានសម្រេចមគ្គ និងផល ។ មនុស្សចំនួន ១៣.០០០ នាក់ បានបួស ។

ព្រះមជ្ឈិមត្ថេរ មួយអន្លើដោយព្រះកស្សបគោត្តត្ថេរ ព្រះអឡកទេវត្ថេរ ព្រះទុន្ទុភិស្សរត្ថេរ និងព្រះសហស្សទេវត្ថេរបាននិមន្តទៅកាន់ចីនប្រទេស(១) ជាចំណែក នៃហេមវន្តប្បទេស(២) ។ ព្រះថេរៈទាំងឡាយ បានសម្តែងនូវធម្មចក្កប្បវត្តនសូត្រ ញ៉ាំងសត្វប្រមាណ ៨០ កោដិ ឱ្យតាំងនៅក្នុងមគ្គ និងផល ។ ជនប្រមាណ ១០០.០០០ រូប បានបួសហើយក្នុងព្រះពុទ្ធសាសនា ។

ចំណែកខាងព្រះមហិន្ទត្ថេរ ដែលនិមន្តទៅកាន់លង្កាទ្វីប បានប្រកាស ព្រះធម៌ជាច្រើនលើក មានសត្វបានត្រេកនូវអមតធម៌ មានចំនួនយ៉ាងច្រើន បាន ញ៉ាំងព្រះបាទទេវានម្បិយតិស្ស ឱ្យជ្រះថ្លា និងជួយឧបត្ថម្ភគាំទ្រព្រះពុទ្ធសាសនា ឱ្យតាំងនៅក្នុងកោះលង្កាទ្វីប រហូតដល់សព្វថ្ងៃ ។

ការលើកឡើងនូវប្រវត្តិខ្លីៗនេះ គ្រាន់តែចង់បំផុសគំនិតរបស់អ្នកសិក្សា ទាំងឡាយ មកពិនិត្យនូវអត្ថប្រយោជន៍នៃព្រះពុទ្ធសាសនា ការវិវត្ត ការផ្សព្វផ្សាយ ព្រះសទ្ធម្មរបស់ព្រះសម្ពុទ្ធ ដែលព្រះថេរៈទាំងឡាយ អ្នកជាបណ្ឌិត ជាមហាកវី បានរចនា និងសង្គាយនាដោយល្អហើយ ។

---

១-គម្ពីរសាសនវង្ស ។

២-គម្ពីរសមន្តប្បាសាទិកា បាលី-ប្រែ ភាគ ១ ទំព័រ ១២៨ ។

គម្ពីរឈ្មោះ **បរមត្ថជោតិកា អដ្ឋកថា ខុទ្ទកបាឋ** ដែលស្ថិតក្នុងព្រះហស្តរបស់ព្រះថេរានុត្ថេរគ្រប់អង្គ និងដៃនៃអ្នកសប្បុរសទាំងឡាយ គឺជាវណ្ណកម្មដ៏ល្អឯករបស់ព្រះពុទ្ធឃោសាចារ្យ ជាអដ្ឋកថាចារ្យដ៏ល្បីល្បាញនាពុទ្ធសតវត្សទី ១០ គង់នៅអនុរាធបុរី នៃកោះលង្កាទ្វីប បានរចនាហើយ ដោយគ្មានការអារាធនាពីជនដទៃ[១] ។ បណ្តុំនៃអត្ថបទធម៌ ដែលព្រះសម្ពុទ្ធសម្តែងហើយដោយល្អ មានប្រាំបួនយ៉ាងគឺៈ **សរណគមន៍, សិក្ខាបទ, អាការៈ ៣២ ប្រការ, កុមារបញ្ហា, មង្គលសូត្រ, រតនសូត្រ, តិរោកុឌ្ឌសូត្រ, និធិកណ្ឌសូត្រ និង ករណីយមេត្តសូត្រ** គឺព្រះពុទ្ធឃោសាចារ្យ បានយកមកអធិប្បាយហើយក្នុងគម្ពីរឈ្មោះ បរមត្ថជោតិកា នេះ ដោយសេចក្តីពិស្តារ ។

**គោលបំណងនៃការបកប្រែ និងរៀបចំបោះពុម្ពផ្សាយនូវគម្ពីរនេះ គឺ**

១-ដើម្បីផ្សព្វផ្សាយព្រះពុទ្ធវាទឱ្យទូលំទូលាយ ។

២-ផ្តល់ជាឯកសារសម្រាប់អាន និងសិក្សាស្រាវជ្រាវឱ្យកាន់តែច្រើន ។

៣-ដើម្បីពន្យល់ព្រះពុទ្ធវចនៈ តាមវាទៈរបស់ព្រះអរហន្តទាំងឡាយ ជាពុទ្ធមតញ្ញូ សម្រាប់យកទៅបកស្រាយឱ្យបានត្រឹមត្រូវតាមពុទ្ធអធ្យាស្រ័យ ។

៤-ចូលរួមលើកកម្ពស់អក្សរសាស្ត្រជាតិ តាមរយៈសាសនារបស់ជាតិ ។

៥-ចូលរួមលើកកម្ពស់សីលធម៌ តាមរយៈអត្ថបទសាសនា ។

៦-ផ្តល់ជាមាគ៌ា សម្រាប់ប្រតិបត្តិធម្មព្រះពុទ្ធសាសនា ។

**ដំណើរនៃការបកប្រែ និងរៀបរៀងបោះពុម្ព ៖**

-ធ្វើការបកប្រែ គម្ពីរបរមត្ថជោតិកា មកជាភាសាខ្មែរ ដោយសរសេរជាសំណៅដៃលើក្រដាសសៀវភៅព្រៀង ។

-ចម្លងចូលកុំព្យូទ័រ

-ត្រួតពិនិត្យសារជាថ្មី លើអត្ថបទដើមមានៈ អត្ថន័យ បទ បាលី អក្ខរៈ ព្យញ្ជនៈ អក្ខរាវិរុទ្ធ និងសម្រួលសេចក្តីជាភាសាខ្មែរ ឱ្យងាយយល់ ។

---

១-គម្ពីរចុល្លគន្ថវង្សរចនាដោយព្រះនន្ទប្បញ្ញាថេរ ។

-ផ្ទៀងផ្ទាត់ឡើយវិញ ដោយប្រើអដ្ឋកថាបរមត្ថជោតិកា ភាសាបាលីរបស់ឆដ្ឋសង្គាយនា (ភូមា) និងគម្ពីរបរមត្ថជោតិកា ភាសាបាលី របស់មហាមកុដរាជ-វិទ្យាល័យសង្ឃ (ថៃ) ដោយប្រើប្រាស់ព្រះត្រៃបិដកជាភាសាខ្មែរ ជាគោល និងប្រើប្រាស់វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ **ជោតញ្ញាណោ ជួន ណាត** ក្នុងការសរសេរអក្សរ ។ ក្រុមការងាធម្មទាន ក៏បានប្រើប្រាស់ឯកសារដទៃទៀតជាជំនួយក្នុងការបកប្រែ និងរៀបរៀងគម្ពីរនេះ ដូចមានក្នុងឯកសារយោងស្រាប់ ។

ទោះបីការបកប្រែ និងរៀបរៀង ព្រមទាំងការកែសម្រួល ដោយហ្មត់ចត់ជាទីបំផុតយ៉ាងណាក៏ដោយ ក៏មិនអាចគេចផុតពីការខុសឆ្គាំឆ្គងបានឡើយ ។ កំហុសទាំងនោះ អាចកើតឡើងដោយអចេតនាក៏មាន ដោយសមត្ថភាពអ្នកធ្វើមិនទាន់គ្រប់គ្រាន់ក៏មាន ។ ទោះបីជាមានកំហុសខ្លះក៏ដោយ ក៏ក្រុមប្រែ និងរៀបរៀងយល់ឃើញថា មានការប្រសើរជាជាងការមិនធ្វើអ្វីសោះ ។

ព្រោះហេតុនេះ ក្រុមប្រែ និងរៀបរៀង សូមធ្វើនូវ **គម្ពីរបរមត្ថជោតិកា** នេះដល់អ្នកសិក្សា និងអត្ថកោវិទ បណ្ឌិត កវី ដើម្បីជួយកែសម្រួលកន្លែងដែលមានកំហុស ហើយក្រុមប្រែ និងរៀបរៀង នឹងយកមកកែលម្អជាថ្មី ក្នុងការបោះពុម្ពលើកក្រោយទៀត ។ ក្រុមប្រែ និងរៀបរៀងសង្ឃឹមយ៉ាងមុតមាំថា អ្នកសប្បុរសទាំងឡាយ នឹងជួយកែសម្រួលដោយក្តីអនុគ្រោះជាមិនខាន ។

បាត់ដំបង, ថ្ងៃ ១៣ កើត ខែ អស្សុជ ព.ស ២៥៥៤

តំណាងក្រុមប្រែ និងរៀបរៀង



**សច្ចកល្យាណោ មឿន សាមុត**

# **បត្តិទានវចនៈ**

ដោយអំណាចនៃការខិតខំប្រឹងប្រែង បកប្រែ និងរៀបរៀង គម្ពីរ **បរមត្ថជោតិកា** អដ្ឋកថា ខុទ្ទកបាឋ នៃគម្ពីរសុត្តន្តបិដក ខុទ្ទកនិកាយ លេខ ៥២ ដោយវិរិយភាពនៃឆន្ទៈក្នុងការងារធម្មទានដ៏ឧដុង្គឧត្តមនេះ

-សូមបូជាចំពោះគុណព្រះរតនត្រៃ ដែលជាកែវដ៏ប្រសើរ ដោយសេចក្តីគោរព ។

-សូមបូជា ចំពោះព្រះធម្មសង្គាហកាចារ្យ ព្រះអដ្ឋកថាចារ្យ ព្រះដីកាចារ្យ ព្រះអនុដីកាចារ្យ ព្រះគន្ថរចនាចារ្យ ព្រះគណ្ឋិបទាចារ្យ ព្រះបុរាណាចារ្យ ព្រះវេយ្យាករណាចារ្យទាំងឡាយ ដែលមានឧបការៈ ក្នុងការថែរក្សាទុកនូវពុទ្ធវចនៈមកដល់សព្វថ្ងៃ ។

-សូមឧទ្ទិសនូវព្រះរាជកុសលនេះ ថ្វាយចំពោះសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ គណៈមហានិកាយ **ជោតញ្ញាណោ ជួន ណាត** ជាព្រះបិតាខាងអក្សរសាស្ត្រខ្មែរ ។

-សូមឧទ្ទិសថ្វាយព្រះអតីតសម្តេច និងសម្តេចព្រះសង្ឃរាជគ្រប់ព្រះអង្គ ។

-សូមឧទ្ទិសថ្វាយ ប្រគេន ជូន ព្រះរាជកុសល និងកុសល ដ៏មហាប្រសើរនេះ ចំពោះសម្តីតិកាចារ្យជាតិ គ្រប់ព្រះអង្គ និងរូប ដែលមានគុណូបការៈ ក្នុងការបកប្រែ រៀបចំបោះពុម្ព ព្រះត្រៃបិដកជាភាសាខ្មែរ ។

-សូមឧទ្ទិសថ្វាយព្រះរាជកុសលចំពោះអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ៗព្រះអង្គ ។

-សូមថ្វាយព្រះរាជកុសល ចំពោះសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី

-សូមថ្វាយព្រះរាជកុសល ចំពោះសម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-សូមប្រគេនកុសល ចំពោះព្រះថេរានុត្ថេរៈគ្រប់ៗព្រះអង្គ

-សូមថ្វាយព្រះរាជកុសល ចំពោះព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សូមថ្វាយព្រះរាជកុសលចំពោះព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ព្រមទាំងព្រះរាជវង្សានុវង្ស ។

-សូមជូនចំពោះ ប្រមុខរាជរដ្ឋាភិបាល មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់

-សូមឧទ្ទិសជូនចំពោះ មាតាបិតា និងគ្រូឧបជ្ឈាយាចារ្យ នៃយើងខ្ញុំទាំងអស់

-សូមជូនលោកគ្រូអគ្គបណ្ឌិត ធម្មាចារ្យ ប៊ុត សាវង្ស

-សូមជូនលោកគ្រូ ធម្មបណ្ឌិត រស់ សុផាត

-សូមជូនលោកគ្រូវិនយាចារ្យ គាំ អ៊ីវ

-សូមជូនលោកគ្រូធម្មាចារ្យ (ទក្ខប្បញ្ញោ) អឿ សៅ

-សូមជូនចំពោះពុទ្ធបរិស័ទទាំងក្នុងប្រទេស និងក្រៅប្រទេស

-និង ជូនដល់សព្វសត្វក្នុងត្រៃភពទាំងអស់..............។

សូមទ្រង់ត្រេកអរ និងត្រេកអរអនុមោទនា យកនូវចំណែកធម្មទានដែលផុសឡើងពីសេចក្តីជ្រះថ្លាក្នុងព្រះរតនត្រៃ និងវិរិយភាពក្នុងការងារធម្មទាននេះ ឲ្យបានគ្រប់ៗព្រះអង្គ គ្រប់ៗរូប គ្រប់ៗគ្នា កុំបីអាក់ខានឡើយ ។

*ចិរំ តិដ្ឋតុ សទ្ធម្មោ កាលេ វស្សំ ចិរំ បជំ*

*តប្បេតុ ទេវោ ធម្មេន រាជា រក្ខតុ មេទនី*

សូមព្រះសទ្ធម្ម ស្ថិតនៅអស់កាលយូរ

សូមទេវតាបង្អុរភ្លៀងដល់សត្វ តាមសមគួរដល់កាល អស់កាលយូរ

សូមព្រះរាជាគ្រប់គ្រងផែនដីប្រកបដោយធម៌ ៕

សូមអនុមោទនា...!!!

# ក្រុមប្រែ និង រៀបរៀង

**១-ព្រះមហាសច្ចកល្យាណោ មឿន សាមុត** សមណនិស្សិតនៃពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ សាខាខេត្តបាត់ដំបង ។

**២-ព្រះមហាធម្មរក្ខិតភិក្ខុ ឡុង កុសល** សមណនិស្សិតនៃពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ សាខាខេត្តបាត់ដំបង ។

**៣-ព្រះភិក្ខុរតនឃោសកោ យឿន យ៉ាង** ព្រះវិនយាចារ្យវត្តបាការនិវេសន៍ ហៅវត្តកំផែង ។

**៤-ព្រះភិក្ខុ រក្ខិតមនោ ឈុន សុវណ្ណៈ** សមណសិស្ស នៃពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង ខេត្តបាត់ដំបង ។

**៥-ព្រះមហា ចន្ទសេនោ សិម សុឃុំ** សមណនិស្សិតនៃពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ ភ្នំពេញ ។

**៦-សាមណេរ គម្ពីរវិជ្ជោ ណែប ស៊ីណា** សមណសិស្ស នៃពុទ្ធិកវិទ្យាល័យ អ៊ឹងធួង ខេត្តបាត់ដំបង ។

**៧-ឧបាសក ញ៉យ សារ៉ាត់** សិស្សនៃពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង បាត់ដំបង ។

## អ្នកពិនិត្យអក្ខរាវិរុទ្ធិ

១-**ព្រះមហាសច្ចកល្យាណោ មឿន សាមុត** សមណនិស្សិតនៃពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ សាខាខេត្តបាត់ដំបង ។

២-ព្រះភិក្ខុ **សមថានុរត្តោ ពេជ្រ សៀក** ជាធម្មាចារ្យ និងជាសមណសិស្ស នៃពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង ខេត្តបាត់ដំបង

៣-**ព្រះមហាធម្មរក្ខិតភិក្ខុ ឡុង កុសល** សមណនិស្សិតនៃពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ សាខាខេត្តបាត់ដំបង ។

៤-ព្រះភិក្ខុ **រតនឃោសកោ យឿន យ៉ាង** ព្រះវិនយាចារ្យ វត្តបាការនិវេសន៍ ហៅវត្តកំផែង ។

៥-ព្រះភិក្ខុ **វេទិតមនោ ឈុន សុវណ្ណា:** សមណសិស្ស នៃពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង ខេត្តបាត់ដំបង ។

៦-ព្រះមហា **ចន្ទសេនោ សិម សុឈុំ** សមណនិស្សិតនៃពុទ្ធិកសាកល-វិទ្យាល័យ ព្រះសីហនុរាជ ភ្នំពេញ ។

៧-សាមណេរ **គម្ពីរវិជ្ជោ ណែប ស៊ីណា** សមណសិស្ស នៃពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង ខេត្តបាត់ដំបង ។

៨-លោក **សួន ម៉ុនឿន** ជាសាស្ត្រាចារ្យភាសាបាលី នៃពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង និងជាប្រធានមន្ទីរធម្មការ និងសាសនា ខេត្តបាត់ដំបង ។

៩-លោកគ្រូធម្មាចារ្យ **ហាយ ចំរើន**

១០-ឧបាសក **ញ៉ូយ សារ៉ាត់** សិស្សនៃពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង បាត់ដំបង ។

## អ្នកជួយកច្ចការធម្មទាន

១-ព្រះតេជគុណ **ញាណសរណោ ឃឿប មូរ** និងពុទ្ធបរិស័ទ វត្តធម្មសាមគ្គី ប្រទេសអូស្ត្រាលី ។

២-ព្រះតេជគុណ **នេត្តបណ្ឌិតោ គឿន ម៉ិច** ចៅអធិការ វត្តបាការនិវេសន៍ កំផែង ។

៣-ព្រះមហា **ធម្មជោតិកោ ហុខ ពឿន** សមណនិស្សិត នៃពុទ្ធិកសាកល-វិទ្យាល័យ ព្រះសីហនុរាជ សាខាខេត្តបាត់ដំបង ។

៤-ព្រះតេជគុណ **សមថានុរត្តោ ពេជ្រ សៀក** គ្រូធម្មាចារ្យ វត្តពោធិវង្ស ។

៥-ព្រះតេជគុណ **ចន្ទជោតោ លឿម សុភាព** គ្រូធម្មាចារ្យ វត្តភ្នំជញ្ជាំង

៦-សាមណេរ **មុត សាមឿន** សមណសិស្ស ពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង

៧-លោកគ្រូធម្មាចារ្យ**ឧក្ខប្បញ្ញោ អឿ សៅ** និងពុទ្ធបរិស័ទ វត្តសន្សំកុសល មានឧបាសិកា **លីម៉ូលីន ស៊ីមម៉ូ** ជាដើម (U.S.A)

៨-លោកគ្រូធម្មាចារ្យ **ហាយ ចំរើន** ក្រុងបាត់ដំបង

៩-ឧបាសិកា **ប៉ាខ ស៊ីន** និងបុត្រ ក្រុងបាត់ដំបង

១០-ឧបាសិកា **តាំខ ប៉ោជឹខ** ហៅ**ឧបាសិកា ទន់** និងបុត្រ ក្រុងបាត់ដំបង

១១-លោក **គឹម សោភ័ណ** និងភរិយា ព្រមទាំងបុត្រ ក្រុងកំពត

១២-ឧបាសក **ធី រ៉ាន់** និងឧបាសក **តឹង សំបូរ** ខេត្តបាត់ដំបង

១៣-ឧបាសិកា **យឹម ជូរ** និងបុត្រ ខេត្តបន្ទាយមានជ័យ

១៤-ទាយិកា **សឹម សុខឡី** ខេត្តបន្ទាយមានជ័យ

១៥-ឧបាសក **ចេត ចេង** ឧបាសិកា **គក ភូឡាប** និងពុទ្ធបរិស័ទ ប្រទេសបារាំង

១៦-ឧបាសក **ឡុង សយ** ឧបាសិកា **ឯក ប៊ុនណា** និងពុទ្ធបរិស័ទ(U.S.A)

១៧-ឧបាសិកា **កៅ គឹមលន់** និងពុទ្ធបរិស័ទ(U.S.A)

១៨-បងស្រី **ឈុំ សារ៉ែម** និងពុទ្ធបរិស័ ប្រទេសកាណាដា

## អ្នករចនាក្រប

១-ព្រះមហាធម្មរក្ខិតភិក្ខុ **ឡុង កុសល**

២-ព្រះមហា ចន្ទសេនោ **សិម សុឈុំ**

៣-លោក **ម៉ុន តិរម្យ**

# មាតិកាធម៌

**មាតិកា** **ទំព័រ**

ពាក្យប្រារព្ធគម្ពីរ.........................................................................១

ការកំណត់ខុទ្ទកបាឋ.......................................................................២

ការជម្រះពាក្យផ្ដើម.......................................................................៦

**១-ពណ៌នាព្រះត្រៃសរណៈ.................................................១០**

ការសម្ដែងឡើងអំពីព្រះពុទ្ធ ........................................................១០

ការសម្ដែងអំពីសរណគមន៍ និងអ្នកដល់សរណគមន៍......................១៤

ការបំភ្លឺ ការដាច់ ការមិនដាច់ និងផលនៃសរណគមន៍.......................១៦

ការបំភ្លឺអំពីការដល់សរណៈ ........................................................១៩

ការសម្ដែងឡើងអំពីព្រះធម៌ និងព្រះសង្ឃ......................................២៤

អធិប្បាយហេតុក្នុងការកំណត់តាមលំដាប់......................................២៧

ប្រកាសដោយសេចក្ដីឧបមា..........................................................២៨

**២-ពណ៌នាសិក្ខាបទ ..........................................................៣៣**

ដំបូងបាឋៈថាដោយសិក្ខាបទ ........................................................៣៣

កំណត់សេចក្ដីប្លែកគ្នារបស់សិក្ខាបទទូទៅ .....................................៣៦

ចន្លុលបង្ហាញបទទូទៅ ..................................................................៣៦

ពណ៌នាសិក្ខាបទ ៥ ខាងដើម ........................................................៤០

វិនិច្ឆ័យសិក្ខាបទដូចគ្នា និងផ្សេងគ្នាជាដើម.....................................៤៣

ពណ៌នា ៥ សិក្ខាបទខាងចុង ........................................................៦៥

**៣.ពណ៌នាអំពីអាការៈ ៣២ ប្រការ.....................................៧៤**

ពណ្ណនាការសម្ព័ន្ធនៃបទ.....................................................................៧៤

អសុភការនា .....................................................................................៧៨

កេសា = សក់ .....................................................................................៨៨

លោមា = រោម ....................................................................................៩០

នខា = ក្រចក ......................................................................................៩១

ទន្តា = ធ្មេញ .......................................................................................៩២

តចោ = ស្បែក ......................................................................................៩៤

មំសំ = សាច់.........................................................................................៩៧

ន្ហារុ = សរសៃ ......................................................................................៩៩

អដ្ឋិ = ឆ្អឹង ..........................................................................................១០១

អដ្ឋិមិញ្ជំ = ខួរក្នុងឆ្អឹង..........................................................................១០៧

វក្កំ = តម្រងបស្សាវៈ ...........................................................................១០៩

ហទយំ = បេះដូង ................................................................................១១០

យកនំ = ថ្លើម .......................................................................................១១១

កិលោមកំ = វាវ ....................................................................................១១២

បិហកំ = ក្រពះ ......................................................................................១១៣

បប្ផាសំ = សួត .......................................................................................១១៥

*អន្តំ = ពោះវៀនធំ* ........................................ ១១៦

*អន្តគុណំ = ពោះវៀនតូច* ........................................ ១១៧

*ឧទរិយំ = អាហារថ្មី* ........................................ ១១៨

*ករីសំ = អាហារចាស់* ........................................ ១២១

*មត្ថលុង្គំ = ខួរក្នុងក្បាល* ........................................ ១២៣

*បិត្តំ = ប្រមាត់* ........................................ ១២៤

*សេម្ហំ = ស្លេស្ម៍* ........................................ ១២៥

*បុព្វោ = ខ្ទុះ* ........................................ ១២៦

*លោហិតំ = ឈាម* ........................................ ១២៧

*សេទោ = ញើស* ........................................ ១២៩

*មេទោ = ខ្លាញ់ខាប់* ........................................ ១៣០

*អស្សុ = ទឹកភ្នែក* ........................................ ១៣១

*វសា = ខ្លាញ់រាវ* ........................................ ១៣៣

*ខេឡោ = ទឹកមាត់* ........................................ ១៣៤

*សិង្ឃាណិកា = ទឹកសំបោរ* ........................................ ១៣៥

*លសិកា = ទឹករំអិល* ........................................ ១៣៧

*មុត្តំ = ទឹកមូត្រ (បស្សាវៈ)* ........................................ ១៣៨

*បកិណ្ណកនយោ = បកិណ្ណកន័យ* ........................................ ១៥១

**៤.ពណ៌នាកុមារបញ្ហា........................................ ១៥៦**

ហេតុកើតឡើងនៃរឿង................................................................១៥៦

ប្រយោជន៍នៃការដាក់បទផ្ដើម .....................................................១៥៧

ពណ៌នាបញ្ហាថាអ្វីដែលហៅថា ១ ?...............................................១៥៨

ពណ៌នាបញ្ហាថាអ្វីដែលហៅថា ២ ? .............................................១៦៣

ពណ៌នាបញ្ហាថាអ្វីដែលហៅថា ៣? .............................................១៦៥

ពណ៌នាបញ្ហាថាអ្វីដែលហៅថា ៤? .............................................១៦៨

ពណ៌នាបញ្ហាថាអ្វីដែលហៅថា ៥?...............................................១៧២

ពណ៌នាបញ្ហាថាអ្វីដែលហៅថា ៦ ?..............................................១៧៤

ពណ៌នាបញ្ហាថាអ្វីដែលហៅថា ៧ ?..............................................១៧៦

ពណ៌នាបញ្ហាថាអ្វីដែលហៅថា ៨ ?..............................................១៧៩

ពណ៌នាបញ្ហាថាអ្វីដែលហៅថា ៩ ?..............................................១៨២

ពណ៌នាបញ្ហាថាអ្វីដែលហៅថា ១០?............................................១៨៦

**៥.ពណ៌នាមង្គលសូត្រ .....................................................១៩០**

ប្រយោជន៍នៃការតាំងបទ...........................................................១៩០

កថាពណ៌នាបឋមមហាសង្គាយនា................................................១៩០

ពណ៌នាបាឋៈថា ឯវំ ជាដើម.........................................................២១១

កែបទ មេ ..........................................................................២១៥

កែបទ សុតំ ........................................................................២១៦

តែអត្ថនៃបទ ឯកំ និង សមយំ ....................................................២២១

កែអត្ថនៃបទ ភគវា ....................................................................២២៧

កែបទ វិភត្តវា ...........................................................................២៣២

កែបទ ភត្តវា .............................................................................២៣២

កែបទ ភវេសុវណ្តគមន ...............................................................២៣៣

កែបទ សាវត្ថិយំ វិហរតិ..............................................................២៣៤

កែអត្ថនៃបទ ជេតវនេ.................................................................២៣៦

កែអត្ថនៃបទ អនាថបិណ្ឌិកស្ស អារាមេ ........................... ......២៣៦

កែ អភិក្កន្តស័ព្ទ .........................................................................២៤០

កែអត្ថនៃបទ កេវលកប្បំ ............................................................២៤៣

ពោលអំពីមូលហេតុកើតមង្គលបញ្ហា.........................................២៤៩

ពណ៌នាគាថា ថា ពហូ ទេវា.........................................................២៥៨

ពណ៌គាថា ថា អសេវនា ច .........................................................២៦០

ពណ៌គាថា ថា បដិរូបទេសវាសោ ច ..........................................២៧៦

ពណ៌នាគាថា ថា ពាហុសច្ចញ្ច ..................................................២៨១

ពណ៌នាគាថា ថា មាតាបិតុឧបដ្ឋានំ ........................................២៨៦

ពណ៌នាគាថា ថា ទានញ្ច ...........................................................២៩២

ពណ៌នាគាថា ថា អារតី ..............................................................២៩៦

ពណ៌នាគាថា ថា គារវោ ច ......................................................៣០០

ពណ៌នាគាថា ថា ខន្តិ ច ...................................................................៣០៩

ពណ៌នាគាថា ថា តបោ ច ...................................................................៣១៥

ពណ៌នាគាថា ថា ផុដ្ឋស្ស លោកធម្មេហិ ...................................................៣១៩

ពណ៌នាគាថា ថា ឯតាទិសានិ ...............................................................៣២២

**៦-ពណ៌នារតនសូត្រ ......................................................................៣៣០**

ប្រយោជន៍នៃការតាំងបទ ....................................................................៣៣០

រឿងក្រុងវេសាលី .............................................................................៣៣១

ការនិមន្តមករបស់ព្រះមានព្រះភាគ .......................................................៣៣៦

ពណ៌នាគាថា ថា យានីធ ...................................................................៣៤៤

ពណ៌នាគាថា ថា តស្មា ហិ ................................................................៣៤៧

ពណ៌នាគាថា ថា យង្កិញ្ចិ ...................................................................៣៥២

ពណ៌នាគាថា ថា ខយំ វិរាគំ ...............................................................៣៧៣

ពណ៌នាគាថា ថា យម្ពុទ្ធសេដ្ឋោ ............................................................៣៧៥

ពណ៌នាគាថា ថា យេ បុគ្គលា .............................................................៣៧៨

ពណ៌នាគាថា ថា យេ សុប្បយុត្តា ........................................................៣៨៣

ពណ៌នាគាថា ថា យថិន្ទខីលោ ...........................................................៣៨៦

ពណ៌នាគាថា ថា យេ អរិយសច្ចានិ .....................................................៣៨៩

ពណ៌នាគាថា ថា សហាវស្ស ...............................................................៣៩១

ពណ៌នាគាថា ថា ចត្វារោធាយេហិ ..........................................៣៩៤

ពណ៌នាគាថា ថា កិញ្ចាបិ សោ ..........................................៣៩៧

ពណ៌នាគាថា ថា វនប្បគុម្ពេ ..........................................៤០០

ពណ៌នាគាថា ថា វរោ វរញ្ញូ ..........................................៤០៣

ពណ៌នាគាថា ថា ខីណំ ..........................................៤០៦

ពណ៌នា ៣ គាថា ថា យានីធជាដើម..........................................៤១០

**៧.ពណ៌នាតិរោកុឌ្ឌសូត្រ ..........................................៤២២**

ប្រយោជន៍នៃការតាំងបទ..........................................៤២២

គាថាអនុមោទនា..........................................៤២៣

ពណ៌នាគាថាទី ១..........................................៤២៥

ពណ៌នាគាថាទី ២..........................................៤៦៥

ពណ៌នាគាថាទី ៣..........................................៤៣៨

ពណ៌នាគាថាទី ៤ សម្ព័ន្ធជាមួយគាថាទី ៣..........................................៤៤១

ពណ៌នាវគ្គខាងចុងនៃគាថាទី ៤ សម្ព័ន្ធជាមួយវគ្គខាងដើមនៃគាថាទី៥...៤៤៣

ពណ៌នាវគ្គខាងចុងនៃគាថាទី ៥ សម្ព័ន្ធជាមួយវគ្គខាងដើមនៃគាថាទី ៦...៤៤៤

ពណ៌នាវគ្គខាងចុងនៃគាថាទី ៦ សម្ព័ន្ធជាមួយគាថាទី ៧..........................................៤៤៩

ពណ៌នាពីរគាថា គឺគាថាទី ៨ និងគាថាទី ៩..........................................៤៥២

ពណ៌នាគាថាទី ១០..........................................៤៥៣

ពណ៌នាគាថាទី១១..........................................៤៥៤

ពណ៌នាគាថាទី ១២.....................................................................៤៥៦

ពណ៌នាគាថាទី ១៣ ...................................................................៤៥៨

**៨.ពណ៌នានិធិកណ្ឌសូត្រ..........................................៤៦៣**

ហេតុនៃការតាំងឡើងព្រះសូត្រ ...................................................៤៦៣

ហេតុកើតឡើងនៃព្រះសូត្រ........................................................៤៦៤

ពណ៌នាគាថាទី ១.......................................................................៤៦៥

ពណ៌នាគាថាទី ២.......................................................................៤៦៨

ពណ៌នាគាថាទី ៣.......................................................................៤៧០

ពណ៌នាគាថាទី ៤ និងទី ៥...........................................................៤៧២

ពណ៌នាគាថាទី ៦.......................................................................៤៧៤

ពណ៌នាគាថាទី ៧.......................................................................៤៧៧

ពណ៌នាគាថាទី ៨.......................................................................៤៨០

ពណ៌នាគាថាទី ៩.......................................................................៤៨៣

ពណ៌នាគាថាទី ១០.....................................................................៤៨៥

ពណ៌នាគាថាទី ១១.................................................................... ៤៨៨

ពណ៌នាគាថាទី១២......................................................................៤៩៣

ពណ៌នាគាថាទី ១៣.....................................................................៤៩៤

ពណ៌នាគាថាទី ១៤.....................................................................៤៩៧

*ពណ៌នាគាថាទី ១៥......................................................................៤៩៩*

*ពណ៌នាគាថាទី ១៦......................................................................៥០០*

**៩.ពណ៌នាមេត្តសូត្រ.................................................. ៥០៥**

*ប្រយោជន៍នៃការតាំងសូត្រ...........................................................៥០៥*

*ការជម្រះនិទាន..........................................................................៥០៦*

*ពណ៌នាគាថាទី ១........................................................................៥១៣*

*ពណ៌នាគាថាទី ២........................................................................៥២៤*

*ពណ៌នាគាថាទី ៣........................................................................៥៣០*

*ពណ៌នាគាថាទី ៤........................................................................៥៣៣*

*ពណ៌នាគាថាទី ៥........................................................................៥៣៨*

*ពណ៌នាគាថាទី ៦........................................................................៥៣៩*

*ពណ៌នាគាថាទី ៧........................................................................៥៤១*

*ពណ៌នាគាថាទី ៨........................................................................៥៤២*

*ពណ៌នាគាថាទី ៩........................................................................៥៤៥*

*ពណ៌នាគាថាទី ១០......................................................................៥៤៧*

*និគមនកថា.................................................................................៥៥៣*

*ឯកសារយោង.............................................................................៥៥៦*

*នាមពុទ្ធបរិស័ទ ..........................................................................៥៥៧*

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្សការចំពោះព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

## បរមត្ថជោតិកា

## អដ្ឋកថាខុទ្ទកនិកាយ ខុទ្ទកបាឋៈ

## គន្ថារម្ភកថា

## ពាក្យប្រារព្ធគម្ពីរ

*និទ្ទេសនៃការកាន់យកព្រះត្រៃសរណគមន៍យ៉ាងនេះថា*

*ខ្ញុំព្រះករុណាសូមដល់ព្រះពុទ្ធជាទីពឹង*

*ខ្ញុំព្រះករុណាសូមដល់ព្រះធម៌ជាទីពឹង*

*ខ្ញុំព្រះករុណាសូមដល់ព្រះសង្ឃជាទីពឹង*

*សូម្បីវារៈទី ២និងទី៣ ក៏ដូចគ្នា*[១] *ជាសេចក្តីផ្តើមរបស់គម្ពីរខុទ្ទកបាឋៈ ។*

*ឥឡូវនេះដើម្បីបង្ហាញធ្វើការបែងចែកធ្វើឱ្យងាយនូវអត្ថនៃបាលីនេះ ខ្ញុំនឹងពោលអធិប្បាយសេចក្តីនេះ ដោយអដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះថា* ***បរមត្ថជោតិកា*** *។*

*ខ្ញុំ(ព្រះពុទ្ធឃោសាចារ្យ) សូមថ្វាយបង្គំព្រះរតនត្រ័យដ៏ខ្ពង់ខ្ពស់ ជាងវត្ថុទាំងឡាយ ដែលគួរថ្វាយបង្គំ ហើយនឹងធ្វើការពណ៌នាអត្ថនៃគម្ពីរខុទ្ទកបាឋៈ ។*

*ការពណ៌នានេះ គឺខ្ញុំអ្នកស្គាល់ព្រះពុទ្ធសាសនាតិចធ្វើបាន ដោយលំបាកក្រៃលែង ព្រោះគម្ពីរខុទ្ទកបាឋៈ មានអត្ថដ៏ជ្រៅយ៉ាងនោះ ។ ព្រោះសេចក្តីវិនិច្ឆ័យរបស់បុរាណាចារ្យ នៅមានជានិច្ចរហូតដល់សព្វថ្ងៃនេះ*

---

១-ច្បាប់ឆដ្ឋសង្គាយនា មិនមានពាក្យថា "**តថា ទុតិយំ តតិយម្បិ ប្រែថា សូម្បីវារៈទី២ ទី៣ ក៏ដូចគ្នា**" ។

*ដែលនវង្គសត្ថុសាសនា ក៏ស្ថិតស្ថេរនៅដូច្នោះដែរ ។ ព្រោះហេតុនោះ ខ្ញុំនឹងអាស្រ័យនវង្គសត្ថុសាសនា និងការវិនិច្ឆ័យរបស់បុរាណាចារ្យនេះ ទើបប្រាថ្នានឹងពណ៌នា ។ ដោយការគោរពយ៉ាងខ្លាំងក្នុងព្រះសទ្ធម្ម មិនមែនបំណងនឹងតម្កើងខ្លួន ជិះជាន់អ្នកដទៃ សូមអ្នកទាំងឡាយផ្ចង់ចិត្តស្តាប់ការពណ៌នាសេចក្តីនោះចុះ។*

## ខុទ្ទកវណ្ណនាធំ

### ការកំណត់ខុទ្ទកបាឋៈ

*ខ្ញុំនឹងពោលទុកក្នុងពាក្យប្រារព្ធនោះថា "នឹងធ្វើការពណ៌នាសេចក្តីរបស់ខុទ្ទកបាឋៈ បាឋៈខ្លះ" ខ្ញុំនឹងកំណត់ខុទ្ទកបាឋៈទាំងឡាយជាមុនសិន ទើបធ្វើការពណ៌នាជាខាងក្រោយ ។ ចំណែកមួយៗ របស់ខុទ្ទកនិកាយនោះឈ្មោះថា* ***ខុទ្ទកៈ*** *។ ចំណែកមួយៗ របស់និកាយទាំង ៥ ឈ្មោះ* ***ខុទ្ទកនិកាយ*** *។*

*គម្ពីរទាំង ៥ និកាយ គឺៈ ទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ និងខុទ្ទកនិកាយ ឈ្មោះថា និកាយ៥ ដោយធម៌ និងដោយអត្ថ ។*

*បណ្តានិកាយទាំង ៥ នោះ ព្រះសូត្រ ៣៤ សូត្រ មាន ព្រហ្មជាលសូត្រ-ជាដើម ឈ្មោះថា* ***ទីឃនិកាយ*** *។ ព្រះសូត្រ មាន ១៥២ សូត្រ មានមូលបរិយាយ-សូត្រជាដើម ឈ្មោះថា* ***មជ្ឈិមនិកាយ*** *។ ព្រះសូត្រ ៧៧៦២ សូត្រ មានឱឃតរណសូត្រជាដើម ឈ្មោះថា* ***សំយុត្តនិកាយ*** *។ ព្រះសូត្រ ៩៥៥៧ សូត្រ*

មានចិត្តបរិយាទានសូត្រជាដើម ឈ្មោះថា **អង្គុត្តរនិកាយ** ។ ខុទ្ទកបាឋៈ ធម្មបទ ឧទាន ឥតិវុត្តកៈ សុត្តនិបាត វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា ជាតក និទ្ទេស បដិសម្ភិទា អបទាន ពុទ្ធវង្ស ចរិយាបិដក ព្រះពុទ្ធវចនៈដ៏សេស វៀរ វិន័យបិដក និងអភិធម្មបិដក ឬនិកាយទាំង ៤ ឈ្មោះថា **ខុទ្ទកនិកាយ** ។

ហេតុដូចម្តេចនិកាយនេះ ទើបលោកហៅថា ខុទ្ទកនិកាយ ? ព្រោះការរួបរួម ឬក៏ជាទីនៅរបស់គំនរនៃធម៌តូចៗចំនួនច្រើន ។ មែនពិតការប្រមូលរួមគ្នា លោកហៅថា **និកាយ** ។ ដោយសាសនា និងលោក ក្នុងសេចក្តីនេះមានសាធកៈជាដើមយ៉ាងនេះថា "ពួកសត្វតិរច្ឆាននេះ ដ៏វិចិត្រយ៉ាងណា ចិត្តណា ដែលវិចិត្រយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញ សូម្បីនូវពួកធម៌មួយដទៃអំពីចិត្តនោះឡើយ[១]។ ពួកក្សត្របោណិកៈពួកក្សត្រចិក្ខខល្លិកា" ។ ចំណែកមួយៗរបស់ខុទ្ទកនិកាយនោះ មានដូច្នេះ ។ ពួកធម៌ល្អិតៗ ដែលរាប់សេចក្តីក្នុងសុត្តន្តបិដកពួកនេះ ដែលលោកប្រាថ្នានឹងបង្ហាញ ចំណែកធ្វើឱ្យឆ្ងាយដោយអត្ថ ខុទ្ទកបាឋៈ ៩ មានប្រភេទ ដោយអំណាចសរណៈ សិក្ខាបទ ទ្វត្តឹសាការ កុមារបញ្ហា (សាមណេរបញ្ហា)

---

១-សុត្តន្តបិដក សំយុត្តនិកាយ ខន្ធវារវគ្គ លេខ ៣៣ ទំព័រ ៣៤៤ ។

មង្គលសូត្រ រតនសូត្រ តិរោកុឌ្ឌសូត្រ និធិកណ្ឌសូត្រ និងមេត្តសូត្រនៃគម្ពីរខុទ្ទកៈនោះ ជាសេចក្តីដើម ដោយអំណាចដែលអាចារ្យក្រោយៗលើកឡើងកាន់វិធីបង្ហាត់បង្រៀន ពុំមែនដោយពាក្យដែលព្រះសម្ពុទ្ធជាម្ចាស់ត្រាស់ទុកទេ ។

មែនពិត គាថានេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា

អនេកជាតិ សំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

កាលតថាគត មិនទាន់បានជួបប្រទះ (ពោធិញ្ញាណរវល់តែ) ស្វះស្វែងរកជាងផ្ទះគឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ការកើតជាទុក្ខរឿយៗ ។ នែ៎!ជាងផ្ទះ អ្នកឯងធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ(របស់តថាគត)ទៀតមិនបានឡើយ ឆ្អឹងជំនីរគឺកិលេស របស់អ្នកទាំងអស់តថាគត កាច់បំបាក់អស់ហើយ ដំបូលផ្ទះ គឺអវិជ្ជា តថាគតកំចាត់ចោលហើយ ចិត្ត

របស់តថាគតដល់ព្រះនិព្វានដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ[១] ។

ប្រជុំពីរនៃព្រះគាថានេះ ជាគាថាខាងដើម នៃព្រះពុទ្ធវចនៈទាំងអស់ ។ គាថានេះទ្រង់ត្រាស់ដោយការពោលតាមផ្លូវចិត្តតែម្យ៉ាង ពុំមែនទ្រង់ត្រាស់ ដោយការធ្វើនូវវចីភេទហើយត្រាស់សម្តែងទេ ។ ចំណែកព្រះគាថានេះថា

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ បជានាតិ សហេតុធម្មំ ។

ធម៌[២]ទាំងឡាយ រមែងប្រាកដដល់ខីណាស្រវព្រាហ្មណ៍ អ្នកមានព្យាយាម ញុំាងកិលេសឱ្យក្តៅ អ្នកដុតបង់នូវកិលេសក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួងរបស់ខីណាស្រវព្រាហ្មណ៍នោះ ក៏ស៊ីង

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ ធម្មបទគាថា បឋមភាគ ភាគ ៥២ ទំព័រ ៥៤ ។

២-**ធម្មាតិ អនុលោមបច្ចយាការបដិវេធសាធកា ពោធិបក្ខិយធម្មា** ប្រែថា ពោធិបក្ខិយធម៌ដែលឱ្យសម្រេចការត្រាស់ដឹងនូវបច្ចយាការជាអនុលោម ឈ្មោះថា ធម៌ (សមន្តប្បាសាទិកា អដ្ឋកថា មហាវគ្គ វិន័យបិដក ) ។

តែរម្ងាប់អស់ទៅក្នុងកាលនោះ ព្រោះថាខីណាសវព្រាហ្មណ៍នោះ ដឹងច្បាស់នូវធម៌ និងហេតុ ។ សេចក្ដីសង្ស័យទាំងពួងរបស់ព្រាហ្មណ៍នោះ រមែងអស់ទៅព្រោះដឹងច្បាស់នូវធម៌ និងហេតុ[១] ។

គាថានេះ ឈ្មោះថា **បឋមគាថា** ដោយអំណាចការធ្វើនូវវិចីភេទហើយត្រាស់សម្ដែង ។ ព្រោះហេតុនោះ **ខុទ្ទកបាឋៈ** ដែលមាន ៩ ប្រភេទនេះឯណា ឈ្មោះថាជាសេចក្ដីខាងដើម នៃគម្ពីរខុទ្ទកនិកាយនោះ យើងនឹងផ្ដើមពណ៌នាសេចក្ដីនៃខុទ្ទកបាឋៈនោះពីខាងដើមតទៅ ។

## និទានសោធនំ

### ការជម្រះពាក្យផ្ដើម

ពុទ្ធំ សរណំ គច្ឆាមិ

ធម្មំ សរណំ គច្ឆាមិ

សង្ឃំ សរណំ គច្ឆាមិ

នេះជាសេចក្ដីដំបូងរបស់ពាក្យផ្ដើមខាងដើមនោះ ។ មាតិកាពណ៌នា សេចក្ដីរបស់ពាក្យផ្ដើមនោះ មានដូច្នេះ

---

១-វិនយបិដក មហាវគ្គ បឋមភាគ លេខ ៦ ទំព័រ ៣ ។

ត្រ័យសរណៈនរណាពោល? ពោលក្នុងទីណា? ពោលកាលណា? ពោលព្រោះហេតុអ្វី? ម្យ៉ាងទៀតពុំបានត្រាស់ទុកមកពីដំបូង ព្រោះហេតុអ្វី? ក្នុងទីនេះ លោកទើបត្រាស់ទុកជាសេចក្តីដំបូង ។ ចាំបាច់ត្រូវជម្រះពាក្យផ្តើមខាងដើម តអំពីនេះទៅ ក្នុងពាក្យផ្តើមខាងដើម ក៏នឹងជាក់ច្បាស់អំពីព្រះពុទ្ធ អំពីការដល់សរណៈ និងអំពីបុគ្គលអ្នកដល់សរណៈ និងសម្តែងការដាច់ ការមិនដាច់នៃសរណគមន៍ ទាំងផល ទាំងសរណៈ ដែលគួរដល់ សូម្បីក្នុងសរណៈ ២ មាន **ធម្មំ សរណំ** ជាដើម ក៏ដឹងហើយថាមានន័យយ៉ាងនេះ នឹងអធិប្បាយហេតុក្នុងការកំណត់ដោយលំដាប់ ហើយនឹងប្រកាសត្រៃសរណៈនោះ ដោយសេចក្តីឧបមា ទាំងឡាយ ។

បណ្តាគាថាទាំងនោះ គាថាដំបូងមុនដទៃ មានបញ្ហា ៥ យ៉ាងគឺ

១-ព្រះត្រៃសរណៈនេះ នរណាពោល ?

២-ពោលក្នុងទីណា ?

៣-ពោលក្នុងកាលណា ?

៤-ពោលព្រោះហេតុអ្វី ?

៥-ព្រោះហេតុអ្វីព្រះតថាគតពុំបានត្រាស់ទុកមកពីដំបូង ?

ព្រោះហេតុអ្វីក្នុងទីនេះទើបត្រាស់ទុកជាសេចក្តីដំបូង ។

ការវិសជ្ជនាចំពោះបញ្ហាទាំង ៥ នោះ គឺ

បញ្ហាថា នរណាពោល? វិសជ្ជនាថា ព្រះមានព្រះភាគជាម្ចាស់ត្រាស់ មិនមែនសាវ័ក មិនមែនពួកឥសី មិនមែនទេវតាពោលទេ ។ បញ្ហាថា ពោលក្នុងទីណា? វិសជ្ជនាថា ក្នុងព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ បញ្ហាថា ពោលក្នុងកាលណា? វិសជ្ជនាថា ក្នុងកាលដែលព្រះយសត្ថេរដ៏មានអាយុ និងសម្លាញ់ទាំងឡាយ បានសម្រេចព្រះអរហត្ត កាលព្រះអរហន្តមាន ៦១ អង្គ ធ្វើការសម្ដែងធម៌ក្នុងលោក ដើម្បីប្រយោជន៍សុខដល់ជនចំនួនច្រើន ។ បញ្ហាថា ពោលព្រោះហេតុអ្វី? វិសជ្ជនាថា ដើម្បីបព្វជ្ជានិងឧបសម្បទា ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបទ្រង់ត្រាស់ទុកថា

"ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវឱ្យបព្វជ្ជា ឱ្យឧបសម្បទាយ៉ាងនេះ ។ កុលបុត្រនោះ ភិក្ខុគប្បីកោរសក់ និងពុកមាត់ជាដំបូងហើយ ឱ្យស្លៀកសំពត់កាសាយៈទាំងឡាយ ឱ្យអង្គុយច្រហោង ហើយផ្គងអញ្ជលីឡើងរួចប្រាប់ថា អ្នកចូរពោលពាក្យនេះ[១]ថា ខ្ញុំព្រះករុណាសូមដល់ព្រះពុទ្ធជាទីរលឹក

---

១-**"យមហំ វទាមិ, តំ វទេហី"តិ វត្តព្វោ** ពាក្យថាចូរពោលនោះ ព្រះអដ្ឋកថាពន្យល់ថា "ខ្ញុំពោលនូវពាក្យណា អ្នកចូរពោលនូវពាក្យនោះ" ។ សមន្តបាសាទិកា អដ្ឋកថាមហាវគ្គ វិន័យបិដក ។

សម្រាប់ជាធម្មទាន

ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីរលឹក ខ្ញុំព្រះករុណាសូមដល់ព្រះសង្ឃជាទីរលឹក”[១] ។

បញ្ហាថា ព្រោះហេតុអ្វី ក្នុងទីនេះព្រះសម្ពុទ្ធទើបទ្រង់ត្រាស់ជាដំបូង? វិសជ្ជនាថា ព្រោះទេវតា និងមនុស្សទាំងឡាយ នាំគ្នាកាន់ព្រះសាសនាដោយភាពជាឧបាសកខ្លះ ជាបព្វជិតខ្លះ ដោយវិធីយ៉ាងនេះ ទើបបុរាណាចារ្យទាំងឡាយ កាលរួបរួមនវង្គសត្ថុសាសន៍នេះ ដោយបិដកទាំង ៣ ហើយលើកឡើងកាន់វិធីបង្ហាត់បង្រៀន ព្រោះដូច្នោះ ទើបត្រាស់ជាសេចក្តីដំបូង ក្នុងខុទ្ទកបាឋៈនេះ ព្រោះជាផ្លូវទៅកាន់ព្រះសាសនា ។

១-វិន័យបិដក មហាវគ្គ បឋមភាគ លេខ ៦ ទំព័រ ៧០ ។

## ១-សរណត្តយវណ្ណនា

## **ពណ៌នាព្រះត្រៃសរណៈ**

### ពុទ្ធវិភាវនា

### **ការសម្តែងឡើងអំពីព្រះពុទ្ធ**

ឥឡូវនេះ ពាក្យណាខ្ញុំពោលទុកថា "នឹងសម្តែងនូវព្រះពុទ្ធ ការដល់សរណៈជាទីពឹង និងបុគ្គលអ្នកដល់សរណៈជាទីពឹង" ក្នុងពាក្យនោះ សត្វវិសេស ឈ្មោះថា **ព្រះពុទ្ធ** ព្រោះបញ្ញត្ត អាស្រ័យខន្ធសន្តាន ដែលត្រូវអប់រំ ដោយការចាក់ធ្លុះនូវអនុត្តរៈ និងវិមោក្ខ ដែលជានិមិត្តនៃញាណ គឺទោសជាតិ មិនខ្ទាំងខ្ទប់ក្នុងធម៌ទាំងឡាយ ឬព្រោះបញ្ញត្ត អាស្រ័យការត្រាស់ដឹងខ្លួនឯងនូវសច្ចៈ ដែលមានសព្វញ្ញុតញ្ញាណជាបទដ្ឋាន ។ សមដូចពាក្យដែលព្រះសុគតសម្តែងទុកថា "ពាក្យថា **ព្រះពុទ្ធ** បានដល់ព្រះមានព្រះភាគជាសយម្ភូឥតមានគ្រូអាចារ្យ បានត្រាស់ដឹងសច្ចៈដោយព្រះអង្គឯង ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនផង ទ្រង់ដល់នូវសព្វញ្ញុតញ្ញាណ ក្នុងសច្ចៈនោះផង ទ្រង់ដល់នូវភាពស្ទាត់ជំនាញក្នុងពលៈទាំងឡាយផង"[១] ។

ការសម្តែងអំពីព្រះពុទ្ធដោយអត្ថប៉ុណ្ណេះ ។

តែថាដោយព្យញ្ជនៈ គប្បីជ្រាបដោយន័យជាដើមយ៉ាងនេះ ថា "ឈ្មោះថា **ពុទ្ធៈ** ព្រោះទ្រង់ជាអ្នកត្រាស់ដឹង ឈ្មោះថា **ពុទ្ធៈ** ព្រោះទ្រង់

១-សុត្តន្តបិដក ខុទ្ទកនិកាយ មហានិទ្ទេស ត្រង់សារីបុត្តសុត្តនិទ្ទេស លេខ ៦៦ ទំព័រ២៣៧ ។

ជាអ្នកដាស់ឱ្យភ្ញាក់ ។ សមដូចព្រះសារីបុត្រពោលទុកថា “ពាក្យថា **ព្រះពុទ្ធ** ចុះព្រះនាមថា ព្រះពុទ្ធ ដោយអត្ថថាដូចម្តេច? ព្រះនាមថា **ព្រះពុទ្ធ** ព្រោះព្រះអង្គត្រាស់ដឹងសច្ចៈទាំងឡាយ ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះព្រះអង្គញុំាងពួកសត្វឱ្យត្រាស់ដឹង ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះទ្រង់ត្រាស់ដឹងនូវធម៌ទាំងអស់ ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះទ្រង់ឃើញច្បាស់នូវធម៌ទាំងអស់ ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះទ្រង់ត្រាស់ដឹងដោយព្រះអង្គឯង ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះព្រះអង្គរីកហើយ ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះការរាប់ថាជា ព្រះខីណាស្រព ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះការរាប់ថាមិនមានឧបក្កិលេស ។ ព្រះនាមថា**ព្រះពុទ្ធ** ព្រោះព្រះអង្គប្រាសចាករាគៈ ដោយចំណែកមួយ ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះព្រះអង្គប្រាសចាកទោសៈ ដោយចំណែកមួយ ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះព្រះអង្គប្រាសចាកមោហៈដោយចំណែកមួយ ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះព្រះអង្គមិនមានកិលេស ដោយចំណែកមួយ ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះព្រះអង្គយាងទៅកាន់ផ្លូវជាទីទៅតែមួយអង្គឯង ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះព្រះអង្គត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិតែ មួយអង្គឯង ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះព្រះអង្គកម្ចាត់បង់នូវសេចក្តីមិនដឹង ព្រោះព្រះអង្គបាននូវការត្រាស់ដឹង ។ ព្រះនាមថា **ព្រះពុទ្ធ** នុ៎ះ ព្រះមាតា មិនបានថ្វាយព្រះបិតាមិនបានថ្វាយ បងប្អូនប្រុសមិនបានថ្វាយ បងប្អូន ស្រីមិនបានថ្វាយ

ពួកមិត្តអាមាត្យមិនបានថ្វាយ ពួកញាតិសាលោហិតមិនបានថ្វាយ ពួកសមណ-ព្រាហ្មណ៍មិនបានថ្វាយ ពួកទេវតាក៏មិនបានថ្វាយ ព្រះនាមថា **ព្រះពុទ្ធ** នុ៎ះ ជាព្រះនាមមានក្នុងទីបំផុត នៃវិមោក្ខរបស់ព្រះពុទ្ធទាំងឡាយ ទ្រង់មានជោគការបញ្ញត្តថា**ព្រះពុទ្ធ** នេះ (កើត) ដោយការធ្វើឱ្យជាក់ច្បាស់ព្រម ដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណទៀបគល់ពោធិព្រឹក្សហេតុនោះ (លោកហៅថា)ចំពោះព្រះពុទ្ធនោះ”[១] ។

ក្នុងបទថា **ពុទ្ធ** នោះ ឈ្មោះថា ពុទ្ធៈ ព្រោះអត្ថថាត្រាស់ដឹងនូវសច្ចៈទាំងឡាយ ដូចអ្នកដែលចុះមកក្នុងលោក ក៏ហៅថាអ្នកចុះមក ។ ឈ្មោះថា **ពុទ្ធៈ** ព្រោះអត្ថថា ទ្រង់ដាស់ពួកសត្វឱ្យភ្ញាក់ ដូចខ្យល់ដែលធ្វើស្លឹកឈើឱ្យស្ងួត ក៏ហៅថាស្លឹកឈើស្ងួត ។ បទថា **សព្វញ្ញុតាយ ពុទ្ធោ** លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធៈ** ព្រោះការដឹង ដែលអាចដឹងបានគ្រប់យ៉ាង ។ បទថា **សព្វទស្សាវិតាយ ពុទ្ធោ** លោកពន្យល់ថា ឈ្មោះថា **ពុទ្ធៈ** ព្រោះការដឹង ដែលអាចញ៉ាំងសត្វឱ្យដឹងធម៌បានគ្រប់យ៉ាង ។ បទថា អនញ្ញនេយ្យតាយ[២]ពុទ្ធោ លោកអធិប្បាយថា ឈ្មោះថា ពុទ្ធៈ ព្រោះ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ មហានិទ្ទេស ត្រង់សារីបុត្តសុត្តនិទ្ទេស លេខ ៦៦ ទំព័រ២៣៧-២៣៩

២-បិដកលេខ ៦៦ ទំព័រ ២៣៨, លោកប្រើពាក្យថា **អភិញ្ញេយ្យតាយ** ហើយក្នុងគម្ពីរ បរមត្ថជោតិកាច្បាប់មហាចុឡាឡង្កណរាជវិទ្យាល័យសង្ឃថា **អនញ្ញញេយ្យតាយ** ។ ក្នុងទីនេះ យើងប្រើពាក្យក្នុង បរមត្ថ-ជោតិកាច្បាប់ឆដ្ឋសង្គាយនា ។

ត្រាស់ដឹងដោយព្រះអង្គឯង ពុំមែនអ្នកដទៃធ្វើឱ្យត្រាស់ដឹងទេ ។ បទថា វិកសិតាយ ពុទ្ធោ លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធៈ** ព្រោះទ្រង់លាបេញ ពោលគឺលាចេញដោយព្រះគុណផ្សេងៗ ដូចផ្កាបទុមរីក ។ ដោយបទជាដើមយ៉ាងនេះថា **ខីណាសវសង្ខាតេន** ពុទ្ធោ លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធៈ** ព្រោះទ្រង់ភ្ញាក់ហើយ គឺការអស់កិលេសទាំងឡាយជាគ្រឿងធ្វើឱ្យលង់លក់ ដូចជាបុរសភ្ញាក់ ព្រោះអស់ការងងុយ ព្រោះជាការលះបង់នូវធម៌ ជាគ្រឿងធ្វើចិត្តឱ្យកម្រើក ។ លោកពោលថា ឯកាយនមគ្គំ គតោតិ ពុទ្ធោ ដូច្នេះ ក៏ដើម្បីសម្ដែងថា ព្រះមានព្រះភាគជាម្ចាស់ លោកហៅថា **ពុទ្ធៈ** ក៏ព្រោះទ្រង់ធ្វើដំណើរតាមឯកាយនមគ្គ ដូចបុរសសូម្បីដើរផ្លូវ ក៏ហៅថាអ្នកដើរទៅ ព្រោះបរិយាយនូវអត្ថ ជាគ្រឿងទៅកាន់ផ្លូវដើម្បីត្រាស់ដឹង ។ បទថា ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ពុទ្ធោ ពាក្យថា ពុទ្ធៈ ព្រោះត្រាស់ដឹងនូវសម្មាសម្ពោធិដ៏ប្រសើរជាងគេ ដោយព្រះអង្គឯងប៉ុណ្ណោះ មិនមែន អ្នកដទៃញុំាងព្រះអង្គឱ្យត្រាស់ដឹងទេ ។ បទនេះថា អពុទ្ធិវិហតត្តា ពុទ្ធិបដិលាភា ពុទ្ធោ ជាពាក្យសម្ដែងបរិយាយថា ពុទ្ធិ ពុទ្ធំ ពោធោ ។ ក្នុងពាក្យនោះ គប្បីជ្រាបអត្ថ ដែលអាចធ្វើ ពុទ្ធ-ស័ព្ទ របស់បទគ្រប់បទ

*ឱ្យសម្រេចដោយន័យយ៉ាងនេះ ដែលលោកអធិប្បាយ ដើម្បីឱ្យដឹងថា ពុទ្ធៈ ព្រោះទ្រង់ប្រកបដោយព្រះគុណ គឺពុទ្ធិ ជាការដឹង ដូចដែលហៅថា សំពត់ខៀវ សំពត់ក្រហម ក៏ព្រោះប្រកបដោយពណ៌ខៀវ ពណ៌ក្រហម ។ បន្ទាប់ពីនោះ អត្ថ ដែលអាចធ្វើឱ្យសម្រេចនូវ* ***ពុទ្ធ****-ស័ព្ទ របស់បទទាំងឡាយគប្បីជ្រាបដោយន័យដែលមានរូបយ៉ាងនេះថា “បទជាដើមថា ពុទ្ធោតិ* នេតំ នាមំ *លោកពោលទុកក៏ដើម្បីឱ្យដឹងថាបញ្ញត្តនេះ ជាដំណើរទៅតាមអត្ថ គឺសេចក្ដី” ។*

*ការសម្ដែងអំពីពុទ្ធៈ សូម្បីដោយព្យញ្ជនៈ មានដូចបានពោលមកនេះ ។*

## សរណាគមនគមកវិភាវនា

## **ការសំដែងអំពីសរណគមន៍ និង អ្នកដល់សរណគមន៍**

*ឥឡូវនេះ នឹងពោលបង្ហាញឱ្យច្បាស់ ក្នុងការដល់សរណគមន៍ជាដើមដូចតទៅនេះ ព្រះរតនត្រ័យ ដែលឈ្មោះថា* ***សរណៈ*** *ព្រោះបៀតបៀន គឺបៀតបៀន កម្ចាត់បង់ នាំចេញ គឺធ្វើឱ្យរលត់នូវភ័យ ការខ្លាច សេចក្ដីទុក្ខ ទុគ្គតិ សេចក្ដីសៅហ្មង ដោយការដល់សរណៈនោះនុ៎ះឯង នៃអ្នកដែលដល់សរណគមន៍ទាំងឡាយ ។ ន័យម្យ៉ាងទៀត ព្រះពុទ្ធ ឈ្មោះថា* ***សរណៈ*** *ព្រោះកម្ចាត់ភ័យរបស់សត្វទាំងឡាយ ដោយការឱ្យចូលដល់វត្ថុ*

ដែលជាប្រយោជន៍ និងនាំចេញវត្ថុដែលមិនមានប្រយោជន៍ ។ ព្រះធម៌ ឈ្មោះថា **សរណៈ** ព្រោះឱ្យសត្វឆ្លងផុតផ្លូវកន្តារ គឺភព និងឱ្យរីករាយចិត្ត ។ ព្រះសង្ឃ ឈ្មោះថា **សរណៈ** ព្រោះធ្វើនូវសក្ការៈ សូម្បីសក្ការៈនោះតិច ក៏រមែងបានផលច្រើន ។ ព្រោះដូច្នោះ ព្រះរតនត្រៃនោះ ទើបឈ្មោះថា **សរណៈ** ដោយបរិយាយដូចពោលមកដូច្នេះ ។ ចិត្តុប្បាទ ដែលប្រព្រឹត្តទៅដោយការជ្រះថ្លា ក្នុងព្រះរតនត្រៃនោះ និងការគោរព ក្នុងព្រះរតនត្រៃនោះ កម្ចាត់បង់នូវកិលេសអស់ បានប្រព្រឹត្តទៅដោយអាការៈ គឺការមានព្រះរតនត្រៃនោះជាត្រើយ ឬមិនមានអ្នកដទៃជាបច្ច័យ (អូសទាញ) ឈ្មោះថា **សរណគមនៈ** ។ សត្វអ្នកព្រមព្រៀងដោយចិត្តុប្បាទនោះ រមែងដល់ព្រះរតនត្រៃនោះ ជាសរណៈ អធិប្បាយថា រមែងចូលដល់ព្រះរតនត្រៃ ដោយចិត្តុប្បាទមានប្រការ ដូចពោលហើយយ៉ាងនេះថា "នេះជាសរណៈ របស់ខ្ញុំ នេះជាគ្រឿងពំនឹងរបស់ខ្ញុំ" ។ ក៏បុគ្គលកាលចូលដល់ រមែងចូលដល់ ដោយវិធីសមាទាន ដូចជានាយពាណិជ្ជពីរនាក់ ឈ្មោះតបុស្សៈ និងផល្លិកៈ ជាដើមថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងពីរនេះ សូមដល់ព្រះពុទ្ធ និងព្រះធម៌ជាសរណៈ សូមព្រះមានព្រះភាគទ្រង់ព្រះមេត្តាចាំនូវខ្ញុំព្រះអង្គទាំងពីរថាជាឧបាសក"ដូច្នេះក្តី ម្យ៉ាងទៀត ការចូលដល់

ដោយភាពជាសិស្ស ដូចជាព្រះមហាកស្សបៈជាដើមថា “បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គជាគ្រូរបស់ខ្ញុំ ខ្ញុំជាសាវ័ករបស់ព្រះអង្គ”[១] ដូច្នេះក្តី មួយទៀត ការចូលដល់ ដោយការបង្អោនទៅរកព្រះរតនត្រៃនោះ ដូចជាព្រហ្មាយុព្រាហ្មណ៍ជាដើម សេចក្តីនៃព្រះបាលីថា “កាលបើឧត្តរមាណពពោលយ៉ាងនេះហើយ ព្រហ្មាយុព្រាហ្មណ៍ ក៏ក្រោកចាកអាសនៈ ធ្វើនូវសំពត់ឧត្តរាសង្គៈ ឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ចំពោះត្រង់ទី ដែលព្រះមានជោគគង់បន្លឺនូវឧទានវាចាអស់វារៈបីដងថា សូមថ្វាយបង្គំព្រះមានព្រះភាគ ជាព្រះអរហន្ត-សម្មាសម្ពុទ្ធអង្គនោះ...សូមថ្វាយបង្គំព្រះសម្ពុទ្ធ ជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ”[២] ដទៃទៀត ការដល់ដោយការអប់រំខ្លួន ដូចជាយោគីបុគ្គលអ្នកខ្វល់ខ្វាយក្នុងកម្មដ្ឋាន ម្យ៉ាងទៀត ការដល់(ព្រះរតនត្រៃ) មានបការៈមិនតែមួយ ដោយវិស័យ និងកិច្ច មានការកម្ចាត់បង់ឧបក្កិលេស ដោយការដល់សរណគមន៍ ដូចជាព្រះអរិយបុគ្គលទាំងឡាយ ។

ការសម្តែងអំពីការដល់សរណគមន៍ និងបុគ្គលអ្នកដល់សរណគមន៍ដូចពោលមកនេះ ។

---

១-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ ចតុត្ថភាគ កស្សបសំយុត្ត បិដកលេខ ៣២ ទំព័រ ១៦៩ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ឆដ្ឋភាគ លេខ ២៥ ទំព័រ ១៩ ។

## ភេទាភេទផលទីបនា

## ការបំភ្លឺការដាច់ ការមិនដាច់ និងផលរបស់សរណគមន៍

ឥឡូវនេះ នឹងសម្ដែងការដាច់សរណគមន៍ជាដើម ដែលខ្ញុំពោលទុកថា "ភេទាភេទំ ផលញ្ចាបិ គមនីយញ្ច ទីបយេ ខ្ញុំនឹងបំភ្លឺការដាច់ ការមិនដាច់ ផល និងការដល់សរណៈ" ដូចតទៅនេះ៖

ការដាច់សរណគមន៍របស់បុគ្គលអ្នកដល់សរណគមន៍ មានពីរយ៉ាង គឺមានទោស និងមិនមានទោស ។ ការដាច់សរណគមន៍ ព្រោះការស្លាប់ ឈ្មោះថា **មិនមានទោស** ការដាច់សរណគមន៍ ព្រោះបែរទៅរាប់អានលទ្ធិដទៃ និងប្រព្រឹត្តខុសក្នុងព្រះសាស្ដានោះ ឈ្មោះថា **មានទោស** ។ ការដាច់ទាំងពីរយ៉ាងនោះ រមែងមានដល់បុថុជ្ជន ។ សរណគមន៍សៅហ្មងរបស់បុថុជ្ជន ព្រោះប្រព្រឹត្តទៅដោយការមិនដឹង ការសង្ស័យ ការយល់ខុស និងព្រោះមិនប្រព្រឹត្តអើពើជាដើមក្នុងព្រះពុទ្ធគុណទាំងឡាយ ។ ចំណែកព្រះអរិយបុគ្គល រមែងជាអ្នកមិនដាច់សរណគមន៍ផង មិនមានសរណគមន៍សៅហ្មងផង ។ សមដូចជាព្រះពុទ្ធតម្រាស់ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ ដោយទិដ្ឋិ[១]ឧទ្ទិសខ្លួនចំពោះគ្រូដទៃ ដោយហេតុឯណា ហេតុ

១-**ទិដ្ឋិសម្បន្នោតិ មគ្គទិដ្ឋិយា សម្បន្នោ សោតាបន្នោ អរិយសាវកោ** ពាក្យថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ សំដៅដល់អរិយបុគ្គលថ្នាក់សោតាបន្ន ដែល បរិបូណ៌មគ្គទិដ្ឋិ (មនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ) ។

សម្រាប់ជាធម្មទាន

នោះ មិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ”(១) ។ ចំណែកបុថុជ្ជន មិនដល់នូវការដាច់សរណគមន៍ដរាបណា ដរាបនោះ ឈ្មោះថា មានសរណគមន៍មិនបែកធ្លាយ ។ ការដាច់សរណគមន៍របស់បុថុជ្ជន ជាការដាច់មានទោស ជាការសៅហ្មង (ក្នុងសរណគមន៍) និងមានផលមិនគួរប្រាថ្នា ។ ការដាច់សរណគមន៍ ដែលមិនមានទោស ក៏មិនមានផល ព្រោះពុំមានវិបាក ចំណែកការមិនដាច់សរណគមន៍ រមែងឱ្យផលជាទីប្រាថ្នាតែម្យ៉ាងដោយផល ។ សមដូចជាព្រះមានព្រះភាគត្រាស់ទុកថា:

យេ កេចិ ពុទ្ធំ សរណំ គតាសេ ន តេ គមិស្សន្តិ អបាយភូមឹ
បហាយ មានុសំ ទេហំ ទេវកាយំ បរិបូរេស្សន្តិ ។

ពួកជនណាមួយ បានដល់នូវព្រះពុទ្ធ ជាទីពឹងរឭកហើយ ពួកជននោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញពពួកនៃទេវតាមិនខាន”(២) ។

ក៏ក្នុងសេចក្តីនោះ គប្បីជ្រាបអធិប្បាយនៃគាថាយ៉ាងនេះថា ជនណាដល់សរណគមន៍ ដោយការកាត់ឧបក្កិលេស ព្រោះសរណគមន៍ ជននោះ

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ៤០ ទំព័រ ៦១

២-សុត្តន្តបិដក ទីឃនិកាយ ចតុត្ថភាគ មហាវគ្គ លេខ ១៧ ទំព័រ ១៧១ ។

នឹងមិនទៅអបាយឡើយ ។ ចំណែកជនក្រៅនោះ នឹងមិនទៅកាន់អបាយដោយការដល់សរណៈឡើយ ។

ការបំភ្លឺពីការដាច់ និងមិនដាច់ ព្រមទាំងផលរបស់សរណគមន៍ ដូចពោលមកនេះឯង ។

## គមនីយទីបនា

## ការបំភ្លឺអំពីការដល់សរណៈ

ការសម្តែងសរណគមន៍ដែលគួរដល់ អ្នកជំទាស់ពោលថា ក្នុងពាក្យនេះថា "ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់ព្រះពុទ្ធជាសរណៈ" អ្នកណាដល់ព្រះពុទ្ធជាសរណៈ អ្នកនោះនឹងគប្បីដល់ព្រះពុទ្ធ ឬសរណៈ សូម្បីពាក្យទាំងពីរ ការពោលពាក្យតែមួយក៏គ្មានប្រយោជន៍ ។ ព្រោះហេតុអ្វី? ព្រោះមានតែកិរិយា គឺការដល់មិនមានកម្មពីរ ។ តាមពិត អ្នកអក្សរសាស្ត្រ[១] មិនមានបំណងនូវកម្មទាំង ២ ដូចក្នុងប្រយោគទាំងឡាយមាន ជាអាទិថា "អជំ គាមំ នេតិ" ជាដើម ដូច្នោះ ។

បើអ្នកជំទាស់ពោលថា ការពោលសូម្បីពាក្យទាំងពីរមានប្រយោជន៍តែម្យ៉ាង ដូចក្នុងពាក្យថា "គច្ឆតេវ បុព្វំ ទិសំ គច្ឆតិ បច្ឆិមំ ទិសំ"

---

១-ពាក្យបាលីថា អក្ខរចិន្តកា ប្រែថា អ្នកគិតនូវអក្សរសាស្ត្រ គឺអ្នកអក្សរសាស្ត្រ ។

អ្នកអក្សរសាស្ត្រ មិនមានបំណងយ៉ាងនោះ ព្រោះលោកមិនបំណងថា ព្រះពុទ្ធ និងសរណៈ ជាតួហេតុស្មើៗគ្នាទេ ។ សេចក្តីពិត កាលបំណងថា ព្រះពុទ្ធ និងសរណៈពួកនោះជាតួហេតុស្មើៗគ្នា បុគ្គលសូម្បីមានការអន់ចិត្តចូលគាល់ព្រះពុទ្ធ ក៏នឹងគប្បីដល់ព្រះពុទ្ធជាសរណៈ ។ សរណៈនោះឯណាធ្វើឱ្យផ្សេងទៅថា ព្រះពុទ្ធ អ្នកនោះក៏ឈ្មោះថាដល់សរណៈនោះដែរ ។ បើអ្នកជំទាស់ពោលថា លោកបំណងយកសេចក្តី ដែលព្រះពុទ្ធជាតួហេតុស្មើៗគ្នា ព្រោះបាលីថា "**ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ** ទុំះឯង ជាទីពឹងដ៏ក្សេម ទុំះឯងជាទីពឹងដ៏ឧត្តម"[១] មិនមានបំណងដូច្នោះ ព្រោះក្នុងបទគាថានោះ មានតែព្រះពុទ្ធជាសរណៈនោះ ។ សេចក្តីពិត ក្នុងបទគាថានោះទុំះឯង លោកបំណងដល់សេចក្តីដែលព្រះពុទ្ធ និងសរណៈ ជាតួហេតុស្មើៗគ្នា យ៉ាងនេះថា សរណៈទាំងក្សេម ទាំងឧត្តម ព្រោះពិចារណាបញ្ជាក់ដល់ព្រះរតនត្រៃ មានព្រះពុទ្ធជាម្ចាស់ជាដើមនោះ ក្នុងសេចក្តីជាសរណៈ ដែលរាប់បានថា កម្ចាត់ភ័យ ដល់អ្នកដល់សរណគមន៍បានពិត ចំណែកក្នុងព្រះបាលីប្រទេសដទៃ កាលមានសេចក្តីសម្ពន្ធដោយអ្នកដល់សរណគមន៍ លោកក៏មិនបំណងសេចក្តី ដែលព្រះពុទ្ធ និងសរណៈ ជាតួហេតុស្មើៗគ្នាទេ ព្រោះមិនសម្រេចជា សរណគមន៍ដូច្នោះ ពាក្យនេះ

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ ធម្មបទគាថា លេខ ៥២ ទំព័រ ៦២ ។

ទើបជាគ្រឿងសំអាងមិនបាន ។ បើអ្នកជំទាស់ពោលថា គួរនឹងបំណង យកសេចក្តីដែលព្រះពុទ្ធ និងសរណៈជា តួហេតុស្មើៗគ្នា ព្រោះសម្រេចជា សរណគមន៍ សូម្បីកាលមានសេចក្តីសម្ពន្ធ ដោយអ្នកដល់សរណគមន៍បាន ក្នុងព្រះបាលីថា “ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ បុគ្គល អាស្រ័យទីពឹងនេះ រមែងរួចស្រឡះចាកទុក្ខទាំងពួងបាន”[១] បុគ្គលអាស្រ័យ សរណៈនោះ រមែងរួចផុតចាកទុក្ខទាំងពួងដូច្នេះ មិនមែនដូច្នោះឡើយ ព្រោះមិនយល់ព្រមដោយទោស ដែលពោលមកមុនហើយ ។ តាមពិត សូម្បីក្នុងសេចក្តីនោះ ក៏នឹងគប្បីមិនយល់ព្រមដោយទោស ដែលពោលមក មុនថា កាលមានសេចក្តីដែលព្រះពុទ្ធ និងសរណៈជាតួហេតុស្មើៗគ្នា បុគ្គល សូម្បីមានចិត្តបៀតបៀន នឹងសរណៈ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ក៏ នឹងគប្បីរួចផុតចាកទុក្ខបាន តែនឹងថាមិនយល់ព្រមដោយទោសក៏ទេ ដូច្នោះ ពាក្យនោះ ទើបអាងមិនបាន ។ គប្បីជ្រាបអធិប្បាយ ក្នុងសេចក្តី នោះ យ៉ាងនេះថា សត្វទាំងឡាយ កាលនឹងរួចផុត ដោយអានុភាពរបស់ ព្រះមានព្រះភាគ ជាកល្យាណមិត្ត លោកក៏ពោលថា “អាស្រ័យកល្យាណ មិត្ត ទើបរួចផុត(ទុក្ខ)បាន” ក្នុងព្រះបាលីនេះថា “ម្នាលអានន្ទ សត្វទាំងឡាយ មានជាតិជាធម្មតា រមែងរួចចាកជាតិបាន ក៏ព្រោះអាស្រ័យនឹងតថាគតជា

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ ធម្មបទគាថា លេខ ៥២ ទំព័រ ៦២ ។

*មិត្តល្អ"[១] យ៉ាងណា សូម្បីក្នុងទីនេះ បុគ្គលកាលរួចផុត ដោយអានុភាពនៃសរណៈ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ទើបលោកពោលថា "បុគ្គលអាស្រ័យសរណៈនេះ រមែងរួចផុតចាកទុក្ខទាំងពួង"ក៏ដូច្នោះដែរ ។*

*ការដល់ព្រះពុទ្ធក៏មិនត្រូវ ការដល់សរណៈក៏មិនត្រូវ សូម្បីទាំងពីរបទក៏មិនត្រូវ ដោយប្រការទាំងពួងយ៉ាងនេះ គមនីយវត្ថុនៃអ្នកដល់សរណគមន៍ ដែលលោកអធិប្បាយថា "ខ្ញុំដល់វត្ថុដែលគប្បីប្រាថ្នា" គួរពោលការដល់បន្តនោះក៏គួរក្នុងសេចក្ដីនេះ ។*

*សេចក្ដីដែលត្រូវក្នុងរឿងនេះ ខ្ញុំនឹងពោលសេចក្ដីគួរ ដូចតទៅនេះ "ក្នុងសេចក្ដីគួរនេះ ព្រះពុទ្ធប៉ុណ្ណោះជា គមនីយៈ តែដើម្បីសម្ដែងអាការៈ គឺការដល់ ពាក្យពោលដល់សរណៈនោះថា ខ្ញុំដល់ព្រះពុទ្ធជាសរណៈ ។ ខ្ញុំសូមដល់ គឺគប់រក គឺសេព ឬថាចូលទៅជិតព្រះពុទ្ធអង្គនោះ ដោយបំណងយ៉ាងនេះថា "ព្រះពុទ្ធអង្គនោះជាសរណៈរបស់ខ្ញុំ ព្រះពុទ្ធអង្គនោះជាទីពឹងរបស់ខ្ញុំ ជាអ្នកកម្ចាត់ទុក្ខ ជាអ្នកទ្រទ្រង់ប្រយោជន៍" ឬថា ខ្ញុំជ្រាបច្បាស់យ៉ាងនេះ ។ មែនពិត គតិជាប្រយោជន៍របស់ធាតុពួកណា សូម្បីការដឹងក៏ជាប្រយោជន៍របស់ធាតុពួកនោះ ។ បើអ្នកជំទាស់ពោលថា*

---

*១-សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ បឋមភាគ លេខ ២៩ ទំព័រ ២៣៩ ។*

"សេចក្តីនោះមិនត្រឹមត្រូវ ព្រោះមិនប្រកបឥតិ-ស័ព្ទ" ពាក្យជំទាស់នោះក៏មិនត្រូវ ។ សេចក្តីត្រឹមត្រូវក្នុងរឿងនោះ គប្បីមានដូច្នេះ ។ ប្រសិនបើសេចក្តីក្នុងរឿងនោះ គប្បីមានយ៉ាងនេះ បន្ទាប់ពីនោះ ការប្រកប ឥតិ-ស័ព្ទ គប្បីមានដូចក្នុងប្រយោគទាំងឡាយជាដើមថា "អនិច្ចំ រូបំ អនិច្ចំ រូបន្តិ យថាភូតំ បជានាតិ (ភិក្ខុនោះ) ដឹងច្បាស់តាមពិតនូវរូបមិនទៀង ថា រូបមិនទៀង"[១] តែ **ឥតិ-ស័ព្ទ** លោកមិនប្រកបទុកទេ ព្រោះដូច្នោះ ទើបសេចក្តីជំទាស់នោះ មិនត្រឹមត្រូវ ។ តែសេចក្តីនោះមិនត្រឹមត្រូវ ព្រោះហេតុអ្វី? ព្រោះអត្ថរបស់ឥតិ-ស័ព្ទ មាននៅក្នុងសេចក្តីនោះហើយ ។ អត្ថរបស់ឥតិ-ស័ព្ទ សូម្បីក្នុងទីនេះ ក៏មានព្រម ដូចក្នុងប្រយោគទាំងឡាយជាដើមយ៉ាងនេះថា "យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ បុគ្គលណាយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង"[២] ដូច្នេះ តែពុំមែនត្រូវប្រកប**ឥតិ-ស័ព្ទ** ទុកគ្រប់ទីកន្លែងទេ ព្រោះមានសេចក្តីនៅព្រមក្នុងតួហើយ បណ្ឌិតគប្បីជ្រាបអត្ថរបស់**ឥតិ-ស័ព្ទ** សូម្បីពុំបានប្រកបទុក ដូចដែលប្រកបទុកក្នុងទីនោះ និងក្នុងទីដទៃ ដែលមានកំណើតយ៉ាងនេះ ព្រោះដូច្នោះ

---

១-សុត្តន្តបិដក សំយុត្តនិកាយ ខន្ធវារវគ្គ បញ្ចមភាគ លេខ ៣៣ ទំព័រ ១៣០ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ ធម្មបទគាថា លេខ ៥២ ទំព័រ ៦២ ។

**ឥតិ-ស័ព្ទ** ទើបមិនមានទោស(មិនខុស) ។ បើអ្នកជំទាស់ពោលថា ពាក្យណា ដែលលោកពោលទុកថា ក៏គប្បីសម្ដែងអាការៈ គឺដល់ទើបត្រូវពោលបញ្ចូលសរណៈដូច្នេះ ពាក្យនោះក៏មិនត្រូវ ព្រោះសរណៈប៉ុណ្ណោះជាគមនីយៈ ជាវត្ថុដែលគួរដល់ ក្នុងបាលីជាដើមថា“អនុជានាមិ ភិក្ខវេ **ឥមេហិ តីហិ សរណាគមនេហិ បព្វជ្ជំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត បព្វជ្ជា ដោយត្រៃសរណគមន៍ទាំងឡាយនេះ”[១]ដូច្នេះ ពាក្យដែលខ្ញុំពោលមកនោះ ក៏មិនត្រឹមត្រូវ និងជាពាក្យមិនសមគួរ ។ ព្រោះហេតុអ្វី? ព្រោះពាក្យនោះ មានសេចក្ដីព្រមក្នុងខ្លួន ។ តាមពិត អត្ថរបស់ឥតិ-ស័ព្ទនោះ ក៏មានព្រមក្នុងពាក្យនោះឯង សូម្បីមិនប្រកបដោយឥតិ-ស័ព្ទ ប្រាកដស្មើដូចពាក្យមុន ក៏គប្បីជ្រាបដូចប្រកបឥតិ-ស័ព្ទទុក ។ ក្រៅអំពីនេះ ក៏គប្បីយល់ព្រមដោយទោស ដែលពោលមកមុននោះឯង ព្រោះដូច្នោះ គប្បីកាន់ យកតាមដែលលោកបង្ហាត់ទុកប៉ុណ្ណោះ ។

**អយំ គមនីយទីបនា**

*ការបំភ្លឺអំពីការដល់សរណៈ មានតែប៉ុណ្ណោះ ។*

---

១-វិន័យបិដក មហាវគ្គ បឋមភាគ លេខ ៦ ទំព័រ ៧១ ។

## ធម្មសង្ឃសរណាភិភាវនា
## ការសម្តែងឡើងអំពីព្រះធម៌ និងព្រះសង្ឃសរណៈ

ឥឡូវនេះ នឹងអធិប្បាយតទៅ ក្នុងពាក្យដែលខ្ញុំពោល ទុកថា សូម្បីក្នុងសរណៈទាំងពីរថា "ធម្មំ សរណំ" ជាដើម ក៏ដឹងហើយថា មានន័យយ៉ាងនេះដូចគ្នា ន័យនៃការពណ៌នាសេចក្តីនេះឯណា ខ្ញុំពោលទុកក្នុងពាក្យនេះថា "ពុទ្ធំ សរណំ គច្ឆាមិ" ក៏គប្បីជ្រាបន័យនៃការពណ៌នាសេចក្តីទាំង ២ បទនេះ ថា ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ ។ មែនពិត សូម្បីក្នុងសេចក្តីនោះ ក៏មានត្រឹមតែការបង្អុលបង្ហាញប៉ុណ្ណោះ ថាដោយអត្ថ និងព្យញ្ជនៈនៃព្រះធម៌ និងព្រះសង្ឃ ដែលមិនដូចគ្នា បទដ៏សេស ប្រាកដស្មើដោយពាក្យដែលបានពោលមកហើយ ។ ព្រោះនឹងពោលអធិប្បាយ ចំពោះទីមិនដូចគ្នា ក្នុងព្រះធម៌ និងព្រះសង្ឃនេះដូច្នេះ អាចារ្យមួយពួក ពោលថា មគ្គ ផល និងនិព្វាន ឈ្មោះថា **ព្រះធម៌** ។ ខន្តិ សេចក្តីពេញចិត្ត ឬមតិរបស់ពួកយើងថាមគ្គ និងវិពាគៈប៉ុណ្ណោះ ឈ្មោះថា ព្រះធម៌ក្នុងអត្ថនេះ ព្រោះទ្រទ្រង់អ្នកចម្រើនមគ្គផល និងអ្នកធ្វើឱ្យច្បាស់ព្រះនិព្វានហើយ ដោយមិនឱ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ និងធ្វើឱ្យរីករាយចិត្តយ៉ាងក្រៃលែង សេចក្តីលើកអគ្គប្បសាទសូត្រនោះឯង ជាគ្រឿងសម្អាង ។ សមដូចដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងអគ្គប្បសាទសូត្រ នោះ

ជាដើម យ៉ាងនេះថា "យាវតា ភិក្ខវេ សង្ខតា ធម្មា អរិយោ អដ្ឋង្គិកោ មគ្គោ តេសំ អគ្គមក្ខាយតិ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មានដែលជាសង្ខតធម៌ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ប្រាកដជាប្រសើរជាងធម៌ទាំងនោះ"[១] ។

បុគ្គលទាំងឡាយ អ្នកព្រមព្រៀងដោយអរិយមគ្គ ៤ យ៉ាង និងអ្នកមានខន្ធសន្តានអប់រំដោយសាមញ្ញផល ៤ និងសមាធិ ឈ្មោះថា **ព្រះសង្ឃ** ព្រោះរួមគ្នាដោយការរួមទិដ្ឋិ និងសីល ។ សមដូចដែលព្រះមានព្រះភាគត្រាស់ទុកដូចនេះថា "ម្នាលអានន្ទ អ្នកយល់សេចក្ដីនោះដូចម្ដេច ធម៌ទាំងឡាយដែលតថាគតត្រាស់ដឹងហើយ សំដែងហើយដល់អ្នកទាំងឡាយ ដូចជាសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ម្នាលអានន្ទ អ្នកឃើញភិក្ខុ ២ រូប ដែលមានវាទៈផ្សេងគ្នាក្នុងធម៌ទាំងឡាយនេះដែរឬ"[២] ។

មែនពិត ព្រះសង្ឃដោយបរមត្ថនេះ ដែលបុគ្គលគប្បីដល់ថាជា **សរណៈ** ។ ក្នុងព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ទុកថា "នេះជាសង្ឃសាវករបស់ព្រះដ៏មានព្រះភាគ គួរទទួលរបស់ដែលគេនាំមកបូជា

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ ទុតិយភាគ លេខ ៥៣ ទំព័រ ១១៧ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក សត្តមភាគ លេខ ២៦ ទំព័រ ៩៧ ។

គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាស្រែបុណ្យដ៏ប្រសើរនៃសត្វលោកប្រាកដជាប្រសើរជាងសង្ឃ ឬគណៈទាំងនោះ"(១) ។ សរណាគមន៍របស់អ្នកដល់សរណៈនោះរមែងមិនដាច់ មិនសៅហ្មង ដោយការធ្វើការសំពះជាដើម ក្នុងព្រះភិក្ខុ-សង្ឃ ឬភិក្ខុនីសង្ឃ សូម្បីពួកដទៃ ឬព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ឬសម្មតិសង្ឃ ផ្សេងដោយសង្ឃចតុវគ្គជាដើម ឬសូម្បីចំពោះបុគ្គលមួយពួក ដែលបួសឧទ្ទិសចំពោះព្រះភគវន្ត ភាពផ្សេងគ្នា ក្នុងសង្ឃសរណៈដែលមានប៉ុណ្ណេះ ។ ចំណែកការដាច់ និងមិនដាច់ជាដើមនៃសរណាគមន៍ទាំងពីរនេះ គឺខុសពីសេចក្តីដែលពោលហើយ គប្បីជ្រាបតាមន័យដែលពោលមកក្នុងកាលមុននោះចុះ ។ ការពណ៌នា សេចក្តីនេះថា សូម្បីក្នុងសរណៈពីរថា ធម្មំ សរណំ ជាដើម ក៏ដឹងហើយថា ន័យនេះ ដូចគ្នាមានប៉ុណ្ណេះឯង ។

## អនុបុព្វវវត្ថានការណាធិប្បាយោ

## **អធិប្បាយហេតុក្នុងការកំណត់តាមលំដាប់**

ក្នុងពាក្យនេះថា នឹងអធិប្បាយហេតុក្នុងការកំណត់តាមលំដាប់ឥឡូវនេះ នឹងអធិប្បាយហេតុក្នុងការកំណត់តាមលំដាប់យ៉ាងនេះថា ក្នុងពាក្យដល់សរណៈទាំង ៣ នោះ លោកប្រកាសព្រះពុទ្ធជាលំដាប់ដំបូង

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត តតិយភាគ លេខ ៤២ ទំព័រ ៨៥ ។

*ព្រោះជាអ្នកប្រសើរជាងសត្វទាំងពួង ប្រកាសព្រះធម៌ជាលំដាប់តមក ព្រោះជាដែនកើតរបស់ព្រះពុទ្ធនោះ និងព្រោះជាធម៌ដែលព្រះពុទ្ធជាម្ចាស់នោះ ទ្រង់នាំចេញបង្ហាត់បង្រៀនហើយ ប្រកាសព្រះសង្ឃជាលំដាប់ចុងក្រោយ ព្រោះជាអ្នកទ្រទ្រង់ទុកនូវព្រះធម៌នោះ និងព្រោះស្រឡាញ់ព្រះធម៌នោះ ។ ន័យម្យ៉ាងទៀត លោកប្រកាសព្រះពុទ្ធជាលំដាប់ដំបូង ព្រោះទ្រង់ប្រកបសត្វទាំងពួងទុកក្នុងហិតប្រយោជន៍ ប្រកាសព្រះធម៌ដែលជាលំដាប់តមក ព្រោះជាដែនកើតនៃព្រះពុទ្ធជាម្ចាស់នោះ និងព្រោះជាធម៌នាំមកនូវប្រយោជន៍ដល់សត្វទាំងពួង ប្រកាសព្រះសង្ឃដែលជាលំដាប់ចុងក្រោយ ព្រោះព្រះសង្ឃជាអ្នកបដិបត្តិ ដើម្បីបន្ទុះហិតប្រយោជន៍ និងមានហិត-ប្រយោជន៍ ដែលបន្ទុះហើយ កំណត់ដោយសេចក្តីថាសរណៈ ។*

## ឧបមាបកាសនា

## **ការប្រកាសដោយសេចក្តីឧបមា**

*ឥឡូវនេះ នឹងពោលអធិប្បាយពាក្យដែលនឹងប្រកាសព្រះសរណត្រៃនោះ ដោយសេចក្តីឧបមាទាំងឡាយ ក៏ក្នុងពាក្យនោះ ព្រះពុទ្ធ ប្រៀបដូចព្រះចន្ទពេញបូណ៌មី ព្រះធម៌ ប្រៀបដូចពន្លឺរស្មីរបស់ព្រះចន្ទ ព្រះសង្ឃ ប្រៀបដូចលោកដែលជ្រាបចូលពេញដោយរស្មីរបស់ព្រះចន្ទពេញបូណ៌មី ដែលធ្វើឱ្យកើតឡើង ។ ព្រះពុទ្ធ ប្រៀបដូចដួងព្រះអាទិត្យចែងចាំងពន្លឺស្រទន់ៗ*

ព្រះធម៌ ប្រៀបដូចរស្មីរបស់ព្រះអាទិត្យនោះ ព្រះសង្ឃ ប្រៀបដូចលោកដែលដួងព្រះអាទិត្យនោះកម្ចាត់បង់នូវងងឹតហើយ ។ ព្រះពុទ្ធ ប្រៀបដូចមនុស្សដុតព្រៃ ព្រះធម៌ ជាគ្រឿងដុតព្រៃគឺកិលេស ប្រៀបដូចភ្លើងដុតព្រៃ ព្រះសង្ឃ ជាបុញ្ញខេត្ត ព្រោះដុតកិលេសបានហើយ ប្រៀបដូចភូមិភាគដែលជាវាលស្រែ ព្រោះដុតព្រៃអស់ហើយ ។ ព្រះពុទ្ធ ប្រៀបដូចមេឃភ្លៀងធំ ព្រះធម៌ ប្រៀបដូចទឹកភ្លៀង ព្រះសង្ឃ មានលំអងគឺកិលេសរម្ងាប់ហើយ ប្រៀបដូចជនបទមានលំអងទៅប្រាសហើយ ព្រោះការបង្អុលចុះនៃភ្លៀង ។ ព្រះពុទ្ធ ប្រៀបដូចសារថីដ៏ល្អ ព្រះធម៌ប្រៀបដូចឧបាយហ្វឹកហាត់សេះអាជានេយ្យ ព្រះសង្ឃប្រៀបដូចហ្វូងសេះអាជានេយ្យដែលហ្វឹកហាត់ល្អហើយ ។ ព្រះពុទ្ធ ប្រៀបដូចសល្យពេទ្យ (ពេទ្យវះកាត់) ព្រោះទ្រង់ដកសរ គឺទិដ្ឋិបានអស់ ព្រះធម៌ ប្រៀបដូចឧបាយដែលដកសរចេញបាន ព្រះសង្ឃ អ្នកដកសរ គឺទិដ្ឋិចេញហើយ ប្រៀបដូចជនដែលត្រូវដកសរចេញហើយ ។ ន័យម្យ៉ាងទៀត ព្រះពុទ្ធប្រៀបដូចចក្ខុពេទ្យ ព្រោះទ្រង់បកសំបកភ្នែក គឺមោហៈចេញបានហើយ ព្រះធម៌ ប្រៀបដូចឧបាយគ្រឿងបកសំបកភ្នែក ព្រះសង្ឃអ្នកមានសំបកភ្នែក គឺមោហៈបកហើយ ជាអ្នកមានកែវភ្នែក គឺញាណដ៏ស្រស់ថ្លាប្រៀបដូចជន ដែលបកភ្នែកហើយមានកែវភ្នែក ស្រស់ថ្លា ។ ន័យម្យ៉ាងទៀត ព្រះពុទ្ធ ប្រៀបដូចពេទ្យដ៏ឆ្លាត

*ព្រោះព្រះអង្គអាចកម្ចាត់ព្យាធិ គឺកិលេស ព្រមទាំងអនុស្ស័យបានហើយ ព្រះធម៌ ប្រៀបដូចថ្នាំ ដែលទ្រង់រៀបចំត្រឹមត្រូវហើយ ព្រះសង្ឃ អ្នកមានព្យាធិ គឺកិលេស និងអនុស្ស័យរម្ងាប់ហើយ ប្រៀបដូចពួកជនដែលព្យាធិរម្ងាប់ហើយ ព្រោះប្រកបថ្នាំ ។*

*ន័យម្យ៉ាងទៀត ព្រះពុទ្ធជាម្ចាស់ ប្រៀបដូចមគ្គុទ្ទេសក៍ ព្រះធម៌ ប្រៀបដូចផ្លូវល្អ ឬកន្លែងដែលរួចផុតពីភ័យ ព្រះសង្ឃ ប្រៀបដូចអ្នកដើរផ្លូវដល់កន្លែងដែលរួចផុតពីភ័យ ។ ព្រះពុទ្ធ ប្រៀបដូចជានាវិកដ៏ឆ្នើម ព្រះធម៌ប្រៀបដូចនាវា ព្រះសង្ឃ ប្រៀបដូចជនអ្នកដើរផ្លូវដល់ច្រាំង ។ ព្រះពុទ្ធ ប្រៀបដូចព្រៃហិមពាន្ត ព្រះធម៌ ប្រៀបដូចឱសថ ដែលកើតពីព្រៃហិមពាន្តនោះ ព្រះសង្ឃ ប្រៀបដូចជនអ្នកមិនមានរោគ ព្រោះប្រើឱសថ ។ ព្រះពុទ្ធ ប្រៀបដូចអ្នកប្រទានទ្រព្យ ព្រះធម៌ ប្រៀបដូចទ្រព្យ ព្រះសង្ឃ អ្នកបានអរិយទ្រព្យមកដោយប្រពៃ ប្រៀបដូចជនអ្នកបានទ្រព្យ ដែលខ្ជួនបំណង ។ ព្រះពុទ្ធ ប្រៀបដូចអ្នកបង្ហាញរណ្តៅទ្រព្យ ព្រះធម៌ ប្រៀបដូចរណ្តៅទ្រព្យ ព្រះសង្ឃ ប្រៀបដូចជនអ្នកបានរណ្តៅទ្រព្យ ។*

*ន័យម្យ៉ាងទៀត ព្រះពុទ្ធ ជាវីរបុរស ប្រៀបដូចអ្នកប្រទានការមិនមានភ័យ ព្រះធម៌ ប្រៀបដូចការមិនមានភ័យ ព្រះសង្ឃ អ្នកកន្លងភ័យគ្រប់យ៉ាង ប្រៀបដូចជនអ្នកដល់នូវសេចក្តីមិនមានភ័យ ។ ព្រះពុទ្ធ ប្រៀបដូចអ្នក*

លួងលោម ព្រះធម៌ ប្រៀបដូចការលួងលោម ព្រះសង្ឃ ប្រៀបដូចជនអ្នកត្រូវលួងលោម ។ ព្រះពុទ្ធ ប្រៀបដូចកល្យាណមិត្ត ព្រះធម៌ ប្រៀបដូចពាក្យបង្រៀនដែលជាហិតប្រយោជន៍ ព្រះសង្ឃ ប្រៀបដូចជនអ្នកប្រទះប្រយោជន៍ ព្រោះប្រកបហិតប្រយោជន៍ ។ ព្រះពុទ្ធ ប្រៀបដូចអណ្តូងកើតទ្រព្យ ព្រះធម៌ ប្រៀបដូចទ្រព្យដែលជាសារៈ ព្រះសង្ឃ ប្រៀបដូចជនអ្នកប្រើទ្រព្យដែលជាសារៈ ។ ព្រះពុទ្ធ ប្រៀបដូចអ្នកស្រង់ទឹកឱ្យព្រះរាជកុមារ ព្រះធម៌ ប្រៀបដូចទឹកដែលស្រង់រហូតព្រះសិរសា ព្រះសង្ឃ អ្នកស្រង់ល្អ ហើយដោយទឹក គឺព្រះសទ្ធម្ម ប្រៀបដូចពួកព្រះរាជកុមារ ដែលស្រង់ទឹកល្អហើយ ។ ព្រះពុទ្ធ ប្រៀបដូចជាងធ្វើគ្រឿងអលង្ការ ព្រះធម៌ ប្រៀបដូចគ្រឿងអលង្ការ ព្រះសង្ឃ អ្នកប្រដាប់ដោយព្រះសទ្ធម្ម ប្រៀបដូចពួកព្រះរាជឱរសដែលទ្រង់ប្រដាប់ហើយ ។ ព្រះពុទ្ធ ប្រៀបដូចដើមចន្ទន៍ ព្រះធម៌ ប្រៀបដូចក្លិនដែលកើតពីដើមចន្ទន៍នោះ ព្រះសង្ឃអ្នករម្ងាប់សេចក្តីក្តៅក្រហាយបានអស់ហើយដោយព្រះសទ្ធម្ម ប្រៀបដូចជនអ្នករម្ងាប់ភាពក្តៅ ព្រោះប្រើលម្អិតខ្លឹមចន្ទន៍នោះ ។ ព្រះពុទ្ធ ប្រៀបដូចបិតាបង្អោនមត៌កគឺធម៌ ព្រះធម៌ ប្រៀបដូចមត៌ក ព្រះសង្ឃ អ្នកទទួលមត៌ក គឺព្រះសទ្ធម្ម ប្រៀបដូចពួកបុត្រអ្នកទទួលមត៌ក ។ ព្រះពុទ្ធ ប្រៀបដូចផ្កាបទុមដែលរីក ព្រះធម៌ ប្រៀបដូចទឹកដមកើតអំពីផ្កាបទុមដែលរីកនោះ ព្រះសង្ឃ ប្រៀបដូចហ្វូងភមរជាតិ ដែលក្រេបផឹកលម្អងផ្កានោះ ។

*គប្បីប្រកាសព្រះត្រ័យសរណៈនោះ ដោយសេចក្ដីឧបមាទាំងឡាយ ដូចពោលមកដូច្នេះចុះ ។*

*មាតិកាខាងដើមរបស់កថាពណ៌នាសេចក្ដី ដែលលើកឡើងក្នុងខាងដើមដោយ ៤ គាថាថា ព្រះសរណៈត្រៃ នរណាពោល ពោលទីណា ពោលកាលណា ពោលព្រោះអ្វីជាដើម ក៏ជាការប្រកាសហើយ ដោយអត្ថ ដោយកថា មានប្រមាណត្រឹមប៉ុណ្ណោះឯង ។*

បរមត្ថជោតិកាយ ខុទ្ទកបាឋដ្ឋកថាយ

សរណត្តយវណ្ណនា និដ្ឋិតា ។

**កថាពណ៌នាព្រះត្រៃសរណៈ ក្នុងអដ្ឋកថាខុទ្ទកបាឋៈ**

**ឈ្មោះបរមត្ថជោតិកា ចប់តែប៉ុណ្ណោះ ៕**

## ២-សិក្ខាបទវណ្ណនា

**ពណ៌នាអំពីសិក្ខាបទ**

## សិក្ខាបទបាឋមាតិកា

**មាតិកាបាឋៈក្នុងសិក្ខាបទ**

គ្រាសម្តែងការចូលទៅកាន់ព្រះសាសនាដោយការដល់សរណ-គមន៍យ៉ាងនេះហើយ ដើម្បីនឹងពណ៌នាបាឋៈ ដែលថា ដោយសិក្ខាបទដែលតាំងជានិក្ខេបបទទុក ដើម្បីសម្តែងសិក្ខាបទទាំងឡាយ ដែលឧបាសក ឬ បព្វជិតអ្នកចូលមកកាន់សាសនានឹងគប្បីសិក្សាជាលំដាប់ដំបូង ឥឡូវនេះខ្ញុំនឹងពោលមាតិកាដើមដូចតទៅនេះ៖

សិក្ខាបទទាំងនេះ អ្នកណាពោល ពោលនៅកន្លែងណា ពោលនៅពេលណា ពោលព្រោះហេតុណា ហើយកំណត់ពោលធ្វើន័យនោះដោយសេចក្តីប្លែកនៃសិក្ខាបទទូទៅ ។ ហើយកំណត់ទោស ជាបកតិវជ្ជៈ និងបណ្ណត្តិវជ្ជៈ ធ្វើការចង្អុល បង្ហាញន័យទូទៅគ្រប់សិក្ខាបទ ដោយព្យញ្ជនៈ និងដោយអត្ថរបស់បទទាំងឡាយ ។ តែក្នុង ៥ សិក្ខាបទខាងដើម គប្បីជ្រាបវិនិច្ឆ័យ ដោយប្រកាសសេចក្តីប្លែកគ្នារបស់សិក្ខាបទទូទៅ ដោយការកើតតែម្យ៉ាង និងសេចក្តីផ្សេងគ្នាជាដើម ។ តាំងពីបាណាតិបាតជាដើមទៅ ដោយអារម្មណ៍ការសមាទាន និងការដាច់ ដោយសេចក្តីមានទោសច្រើន ដោយប្រយោគ អង្គ និងសមុដ្ឋាន ដោយវេទនា មូល និងកម្ម ដោយការវៀរចាក និងដោយផល ។ យុត្តិ គឺសេចក្តីត្រឹមត្រូវអំពីការពណ៌នា ៥ សិក្ខាបទខាងដើម គប្បីនាំមកប្រើក្នុង ៥ សិក្ខាបទក្រោយ គប្បីពោល

សិក្ខាបទជាសេចក្តីៗ គប្បីជ្រាបថា សិក្ខាបទ មានសេចក្តីយ៉ាងល្អិតជាដើមទុកផង ។

ក្នុងមាតិកាដំបូងនោះ សិក្ខាបទ ១០ មាន ចាណាតិចាតា វេរមណី ជាដើមនោះ ព្រះដ៏មានព្រះភាគព្រះអង្គត្រាស់ទុក ពុំមែនសាវកសម្តែងទេ ។ មែនពិត ព្រះដ៏មានព្រះភាគ ព្រះអង្គស្តេចយាងពីក្រុងកបិលភស្តុ ដល់ក្រុងសាវត្ថី ទ្រង់ឱ្យរាហុលបព្វជ្ជាហើយ ក្នុងជេតវនារាមរបស់អនាថបិណ្ឌិកៈ ទៀបក្រុងសាវត្ថី ព្រះអង្គត្រាស់សម្តែងសិក្ខាបទ ១០ នោះ ដើម្បីកំណត់សិក្ខាបទដល់សាមណេរទាំងឡាយ ។សមដូចពាក្យដែលព្រះធម្មសង្គាហកាចារ្យទាំង-ឡាយ ពោលពាក្យនេះទុកថា "លំដាប់ពីនោះមក ព្រះមានជោគ ទ្រង់គង់ក្នុងក្រុងកបិលវត្ថុ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់យាងសំដៅទៅកាន់ចារិកឯទីក្រុងសាវត្ថី ទ្រង់ត្រាច់ទៅកាន់ចារិកដោយលំដាប់ៗហើយ ទ្រង់បានទៅដល់ក្រុងសាវត្ថីនោះ ។ តាមដំណាលក្នុងនិទាននោះថា ព្រះដ៏មានបុណ្យ ទ្រង់គង់ក្នុងជេតវនារាម របស់អនាថ-បិណ្ឌិកក្បែរក្រុងសាវត្ថី ។ ក្នុងសម័យនោះឯង ។ល។ លំដាប់ពីនោះមក សាមណេរទាំងឡាយ បានត្រិះរិះសេចក្តីនេះនឹងគ្នាថា សិក្ខាបទរបស់យើងទាំងឡាយមានប៉ុន្មានហ្ន៎ ម្យ៉ាងទៀត យើងទាំងឡាយគួរសិក្សា

ក្នុងវិន័យដូចម្ដេចខ្លះ ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្ដីនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសិក្ខាបទ ១០ ដល់សាមណេរទាំងឡាយ ម្យ៉ាងទៀត អនុញ្ញាតឱ្យសាមណេរទាំងឡាយ សិក្សាក្នុងសិក្ខាបទទាំងឡាយ ១០ នោះ គឺ ចេតនាជាហេតុវៀរចាកកិរិយា ធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះ គន្លង១។ល។ ចេតនាជាហេតុវៀរចាកកិរិយាទទួលកាន់យកនូវមាសនិងប្រាក់ ១”[១] ។

សិក្ខាបទទាំង ១០ នេះនោះ គប្បីជ្រាបថា លោកលើកឡើងដើម្បីបង្ហាត់បង្រៀន ដោយព្រះសូត្រថា “សមាទាយ សិក្ខតិ សិក្ខាបទេសុ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ”[២] និងដោយបាឋៈដែលលោកសម្ដែងទុកក្នុងសរណគមន៍យ៉ាងនេះថា “បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំសូមសមាទានសិក្ខាបទ គឺចេតនាវៀរចាកបាណាតិបាត”ជាដើម គប្បីជ្រាបន័យថា “សិក្ខាបទពួកនេះ អ្នកណាពោល ពោលនៅកន្លែងណា ពោលនៅពេលណា ពោលព្រោះហេតុអ្វី និងពោលន័យនោះ” ប៉ុណ្ណេះមុន ។

---

១ -វិន័យបិដក មហាវគ្គ បឋមភាគ លេខ ៦ ទំព័រ ២៧៥-២៧៧ ។

២-សុត្តន្តបិដក ទីឃនិកាយ បឋមភាគ សីលក្ខន្ធវគ្គ លេខ ១៤ ទំព័រ ១៥៦ ។

## សាធារណាវិសេសវវត្ថានំ

## ការកំណត់សេចក្តីប្លែកគ្នារបស់សិក្ខាបទទូទៅ

ក៏បណ្តាសិក្ខាបទទាំងនោះ សិក្ខាបទទី ៤-៥ ពីរសិក្ខាបទខាងដើមទូទៅដល់ឧបាសក និងសាមណេរ ជានិច្ចសីល ។ តែជាឧបោសថសីលរបស់ឧបាសក វៀរសិក្ខាបទក្រោយទាំងអស់ ព្រោះរួមសិក្ខាបទទី ៧ និងទី ៨ ចូលគ្នាជាអង្គតែមួយ សិក្ខាបទទាំងអស់ក៏ទូទៅជាមួយសាមណេរទាំងឡាយ ចំណែកសិក្ខាបទក្រោយ ជាពិសេសសម្រាប់តែសាមណេរប៉ុណ្ណោះ ។ គប្បីជ្រាបការកំណត់ដោយសេចក្តីប្លែកគ្នារបស់សិក្ខាបទទូទៅ ដូចពោលមកដូច្នេះ គប្បីកំណត់បកតិវជ្ជៈ និងបណ្ណត្តិវជ្ជៈយ៉ាងនេះ គឺបណ្តាសិក្ខាបទទាំងឡាយនោះ សិក្ខាបទ ៥ ខាងដើម កំណត់ដោយចេតនាវៀរចាកបកតិវជ្ជៈរបស់បាណាតិបាតជាដើម ព្រោះមានអកុសលចិត្តជាសមុដ្ឋានតែម្យ៉ាង សិក្ខាបទក្រៅពីនោះ កំណត់ដោយចេតនាវៀរចាកបណ្ណត្តិវជ្ជៈ ។

## សាធារណាវិភាវនា

## ការចង្អុលបង្ហាញបទទូទៅ

ក៏បណ្តាបទទាំងនោះ បទថា “វេរមណី សិក្ខាបទំ សមាទិយាមិ” ជាបទទូទៅទាំងអស់ដូច្នោះ គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនោះ

ទូទៅ ទាំងព្យញ្ជនៈ ទាំងអត្ថដូចតទៅនេះ

ក្នុងបទទាំងនោះគប្បីជ្រាប **ដោយព្យញ្ជនៈ**មុន ឈ្មោះថា **វេរមណី** ព្រោះវៀរ អធិប្បាយថា លះពៀរ គឺធ្វើឱ្យអស់ ឱ្យដល់ការមិនមាន ។ ន័យម្យ៉ាងទៀត បុគ្គលរមែងវៀរចាកពៀរ ដោយចេតនាខ្លួន ធ្វើនោះ ហេតុនោះ ចេតនានោះ ទើបឈ្មោះថា **វេរមណី** ព្រោះផ្លាស់ **វិ**-អក្សរជា **វេ**-អក្សរ ។ ព្រោះហេតុនោះទុ៎ះឯង ក្នុងពាក្យនេះ ពុទ្ធបរិស័ទ ទើបសូត្រជាមួយគ្នាជា ២ យ៉ាងថា វេរមណី សិក្ខាបទំ ឬ វិរមណី សិក្ខាបទំ ។ ឈ្មោះថា **សិក្ខា** ព្រោះបុគ្គលគប្បីសិក្សា ។ ឈ្មោះថា **បទ** ព្រោះជាគ្រឿងដល់បទនៃសិក្ខា ។ បទនៃសិក្ខា ឈ្មោះថា **សិក្ខាបទ** អធិប្បាយថា ឧបាយជាគ្រឿងដល់សិក្ខា ។ ន័យម្យ៉ាងទៀត លោកអធិប្បាយថា ជាមូល ជាទីអាស្រ័យ ជាទីតាំង ។ សិក្ខាបទ គឺ ចេតនាជាគ្រឿងវៀរចាក ឈ្មោះថា វេរមណី សិក្ខាបទំ ឬ វិរមណី សិក្ខាបទំ តាមន័យទីពីរ ។ ខ្ញុំសូមសមាទានដោយល្អ ឈ្មោះថា សមាទិយាមិ លោកអធិប្បាយថា ខ្ញុំសូមសមាទាន ដោយបំណងនឹង មិនកន្លងល្មើស ព្រោះជាអ្នកធ្វើសិក្ខាបទ មិនឱ្យដាច់ មិនឱ្យពពាល ។

តែ**ដោយអត្ថ** បទថា វេរមណី បានដល់ **វិរតិ** គឺចេតនាវៀរ ដែលប្រកបដោយចិត្តជាកាមាវចរកុសល ។ វិរតិនោះ របស់បុគ្គល អ្នកវៀរចាកបាណាតិបាត លោកពោលទុកក្នុងវិភង្គ ដោយន័យជាដើម យ៉ាងនេះថា "ក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្តេញនូវពៀរចាកពីបាណាតិបាត គឺការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលាការសម្លាប់ហេតុណា..."(១) ។ ឈ្មោះថា **វេរមណី** នោះ សូម្បីជាលោកុត្តរៈក៏មានពិតមែនហើយ ក៏ ប៉ុន្តែថា ក្នុងទីនេះ ការគួរនឹងពោលថា **វេរមណី** ដែលប្រព្រឹត្តដោយ ការសមាទាន ព្រោះហេតុនោះ អ្នកសមាទានពោលថា **សមាទិយាមិ** ព្រោះដូច្នោះ **វេរមណី** ជាលោកុត្តរៈនោះទើបមិនមាន ខ្ញុំពោលថា វិរតិ ចេតនា លះបង់ វៀរប្រកបដោយចិត្តជាកាមាវចរកុសល ។

បទថា **សិក្ខា** បានដល់ សិក្ខា ៣ គឺ អធិសីលសិក្ខា អធិចិត្ត-សិក្ខា អធិបញ្ញាសិក្ខា ។ តែក្នុងទីនេះ សីល គឺសម្បត្តវិរតិ លោកិយ-វិបស្សនា រូបឈាន និងអរូបឈាន និងអរិយមគ្គ គឺលោកបំណងថា **សិក្ខា** ក្នុងបទថាសិក្ខានេះ ។ សមដូចពាក្យដែលព្រះដ៏មានបុណ្យបាន ត្រាស់ទុកថា "ធម៌ទាំងឡាយដូចម្តេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា ចិត្ត

១-អភិធម្មបិដក វិភង្គ តតិយភាគ សិក្ខាបទវិភង្គ លេខ ៨២ ទំព័រ ១៕

ជាកាមាវចរកុសល ប្រកបដោយសោមនស្សសម្បយុត្ត ដោយញាណ ។បេ។ ក្នុងសម័យនោះ ការប៉ះពាល់ក៏កើតមាន ។បេ។ ការមិនរាយមាយ ក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា **សិក្ខា** ។ ធម៌ទាំងឡាយដូចម្ដេច ឈ្មោះថា **សិក្ខា** ។ ក្នុងសម័យណា បុគ្គលចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាម ទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលដល់បឋមជ្ឈាន ។បេ។ ចូលដល់បញ្ចមជ្ឈាន ។បេ។ ការមិនរាយមាយ ក៏កើតមាន ធម៌ទាំងឡាយ នេះ ឈ្មោះថា **សិក្ខា** ។ ធម៌ទាំងឡាយដូចម្ដេច ឈ្មោះថា **សិក្ខា** ។ ក្នុង សម័យណា បុគ្គលចម្រើនមគ្គ ដើម្បីចូលដល់អរូបឈាន ។បេ។ ដើម្បីចូល ដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។បេ។ ការមិនរាយមាយ ក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា **សិក្ខា** ។ ធម៌ទាំងឡាយដូចម្ដេច ឈ្មោះថា **សិក្ខា** ។ សម័យណា បុគ្គលចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ។បេ។ ការមិន រាយមាយ ក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា **សិក្ខា**”[១] ។

**បទ** គឺឧបាយជាគ្រឿងដល់ ម្យ៉ាងទៀតជាមូល ជាទីអាស្រ័យជា ទីតាំងនៃសិក្ខាបទយ៉ាងណាមួយ បណ្ដាសិក្ខាទាំងនោះ ហេតុនោះ ទើប ឈ្មោះថា **សិក្ខាបទ** ។ សមពិតដូចដែលព្រះមានព្រះភាគត្រាស់ ទុកថា

---

១-អភិធម្មបិដក វិភង្គ តតិយភាគ សិក្ខាបទវិភង្គ លេខ ៨២ ទំព័រ ១៥-១៦ ។

"ភិក្ខុអាស្រ័យសីល តាំងនៅស៊ប់ក្នុងសីល កាលចម្រើននូវពោជ្ឈង្គទាំង ៧ កាលធ្វើឱ្យក្រាស់ក្រែល(នូវពោជ្ឈង្គទាំង ៧)"(១) យ៉ាង នេះជាដើម ។ គប្បីធ្វើការចង្អុលដោយព្យញ្ជនៈ ដោយអត្ថទូទៅដល់បទទាំងឡាយ ទូទៅក្នុងបទទាំងនេះ ដោយប្រការដូច្នេះ ។

## បុរិមបញ្ចសិក្ខាបទវណ្ណនា

## ពណ៌នាសិក្ខាបទ ៥ ខាងដើម

ពាក្យណា ខ្ញុំពោលទុកថា តែក្នុង ៥ សិក្ខាបទខាងដើម នឹងត្រូវចង្អុលបង្ហាញដោយប្រកាសសេចក្តីដែលប្លែកគ្នា ។ល។ គប្បីជ្រាបវិនិច្ឆ័យ ។ល។ ក្នុងពាក្យនោះ ឥឡូវនេះខ្ញុំនឹងពោលបង្ហាញដូច្នេះ មុនដទៃក្នុងបទថា បាណាតិបាតា នេះ បទថា បាណោ(២) បានដល់សេចក្តីបន្តនៃខន្ធ ដែលជាប់ដោយជីវិតិន្ទ្រិយ ។ ន័យម្យ៉ាងទៀត បានដល់សត្វ ដែលបណ្ឌិតអាស្រ័យសេចក្តីបន្តនៃខន្ធនោះបញ្ញត្តទុក ។ ក៏ **វធកចេតនា** ចេតនាគិតនឹងសម្លាប់របស់បុគ្គល អ្នកមានសេចក្តីសម្គាល់ក្នុងសត្វ

---

១-សុត្តន្តបិដក សំយុត្តនិកាយ មហាវគ្គ នវមភាគ លេខ ៣៧ ទំព័រ ១៦៩ ។

២-បាណោតិ វោហារតោ សត្តោ បរមត្ថតោ ជីវិតិន្ទ្រិយំ បទថា បាណោ បានដល់ សត្វដោយវោហារ ជាជីវិតិន្ទ្រិយ ដោយបរមត្ថ (កង្ខាវិតរណី អដ្ឋកថាបាតិមោក្ខ ភាគ ១ ទំព័រ ៨២) ។

មានជីវិតនោះ ថាជាសត្វមានជីវិត ជាសមុដ្ឋាននៃសេចក្តីព្យាយាម ដែលនឹងកាត់ជីវិតិន្ទ្រិយ របស់សត្វមានជីវិតនោះ ប្រព្រឹត្តិទៅតាមកាយទ្វារ និងវចីទ្វារ ទ្វារណាទីមួយ ឈ្មោះថា បាណាតិបាត ។ ក្នុងបទថា អទិន្នាទានំ នេះ បទថា អទិន្នំ បានដល់ទ្រព្យសម្បត្តិ ដែលមានម្ចាស់ហួងហែង ។ ម្ចាស់ទ្រព្យ កាលធ្វើតាមដែលត្រូវការក៏មិនត្រូវទោស មិនត្រូវតិះដៀល ។ ថេយ្យចេតនា ចេតនាគិតនឹងលួច របស់បុគ្គលអ្នកមានសេចក្តីសម្គាល់ក្នុងទ្រព្យដែលមានម្ចាស់ហួងហែង ថាជាទ្រព្យដែលមានម្ចាស់ហួងហែង ជាសមុដ្ឋាននៃសេចក្តីព្យាយាម ការលួចទ្រព្យនោះ ប្រព្រឹត្តទៅតាមកាយទ្វារ និងវចីទ្វារ ទ្វារណាមួយនោះឯង ឈ្មោះថា **អទិន្នាទាន** ។ បទថា អព្រហ្មចរិយំ បានដល់ ការប្រព្រឹត្តមិនប្រសើរ ។ ចេតនាជាហេតុល្មើស គឺការបំណងសេពអសទ្ធម្ម ប្រព្រឹត្តទៅតាមកាយទ្វារ ដោយការបំណងសេពមេថុន គឺការរួមសង្វាស ឈ្មោះថា អព្រហ្មចរិយំ ។ ក្នុងពាក្យថា មុសាវាទោ នេះ បទថា មុសា បានដល់ វចីបយោគ ឬកាយបយោគ ដែលកាត់បង់ប្រយោជន៍របស់បុគ្គល អ្នកមានបំណងនឹងឱ្យឃ្លាតពីការពិត ជាមិច្ឆាចេតនា ចេតនាដែលនឹងនិយាយខុស ធ្វើខុសរបស់បុគ្គលនោះ ដោយបំណងនឹងឱ្យអ្នកដទៃយល់ខុសជាសមុដ្ឋាននៃកាយប្រយោគ ដែលនឹងធ្វើ

អ្នកដទៃឱ្យយល់ខុស ប្រព្រឹត្តទៅតាមកាយទ្វារ និងវចីទ្វារ ទ្វារណាមួយ ឈ្មោះថា **មុសាវាទ** ។ ក៏ក្នុងបទថា សុរាមេរយមជ្ជប្បមាទដ្ឋានំ នេះ បទថា **សុរា** បានដល់ សុរា ៥ យ៉ាងគឺ

១-បិដ្ឋសុរា = សុរាធ្វើដោយម្សៅ

២-បូវសុរា = សុរាធ្វើដោយនំ

៣-ឱទនសុរា = សុរាធ្វើដោយបាយ

៤-កិណ្ណបក្ខិត្តា = សុរាដែលគេដាក់ពូជសុរា

៥-សម្ភារសំយុត្តា=សុរាដែលគេផ្សំដោយគ្រឿងផ្សំផ្សេងៗ មានគ្រាប់ម្រេច និងគ្រាប់ស្ពៃជាដើម ។

សូម្បី មេរ័យក៏មាន ៥ យ៉ាងគឺ

១-បុប្ផាសវោ = ទឹកត្រាំធ្វើពីផ្កាឈើ

២-ផលាសវោ = ទឹកត្រាំធ្វើពីផ្លែឈើ

៣-មធ្វាសវោ = ទឹកត្រាំធ្វើពីផ្លែចន្ទន៍ ឬ ទឹកឃ្មុំ

៤-គុឡាសវោ = ទឹកត្រាំធ្វើពីទឹកអំពៅ

៥-សម្ភារសំយុត្តោ = ទឹកត្រាំដែលគេប្រកបគ្រឿងផ្សំផ្សេងៗ

*មានផ្លែសម៉ និងផ្លែកន្ទួតព្រៃជាដើម ។ បទថា មជ្ជំ បានដល់ វត្ថុទាំងពីរយ៉ាងនោះនុ៎ះឯង ឈ្មោះថា **មជ្ជៈ** ព្រោះអត្ថថា ជាទីតាំងនៃសេចក្ដីស្រវឹង ។ សូម្បីវត្ថុណាទីមួយ ជាទីតាំងនៃសេចក្ដីស្រវឹង បុគ្គលស្រវឹងប្រមាទដោយវត្ថុណាដែលផឹកហើយ វត្ថុនោះ ក៏ហៅថា **មជ្ជៈ** ។ បទថា បមាទដ្ឋានំ បានដល់ ចេតនាគឺលេបកន្ទងនូវមជ្ជៈនោះ ចេតនានោះ លោកហៅថា បមាទដ្ឋានំ ព្រោះជាហេតុនៃសេចក្ដីស្រវឹង ធ្វើឱ្យប្រមាទ ចេតនាលេបមជ្ជៈ គឺសុរា និងមេរ័យ ប្រព្រឹត្តទៅតាមផ្លូវកាយទ្វារដោយបំណងនឹងលេប គប្បីជ្រាបថា សុរាមេរ័យ ជាទីតាំងនៃសេចក្ដីប្រមាទ ដោយប្រការណា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទាំងពួងមុន រាប់តាំងអំពីបាណាតិបាតជាដើម ទៅដោយប្រការនោះ ។*

## ឯកតានានតាទិវិនិច្ឆយំ

## **ការវិនិច្ឆ័យសិក្ខាបទដូចគ្នា និងផ្សេងគ្នាជាដើម**

*ក្នុងបទថា **ឯកតានានតាទិតោ** ដោយសិក្ខាបទជាមួយគ្នា តែផ្សេងគ្នាជាដើម អ្នកជំទាស់ពោលថា**បាណាតិបាត** ឬសិក្ខាបទ មានអទិន្នាទានជាដើមជាមួយគ្នា ព្រោះអ្នកនឹងគប្បីត្រូវសម្លាប់ អ្នកសម្លាប់ ប្រយោគ និងចេតនាជាដើម ជាមួយគ្នា ដែលផ្សេងគ្នា ព្រោះមាន*

អ្នកនឹងត្រូវសម្លាប់ជាដើមផ្សេងគ្នា ឬថាមិនប្រើទាំងពីរយ៉ាង ។ ក៏ព្រោះហេតុអ្វី អ្នកជំទាស់ទើបពោលពាក្យនេះ បើថាសិក្ខាបទនឹងជាមួយគ្នា ព្រោះអ្នកដែលនឹងគប្បីត្រូវសម្លាប់ជាដើម ជាមនុស្សជាមួយគ្នា កាលដូច្នោះ កាលណាអ្នកសម្លាប់គ្នាច្រើន សម្លាប់មនុស្សដែលនឹងគប្បីសម្លាប់ម្នាក់ ឬអ្នកសម្លាប់ម្នាក់ ដែលនឹងគប្បីសម្លាប់មនុស្សច្រើននាក់ អ្នកដែលនឹងគប្បីត្រូវមនុស្សច្រើនសម្លាប់ ក៏នឹងត្រូវសម្លាប់ ដោយប្រយោគតែមួយ មានសាហត្ថិកប្រយោគជាដើម ឬចេតនាតែមួយ ក៏នឹងញ៉ាំងប្រយោគរបស់អ្នកចូលទៅផ្តាច់ជីវិតិន្ទ្រិយរបស់អ្នក ដែលនឹងគប្បីត្រូវមនុស្សច្រើនសម្លាប់ឱ្យតាំងឡើង កាលនោះបាណាតិបាត ក៏នឹងគប្បីមានតែម្យ៉ាង ។ តែបើសិក្ខាបទនឹងផ្សេងគ្នា ព្រោះអ្នកដែលនឹងគប្បីត្រូវសម្លាប់ជាដើមផ្សេងគ្នា ។ កាលបើដូច្នោះ កាលណា អ្នកសម្លាប់ម្នាក់ កាលធ្វើប្រយោគតែមួយ ដើម្បីមនុស្សម្នាក់ៗ ក៏រមែងសម្លាប់មនុស្សដែលគប្បីសម្លាប់ច្រើនគ្នា ឬអ្នកសម្លាប់ច្រើនគ្នា ធ្វើនូវប្រយោគច្រើន ដើម្បីមនុស្សច្រើននាក់ មានទេវទត្ត យញ្ញទត្ត និងសោមទត្តជាដើម ក៏រមែងសម្លាប់បានចំពោះទេវទត្ត យញ្ញទត្ត ឬសោមទត្ត តែម្នាក់ប៉ុណ្ណោះ ឬក៏អ្នកដែលនឹងគប្បី

សម្លាប់ម្នាក់ ត្រូវអ្នកសម្លាប់ ដោយប្រយោគច្រើន មានសាត្ថិក-ប្រយោគជាដើម ឬក៏ចេតនាច្រើន ក៏នឹងញុំាងប្រយោគរបស់អ្នកចូលទៅកាត់ផ្តាច់ជីវិតិន្ទ្រិយរបស់អ្នក ដែលនឹងគប្បីត្រូវសម្លាប់មនុស្សម្នាក់ប៉ុណ្ណោះ ឱ្យតាំងឡើង កាលនោះ បាណាតិបាតក៏នឹងគប្បីមានច្រើនយ៉ាង ។ សូម្បីពាក្យទាំងពីរនោះ ក៏មិនត្រូវ ។ សិក្ខាបទនឹងឈ្មោះថាដូចគ្នា ព្រោះអ្នកដែលនឹងគប្បីត្រូវសម្លាប់ជាដើម ទាំងនោះមានអ្នកតែម្នាក់ ក៏មិនមែន សិក្ខាបទឈ្មោះថាផ្សេងគ្នា ព្រោះអ្នកនឹងគប្បីត្រូវសម្លាប់ជាដើមទាំងនោះ ផ្សេងគ្នាក៏មិនមែន សេចក្តីពិត សិក្ខាបទដូចគ្នា និង ផ្សេងគ្នា ក៏ដោយហេតុយ៉ាងដទៃ ពាក្យនោះគប្បីពោលដល់បាណាតិបាត សូម្បីសិក្ខាបទក្រៅនោះ ក៏គប្បីពោលដល់យ៉ាងនោះ ។

ខ្ញុំសូមបន្តុលបង្ហាញតទៅនេះ មុនដំបូង បាណាតិបាតនោះឈ្មោះថាដូចគ្នា ព្រោះអ្នកដែលនឹងគប្បីត្រូវសម្លាប់ជាដើម ដែលឈ្មោះថាផ្សេងគ្នា ព្រោះអ្នកដែលនឹងគប្បីសម្លាប់ជាដើមផ្សេងៗ ក៏មិនមែន ដែលពិតបាណាតិបាត ឈ្មោះថាដូចគ្នា ព្រោះអ្នកដែលនឹងគប្បីត្រូវសម្លាប់ និងអ្នកសម្លាប់ជាដើម ដូចគ្នា ដោយចាត់ជាគូៗគ្នា ។ ទាំងឈ្មោះថា **ដូចគ្នា** ព្រោះអ្នកនឹងគប្បីត្រូវសម្លាប់ និងអ្នក

សម្លាប់ជាដើម សូម្បីទាំងពីរនោះដូចគ្នា ដោយចាត់ជាគូៗ ឬឈ្មោះថា ផ្សេងគ្នា ព្រោះអ្នកដែលនឹងគប្បីសម្លាប់ និងអ្នកសម្លាប់ជាដើមនោះ ចំពោះម្នាក់ទៀត ដទៃអំពីអ្នកទាំងពីរនោះ ។ ពិតយ៉ាងនោះ កាល មនុស្សអ្នកសម្លាប់ច្រើនគ្នា សូម្បីសម្លាប់មនុស្សអ្នកដែលត្រូវសម្លាប់ ច្រើនគ្នា ដោយប្រយោគច្រើនប្រយោគ មានសរក្ខេបប្រយោគ(ជីកស្រះ) ជាដើម ឬដោយប្រយោគៗ មានឱបាតខណនប្រយោគ (ការជីកអណ្តូង) ជាដើម ក៏ជាបាណាតិបាត ។ កាលអ្នកសម្លាប់ម្នាក់ សូម្បីសម្លាប់ អ្នក ដែលត្រូវសម្លាប់ច្រើននាក់ ដោយប្រយោគមួយ ឬច្រើន ដោយចេតនា មួយ ដែលញុំាងប្រយោគនោះ ឱ្យតាំងឡើង ឬដោយចេតនាច្រើន ក៏ជា បាណាតិបាត ម្យ៉ាងវិញទៀត កាលអ្នកសម្លាប់មនុស្សច្រើន សូម្បីសម្លាប់ អ្នកដែលត្រូវសម្លាប់ម្នាក់ ដោយច្រើនប្រយោគតាមដែលពោលមកហើយ ឬ ដោយប្រយោគតែមួយ ក៏ជាបាណាតិបាតច្រើន ។ សូម្បីក្នុងសិក្ខាបទ មាន អទិន្នាទានជាដើម ក៏ន័យនេះ ។ ក្នុងរឿងនេះ គប្បីជ្រាបវិនិច្ឆ័យ ដោយ សិក្ខាបទ នឹងផ្សេងគ្នាជាដើម ដោយប្រការដូចពោលមកដូច្នេះ ។

**ពោលដោយអារម្មណ៍** ក្នុងសេចក្តីនេះ បាណាតិបាត មាន ជីវិតិន្ទ្រិយជាអារម្មណ៍ ។ អទិន្នាទាន អព្រហ្មចរិយៈ និងសុរាមេរយ-

មជ្ឈប្បមាទដ្ឋាន មានសង្ខារ គឺរូបធម៌ មានរូបាយតនៈជាដើមណាមួយ ជាអារម្មណ៍ ។ មុសាវាទ មានសត្វជាអារម្មណ៍ ព្រោះប្រារព្ធចំពោះមនុស្សដែលនិយាយកុហក ។ អាចារ្យមួយពួក ពោលថា សុម្បីអព្រហ្មចរិយ ក៏មានសត្វជាអារម្មណ៍ ។ មួយទៀត អទិន្នាទាន មានសត្វជាអារម្មណ៍ ក្នុងវេលាដែលសត្វជាអ្នកគប្បីទឹងលួច ។ ប្រការមួយទៀត អទិន្នាទាន មានសត្វជាអារម្មណ៍ ដោយអំណាចសង្ខារ ពុំមែនដោយអំណាចបញ្ញត្តទេ ។ ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយអារម្មណ៍ ដូចពោលមកដូច្នេះឯង ។

**ការពោលដោយសមាទាន** ក៏សិក្ខាបទទាំងនេះ មាន បាណាតិបាតា-វេរមណីសិក្ខាបទជាដើម សាមណេរសមាទានក្នុងសម្នាក់ភិក្ខុពួកនោះ ទើបជាការសមាទាន ចំណែកឧបាសក ការសមាទានខ្លួនឯងក្តី សមាទានក្នុងសម្នាក់របស់អ្នកដទៃក្តី ក៏ជាការសមាទានហើយ សមាទានរួមគ្នាក្តី សមាទានបែកគ្នាក្តី ក៏ជាការសមាទាន ។ តើផ្សេងគ្នាយ៉ាងណា បុគ្គលសមាទានរួមគ្នា ក៏មានវិរតិមួយ មានចេតនាមួយប៉ុណ្ណោះ តែប្រាកដថា វិរតិ និងចេតនាពួកនោះ មានដល់ទៅ ៥ ដោយអំណាចកិច្ច គឺតួនាទី ។ ចំណែកបុគ្គលដែលសមាទានផ្សេងគ្នា ក៏គប្បី

ជ្រាបថាមានវិរតិ ៥ ចេតនាក៏ ៥ ។ ក្នុងសេចក្ដីនេះ គប្បីជ្រាបវិនិច្ឆ័យដោយការសមាទានដោយប្រការដូច្នេះឯង ។

**ការពោលដោយការដាច់** ក្នុងសេចក្ដីនេះ សម្រាប់សាមណេរទាំងឡាយ កាលសិក្ខាបទមួយដាច់ គ្រប់សិក្ខាបទក៏ដាច់ ។ ព្រោះសិក្ខាបទពួកនោះ ជាឋានទីតាំងនៃបារាជិករបស់សាមណេរពួកនោះ ដោយសិក្ខាបទដែលសាមណេរកន្លងល្មើសនោះឯង ក៏មានកម្មជាប់តាមមក ។ តែសម្រាប់គ្រហស្ថ កាលបើសីលមួយដាច់ ក៏ដាច់តែមួយប៉ុណ្ណោះ ព្រោះសីលរបស់គ្រហស្ថនោះ មានអង្គ ៥ រមែងនឹងកើតទៀតដោយការសមាទានសីលនោះប៉ុណ្ណោះ ។ តែអាចារ្យមួយពួក ពោលថាបណ្ដាសីលដែលគ្រហស្ថសមាទានផ្សេងៗគ្នា កាលបើសីលមួយដាច់ក៏ដាច់តែមួយប៉ុណ្ណោះ តែបណ្ដាសីល ដែលគ្រហស្ថសមាទានរួមគ្នាយ៉ាងនេះថា ខ្ញុំសូមសមាទានសីល ដែលប្រកបដោយអង្គ ៥ ដូច្នេះ កាលសីលមួយដាច់ សីលសូម្បីដ៏សេស ក៏ដាច់គ្រប់ទាំងអស់ ។ ព្រោះហេតុអ្វី? ព្រោះសីលដែលសមាទានមិនដាច់ ដោយការកន្លងនូវសិក្ខាបទណាមួយ រមែងជាកម្មជាប់គ្នា ដោយការសមាទាននោះ ។ គប្បីជ្រាបវិនិច្ឆ័យសូម្បីការដាច់ ដោយប្រការដូច្នេះ ។

***ការពោលដោយទោសច្រើន*** *បណ្តាសត្វមានជីវិត ដែលវៀរចាកគុណ មានសត្វតិរច្ឆានជាដើម បាណាតិបាត ឈ្មោះថា មានទោសតិច ក៏ព្រោះសត្វមានខ្លួនតូច ឈ្មោះថា មានទោសច្រើន ក៏ព្រោះសត្វមានខ្លួនធំ ។ ព្រោះហេតុអ្វី? ព្រោះប្រយោគធំ (សេចក្តីព្យាយាមច្រើន) ។ សូម្បីកាលមានប្រយោគស្មើគ្នា ឈ្មោះថាមានទោសច្រើន ព្រោះវត្ថុធំ ។ ចំណែកបណ្តាសត្វមានជីវិត ដែលមានគុណ មានមនុស្សជាដើម បាណាតិបាត ឈ្មោះថា មានទោសតិច ក៏ព្រោះមនុស្សមានគុណតិច ។ ឈ្មោះថាមានទោសច្រើន ក៏ព្រោះមនុស្សមានគុណច្រើន ។ តែកាលមានខ្លួន និងគុណស្មើគ្នា ក៏គប្បីជ្រាបថា មានទោសតិច ព្រោះកិលេស និងសេចក្តីព្យាយាមខ្សោយ នឹងមានទោសច្រើន ព្រោះកិលេស និងសេចក្តីព្យាយាមខ្លាំងក្លា ។ សូម្បីក្នុងសិក្ខាបទដ៏សេស ក៏មានន័យដូច្នេះដែរ ។ម្យ៉ាងទៀត ក្នុងសេចក្តីនេះ សុរាមេរយមជ្ជបមាទដ្ឋានប៉ុណ្ណោះ ឈ្មោះថា* **មានទោសច្រើន** *ចំណែកឯសិក្ខាបទទាំងឡាយមានបាណាតិបាតជាដើម ពុំដូច្នោះទេ ។ ព្រោះអ្វី? ព្រោះធ្វើសេចក្តីអន្តរាយដល់អរិយធម៌ ជាហេតុធ្វើ អ្នកកើតមកជាមនុស្សឱ្យក្លាយជា*

មនុស្សឆ្កួត ។ ក្នុងសេចក្ដីនេះ គប្បីជ្រាបវិនិច្ឆ័យ សូម្បីដោយសេចក្ដីមានទោសច្រើន ដោយប្រការដូច្នោះ ។

**ការពោលដោយប្រយោគ** ក៏ន័យនេះ ។ បាណាតិបាត មាន ៦ ប្រយោគ គឺ សាហត្ថិកប្រយោគ អាណត្តិកប្រយោគ និស្សគ្គិយ-ប្រយោគ ថាវរប្រយោគ វិជ្ជាមយប្រយោគ ឥទ្ធិមយប្រយោគ ។ បណ្ដាប្រយោគទាំងនោះ ការប្រហារដោយកាយ ឬរបស់ដែលជាប់ដោយកាយឈ្មោះថា សាហត្ថិកប្រយោគ សាហត្ថិកប្រយោគនោះចែកជា ២ គឺសាហត្ថិកប្រយោគចំពោះ និងសាហត្ថិកប្រយោគមិនចំពោះ ។ បណ្ដាសាហត្ថិកប្រយោគទាំងពីរនោះ សាហត្ថិកប្រយោគចំពោះបុគ្គលរមែងជាប់ដោយកម្ម ព្រោះសេចក្ដីស្លាប់របស់បុគ្គលដែលចំពោះនោះ ។ សាហត្ថិកប្រយោគមិនចំពោះ យ៉ាងនេះថា "អ្នកណាមួយចូរស្លាប់ចុះ" ដូច្នេះ បុគ្គលរមែងជាប់ដោយកម្ម ព្រោះសេចក្ដីស្លាប់របស់សត្វណាមួយ មានការប្រហារជាបច្ច័យ ។ ម្យ៉ាងទៀត សូម្បីដោយសាហត្ថិក-ប្រយោគទាំងពីរ ត្រឹមតែការជាការប្រហារក៏ស្លាប់ ឬស្លាប់ដោយរោគនោះ ក្នុងកាលជាក្រោយបុគ្គលក៏រមែងជាប់ដោយកម្ម ក្នុងខណៈដែលគេប្រហារប៉ុណ្ណោះ ។ តែកាលបុគ្គលប្រហារដោយបំណងនឹងឱ្យ

គេស្លាប់ តែគេមិនស្លាប់ដោយការប្រហារនោះ ត្រឡប់គិតប្រហារម្ដងទៀត សូម្បីខាងក្រោយមកគេស្លាប់ ដោយការប្រហារគ្រាដំបូង បុគ្គលក៏រមែងជាប់ដោយកម្ម ក្នុងវេលានោះប៉ុណ្ណោះ ។ បើថា គេស្លាប់ដោយការប្រហារលើកទីពីរ ក៏មិនជាបាណាតិបាត ។ សូម្បីកាលគេស្លាប់ដោយសាហត្ថិកប្រយោគទាំងពីរ បុគ្គលក៏ជាប់ដោយកម្ម ដោយការប្រហារលើកដំបូងប៉ុណ្ណោះ កាលគេមិនស្លាប់ សូម្បីដោយសាហត្ថិកប្រយោគទាំងពីរ ក៏មិនជាបាណាតិបាតឡើយ ។ ក្នុងហេតុដែលមនុស្សច្រើននាក់ប្រហារមនុស្សម្នាក់ ក៏ន័យនេះ ។ សូម្បីក្នុងសេចក្ដីនោះ ការជាប់ដោយកម្ម រមែងមានដល់អ្នក ដែលប្រហារគេឱ្យស្លាប់ប៉ុណ្ណោះ ។

ការតាំងចិត្តបង្គាប់ឱ្យគេធ្វើ ឈ្មោះថា **អាណត្តិកប្រយោគ** ។ សូម្បីក្នុងអាណត្តិកប្រយោគនោះ ក៏គប្បីជ្រាបសេចក្ដីជាប់ដោយកម្ម ដោយន័យ ដែលពោលទុកក្នុងសាហត្ថិកប្រយោគនុ៎ះឯង ។ ក៏ក្នុងអាណត្តិកប្រយោគនោះ គប្បីជ្រាបមានកំណត់ទុក ៦ យ៉ាង:

វត្ថុ កាលោ ច ឱកាសោ អាវុធំ ឥរិយាបថោ
កិរិយាវិសេសោតិ ឥមេ ឆ អាណត្តិនិយាមកាតិ
អាណត្តិកប្រយោគកំណត់ទុក ៦ យ៉ាងគឺ វត្ថុ ១ កាល ១

ឱកាស ១ អាវុធ ១ ឥរិយាបថ ១ កិរិយាវិសេស ១[១] ។

បណ្ដាឋានៈមានវត្ថុជាដើមនោះ ឋានៈថា **វត្ថុ** បានដល់ សត្វដែលត្រូវសម្លាប់ ។ ឋានៈថា **កាល** បានដល់ កាល មានវេលាព្រឹក វេលាល្ងាចជាដើម និងមានវ័យកម្លោះ ក្រមុំ មានកម្លាំង និងមានការព្យាយាមជាដើម ។ ឋានៈថា **ឱកាស** បានដល់ ទី មានជាដើមយ៉ាងនេះ គឺស្រុក និគម ព្រៃ ផ្លូវ ឬផ្លូវបែកជាបី ។ ឋានៈថា **អាវុធ** បានដល់ អាវុធជាដើម យ៉ាងនេះគឺ ដាវ ធ្នូ ឬលំពែង ។ ឋានៈថា **ឥរិយាបថ** បានដល់ ឥរិយាបថ មានជាដើមយ៉ាងនេះ គឺការអង្គុយរបស់អ្នកដែលត្រូវសម្លាប់ ។

ឋានៈថា **កិរិយាវិសេស** បានដល់ កិរិយា ដែលធ្វើមានជាដើមយ៉ាងនេះ គឺការចាក់ ការកាត់ ការទម្លាយ ពន្លាត់ស្បែកក្បាល ធ្វើឱ្យរលីងដូចស័ង្ខ ។ ក៏បើថា អ្នកត្រូវគេបង្គាប់ឱ្យទៅសម្លាប់ អ្នកណាធ្វើវត្ថុឱ្យឃ្លាតចាក(សម្លាប់ខុស) ទៅសម្លាប់អ្នកដទៃក្រៅអំពីអ្នកនោះវិញ អ្នកបង្គាប់ក៏មិនត្រូវជាប់ដោយកម្ម ។ បើគេមិនធ្វើវត្ថុឱ្យឃ្លាតចាក សម្លាប់មិនខុស សូម្បីទាំងពីរអ្នកក៏ត្រូវជាប់ដោយកម្ម គឺអ្នកបង្គាប់

---

១-អដ្ឋកថាព្រះវិន័យឈ្មោះ សមន្តប្បាទិកា ប្រែជាភាសាខ្មែរភាគ ៥ ទំព័រ១២០ ។

ក្នុងខណៈបន្ទាប់ អ្នកត្រូវបន្ទាប់ក្នុង ខណៈសម្លាប់ ។ សូម្បីក្នុងការកំណត់ដទៃៗ មានកាលជាដើម ក៏ន័យនេះ ។

ការចោលគ្រឿងប្រហារ ដោយកាយ ឬរបស់ដែលជាប់ដោយកាយ ដើម្បីធ្វើគេឱ្យស្លាប់ ឈ្មោះថា **និស្សគ្គិយប្រយោគ** ។ សូម្បីនិស្សគ្គិយប្រយោគនោះ ក៏ចែកជា ២ ដូចគ្នា គឺនិស្សគ្គិយប្រយោគចំពោះ និងមិនចំពោះ ក្នុងសេចក្តីនេះ ការជាប់ដោយកម្ម ក៏គប្បីជ្រាបតាមន័យដែលពោលមកហើយ ក្នុងសេចក្តីខាងដើមៗនុ៎ះឯង ។ ការជីករណ្តៅ ការដាក់ក្តារ ការប្រកបនុយថ្នាំពិស និងគ្រឿងយន្តជាដើម ដើម្បីធ្វើឱ្យគេស្លាប់ ឈ្មោះថា **ថាវរប្រយោគ** ។ សូម្បីថាវរប្រយោគនោះក៏ចែកជា ២ គឺថាវរប្រយោគចំពោះ និងមិនចំពោះ ។ ក៏ក្នុងសេចក្តីនេះការជាប់ដោយកម្ម គប្បីជ្រាបតាមន័យដែលពោលមកហើយក្នុងសេចក្តីខាងដើមៗ ។ ប៉ុន្តែសេចក្តីប្លែកមានដូច្នេះ កាលមនុស្សរកជំឡួង ធ្វើរណ្តៅជាដើមជិតៗ ឬធ្វើរណ្តៅទទេក្តីរបស់អ្នកដទៃៗ បើថាគេស្លាប់ ព្រោះរណ្តៅជាដើមនោះ ជាបច្ច័យ សេចក្តីជាប់ដោយកម្ម ក៏មានដល់អ្នករកជំឡួង ។ ម្យ៉ាងទៀត កាលអ្នកនោះ ឬអ្នកដទៃលុបរណ្តៅនោះចេញហើយធ្វើផ្ទៃឱ្យរាប ឬអ្នកបោសធូលី កាយធូលី

ទៅ ឬអ្នកជីកជំឡូងធ្វើឱ្យអន្លង់ទុក ឬកាលភ្លៀងធ្លាក់កើតភក់ មនុស្សចុះ ទៅជាប់ស្លាប់ក្នុងភក់នោះ ការជាប់ដោយកម្មក៏មាន ដល់អ្នករកជំឡូងនុ៎ះឯង ។ ប្រសិនបើថា អ្នកដែលបានជំឡូង ឬអ្នកដទៃធ្វើអន្លង់នោះឱ្យទូលាយ ឬជ្រៅជាងដើម អ្នកចុះទៅស្លាប់ ព្រោះក្រឡុកទូលាយ ឬជ្រៅនោះ សេចក្តីជាប់ដោយកម្ម ក៏មានដល់អ្នកសូម្បីទាំងពីរ ។ ចំណែកឯមូលហេតុទាំងឡាយរមែងធៀបគ្នាបាន និងការជីកជំឡូង យ៉ាងណា កាលអ្នកលុបអន្លង់ឱ្យរាបក្នុងទីនោះ ក៏រមែងរួចចាកទោសដែលកើតអំពីការជីកអន្លង់នោះ ។ សូម្បីក្នុងថាវរប្រយោគ មានការដាក់ក្តារជាដើម ក៏យ៉ាងនោះដូចគ្នា ការជាប់ដោយកម្មតាមហេតុដែលកើត ក៏គប្បីជ្រាបដរាបដល់ថាវរប្រយោគទាំងនោះប្រព្រឹត្តទៅ ។

ការរាយវិជ្ជាប្រយោជន៍ដើម្បីឱ្យសត្វស្លាប់ ឈ្មោះថា **វិជ្ជាមយប្រយោគ** ។

ការធ្វើឫទ្ធិផ្សេងៗ ដែលកើតអំពីវិបាកកម្ម ដើម្បីធ្វើឱ្យគេស្លាប់ ដូចជាប្រើអាវុធ ឬចង្កូមជាដើម ដែលខាំដោយចង្កូមជាដើម ឈ្មោះថា **ឥទ្ធិមយប្រយោគ** ។ ចំណែកអទិន្នាទាន ក៏មានប្រយោគ គឺសាហត្ថិក-ប្រយោគ និងអាណត្តិកប្រយោគជាដើម ដែលប្រព្រឹត្តទៅដោយអំណាច **ថេយ្យាវហារ បសយ្ហាវហារ បដិច្ឆន្នាវហារ បរិកប្បាវហារ**

និង **កុសាវហារ**[១] ប្រភេទ នៃប្រយោគសូម្បីទាំងនោះ ក៏គប្បីជ្រាប ដោយទំនងដែលពោលមកហើយនុ៎ះឯង សិក្ខាបទទាំងបីមានអព្រហ្មចរិយៈ ជាដើម ក៏ជាសាហត្ថិកប្រយោគតែម្យ៉ាង ក្នុងសេចក្ដីនេះ គប្បីជ្រាប វិនិច្ឆ័យ សូម្បីដោយប្រយោគដោយប្រការដូចពោលមកដូច្នេះ ។

**ការពោលដោយអង្គ** ក្នុងសេចក្ដីនេះ

**បាណាតិបាត** មានអង្គ ៥ គឺ

១.ចាណោ = សត្វមានជីវិត

២.ចាណសញ្ញី = សម្គាល់ថាសត្វមានជីវិត

៣.វធកចិត្តំ = ចិត្តគិតនឹងសម្លាប់

៤.វាយមតិ = ព្យាយាមនឹងសម្លាប់

៥.តេន មរតិ = សត្វស្លាប់ដោយសេចក្ដីព្យាយាមនោះ ។

សូម្បីអទិន្នាទាន ក៏មានអង្គ ៥ ដូចគ្នា គឺ

១.បរបរិគ្គហិតំ = របស់មានម្ចាស់ហួងហែងរក្សា

---

១_អវហារទាំង ៥ នេះ មានសេចក្ដីពិស្ដារនៅក្នុងគម្ពីរសមន្តប្បាសាទិកា (បាលី-ខ្មែរ) ភាគ ៥ ទំព័រ ៤៤ និង គម្ពីរកង្ខាវិតរណី អដ្ឋកថាបាតិមោក្ខ ភាគ ១ ទំព័រ ៨៦ ។

២.បរបរិគ្គហិតសញ្ញី = សម្គាល់ថារបស់មានម្ចាស់ហួងហែងរក្សា

៣.ថេយ្យចិត្តំ = មានចិត្តគិតនឹងលួច

៤.វាយមតិ = ព្យាយាមនឹងលួច

៥.តេន អាទាតព្វំ អាទានំ គច្ឆតិ = ដល់នូវការលួចនូវរបស់ដែលគេមិនឱ្យ ដោយសេចក្ដីព្យាយាមនោះ ។

ចំណែកអព្រហ្មចរិយៈ មានអង្គ ៤ គឺ

១.អជ្ឈាចរិយវត្ថុ = វត្ថុដែលគប្បីកន្លងល្មើស

២.សេវនចិត្តំ = ចិត្តគិតនឹងសេព

៣.បយោគំ សមាបជ្ជតិ = ព្យាយាមនឹងប្រកបដែលមានសេវនកិច្ចជាបច្ច័យ

៤.សាទិយតិ = ត្រេកអរចំពោះសេវនកិច្ចនោះ ។

មុសាវាទ ក៏មានអង្គ ៤ ដូចគ្នា គឺ

១.អតថំវត្ថុ = វត្ថុមិនពិត

២.វិសំវាទនចិត្តំ = គិតនឹងពោលឱ្យខុស

៣.តជ្ជោ វាយាមោ = ព្យាយាមនឹងពោលឱ្យខុសនោះ

៤.បរស្សតេឧត្តវិជ្ជានធំ = ញ៉ាំងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្ដីនោះៗ

សុរាមេរ័យមានអង្គ ៤ គឺ

១.មជ្ជនីយវត្ថុ = វត្ថុជាទីតាំងនៃសេចក្ដីស្រវឹង គឺសុរា និងមេរ័យ

២.ចាតុកម្យតាចិត្តំ = ចិត្តប្រាថ្នានឹងផឹក

៣.តជ្ជោវាយាមោ = ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ

៤.តស្សចានំ= បានផឹកនូវទឹកស្រវឹងនោះឱ្យកន្លងបំពង់កចូលទៅ ។

ក្នុងសេចក្ដីនេះ គប្បីជ្រាបវិនិច្ឆ័យ សូម្បីជ្រាបដោយអង្គដោយប្រការដូចពោលមកដូច្នេះ ។

**ការពោលដោយសមុដ្ឋាន** ក្នុងសេចក្ដីនេះ បាណាតិបាត អទិន្នាទាន និងមុសាវាទ មានសមុដ្ឋាន ៣ គឺ កាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ។ អព្រហ្មចរិយៈ មានសមុដ្ឋានមួយប៉ុណ្ណោះ គឺ កាយចិត្ត ។ សុរាមេរយមជ្ជបមាទដ្ឋាន មានសមុដ្ឋាន ២ គឺ កាយ ១ កាយចិត្ត ១ ។ ក្នុងសេចក្ដីនេះ គប្បីជ្រាបវិនិច្ឆ័យ ដោយសមុដ្ឋាន ដោយប្រការដូចពោលមកដូច្នេះ ។

**ការពោលដោយវេទនា** ក្នុងសេចក្ដីនេះ បាណាតិបាត ប្រកប ដោយទុក្ខវេទនា ។ អទិន្នាទាន ប្រកបដោយវេទនាណាមួយក្នុង

ចំណោមវេទនាទាំងបី មុសាវាទក៏ដូចគ្នា ។ ពីរសិក្ខាបទទៀត ប្រកប ដោយសុខវេទនា និងអទុក្ខមសុខវេទនា ។ ក្នុងសេចក្តីនេះ គប្បីជ្រាប វិនិច្ឆ័យសូម្បីដោយវេទនា ដោយប្រការដូចពោលមកដូច្នេះ ។

**ការពោលដោយមូល** ក្នុងសេចក្តីនេះបាណាតិបាតមាន ទោសៈ និង មោហៈជាមូល ។ អទិន្នាទាន និងមុសាវាទ មានលោភៈ និងមោហៈ ជាមូលខ្លះ មានទោសៈ និងមោហៈ ជាមូលខ្លះ ។ ពីរសិក្ខាបទក្រៅនេះ មានលោភៈ និងមោហៈ ជាមូល ។ ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យ ដោយមូល តាមប្រការដូចពោលមកដូច្នេះ ។

**ការពោលដោយកម្ម** ក្នុងសេចក្តីនេះ បាណាតិបាត អទិន្នាទាន និងអព្រហ្មចរិយ ជាកាយកម្ម និងជាកម្មបថ ។ មុសាវាទ ជាវចីកម្ម តែម្យ៉ាង ។ ក៏បុគ្គលណា ជាអ្នកកាច់បំបាក់នូវប្រយោជន៍បុគ្គលនោះ រមែងដល់នូវកម្មបថ (គឺជាច់កម្មបថ) ។ សិក្ខាបទក្រៅនេះ ជាកម្មបថ តែប៉ុណ្ណោះ។សុរាមេរយមជ្ជបមាទដ្ឋានជាកាយកម្មតែម្យ៉ាង ។ ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យសូម្បីដោយកម្ម ដោយប្រការដូចពោលមកដូច្នេះ ។

**ការពោលដោយវិរតិវៀរ** ក្នុងសេចក្តីនេះ អ្នកជំទាស់ ពោលថា បុគ្គលកាលលះបង់ចាកបាណាតិបាតជាដើម លះបង់ដោយរបៀបណា ។ នឹង

ពោលបង្ហាញដូច្នេះ មុនដំបូងបុគ្គលកាលលះបង់ ដោយសមាទានវិរតិរមែងលះបង់ចាកអកុសលកម្ម មានបាណាតិបាតជាដើម របស់ខ្លួនឯងឬរបស់បុគ្គលដទៃ ។ ព្រោះប្រារព្ធអ្វី ។ ព្រោះប្រារព្ធ អកុសលកម្មដែលនឹងលះបង់នោះឯង ។ កាលលះបង់ដោយ សម្បត្តវិរតិរមែងលះបង់ចាកអកុសលកម្ម ដូចពោលហើយនោះឯង ។ ព្រោះប្រារព្ធអ្វី ។ ក៏ព្រោះប្រារព្ធអារម្មណ៍នៃអកុសលកម្ម មានបាណាតិបាតជាដើម ដែលបានពោលហើយ ។ តែអាចារ្យពួកខ្លះ ពោលថា បុគ្គលប្រារព្ធសង្ខារទាំងឡាយ ពោលគឺទឹកស្រវឹង គឺសុរា និងមេរ័យ ទើបលះបង់ចាកទីតាំងនៃសេចក្តីប្រមាទ គឺការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ បុគ្គលប្រារព្ធ បណ្ដាសត្វ និងសង្ខារ ចំពោះខ្លួន គប្បីលួច និងគប្បីកាត់បន្ថយ ទើបលះបង់អទិន្នាទាន និងមុសាវាទ ។ ប្រារព្ធសត្វតែម្យ៉ាងទើបលះបង់ចាកបាណាតិបាត និងអព្រហ្មចរិយៈ ។ អាចារ្យក្រៅអំពីនោះ មានសេចក្តីយល់ឃើញយ៉ាងនេះថា កាលដូច្នោះ បុគ្គលគិតយ៉ាងដទៃ ក៏ធ្វើយ៉ាងដទៃ លះវត្ថុណា ក៏មិនដឹងវត្ថុនោះ ដូច្នេះ កាលមិនត្រូវការ(យ៉ាងនោះ) ទើបពោលថា បុគ្គលលះវត្ថុណា ក៏ប្រារព្ធវត្ថុនោះ គឺអកុសលកម្ម មានបាណាតិបាតជាដើមរបស់ខ្លួនទុះឯង ទើប

លះបង់ ។ ពាក្យនោះមិនត្រូវ ព្រោះហេតុអ្វី? ព្រោះវត្ថុនោះ មិនមានអារម្មណ៍ជាបច្ចុប្បន្ន និងមិនមានអារម្មណ៍ខាងក្រៅ ។ មែនពិត ក្នុងបាលីវិភង្គនៃសិក្ខាបទទាំងឡាយ លោកសួរថា “សិក្ខាបទទាំង ៥ ជាកុសលប៉ុណ្ណា ។ល។ ជាអរណៈប៉ុណ្ណា”[១] ហើយក្នុងការឆ្លើយបញ្ហាអំពីដើម យ៉ាងនេះថា “កុសលទាំងឡាយ ប្រកបដោយសុខវេទនាក៏មាន” ទើបពោលដល់សេចក្តី ដែលធម៌មានអារម្មណ៍ជាបច្ចុប្បន្ន និងអារម្មណ៍ខាងក្រៅ យ៉ាងនេះថាមានអារម្មណ៍ ជាបច្ចុប្បន្នផង មានអារម្មណ៍ខាងក្រៅ ពាក្យនោះ រមែងមិនត្រូវសម្រាប់អ្នកដែលប្រារព្ធអកុសលធម៌ មានបាណាតិបាតជាដើមរបស់ខ្លួន ។ ក្នុងពាក្យថា បុគ្គលគិតយ៉ាងដទៃ ធ្វើយ៉ាងដទៃ នឹងលះបង់វត្ថុណាក៏មិនដឹងវត្ថុនោះ សូមពោលចង្អុល បង្ហាញយ៉ាងនេះ បុគ្គលកំពុងបដិបត្តិដោយធ្វើកិច្ចឱ្យសម្រេចនូវណា នឹងពោលនឹងមិនថា គិតតែម្យ៉ាង ធ្វើតែម្យ៉ាង ឬថាលះវត្ថុណា មិនដឹងវត្ថុនោះដូច្នេះទេ ។

អារភិត្វាន អមតំ ជហាន្តោ សព្វចាបកេ
ឆិនស្សនពោត្ត ភវេ មគ្គដ្ឋោរិយបុគ្គលោ

---

១-អភិធម្មបិដក វិភង្គ លេខ ៨២ ទំព័រ ១៨ ។

ព្រះអរិយបុគ្គលអ្នកតាំងនៅក្នុងមគ្គ ប្រារព្ធអមតធម៌

ក៏លះបង់បាបធម៌បានអស់ ជាឧទាហរណ៍ក្នុងសេចក្ដីនេះ ។

ក្នុងសេចក្ដីនេះគប្បីជ្រាបវិនិច្ឆ័យសូម្បីដោយវិរតិ ដោយប្រការដូចពោលមកដូច្នេះ ។

**ការពោលដោយផល** បាបធម៌មានបាណាតិបាតជាដើម ពួកនោះទាំងអស់ រមែងឱ្យកើតផលគឺទុគ្គតិ និងឱ្យកើតវិបាក ដែលមិនគួរប្រាថ្នា មិនគួរស្រឡាញ់ មិនគួរពេញចិត្តក្នុងសុគតិ ទាំងឱ្យកើតផលមានសេចក្ដីមិនក្ដៀវក្ដាជាដើម ទាំងអនាគត និងបច្ចុប្បន្ន ។ មយ៉ាងទៀត ក្នុងសេចក្ដីនេះ គប្បីជ្រាបវិនិច្ឆ័យ សូម្បីដោយផលតាមន័យជាដើមយ៉ាងនេះថា វិបាករបស់បាណាតិបាតយ៉ាងស្រាលបំផុត កាលកើតជាមនុស្ស ក៏ធ្វើឱ្យជាអ្នកមានអាយុខ្លី(១) ។

ប្រការមួយទៀត ក្នុងសេចក្ដីនេះ ក៏គប្បីជ្រាបវិនិច្ឆ័យ សូម្បីដោយសមុដ្ឋាន វេទនា មូល កម្ម និងផលរបស់ចេតនាវៀរចាកបាណាតិបាតជាដើម ។ ក្នុងចេតនាវៀរចាកនោះ គប្បីជ្រាបដូច្នេះ **វេរមណី** ចេតនាវៀរចាកពួកនេះទាំងអស់ តាំងឡើងដោយសមុដ្ឋាន ៤ គឺ កាយ

---

១-សេចក្ដីពិស្ដារមានសម្ដែងក្នុងបិដកលេខ ៤៨ ទំព័រ ១៨០-១៨២ ។

១ កាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ។ សិក្ខាបទទាំងអស់នោះ នឹងប្រកបដោយសុខវេទនាក្តី ប្រកបដោយអទុក្ខមសុខវេទនាក្តី មានអលោភៈ អទោសៈជាមូលក្តី មានអលោភៈ អទោសៈ និងអមោហៈជាមូលក្តី ។ ក្នុងសេចក្តីនេះ ការវៀរចាក សិក្ខាបទទាំង ៤ ជាកាយកម្ម ការវៀរចាកមុសាវាទ ជាវចីកម្ម តែក៏តាំងឡើងអំពីចិត្តក្នុងខណៈមគ្គចិត្ត សូម្បីការវៀរចាកទាំងពួង ក៏ជាមនោកម្ម ។

ចាណាតិបាតា វេរមណី មានផលជាដើមយ៉ាងនេះ គឺភាពជាអ្នកមានអវយវៈធំតូចពេញបរិបូណ៌ ភាពជាអ្នកមានរាងកាយខ្ពស់សមស្អាត ភាពជាអ្នកមានរាងកាយរហ័សរហួន ភាពជាអ្នកមានជើងទាំងពីរជាន់ស៊ប់ធូន់ស្មើគ្នា ភាពជាអ្នកស្រស់ស្អាត ភាពជាអ្នកទន់ភ្លន់ ភាពជាអ្នកមានចរិយាល្អ ភាពជាអ្នកក្លៀវក្លា ភាពជាអ្នកមានកម្លាំងកាយបរិបូណ៌ច្រើន ភាពជាអ្នកមានសម្តីពីរោះក្បោះក្បាយ ភាពជាអ្នកជាទីស្រឡាញ់របស់មនុស្ស ភាពជាអ្នកមានវាចាមិនមានទោស ភាពជាអ្នកមានបរិស័ទមិនបែកគ្នា ភាពជាអ្នកមិនមានភ័យតក់ស្លុតព្រោះហេតុផ្សេងៗ ភាពជាអ្នកមិនមានសត្រូវមកបៀតបៀន ភាពជាអ្នកមិនស្លាប់ព្រោះសត្រូវ ភាពជាអ្នកមានបរិវារច្រើន ភាពជាអ្នក

មានរូបស្រស់ស្អាត ភាពជាអ្នកមានសណ្ឋានល្អ ភាពជាអ្នកមានរោគតិច ភាពជាអ្នកមិនសោកសៅ ភាពជាអ្នកមិនមានការព្រាត់ប្រាសចាកសត្វ និង សង្ខារជាទីស្រឡាញ់ពេញចិត្ត ភាពជាអ្នកមានអាយុច្រើន ។

អទិន្នាទានា វេរមណី មានផលជាដើមយ៉ាងនេះ គឺភាពជាអ្នក មានធនធានច្រើន ភាពជាអ្នកមានរបស់ប្រើប្រាស់ច្រើន ភាពជាអ្នក រកបានមិនមានទីបំផុត ភាពជាអ្នកធ្វើទ្រព្យមិនទាន់កើតឱ្យកើតឡើង ភាពអ្នកជាមានទ្រព្យគង់វង្សល្អ ភាពជាអ្នកបានភោគទ្រព្យដោយការ ប្រាថ្នាយ៉ាងរហ័ស ភាពជាអ្នកមានភោគៈមិនសាធារណៈដល់ភ័យមាន ព្រះរាជា ចោរ ទឹក ភ្លើង និងទាយាទមិនជាទីស្រឡាញ់ ភាពជាអ្នក ប្រើប្រាស់ទ្រព្យដែលមិនសាធារណៈ ភាពជាអ្នកបានចំពោះនូវទ្រព្យ សម្បត្តិដែលមិនសាធារណៈ ភាពជាអ្នកបាននូវលោកុត្តរសម្បត្តិ ភាព ជាអ្នកមិនដឹងនូវវត្ថុដែលមិនមាន ភាពជាអ្នកនៅជាសុខ ។

អព្រហ្មចរិយា វេរមណី មានផលជាដើមដូច្នេះ គឺភាពជាអ្នក មិនមានសត្រូវ ភាពជាអ្នកជាទីស្រឡាញ់របស់មនុស្សទាំងពួង ភាព ជាអ្នកបានបាយទឹកសំពត់ និងទីដេកជាដើម ភាពជាអ្នកដេកជាសុខ ភាពជា អ្នកភ្ញាក់ឡើងជាសុខ ភាពជាអ្នកផុតភ័យក្នុងអបាយ ភាពជាអ្នកមិន

កើតជាស្ត្រី ឬកើតជាមនុស្សមិនមានភេទ ភាពជាអ្នកមិនក្រោធ ភាពជាអ្នកសម្បូរដោយការគោរព ភាពជាអ្នកមានខន្ធមិនធ្លាក់ចុះ ភាពជាអ្នកមិនមានមុខឱនចុះក្នុងទីប្រជុំ ភាពជាអ្នកជាទីស្រឡាញ់នៃស្ត្រី និងបុរស ភាពជាអ្នកមានឥន្ទ្រិយបរិបូណ៌ ភាពជាអ្នកមានលក្ខណៈបរិបូណ៌ ភាពជាអ្នកមិនមានសេចក្តីសង្ស័យ ភាពជាអ្នកខ្វល់ខ្វាយតិច ភាពជាអ្នកនៅជាសុខភាព ភាពជាអ្នកមិនមានភ័យក្នុងទីទាំងពួង ភាពជាអ្នកមិនមានការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ។

មុសាវាទា វេរមណី មានផលជាដើមយ៉ាងនេះ គឺភាពជាអ្នកមានឥន្ទ្រិយស្រស់ថ្លា ភាពជាអ្នកនិយាយវាចាពីរោះទន់ភ្លន់ ភាពជាអ្នកមានធ្មេញរាបស្មើល្អ ភាពជាអ្នកមិនធាត់ពេក ភាពជាអ្នកមិនស្គមពេក ភាពជាអ្នកមិនតឿពេក ភាពជាអ្នកមិនខ្ពស់ពេក ភាពជាអ្នកមានសម្ផស្សល្អ ភាពជាអ្នកមានក្លិនមាត់ដូចផ្កាឧប្បល ភាពជាអ្នកមានញាតិមិត្តជិតខាងគោរពជឿស្តាប់ ភាពជាអ្នកមានវាចាដែលគួរកាន់យកបាន ភាពជាអ្នកមានអណ្តាតទន់ក្រហមស្រដៀងផ្កាឈូកនិងឧប្បលភាពជាអ្នកមិនចំបែងចិត្ត ភាពជាអ្នកវាចាមិនរបុិលរប៉ូច ។

សុរាមេរយមជ្ជបមាទដ្ឋានាវេរមណី មានផលជាដើមយ៉ាងនេះ គឺ

*ភាពជាអ្នកដឹងច្បាស់បានដោយរហ័សក្នុងករណីយកិច្ចទាំងពួង ទាំងក្នុង អតីត អនាគត និងបច្ចុប្បន្ន ភាពជាអ្នកមានសតិមាំទាំគ្រប់កាល ភាពជាអ្នក មិនច្ឆួត ភាពជាអ្នកមានញាណ ភាពជាអ្នកមិនខ្ជិលច្រអូស ភាពជាអ្នកមិន ល្ងង់ ភាពជាអ្នកមិនគ ភាពជាអ្នកមិនស្រវឹង ភាពជាអ្នកមិនប្រមាទ ភាពជាអ្នកមិនវង្វេង ភាពជាអ្នកមិនតក់ស្លុត ភាពជាអ្នកមិនមានការ អួតអាង ភាពជាអ្នកមិនមានសេចក្តីសង្ស័យ ភាពជាអ្នកនិយាយពាក្យពិត ភាពជាអ្នកនិយាយតែរាំចាមិនញុះញង់ មិនទ្រគោះបោះបោក មិននិយាយលេង ឥតប្រយោជន៍ ភាពជាអ្នកមិនខ្ជិលច្រអូសទាំងថ្ងៃទាំងយប់ ភាពជាអ្នកមាន កតញ្ញូ ភាពជាអ្នកមានកតវេទី ភាពជាអ្នកមិនមានកំណាញ់ ភាពជា អ្នកមានការបរិច្ចាគ ភាពជាអ្នកមានសីល ភាពជាអ្នកស្មោះត្រង់ ភាព ជាអ្នកមិនក្រោធ ភាពជាអ្នកមានហិរិ ភាពជាអ្នកមានឱត្តប្បៈ ភាពជាអ្នក មានទិដ្ឋិត្រង់ ភាពជាអ្នកមានបញ្ញាច្រើន ភាពជាអ្នកប្រាជ្ញ ភាពជាបណ្ឌិត ភាពជាអ្នកឆ្លាតក្នុងវត្ថុដែលជាប្រយោជន៍ និងមិន ជាប្រយោជន៍ ។*

*ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យ សូម្បីដោយសមុដ្ឋាន វេទនា មូល កម្ម និងផលដោយប្រការដូចពោលមកដូច្នេះ ។*

បច្ឆិមបញ្ចសិក្ខាបទវណ្ណនា

## ពណ៌នា ៥ សិក្ខាបទខាងចុង

ពាក្យដែលខ្ញុំពោលទុកថា

យោជេតព្វំ តតោ យុត្តំ បច្ឆិមេសុបិ បញ្ចសុ

អាវេណិកញ្ច វត្តព្វំ ញេយ្យា ហីនាធិតាបិ ចាតិ ។

បន្ទាប់អំពីការពណ៌នា ៥ សិក្ខាបទដើមនោះ ការគួរ គឺបណ្ឌិតគប្បីនាំមកប្រើក្នុង ៥ សិក្ខាបទខាងចុង គួរពោលជាសេចក្ដី និងគួរជ្រាបថា សិក្ខាបទ មានភាពអាក្រក់ជាដើមទុកផង ។

ឥឡូវនេះ នឹងពណ៌នាសេចក្ដីដូចតទៅនេះ ពាក្យណាក្នុងការពណ៌នា ៥ សិក្ខាបទខាងដើម រមែងត្រឹមត្រូវ ពាក្យនោះគួរកាន់យកបន្ទាប់អំពីការពណ៌នាសិក្ខាបទ ៥ ខាងដើមនោះ ហើយយកមកប្រកបក្នុងសិក្ខាបទ ៥ ខាងចុង ។ ក្នុងសេចក្ដីនោះ មានសេចក្ដីអធិប្បាយដូច្នេះថា **ការពោលដោយអារម្មណ៍** ក្នុងសិក្ខាបទមុនៗសុរាមេរយមជ្ជបមាទដ្ឋាន មានសង្ខារ មានរូបាយតនៈជាដើមណាមួយជាអារម្មណ៍យ៉ាងណាក្នុងទីនេះ វិកាលភោជនៈក៏យ៉ាងនោះ គប្បីជ្រាបសេចក្ដីផ្សេងគ្នានៃអារម្មណ៍របស់សិក្ខាបទ ៥ ខាងចុង គ្រប់សិក្ខាបទ

*ដោយន័យនេះ ។* ***ការពោលដោយសមាទាន*** *៥ សិក្ខាបទ ដើម ដែលសាមណេរ ឬឧបាសកសមាទាន រមែងជាអ្នកសមាទានហើយ យ៉ាងណា សិក្ខាបទ ៥ ខាងចុងនេះ ក៏យ៉ាងនោះ ។ សូម្បី****ការពោលដោយអង្គ*** *សេចក្តីផ្សេងគ្នានៃអង្គរបស់ ៥ សិក្ខាបទដើម មានបាណាតិបាតជាដើម ពោលទុកហើយក្នុងទីនោះយ៉ាងណា សូម្បីក្នុងទីនេះក៏យ៉ាងនោះ ។ វិកាលភោជនៈមានអង្គ ៤*[១] *គឺ*

*១. វិកាលោ = កាលខុស*

*២. យាវកាលិកំ = របស់ជាយាវកាលិក*

*៣. អជ្ឈោហរណំ = ការលេបចូលទៅក្នុងបំពង់ក*

*៤. អនុម្មត្តកតា = ភាពជាអ្នកមិនជាមនុស្សឆ្កួត ។*

*គប្បីជ្រាបសេចក្តីផ្សេងគ្នានៃអង្គរបស់សិក្ខាបទ សូម្បីក្រៅនោះដោយទំនងនេះ ។ មួយវិញទៀត* ***ការពោលដោយសមុដ្ឋាន*** *ក្នុងទីនោះ សុរាមេរយមជ្ជបមាទដ្ឋាន មាន ២ សមុដ្ឋាន គឺ កាយ ១ កាយចិត្ត ១ យ៉ាងណា ក្នុងទីនេះ វិកាលភោជនៈក៏យ៉ាងនោះ គប្បីជ្រាបសមុដ្ឋាន*

---

*១-អង្គនៃវិកាលភោជនសិក្ខាបទនេះ យើងតែងឃើញមានតែបី ប៉ុន្តែក្នុងទីនេះ ព្រះអដ្ឋកថាចារ្យពោលថាមាន ៤ ។*

របស់សិក្ខាបទគ្រប់សិក្ខាបទ ដោយន័យដូច្នេះ ។ម្យ៉ាងទៀត ការ **ពោលដោយវេទនា**ក្នុងទីនេះ អទិន្នាទានប្រកបដោយវេទនាទាំង ៣ ណាមួយ ក្នុងទីនេះ វិកាលភោជនៈក៏យ៉ាងនោះ ។ គប្បីជ្រាបការ ប្រកបព្រម**ដោយវេទនា**របស់សិក្ខាបទគ្រប់សិក្ខាបទ ដោយន័យនេះ ។ ម្យ៉ាងទៀត ក្នុងទីនោះ អព្រហ្មចរិយៈ មានលោភៈ និងមោហៈ ជាមូល យ៉ាងណា សូម្បីក្នុងទីនេះ វិកាលភោជនសិក្ខាបទ ក៏យ៉ាងនោះ ។ ចំណែកសិក្ខាបទ ២ ក្រៅពីនោះ គប្បីជ្រាបសេចក្តីផ្សេងគ្នា**ដោយមូល** គ្រប់សិក្ខាបទទាំងអស់ ដោយន័យនេះ ។ ម្យ៉ាងទៀត ក្នុងទីនោះ បាណាតិបាតជាដើម ជាកាយកម្មយ៉ាងណា សូម្បីក្នុងទីនេះ វិកាល-ភោជនៈ ជាដើម ក៏យ៉ាងនោះ ។ ម្យ៉ាងទៀត ជាតរូបរជតប្បដិគ្គហណៈ ជាកាយកម្មក៏មាន ជាវចីកម្មក៏មាន ដោយបរិយាយនៃការប្រព្រឹត្តទៅ និងការកើតឡើង តាមកាយទ្វារជាដើម មិនមែនជាកម្មបថទេ ។ ម្យ៉ាង ទៀត **ការពោលដោយវិរតិ** ក្នុងទីនោះ បុគ្គលកាលលះបង់ រមែងលះ បង់នូវអកុសល មានបាណាតិបាតជាដើមរបស់ខ្លួន ឬរបស់អ្នកដទៃៗ យ៉ាងណា សូម្បីក្នុងទីនេះក៏រមែងលះបង់នូវអកុសល មានវិកាលភោជនៈ ជាដើម ក៏យ៉ាងនោះ ។ ម្យ៉ាងទៀត ការពោលដោយសេចក្តីជាកុសល

*ក៏ដូចគ្នា ។ ក៏ការវៀរចាកសិក្ខាបទ ៥ ខាងដើម មាន ៤ សមុដ្ឋាន គឺ កាយ ១ កាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ គ្រប់ការវៀរចាក សិក្ខាបទទាំងអស់ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនា ក៏មាន មានអលោភៈ អទោសៈជាមូលក៏មាន មានអលោភៈ អទោសៈ អមោហៈជាមូលក៏មាន និងគ្រប់ការវៀរចាក សិក្ខាបទឱ្យកើតផល ដែល គួរប្រាថ្នាមានប្រការផ្សេងៗយ៉ាងណា សូម្បីក្នុងទីនេះក៏យ៉ាងនោះ ។ បន្ទាប់ អំពីការពណ៌នា ៥ សិក្ខាបទដើមនោះ ភាពគួរគឺបណ្ឌិតគប្បីនាំមកប្រើ ក្នុង ៥ សិក្ខាបទខាងចុងគួរពោលជា សេចក្តី និងគួរជ្រាបថា សិក្ខាបទ មានភាពអាក្រក់ ជាដើមទុកផង ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ៥ សិក្ខាបទខាងចុងនោះ ដូចតទៅ៖ បទថា* ***វិកាលភោជនំ*** *បានដល់ ការបរិភោគអាហារកន្លងហួសវេលាថ្ងៃត្រង់ ។ មែនពិត ការបរិភោគ អាហារកន្លងហួសវេលាថ្ងៃត្រង់នោះ ក៏គឺការបរិភោគ អាហារហួសកាល ដែលទ្រង់អនុញ្ញាតទុក ព្រោះដូច្នោះ ទើបលោកហៅថា វិកាលភោជនៈ ចេតនាលះបង់នូវការបរិភោគអាហារក្នុងវេលាវិកាលនោះ ។ ក្នុងបទថា* ***នច្ចគីតវាទិតវិសូកទស្សនំ*** *នេះ ការរាំយ៉ាងណាមួយ ឈ្មោះថា* ***នច្ចៈ*** *។ ការច្រៀងយ៉ាងណាមួយ ឈ្មោះថា* ***គីតៈ*** *។ ការប្រគំយ៉ាងណាមួយ*

ឈ្មោះថា **វាទិតៈ** ។ ការមើលវត្ថុ ដែលជាសឹកសត្រូវ ព្រោះទម្លាយធម៌ចំណែកកុសល ដែលជាបច្ច័យធ្វើឱ្យកើតកិលេស ឈ្មោះថា **វិសូកទស្សនៈ** ឬការមើល ការឃើញ ដែលជាសឹកសត្រូវ ក៏ឈ្មោះថា **វិសូកទស្សនៈ** ។ ការរាំផង ការច្រៀងផង ការប្រគំផង ការមើលវត្ថុដែលជាសឹកសត្រូវផង ឈ្មោះថា **នច្ចគីតវាទិតវិសូកទស្សនៈ** ។ ក៏**វិសូកទស្សនៈ**ក្នុងទីនេះ គប្បីកាន់យកតាមន័យ ដែលព្រះមានព្រះភាគ ព្រះអង្គត្រាស់ទុកក្នុងព្រហ្មជាលសូត្រ ។ មែនពិត ក្នុងព្រហ្មជាលសូត្រនោះ ព្រះមានព្រះភាគ ត្រាស់ទុកថា[១] "ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគភោជនដែលគេឱ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយៗនូវការស្តាប់ និងការមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ មានសភាពយ៉ាងនេះ ។ ឯល្បែងដែលជាសត្រូវដល់កុសលធម៌នោះតើដូចម្តេចខ្លះ ។ គឺល្បែងរាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ មហោស្រពខ្លះ ចម្បាំងស្តេចការតៈនិងព្រះរាមជាដើមខ្លះ គងខ្លះ រគាំងខ្លះ ស្គរមានជ្រុង ៤ ខ្លះ រូបគំនូរខ្លះ ល្បែងជុំដែកខ្លះ ល្បែងរាវខ្លះ ល្បែងលាងឆ្អឹងខ្លះ ដំរីជល់គ្នាខ្លះ សេះប្រខាំគ្នាខ្លះ ក្របីជល់គ្នាខ្លះ

---

១-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៤ ទំព័រ ១៤

គោជល់គ្នាខ្លះ ពពែជល់គ្នាខ្លះ កែះជល់គ្នាខ្លះ មាន់ជល់គ្នាខ្លះ ចាបជល់គ្នាខ្លះ ល្បែងគុនដំបងខ្លះ ប្រដាល់ខ្លះ ចំបាប់ខ្លះ ទីសម្រាប់ច្បាំងគ្នាខ្លះ ទីសម្រាប់រៀបពលខ្លះ លំនៅកងទ័ពខ្លះ ទីមើលសេនាប្រកបដោយអង្គ ៤ ខ្លះ[១] ។ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកកិរិយាស្តាប់ និងការមើលល្បែង ដែលជាសត្រូវដល់កុសលធម៌ មានសភាពដូច្នេះឯង ។

ម្យ៉ាងទៀត ការរាំ ការច្រៀង និងការប្រគំ ដោយន័យដែលបានពោលមកហើយប៉ុណ្ណោះ ជាសត្រូវ ឈ្មោះថា **នច្ចគីតវាទិតវិសូកទស្សនៈ** ការមើល ការរាំ ការច្រៀង និងការប្រគំដែលជាសឹកសត្រូវទាំងនោះ ឈ្មោះថា **នច្ចគីតវាទិតវិសូកទស្សនៈ** ចេតនាលះបង់នូវការរាំ ការច្រៀង និងការប្រគំ ដែលជាសឹកសត្រូវនោះ កាលគួរនឹងពោលថា **ទស្សនសវនា** សូម្បីការស្តាប់ក៏លោកហៅថា **ទស្សនៈ** ដូចគ្នា ដូចការចាប់អារម្មណ៍ សូម្បីមិនមែនប្រព្រឹត្តទៅតាមចក្ខុទ្វារ លោកក៏ហៅថា ទស្សនៈ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា "**សោ ច ហោតិ មិច្ឆា-ទិដ្ឋិកោ វិបរីតទស្សនោ** បុគ្គលនោះ គឺជាបុគ្គលជាមិច្ឆាទិដ្ឋិ ជាអ្នក

---

១-សេនាដំរី ១ សេនាសេះ ១ សេនារទេះ ១ សេនាថ្មើរជើង ១ ។

មានការឃើញខុស”[១] ការប្រព្រឹត្តល្មើសក្នុងសិក្ខាបទនេះ រមែងមាន ដល់អ្នកចូលទៅមើល ។ ចំណែកអ្នកដើរទៅជួប ឬឃើញចំពោះដែលមកប្រាកដ ក្នុងឱកាសដែលឈរ អង្គុយ ដេកក៏មាន ដែលជាសេចក្តីសៅហ្មង មិនមែនប្រព្រឹត្តល្មើស ក្នុងសិក្ខាបទនេះទេ ។ ការច្រៀងសូម្បីអាស្រ័យធម្មៈ ក៏មិនគួរ តែធម្មៈដែលអាស្រ័យការច្រៀង គប្បីជ្រាបថាសមគួរ ។

ផ្កាឈើជាដើម គប្បីប្រើប្រកបស្មើដោយការទ្រទ្រង់ជាដើម ។ ក្នុងសិក្ខាបទនោះ បទថា **មាលា** បានដល់ផ្កាឈើប្រភេទណាមួយ ។ ពាក្យថា **វិលេបនៈ** បានដល់របស់យ៉ាងណាមួយ ដែលគេកិនចាត់ទុក ដើម្បីលាប ។ ក្រៅអំពីនោះ គ្រឿងក្រអូបមានម្សៅ និងផ្សែងជាដើមគ្រប់យ៉ាង ឈ្មោះថា គ្រឿងក្រអូប ។ គ្រឿងក្រអូបគ្រប់យ៉ាងនោះ ប្រើតាក់តែងប្រដាប់មិនគួរតែប្រើជាថ្នាំក៏គួរ ។ តែគ្រឿងក្រអូប ដែលគេនាំមកដើម្បីបូជា សម្រាប់អ្នកទទួលទុករមែងមិនគួរ មិនថាដោយបរិយាយណាៗទេ ។ ពាក្យ **ឧច្ចាសយនៈ** បានដល់ទីដេកខ្ពស់ហួសប្រមាណ លោកហៅថា **ទីដេកខ្ពស់** ។ ទីដេកជាអកប្បិយៈ និងគ្រឿងក្រាលទីដេកជាអកប្បិយៈ

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត បិដកលេខ ៤០ ទំព័រ ៧៥ ។

លោកហៅ **មហាសយនំ** ។ ទីដេកសូម្បីទាំងពីរយ៉ាងនោះ សម្រាប់អ្នកទទួលទុករមែងមិនគួរ មិនថាដោយបរិយាយណាៗ ។ ពាក្យថា **ជាតរូបៈ** បានដល់ មាស ។ ពាក្យថា **រជតៈ** បានដល់ កហាបណៈ គឺ របស់ណាៗ មានមាសកលោហៈ មាសកឈើ និងមាសកជ័រជាដើម ដែលគេប្រើផ្លាស់ប្តូរគ្នាក្នុងប្រទេសនោះៗ ។ មាស និងប្រាក់ទាំងពីរនោះ ឈ្មោះថា **ជាតរូបរជតៈ** ។ ការទទួលយកមាស និងប្រាក់នោះ ឈ្មោះថា **បដិគ្គហៈ** ការទទួល ។ ការទទួលនោះ រមែងមិនគួរ មិនថាបរិយាយណាៗ ។

គប្បីជ្រាបសិក្ខាបទ ដូចពោលមកដូច្នេះ ។

សិក្ខាបទទាំង ១០ នេះ បុគ្គលសមាទានដោយឆន្ទៈ វិរិយៈ ចិត្តៈ វិមង្សា យ៉ាងថមថយ ក៏ឈ្មោះថា សមាទានយ៉ាងថមថយ ។ ដោយឆន្ទៈ វិរិយៈ ចិត្តៈ វិមង្សា យ៉ាងកណ្តាល ក៏ឈ្មោះថា សមាទានយ៉ាងកណ្តាល ។ ដោយឆន្ទៈ វិរិយៈ ចិត្តៈ វិមង្សា យ៉ាងប្រណីត ឈ្មោះថា សមាទានយ៉ាងប្រណីត ។ ន័យម្យ៉ាងទៀត សិក្ខាបទទាំង ១០ នេះ សៅហ្មង ដោយតណ្ហា ទិដ្ឋិ មានៈ ឈ្មោះថា សមាទានយ៉ាងអាក្រក់ ។ ដែលមិនសៅហ្មង ឈ្មោះថា សមាទានយ៉ាងកណ្តាល ។ បញ្ញាជាមួយនិងការសមាទានសិក្ខាបទនោះៗ ឈ្មោះថា សមាទានយ៉ាងប្រណីត ។ ន័យម្យ៉ាងទៀត សិក្ខាបទទាំងនោះ ដែលសមាទាន ដោយកុសលចិត្តជា

ញាណវិប្បយុត្ត ប្រាសចាកបញ្ញា ឈ្មោះថា សមាទានយ៉ាងអាក្រក់ ។ ដែលសមាទានដោយកុសលចិត្តជា ញាណសម្បយុត្ត ប្រកបដោយបញ្ញាជាសសង្ខារិក ឈ្មោះថា សមាទានយ៉ាងកណ្តាល ។ ដែលសមាទានដោយកុសលចិត្តជាញាណសម្បយុត្ត ជាអសង្ខារិក ឈ្មោះថាសមាទានយ៉ាងប្រណីត ។ គប្បីជ្រាបថាសិក្ខាបទ មានអាក្រក់ជាដើម ដូចពោលមក ដូច្នេះ ។

មាតិកាឯណា ដែលខ្ញុំលើកជាបទតាំងទុក ដើម្បីពណ៌នាបាឋៈនៃសិក្ខាបទ ដោយគាថា ៦ គាថាថា សិក្ខាបទនេះ អ្នកណាពោល ពោលទុកទីណា ពោលកាលណា ពោលព្រោះហេតុណា ដូច្នេះជាដើម មាតិកានោះ ដែលខ្ញុំប្រកាសដោយអត្ថដោយពាក្យមានប្រមាណត្រឹមតែប៉ុណ្ណោះឯង ។

បរមត្ថជោតិកាយ ខុទ្ទកបាឋដ្ឋកថាយ

សិក្ខាបទវណ្ណនា និដ្ឋិតា

**ពណ៌នាសិក្ខាបទ**

**នៃ**

**អដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះ បរមត្ថជោតិកា ចប់ ។**

## ៣-ទ្វត្តឹសាការវណ្ណនា

**ពណ៌នាអំពីអាការៈ ៣២ ប្រការ**

### បទសម្ពន្ធវណ្ណនា

**ពណ៌នាការសម្ព័ន្ធនៃបទ**

*កម្មដ្ឋាន គឺកាយគតាសតិនេះឯណា ដែលពួកអន្យតិ្ថិយទាំងពួង មិនធ្លាប់ឱ្យប្រព្រឹត្តទៅឡើយក្រៅពុទ្ធកាល ដើម្បីសេចក្ដីបរិសុទ្ធនៃអាសយញ្ញាណ និងដើម្បីចិត្តការនៃរបស់កុលបុត្រ ដែលមានប្រយោគដ៏បរិសុទ្ធដោយសិក្ខាបទ ១០ យ៉ាងនេះ ដែលតាំងនៅក្នុងសីល ព្រះមានព្រះភាគទ្រង់សរសើរហើយ ដោយអាការៈដ៏ច្រើនក្នុងព្រះសូត្រនោះៗយ៉ាងនេះថា៖*

*"ម្នាលភិក្ខុទាំងឡាយ ធម៌មួយយ៉ាងដែលបុគ្គលបានចម្រើនហើយ បានសន្សំរឿយៗហើយ តែងប្រព្រឹត្តទៅដើម្បីសេចក្ដីសង្វេគច្រើន តែងប្រព្រឹត្តទៅដើម្បីសេចក្ដីចម្រើនច្រើន តែងប្រព្រឹត្តទៅដើម្បីសេចក្ដីក្សេមចាកយោគៈច្រើន តែងប្រព្រឹត្តទៅដើម្បីសតិ និងសម្បជញ្ញៈ តែងប្រព្រឹត្តទៅដើម្បីបាននូវញាណ-ទស្សនៈ តែងប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្នតែងប្រព្រឹត្តទៅដើម្បីធ្វើឱ្យជាក់ច្បាស់នូវវិជ្ជា វិមុត្តិ និងផល[១] ។*

*ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាមិនបរិភោគកាយគតាសតិ ពួកភិក្ខុនោះឈ្មោះថាមិនបរិភោគនូវព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាបរិភោគនូវកាយគតាសតិ ពួកភិក្ខុនោះទើបឈ្មោះថា បរិភោគនូវព្រះនិព្វាន ។*

---

*១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត បិដកលេខ ៤០ ទំព័រ ៩៥ ។*

ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលភិក្ខុពួកណាមិនបរិភោគ ព្រះនិព្វាន ក៏ឈ្មោះថា ពួកភិក្ខុទាំងនោះមិនបរិភោគដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយ-គតាសតិ ដែលភិក្ខុពួកណាបរិភោគហើយ ព្រះនិព្វាន ក៏ឈ្មោះថា ពួកភិក្ខុនោះបរិភោគដែរ ។

ម្នាលភិក្ខុទាំងឡាយ កាយគតាសតិរបស់ពួកភិក្ខុណាសាបសូន្យហើយ ព្រះនិព្វានរបស់ពួកភិក្ខុនោះ ក៏ឈ្មោះថា សាបសូន្យដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិ របស់ពួកភិក្ខុណាមិនសាបសូន្យ ព្រះនិព្វានរបស់ពួកភិក្ខុនោះ ក៏ឈ្មោះថា មិនសាបសូន្យដែរ ។

ម្នាលភិក្ខុទាំងឡាយកាយគតាសតិដែលពួកភិក្ខុណាបោះបង់ហើយព្រះនិព្វាន ក៏ឈ្មោះថា ពួកភិក្ខុនោះបោះបង់ដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិ ដែលពួកភិក្ខុណាប្រារព្ធហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះ ប្រារព្ធដែរ[១] ។

ដូច្នេះហើយទ្រង់សម្ដែងទុកជា ១៤ បព្វៈ គឺអានាបានបព្វៈ ឥរិយាបថបព្វៈ ចតុសម្បជញ្ញបព្វៈ បដិកូលមនសិការបព្វៈ ធាតុមនសិការបព្វៈ សីវថិកាបព្វៈ ៩ ដោយន័យថា៖

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត បិដកលេខ ៤០ ទំព័រ ១០០-១០១

ម្នាលភិក្ខុទាំងឡាយ កាយគតាសតិ ដែលបុគ្គលបានចម្រើនដូចម្តេច បានធ្វើឱ្យច្រើនដូចម្តេច ទើបមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី...ដូច្នេះជាដើម[១] ។

ឥឡូវនេះ និទ្ទេសនៃការចម្រើនកាយគតាសតិកម្មដ្ឋាននោះ មកតាមលំដាប់ហើយក្នុងនិទ្ទេសនោះ ។ ខ្ញុំពោលថា បណ្តាបព្វៈទាំងឡាយនោះ បព្វៈ ៣ នេះ គឺឥរិយាបថបព្វៈ ១ ចតុសម្បជញ្ញបព្វៈ ១ ធាតុមនសិការបព្វៈ ១ ដោយអំណាចនៃវិបស្សនា ។ សីវថិកាបព្វៈទាំង ៩ ពោលដោយអំណាចអាទីនវានុបស្សនាទុកក្នុងវិបស្សនាញាណប៉ុណ្ណោះ ។ ចំណែកឯសមាធិភាវនា ក្នុងឧទ្ធុមាតកអសុភៈជាដើមក្នុងនិទ្ទេសនោះ ដែលគប្បីប្រាថ្នាខ្ញុំក៏ប្រកាសទុកដោយពិស្តារហើយក្នុងអសុភភាវនានិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គទាំងនោះ ។ ២ បព្វៈនេះ គឺអនាបានបព្វៈ ១ និងបដិកូលមនសិការបព្វៈ ១ ក៏ពោលដោយអំណាចសមាធិ ។ បណ្តា ២ បព្វៈនោះ អនាបានបព្វៈ ជាកម្មដ្ឋាន មួយផ្នែកដោយពិត ដោយអនាបានស្សតិ ។ ចំណែកទ្វត្តិង្សាការកម្មដ្ឋាននោះឯណា ជាបរិយាយនៃភាវនាមួយរបស់កាយគតាសតិ ដែលព្រះមានព្រះភាគទ្រង់សម្តែងសង្គ្រោះខួរក្បាលទុក ដោយខួរក្នុងឆ្អឹងក្នុងនិទ្ទេសនោះៗ យ៉ាងនេះថា ៖

"ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណា ឃើញច្បាស់នូវកាយនេះឯង ខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក ដែល

---

១-សុត្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ បិដកលេខ ២៦ ទំព័រ ៣៧៧

មានស្បែកបិទបាំងជុំវិញ ពេញទៅដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះ ថាក្នុងកាយនេះមានសក់ រោម ។ល។មូត្រ”[១] ដូច្នេះ ។ ខ្ញុំនឹងពណ៌នានូវទ្វត្តិង្សាការកម្មដ្ឋាន ដូចតទៅនេះ៖

បណ្ដាបទទាំងនោះ បទថា អត្ថិ ប្រែថា រមែងមាន ។ បទថា **ឥមស្មឹ** សេចក្ដីថា ដែលពោលថា តាំងអំពីបាតជើងឡើងទៅ និងអំពីចុងសក់ចុះមក មានស្បែកព័ទ្ធដោយជុំវិញ ពេញដោយរបស់មិនស្អាតមានប្រការផ្សេងៗ ។ បទថា កាយេ បានដល់ក្នុងសរីរៈ ។ មែនពិត **សរីរៈ** ហៅថា **កាយ** ព្រោះសន្សំរបស់មិនស្អាត ឬព្រោះជាទីចម្រើនលូតលាស់នៃរបស់ផ្សេងៗ មានសក់ជាដើម ដែលគួរខ្ពើម និងរោគទាំងឡាយមានរោគភ្នែកជាដើម ។ បទថា កេសា ។ល។ មុត្តំ គឺអាការៈ ៣២ មានសក់ជាដើមទាំងនេះក្នុងទ្វត្តិង្សាការនេះ គប្បីជ្រាបសេចក្ដីសម្ពន្ធយ៉ាងនេះថា សក់មាននៅក្នុងកាយនេះ រោមមាននៅក្នុងកាយនេះជាដើម ។ ត្រាស់អ្វីទុកដោយទ្វត្តិង្សាការកម្មដ្ឋាននោះ ត្រាស់ទុកថា អ្នកណាកាលពិចារណានោះ សូម្បីដោយអាការៈគ្រប់យ៉ាងក្នុងកឡេវរៈ[២] រាងកាយមានខ្នាតប្រមាណមួយព្យាមប៉ុណ្ណោះ គឺខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុង

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ បិដកលេខ ២៦ ទំព័រ ៣៨០

២-ក្នុងអភិធានប្បទីបិកា ទំព័រ ៩៩ ថា **កឡេវរៈ** ស្មើ **តនុ** ប្រែថា រាងកាយ ។ ក្នុងវចនានុក្រមបាលី-អង់គ្លេស ទំព័រ ២០០ ប្រែថា រាងកាយដែលស្លាប់ សាកសព គ្រោងឆ្អឹង ដូចក្នុងវចនានុក្រមបាលី-ថៃ ច្បាប់ភូមិពលោភិក្ខុ ទំព័រ ១៤ បោះពុម្ព ព.ស ២៥៣៥ ដែរ ។

សក់ចុះមក រុំព័ទ្ធដោយស្បែកជុំវិញ រមែងមិនឃើញអ្វីមិនថា កែវមុក្តា កែវមណី កែវពិទូរ្យ ក្រស្នា ចន្ទន៍ ម្សៅឈ្ពុងជាដើម សូម្បីខាតតូចថា ស្អាត តាមពិតរមែងឃើញកាយផ្សេងដោយសក់ រោមជាដើម ដែលមានក្លិនស្អុយ គួរខ្ពើមយ៉ាងក្រៃលែង មិនមានសិរី គួរមើលឡើយមានប្រការផ្សេងៗថា មិនស្អាតតែម្យ៉ាង ។

ពណ៌នាដោយការសម្ព័ន្ធនៃបទក្នុងវុត្តិវិធានការកម្មដ្ឋាននេះប៉ុណ្ណោះ ។

## អសុភភាវនា

គប្បីជ្រាបការពណ៌នាវុត្តិវិធានការកម្មដ្ឋាននោះ ដោយអំណាចអសុភភាវនាដូចតទៅនេះ ។

ជាលំដាប់ដំបូង កុលបុត្រដែលផ្តើមបំពេញកម្មដ្ឋាន ជាអ្នកតាំងនៅក្នុងសីល ផ្សេងដោយបាណាតិបាតាវេរមណីសិក្ខាបទ ជាដើមយ៉ាងនេះហើយ មានប្រយោគដ៏បរិសុទ្ធ បំណងនឹងប្រកបរឿយៗនូវអនុយោគៈ គឺការចម្រើនកម្មដ្ឋានដោយចំណែកវុត្តិវិធានការ គឺដើម្បីត្រាស់ដឹងនូវសេចក្តីបរិសុទ្ធនៃអាសយញ្ញាណ កុលបុត្រនោះ រមែងមានកង្វល់ ១០ ប្រការ គឺកង្វល់ដោយលំនៅ ដោយត្រកូល ដោយលាភ ដោយគណៈ ដោយការងារ ដោយការធ្វើដំណើរ ដោយញាតិ ដោយការរៀនគម្ពីរ ដោយរោគ និងដោយឥទ្ធិឫទ្ធិឬការកង្វល់ដោយកេរ្តិ៍ឈ្មោះ ។ កាលបើដូច្នោះ កុលបុត្រនេះ ក៏ត្រូវកាត់កង្វល់ទាំង ១០ ប្រការនោះចេញដោយវិធីយ៉ាងនេះ គឺដោយការលះទំនាក់ទំនងក្នុងអាវាស ត្រកូល លាភ គណៈ ញាតិ

និងកេរ្តិ៍ឈ្មោះ ដោយការមិនខ្វល់ខ្វាយក្នុងការងារ ការធ្វើដំណើរ ការរៀនគម្ពីរ និងដោយការព្យាបាលរោគ កាលបើដូច្នោះ កុលបុត្រដែលកាត់កង្វល់បានហើយ មិនកាត់ការត្រេកអរក្នុងនេក្ខម្មៈ កំណាត់ការបដិបត្តិដុសខាត់ដល់ទីបំផុត មិនលះបង់អាចារៈ ផ្អែកខាងវិន័យសូម្បីតិចតួច ក៏គប្បីចូលទៅរកអាចារ្យដែលឱ្យកម្មដ្ឋាន ដែលជាអ្នកប្រកបដោយអាគមៈ (បរិយត្តិ) និង អធិគមៈ (បដិបត្តិ និង បដិវេធ) ឬប្រកបដោយគុណសម្បត្តិយ៉ាងណាមួយ អំពីអាគមៈ និងអធិគមៈនោះ ដោយវិធីដ៏សមរម្យដល់ព្រះវិន័យ ហើយគប្បីប្រាប់ពីបំណងរបស់ខ្លួន ដល់អាចារ្យនោះ ដែលខ្លួនធ្វើឱ្យលោកមានចិត្តត្រេកអរដោយវត្តសម្បទា ។ អាចារ្យនោះ គប្បីដឹងប្រភេទនៃនិមិត្ត អជ្ឈាស្រ័យចរិយា និងអធិមុត្តិរបស់កុលបុត្រនោះ ប្រសិនបើកម្មដ្ឋាននោះជារបស់គួរសម កាលបើដូច្នោះ កុលបុត្រនោះសូម្បីមានបំណងនឹងនៅក្នុងវិហារដែលខ្លួននៅ តពីនោះ ក៏គប្បីឱ្យកម្មដ្ឋានដោយសង្ខេប ។ ប្រសិនបើ កុលបុត្រនោះ បំណងនៅក្នុងវិហារដទៃ ក៏គប្បីប្រាប់កម្មដ្ឋានពិស្តារ ព្រមទាំងសេចក្តីដែលគួរធ្វើមុន ដោយប្រាប់សេចក្តីដែលគួរលះ និងសេចក្តីដែលគួរកំណាត់ដឹងជាដើម ព្រមទាំងប្រភេទចរិត ដោយប្រាប់កម្មដ្ឋាន ដែលសមរម្យដល់រាគចរិតជាដើម ។ កុលបុត្រនោះ កាលរៀនកម្មដ្ឋានព្រមដោយ

សេចក្តីដែលគួរធ្វើមុនទាំងប្រភេទនោះ ហើយលាអាចារ្យ វៀរចាកសេនាសនៈ ១៨ ប្រភេទ ដែលលោកពោលថា គួរវៀរចាកយ៉ាងនេះថា ៖

អាវាសធំ អាវាសថ្មី អាវាសចាស់ អាវាសជិតផ្លូវ អាវាសជិត
អណ្តូងថ្ម អាវាសមានស្លឹកឈើ អាវាសមានផ្កាឈើអាវាស
មានផ្លែឈើអាវាសដែលមនុស្សប្រាថ្នា អាវាសដែលជិតនគរ
អាវាសដែលជិតមនុស្សចូលទៅកាត់ឈើអាវាសដែលជិត
ស្រែចម្ការអាវាសដែលមានអារម្មណ៍ជាសត្រូវអាវាស
ដែលជិតកំពង់ អាវាសដែលជិតជាយដែនអាវាសមានសីមា
អាវាសដែលមិនទីសប្បាយនិងអាវាសមិនមានកល្យាណមិត្ត
បណ្ឌិតស្គាល់សេនាសនៈ១៨ប្រភេទដូច្នេះហើយគប្បីវៀរឱ្យឆ្ងាយ
ដូចមនុស្សដើរផ្លូវវៀរចាកភ័យចំពោះមុខដូច្នោះ[១] ។ ហើយចូលទៅកាន់

សេនាសនៈប្រកបដោយអង្គ ៥ ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ យ៉ាងនេះថា ៖

ម្នាលភិក្ខុទាំងឡាយចុះសេនាសនៈប្រកបដោយអង្គ ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេនាសនៈក្នុងលោកនេះ មិនឆ្ងាយពេក មិនជិតពេក ល្មម

---

១-សេចក្តីពិស្តារ មានក្នុងវិសុទ្ធិមគ្គ បាលីខ្មែរ ភាគ ១ ទំព័រ ២៣៣ ត្រង់បឋវីកសិណនិទ្ទេស ។

ទៅមកស្រួល មិនកុះករដោយមនុស្សក្នុងវេលាថ្ងៃ មិនសូវមានសំឡេង មិនសូវគឹកកងក្នុងរាត្រីមិនសូវមានសម្ផស្សដោយរបោមមូសខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំ ១ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារកើតឡើងដល់ភិក្ខុដែលនៅក្នុងសេនាសនៈនោះ ដោយមិនលំបាក ១ ពួកភិក្ខុជាថេរៈដែលនៅក្នុងសេនាសនៈនោះ ជាពហុស្សូត ចេះចាំនូវនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ១ ភិក្ខុចូលទៅរកភិក្ខុជាថេរៈទាំងនោះម្តងៗហើយសួរប្រឹក្សាថា បពិត្រលោកដ៏ចម្រើន រឿងនេះតើដូចម្តេច សេចក្តីអធិប្បាយនៃរឿងនេះតើដូចម្តេច ១ លោកដ៏មានអាយុទាំងនោះ រមែង ពន្យល់រឿងដែលមិនទាន់ច្បាស់លាស់ផង ធ្វើឱ្យងាយនូវរឿងដែលជ្រៅផង បន្ទោបង់នូវសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីសង្ស័យច្រើនប្រការផង ១ ។ ម្នាលភិក្ខុទាំងឡាយ សេនាសនៈប្រកបដោយអង្គ ៥ យ៉ាងនេះឯង[១] ។

ភិក្ខុកាលអាស្រ័យនូវសេនាសនៈ មានសភាពបែបនេះ ពិចារណាទោសក្នុងកាមទាំងឡាយ និងអានិសង្សក្នុងនេក្ខម្មៈ ដោយធ្វើកិច្ចគ្រប់យ៉ាងឱ្យសម្រេចហើយញ៉ាំងចិត្តឱ្យជ្រះថ្លាដោយការរលឹកដល់ព្រះសម្មាសម្ពុទ្ធ ដែលត្រាស់ដឹង

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ទសកនិបាត បិដកលេខ ៥០ ទំព័រ ៣៣-៣៤ ។

ល្អហើយព្រះធម៌ជាធម៌ដ៏ល្អ និងព្រះសង្ឃជាអ្នកប្រតិបត្តិល្អហើយ មិនលះឧគ្គហកោសល[១]៧យ៉ាង ដែលលោកពោលទុកយ៉ាងនេះថា៖ “អ្នកប្រាជ្ញឆ្លាតក្នុងការរៀនសូត្រ ៧ យ៉ាងគឺ ដោយវាចា ដោយចិត្ត ដោយវណ្ណៈ ដោយសណ្ឋាន ដោយទិស ដោយឱកាស និងដោយបរិច្ឆេទ ហើយមានមនសិការកោសល គឺភាពឆ្លាតដោយការយកចិត្តទុកដាក់ ១០ យ៉ាង ដែលលោកពោលទុកយ៉ាងនេះគឺ ដោយលំដាប់ ដោយមិនឆាប់ពេក ដោយមិនយឺតពេក ដោយការការពារភាពរាយមាយ ដោយល្មើសបញ្ញត្ត ដោយបណ្តោយលំដាប់ ដោយអប្បនា ដោយសុត្តន្តៈទាំង ៣[២] ទើបគួរផ្តើមចម្រើនទុត្តិង្សាការ ដោយការមិនលះបង់នូវមនសិការកោសលនោះ ។ មែនពិត ការចម្រើនទុត្តិង្សាការ ដោយអាការៈគ្រប់យ៉ាង រមែងសម្រេចដល់អ្នកផ្តើម ដូចពោលមកនេះ មិនសម្រេចដោយប្រការដទៃឡើយ ។

---

១-បរមត្ថទីបនី ថា **ឧគ្គហកោសលន្តិ ភាវនាកម្មំ អារព្ភិតុកាមេន ភិក្ខុនា អាចរិយស្ស សន្តិកេ សព្វស្ស កម្មដ្ឋានវិធានស្ស ឧគ្គហណំ ឧគ្គហោ** ប្រែថា ឧគ្គហៈ គឺភិក្ខុអ្នកមានប្រាថ្នានូវភាវនាកម្ម ហើយរៀនយក គឺថាកាន់យកនូវវិធាននៃកម្មដ្ឋានទាំងពួងក្នុងសំណាក់លោកអាចារ្យ ឈ្មោះថា **ឧគ្គហកោសល** ។

២-សុត្តន្ត ៣ គឺ អធិចិត្តសូត្រ សីតិភាវសូត្រ និង ពោជ្ឈង្គកោសលសូត្រ ។ សេចក្តីពិសារសម្តែងក្នុងគម្ពីរ វិសុទ្ធិមគ្គ ភាគ ២ ទំព័រ ៤៧៨-៤៨១ បាលី-ខ្មែរ បោះពុម្ព ព.ស ២៥៤០ ។

ក្នុងការចម្រើនទ្វត្តិង្សាការនោះ ភិក្ខុទទួល**តចបញ្ចកកម្មដ្ឋាន**[១]មុនជាខាងដើម ពោលដោយព្រះត្រៃបិដក កាលតចបញ្ចកកម្មដ្ឋានស្ទាត់ជំនាញ ដោយអនុលោម តាមន័យថា កេសា លោមា ជាដើម ស្ទាត់ជំនាញដោយបដិលោម តាមន័យថា តចោ ទន្តា ជាដើម គប្បីចម្រើនអស់កន្ទះខែ តាមវាចាដើម្បីកាត់សេចក្តីកង្វល់ ដែលរាយមាយចេញទៅខាងក្រៅ ដោយអនុលោម និងបដិលោម តាមន័យទាំង ២ នោះឯង ដើម្បីឱ្យស្ទាត់បាលី និងតាមផ្លូវចិត្ត ដើម្បីកំណត់សភាវៈនៃចំណែករាងកាយជាអារម្មណ៍ ។ មែនពិត ការចម្រើនតាមវាចានូវតចបញ្ចកកម្មដ្ឋាននោះ កាត់វិតក្កដែលរាយមាយខាងក្រៅបានហើយ រមែងជាបច្ច័យដល់ការចម្រើនតាមវាចា ព្រោះស្ទាត់បាលីហើយ ការចម្រើនផ្លូវចិត្ត រមែងជាបច្ច័យដល់ការកំណត់អសុភៈ វណ្ណៈ និងលក្ខណៈ ចំណែកណាមួយ កាលបើដូច្នោះដោយន័យនោះក៏គប្បីចម្រើននូវវក្កបញ្ចកកម្មដ្ឋាន (កម្មដ្ឋានមានវក្កជាគម្រប់ ៥ ) អស់កន្ទះខែ តពីនោះ ទើបចម្រើននូវតចបញ្ចកកម្មដ្ឋាន និងចម្រើននូវវក្កបញ្ចកកម្មដ្ឋាន ទាំង ២ នោះអស់កន្ទះខែ តពីនោះ ទើបចម្រើននូវបប្ផាសបញ្ចកកម្មដ្ឋានអស់កន្ទះខែ តពីនោះក៏ចម្រើនទាំង ៣ បញ្ចកៈ នោះអស់កន្ទះខែ កាលបើដូច្នោះក៏គប្បីបន្ថែម មត្ថលុង្គំ ដែលមិនបានត្រាស់ទុកក្នុងវគ្គក្រោយទុកក្នុង ៣ ពួកនេះ ដើម្បីចម្រើនរួមគ្នា និងអាការៈនៃបឋវីធាតុទាំងឡាយហើយចម្រើន មត្ថលុង្គំ

---

១- **តចបញ្ចកកម្មដ្ឋាន** មានន័យថា កម្មដ្ឋាន ដែលមានស្បែកជាគម្រប់ ៥ ។

អស់កន្លះខែ តពីនោះ ក៏ចម្រើនបញ្ចកៈ និងចតុក្កៈអស់កន្លះខែ មេទចក្កៈ[1] កន្លះខែ តពីនោះ ក៏ចម្រើនបញ្ចកៈ និងចតុក្កៈរួមគ្នា និងមេទចក្កៈកន្លះខែ មុត្តចក្កៈ កន្លះខែ តពីនោះ ក៏ចម្រើនទ្វត្តិង្សាការទាំងអស់អស់កន្លះខែ គប្បីចម្រើនកំណត់វណ្ណៈ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ ៦ ខែ ដូចពោលមកនេះ ។ សេចក្តីនេះ លោកពោលសំដៅដល់បុគ្គលដែលមានបញ្ញាថ្នាក់កណ្តាល ចំណែកបុគ្គលអ្នកមានបញ្ញាទន់ខ្សោយ គប្បីចម្រើនអស់មួយជីវិត អ្នកមានបញ្ញាមុតស្រួច ការចម្រើនរមែងសម្រេចបានមិនយូរឡើយ ។

## កេសា = **សក់**

ក្នុងសេចក្តីនេះ អ្នកសួរពោលថា ភិក្ខុដែលផ្តើមកម្មដ្ឋាននេះ កំណត់ទ្វត្តិង្សាការនេះដោយវណ្ណៈជាដើមយ៉ាងណា?សេចក្តីពិត ភិក្ខុផ្តើមកម្មដ្ឋាននេះ កាលចម្រើនទ្វត្តិង្សាការដោយការចែកជា **តចបញ្ចកៈ**ជាដើម ដោយន័យថា ក្នុងកាយនេះមានសក់ដូច្នេះជាដើម រមែងកំណត់សក់ជាវត្ថុដូចដែលភិក្ខុនេះឃើញហើយ ដោយវណ្ណៈថាមានពណ៌ខ្មៅ ។ កំណត់សក់ជារបស់មូលវែង ដោយសណ្ឋានថាដូចជាដងជញ្ជីង ។ ព្រោះហេតុតែក្នុងកាយនេះ លើពោះឡើងទៅហៅថា **ទិសខាងលើ** ក្រោមពោះចុះមក ហៅថា **ទិសខាងក្រោម** ដូច្នោះ ទើប

---

១-**មេទចក្កៈ** កម្មដ្ឋាន មានញើសជាគម្រប់ ៦ ។

កំណត់ទិសថា កើតក្នុងទិសខាងលើនៃកាយនេះ ។ កំណត់ដោយឱកាសថា កើតត្រង់លលាដ៍ក្បាលជុំវិញត្រចៀក និង ក ។ កំណត់ដោយសក់នោះថា សក់មិនដឹងថា វាកើតនៅលើស្បែកក្បាល សូម្បីស្បែកក្បាលក៏មិនដឹងថា សក់កើតនៅលើវា ប្រៀបដូចស្មៅកុណ្ឌៈ ដែលកើតលើកំពូលដំបូក មិនដឹងថា វាកើតនៅលើកំពូលដំបូកទេ សូម្បីកំពូលដំបូកក៏មិនដឹងថា ស្មៅកុណ្ឌៈកើតនៅលើវា ។ ដូច្នោះកំណត់ថា តាមពិតសក់ទាំងនេះ វៀរចាកការត្រិះរិះ និងការពិចារណាហើយ ជាធម៌មិនមានចេតនា (ចិត្ត) ជាអព្យាកតៈ សូន្យទទេ ជារបស់បដិកូលមានក្លិនស្អុយ គួរខ្ពើមយ៉ាងក្រៃលែង មិនមែនសត្វ មិនមែនបុគ្គល ។ កាលបើពោលដោយបរិច្ឆេទសក់មានការកំណត់ ២ យ៉ាងដោយអំណាចសភាគៈ១វិសភាគៈ១ ។ បណ្តាការកំណត់ ២ យ៉ាងនោះ ការកំណត់សភាគៈ គឺសក់មានស្បែកខាងក្រោម ដែលជាទីតាំង និងដោយគល់របស់ខ្លួន ដែលចូលទៅក្នុងស្បែកនោះប្រមាណប៉ុនចុងអង្កាម តាំងនៅខាងលើដោយអាកាស ខាងទទឹងដោយសក់ និងសក់ និងការកំណត់ដោយវិសភាគៈ គឺសក់មិនមែនជាអាការៈ ៣១ ដ៏សេសអាការៈ ៣១ ដ៏សេសក៏មិនមែនជាសក់ ។ ការកំណត់សក់ ដោយវណ្ណៈជាដើមមានប្រការដូចពោលមកហើយយ៉ាងនេះ ។

លោមា=រោម

ក្នុងអាការៈ ៣១ ដ៏សេសក៏កំណត់រោមដូចដែលកិក្ខុនេះឃើញហើយ ដោយវណ្ណៈ ភាគច្រើនមានពណ៌ខៀវ ។ ដោយសណ្ឋាន រោមមានសណ្ឋានដូចជន្ទ្ធ ឬមានសណ្ឋានដូចជាធាងត្នោតកោង កំណត់ដោយទិស រោមកើតក្នុងទិសទាំង ២ កំណត់ដោយឱកាសថា កើតនៅត្រង់ស្បែកនៃសរីរៈដ៏សេសដោយច្រើន វៀរលែងតែបាតដៃ បាតជើង ។

ក្នុងអាការៈ ៣២ ដ៏សេសនោះកំណត់ថា រោមរមែងមិនដឹងថា វាកើតនៅត្រង់ស្បែកសរីរៈ សូម្បីស្បែកនៃសរីរៈ ក៏មិនដឹងថា រោមកើតនៅលើវា ប្រៀបដូចស្មៅស្គា ដែលកើតនៅក្នុងទីផ្ទះចាស់ សូម្បីផ្ទះចាស់ ក៏មិនដឹងថាស្មៅស្គាកើតនៅលើវា ។ ព្រោះថា រោមទាំងនោះ វៀរចាកការត្រិះរិះ និងការពិចារណា ជាធម៌មិនមានចេតនា (ចិត្ត) ជាអព្យាកតៈ សូន្យទទេ ជារបស់បដិកូលមានក្លិនស្អុយ គួរខ្ពើមយ៉ាងក្រៃលែង មិនមែនសត្វ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ការកំណត់ ដោយសភាគៈថា រោមខាងក្រោមកំណត់ដោយស្បែកដែលតាំងនៅ និងដោយគល់របស់ខ្លួនដែលនៅក្នុងស្បែកនោះប្រមាណ ប៉ុនពងចៃ រោមខាងលើកំណត់ដោយអាកាស រោមខាងទទឹងកំណត់ដោយរោមគ្នាឯង ។ ចំណែកការ

កំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់រោមដោយវណ្ណៈ ជាដើមមានប្រការដូចពោលមកហើយដូច្នេះ។

**ឆ៧ = ក្រចក**

តពីនេះទៅ ក៏កំណត់ថា អ្នកមានក្រចកគ្រប់ គឺមាន ២០ ក្រចក ។ ក្រចកទាំងអស់នោះ កំណត់ដោយវណ្ណៈ មានពណ៌ស ក្នុងឱកាសដែលចេញផុតពីសាច់ មានពណ៌ក្រហម ក្នុងឱកាសដែលជាប់នឹងសាច់ ។ ដោយសណ្ឋាន ក្រចកមានសណ្ឋានដូចឱកាសដែលតាំងនៅ ដោយច្រើនមានសណ្ឋានដូចគ្រាប់ស្រគំ ឬមានសណ្ឋានដូចជាស្រកាត្រី ដោយសណ្ឋានគប្បីកំណត់ដូច្នេះ ។ ដោយទិស ក្រចកតាំងនៅក្នុងទិសទាំង ២ ។ ដោយឱកាស ក្រចកតាំងនៅចុងម្រាម ។

ក្នុងក្រចកនោះ កំណត់ថា ក្រចករមែងមិនដឹងថា វាតាំងនៅចុងម្រាម សូម្បីម្រាមក៏មិនដឹងថា ក្រចកតាំងនៅខាងចុងរបស់វា ប្រៀបដូចគ្រាប់ស្រគំដែលពួកក្មេងអ្នកស្រុកដោតទុកលើចុងឈើ មិនដឹងថាវាត្រូវគេដោតទុកលើចុងឈើ សូម្បីឈើក៏មិនដឹងថា គ្រាប់ស្រគំត្រូវគេដោតទុកលើវាដូច្នោះ ។ ក្រចកនោះ វៀរចាកការត្រិះរិះ និងការពិចារណាហើយ ជាធម៌មិនមានចេតនា ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ការកំណត់ដោយសភាគៈថា ក្រចកខាងក្រោម

ត្រូវគេកំណត់ត្រឹមសាច់ម្រាម ខាងគល់ ឬដោយផ្ទៃដែលតាំងនៅត្រង់គល់នោះ ហើយក្រចកខាងលើ កំណត់ដោយឱកាសខាងចុង ដោយស្បែកចុងសងខាង របស់ម្រាមទាំង ២ នេះជាការកំណត់ក្រចកទាំងនោះដោយសភាគៈ ចំណែកការ កំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង កំណត់ក្រចកដោយវណ្ណៈជា ដើម មានប្រការដូចពោលមកដូច្នេះ ។

## ទន្តា = ធ្មេញ

តពីនោះទៅ ក៏កំណត់ថា អ្នកមានធ្មេញគ្រប់ គឺធ្មេញ ៣២ ។ ធ្មេញ ទាំងអស់នោះ កំណត់ដោយវណ្ណៈ ក៏មានពណ៌ស ។ ដោយសណ្ឋាន ធ្មេញ របស់អ្នកមានធ្មេញរាប ប្រាកដដូចផ្ទាំងស័ង្ខកាត់យកទីរឹង និងដូចជាផ្កាឈើក្រពុំ ពណ៌ស ដែលគេក្រងល្អហើយ ។ ធ្មេញរបស់អ្នកមានធ្មេញមិនរាប មាន សណ្ឋានផ្សេងៗ ប្រៀបដូចជាតាំងដែលគេរៀបទុកនៅលើអាសនៈ នៃសាលា ចាស់ ។ ក៏ក្នុងទីបំផុតនៃជួរធ្មេញទាំងសងខាងរបស់ធ្មេញទាំងនោះ ធ្មេញ ៨ មាន ចុង ៤ និងមានគល់ ៤ ហើយចែកជា ២ ផ្នែក គឺខាងលើ ២ ខាងក្រោម ២ មាន សណ្ឋានដូចកៅអីវែង ។ ធ្មេញ ៨ ដែលតាំងនៅតាមលំដាប់នោះ ខាងក្នុងធ្មេញ ទាំងនោះ មានចុង ៣ មានឫស ៣ មានសណ្ឋានដូចក្រចាប់ ។ ធ្មេញ ៤ ខាង

ក្រោម ១ ខាងលើ ១ តាមលំដាប់នោះ ខាងក្នុងធ្មេញទាំងនោះ មានចុង ២ មានឫស ២ មានសណ្ឋានដូចកាំយាន(រទេះ) ។ ធ្មេញចង្កូម ៤ ដែលតាំងនៅតាមលំដាប់នោះ ខាងក្នុងរបស់ធ្មេញទាំងនោះ ខាងក្រោម ១ ខាងលើ ១ មានចុងតែ ១ មានឫសតែ ១ មានសណ្ឋានដូចជាក្ដួងម្ទេះ ។ តពីនោះ ធ្មេញ ៨ ខាងក្រោម ៤ ខាងលើ ៤ ត្រង់កណ្ដាលថ្ពាល់ធ្មេញសងខាង មានចុង ១ មានឫស ១ មានសណ្ឋាន ដូចគ្រាប់ឃ្លោក ដោយទិស ធ្មេញកើតក្នុងទិសខាងលើ ។ ដោយឱកាស ធ្មេញខាងលើ តាំងនៅក្នុងឆ្អឹងចង្កាលើមានចុងចុះក្រោម ខាងក្រោមតាំងនៅក្នុងឆ្អឹង ចង្កាក្រោម មានចុងឡើងលើ ។

បណ្ដាធ្មេញទាំងនោះ ក៏កំណត់ថា ធ្មេញមិនដឹងថា វាតាំងនៅក្នុងឆ្អឹងចង្កាក្រោម និងតាំងនៅក្នុងឆ្អឹងចង្កាលើ សូម្បីឆ្អឹងចង្កាក្រោម ក៏មិនដឹងថា ធ្មេញតាំងនៅក្នុងវា ហើយឆ្អឹងចង្កាលើ ក៏មិនដឹងថា ធ្មេញតាំងនៅក្នុងវា ប្រៀបដូចសសរ ដែលបុរសជាជាងបានតាំងទុកក្នុងថ្ពាំងថ្ម ខាងក្រោមស៊កចូលទៅក្នុងថ្ពាំងថ្មខាងលើ សសររមែងមិនដឹងថា វាត្រូវគេតាំងទុកក្នុងថ្ពាំងថ្មខាងក្រោម ស៊កចូលទៅក្នុងថ្ពាំងថ្មខាងលើ ថ្ពាំងថ្មខាងក្រោម ក៏មិនដឹងថា សសរត្រូវគេដោតទុកលើវា ថ្ពាំងថ្មខាងលើ ក៏មិនដឹងថា សសរត្រូវគេស៊កទុកលើវាដូច្នោះ ។

ដោយថាធ្មេញទាំងនោះ វៀរចាកការត្រិះរិះ និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ធ្មេញក្រោមកំណត់ដោយរណ្ដៅធ្មេញចង្កា ស៊កចូលឆ្អឹងចង្កាហើយតាំងនៅ និងដោយឫសរបស់ខ្លួន ធ្មេញលើកំណត់ដោយអាកាស ខាងទទឹងកំណត់ដោយធ្មេញនឹងធ្មេញ នេះជាការកំណត់ធ្មេញទាំងនោះដោយសភាគៈ ។ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ធ្មេញដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះឯង ។

**តចោ =ស្បែក**

តពីនោះ វត្ថុដែលបិទបាំងសាកសពផ្សេងៗ ក្នុងខាងក្នុងសរីរៈ ឈ្មោះថា តចោ ស្បែក កំណត់ដោយវណ្ណៈ ស្បែកមានពណ៌ស ។ ប្រសិនបើស្បែកនោះប្រាកដដូចពណ៌ផ្សេងៗ មានពណ៌ខ្មៅ ពណ៌សជាដើម ព្រោះត្រូវជ្រលក់ដោយគ្រឿងជ្រលក់ស្បែក ទោះបីដូច្នោះ ក៏ពណ៌សនោះឯង ដោយវណ្ណៈដែលជាសភាគៈនឹងគ្នា ។ កាលដែលស្បែកនោះ មានពណ៌សនោះ រមែងប្រាកដដូចស្បែកដែល ត្រូវរលោកដោយអណ្ដាតភ្លើង និងត្រូវប្រហារដោយគ្រឿងប្រហារជាដើម ។ កំណត់ដោយសណ្ឋាន ដោយសង្ខេបថា មានសណ្ឋានដូចអាវ ដោយពិស្ដារថា មានសណ្ឋានផ្សេងៗ ។ មែនពិត ស្បែកម្រាមជើង មានសណ្ឋានដូច

សំបុកនាង ស្បែកខ្នងជើង មានសណ្ឋានដូចទ្រាប់ជើងដែលខ្ចប់ទុក ស្បែកស្មង មានសណ្ឋានដូចស្ទឹកត្នោតខ្ចប់បាយ ស្បែកបាទជើង មានសណ្ឋានដូចទៃដែលមានអង្ករពេញ ស្បែកត្រចៀក មានសណ្ឋានដូចសំពត់តម្រងទឹកដែលមានទឹកពេញ ស្បែកខ្នង មានសណ្ឋានដូចស្បែកហ៊ុមបាំង ស្បែកពោះ មានសណ្ឋានដូចស្បែកហ៊ុមពិណ ស្បែកទ្រូងដោយច្រើន មានសណ្ឋាន ៤ ជ្រុង ស្បែកដៃទាំង ២ មានសណ្ឋានដូចស្បែករុំដងធ្នូ ស្បែកខ្នងដៃ មានសណ្ឋានដូចស្រោមកាំបិតកោរ ឬមានសណ្ឋានដូចស្រោមស្និត ស្បែកម្រាមដៃ មានសណ្ឋានដូចប្រអប់សោរ ស្បែកក មានសណ្ឋានដូចអាវមានក ស្បែកមុខ មានសណ្ឋានដូចសំបុកនាង មានប្រហោងតិចតួច ស្បែកក្បាលមាន សណ្ឋានដូចស្បោកបាត្រ ។

ព្រះយោគាវចរ ដែលកំណត់ស្បែកជាអារម្មណ៍ បញ្ជូនចិត្តចូលទៅក្នុងចន្លោះស្បែក និងសាច់តាំងពីបបូរមាត់លើ កំណត់ស្បែកមុខជាលំដាប់ដំបូង តពីនោះ ស្បែកក្បាល ស្បែកកខាងក្រៅ តពីនោះ ក៏គប្បីកំណត់ស្បែកដៃស្តាំ ទាំងអនុលោម និងបដិលោម ។ ដោយលំដាប់តមក ក៏គប្បីកំណត់ស្បែកដៃឆ្វេង ស្បែកខ្នង ស្បែកត្រចៀក តពីនោះ ស្បែកខ្នងជើងស្តាំ ទាំងអនុលោម និងបដិលោម ស្បែកខ្នងជើងឆ្វេង ស្បែកក្រពេញបស្សាវៈ បេះដូង ក៏ខាងក្នុងតពី

នោះ ស្បែកចង្កាក្រោម ស្បែកបបូរមាត់ក្រោម កំណត់យ៉ាងនេះទៀត រហូតដល់ស្បែកបបូរមាត់លើ ។ កំណត់ដោយទិសថា ស្បែកកើតក្នុងទិសទាំង២ ។ កំណត់ដោយឱកាសថា ហ៊ុមព័ទ្ធនូវសរីរៈហើយតាំងនៅ ។

ក្នុងស្បែកនោះ ព្រះយោគាវចរកំណត់ថា ស្បែករមែងមិនដឹងថា វាហ៊ុមព័ទ្ធសរីរៈ ដែលប្រកបដោយមហាភូតរូបទាំង ៤ នេះ សូម្បីសរីរៈ ដែលប្រកបដោយមហាភូតរូបទាំង ៤ នេះ ក៏មិនដឹងថា វាត្រូវស្បែកហ៊ុមព័ទ្ធទេ ប្រៀបដូចជាហិបហ៊ុមព័ទ្ធដោយស្បែកស្រស់ ហិបក៏មិនដឹងថា វាហ៊ុមព័ទ្ធដោយស្បែកស្រស់ទេ សូម្បីហិបក៏មិនដឹងថា វាត្រូវស្បែកស្រស់ហ៊ុមព័ទ្ធដូច្នោះដែរ ។ ព្រោះថាស្បែកទាំងនោះវៀរចាកការត្រិះរិះ និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ លោកពោលដូច្នេះថា៖

អល្លចម្មបដិច្ឆន្នោ នវទ្វារោ មហាវណោ

សមន្តតោ បគ្ឃរតិ អសុចិបូតិគន្ធិយោ ។

រាងកាយនេះ ហ៊ុមព័ទ្ធដោយស្បែកស្រស់ មានទ្វារ ៩ មានដំបៅច្រើន មិនស្អាត មានក្លិនស្អុយរមែងហូរចេញដោយជុំវិញ ។

ដោយបរិច្ឆេទកំណត់ថា ស្បែកខាងក្រោមកំណត់ ដោយស្បែក ឬផ្ទៃដែល

តាំងនៅលើស្បែកនោះ ស្បែកខាងលើកំណត់ដោយស្បែកសម្បុរថ្ងៃ នេះជាការកំណត់ស្បែកនោះដោយសភាគៈ ។ ការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះដែរ ការកំណត់ស្បែកដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

**មំសំ = សាច់**

តពីនោះទៅ ក៏កំណត់សាច់ ដែលផ្សេងដោយសាច់ ៩០០ ចំរៀក ក្នុងសរីរៈ ដោយវណ្ណៈថា មានពណ៌ក្រហមស្រដៀងផ្កាចារ ។ ដោយសណ្ឋាន មានសណ្ឋានផ្សេងៗគ្នា ។ ពិតដូច្នោះ សាច់កំភួនជើងនៃសរីរៈនោះ មានសណ្ឋានដូចបាយខ្ចប់ស្លឹកត្នោត អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចផ្ការំចេកដែលមិនទាន់រីកដូច្នេះក៏មាន ។ សាច់ជើង មានសណ្ឋានដូចថ្មកំបោរស សាច់ត្រចៀក មានសណ្ឋានដូចចុងជុំសសរ សាច់ឆ្អឹងខ្នង មានសណ្ឋានដូចដុំផែនស្ករត្នោត សាច់ចំរៀកគ្រោង ទាំង ២ មានសណ្ឋានដូចដីបូកស្តើងៗក្នុងថ្ពៃ ដែលធ្វើដោយឫស្សី សាច់ដោះ មានសណ្ឋានដូចដុំដីសើម ដែលដុះចេញទៅមុខ សាច់ដៃទាំង ២ មានសណ្ឋានដូចកណ្តុរធំ ដែលគេកាត់កន្ទុយ ក្បាល និងជើង មិនមានស្បែកតាំងនៅ អាចារ្យមួយពួកពោលថា មានសណ្ឋានដូចកួងសាច់ដូច្នេះក៏មាន សាច់ថ្ពាល់ មានសណ្ឋានដូចគ្រាប់ក្រសាំង ដែលគេដាក់នៅលើថ្ពាល់ ។ អាចារ្យមួយពួក

ពោលថា មានសណ្ឋានដូចកន្ត្រៃបដូច្នេះក៏មាន ។ សាច់អណ្តាត មានសណ្ឋានដូចត្របកឈូក សាច់ច្រមុះមានសណ្ឋានដូចទូសៀវភៅផ្កាប់មុខ សាច់រន្ធភ្នែក មានសណ្ឋានដូចផ្លែល្វាទុំពាក់កណ្តាល សាច់ក្បាល មានសណ្ឋានដូចប្រេងលាបខ្ទះស្តើងៗជុំវិញបាត ព្រះយោគាវចរ ដែលកំណត់សាច់ជាអារម្មណ៍គប្បីកំណត់សាច់ ដែលជាចំណែកគ្រោតគ្រាតៗទាំងនេះ ដោយសណ្ឋាននោះឯង ។ ដោយសណ្ឋាន ព្រះយោគាវចរកំណត់យ៉ាងនេះ សាច់ ចំណែកល្អិតក៏ប្រាកដដល់ញាណ ។ កំណត់ដោយទិស សាច់កើតក្នុង ទិសទាំង ២ ។ កំណត់ដោយឱកាស សាច់បូកតាមឆ្អឹង ៣០០ កំណាត់ ដែលមានគ្រោងតាំងនៅ ។

ក្នុងសាច់នោះ ក៏កំណត់ថា សាច់ ៩០០ ចំរៀក រមែងមិនដឹងថា វាបូកលាបឆ្អឹង ៣០០ កំណាត់ សូម្បីឆ្អឹង ៣០០ កំណាត់ ក៏មិនដឹងថា វាត្រូវសាច់ ៩០០ ចំរៀកបូកលាបដែរ ប្រៀបដូចជញ្ជាំងផ្ទះ ដែលត្រូវបូកលាបដោយដីគគ្រីម ដីគគ្រីម ក៏មិនដឹងថាវាបូកលាបជញ្ជាំងផ្ទះដែរ សូម្បីជញ្ជាំងផ្ទះក៏មិនដឹងថា វាត្រូវដីគគ្រីមបូកលាបដែរ ។ ព្រោះថា សាច់ទាំងនោះ វៀរចាកការត្រិះរិះ និងការពិចារណា ជាធម៌ ។ល។ មិនមែនជាបុគ្គល លោកពោលដូច្នេះថា៖

នវបេសិសតា មំសា អនុលិត្តា កឡេវរំ
នានាកិមិគលាកិណ្ណំ មីឡ្ហដ្ឋានំវ បូតិកំ។

សាច់ ៩០០ ចំរៀកបូកលាបដោយកម្បោរៈ រាងកាយ ដែលជ្រៀតបៀត ដោយពួកជន្តុវប្រភេទផ្សេងៗ ស្អុយដូចលាមក ។

ដោយបរិច្ឆេទកំណត់ថា សាច់ខាងក្រោមកំណត់ដោយគ្រោងឆ្អឹង ឬទីតាំងនៃគ្រោងឆ្អឹងនោះ សាច់ខាងលើកំណត់ដោយស្បែក សាច់ខាងទទឹងកំណត់ដោយសាច់ទីងសាច់គ្នាឯង នេះជាការកំណត់សាច់ដោយសភាគៈ ចំណែកការកំណត់ ដោយវិសភាគៈក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់សាច់ ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

ន្ហារុ = **សរសៃ**

តពីនោះទៅ ក៏កំណត់ថា សរសៃ ៩០០ ក្នុងសរីរៈដោយវណ្ណៈ មានពណ៌ស អាចារ្យពួកខ្លះពោលថា មានពណ៌ដូចទឹកឃ្មុំ ។ ដោយសណ្ឋាន សរសៃមានសណ្ឋានផ្សេងៗ ។ ពិតដូច្នោះ បណ្តាសរសៃ ៩០០ នោះ សរសៃធំៗ មានសណ្ឋានដូចកក់ទ្វី[១] ដែលល្អិតជាងនោះ មានសណ្ឋានដូចខ្សែសំណាញ់ទាក់ជ្រូក ដែលតូចក្រៃលែងជាងនោះ មានសណ្ឋានដូចវល្លិ៍ផោម ដែលតូចជាងនោះទៅទៀត មានសណ្ឋានដូចខ្សែពិណាធំ របស់ជនជាតិសីហឡៈ ដែលតូចជាងនោះទៅទៀត ក៏មានសណ្ឋានដូចអំបោះគគ្រាត សរសៃដែលនៅលើខ្នងដៃ ខ្នងជើង មាន

---

១-**សីលក្ខន្ធវគ្គអភិនវដីកា** ទំព័រ ៣២៦ ពន្យល់ថា**កន្ទលោ នាម បុប្ផគច្ឆវិសេសោ** ប្រែថា រុក្ខជាតិវិសេសម្យ៉ាងដែលមានផ្កាផុសចេញមក ឈ្មោះថា **កន្ទលោ** ។

សណ្ឋានដូចជើងសត្វស្វាប សរសៃក្បាល មានសណ្ឋានដូចសំពត់ស្តើងៗ ដែលដាក់លើក្បាលរបស់ក្មេងអ្នកស្រុក សរសៃខ្នង មានសណ្ឋានដូចសំណាញ់ចាប់ត្រីដែលប្រឡាក់ទឹកហើយលាតហាលថ្ងៃ សរសៃដ៏សេសដែលនៅតាមអវយវៈធំតូចនោះៗក្នុងសរីរៈនេះ មានសណ្ឋានដូចជាអាវដែលស្រោបលើសរីរៈ ។ ដោយទិស សរសៃកើតក្នុងទិសទាំង ២ ។ បណ្តាសរសៃទាំងនោះ សរសៃធំ មានឈ្មោះថា កណ្ឌរៈ មាន ៥ តាំងពីដើមត្រចៀកស្តាំមកខាងមុខ និងខាងក្រោយដល់ខាងឆ្វេង ចងតាំងពីគុម្ពត្រចៀកខាងឆ្វេងមកខាងមុខ និងខាងក្រោយដល់ខាងស្តាំ ចងតាំងពីរណ្តៅកខាងស្តាំមកខាងមុខ និងខាងក្រោយដល់ខាងឆ្វេង ចងតាំងពីរណ្តៅខាងឆ្វេងមកខាងមុខ និងខាងក្រោយដល់ខាងស្តាំ ចងដៃស្តាំមកខាងមុខ ៥ ខាងក្រោយ ៥ រួមសរសៃធំដែលឈ្មោះថា កណ្ឌរៈ មាន ១០ យ៉ាង ។ ដៃខាងឆ្វេង ជើងខាងស្តាំ និងជើងខាងឆ្វេងក៏ដូចគ្នាយ៉ាងនោះ ។ រួមសេចក្តីមកសរសៃធំ ៦០ ដូចពោលមកយ៉ាងនេះ ក៏កំណត់ថា ជាគ្រឿងជួយទ្រទ្រង់សរីរៈជួយកំណត់សរីរៈក៏មាន ។ កំណត់ដោយឱកាស សរសៃចងឆ្អឹងខាងក្នុងឆ្អឹងជាមួយស្បែក និងឆ្អឹងជាមួយសាច់តាំងនៅទូទាំងសរីរៈ។

បណ្តាសរសៃនោះកំណត់ថា សរសៃរមែងមិនដឹងថា ឆ្អឹង ៣០០ កំណាត់ត្រូវវាចងទុក សូម្បីឆ្អឹង ៣០០ កំណាត់ ក៏មិនដឹងថា វាត្រូវសរសៃចងដែរ ប្រៀបដូចឈើកោង ដែលត្រូវវល្លិ៍រុំព័ទ្ធ វល្លិ៍រមែងមិនដឹងថា ឈើកោងត្រូវវាចងទុក

សូម្បីឈើកោងក៏មិនដឹងថា វាត្រូវវល្លិ៍រុំព័ទ្ធដែរដូច្នោះ ។ ព្រោះថាសរសៃទាំងនោះ វៀរចាកការត្រិះរិះ និងការពិចារណា ជាធម៌ ។ល។ មិនមែនជាបុគ្គល ។ លោកពោលដូច្នេះថា ៖

នវន្ហារុសតា ហោន្តិ ព្យាមមត្តេ កឡេវរេ
ពន្ធន្តិ អដ្ឋសង្ឃាដំ អគារមិវវល្លិយោ ។

សរសៃ ៩០០ រមែងមាន ត្រូវគ្រោងឆ្អឹងក្នុងរាងកាយប្រមាណមួយព្យាមពន្ធព័ទ្ធហើយ ដូចវល្លិ៍ចងផ្ទះដូច្នោះ ។

ដោយបរិច្ឆេទថា សរសៃខាងក្រោម កំណត់ដោយឆ្អឹង ៣០០ កំណាត់ ឬផ្ទៃដែលតាំងនៅឯឆ្អឹងនោះ សរសៃខាងលើកំណត់ដោយស្បែក និងសាច់ ខាងទទឹង កំណត់ដោយសរសៃរបស់គ្នា នឹងគ្នាឯង ។ នេះជាការកំណត់សរសៃទាំងនោះ ដោយសភាគៈ ។ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះដែរ ។ កំណត់សរសៃដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

**អដ្ឋិ = ឆ្អឹង**

តពីនោះទៅ គប្បីកំណត់ឆ្អឹង ដោយវណ្ណៈថា ឆ្អឹងមានប្រភេទ ដែលលោកពោលទុកដោយន័យជាដើមយ៉ាងនេះថា ព្រោះលោកកាន់យកឆ្អឹងធ្មេញ ៣២ បំបែកទុកដោយឡែក ឆ្អឹងដ៏សេសក្នុងសរីរៈមានឆ្អឹងដៃ ៦៤ ឆ្អឹងជើង ៦៤ ឆ្អឹងខ្ចី

ដែលជាប់សាច់ ៦៤ ឆ្អឹងកែងជើង ២ ឆ្អឹងកជើង មួយៗ មាន ២ ឆ្អឹងស្មង ២ ឆ្អឹងជង្គង់ ១ ឆ្អឹងភ្លៅ ១ ឆ្អឹងចង្កេះ ២ ឆ្អឹងខ្នង ១៨ ឆ្អឹងគ្រោង ២៤ ឆ្អឹងជំនីរ ១៤ ឆ្អឹងជិតបេះដូង ១ ឆ្អឹងដងកាំបិត ២ ឆ្អឹងខ្នងដៃ ២ ឆ្អឹងដៃ ២ ឆ្អឹងចុងដៃ ២ ឆ្អឹងក ៧ ឆ្អឹងចង្កា ២ ឆ្អឹងច្រមុះ ១ ឆ្អឹងភ្នែក២ ឆ្អឹងត្រចៀក ២ ឆ្អឹងថ្ងាស ១ ឆ្អឹងក្បាល១ ឆ្អឹងលលាដ៍ក្បាល៩ ឆ្អឹងទាំងអស់នោះឯងមានពណ៌ស ។

កំណត់ដោយសណ្ឋានថា ឆ្អឹង មានសណ្ឋានផ្សេងៗគ្នា ។ មែនពិត បណ្ដាឆ្អឹងទាំងនោះ ឆ្អឹងចុងម្រាមជើង មានសណ្ឋានដូចគ្រាប់ពោន ឆ្អឹងតពីនោះគឺជាឆ្អឹងកណ្ដាលនៃម្រាមជើង មានសណ្ឋានដូចគ្រាប់ខ្នុរដែលមិនពេញ ឆ្អឹងដើមនៃម្រាមជើង មានសណ្ឋានដូចស្គរជ័យ អាចារ្យមួយពួកពោលថា មានសណ្ឋានដូចស្រកាជើងក្ងោកដូច្នេះក៏មាន ។ ឆ្អឹងខ្នងជើង មានសណ្ឋានដូចជាគំនរកក់ដំឡូងរាប ឆ្អឹងកែងជើង មានសណ្ឋានដូចផ្លែត្នោតដែលមានគ្រាប់មួយ ឆ្អឹងកជើង មានសណ្ឋានដូចប៊ូលរបស់លេងដែលចងរួមគ្នា ឆ្អឹងតូចៗក្នុងឆ្អឹងស្មង មានសណ្ឋានដូចដងធ្នូ ឆ្អឹងធំៗ មានសណ្ឋានដូចខ្នងសត្វដែលរាំងដោយសរសៃ ព្រោះស្រេកឃ្លាន ឆ្អឹងស្មងតាំងនៅក្នុងឆ្អឹងជើង មានសណ្ឋានដូចពន្លកដើមបេងបកសំបក ឆ្អឹងដែលតាំងលើស្មងជើងនៃឆ្អឹងជង្គង់ មានសណ្ឋានដូចកំពូលសំភោរ ឆ្អឹងជង្គង់ មានសណ្ឋានដូចពពុះទឹកម្ខាងដែលបែក ឆ្អឹងភ្លៅ មានសណ្ឋានដូចដងកាំបិត និង

ពូថៅដែលចាំងត្រួសៗ ឆ្អឹងក្លៀតាំងនៅក្នុងឆ្អឹងចង្កេះ មានសណ្ឋានដូចបំពង់ផ្ចុំភ្លើងរបស់ជាងមាស ឱកាសដែលឆ្អឹងក្លៀតាំងនៅក្នុងឆ្អឹងចង្កេះនោះ មានសណ្ឋានដូចផ្លែបុសនាគដែលកាត់ចុង ឆ្អឹងចង្កេះសូម្បីមាន ២ ក៏ជាប់គ្នាតែមួយ មានសណ្ឋានដូចចង្ក្រានភ្លើងដែលស្ទូនផ្ទាំងសាងទុក អាចារ្យមួយពួកពោលថា មានសណ្ឋានដូចខ្នើយឱបរបស់តាបសដូច្នេះក៏មាន ។ ឆ្អឹងត្រគាក មានសណ្ឋានដូចសំណាកពស់ដែលគេដាក់ផ្កាប់មុខ ឆ្អឹងខ្នង ១៨ កំណាត់ មានប្រហោងតូចៗក្នុងទី ៧-៨ កន្លែងខាងក្នុង មានសណ្ឋានដូចផ្ទាំងសំពត់ជួតក្បាល ដែលគេដាក់ត្រួតៗគ្នាខាងក្រៅ មានសណ្ឋានដូចបំពង់មូល ឆ្អឹងខ្នងទាំងនោះមានបន្លា ២-៣ ដូចធ្មេញរណា ។ បណ្តាឆ្អឹងគ្រោង ២៤ កំណាត់ ចំណែកដែលបរិសុទ្ធ មានសណ្ឋានដូចចិញ្ចើមអ្នកសីហឡៈដែលបរិបូណ៌ ចំណែកដែលមិនបរិបូណ៌ មានសណ្ឋានដូចចិញ្ចើមអ្នកសីហឡៈដែលមិនបរិបូណ៌ អាចារ្យមួយពួកពោលថា ទាំងអស់នេះឯង មានសណ្ឋានដូចស្លាបសងខាងរបស់មាន់ស ដែលលាតចេញដូច្នេះក៏មាន ឆ្អឹងជំនីរ ១៤ កំណាត់ មានសណ្ឋានដូចផ្ទាំងឈើគ្រែស្នែងចាស់ៗ ឆ្អឹងបេះដូង មានសណ្ឋានដូចពពារវែក ឆ្អឹងដងកាំបិត មានសណ្ឋានដូចដងកាំបិតលោហៈតូចៗ បណ្តាឆ្អឹងដងកាំបិតទាំងនោះ ឆ្អឹងខាងក្រោម មានសណ្ឋានដូច

អឌ្ឍចន្ទ (ព្រះចន្ទពាក់កណ្ដាល) ឆ្អឹងខ្នងដៃ មានសណ្ឋានដូចពូថៅ អាចារ្យមួយពួកពោលថា មានសណ្ឋានដូចចបអ្នកសីហឡៈកាត់ពាក់កណ្ដាលដូច្នេះក៏មាន ឆ្អឹងដៃ មានសណ្ឋានដូចដងកញ្ចក់ឆ្លុះ អាចារ្យមួយពួកពោលថា មានសណ្ឋានដូចដងកាំបិតធំដូច្នេះក៏មាន ។ ឆ្អឹងចុងដៃ មានសណ្ឋានដូចឫសត្នោតគូ ឆ្អឹងដៃ មានសណ្ឋានដូចសំពត់ជូតក្បាលដែលគេដាក់ជាប់រួមគ្នា ឆ្អឹងខ្នងដៃ មានសណ្ឋានដូចជាគំនរកក់ដំឡូងរាប ឆ្អឹងដើមរបស់ម្រាមដៃ មានសណ្ឋានដូចស្គរជ័យ ឆ្អឹងកណ្ដាលនៃម្រាមដៃ មានសណ្ឋានដូចគ្រាប់ខ្នុរដែលមិនបរិបូណ៌ ឆ្អឹងចុងនៃម្រាមដៃ មានសណ្ឋានដូចគ្រាប់ផ្លែពោន ឆ្អឹងកទាំង ៧ មានសណ្ឋានដូចចំណិតទំពាំង ដែលគេចោះដាក់តម្រៀបតាមលំដាប់ទុក ឆ្អឹងចង្កាក្រោម មានសណ្ឋាន ដូចចំណងចង្ញញួរដែករបស់ជាងមាស ឆ្អឹងចង្កាលើ មានសណ្ឋានដូចឈើជម្រះ ៧ ឆ្អឹងរន្ធភ្នែក និងប្រហោងច្រមុះ មានសណ្ឋានដូចកូនត្នោតខ្ចីដែលមិនទាន់បកសំបក ឆ្អឹងថ្ងាស មានសណ្ឋានដូចត្រឡោកស័ង្ខបែក ដែលគេដាក់ផ្កាប់មុខ ឆ្អឹងគុម្ពត្រចៀក មានសណ្ឋានដូចស្រោមកាំបិតកោររបស់ជាងកាត់សក់ បណ្ដាឆ្អឹងថ្ងាស និងឆ្អឹងគុម្ពត្រចៀក ឆ្អឹងក្នុងឱកាសដែលជាប់គ្នាជាផ្ទាំងខាងលើ មានសណ្ឋានដូចចំរៀកសំពត់ចាស់បិទក្អមក្រាស់ពេញដោយទឹក

ឆ្អឹងអំបែងក្បាល មានសណ្ឋានដូចដូងកាត់មាត់ ឆ្អឹងក្បាល មានសណ្ឋានដូចត្រឡោកឃ្លោកចាស់ដែលគេដាក់ចូលទៅទុក ។ ដោយទិសឆ្អឹងទាំងឡាយកើតក្នុងទិសទាំង២ ។ ដោយឱកាស ឆ្អឹងទាំងឡាយតាំងនៅទូទាំងសរីរៈ មិនមានចំណែកសល់ ប៉ុន្តែពោលដោយពិសេស ឆ្អឹងសីសៈតាំងនៅលើឆ្អឹងក ឆ្អឹងកតាំងនៅលើឆ្អឹងខ្នង ឆ្អឹងខ្នងតាំងនៅលើឆ្អឹងចង្កេះ ឆ្អឹងចង្កេះតាំងនៅលើឆ្អឹងភ្លៅ ឆ្អឹងភ្លៅតាំងនៅលើឆ្អឹងក្បាលជង្គង់ ឆ្អឹងក្បាលជង្គង់តាំងនៅលើឆ្អឹងស្មង ឆ្អឹងស្មងតាំងនៅលើឆ្អឹងកជើង ឆ្អឹងកជើងតាំងនៅលើឆ្អឹងខ្នងជើង ឆ្អឹងខ្នងជើងក៏លើកឆ្អឹងជើងឡើងតាំង ឆ្អឹងជើងក៏លើកឆ្អឹងស្មងឡើងតាំង ។ល។ ឆ្អឹងកក៏លើកឆ្អឹងក្បាលឡើងតាំង ។ គប្បីជ្រាបចំណែកដ៏សេសដោយទំនងដូចពោលមកដូច្នេះ ។

ក្នុងឆ្អឹងទាំងនោះកំណត់ថា ឆ្អឹងសីសៈរមែងមិនដឹងថា វាតាំងនៅលើឆ្អឹងក ។ល។ ឆ្អឹងកជើងរមែងមិនដឹងថា វាតាំងនៅលើឆ្អឹងខ្នងជើង សូម្បីឆ្អឹងខ្នងជើងក៏មិនដឹងថាវាលើកឆ្អឹងកជើងឡើងតាំង ប្រៀបដូច បណ្តាទព្វសម្ភារៈ មានឥដ្ឋ និង ឈើនិងទុកជាដើម ពេលនៅលើរមែងមិនដឹងថា វាតាំងនៅលើសម្ភារៈទាំងឡាយ មានឥដ្ឋផ្នែកក្រោមជាដើម ឥដ្ឋផ្នែកក្រោមក៏មិនដឹងថា វាលើកឥដ្ឋផ្នែកខាងលើតាំងឡើងដូច្នោះ ។ ព្រោះថាឆ្អឹងទាំងនោះ វៀរចាកការត្រិះរិះ និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ឆ្អឹង ៣០០ កំណាត់ ដែលសម្រេច

*ហើយ គឺសរសៃ ៩០០ និងសាច់ ៩០០ ចំណិត ចង និងលាបស្បែកហ៊ុមជាដុំតែមួយ បូកលាបដោយជរស្អិតទៅតាមប្រសាទទទួលរស ៧.០០០ មានតំណក់ញើស ក្រងដោយរណ្តៅរោម ៩៩.០០០ មានត្រកូលដង្កូវ ៨០ ត្រកូលរាប់បានថា កាយតែម្យ៉ាង ដែលព្រះយោគាវចរ កាលពិចារណាដោយសភាវៈពិត រមែងមិនឃើញវត្ថុអ្វីៗ ដែលគួរចូលទៅប្រកាន់យក ប៉ុន្តែនឹងឃើញគ្រោងឆ្អឹងតែម្យ៉ាង ដែលរួបរឹតដោយសរសៃ បៀតបៀនដោយសាកសពផ្សេងៗ កាលឃើញហើយរមែងចូលដល់ភាវៈជាឱសេរបស់ព្រះទសពល ដូចដែលត្រាស់ទុកថា៖*

បដិចាដិយដ្ឋីនិ ឋិតានិ កោដិយា

អនេកសន្ធិយមិតោ ន កេហិចិ

ពទ្ធោ ន្ហារុហិ ជរាយ ចោទិតោ

អចេតនោ កដ្ឋកលិង្គរូបមោ។

*ឆ្អឹងទាំងឡាយ តាំងចុះរៀងគ្នាក្នុងទីត ភាគច្រើនពី*

*កាយនេះ វត្ថុអ្វីៗមិនបានចងទុក កាយនេះប្រសិនបើ*

*សរសៃទាំងឡាយចងរឹតទុក គឺជរាជាស់តឿនហើយ*

*មិនមានចេតនា (ចិត្ត) ឧបមាដូចកំណាត់ឈើ ។*

កុណបំ កុណបេ ជាតំ អសុចិម្ហិ ច បូតិនិ

ទុគ្គន្ធេ ចាបិ ទុគ្គន្ធំ ភេទនម្ហិ ច ភេទនំ
អដ្ឋិបុដេ អដ្ឋិបុដោ ជិគុច្ឆិតោ បូតិនិ បូតិកាយម្ហិ
តម្ហិ ច វិនេថ ឆន្ទំ ហោស្សថេ បុត្តា ទសពលស្ស ។

*សាកសពកើតក្នុងសាកសព របស់ស្អុយកើតក្នុងរបស់មិនស្អាត*
*របស់ស្អុយកើតក្នុងរបស់ស្អុយ របស់ដែលសូន្យទៅកើតក្នុង*
*របស់ដែលបែកធ្លាយទៅ គំនរឆ្អឹងកើតក្នុងគំនរឆ្អឹង របស់ស្អុយ*
*កើតក្នុងកាយស្អុយ អ្នកទាំងឡាយចូរកម្ចាត់សេចក្តីពេញចិត្ត*
*ក្នុងកាយដ៏ស្អុយនោះចេញ នឹងជាបុត្ររបស់ព្រះទសពល ។*

*ដោយបរិច្ឆេទក៏កំណត់ថា ខាងក្នុងឆ្អឹងកំណត់ដោយខួរក្នុងឆ្អឹង ខាងក្រៅឆ្អឹងកំណត់ដោយសាច់ចុង និងគល់កំណត់ដោយឆ្អឹងរបស់គ្នា នឹងគ្នា នេះជាការកំណត់ដោយឆ្អឹងទាំងនោះដោយសភាគៈ ចំណែកការកំណត់ ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ឆ្អឹងដោយវណ្ណៈជាដើម មានប្រការដូចពោលមកហើយដូច្នេះ ។*

### អដ្ឋិមិញ្ជំ =**ខួរក្នុងឆ្អឹង**

*តពីនោះទៅ ក៏កំណត់ថា ខួរក្នុងឆ្អឹង ដែលនៅខាងក្នុងឆ្អឹងទាំងឡាយមានប្រភេទតាមដែលពោលមកហើយក្នុងសរីរៈ ដោយវណ្ណៈមានពណ៌ស ។ ដោយសណ្ឋានខួរក្នុងឆ្អឹង មានសណ្ឋានដូចជាឱកាសរបស់ខួន ។ នៅក្នុងឆ្អឹង*

ទាំងឡាយ ខ្នាតធំៗ មានសណ្ឋានដូចពន្លកស្ពៅ ខ្នាតធំដែលគេស៊កបង្ហិលដាក់ក្នុងឫស្សី និងដើមបបុសខ្នាតធំ ខួរឆ្អឹងដែលនៅខាងក្នុងឆ្អឹងតូចៗ មានសណ្ឋានដូចពន្លកស្ពៅខ្នាតតូច ដែលគេស៊កបង្ហិលដាក់ក្នុងថ្នាំងឫស្សី និងដើមបបុសខ្នាតតូច ។ ដោយទិស ខួរក្នុងឆ្អឹងកើតក្នុងទិសទាំង ២ ដោយឱកាស ខួរក្នុងឆ្អឹងតាំងនៅក្នុងចន្លោះនៃឆ្អឹងទាំងឡាយ ។

ខួរក្នុងឆ្អឹងនោះក៏កំណត់ថា ខួរក្នុងឆ្អឹងរមែងមិនដឹងថា វានៅក្នុងឆ្អឹង សូម្បីឆ្អឹងក៏មិនដឹងថា ខួរក្នុងឆ្អឹងនៅក្នុងវា ប្រៀបដូចទឹកដោះ និងទឹកអំពៅនៅក្នុងឫស្សី និងដើមបបុសជាដើម រមែងមិនដឹងថា វានៅក្នុងដើមឫស្សី និងដើមបបុសជាដើម សូម្បីដើមឫស្សី និងដើមបបុសជាដើម ក៏មិនដឹងថា ទឹកដោះជូរ និងទឹកអំពៅនៅខាងក្នុងវាដូច្នោះ ។ មែនពិត ធម៌ទាំងនេះ វៀរចាកការត្រិះរិះ និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទថា ខួរក្នុងឆ្អឹង គប្បីកំណត់ ដោយផ្ទៃខាងក្នុងឆ្អឹងទាំងឡាយ ដោយចំណែកនៃខួរក្នុងឆ្អឹង នេះជាការកំណត់ខួរក្នុងឆ្អឹងនោះ ដោយសភាគៈ ចំណែកការកំណត់វិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ខួរក្នុងឆ្អឹងដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះៗ

វក្កំ = **តម្រងបស្សាវៈ**

តពីនោះទៅ ក៏កំណត់ថា វក្កា តម្រងបស្សាវៈមានប្រភេទដូចកូនប៊ូល ២ ខាងក្នុងសរីរៈ ។ ដោយវណ្ណៈ មានពណ៌ក្រហមទន់ មានពណ៌ដូចគ្រាប់រលួសបាយ ដោយសណ្ឋាន តម្រងបស្សាវៈ មានសណ្ឋានដូចកូនប៊ូលលេង ដែលធ្វើពី

អំបោះរបស់ក្មេងអ្នកស្រុក អាចារ្យមួយពួកពោលថា មានសណ្ឋានដូចស្វាយ ២ ផ្លែ ទងតែមួយដូច្នេះក៏មាន ។ ដោយទិស តម្រងបស្សាវៈ កើតក្នុងទិសខាងលើ ។ ដោយឱកាស តម្រងបស្សាវៈនោះ ត្រូវសរសៃគគ្រាត ដែលចេញមកពីរណ្ដៅក មានគល់តែមួយទៅបន្តិចហើយ ក៏បែកចេញជា ២ ចំណែក រួបរឹតសាច់បេះដូង ហើយតាំងនៅ ។

បណ្ដាតម្រងបស្សាវៈនោះ ក៏កំណត់ថា តម្រងបស្សាវៈរមែងមិនដឹងថា វាត្រូវសរសៃគគ្រាតរួបរឹត សូម្បីសរសៃក៏មិនដឹងថាវាត្រូវរួបរឹត ដោយតម្រង-បស្សាវៈ ប្រៀបដូចស្វាយ ២ ផ្លែជាប់ទងតែមួយ រមែងមិនដឹងថា វាត្រូវទងជាប់ សូម្បីទង ក៏មិនដឹងថា វាត្រូវស្វាយ ២ ផ្លែ ជាប់ដូច្នោះ ព្រោះថាធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ថាតម្រងបស្សាវៈ កំណត់ដោយចំណែកនៃតម្រងបស្សាវៈ នេះជាការកំណត់តម្រងបស្សាវៈនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង កំណត់តម្រងបស្សាវៈ ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

## ហទយំ = **បេះដូង**

តពីនោះទៅ ក៏កំណត់ថាបេះដូងមានក្នុងសរីរៈ ដោយវណ្ណៈ បេះដូងមានពណ៌ក្រហម ដូចជាស្រទាប់នៃផ្កាឈូកក្រហម ។ ដោយសណ្ឋានបេះដូង មានសណ្ឋានដូចផ្កាបទុមក្រពុំបកស្រទាប់ក្រៅចេញហើយ ដាក់ផ្កាប់ចុះ ។ ក៏បេះដូងនោះ ម្ខាងដូចផ្លែបុសនាគកាត់កំពូលខាងក្រៅឱ្យរលោង ខាងក្នុងក៏ដូចខាងក្នុងនៃ

ផ្ទៃនៅឯព្រៃ ។ បេះដូងរបស់អ្នក មានបញ្ញាច្រើនរីកធំបន្តិច របស់អ្នកមានបញ្ញាតិចក្តោបតែម្យ៉ាង ។ មនោធាតុ និងមនោវិញ្ញាណធាតុ អាស្រ័យរូបណាប្រព្រឹត្តទៅ ដករូបនោះចេញហើយ ឈាមកកនៅក្នុងទូកដៃខាងក្នុងបេះដូង ពោល គឺចំណិតសាច់ដ៏សេស ឈាមរបស់អ្នកមានរាគចរិតនោះ ពណ៌ក្រហម របស់អ្នកមានទោសចរិត ពណ៌ខ្មៅ របស់អ្នកមានមោហចរិត មានពណ៌ដូចទឹកលាងសាច់ របស់អ្នកវិតក្កចរិត មានពណ៌ដូចទឹកសណ្តែក របស់អ្នកសទ្ធាចរិត មានពណ៌ដូចផ្កាកណិការ របស់អ្នកមានបញ្ញាចរិត ផូរផង់ថ្លាមិនល្អក់កករ ដូចជាកែវមណីដ៏រុងរឿងពីកំណើត ដែលជម្រះហើយ ។ ដោយទិស បេះដូងកើតក្នុងទិសខាងលើ ។ ដោយឱកាស បេះដូង តាំងនៅត្រង់កណ្តាល (ចន្លោះ)ដោះទាំង ២ ខាង ក្នុងសរីរៈ ។

ក្នុងបេះដូងនោះកំណត់ថា បេះដូងរមែងមិនដឹងថា វាតាំងនៅកណ្តាលដោះទាំង ២ សូម្បីដោះក៏មិនដឹងថា បេះដូងនៅត្រង់កណ្តាលវា ប្រៀបដូចជាគន្លឹះតាំងនៅកណ្តាលនៃមេបង្អួច និងទ្វារទាំង ២ សូម្បីបង្អួច និងទ្វារក៏មិនដឹងថាគន្លឹះជាតតាំងនៅត្រង់កណ្តាលវាដូច្នោះ ។ ព្រោះថាធម៌ទាំងនោះ វៀរចាកការត្រិះរិះការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថាបេះដូង កំណត់ដោយចំណែកនៃបេះដូង នេះជាការកំណត់បេះដូងនោះ ដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង កំណត់បេះដូង ដោយវណ្ណៈជាដើមមានប្រការដូចពោលមកដូច្នេះ ។

## យកនំ = ថ្លើម

តពីនោះទៅ ក៏កំណត់ថា ចំរៀកសាច់គូៗ ដែលគេសម្គាល់ថា **យកនៈ** ថ្លើម មានក្នុងសរីរៈ ដោយវណ្ណៈថ្លើមមានពណ៌ក្រហម ដូចពណ៌ស្រទាប់ក្រៅផ្កាកុមុទក្រហម ។ ដោយសណ្ឋាន ថ្លើមមានគល់តែមួយចុងមួយគូ មានសណ្ឋានដូចផ្កាល្ហុសផ្លុង ។ ក៏ថ្លើមរបស់មនុស្ស អ្នកមានបញ្ញាអន់ថយ មានចែកមួយប៉ុន្តែធំ ថ្លើមរបស់មនុស្សអ្នកមានបញ្ញាមានចែក ២-៣ ប៉ុន្តែតូចៗ ។ ដោយទិស ថ្លើមកើតក្នុងទិសខាងលើ ។ ដោយឱកាស ថ្លើមអាស្រ័យផ្នែកខាងស្តាំហើយស្ថិត នៅត្រង់ចន្លោះនៃដោះទាំង២ ។

ក្នុងថ្លើមនោះក៏កំណត់ថា ថ្លើមរមែងមិនដឹងថា វាអាស្រ័យផ្នែកខាងស្តាំនៅត្រង់ចន្លោះនៃដោះទាំង ២ សូម្បីផ្នែកខាងស្តាំនៅត្រង់ចន្លោះនៃដោះទាំង ២ នោះ ក៏មិនដឹងថា ថ្លើមអាស្រ័យវា ហើយតាំងនៅ ប្រៀបដូចចំណិតសាច់ដែលព្យួរនៅលើថ្នាំងដី រមែងមិនដឹងថា វាព្យួរនៅលើថ្នាំងដី សូម្បីថ្នាំងដីក៏មិនដឹងថា ចំរៀកសាច់ព្យួរនៅលើវាដូច្នោះ ។ ព្រោះថាធម៌ទាំងនេះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ប៉ុន្តែដោយបរិច្ឆេទកំណត់ថា ថ្លើមកំណត់ ដោយចំណែកនៃថ្លើម នេះជាការកំណត់ថ្លើមនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ថ្លើម ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

## កិលោមកំ = **វាវ**

*តពីនោះទៅក៏កំណត់ថា កិលោមកំវាវមានក្នុងសរីរៈនេះ ដោយវណ្ណៈ វាវមាន ២ ប្រភេទគឺ ប្រភេទបិទ និងប្រភេទមិនបិទ មានពណ៌ស ដូចសំពត់ចាស់ ។ ដោយសណ្ឋាន វាវ មានសណ្ឋានដូចឱកាសរបស់ខ្លួន ។ដោយទិស វាវកើតក្នុងទិសទាំង ២ដោយឱកាស វាវ ប្រភេទបិទហ៊ុមព័ទ្ធបេះដូងផង និងតម្រងបស្សាវៈផងហើយតាំងនៅ វាវ ប្រភេទមិនបិទហ៊ុមសាច់ក្រោមស្បែកទូទាំងសរីរៈហើយតាំងនៅ ។*

*បណ្ដាវាវទាំងនោះ កំណត់ថា វាវរមែងមិនដឹងថា វាត្រូវហ៊ុមព័ទ្ធបេះដូង និងតម្រងបស្សាវៈ និងហ៊ុមព័ទ្ធសាច់ក្រោមស្បែកទូទាំងសរីរៈ សូម្បីបេះដូង និងតម្រងបស្សាវៈ និងសាច់ទូទាំងសរីរៈ ក៏រមែងមិនដឹងថា វាត្រូវវាវហ៊ុមព័ទ្ធដែរ ប្រៀបដូចជាសាច់ដែលត្រូវសំពត់ចាស់ហ៊ុមព័ទ្ធ សំពត់ចាស់ក៏រមែងមិនដឹងថា វាហ៊ុមព័ទ្ធសាច់ សូម្បីសាច់ក៏រមែងមិនដឹងថា វាត្រូវសំពត់ចាស់ហ៊ុមព័ទ្ធដូច្នោះ ។ ព្រោះថាធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទក៏កំណត់ថា វាវខាងក្រោមកំណត់ដោយសាច់ ខាងលើកំណត់ដោយស្បែក ខាងទទឹងកំណត់ដោយចំណែកនៃវាវ នេះជាការកំណត់វាវទាំងនោះ ដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់វាវដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។*

## បិហកំ = **ក្រពះ**

តពីនោះទៅក៏កំណត់ថា ដោយវណ្ណៈ ក្រពះខាងក្នុងសរីរៈ មានពណ៌ខៀវ មានពណ៌ដូចផ្កាគន្ទីស[១]ក្រៀមៗ ដោយសណ្ឋាន ភាគច្រើនក្រពះមានសណ្ឋានដូចអណ្ដាតកូនគោខ្មៅ មិនព័ទ្ធគ្នាប្រមាណ ៧ ផ្ទាប់ ។ ដោយទិស ក្រពះកើតក្នុងទិសខាងលើ ។ ដោយឱកាស ក្រពះតាំងនៅខាងឆ្វេងនៃបេះដូង អាស្រ័យផ្នែកខាងលើផ្ទៃពោះ ។ កាលចេញមកខាងក្រៅ ព្រោះត្រូវប្រហារដោយគ្រឿងប្រហារសត្វក៏អស់ជីវិត ។

ក្នុងក្រពះនោះក៏កំណត់ថា ក្រពះរមែងមិនដឹងថាវាអាស្រ័យផ្នែកខាងលើផ្ទៃពោះ សូម្បីផ្នែកខាងលើផ្ទៃពោះ ក៏រមែងមិនដឹងថា ក្រពះអាស្រ័យវាហើយតាំងនៅ ប្រៀបដូចដុំអាចម៍គោ អាស្រ័យនៅខាងលើពោះហើយតាំងនៅ រមែងមិនដឹងថា វាអាស្រ័យខាងលើពោះហើយតាំងនៅ សូម្បីផ្នែកខាងលើនៃពោះក៏មិនដឹងថា ដុំអាចម៍គោអាស្រ័យនៅលើវាដូច្នោះ ព្រោះថាធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ក្រពះកំណត់ដោយចំណែកនៃក្រពះ នេះជាការកំណត់ក្រពះនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

---

១-អភិធានប្បទីបិកា ទំព័រ ២៣៤ ថា និគ្គុណ្ឌិ ប្រែថា ដើមគន្ទីស ។ តែបិដកលេខ ៧៣ ទំព័រ ១៤០ និគ្គណ្ឌិ ប្រែថា ឈើភ្លីង ។

## បច្ចាសំ = **ស្ងួត**

*តពីនោះទៅក៏កំណត់ថា ដោយវណ្ណៈ ស្អួតមានប្រភេទចំរៀកសាច់ ៣២ ចំរៀកខាងក្នុងសរីរៈ ពណ៌ក្រហមដូចផ្លៃល្វាស្ទើរទុំ ។ ដោយសណ្ឋាន ស្អួតមាន សណ្ឋានដូចនំដែលកាត់មិនស្មើ អាចារ្យមួយពួកពោលថា មានសណ្ឋានដូច គំនរជុំឥដ្ឋសម្រាប់ប្រក់ ដូច្នេះក៏មាន ។ ស្អួតនោះមិនមានរស មិនមានឱជៈ ដូច ចំបើង ដែលសត្វទំពាស៊ីហើយ ព្រោះត្រូវប៉ះចំហាយក្តៅខណ្ឌៗ ដែលកើតពីកម្ម ដែលហុយឡើង ព្រោះមិនមានអាហារដែលទំពា ដែលលេប ។ ដោយទិស ស្អួត កើតក្នុងទិសខាងលើ ដោយឱកាស ស្អួតតាំងសំយុងចុះឱន ក្រសោបបេះដូង និង ថ្លើម ត្រង់ចន្លោះដោះទាំង ២ ខាងក្នុងសរីរៈ ។*

*បណ្តាស្អួតនោះក៏កំណត់ថា ស្អួតរមែងមិនដឹងថា វាតាំងព្យួរត្រង់ចន្លោះ ដោះទាំង ២ ខាងក្នុងសរីរៈ សូម្បីដោះទាំង ២ ក្នុងសរីរៈក៏មិនដឹងថា ស្អួតតាំង ព្យួរក្នុងវា ប្រៀបដូចសំបុកសត្វតាំងព្យួរខាងក្នុងជង្រុកចាស់ រមែងមិនដឹងថា វា តាំងព្យួរខាងក្នុងជង្រុកចាស់ សូម្បីខាងក្នុងជង្រុកចាស់ក៏មិនដឹងថា សំបុកសត្វ តាំងព្យួរ ក្នុងវាដូច្នោះ ព្រោះថា ធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ នេះជាការកំណត់ស្អួតនោះ ដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ស្អួត ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។*

## អន្តំ = **ពោះវៀនធំ**

គតិនោះទៅក៏កំណត់ថា ដោយវណ្ណៈ ពោះវៀនធំមានប្រវែង ៣២ ហត្ថជារបស់បុរស បត់ជា ២១ ផ្នត់ ប្រវែង ២៨ ហត្ថជារបស់ស្ត្រី ហើយបត់ទៅមកបាន ២១ ផ្នត់ ពណ៌សដូចពណ៌ស្ករក្រួស ឬកំបោរស ។ ដោយសណ្ឋាន ពោះវៀនធំ មានសណ្ឋានដូចពស់ ដែលគេកាត់ក្បាលដាក់ធ្លាយក្នុងថ្លុកឈាម ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស ពោះវៀនធំតាំងនៅខាងក្នុងសរីរៈ ដែលមានរណ្តៅក និងផ្លូវធ្វើដំណើររបស់ករីសៈ(ឧច្ចារៈ)ជាទីបំផុត ព្រោះវាជាប់នឹងបំពង់កខាងលើ និងផ្លូវលាមកក្នុងផ្នែកខាងក្រោម ។

ក្នុងពោះវៀនធំក៏កំណត់ថា ពោះវៀនធំមែនមិនដឹងថា វាតាំងនៅខាងក្នុងសរីរៈ សូម្បីសរីរៈក៏មិនដឹងថា ពោះវៀនធំតាំងនៅក្នុងវា ប្រៀបដូចរាងកាយសត្វពស់ដាច់ក្បាល ដែលតាំងនៅខាងក្នុងស្នូកឈាម រមែងមិនដឹងថា វាតាំងនៅក្នុងស្នូកឈាម សូម្បីស្នូកឈាមក៏មិនដឹងថា រាងកាយសត្វពស់ដាច់ក្បាលតាំងនៅក្នុងវាដូច្នេះ ព្រោះថា ធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទក៏កំណត់ថា ពោះវៀនធំកំណត់ ដោយចំណែកនៃពោះវៀនធំ នេះជាការកំណត់ពោះវៀនធំដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈក៏ដូចគ្នានឹងសក់នោះឯង ។

## អង្គគុណំ = **ពោះវៀនតូច**

*តពីនោះទៅក៏កំណត់ថា ដោយវណ្ណៈ ពោះវៀនតូចក្នុងចន្លោះពោះវៀនធំខាងក្នុងសរីរៈ មានពណ៌សដូចពណ៌នៃឫសស្គន់ ។ ដោយសណ្ឋាន ពោះវៀនតូច មានសណ្ឋានដូចឫសស្គន់ នោះឯង អាចារ្យមួយពួកពោលថា មានសណ្ឋានដូចទឹកនោមគោដូច្នេះក៏មាន ។ ដោយទិស ពោះវៀនតូចកើតក្នុងទិសទាំង ២ ។ ដោយឱកាស ពោះវៀនតូចព័ទ្ធចុងមាត់ចង្វាយពោះវៀនធំរួមគ្នា ដូចខ្សែគ្រឿងយន្ត ដែលគ្រឿងយន្តទាញ របស់នាយជាងធ្វើការងារទាំងឡាយ មានការបោះនិងការចាំងជាដើម ដែលតាំងនៅក្នុងចង្វាយពោះវៀនធំ ២១ ចង្វាយ ដូចខ្សែដែល ក្រងធ្វាយ ក្នុងចន្លោះមណ្ឌលខ្សែជូតជើងតាំងនៅខ្សែជូតជើងនោះ ។*

*ក្នុងពោះវៀនតូចនោះ ក៏កំណត់ថា ពោះវៀនតូចរមែងមិនដឹងថា វាព័ទ្ធពោះវៀនធំខាងក្នុងពោះវៀនធំ ២១ ចង្វាយទុក សូម្បីពោះវៀនធំក៏មិនដឹងថា ពោះវៀនតូចព័ទ្ធវាទុក ប្រៀបដូចខ្សែ(តូច)ដោតចង្វាយខ្សែជូតជើង(ខ្សែធំ) រមែងមិនដឹងថា វាដោតខ្សែជូតជើងទុក សូម្បីចង្វាយខ្សែជូតជើងក៏មិនដឹងថា ខ្សែ(តូច) ដោតវាទុកដូច្នេះ ។ ព្រោះថា ធម៌ទាំងនេះ វៀកចាកការត្រិះរិះ និងការពិចារណា ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា ពោះវៀនតូច កំណត់ដោយ*

ចំណែកនៃពោះវៀនតូច នេះជាការកំណត់ពោះវៀនតូចដោយសភាគៈ ចំណែកការកំណត់ ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ពោះវៀនតូចដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

## ឧទរិយំ = **អាហារថ្មី**

តពីនោះទៅក៏កំណត់ថា ដោយវណ្ណៈ អាហារថ្មី មានពណ៌ដូចដែលលេបចូលទៅ ដោយសណ្ឋាន អាហារថ្មី មានសណ្ឋានដូចអង្ករដែលចងជូរៗក្នុងសំពត់តម្រងទឹក ។ ដោយទិស អាហារថ្មីកើតក្នុងទិសខាងលើ ។ ដោយឱកាស អាហារថ្មីតាំងនៅខាងក្នុងផ្ទៃពោះ ធម្មតាផ្ទៃពោះ មានជាផ្ទាំងរបស់ពោះវៀនធំប៉ោងខ្យល់ ដែលកើតឯងត្រង់កណ្តាលសំពត់សើម ដែលត្រូវប្របាច់ទាំងសងខាង ខាងក្រៅរលោង ខាងក្នុងកកកុញដោយគំនរសាច់ ដូចសំពត់ជូតឈាមរដូវរបស់ស្ត្រី អាចារ្យមួយពួកពោលថា ដូចខាងក្នុងនៃផ្ទៃខ្នុរស្អោរដូច្នេះក៏មាន ។ ក្នុងពោះនោះ មានដង្កូវផ្សេងដោយដង្កូវ ៣២ ត្រកូលយ៉ាងនេះគឺ ត្រកូលតក្កោលកៈ (ខ្នាតផ្ទៃក្រវាញ) កណ្ឌុប្បាទកៈ (ខ្នាតជន្ទេន) តាលហីរកៈ (ខ្នាតបន្ទាត្នោត) ជាដើម ជ្រៀតបៀតជញ្ជគ្នាដណ្តើមចំណី អាស្រ័យជាប្រចាំ កាលមិនមានអាហារ មានទឹក និងបាយជាដើម ក៏លោតកម្រើកស្រែករងំត្បុលចូលសាច់បេះ

ដូង និងពេលមនុស្សបរិភោគអាហារចូល មានទឹក និងបាយជាដើមទៅ ក៏បែរមុខ ប្រញាប់ប្រញាល់ដណ្ដើមអាហារ ២-៣ មាត់ ដែលមនុស្សលេបចូលទៅគ្រា ដំបូង ។ (ពោះ)នោះ ក៏ក្លាយទៅជាផ្ទះកំណើត មានបង្គន់ មានមន្ទីរពេទ្យ និងមាន ព្រៃស្មសានរបស់ដង្កូវទាំងនោះ ប្រៀបដូចជាក្នុងសរទរដូវភ្លៀងខ្លាំងៗ បង្អុរចុះ ក្នុងស្រះកខ្វក់ ជិតទ្វារស្រុកនៃមនុស្សចណ្ឌាល សំណល់ផ្សេងៗ មានឧច្ចារៈ បស្សាវៈ ចំរៀកស្បែក ឆ្អឹង សរសៃ ទឹកមាត់ ទឹកសំបោរ និងឈាមជាដើម ត្រូវ ទឹកនាំយកទៅ រួមប្រឡូកប្រឡំ ដូចពាង និងទឹក ក៏មានត្រកូលដង្កូវតូចធំកើតឯង កន្លងទៅ ២-៣ ថ្ងៃ ក៏ក្ដៅ និងពុះឡើងដោយព្រះអាទិត្យ ពពុះខាងលើ មានពណ៌ ខៀវ មិនសមគួរដើរចូលទៅជិត ឬមើលមិនចាំបាច់ពោលទៅថ្វីដល់ការស្រូប ក្លិន ឬលិទ្ធរស មានឧបមាយ៉ាងណា ទឹក និងបាយជាដើម មានប្រការផ្សេងៗ ក៏ មានឧបមេយ្យយ៉ាងនោះឯង ។ អញ្ចែ្រ គឺធ្មេញបុកល្អិតហើយ ដៃ គឺអណ្ដាតត្រឡប់ទៅមកហើយ ប្រឡាក់ដោយទឹកមាត់ ប្រាសចាកសេចក្ដីព្រមដោយពណ៌ ក្លិន រស ក្នុងខណៈនោះជាដើម ដូចកំអួតក្នុងរាងកាយសុនខ រួមគ្នាប្រឡូក ប្រឡាក់ដោយស្លេស្មក្ដៅ ដោយកម្ដៅភ្លើងក្នុងពោះ និងការក្ដៅ មានត្រកូលដង្កូវ ធំតូចបណ្ដែតពងឡើងលើ ក៏ក្លាយទៅជាគំនរសម្រាម មានក្លិនស្អុយ គួរខ្ពើម

យ៉ាងក្រៃលែង ដែលស្អាប់ហើយធ្វើឱ្យមិនចង់ផឹកទឹក ស៊ីបាយជាដើម មិនចាំបាច់ពោលទៅថ្វីដល់បញ្ញាចក្ខុនោះ ។ ពោះជាទីកន្លែងនៃទឹក និងបាយជាដើម ដែលធ្លាក់ចុះទៅហើយ នឹងបែងចែកជា ៥ ចំណែក គឺ

១-សម្រាប់សត្វក្នុងពោះស៊ី

២-សម្រាប់ភ្លើងក្នុងពោះដុតឆេះ

៣-ក្លាយទៅជាបស្សាវៈ

៤-ក៏ក្លាយទៅជាឧច្ចារៈ

៥-ក្លាយទៅជាឱជារស ដែលទំនុកបម្រុងឧបត្ថម្ភដល់រាងកាយមានឈាម និងសាច់ជាដើម ។

ក្នុងអាហារថ្មីនោះ ក៏កំណត់ថា អាហារថ្មីរមែងមិនដឹងថា វានៅក្នុងពោះដែលមានក្លិនស្អុយ គួរខ្ពើមយ៉ាងក្រៃលែង សូម្បីពោះក៏មិនដឹងថា អាហារថ្មីនៅក្នុងវា ប្រៀបដូចកំអួតសុនខ ដែលនៅក្នុងពោះសុនខគួរខ្ពើមយ៉ាងក្រៃលែង សូម្បីពោះសុនខក៏មិនដឹងថា កំអួតសុនខនៅក្នុងវាដូច្នោះ ព្រោះថា ធម៌ទាំងនោះវៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទក៏កំណត់ថា អាហារថ្មីកំណត់ដោយចំណែកនៃអាហារថ្មី នេះជាការកំណត់

អាហារថ្មីនោះ ដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់អាហារថ្មី ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

## ករីសំ= អាហារចាស់

តពីនោះទៅក៏កំណត់ថា ដោយវណ្ណៈ អាហារចាស់ខាងក្នុងសរីរៈ ដោយច្រើន ក៏មានពណ៌ដូចអាហារដែលលេបចូលទៅ ។ ដោយសណ្ឋាន ក៏មានសណ្ឋានដូចឱកាស ដោយទិស កើតក្នុងទិសខាងក្រោម ដោយឱកាស តាំងនៅក្នុងអាហារ ដែលម្ដាយហើយនៅអាស្រ័យ ។ ធម្មតា ប្រទេសដែលអាហារម្ដាយហើយនៅអាស្រ័យក៏ជាប្រទេស ដូចខាងក្នុងបំពង់ឫស្សី និងបបុស មានកម្ពស់ប្រមាណ ៨ ធ្នាប់ នៅចុងពោះវៀនធំ ចន្លោះគល់ផ្ចិត និងឆ្អឹងខ្នងខាងក្រោម ប្រៀបដូចទឹកភ្លៀង ធ្លាក់ក្នុងទីខាងលើ (ខ្ពស់) ក៏ហូរចុះធ្វើទីខាងក្រោម (ទាប) ឱ្យពេញ មានឧបមាយ៉ាងណា ទឹក និងបាយជាដើមណាមួយ ដែលធ្លាក់ក្នុងទីនៅរបស់អាហារស្រស់(ថ្មី) ដែលភ្លើងក្នុងពោះដុតឱ្យឆ្អិនក្ដៅកើតជាពងក្លាយជារបស់ល្អិតទៅដូចម្សៅ ព្រោះភ្លើងធាតុធ្វើឱ្យល្អិតហើយក៏ហូរទៅតាមប្រហោងពោះវៀនធំ គាបប្រចាប់សន្សំទុក ដូចដីលឿង ដែលគេដាក់ក្នុងបំពង់ឫស្សី និងបបុស ក៏មានឧបមេយ្យដូច្នោះឯង ។

ក្នុងអាហារចាស់នោះ ក៏កំណត់ថា អាហារចាស់រមែងមិនដឹងថា វានៅក្នុងទីលំនៅរបស់អាហារដែលរម្ងាយទៅហើយ សូម្បីទីលំនៅរបស់អាហារចាស់ដែលរម្ងាយទៅហើយ ក៏មិនដឹងថា អាហារចាស់នៅក្នុងវា ប្រៀបដូចដីលៀងដែលគេ ដាក់ក្នុងបំពង់ឫស្សី ឬបបុស រមែងមិនដឹងថា ដីលៀងនៅក្នុងវាសូម្បីបំពង់ឫស្សី និងដើមបបុស ក៏មិនដឹងថា ដីលៀង នៅក្នុងវាដូច្នោះ ។ ព្រោះថាធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា អាហារចាស់កំណត់ដោយចំណែកនៃអាហារចាស់នេះជាការកំណត់ អាហារចាស់នោះដោយសភាគ ចំណែកការកំណត់ដោយវិសភាគៈក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់អាហារចាស់ ដោយវណ្ណៈជាដើមមានប្រការដូចពោលមកដូច្នេះ ។

## មត្ថលុង្គំ = ខួរក្បាល

តពីនោះទៅ ក៏កំណត់ថា ដោយវណ្ណៈ ខួរក្នុងក្បាលខាងក្នុងលលាដ៍សីសៈក្នុងសរីរៈ មានពណ៌សដូចផ្សិត ។ អាចារ្យមួយពួកពោលថា មានពណ៌ដូចទឹកដោះធ្និនដូច្នេះក៏មាន ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ដោយទិស កើតក្នុងទិសខាងលើ ដោយឱកាស ជាប្រភេទដុំខួរក្បាល ៤ ដុំ ដែលអាស្រ័យកម្រង

សរសៃ ៤ ស្នាម ខាងក្នុងត្រឡោកក្បាលនៃសរីរៈរួមគ្នា តាំងនៅ ដូចដុំម្សៅ ៤ ដុំ ដែលគេរួមគ្នាតាំងទុក ។ ក្នុងខួរក្បាលនោះ ក៏កំណត់ថា ខួរក្នុងក្បាលរមែងមិនដឹងថា វាតាំងនៅក្នុងត្រឡោកសីសៈ សូម្បីត្រឡោកសីសៈ ក៏មិនដឹងថា ខួរក្នុងក្បាលនៅក្នុងវា ប្រៀបដូចដុំម្សៅ ដែលគេដាក់ទុកក្នុងត្រឡោកឃ្លោកចាស់ ឬទឹកដោះឆ្អិន រមែងមិនដឹងថា វាតាំងនៅក្នុងត្រឡោកឃ្លោកចាស់ សូម្បីត្រឡោក-ទឹកឃ្លោកចាស់ ក៏មិនដឹងថា ដុំម្សៅឬទឹកដោះឆ្អិន នៅក្នុងវាដូច្នោះ ។ ព្រោះថាធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ខួរក្នុងក្បាលកំណត់ដោយ ចំណែកនៃខួរក្នុងក្បាល នេះជាការកំណត់ ខួរក្បាលនោះដោយសភាគៈ ចំណែកការកំណត់ ដោយវិសភាគៈក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ខួរក្នុងក្បាល ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

**បិត្តំ = ប្រមាត់**

តពីនោះទៅកំណត់ថា ប្រមាត់មាន ២ ប្រភេទគឺ ប្រមាត់ក្រៅស្រោម និងប្រមាត់ក្នុងស្រោម មានពណ៌ដូចប្រេងស្រគំចាស់ ។ អាចារ្យមួយពួក ពោលថាប្រមាត់ក្រៅស្រោម មានសណ្ឋានដូចផ្កាថ្កុលក្រៀម ដូច្នេះក៏មាន ។ ដោយសណ្ឋាន

មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស ប្រមាត់ក្រៅស្រោម វៀរត្រង់ក្រចក រោម សក់ និងធ្មេញ ដែលផុតពីសាច់ និងស្បែកដែលរឹងស្ងួតហើយ ជ្រាបចូលសរីរៈ ចំណែកដ៏សេស ដូចដំណក់ប្រេងជ្រាបចូលទឹក កាលកម្រើកហើយ កែវភ្នែកនឹងលឿង វិលមុខ ញ័រខ្លួន និងរមាស់ ។ ប្រមាត់ក្នុងស្រោម តាំងនៅក្នុងស្រោមទឹកប្រមាត់ ដែលដូចសំបកននោងព្រៃធំ អាស្រ័យសាច់ថ្លើមតាំងនៅក្នុងចន្លោះបេះដូង និងសួត កាលកម្រើកហើយ សត្វទាំងឡាយ នឹងឆ្កួតមានចិត្តវិបល្លាស លះបង់ហិរិឱត្តប្បៈ ធ្វើការដែលមិនគួរធ្វើ និយាយពាក្យដែលមិនគួរនិយាយ គិតសេចក្ដីដែលមិនគួរគិត ។

ក្នុងប្រមាត់នោះក៏កំណត់ថាប្រមាត់ក្រៅស្រោម រមែងមិនដឹងថា វាជ្រាបគ្រប់សរីរៈ សូម្បីសរីរៈ ក៏មិនដឹងថា ប្រមាត់ក្រៅស្រោមជ្រាបលើវា ប្រៀបដូចប្រេងជ្រាបលើទឹក រមែងមិនដឹងថា វាជ្រាបលើទឹក សូម្បីទឹកក៏មិនដឹងថា ប្រេងជ្រាបលើវាដូច្នោះ ។ ប្រមាត់ក្នុងស្រោម ក៏រមែងមិនដឹងថា វានៅក្នុងស្រោមទឹកប្រមាត់ សូម្បីស្រោមទឹកប្រមាត់ក៏មិនដឹងថា ប្រមាត់ក្នុងស្រោមនៅក្នុងវា ប្រៀបដូចទឹកភ្លៀង ដែលនៅក្នុងសំបកននោងព្រៃ រមែងមិនដឹងថា វានៅក្នុងសំបកននោងព្រៃ

សូម្បីសំបកននោងព្រៃ ក៏មិនដឹងថា ទឹកភ្លៀងនៅក្នុងវាដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា ប្រមាត់កំណត់ដោយចំណែកនៃប្រមាត់ នេះជាការកំណត់ប្រមាត់នោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ប្រមាត់ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

### សេម្ហំ=ស្លេស្ម

តពីនោះទៅ ក៏កំណត់ថា ដោយវណ្ណៈ ស្លេស្មមានប្រមាណ ១ បាត្រ ក្នុងសរីរៈ មានពណ៌ស ដូចពណ៌នៃស្លឹកខ្ទុង ។ ដោយសណ្ឋាន មានសណ្ឋាន ដូចឱកាស ។ ដោយទិស កើតក្នុងទិសខាងលើ ។ ដោយឱកាស តាំងនៅក្នុងផ្ទៃពោះ ។ ក្នុងវេលាបរិភោគទឹក និងភោជនជាដើម កាលទឹក និងភោជនជាដើមធ្លាក់ចុះ ក៏បែកចេញជា ២ ចំណែក ហើយត្រឡប់មកគ្របទៀត កាលមានតិច ផ្ទៃពោះក៏មានក្លិនដូចសាកសពគួរខ្ពើមយ៉ាងក្រៃលែង ដូចក្បាលខ្មោច ដូចពងមាន់ស្អុយប្រៀបដូចសារាយក្នុងទឹក កាលចំរៀកឈើ ឬក៏ក្បឿងធ្លាក់ ក៏ដាច់ជា ២ ចំណែក ហើយក៏ត្រឡប់មកក្រសោបទៀតដូច្នោះ ។ ការភេីក្ត និយាយក្តី ក៏មានក្លិនស្អុយដូចសាកសពស្អុយដោយក្លិន ដែលភាយឡើងពីពោះនោះ ហើយមនុស្សនោះ ក៏ត្រូវគេនិយាយដេញថា ចេញទៅឯងមានក្លិនមិនល្អ កាលស្លេស្មកកពូនក្រាស់ឡើង ក៏ជួយរម្ងាប់ក្លិនស្អុយ តាំងនៅក្នុងពោះនោះឯង ដូចក្តារបិទបង្គន់ ។

ក្នុងស្ទេស្មនោះ ក៏កំណត់ថា ស្ទេស្មរមែងមិនដឹងថា វានៅក្នុងពោះ សូម្បីពោះក៏មិនដឹងថា ស្ទេស្មនៅក្នុងវា ប្រៀបដូចពពងនៅលើស្រះកខ្វក់ រមែងមិនដឹងថាវា នៅក្នុងស្រះកខ្វក់ សូម្បីស្រះកខ្វក់ ក៏មិនដឹងថា ពពងនៅលើវាដូច្នោះ ។ ព្រោះថា ធម៌ទាំងនេះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា ស្ទេស្មកំណត់ដោយចំណែកនៃស្ទេស្មនេះ ជាការកំណត់ស្ទេស្មនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ស្ទេស្មដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

### បុព្វោ=ខ្ទុះ

តពីនោះទៅក៏កំណត់ថា ដោយវណ្ណៈ ខ្ទុះមានពណ៌ដូចស្លឹកឈើលឿង ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស ធម្មតាឱកាសរបស់ខ្ទុះតាំងនៅប្រចាំមិនបាន ។ ខ្ទុះតាំងនៅក្នុងសរីរៈ កាលត្រូវដង្គត់ បន្លា គ្រឿងប្រហារ ឬអណ្ដាតភ្លើងជាដើម ពាល់ត្រូវហើយក៏ចេញឈាម ឬកើតបូស និងដំុពកជាដើម ខ្ទុះក៏មានក្នុងទីនោះៗ ។

ក្នុងខ្ទុះនោះ ក៏កំណត់ថា ខ្ទុះរមែងមិនដឹងថា វាតាំងនៅក្នុងកន្លែងដែលត្រូវដង្គត់ ឬបន្លាជាដើមពាល់ត្រូវ ឬក្នុងកន្លែងដែលកើតបូស និងដំុពកជាដើម ក្នុងទី

*នោះៗ នៃសរីរៈ សូម្បីកន្ទែងសរីរៈក៏មិនដឹងថា ខ្ទុះនៅក្នុងវា ប្រៀបដូចជ័រឈើដែលហូរចេញ តាំងនៅក្នុងទីត្រវមុខពូថៅជាដើម ចោះក្នុងទីនោះៗ របស់ដើមឈើរមែងមិនដឹងថា វាតាំងនៅក្នុងទីត្រូវចោះរបស់ដើមឈើ សូម្បីទីត្រូវចោះរបស់ដើមឈើ ក៏មិនដឹងថា ជ័រតាំងនៅក្នុងវាដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ខ្ទុះកំណត់ដោយចំណែកនៃខ្ទុះ នេះជាការកំណត់ខ្ទុះនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ខ្ទុះដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។*

### លោហិតំ = **ឈាម**

*តពីនោះទៅ ឈាម មាន ២ យ៉ាងគឺ សន្និចិតលោហិត (ឈាមកក) និងសំសរណលោហិត (ឈាមរាវ) ។ ក៏កំណត់សន្និចិតលោហិតមុន ដោយវណ្ណៈមានពណ៌ ដូចជ័រក្តៅកក សំសរណលោហិត មានពណ៌ដូចជ័រពេលថ្លា ។ ដោយសណ្ឋាន ឈាមគ្រប់យ៉ាង មានសណ្ឋានដូចឱកាសរបស់ខ្លួន ។ ដោយទិសឈាមកក ស្ថិតនៅទិសខាងលើ ឈាមរាវកើតនៅទិសទាំងពីរ ។ ដោយឱកាសឈាមរាវផ្សាយទៅគ្រប់សរីរៈទាំងអស់ នៃឧបាទិន្នកសត្វតាមលំអាន នៃសរសៃ*

ឈាម វៀរលែងតែសក់ រោម និងធ្មេញដែលផុតចាកសាច់ និងស្បែកដែលរឹង និងស្ងួត ។ ឈាមកក ធ្វើចំណែកក្រោមរបស់ថ្លើមឱ្យពេញ ហើយធ្វើដំណក់ឈាមឱ្យធ្លាក់បន្តិចៗ លើបេះដូងតម្រងបស្សាវៈ និងសួតប្រមាណពេញមួយទូកដៃ ធ្វើបេះដូង តម្រងបស្សាវៈ និងសួតឱ្យសើម កាលមិនធ្វើបេះដូង និងតម្រងបស្សាវៈ ថ្លើមជាដើមឱ្យសើម សត្វទាំងឡាយនឹងស្រេកទឹក ។

ក្នុងឈាម ក៏កំណត់ថា ឈាមរមែងមិនដឹងថា វាធ្វើបេះដូង និងតម្រងបស្សាវៈជាដើមឱ្យសើម ហើយតាំងនៅត្រង់ចំណែកខាងក្រោមនៃថ្លើម សូម្បីត្រង់បេះដូង និងតម្រងបស្សាវៈជាដើម ក៏មិនដឹងថា ឈាមតាំងនៅក្នុងវា ឬធ្វើឱ្យវាសើមតាំងនៅ ប្រៀបដូចទឹកដែលនៅក្នុងភាជនៈចាស់ៗ ធ្វើដុំដីជាដើម ខាងក្រោមឱ្យសើម សូម្បីភាជនៈចាស់ៗ ឬក៏ដុំដីខាងក្រោម ក៏មិនដឹងថា ទឹកនៅក្នុងវា ឬធ្វើវាឱ្យសើមដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ឈាមកំណត់ដោយចំណែកនៃឈាម នេះជាការកំណត់ឈាមដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ឈាមដោយវណ្ណៈជាដើមប្រការដូចពោលមកដូច្នេះ ។

**សេទោ = ញើស**

*តពីនោះទៅ ក៏កំណត់ថា ដោយវណ្ណៈ ញើសក្នុងសរីរៈ មានពណ៌ដូចប្រេងល្ងថ្លា ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសទាំង២។ ដោយឱកាស ធម្មតាញើសមិនចេញគ្រប់ពេលទេ ។ ប៉ុន្តែប្រសិនបើញើសចេញគ្រប់កាល ឬព្រោះហេតុវេលាណាដែលសរីរៈក្តៅ ដោយកម្តៅភ្លើងពន្លឺថ្ងៃ និងរដូវវិបរិតជាដើម វេលានោះ ញើសហូរចេញចាកគ្រប់រណ្តៅសក់ និងរន្ធរោម ដូចទឹកក្នុងក្រឪឈូក និងជាងឈូក ដែលកាត់មិនស្មើល្មមលើកឡើងផុតពីទឹកដូច្នោះ ។ ព្រះយោគាវចរ ទើបកំណត់ញើសនោះ ដោយសណ្ឋានដោយរន្ធសក់ និងរណ្តៅរោមប៉ុណ្ណោះ ។ បុព្វាចារ្យទាំងឡាយពោលទុកថា ដែលព្រះយោគាវចរ កំណត់យកញើសជាអារម្មណ៍ គប្បីធ្វើទុកក្នុងចិត្ត ញើសដោយញើស ធ្វើរន្ធសក់ និងរណ្តៅរោមឱ្យពេញហើយតាំងនៅ ។*

*ក្នុងញើសនោះក៏កំណត់ថា ញើសរមែងមិនដឹងថា វាហូរចេញអំពីរន្ធសក់និងរណ្តៅរោម សូម្បីរន្ធសក់ និងរណ្តៅរោម ក៏មិនដឹងថា ញើសហូរចេញពីវាប្រៀបដូចទឹកដែលហូរចេញពីប្រហោងក្រឪឈូក និងជាងឈូក សូម្បីក្រឪឈូកនិងជាងឈូក ក៏មិនដឹងថា ទឹកហូរចេញពីវាដូច្នោះ ។ ព្រោះថា ធម៌ទាំងនេះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ញើសកំណត់ដោយចំណែកនៃញើស ។ នេះជាការកំណត់ញើសនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ញើស ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។*

## មេទោ = ខ្លាញ់ខាប់

*តពីនោះទៅ ក៏កំណត់ថា ដោយវណ្ណៈ ខ្លាញ់ខាប់នៅចន្លោះស្បែក និងសាច់ក្នុងសរីរៈ មានពណ៌ដូចរមៀត ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ។ មែនពិត សម្រាប់មនុស្សធាត់ ដែលមានខ្លាញ់ខាប់ផ្សាយទៅចន្លោះស្បែក និងសាច់ មានសណ្ឋានដូចសំពត់សំបកឈើចាស់ជ្រលក់រមៀត សម្រាប់មនុស្សស្គម ខ្លាញ់ខាប់អាស្រ័យសាច់ស្មង សាច់ជើង សាច់អាស្រ័យឆ្អឹងខ្នង និងសាច់ខ្នង និងសាច់ពោះរួមទុក មានសណ្ឋានដូចសំពត់សំបកឈើចាស់ជ្រលក់រមៀតដែលគេរួតដាក់ទុក ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស ខ្លាញ់ខាប់សម្រាប់មនុស្សធាត់ផ្សាយទៅទូទាំងសរីរៈ សម្រាប់មនុស្សស្គម អាស្រ័យសាច់ឆ្អឹងខ្នងជាដើម ក៏គឺខ្លាញ់ស្អិត មិនមែនរួតទុកដើម្បីជាប្រេងក្នុងក្បាល មិនមែនជាប្រេងក្នុងស្រូវ មិនមែនដើម្បីជាប្រទីប (ចង្កៀង) ព្រោះជារបស់គួរខ្ពើមយ៉ាងក្រៃលែង ។*

*ក្នុងខ្លាញ់ខាប់នោះកំណត់ថា ខ្លាញ់ខាប់រមែងមិនដឹងថា វាអាស្រ័យនៅទូទាំងសរីរៈ ឬសាច់ ស្មងជាដើមតាំងនៅ សូម្បីទូទាំងសរីរៈ ឬសាច់ស្មងជាដើមក៏មិនដឹងថា ខ្លាញ់ខាប់អាស្រ័យវាតាំងនៅ ប្រៀបដូចសំពត់សំបកឈើចាស់ជ្រលក់រមៀត ដែលផ្អែកលើគំនរសាច់ រមែងមិនដឹងថា វាដាក់ផ្អែកលើគំនរសាច់ សូម្បីគំនរសាច់ ក៏មិនដឹងថា សំពត់សំបកឈើចាស់ជ្រលក់រមៀត ផ្អែកលើវា*

ដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ខ្លាញ់ខាប់ខាងក្រោមកំណត់ដោយសាច់ ខាងលើកំណត់ដោយស្បែក ដោយជុំវិញកំណត់ដោយចំណែកនៃខ្លាញ់ខាប់ ។ នេះជាការកំណត់ខ្លាញ់ខាប់នោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ខ្លាញ់ខាប់ ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

អស្សុ =**ទឹកភ្នែក**

តពីនោះទៅកំណត់ថា ទឹកភ្នែកមានពណ៌ដូចប្រេងល្ងថ្លា ដោយសណ្ឋានមានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសទាំងពីរខាង ។ ដោយឱកាសតាំងនៅក្នុងប្រហោងភ្នែក ។ ក៏ទឹកភ្នែកនោះ មិនកកនៅក្នុងប្រហោងភ្នែកគ្រប់កាលដូចទឹកប្រមាត់ក្នុងស្រោមទឹកប្រមាត់ទេ ។ កំណត់បានយ៉ាងណាទៅ កាលណាសត្វទាំងឡាយ កើតសោមនស្ស ត្រេកអរ ក៏សើចខ្លាំង កើតទោមនស្ស តូចចិត្តក៏យំត្អូញត្អែរ ឬបរិភោគអាហារហឹរក៏ដូចគ្នា និងកាលណាភ្នែកទាំងសងខាងរបស់សត្វទាំងនោះ ត្រូវផ្សែងលម្អងធូលីជាដើមប៉ះ កាលនោះទឹកភ្នែកកើតឡើងព្រោះសោមនស្ស ទោមនស្ស និងអាហារហឹរជាដើម ក៏ញុំាងទឹកភ្នែកពេញតាមប្រហោងភ្នែក លោកអាចារ្យទាំងឡាយពោលថា ព្រះយោគាវចរកំណត់យកទឹកភ្នែកជាអារម្មណ៍ សូម្បីធ្វើទុកក្នុងចិត្តថា ទឹកភ្នែកនោះគឺទឹកភ្នែកក្នុងរណ្ដៅភ្នែកនោះឯង ។

ក្នុងទឹកភ្នែកនោះក៏កំណត់ថា ទឹកភ្នែករមែងមិនដឹងថា វាតាំងនៅក្នុងប្រហោងភ្នែក សូម្បីប្រហោងភ្នែក ក៏មិនដឹងថា ទឹកភ្នែកនៅក្នុងវា ប្រៀបដូចទឹកដែលនៅក្នុងគ្រាប់ផ្លែត្នោតខ្ចីកាត់ចុង រមែងមិនដឹងថា វាតាំងនៅក្នុងប្រហោងគ្រាប់ផ្លែត្នោតខ្ចីកាត់ចុង សូម្បីប្រហោងគ្រាប់ផ្លែត្នោតខ្ចីកាត់ចុង ក៏មិនដឹងថា ទឹកនៅក្នុងវាដូច្នោះ ព្រោះថា ធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ទឹកភ្នែកកំណត់ ដោយចំណែកនៃទឹកភ្នែក នេះជាការកំណត់ទឹកភ្នែកនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹកភ្នែកដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

## វសា = **ខ្លាញ់រាវ**

តពីនោះទៅកំណត់ថា ដោយវណ្ណៈ ខ្លាញ់រាវ គឺខ្លាញ់ដែលរលាយក្នុងសរីរៈ មានពណ៌ដូចប្រេងដែលចាក់ក្នុងបាយក្តាំង ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស តាំងនៅលើបាតដៃ ខ្នងដៃ បាតជើង ខ្នងជើង ខ្នងច្រមុះ ថ្ងាស និងចង្កេះស្មា ។ ប៉ុន្តែខ្លាញ់រាវនោះ មិនរលាយ តាំងនៅក្នុងឱកាសទាំងនោះគ្រប់ពេលទេ ។ ហេតុដូចម្តេចទៅ កាលណាកន្លែងទាំងនោះ កើតក្នុងចំហាយក្តៅ ព្រោះមិនត្រូវគ្នានឹងកម្តៅភ្លើង ពន្លឺថ្ងៃ រដូវ

និងធាតុដែលមិនត្រូវគ្នា កាលនោះខ្ញាញ់រាវ ក៏នឹងរលាយជ្រាបទៅក្នុងកន្លែងនោះ ដូចទឹកសន្សើមក្នុង អណ្ដូងដែលមានទឹកថ្លា ។

ក្នុងខ្ញាញ់រាវក៏កំណត់ថា ខ្ញាញ់រាវរមែងមិនដឹងថា វាជន់ទៅតាមបាតដៃជាដើម សូម្បីបាតដៃជាដើម ក៏មិនដឹងថាខ្ញាញ់រាវជន់ក្នុងវា ប្រៀបដូចទឹកសន្សើមដែលជន់ក្នុងស្រះ រមែងមិនដឹងថា វាជន់ក្នុងស្រះ សូម្បីស្រះក៏មិនដឹងថា ទឹកសន្សើមជន់ក្នុងវាដូច្នោះ។ព្រោះថាធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ខ្ញាញ់រាវកំណត់ដោយចំណែកនៃខ្ញាញ់រាវ នេះជាការកំណត់ខ្ញាញ់រាវនោះដោយសភាគៈ ចំណែកការកំណត់ ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ ខ្ញាញ់រាវដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

## ១៧ខេឡោ = **ទឹកមាត់**

តពីនោះទៅកំណត់ថា ដោយវណ្ណៈ ទឹកមាត់ខាងក្នុងមាត់ ក្នុងសរីរៈ ពណ៌ដូចពណ៌ពពុះទឹក ។ ដោយសណ្ឋាន មានសណ្ឋាន ដូចឱកាស ។ អាចារ្យមួយពួកពោលថា មានសណ្ឋានដូចពពុះទឹកសមុទ្រ ដូច្នេះក៏មាន ។ ដោយទិសកើតក្នុងទិសខាងលើ ។ ដោយឱកាស ហូរចុះចាកថ្ពាល់ទាំងសងខាងតាំងនៅត្រង់អណ្ដាត ។ ប៉ុន្តែទឹកមាត់នោះ មិនសន្សំតាំងនៅត្រង់ថ្ពាល់នោះគ្រប់កាលទៅទេ

ហេតុអ្វីទៅ? កាលណាសត្វទាំងឡាយឃើញ ឬលើកដល់អាហារដូច្នោះ ឬដាក់របស់ក្តៅ របស់ល្វីង ហឹរ ប្រៃ និងជូរអ្វីម្យ៉ាងក្នុងមាត់ និងកាលណាបេះដូងរបស់សត្វទាំងនោះ មិនសប្បាយ ឬកើតការហេវឡើងក្នុងកាលខ្លះ កាលនោះទឹកមាត់ក៏កើត ហូរចាកថ្ពាល់ទាំងសងខាង តាំងនៅត្រង់អណ្តាត ។ ប៉ុន្តែចុងអណ្តាត ទឹកមាត់នោះស្តើងត្រង់គល់អណ្តាតក្រាស់ ក៏ត្រប៉ៃ ឬរបស់ស៊ីដទៃៗអ្វីម្យ៉ាង ដែលគេដាក់ក្នុងមាត់ នឹងមិនទាន់រលាយទៅដូចទឹកក្នុងស្រះ ដែលជីកលើខ្សាច់ក្បែរមាត់ទន្លេ កាលនោះទឹកមាត់អាចធ្វើរបស់ស៊ីឱ្យសើម ។

ក្នុងទឹកមាត់នោះក៏កំណត់ថា ទឹកមាត់រមែងមិនដឹងថា វាហូរចេញអំពីថ្ពាល់ ទាំងសងខាងតាំងនៅត្រង់ផ្ទៃអណ្តាត សូម្បីផ្ទៃអណ្តាត ក៏មិនដឹងថា ទឹកមាត់ហូរចេញអំពីថ្ពាល់សងខាងតាំងនៅក្នុងវា ប្រៀបដូចទឹកដែលតាំងនៅក្នុងស្រះ ដែលគេជីកខ្សាច់ក្បែរទន្លេ រមែងមិនដឹងថា វាតាំងនៅលើផ្ទៃស្រះ សូម្បីផ្ទៃស្រះក៏មិនដឹងថា ទឹកនៅក្នុងវាដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះ វៀរចាកការត្រិះរិះការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ទឹកមាត់កំណត់ ដោយចំណែកនៃទឹកមាត់ នេះជាការកំណត់ទឹកមាត់នោះ ដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹកមាត់ ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ។

## សិង្ឃាណិកា = ទឹកសំបោរ

តពីនោះទៅក៏កំណត់ថា ដោយវណ្ណៈ ទឹកសំបោរ មានពណ៌ស ដូចពណ៌សន្ទះគ្លោតខ្ចី ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស អាចារ្យមួយពួកពោលថា មានសណ្ឋានដូចពន្លកផ្ដៅ ដែលគេដាក់ជាប់គ្នា ស្បៀតៗចូលទៅក្នុងប្រហោងច្រមុះដូច្នោះក៏មាន ។ ដោយទិស កើតក្នុងទិសខាងលើ ។ ដោយឱកាសសំបោរនៅពេញច្រមុះ ប៉ុន្តែថា ទឹកសំបោរនោះ មិនសន្សំនៅក្នុងប្រហោងច្រមុះគ្រប់កាលទេ ហេតុអ្វីទៅ? បុរសខ្ចប់ទឹកដោះជូរទុកក្នុងស្លឹកឈូក យកបន្លាចោះស្លឹកឈូក ខាងក្រោមទីនោះ ដុំទឹកដោះជូរ ក៏នឹងហូរចេញចាកប្រហោងនោះ ធ្លាក់ចុះមកក្រៅ មានឧបមាយ៉ាងណា កាលណាសត្វទាំងឡាយយំ ឬកើតធាតុកម្រើក ដោយអាហារ និងរដូវ ដែលមិនត្រូវគ្នា កាលនោះ ខួរក្នុងក្បាលដែលក្លាយជាស្លេស្ម៍ ហើយហូរចេញពីក្បាលតាមប្រហោងលើពិតានមាត់នៅពេញច្រមុះ ដូច្នោះដូចគ្នា ។

ក្នុងទឹកសំបោរនោះកំណត់ថា ទឹកសំបោររមែងមិនដឹងថា វានៅក្នុងប្រហោងច្រមុះ សូម្បីប្រហោងច្រមុះក៏មិនដឹងថា ទឹកសំបោរនៅក្នុងវា ប្រៀបដូចទឹកដោះជូរ ដែលគេដាក់ក្នុងប្រហោងខ្យង រមែងមិនដឹងថា វានៅក្នុងប្រហោងខ្យង

សួម្បីប្រហោងខ្យង ក៏មិនដឹងថា ទឹកដោះជូរនៅក្នុងវាដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថាទឹកសំបោរ កំណត់ដោយចំណែកនៃទឹកសំបោរ នេះជាការកំណត់ទឹកសំបោរនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹកសំបោរដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

## លសិកា = ទឹករំអិល

តពីនោះទៅ ក៏កំណត់ថា សាកសពដែលរអិលកើតក្នុងខាងក្នុងទីតនៃសរីរៈ ខាងក្នុងសរីរៈ ឈ្មោះថា ទឹករំអិល ។ ដោយវណ្ណៈទឹករំអិលនោះ មានពណ៌ដូចជ័រដើមកណិការ ។ ដោយសណ្ឋាន មានសណ្ឋាន ដូចឱកាស ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស ឱ្យសម្រេចកិច្ច គឺនាទីជាជំណាក់ប្រេង ដែលតនៃឆ្អឹងទាំងឡាយ តាំងនៅខាងក្នុងទីត ១៨០ កន្លែង ។ ទឹករំអិលនោះ របស់អ្នកណាមានតិច អ្នកនោះ ក្រោកឡើង អង្គុយចុះ ឈានដើរទៅខាងមុខ ថយមកខាងក្រោយ ផ្ការដៃ លាតដៃ ឆ្អឹងទាំងឡាយក៏លាន់ឮ ដើរទៅក៏ដូចធ្វើសំឡេងផ្ទាត់ម្រាមដើរផ្លូវឆ្ងាយទៅបានសួម្បី ១ យោជន៍ ២ យោជន៍ វាយោធាតុក៏កម្រើក (ខ្យល់)

ខ្ជួនក៏លំបាក ចំណែកទឹករំអិលរបស់អ្នកណាមានច្រើន អ្នកនោះឆ្អឹងទាំងឡាយក៏មិនលាន់ឮកុបកាប់ ក្នុងខណៈក្រោកឡើង និងអង្គុយចុះជាដើម សូម្បីដើរផ្លូវយូរៗ វាយោធាតុក៏មិនកម្រើក ខ្ជួនក៏មិនលំបាក ។

ក្នុងទឹករំអិលនោះក៏កំណត់ថា ទឹករំអិលរមែងមិនដឹងថា វាបន្តក់ប្រេងក្នុងទីត ១៨០ កន្លែង សូម្បីទីត ១៨០ កន្លែង ក៏មិនដឹងថា ស្រក់ដំណក់ប្រេងនៅលើវា ប្រៀបដូចប្រេងបន្តក់ក្លៅរថ រមែងមិនដឹងថា វាបន្តក់ប្រេងក្លៅរថ សូម្បីក្លៅរថក៏មិនដឹងថា ដំណក់ប្រេងនោះ នៅលើវាដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ទឹករំអិលកំណត់ដោយចំណែកនៃទឹករំអិល នេះជាការកំណត់ទឹករំអិលនោះ ដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹករំអិលដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

**មុត្តំ = ទឹកមូត្រ (បស្សាវៈ)**

តពីនោះទៅកំណត់ថា ដោយវណ្ណៈ ទឹកមូត្រខាងក្នុងសរីរៈ មានពណ៌ ដូចទឹកក្បុងសណ្តែករាជមាស ។ ដោយសណ្ឋាន មានសណ្ឋានដូចទឹក ដែលនៅក្នុងថ្នាំងទឹកពេញដោយទឹក ដែលគេដាក់ផ្កាប់មាត់ ។ ដោយទិស កើតក្នុងទិសខាង

ក្រោម ។ ដោយឱកាស តាំងនៅក្នុងតម្រងបស្សាវៈ ។ ថង់បស្សាវៈ លោកហៅថាតម្រងបស្សាវៈ ប្រៀបដូចរសទឹកកខ្វក់រមែងចូលទៅក្នុងឆ្នាំង ដែលមិនមានមាត់ ដែលគេដាក់ក្នុងស្រះកខ្វក់ ផ្លូវចូលរបស់រសទឹកកខ្វក់នោះ មិនប្រាកដយ៉ាងណា ទឹកមូត្រចូលក្នុងសរីរៈ អំពីផ្លូវចូលទៅរបស់ទឹកមូត្រនោះមិនប្រាកដ ចំណែកផ្លូវចេញប៉ុណ្ណោះប្រាកដ ។

ក្នុងទឹកមូត្រនោះក៏កំណត់ថា ទឹកមូត្ររមែងមិនដឹងថា វានៅក្នុងតម្រង-បស្សាវៈ សូម្បីតម្រងបស្សាវៈ ក៏មិនដឹងថា ទឹកមូត្រតាំងនៅក្នុងវា ប្រៀបដូចរសទឹកកខ្វក់ ដែលគេដាក់ក្នុងស្រះកខ្វក់ រមែងមិនដឹងថា វានៅក្នុងឆ្នាំងជ្រៅដែលមិនមានមាត់ សូម្បីឆ្នាំងជ្រៅក៏មិនដឹងថា រសទឹកកខ្វក់នៅក្នុងវាដូច្នោះ ។ ព្រោះថាធម៌ទាំងនោះ វៀរចាកការគិត និងការពិចារណា ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ទឹកមូត្រកំណត់ដោយចំណែកនៃតម្រងបស្សាវៈ ព្រោះថាចំណែកនៃទឹកមូត្រ នេះជាការកំណត់ទឹកមូត្រនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹកមូត្រ ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។ ការកំណត់អាការៈ ៣២ ប្រការដោយពណ៌ជាដើម ចប់តែប៉ុណ្ណេះ ។

ព្រោះអាស្រ័យការប្រកបរឿយៗនូវភាវនា ការចម្រើន ទ្វត្តិង្សាការនោះៗ ទ្វត្តិង្សាការមានសក់ជាដើម ក៏រមែងស្ទាត់ជំនាញ ប្រាកដច្បាស់នូវកោដ្ឋាសៈ ជាចំណែកៗដល់ព្រះយោគាវចរនោះ ដែលកំណត់ទ្វត្តិង្សាការនេះ ដោយវណ្ណៈ ជាដើមដោយប្រការដូច្នេះ ។ តពីនោះទៅ បុរសដែលមានកែវភ្នែកពិនិត្យមើលភួង-មាល័យនៃផ្កាទាំងឡាយដែលមាន ៣២ ពណ៌ ដែលក្រងដោយអំបោះតែមួយសរសៃ ផ្កាគ្រប់ផ្កា ក៏រមែងប្រាកដមិនមុនមិនក្រោយដូច្នោះ កាលព្រះយោគាវចរក្រឡេកមើលនូវកាយនេះដោយសតិថា ក្នុងកាយនេះមានសក់ជាដើម ធម៌ពួកនោះទាំងអស់ រមែងជាការប្រាកដមិនមុន មិនក្រោយក៏យ៉ាងនោះដែរ ។ សតិដែលតាំងឡើងក្នុងសក់ទាំងឡាយ ដែលទឹកដល់រមែងប្រព្រឹត្តទៅរហូតដល់ទឹកមូត្រតាំងតែពីនោះទៅមនុស្ស និងតិរច្ឆានជាដើម ដែលដើរទៅមកនឹងលះអាការៈជាសត្វប្រាកដច្បាស់អំពីគំនរនៃកោដ្ឋាសៈប៉ុណ្ណោះដល់ព្រះយោគាវចរនោះ ទឹកនិងភោជនដើមដែលសត្វទាំងនោះបរិភោគក៏ប្រាកដច្បាស់ដូចដាក់ទៅក្នុងកោដ្ឋាសៈ ។

ក្នុងសេចក្តីនេះ អ្នកសួរពោលថា កាលបើដូច្នោះ ព្រះយោគាវចរនេះគប្បីធ្វើអ្វីតពីនោះទៅ? សូមពោលពន្យល់ដូច្នេះ និមិត្តនោះឯង ដែលព្រះយោ-គាវចរ គប្បីសេព គប្បីចម្រើន គប្បីធ្វើឱ្យច្រើន គប្បីកំណត់ឱ្យជាការកំណត់

ដោយល្អ ។ សួរថា ព្រះយោគាវចរនេះ សេព ចម្រើននិមិត្តនោះ ធ្វើឱ្យច្រើន កំណត់ឱ្យជាការកំណត់ដោយល្អ យ៉ាងណា? ឆ្លើយថា តាមពិត ព្រះយោគាវចរនេះ សេពនិមិត្ត ដែលទុត្តិងព្យាការ មានសក់ជាដើមប្រាកដមានដោយកោដ្ឋាសនោះ រមែងចងគួប ចូលទៅជិតដោយសតិ ឱ្យទាញបន្ទប់ គឺសតិ ឬធ្វើសតិដែលបាន ក្នុងនិមិត្តនោះ ឱ្យលូតលាស់ លោកហៅថា ចម្រើននិមិត្តនោះ ។ សេចក្តីថាធ្វើឱ្យច្រើន បានដល់ធ្វើនិមិត្តនោះឱ្យញយៗ ឱ្យប្រកបដោយសតិ ដែលវិតក្កៈ និងវិចារៈ ពាល់ត្រូវហើយ ។ សេចក្តីថា កំណត់ឱ្យជាការកំណត់ដោយល្អ បានដល់និមិត្ត ដែលជាការកំណត់ដោយល្អ មិនបាត់ទៅដោយប្រការណា ព្រះយោគាវចរ រមែង កំណត់ចូលទៅទទួល ចូលទៅចងនិមិត្តនោះដោយសតិ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត មនសិការកោសល្យ ការឆ្លាតក្នុងមនសិការណា ដែលពោល ទុកពីមុន ១០ យ៉ាងនេះគឺ១ ដោយលំដាប់ ២ ដោយមិនលឿនពេក ៣ ដោយ មិនយូរពេក ៤ ដោយការពារការរាយមាយ ៥ ដោយការកន្លងបញ្ញត្ត ៦ ដោយ បណ្តោយលំដាប់ ៧ ដោយលក្ខណៈ ៨-៩-១០ សូត្រទាំង ៣ ក្នុងមនសិការ-កោសល្យនោះ គប្បីជ្រាបថា ព្រះយោគាវចរធ្វើទុកក្នុងចិត្ត ដោយលំដាប់ឈ្មោះថា សេព ។ មនសិការដោយមិនលឿនពេក និងដោយមិនយូរពេក ឈ្មោះថា ចម្រើន មនសិការដោយការពារសេចក្តីរាយមាយ ឈ្មោះថា ការធ្វើឱ្យច្រើន មនសិការ ដោយការកន្លងបញ្ញត្តជាដើម ឈ្មោះថា កំណត់ឱ្យជាការកំណត់ដោយល្អ ។

ក្នុងសេចក្តីនេះ អ្នកសួរពោលថា ព្រះយោគាវចរនេះ ធ្វើទុកក្នុងធម៌ទាំង នេះ ដោយមនសិការកោសល្យ មានដោយលំដាប់ជាដើមយ៉ាងណា ។ សូម ពន្យល់ដូច្នេះ តាមពិតព្រះយោគាវចរនេះ ធ្វើទុកក្នុងចិត្តនូវសក់ ហើយលំដាប់ ពីនោះ ក៏ធ្វើទុកក្នុងចិត្តនូវរោម និងមិនធ្វើទុកក្នុងចិត្តនូវក្រចកទេ ដូចគ្នាយ៉ាងនោះ ព្រះយោគាវចរ ធ្វើទុកក្នុងចិត្តនូវរោម បន្ទាប់ពីនោះ មកធ្វើទុកក្នុងចិត្តនូវក្រចក មិនធ្វើទុកក្នុងចិត្តនូវធ្មេញទេ ។ ក្នុងអាការៈ ទាំងអស់នោះ ក៏នយ័នេះ ព្រោះ ហេតុអ្វី? ព្រោះថាព្រះយោគាវចរ កាលធ្វើទុកក្នុងចិត្តខុសលំដាប់ ក៏មានចិត្ត លំបាក ធ្លាក់ទៅចាកទ្វត្តិង្សាការភាវនាចម្រើនភាវនា មិនសម្រេច ព្រោះមិនបាន អស្សាទៈ សេចក្តីរីករាយដែលគួរបាន ដោយភាវនាសម្បត្តិ ប្រៀបដូចបុរសមិន ឆ្លាតឡើងកាំជណ្តើរ ៣២ កាំ ខុសលំដាប់ក៏លំបាកកាយ រមែងធ្លាក់ពីកាំជណ្តើរ ដែលខ្លួនឡើង មិនសម្រេចការឡើងដូច្នេះ ។

ម្យ៉ាងទៀត ព្រះយោគាវចរ សូម្បីធ្វើទុកក្នុងចិត្តដោយលំដាប់ ក៏ការធ្វើ ទុកក្នុងចិត្តមិនរហ័សពេកថា កេសា លោមាជាដើម ។ ព្រោះថា ព្រះយោគាវចរ កាលធ្វើទុកក្នុងចិត្តរហ័សពេក ក៏មិនអាចកំណត់ពណ៌ និងសណ្ឋានជាដើម ដែល ផុតចាកទ្វត្តិង្សាការ តពីនោះ ក៏មិនឈ្វាសក្នុងទ្វត្តិង្សាការ កម្មដ្ឋានក៏សូន្យទៅ ប្រៀបដូចបុរសកំពុងធ្វើដំណើរផ្លូវឆ្ងាយ មិនអាចកំណត់ផ្លូវរាប ផ្លូវលោក ដើម

ឈើ ទីទួល ទីក្រឡុក ផ្លូវបែកជាពីរជាដើម ដែលទៅផុតពីផ្លូវនោះក៏មិនឈ្លាស ក្នុងផ្លូវ ការដើរផ្លូវឆ្ងាយអស់ទៅដូច្នេះ ។

ម្យ៉ាងទៀត ព្រះយោគាវចរ ធ្វើទុកក្នុងចិត្តដោយមិនរហ័សពេក យ៉ាងណា ក៏ការធ្វើទុកក្នុងចិត្ត សូម្បីដោយមិនយឺតយូរពេកក៏យ៉ាងនោះ ។ ព្រោះថា ព្រះយោគាវចរ កាលធ្វើទុកក្នុងចិត្តយឺតយូរពេក ។ ក៏មិនដល់ការ សម្រេច ទុត្តិឯក្សាការភាវនា ប៉ុន្តែនឹងដល់ការផ្លាស់ប្តូរដោយកាមវិតក្កៈជាដើម ក្នុង ចន្លោះ ព្រោះដាច់ភាវនា ប្រៀបដូចបុរសដើរផ្លូវឆ្ងាយ ត្រូវស្នាក់ស្មើរនៅឯដើម ឈើ ភ្នំ និងត្រពាំងជាដើមក្នុងចន្លោះផ្លូវ ក៏មិនដល់តំបន់តាមបំណង ប៉ុន្តែដល់ការវិនាស ដោយសិង្ហ គោ និងខ្លា ជាដើមក្នុងចន្លោះផ្លូវនោះដូច្នោះ ។

ម្យ៉ាងទៀត ព្រះយោគាវចរ សូម្បីធ្វើទុកក្នុងចិត្តដោយមិនយឺតយូរពេក ក៏ រមែងធ្វើទុកក្នុងចិត្ត ដើម្បីដោយការពារសេចក្តីរាយមាយ ព្រះយោគាវចររមែង ធ្វើទុក ក្នុងចិត្តដោយប្រការដែលមិនរាយមាយ ព្រោះការងារដទៃៗ មានការងារ នវកម្ម ការកសាងជាដើម ។ ព្រះយោគាវចរដែលមានចិត្តរាយមាយទៅខាងក្រៅ មានការត្រិះរិះនៃចិត្ត មិនតាំងមាំក្នុងទុត្តិឯក្សាការ មានសក់ជាដើម ក៏មិនដល់ការ សម្រេចភាវនា ដល់ការវិនាសទៅក្នុងចន្លោះផ្លូវនោះឯង ដូចសម្លាញ់របស់ ព្រះពោធិសត្វ រមែងដល់នូវសេចក្តីវិនាស ក្នុងការធ្វើដំណើរទៅក្រុងតក្កសិលា

ចំណែកព្រះយោគាវចរ ដែលមានចិត្តមិនរាយមាយ មានការត្រិះរិះនៃចិត្តតាំងមាំក្នុងវុត្តិឯព្រាការមានសក់ជាដើម ក៏ដល់ការសម្រេចភាវនា ដូចព្រះពោធិសត្វដល់នូវការសម្រេចនៃរាជសម្បត្តិក្នុងក្រុងតក្កសិលាដូច្នេះដែរ ។ ធម៌ទាំងនោះ រមែងសម្រេចដោយអសុភៈ ដោយពណ៌ ឬដោយភាវៈទទេ ដោយអំណាចបារមី-ចរិយា និងការបង្អោនចិត្តជឿរបស់ព្រះយោគាវចរនោះ ដែលធ្វើទុកក្នុងចិត្តដោយការការពារ សេចក្ដីរាយមាយដោយប្រការដូច្នេះ ។

ម្យ៉ាងទៀតព្រះយោគាវចរធ្វើទុកក្នុងចិត្តទាំងនោះ ដោយការកន្លងបញ្ញត្ត ។ សេចក្ដីថា ដោយការកន្លងបញ្ញត្ត បានដល់ការធ្វើទុកក្នុងចិត្ត ដោយកន្លង គឺការលះបង់នូវវោហារជាដើមយ៉ាងនេះថា កេសា លោមា ហើយធ្វើទុកក្នុងចិត្ត ដោយអសុភៈជាដើម តាមដែលប្រាកដហើយ ។ ការធ្វើទុកក្នុងចិត្តយ៉ាងណា ? ប្រៀបដូច មនុស្សទាំងឡាយ ដែលចូលទៅអាស្រ័យក្នុងព្រៃ ធ្វើគ្រឿងសម្គាល់ ដោយកាច់មែកឈើជាដើម ដើម្បីសម្គាល់ទីដែលមានទឹក ព្រោះជាភូមិភាគដែលមិនធ្លាប់ស្គាល់ទៅ តាមគ្រឿងសម្គាល់នោះ រមែងបរិភោគទឹកបាន ប៉ុន្តែកាលណាធ្លាប់ស្គាល់ភូមិភាគហើយ ក៏បណ្ដោយមិនចាប់អារម្មណ៍នូវសញ្ញាសម្គាល់នោះ ចូលទៅកាន់ទី ដែលមានទឹកបរិភោគបានយ៉ាងណា ព្រះយោគាវចរនេះ ក៏ដូច្នោះដូចគ្នាការធ្វើទុកក្នុងចិត្តដោយធម៌ទាំងនោះ ដោយវោហារនោះៗ មាន **កេសា លោមា** ជាដើម ជាដំបូង កាលធម៌ទាំងនោះប្រាកដច្បាស់ ដោយអារម្មណ៍មាន

អសុភៈ ជាដើមយ៉ាងណាមួយ ក៏កន្លងគឺលះបង់វោហារនោះធ្វើទុកក្នុងចិត្ត ដោយអារម្មណ៍មានអសុភៈជាដើម ។

ក្នុងសេចក្តីនេះ អ្នកសួរពោលថា ធម៌ទាំងនោះប្រាកដដោយភាពជាអសុភៈជាដើមដល់ព្រះយោគាវចរនោះយ៉ាងណា ដោយវណ្ណៈយ៉ាងណា ឬដោយការៈជារបស់ទទេយ៉ាងណា? ម្យ៉ាងទៀត ព្រះយោគាវចរនេះធ្វើទុកក្នុងចិត្តដោយធម៌ទាំងនេះ ដោយអសុភៈយ៉ាងណា ដោយវណ្ណៈយ៉ាងណា ឬដោយការៈទទេយ៉ាងណា? ជាដំបូង សក់ទាំងឡាយ រមែងប្រាកដដល់ព្រះយោគាវចរនោះដោយអសុភៈមាន ៥ ចំណែកគឺ វណ្ណៈ (ពណ៌) សណ្ឋាន (ទ្រង់ទ្រាយ) គន្ធៈ (ក្លិន) អាសយៈ (ទីនៅ) និងឱកាស (ទីកើត) ព្រះយោគាវចរនេះ ក៏ធ្វើទុកក្នុងចិត្តក្នុងធម៌ទាំងនេះ មាន ៥ ចំណែកនោះឯងដោយអសុភៈ ។ យ៉ាងណាទៅ? ធម្មតាសក់ទាំងនោះដោយវណ្ណៈ មិនល្អ ជារបស់បដិកូល គួរខ្ពើមយ៉ាងក្រៃលែង ។ ពិតមែនហើយ មនុស្សទាំងឡាយឃើញសំបកឈើ ឬសរសៃអំបោះ មានពណ៌ដូចសក់ដែលធ្លាក់ទៅក្នុងទឹក ឬក្នុងបាយវេលាថ្ងៃ រមែងលះបង់ ឬខ្ពើមទឹក និងបាយសូម្បីជារបស់ពេញចិត្តដោយសម្គាល់ថា សក់ ។ ដោយសណ្ឋានក៏មិនល្អ ។ មែនពិត មនុស្សទាំងឡាយ ប៉ះសំបកឈើ ឬសរសៃអំបោះ ដែលមានសណ្ឋានដូចសក់ ដែលធ្លាក់ទៅក្នុងទឹក និងបាយក្នុងវេលាយប់ រមែងបោះបង់ចោល ឬខ្ពើម ទឹកនិងបាយ សូម្បីជារបស់ពេញចិត្តដោយសម្គាល់ថា សក់ ។ ដោយក្លិន

ក៏មិនល្អ ។ មែនពិត សក់ទាំងឡាយដែលវៀរចាកការតាក់តែង មានលាបប្រេង ជាប់ផ្កាឈើ វុំផ្សែងជាដើម មានក្លិនគួរខ្ពើមយ៉ាងក្រៃលែង មនុស្សស្រូបក្លិនសក់ ដែលបោះដាក់ក្នុងភ្លើង ត្រូវបិទច្រមុះ គេចចេញពីក្លិនអាក្រក់ ។ សូម្បីដោយលំនៅក៏មិនល្អ ។ មែនពិត សក់ទាំងនោះ ដែលដល់នូវការសន្សំហើយបន្ថែម ធ្វើឱ្យបរិបូណ៌ ដោយការអាស្រ័យដោយប្រមាត់ ស្លេស្ម ខ្ទុះ និងឈាម ដូចដើមម្រះព្រៅជាដើម ក្នុងគំនរសម្រាម ដោយការហូរមកកកនូវវត្ថុមិនស្អាតរបស់មនុស្សផ្សេងៗ ។ សូម្បីដោយឱកាសក៏មិនល្អ ។ មែនពិត សក់ទាំងនោះកើតក្នុងស្បែកទន់ ដែលគ្របសីសៈរបស់មនុស្សទាំងឡាយ លើកំពូលគំនរសាកសព ៣១ មាន រោមជាដើមដែលគួរខ្ពើមយ៉ាងក្រៃលែង ដូចដើមម្រះព្រៅជាដើមក្នុងគំនរសម្រាម ។ ក្នុងសាកសព ៣១ មានរោមជាដើមក៏ន័យនេះ ។ ព្រះយោគាវចរនេះ ធ្វើទុកក្នុងចិត្តដោយសក់ទាំងនោះ ដែលប្រាកដដោយអសុភៈដោយភាវៈ ជារបស់ មិនស្អាត ដោយប្រការយ៉ាងនេះ ។

ប្រសិនបើថា ធម៌ទាំងនេះប្រាកដដល់ព្រះយោគាវចរនោះ ដោយវណ្ណៈកាលបើដូច្នោះ សក់ទាំងឡាយក៏ប្រាកដដោយអំណាចនីលកសិណ ។ រោមធ្មេញក៏យ៉ាងនោះ រមែងប្រាកដដោយអំណាចឱទាតកសិណ ។ ក្នុងទ្វត្តិង្សាការគ្រប់យ៉ាងក៏ន័យនេះ ។ ព្រះយោគាវចរនេះរមែងធ្វើទុកក្នុងចិត្តក្នុងធម៌ទាំងនេះ ដោយ

អំណាចកសិណនោះៗឯង។ ធម៌ដែលប្រាកដដោយវណ្ណៈយ៉ាងនេះ ព្រះយោគាវចរក៏ធ្វើទុកក្នុងចិត្តដោយវណ្ណៈ ។ ប្រសិនបើធម៌ទាំងនោះប្រាកដដល់ព្រះយោគាវចរនោះ ដោយសភាវៈជារបស់ទទេ កាលបើដូច្នោះ សក់ទាំងឡាយ រមែងប្រាកដដោយមានការប្រជុំវិនិភោគរូប ដែលមានឱជៈគ្រប់ ៨ ដោយការកំណត់បំបែកចេញពីក្រុមនៃដុំ ។ រោមជាដើម ក៏ប្រាកដដូចសក់នោះដែរ ។ ព្រះយោគាវាចរនេះ រមែងធ្វើទុកក្នុងចិត្ត ក្នុងធម៌ទាំងនោះយ៉ាងនោះដូចគ្នា ។ ធម៌ដែលប្រាកដដោយភាវៈជារបស់សូន្យទទេនេះ ក៏ធ្វើទុកក្នុងចិត្តដោយភាវៈជារបស់សូន្យទទេ ។

ព្រះយោគាវចរនេះ ក៏ធ្វើទុកក្នុងចិត្តយ៉ាងនេះ ឈ្មោះថា ការធ្វើទុកក្នុងចិត្តក្នុងធម៌ទាំងនោះដោយលំដាប់ ។ សេចក្តីថាដោយបណ្តាយលំដាប់ អធិប្បាយថា ព្រះយោគាវចរ ដកសក់ដែលប្រាកដ ដោយមានអសុភៈជាដើមណាមួយ ហើយធ្វើទុកក្នុងចិត្តនូវរោម ជាអ្នកព្រងើយកន្តើយក្នុងសក់ទាំងឡាយ ហើយធ្វើទុកក្នុងចិត្តនូវរោមទាំងឡាយ កាលតាំងទុកក្នុងចិត្តនូវរោមទាំងឡាយ ក៏ឈ្មោះថាដកសក់ ប្រៀបដូចឈ្លើងព្រងើយកន្តើយត្រង់កន្លែង ដែលវាចាប់បានដោយកន្ទុយ ហើយទាមត្រង់កន្លែងដទៃដោយមាត់ កាលចាប់ទីនោះបាន ក៏ឈ្មោះថាបោះបង់ទីដទៃៗ ចេញដូច្នោះ ។ ក្នុងទ្វត្តិង្សាការទាំងអស់ ក៏យ៉ាងនេះ ។ ធម៌ទាំងនេះ កាលប្រាកដដល់ព្រះយោគាវចរនោះ ដែលធ្វើទុកក្នុងចិត្ត ដោយ

បណ្តាយលំដាប់យ៉ាងនេះ រមែងប្រាកដមិនសេសសល់ គឺថាធ្វើឱ្យប្រាកដច្បាស់ដោយអំណាចជារបស់មិនស្អាតជាដើម ។

កាលបើដូច្នោះ ធម៌ពួកណា ប្រាកដដោយភាវៈជារបស់មិនស្អាត ដល់ព្រះយោគាវចរណា ទាំងប្រាកដច្បាស់ជាង ប្រៀបដូចស្វាត្រូវព្រានដេញនៅក្នុងព្រៃត្នោត ៣២ ដើម មិនឈប់សូម្បីតែមួយដើមលោតទៅ កាលណាត្រឡប់ក៏បាញ់កាលនោះ ទើបឈប់ផ្អែកត្រង់ដើមត្នោតទី្ន ដែលស្អាតដែលហ៊ុមព័ទ្ធដោយស្លឹកត្នោតក្រាស់មួយដើមប៉ុណ្ណោះយ៉ាងណា ស្វា គឺចិត្តរបស់ព្រះយោគាវចរនោះក៏ដូច្នោះដែរ ព្រះយោគាវចរនោះៗឯងពិចារណាក្នុងកាយនេះ ដែលមាន ៣២ កោដ្ឋាសៈ គឺមិនឱ្យស្ថិតនៅ សូម្បីតែកោដ្ឋាសៈ ១ ហើយស្ទុះទៅកាលណា ក៏ត្រឡប់មកវិញ ព្រោះមានការប្រាថ្នា កម្រើកទៅកាន់អារម្មណ៍ដ៏ច្រើនក៏នឿយហត់(បាញ់)កាលនោះ ។ លំដាប់នោះព្រះយោគាវចរនោះ ជាអ្នកស្ទាត់ជំនាញឬសមរម្យដល់ ចរិតក្នុងអាការៈ ៣២ មានសក់ជាដើម ឬដោយការបំពេញបារមីទុកក្នុងធម៌ណា ក៏អាស្រ័យធម៌នោះ ហើយស្ថិតនៅ ដោយអំណាចឧបចារសមាធិ ។ កាលបើដូច្នោះ ព្រះយោគាវចរនោះឯង ធ្វើនូវនិមិត្តនោះ ដោយការកើត គឺថាការពិចារណារឿយៗ ក៏ធ្វើបឋមជ្ឈានឱ្យកើតឡើងតាមលំដាប់ តាំងនៅក្នុងបឋមជ្ឈាននោះហើយ ផ្តើមវិបស្សនារមែងត្រាស់ដឹងអរិយភូមិបាន ។

ម្យ៉ាងទៀត ធម៌ទាំងនោះ រមែងប្រាកដដោយវណ្ណៈដល់ព្រះយោគាវចរណា ប្រៀបដូចស្វាត្រូវព្រានដេញនៅក្នុងព្រៃត្នោត ៣២ ដើម មិនឈប់សូម្បី តែមួយដើម លោតទៅ កាលណាត្រឡប់ក៏បាញ់កាលនោះ ទើបឈប់ផ្អែកត្រង់ដើមត្នោតខ្ចី ដែលស្អាត ដែលហ៊ុមព័ទ្ធដោយស្លឹកត្នោតក្រាស់មួយដើមប៉ុណ្ណោះ យ៉ាងណាស្វា គឺចិត្តរបស់ព្រះយោគាវចរនោះ ក៏ដូច្នោះដែរ ព្រះយោគាវចរនោះៗ ឯងពិចារណាក្នុងកាយនេះ ដែលមាន ៣២ កោដ្ឋាសៈ គឺមិនឱ្យស្ថិតនៅសូម្បីតែកោដ្ឋាសៈ ១ ហើយស្ទុះទៅ កាលណា ក៏ត្រឡប់មកវិញ ព្រោះមានការប្រាថ្នា កម្រើកទៅកាន់អារម្មណ៍ដ៏ច្រើន ក៏នឿយហត់ (បាញ់) ។ កាលនោះ ធម៌ណារបស់ព្រះយោគាវចរនោះ ស្ទាត់ជំនាញ ឬសមគួរដល់ចរិតថា ក្នុង ៣២ ចំណែក មានសក់ជាដើម ឬដោយការបំពេញបារមី មកតាំងពីមុនក្នុងធម៌ណា ក៏អាស្រ័យធម៌នោះ តាំងនៅដោយអំណាចឧបចារសមាធិ ។ កាលបើដូច្នោះ ព្រះយោគាវចរនុ៎ះឯង ធ្វើនូវនិមិត្តនោះឱ្យជាការពិចារណា គឺការត្រិះរិះញយៗ ក៏ធ្វើឱ្យកើតរូបាវចរឈាន សូម្បីទាំង ៥ ដោយនីលកសិណ ឬដោយបិតកសិណតាមលំដាប់ហើយតាំងនៅក្នុងរូបាវចរឈាននោះ យ៉ាងណាមួយ ផ្ដើមចម្រើនវិបស្សនា ក៏ត្រាស់ដឹងអរិយភូមិបាន ។

ម្យ៉ាងទៀត ធម៌ទាំងនោះ ប្រាកដដោយការៈជារបស់ទទេ ដល់ព្រះយោ-គាវចរណា ព្រះយោគាវចរនោះ រមែងធ្វើទុកក្នុងចិត្ត ដោយលក្ខណៈកាលធ្វើទុក

*ក្នុងចិត្តដោយលក្ខណៈ រមែងត្រាស់ដឹង ដោយឧបចារឈាន ដោយអំណាចកំណត់ធាតុ ៤ ក្នុងធម៌ទាំងនោះ ។ កាលបើដូច្នោះ កាលធ្វើទុកក្នុងចិត្តក៏ធ្វើទុកក្នុងចិត្តក្នុងធម៌ទាំងនោះដោយសូត្រទាំង ៣ គឺមិនទៀង ជាទុក្ខ ជាអនត្តា ។ នេះជាវិបស្សនានយ របស់ព្រះយោគាវចរនោះ ។ ព្រះយោគាវចរផ្តើមចម្រើនវិបស្សនានេះ និងបដិបត្តិទៅតាមលំដាប់ ក៏រមែងត្រាស់ដឹងអរិយភូមិបាន ។*

*ពាក្យណាដែលខ្ញុំពោលទុកថា ព្រះយោគាវចរនេះធ្វើទុកក្នុងចិត្ត ក្នុងធម៌ទាំងនោះ ដោយអំណាចការពិចារណា មានការពិចារណាតាមលំដាប់ជាដើម យ៉ាងណា? ពាក្យនោះដែលខ្ញុំព្យាករណ៍ហើយថាមានប្រមាណប៉ុណ្ណោះ ។ ម្យ៉ាងទៀត ពាក្យណាដែលខ្ញុំពោលថា គប្បីជ្រាបការពណ៌នាបាឋៈនោះយ៉ាងនេះ ដោយកំណត់ភាវនា ។ សេចក្តីរបស់ពាក្យនោះ គឺខ្ញុំប្រកាសហើយ ដោយពិត ។*

បកិណ្ណកនយោ

**បកិណ្ណកន័យ**

*ឥឡូវនេះ គប្បីជ្រាបបកិណ្ណកន័យនេះ ដើម្បីសេចក្តីជំនាញ និងការឈ្លាសក្នុងទ្វត្តិង្សាការនេះថា ៖*

និមិត្តតោ លក្ខណតោ ធាតុតោ សុញ្ញតោបិ ច
ខន្ធាទិតោ ច វិញ្ញេយ្យោ ទ្វត្តឹសាការនិច្ឆយោ ។

*គប្បីជ្រាបការវិនិច្ឆ័យទ្វត្តិង្សាការ ដោយនិមិត្ត ដោយលក្ខណៈ*
*ដោយធាតុ ដោយភាពទទេ និងដោយខន្ធជាដើម ។*

បណ្តាសេចក្តីនៃបកិណ្ណកនោះ សេចក្តីថា ដោយនិមិត្តក្នុងទ្វត្តិង្សាការនេះ មានប្រការដូចពោលមកហើយនេះ មាននិមិត្ត ១៦០ ដែលព្រះយោគាវចរអាច កំណត់ទ្វត្តិង្សាការបានដោយកោដ្ឋាសៈ គឺជាចំណែកៗ ។ គឺសក់មាននិមិត្ត ៥គឺ វណ្ណៈ (ពណ៌) សណ្ឋាន (រូបរាង) ទិសា (ទិស) ឱកាស (ទីកើត) បរិច្ឆេទ (ការកំណត់) ដោយរោម ជាដើម ក៏យ៉ាងនេះ ។

សេចក្តីថា ដោយលក្ខណៈក្នុងទ្វត្តិង្សាការ មានលក្ខណៈ ១២៨ ដែល ព្រះយោគាវចរ អាចធ្វើទុកក្នុងចិត្តក្នុងទ្វត្តិង្សាការបានដោយលក្ខណៈ គឺសក់មាន ៤ លក្ខណៈ គឺ លក្ខណៈស្អួត លក្ខណៈជាប់ លក្ខណៈក្តៅ លក្ខណៈកម្រើកៗ ក្នុងរោមជាដើមក៏យ៉ាងនេះ ។

សេចក្តីថា ដោយធាតុក្នុងទ្វត្តិង្សាការក្នុងធាតុទាំងឡាយ ដែលព្រះមាន-ព្រះភាគត្រាស់ទុកក្នុងបាលីនេះថា

ម្នាលភិក្ខុទាំងឡាយ បុរសនេះមានធាតុ ៦ ដូច្នេះ[១] មានធាតុ ១២៨ ដែល ព្រះយោគាវចរ អាចកំណត់ទ្វត្តិង្សាការបានដោយធាតុ ។ គឺក្នុងសក់មានធាតុ ៤ គឺចំណែករឹង ជាបឋវីធាតុ ចំណែកជាប់ ជាអាបោធាតុ ចំណែកក្តៅជា តេជោធាតុ ចំណែកកម្រើក ជាវាយោធាតុ ។ ក្នុងរោមជាដើម ក៏យ៉ាងនេះ ។

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ លេខ ២៨ ទំព័រ ១៧៤ ។

សេចក្តីថា ដោយការៈទទេក្នុងទ្វត្តិង្សាការ មានសុញ្ញតា ១២៨ ដែលព្រះយោគាវចរអាចពិចារណាឃើញទ្វត្តិង្សាការដោយភាពទទេ ។ ក្នុងសក់មុនមានសុញ្ញតា ៤ គឺបឋវីធាតុ ទទេចាកអាបោធាតុជាដើម អាបោធាតុជាដើមក៏យ៉ាងនោះ ទទេចាកបឋវីធាតុជាដើម ។ ក្នុងរោម ជាដើមក៏យ៉ាងនោះ ។

សេចក្តីថា ដោយខន្ធជាដើម ក្នុងទ្វត្តិង្សាការ កាលសក់ជាដើម លោកសង្គ្រោះដោយខន្ធជាដើម គប្បីជ្រាបវិនិច្ឆ័យដោយន័យជាដើម យ៉ាងនេះថា សក់ទាំងឡាយមានខន្ធប៉ុណ្ណា មានអាយតនៈប៉ុណ្ណា មានធាតុប៉ុណ្ណា មានសច្ចៈប៉ុណ្ណា មានសតិប្បដ្ឋានប៉ុណ្ណា ។ កាយ រមែងប្រាកដដូចគំនរស្មៅ ឬឈើដល់ព្រះយោគាវចរនោះ ដែលពិចារណាឃើញយ៉ាងនេះដូចលោកពោលថា

នត្ថិ សត្តោ នរោ ពោសោ បុគ្គលោ នូបលព្ភតិ

សុញ្ញភូតោ អយំ កាយោ តិណាកដ្ឋសមូបមោ។

មិនមានសត្វ នរៈ បុរស មិនមានបុគ្គល កាយនេះ

មានសភាពទទេ ប្រៀបដូចជាស្មៅ និងឈើ ។

ម្យ៉ាងទៀត ការត្រេកអរនោះឯណា ដែលមិនមែនជារបស់មនុស្ស ដែលលោកពោលទុកយ៉ាងនេះថា

សុញ្ញាគារំ បវិដ្ឋស្ស សន្តចិត្តស្ស ភាធិនោ

អមានុសី រតិ ហោតិ សម្មា ធម្មំ វិបស្សតោ ។

លោកចូលទៅកាន់ផ្ទះទទេ មានចិត្តស្ងប់ គង់ពិចារណាឃើញធម៌ដោយប្រពៃ រមែងមានការត្រេកអរ ដែលមិនមែនជារបស់មនុស្ស[១] ។

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ គាថាធម្មបទ លេខ ៥២ ទំព័រ ១០០ ។

*ការត្រេកអរនោះទៅមិនឆ្ងាយឡើយ តពីនោះ អមតៈ គឺបីតិ និងបាមោជ្ជៈ នោះឯណា ដែលសម្រេចមកពីវិបស្សនា ដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាង នេះថា ៖*

យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ

លភតិ បីតិបាមោជ្ជំ អមតំ តំ វិជានតំ។

*ពិចារណាឃើញការកើត និងការរលត់នៃខន្ធទាំងឡាយ*

*ដោយប្រការណាៗ បីតិ និងបាមោជ្ជៈ ដែលជាអមតៈរមែងបាន*

*ដល់អ្នកពិចារណាឃើញការកើតរលត់នោះ ដោយប្រការនោះៗ ។*

*ព្រះយោគាវចរ កាលសោយបីតិ និងបាមោជ្ជៈ ដែលជាអមតៈនោះមិន យូរឡើយ ក៏នឹងធ្វើឱ្យប្បាស់អមតៈ គឺព្រះនិព្វានដែលមិនចាស់ មិនស្លាប់ដែល អរិយជនសេពហើយដោយពិត ។*

បរមត្ថជោតិកាយ ខុទ្ទកបាឋដ្ឋកថាយ

ទ្វត្តឹសាការវណ្ណនា និដ្ឋិតា

**ពណ៌នាអាការៈ ៣២ ប្រការ**

**នៃ**

**អដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះ បរមត្ថជោតិកា ចប់ ។**

## ៤-កុមារបញ្ហាវណ្ណនា

**ការពណ៌នាកុមារបញ្ហា**

### អត្ថុប្បត្តិ

**ហេតុកើតឡើងនៃរឿង**

ឥឡូវនេះ ដល់លំដាប់ពណ៌នានន័យរបស់កុមារបញ្ហា (សាមណេរបញ្ហា) ជាដើមយ៉ាងនេះថា អ្វីទៅដែលឈ្មោះថា ១ ។ ខ្ញុំនឹងពោលហេតុកើតឡើងនៃរឿងរបស់កុមារបញ្ហាទាំងនោះ និងប្រយោជន៍នៃការដាក់បទដើមទុកក្នុងទីនេះ ហើយទើបធ្វើការពណ៌នានន័យ ។

ពោលហេតុកើតឡើងនៃរឿង របស់កុមារបញ្ហាទាំងនោះទុកជាមុនសិន ។ ឈ្មោះថា ***សោបាកៈ*** ជាព្រះមហាសាវ័ករបស់ព្រះមានព្រះភាគ ។ ព្រះថេរៈ ***សោបាកៈ***[១] នោះ សម្រេចជាព្រះអរហន្ត តាំងតែពីអាយុបាន ៧ ឆ្នាំ ពីកំណើត ។ ព្រះមានព្រះភាគ មានព្រះពុទ្ធបំណងទ្រង់អនុញ្ញាតការឧបសម្បទា ដោយការ

---

១-ក្នុងគម្ពីរធម្មបទដ្ឋកថា ភាគ ៨ ទំព័រ ១៩៦ បានពោលថា “តស្ស សង្កិច្ចោ បណ្ឌិតោ សោចាកោ រេវតោតិ សត្តវស្សិកា ចត្តារោ ខីណាសវសាមណេរា ចាបុណឹសុ ប្រែថា សាមណេរជាព្រះខីណាស្រពទាំងឡាយបួន ដែលមានព្រះជន្ម ៧ វស្សា គឺ សង្កិច្ចសាមណេរ ១ បណ្ឌិតសាមណេរ ១ សោបាកសាមណេរ ១ រេវតសាមណេរ ១ បានទៅដល់ផ្ទះរបស់ព្រាហ្មណ៍នោះ” ។ ***ក្នុងអដ្ឋកថា អបទាន ឈ្មោះ វិសុទ្ធជនវិលាសិនី*** ពោលថា ព្រះសាមណេរ ឈ្មោះសោបាកៈ បានសម្រេចជាព្រះអរហន្ត បន្ទាប់ពីបានបព្វជ្ជា ក្នុងព្រះជន្ម ៧ វស្សា ក្នុងសំណាក់ព្រះសាស្តា ដោយការចម្រើនមេត្តាឈានជាបាទ ញុំាងវិបស្សនាឱ្យចម្រើន ហើយធ្វើឱ្យជាក់ច្បាស់នូវព្រះអរហត្ត ។

ព្យាករណ៍(ឆ្លើយ)បញ្ហាដល់លោក ។ ព្រះអង្គទ្រង់ជ្រាបថា លោកអាចព្យាករណ៍បញ្ហាទាំងឡាយបាន ។ ព្រះអង្គទ្រង់បំណងហើយ ទើបត្រាស់សួរបញ្ហាដោយន័យជាដើមថា អ្វីទៅដែលឈ្មោះថា ១ ។ ព្រះថេរៈ ក៏ព្យាករណ៍ ធ្វើទឹកព្រះទ័យរបស់ព្រះមានព្រះភាគឱ្យត្រេកអរដោយការព្យាករណ៍នោះ ។ ការព្យាករណ៍នោះបានជាឧបសម្បទារបស់ព្រះថេរៈ **សោបាកៈ**នោះ ។

នេះជាហេតុកើតឡើងរបស់សាមណេរបញ្ហាទាំងនោះ ។

## និក្ខេបប្បយោជនំ

## ប្រយោជន៍នៃការដាក់បទផ្តើម

ក៏ព្រោះហេតុប្រកបចិត្តភាវនា ដោយការរឭកដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដោយសរណគមន៍ ប្រកាសសីលភាវនា ដោយសិក្ខាបទ និងប្រកាសកាយភាវនាដោយទ្វត្តិង្សាការៈ ព្រោះដូច្នេះ ឥឡូវនេះទើបដាក់ការព្យាករណ៍បញ្ហាទាំងនេះ ជាបទផ្តើមទុកត្រង់ទីនេះ ដើម្បីសម្តែងមុខ គឺបញ្ញាភាវនាដោយប្រការផ្សេងៗ ។ ម្យ៉ាងទៀត សមាធិ មានសីល ជាបទដ្ឋាន ហើយបញ្ញា មានសមាធិជាបទដ្ឋាន ដូចព្រះមានព្រះភាគត្រាស់ទុកថា៖

“ សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ នរជន

*មានប្រាជ្ញា បានតាំងមាំក្នុងសីលហើយ ចម្រើននូវសមាធិចិត្ត និងវិបស្សនាបញ្ញា[១]” ដូច្នេះ ព្រោះដូច្នោះ ទើបគួរជ្រាបសូម្បីថា ខ្ញុំកាលសម្តែងសីលដោយសិក្ខាបទទាំងឡាយ ហើយសមាធិមានសីលនោះជាគោចរ ដោយទូត្តិង្គាការៈ ហើយទើបដាក់បញ្ហាព្យាករណ៍ជាបទផ្តើមទុកត្រង់ទីនេះ ដើម្បីសម្តែងប្រភេទនៃបញ្ញាដែលជាគ្រឿងត្រួតពិនិត្យធម៌ផ្សេងៗ សម្រាប់បុគ្គលដែលមានចិត្តរឹងប៉ឹងហើយ ។*

*នេះជាប្រយោជន៍របស់ការដាក់បញ្ហាទាំងនោះជាបទផ្តើមត្រង់ទីនេះ ។*

## ឯកំ នាម កិន្តិបញ្ហាវណ្ណនា

### ពណ៌នាបញ្ហាថា អ្វីទៅដែលហៅថា ១ ?

*ឥឡូវនេះ នឹងពណ៌នាន័យរបស់បញ្ហាទាំងនោះ ។ ភិក្ខុកាលនឿយណាយដោយប្រពៃក្នុងធម៌ណាមួយ តែងធ្វើទីបំផុតទុក្ខបានដោយលំដាប់ ម្យ៉ាងវិញទៀត ព្រះថេរៈ**សោបាកៈ**រូបនេះ កាលដែលនឿយណាយក្នុងធម៌ណាមួយ បានធ្វើទីបំផុតទុក្ខហើយ ព្រះមានព្រះភាគ ទ្រង់សំដៅដល់ធម៌នោះ ទើបត្រាស់សួរបញ្ហាថា អ្វីទៅដែលហៅថា ១ ។ ព្រះថេរៈទូលឆ្លើយដោយទេសនាជាបុគ្គលាធិដ្ឋានថា សត្វទាំងពួងស្ថិតនៅបានដោយអាហារ ។ ក្នុងសេចក្តីនេះ ព្រះសូត្រទាំងឡាយជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សម្មាសតិដូចម្តេច ភិក្ខុក្នុងធម្មវិន័យ*

---

*១-សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ លេខ ២៩ ទំព័រ ៣៣ ។*

ពិចារណាឃើញក្នុងកាយដូច្នេះ[១]ជាឧទាហរណ៍ ក្នុងការកើតសេចក្ដីបញ្ចប់ដោយការធ្វើយ៉ាងនេះ ។ ក្នុងសេចក្ដីនេះ សត្វទាំងពួង លោកពោលទុកថា ស្ថិតនៅបានដោយអាហារណា អាហារនោះ ឬសភាពដែលសត្វទាំងនោះ ស្ថិតនៅបានដោយពិតមែនហើយ សេចក្ដីនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ឈ្មោះថា ១ ក្នុងទីនេះ មិនមែនត្រាស់ដើម្បីឱ្យយល់ដឹងថា ឈ្មោះថា ១ ដទៃក្នុង ព្រះសាសនា ឬក្នុងលោកទេ ។ ការពិត ព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា៖

ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ ១ ភិក្ខុកាលនឿយណាយដោយប្រពៃ កាលប្រាសចាកដោយប្រពៃ កាលរួចផុតដោយប្រពៃ ឃើញទីបំផុតដោយធ្វើទីបំផុតទុក្ខបានក្នុងបច្ចុប្បន្ន ក្នុងធម៌យ៉ាងដូចម្ដេច ធម៌យ៉ាង គឺសត្វទាំងពួងស្ថិតនៅបានដោយអាហារ ។

"ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌មួយ រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌មួយគឺអ្វី? គឺពួកសត្វទាំងពួងរស់នៅដោយសារអាហារ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។ល។ ក្នុងធម៌មួយនោះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ១

---

១-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ លេខ ៣៧ ទំព័រ ២១ ។

ឧទ្ទេស ១ វេយ្យាករណ៍ ១ ដូច្នេះ ពាក្យនេះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនោះ[១] ” ។

ក្នុងពាក្យថា **អាហារដ្ឋិតិកា**នេះ ព្រះថេរៈកាន់យកបច្ច័យផង អាហារស័ព្ទហៅសត្វទាំងពួង ដែលស្ថិតនៅបានដោយអាហារបច្ច័យថា ស្ថិតនៅបានដោយអាហារដូចជាបច្ច័យ លោកហៅថា អាហារ ក្នុងព្រះបាលីជាដើមថា “ម្នាលភិក្ខុទាំងឡាយ មានតែសុភនិមិត្ត និងការធ្វើឱ្យច្រើននូវអយោនិសោមនសិការក្នុងសុភនិមិត្តនោះ នេះធម៌ជាអាហាររបស់កាមច្ឆន្ទៈដែលមិនទាន់កើត ឱ្យកើតឡើង”[២] ព្រោះដូច្នោះ កាលលោកកំណត់យកអាហារ ៤ ពោលទុកថា ស្ថិតនៅបានដោយអាហារដូច្នោះ ។ ពាក្យថា ទាំងពួង ទំនងជាមិនទាន់ត្រូវ ព្រោះព្រះបាលីថា “ពួកទេវតាជាអសញ្ញសត្វ មិនមានហេតុ មិនមានអាហារ មិនមានផស្សៈ មិនមានវេទនា”[៣] ។

ក្នុងសេចក្តីនោះ គប្បីមានពាក្យបញ្ជាក់ប្រាប់ដូច្នេះ សូម្បីបើត្រូវពោលយ៉ាង

---

១.សុត្តន្តបិដក ខុទ្ទកនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១២២ ។

២.សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ លេខ ៣៧ ទំព័រ ២៥៩ ។

៣.អភិធម្មបិដក វិភង្គ លេខ ៨២ ទំព័រ ៣២៤ ។

នេះ សភាវៈដែលខន្ធទាំងឡាយប៉ុណ្ណោះស្ថិតនៅបានដោយបច្ច័យក៏ត្រឹមត្រូវ ព្រោះព្រះបាលីថាធម៌ពួកណាមានបច្ច័យ ។បញ្ចក្ខន្ធគឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ ប៉ុន្តែការដែលសត្វទាំងឡាយ ស្ថិតនៅបានដោយបច្ច័យ ពាក្យនេះ ទំនងមិនត្រូវសោះ សេចក្ដីនេះ មិនគួរយល់ឃើញយ៉ាងនេះ ។ ព្រោះហេតុអ្វីព្រោះពោលសរុបខន្ធរបស់សត្វទាំងឡាយ ។ មែនពិត លោកពោលសរុបស្រេចក្នុងសត្វទាំងឡាយ ព្រោះអ្វី ។ ព្រោះលោកអាស្រ័យ ខន្ធបញ្ញត្តិ ។ ឧបមាដូចជាអ្វីដូចជាឧបចារៈរបស់ស្រុកក្នុងផ្ទះ កាលបើផ្ទះមួយខ្នង ឬពីរខ្នង សូម្បីបីខ្នងនៃស្រុកត្រូវភ្លើងឆេះ ក៏លោកពោលសរុបដល់ស្រុកក្នុងផ្ទះ យ៉ាងនេះថា ស្រុកត្រូវភ្លើងឆេះ ព្រោះអាស្រ័យផ្ទះច្រើនខ្នង បញ្ញត្តយ៉ាងណាមិញ ក៏គួរជ្រាបថា ពោលសរុបស្រេច ដល់សត្វទាំងឡាយស្ថិតនៅបានដោយអាហារក្នុងសត្វទាំងឡាយ ដែលស្ថិត នៅបានដោយអាហារ ព្រោះអត្ថថា បច្ច័យក្នុងខន្ធទាំងឡាយ កើតចាស់ និងស្លាប់ ព្រះមានព្រះភាគកាលត្រាស់ទុកថា ម្នាលភិក្ខុ អ្នកកើត ចាស់ និងស្លាប់គ្រប់ខណៈដូច្នេះ គឺទ្រង់ត្រាស់សម្ដែងថា សរុបដល់ខន្ធ ក្នុងសត្វទាំងនោះ ។ ពេលណាសត្វទាំងពួង ស្ថិតនៅបានដោយអាហារ ពោលគឺ បច្ច័យណា អាហារនោះ ឬសភាពដែលសត្វស្ថិតនៅបានដោយអាហារ គប្បីជ្រាបថា មាន ម្យ៉ាងព្រោះ

ថាអាហារឬសភាវៈដែលសត្វស្ថិតនៅបានដោយអាហារ រមែងជាទីតាំងនៃនិព្វិទា (ការនឿយណាយ) ព្រោះជាហេតុនៃអនិច្ចតា ភាពជារបស់មិនទៀង ។ កាលនោះ ភិក្ខុនឿយណាយ ព្រោះឃើញអនិច្ចតា ក្នុងសង្ខារទាំងឡាយ ដែលសន្មតគ្នាថា សត្វទាំងពួងនោះ រមែងនឹងជាបុគ្គលធ្វើទីបំផុតទុក្ខបានដោយលំដាប់ រមែងសម្រេច បរមត្ថវិសុទ្ធ សេចក្ដីបរិសុទ្ធដោយបរមត្ថ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា៖

សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង មិនទៀង ដូច្នេះ កាលនោះ រមែងនឿយណាយក្នុងសេចក្ដីទុក្ខ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធ[១] ។

ក៏ក្នុងបញ្ហាដំបូងនេះ មានបាឋៈ ២ យ៉ាងថា ឯកំ នាម កឹ និង(ឯកំ នាម) កិហ ។ ក្នុងបាឋៈទាំង ២ នោះ បាឋៈក្នុងកោះលង្កាថា កិហ ។ ត្បិតថា អ្នកលង្កាទាំងនោះ ជំនួសពាក្យពោលថា កឹ ក៏បែរពោលថា កិហ ទៅវិញ អាចារ្យកោះលង្កាពួកខ្លះពោលថា ពាក្យថា ហ ជានិបាត បាឋៈសូម្បីរបស់ពួក

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៧៩ ។

សម្រាប់ជាធម្មទាន

ដែលប្រកាន់លទ្ធិថេរវាទ ក៏យ៉ាងនេះដូចគ្នា ។ ប៉ុន្តែទាំងពីរបាឋៈ ក៏មានសេចក្តីដូចគ្នា ។ ពេញចិត្តមួយណា ក៏គប្បីសូត្រគប្បីពោលយ៉ាងនេះ ។ ដូចជាកន្លែងខ្លះ ក៏ពោលថា ទុខំ និងកន្លែងខ្លះ ក៏ពោលថា ទុក្ខំ ក្នុងព្រះបាលីទាំងឡាយជាដើម យ៉ាងនេះថា សុខេន ផុដ្ឋា អថ វា ទុខេន[១] ទុក្ខំ ទោមនស្សំ បដិសំវេទេតិ យ៉ាងណា កន្លែងខ្លះថា ឯកំ កន្លែងខ្លះថា ឯកកំ ក៏ដូច្នោះដែរ ។ ប៉ុន្តែក្នុងទីនេះវិញ មានបាឋៈតែម្យ៉ាងថា ឯកំ នាម ។

## ទ្វេ នាម កិន្តិបញ្ហាវណ្ណនា

### ពណ៌នាបញ្ហាថា អ្វីទៅដែលហៅថា ២ ?

ព្រះសាស្តា ព្រះអង្គមានព្រះទ័យគឺ ព្រះថេរៈធ្វើឱ្យទ្រង់ត្រេកអរ ដោយការព្យាករណ៍នេះយ៉ាងនេះហើយ ទើបត្រាស់សួរបន្តទៅ ដូចន័យដំបូងថា អ្វីទៅដែលហៅថា ២ ព្រះថេរៈពោលបន្ថែមថា ទ្វេ ដើម្បីទូលឆ្លើយ ដោយទេសនាជាធម្មាធិដ្ឋានថា គឺនាម និងរូប ។ បណ្តានាម និងរូបនោះ រឿងដែលមិនមែនរូបទាំងអស់ លោកហៅថា នាម ព្រោះបង្អោនមុខឆ្ពោះកាន់ អារម្មណ៍ម្យ៉ាង ព្រោះជាហេតុបង្អោនចិត្តទៅ ។ តែក្នុងទីនេះ លោកបំណងយកធម៌ដែលមានអាសវៈ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៣៩ ។

ប៉ុណ្ណោះ ព្រោះជាហេតុនៃសេចក្តីនឿយណាយ ចំណែកមហាភូតរូប ៤ និងរូបទាំងអស់ ដែលអាស្រ័យមហាភូតរូបនោះឱ្យប្រព្រឹត្តទៅ លោកហៅថារូប ព្រោះអត្ថថា បែកធ្លាយ ។ រូបក្នុងទីនេះ លោកបំណងយកទាំងអស់ ។ តែព្រះថេរៈពោលក្នុងទីនេះថា ឈ្មោះថា នាម និងរូប ព្រោះពោលដោយបំណង នេះឯងពុំមែនពោលព្រោះមិនមានធម៌ ២ យ៉ាង ដទៃទេ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា៖

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ២ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌ ២ គឺអ្វី? គឺនាម ១ រូប ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។ល។ ក្នុងធម៌ ២ នេះឯង រមែងធ្វើនូវ ទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ ដូច្នេះ ពាក្យនុ៎ះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ[១] ។ ក៏ក្នុងបញ្ហានេះ គប្បីជ្រាបថា ភិក្ខុលះបោលអត្តទិដ្ឋិ សេចក្តីយល់ថាជាខ្លួន បានដោយការឃើញត្រឹមតែនាមរូប ហើយនឿយណាយដោយមុខ គឺការ

១- សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១១២-១១៣ ។

ពិចារណាឃើញអនត្តា រមែងនឹងជាអ្នកធ្វើទីបំផុតបាន តែងសម្រេចបរមត្ថវិសុទ្ធិបានដូចដែលព្រះមានព្រះភាគត្រាស់ទុកថា៖

សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង មិនមែនជារបស់ខ្លួនដូច្នេះ កាលនោះ រមែងនឿយណាយក្នុងសេចក្ដីទុក្ខ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធ[១] ។

## តីណិ នាម កិន្តិបញ្ហាវណ្ណនា

### ពណ៌នាបញ្ហាថា អ្វីទៅដែលឈ្មោះថា ៣ ?

ឥឡូវនេះ ព្រះសាស្ដាព្រះអង្គមានព្រះទ័យគឺ ព្រះថេរៈធ្វើឱ្យទ្រង់ត្រេកអរដោយការព្យាករណ៍បញ្ហាសួម្បីនេះហើយ ទើបត្រាស់សួរបញ្ហាបន្តទៅដូចន័យមុនៗថា អ្វីទៅដែលឈ្មោះថា ៣ ។ ព្រះថេរៈពោលបន្ថែមថា តីណិ ៣ កាលសម្ដែងសំខ្យា ចំនួនដែលសមគួរដល់លិង្គ ភេទស័ព្ទនៃសេចក្ដីដែលគប្បីព្យាករណ៍ទៀត ទើបទូលឆ្លើយថា តិស្សោ វេទនា គឺវេទនា ៣ ។ ន័យម្យ៉ាងទៀត ព្រះថេរៈគិតថាចាំយើងត្រឡប់ពាក្យថា តីណិ សភាវៈរបស់វេទនា ដែលព្រះមានព្រះភាគ

---

២-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៧៩ ។

*ត្រាស់ទុកថា* **តិស្សោ វេទនា** *កាលសម្តេងទើបទូលឆ្លើយ ។ បណ្ឌិតគប្បីជ្រាប សេចក្តីនេះដូចពោលមកដូច្នេះ ។ ត្បិតថា ទេសនារបស់ពួកបុគ្គល ដែលសម្រេច ទេសនាដ៏ប្រសើរ ព្រោះការបែកធ្លាយនៃបដិសម្ភិទា មានកថាមុខដ៏ច្រើន ។ តែ អាចារ្យពួកខ្លះពោលថា បទថា* **តីណិ** *នេះជាបទលើស ។ តែព្រះថេរៈ ពោលក្នុងទី នេះ ថា* **តិស្សោ វេទនា** *គឺវេទនា ៣ ក៏តាមន័យមុនៗនោះឯង មិនមែន ពោលព្រោះ មិនមានធម៌ ៣ យ៉ាងដទៃនោះទេ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា៖*

*ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវ ប្រយោជន៍ដោយប្រពៃ ក្នុងធម៌៣នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌ ៣ គឺអ្វី? គឺវេទនាទាំង ៣ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយ ដោយប្រពៃ ។ល។ ក្នុងធម៌ ៣ នេះឯង រមែងធ្វើនូវ ទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ ដូច្នេះ ពាក្យនុ៎ះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ*[១] *។ ក្នុងបញ្ហានេះ គប្បីជ្រាបថា ភិក្ខុលះបង់សុខសញ្ញា សេចក្តីសម្គាល់ថា សុខ ដោយការឃើញ វេទនាទាំង ៣ ជាទុក្ខ ហើយ នឿយណាយដោយចំពោះ គឺការពិចារណាឃើញ*

---

*១-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១១៣-១១៤ ។*

ទុក្ខតាមគន្លងព្រះសូត្រទុកថា វេទនា ការសោយណាមួយ ទាំងអស់នោះ តថាគតពោលថា ជាទុក្ខ[១] ។ តាមលំអានជាទុក្ខ ព្រោះទុក្ខជាទុក្ខ ព្រោះប្រែប្រួល និងជាទុក្ខព្រោះបច្ច័យ គាត់តែងយ៉ាងនេះថា៖

យោ សុខំ ទុក្ខតោ ទក្ខិ ទុក្ខមទ្ទក្ខិ សល្លតោ
អទុក្ខមសុខំ សន្តំ អទក្ខិ នំ អនិច្ចតោ ។

ភិក្ខុណា បានឃើញសុខវេទនាថា ជាទុក្ខ បានឃើញទុក្ខវេទនាថា ជាព្រួញ បានឃើញអទុក្ខមសុខវេទនា ជាទីស្ងប់នោះថាជារបស់មិនទៀង[២] ។ រមែងជាបុគ្គលធ្វើទីបំផុតទុក្ខបាន តែងសម្រេចបរមត្ថវិសុទ្ធិ ដូចដែលព្រះមានព្រះភាគបានត្រាស់ទុកថា៖

សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងនាំមកនូវសេចក្ដីទុក្ខ ដូច្នេះ កាលនោះ រមែងនឿយណាយក្នុងសេចក្ដីទុក្ខ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធ[១] ។

---

១-សុត្តន្តបិដក សំយុត្តនិកាយ សឡាយតនវគ្គ លេខ ៣៦ ទំព័រ ៣០ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ លេខ ៥៣ ទំព័រ ៦២ ។

## ចត្តារិ នាម កិន្តិបញ្ហាវណ្ណនា

### ពណ៌នាបញ្ហាថា អ្វីទៅដែលហៅថា ៤ ?

ព្រះសាស្តាព្រះអង្គមានព្រះទ័យ គឺព្រះថេរៈធ្វើឱ្យទ្រង់ត្រេកអរ ដោយការព្យាករណ៍បញ្ហា សូម្បីយ៉ាងនេះហើយ ទើបត្រាស់សួរបញ្ហាបន្តទៅ ដូចន័យមុនៗថា អ្វីទៅដែលឈ្មោះថា ៤ ក្នុងបញ្ហានេះ ក្នុងចំណែកព្យាករណ៍បញ្ហានេះ កន្លែងខ្លះលោកបំណងយកអាហារ ៤ តាមន័យមុនៗ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា៖

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃក្នុងធម៌ ៤ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌ ៤ គឺអ្វី? គឺអាហារទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ ក្នុងធម៌ ៤ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុង បច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះ ពាក្យនេះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ[២] ។

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៧៩ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១១៤ ។

កន្លែងខ្លះ ភិក្ខុមានចិត្តបានអប់រំល្អហើយក្នុងគុណធម៌ពួកណា រមែងជាបុគ្គលធ្វើទីបំផុតទុក្ខបានដោយលំដាប់ គុណធម៌ពួកនោះ ក៏គឺសតិប្បដ្ឋាន ៤ ។ ដូចដែលព្រះកជន្តលាភិក្ខុនីពោលថា ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៤ រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌ ៤ គឺអ្វី ? គឺសតិប្បដ្ឋាន ៤ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អ ដោយប្រពៃ ។ល។ ក្នុងធម៌ ៤ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុង បច្ចុប្បន្នបាន ។ ពាក្យណាដែលព្រះដ៏មានព្រះភាគសំម្តែងថា បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះ ពាក្យនោះ ព្រះដ៏មានព្រះភាគសំដែងហើយ ព្រោះអាស្រ័យហេតុនេះ[១] ។

តែក្នុងទីនេះ ការកាត់កវតណ្ហាបាន ព្រោះត្រាស់ដឹង និងចាក់ធ្លុះអរិយសច្ចៈ ៤ ពួកណា ព្រោះហេតុដែលអរិយសច្ចៈ៤ពួកនោះ លោកបំណងយកហើយ ។ ព្រោះហេតុ បញ្ហាកម្មដែលលោកព្យាករណ៍ដោយបរិយាយ នេះជាការព្យាករណ៍ល្អទាំងអស់ ព្រោះដូច្នោះ ព្រះថេរៈពោលបន្ថែមថា ចត្តារិ ៤ ទើបទូលឆ្លើយថា អរិយសច្ចានិ អរិយសច្ចៈទាំងឡាយ ។ ក្នុងពាក្យនោះ ស័ព្ទថា ចត្តារិ ៤ ជាការកំណត់ដោយចំនួន ។ បទថា អរិយសច្ចានិ បានដល់ សច្ចៈជាអរិយៈ អធិប្បាយ

---

១- សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១២៤ ។

ថា ពុំខុសក្លាំងក្លាត់ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំង-ឡាយ អរិយសច្ចៈ ៤ នេះជា របស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ព្រោះហេតុនោះ បាន ជាតថាគតហៅថា **អរិយសច្ចៈ**[១] ។ មយ៉ាងទៀត ព្រោះហេតុណា ទើបលោក អធិប្បាយទុកថា ព្រោះជាសច្ចៈដែលលោក និងទេវលោក គប្បីដើរ គប្បីសម្រេច ។ ព្រោះដំណើរទៅក្នុងផ្លូវដែលចម្រើន សន្មតថា ឋានដែលគួរ ព្យាយាមខ្វះ ព្រោះ មិនដើរទៅកាន់ផ្លូវមិនចម្រើនខ្វះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះពុទ្ធសាវកទាំងឡាយ ទទួលស្គាល់ថាជាព្រះអរិយៈ ព្រោះប្រកបព្រមដោយអរិយធម៌ គឺពោធិបក្ខិយធម៌ ៣៧ ប្រការ រមែងត្រាស់ដឹង អរិយសច្ចៈទាំងនេះ សូម្បីព្រោះហេតុនោះ ទើបលោក ហៅថា អរិយសច្ចៈ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អរិយសច្ចៈ ៤ ពួកនេះ ។ល។ អរិយសច្ចៈ ៤ ទាំងនេះឯង ព្រះអរិយៈទាំងឡាយ រមែងចាក់ធ្លុះ អរិយសច្ចៈ ៤ ព្រោះដូច្នោះ ទើបហៅថា **អរិយសច្ចៈ** ។ ន័យម្យ៉ាងទៀត ឈ្មោះថា **អរិយសច្ចៈ** ព្រោះជាសច្ចៈរបស់ព្រះមានព្រះភាគ ព្រះអង្គជាអរិយៈ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ តថាគតជាអរិយៈ ក្នុង

---

១- សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ លេខ ៣៩ ទំព័រ ២៦៩ ។

លោក និងទេវលោក ។ល។ ព្រមទាំងទេវតា និងមនុស្ស ព្រោះដូច្នោះ ទើបហៅថា **អរិយសច្ចៈ**” ។ ន័យម្យ៉ាងទៀត ឈ្មោះថា **អរិយសច្ចៈ** ព្រោះធ្វើឱ្យសម្រេចភាពជាអរិយៈ ព្រោះអរិយសច្ចៈពួកនោះ ព្រះអង្គទ្រង់ត្រាស់ដឹងដ៏ក្រៃលែង ដោយខ្លួនព្រះអង្គឯងហើយ ។ ដូចដែលព្រះមានព្រះភាគត្រាស់ ទុកថា “ម្នាលភិក្ខុទាំងឡាយ ព្រោះអរិយសច្ចៈ ៤ ទាំងនេះ តថាគតត្រាស់ដឹង ខ្លួនឯងតាមសេចក្តីពិត តថាគតទើបហៅថា ព្រះអរហន្តសម្មាសម្ពុទ្ធ” ។ អត្ថនៃបទរបស់អរិយសច្ចៈទាំងនោះ មានដូច្នេះ ។ ការកាត់ផ្តាច់ភវតណ្ហា រមែងមានព្រោះការត្រាស់ដឹងតាម និងចាក់ធ្លុះអរិយសច្ចៈទាំងនេះ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ចៈនេះ តថាគតក្តី អ្នកទាំងឡាយក្តី បានត្រាស់ដឹងហើយ បានចាក់ធ្លុះហើយ ។ល។ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ តថាគតក្តី អ្នកទាំងឡាយក្តីបានត្រាស់ដឹងហើយ បានចាក់ធ្លុះហើយ ។ ភវតណ្ហា ជាធម្មជាតិនាំសត្វឱ្យចូលទៅកាន់ភព បានផ្តាច់ផ្តិលអស់ហើយ ភពថ្មីទៀត ក្នុងកាលឥឡូវនេះមិនមានឡើយ[១]” ។

---

១-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ លេខ ៣៩ ទំព័រ ២៦១-២៦២ ។

## បញ្ចនាមកិត្តិបញ្ហាវណ្ណនា

### ពណ៌នាបញ្ហាថា អ្វីទៅដែលឈ្មោះថា ៥ ?

ព្រះសាស្តាមានព្រះទ័យ គឺព្រះថេរៈធ្វើឱ្យទ្រង់ត្រេកអរ ដោយការព្យាករណ៍បញ្ហា សូម្បីនេះហើយ ទើបត្រាស់សួរបញ្ហាទៅតាមន័យមុនៗថា អ្វីទៅដែលឈ្មោះថា ៥ ។ ព្រះថេរៈពោលបន្ថែមថា បញ្ច ៥ ទើបទូល ឆ្លើយថា **ឧបាទានក្ខន្ធ** ។ បណ្តាពាក្យទាំងនោះ ពាក្យថា បញ្ច ៥ ជាការ កំណត់ចំនួន ។ ខន្ធទាំងឡាយ គឺត្រូវឧបាទានឱ្យកើតមាន ឬដែលធ្វើឧបាទានឱ្យកើត ឈ្មោះថា **ឧបាទានក្ខន្ធ** ។ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ណាមួយ មានអាសវៈ ដែលបុគ្គលគប្បីប្រកាន់ ពាក្យនេះ ជាឈ្មោះរបស់ឧបាទានក្ខន្ធពួកនោះ ។ ក៏ក្នុងទីនេះ ព្រះថេរៈពោលថា **ឧបាទានក្ខន្ធ** ៥ តាមន័យមុននោះឯង មិនមែនពោលព្រោះតែមិនមានធម៌ ៥ យ៉ាងដទៃ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

"ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៥ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌ ៥ គឺអ្វីខ្លះ ។ គឺឧបាទានក្ខន្ធទាំង ៥ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។ល។ ក្នុងធម៌ ៥ នេះឯង រមែងធ្វើនូវ

*ទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ៥ ឧទ្ទេស ៥ វេយ្យាករណ៍ ៥ ដូច្នេះ ពាក្យនេះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ[១]" ។*

*ក៏ក្នុងបញ្ហានេះ ភិក្ខុកាលពិចារណានូវបញ្ចក្ខន្ធដោយការកើត និងការរំលត់ជាអារម្មណ៍បានអមតៈដោយវិបស្សនាហើយ តែងធ្វើឱ្យជាក់ច្បាស់នូវអមតៈ គឺព្រះនិព្វានដោយលំដាប់ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖*

យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ
លភតិ បីតិ បាមោជ្ជំ អមតំ តំ វិជានតំ ។

*ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះរមែងបានបីតិ និងបាមោជ្ជៈ បីតិ និងបាមោជ្ជៈនោះ ឈ្មោះថាជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ[២] ។*

ជនាម កិត្តិបញ្ហាវណ្ណនា

**ពណ៌នាបញ្ហាថា អ្វីទៅដែលឈ្មោះថា ៦ ?**

*ព្រះសាស្តាព្រះអង្គមានព្រះទ័យ គឺព្រះថេរៈធ្វើឱ្យទ្រង់ត្រេកអរ ដោយការព្យាករណ៍សួម្បីយ៉ាងនេះហើយ ទើបត្រាស់សួរបញ្ហាបន្តទៅតាមន័យមុនៗ ថា*

---

*១-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១១៥ ។*

*២-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ១០០ ។*

អ្វីទៅដែលឈ្មោះថា ៦ ព្រះថេរៈពោលបន្ថែមថា ឆ ៦ ? ទើបទូលឆ្លើយថា អាយតនៈខាងក្នុង ។ បណ្តាពាក្យទាំងនោះ ពាក្យថា ឆ ៦ ជាការកំណត់ចំនួន ។ អាយតនៈទាំងឡាយដែលប្រកបក្នុងខាងក្នុង ឬធ្វើខ្លួនឱ្យជាទីអាស្រ័យប្រព្រឹត្តទៅ ឈ្មោះថា **អជ្ឈត្តិកៈ** ។ ឈ្មោះថា **អាយតនៈ** ព្រោះបន្ត ឬព្រោះកើតសេចក្តីចម្រើន ឬព្រោះនាំសង្សារទុក្ខមកយូរអង្វែង ពាក្យនេះជាឈ្មោះ របស់**ចក្ខុ** (ភ្នែក) **សោតៈ** (ត្រចៀក)**ឃានៈ** (ច្រមុះ )**ជិវ្ហា** (អណ្តាត) **កាយៈ** (កាយ) **មនៈ** (ចិត្ត) ។ ក្នុងទីនេះ ព្រះថេរៈពោលថា អាយតនៈខាងក្នុង ៦ តាមន័យមុន មិនមែនពោលព្រោះធម៌ ៦ យ៉ាងដទៃទេ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

“ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនៀយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៦ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៦ គឺអ្វី? គឺអាយតនៈខាងក្នុងទាំង ៦ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនៀយណាយដោយប្រពៃ ។ល។ ក្នុងធម៌ ៦ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ៦ ឧទ្ទេស ៦ វេយ្យាករណ៍ ៦ ដូច្នេះ ពាក្យនេះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ”[១] ។

១-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១១៦ ។

*ក្នុងបញ្ហានេះ ភិក្ខុពិចារណាអាយតនៈខាងក្នុង ៦ ដោយសភាពជារបស់ទទេ តាមព្រះបាលីថា "សុញ្ញគាមោតិ ខោ ភិក្ខវេ ឆន្នេតំ អជ្ឈត្តិកានំ អាយតនានំ អធិវចនំ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ស្រុកស្ងាត់នោះ ជាឈ្មោះរបស់អាយតនៈខាងក្នុង ៦"[១] ដោយសភាពជារបស់ទទេ និងសភាពជារបស់បោកប្រាស់ ព្រោះស្ថិតនៅបានពុំយូរដូចពពុះទឹក និងថ្ងៃបណ្តើរកូនដូច្នោះ ហើយក៏នឿយណាយធ្វើទីបំផុតទុក្ខដោយលំដាប់ រមែងសម្រេចដល់ទីដែលមច្ចុរាជមើលមិនឃើញ ។ ដូចដែលព្រះមានព្រះភាគ ត្រាស់ទុកថា ៖*

យថា ពុព្វុឡកំ បស្សេ យថា បស្សេ មរីចិកំ
ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។

*បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញព្រេញ[២]ថ្ងៃយ៉ាងណា ស្តេចមច្ចុរាជ*
*មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ[៣] ។*

*សត្ត នាម កិន្តិបញ្ហាវណ្ណនា*

**ពណ៌នាបញ្ហាថា អ្វីនៅដែលឈ្មោះថា ៧ ?**

*ព្រះសាស្តាព្រះអង្គមានព្រះទ័យ គឺព្រះថេរៈធ្វើឱ្យទ្រង់ត្រេកអរ ដោយការ*

---

*១-សុត្តន្តបិដក សំយុត្តនិកាយ សឡាយតនវគ្គ លេខ ៣៥ ទំព័រ ៣៩៨ ។*

*២-ពាក្យនេះ អាចប្រែថា **ថ្ងៃបណ្តើរកូន** ក៏បាន ។*

*៣-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៥៨ ។*

ព្យាករណ៍បញ្ហានេះហើយ ទើបត្រាស់សួរបន្ថែមទៅតាមន័យមុនៗថា អ្វីទៅដែលឈ្មោះថា៧ៗ**វិញ្ញាណដ្ឋិតិ**៧ព្រះថេរៈពោលការព្យាករណ៍បញ្ហាច្រើនក៏ពិតមែន សូម្បីយ៉ាងនោះ ភិក្ខុអ្នកមានចិត្តអប់រំល្អហើយនូវធម៌ពួកណា រមែងធ្វើទីបំផុតទុក្ខបាន ព្រះថេរៈកាលសម្តែងធម៌ទាំងនោះ ទើបទូលឆ្លើយថា ពោជ្ឈង្គទាំង ៧ ។ សេចក្តីនេះសោត ព្រះមានព្រះភាគក៏ទ្រង់យល់ព្រមហើយ ដូចដែលព្រះអង្គត្រាស់ទុកថា ៖

“ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនី ជាអ្នកប្រាជ្ញ ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនី ជាមនុស្សមានប្រាជ្ញាច្រើនមែន ម្នាលគហបតីទាំង-ឡាយ ប្រសិនបើអ្នកទាំងឡាយចូលមករកតថាគត ហើយសួរនូវសេចក្តីនោះតថាគតក៏ដោះស្រាយសេចក្តីនោះ យ៉ាងនោះ ដូចជាកជង្គលាភិក្ខុនី ដែលដោះស្រាយដែរ[១] ។ កជង្គលាភិក្ខុនីនោះព្យាករណ៍ទុកយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៧ រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌ ៧ គឺអ្វី ? គឺពោជ្ឈង្គទាំង ៧ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ។ល។ក្នុងធម៌ ៧ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ន

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១២៨ ។

បាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្ដែងថា បញ្ហា ៧ ឧទ្ទេស ៧ វេយ្យាករណ៍ ៧ ពាក្យនោះ ព្រះដ៏មាន ព្រះភាគសម្ដែងហើយ ព្រោះអាស្រ័យហេតុនេះ[១] ។

សេចក្ដីនេះគួរជ្រាបថាព្រះមានព្រះភាគ ទ្រង់យល់ព្រមដោយប្រការដូច្នេះ ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **សត្ត** ៧ ជាការកំណត់ចំនួនដាច់ខាត មិនខ្វះមិនលើស ។ ពាក្យថា **ពោជ្ឈង្គះ** នេះជាឈ្មោះរបស់ធម៌មានសតិជាដើម ។ អត្ថរបស់បទក្នុងពោជ្ឈង្គះ ៧ នេះមានដូច្នេះ ឈ្មោះថា **ពោធិ** ព្រោះមានវិគ្គហៈថា ព្រះអរិយសាវក រមែងត្រាស់ដឹងដោយធម្មសាមគ្គីពោលគឺ សតិ ធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខា ជាបដិបក្ខចំពោះឧបទ្រពជាច្រើន មានការរួញរាចិត្ត សេចក្ដីរាយមាយ ការបញ្ឈប់សេចក្ដីព្យាយាម សេចក្ដីព្យាយាមក្នុងកាមសុខល្លិកានុយោគ អត្តកិលមថានុយោគ និងការ ប្រកាន់ដោយឧច្ឆេទទិដ្ឋិ និងសស្សតទិដ្ឋិជាដើម ដែលកើតឡើងក្នុងខណៈនៃ មគ្គចិត្ត ចំណែកលោកិយៈ និងលោកុត្តរៈនោះ លោកអធិប្បាយថា ក្រោក ឡើងពីការលក់ គឺសន្តានដែលមានកិលេស ឬចាក់ធ្លុះអរិយសច្ចៈ ៤ ឬធ្វើឱ្យ ច្បាស់នូវព្រះនិព្វាននោះឯង ។ ដូចដែលលោកពោលទុកថា ទ្រង់ចម្រើនពោជ្ឈង្គះ ៧ ត្រាស់ដឹងដ៏ក្រៃលែងនូវអនុត្តរសម្មាសម្ពោធិញាណ ។

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១២៤-១២៥ ។

ម្យ៉ាងទៀត សូម្បីព្រះអរិយសាវ័ក ក៏ឈ្មោះថា **ពោធិ** ព្រោះ វិគ្រោះថា ត្រាស់ដឹងដោយធម្មសាមគ្គីនោះ មានប្រការតាមដែលពោលមកហើយ ។ ដូច្នេះ ឈ្មោះថា **ពោជ្ឈង្គៈ** ព្រោះជាអង្គ គឺចំណែកនៃពោធិ ពោលគឺ ធម្មសាមគ្គីនោះ ដូចជាអង្គនៃឈាន និងអង្គនៃមគ្គ ម្យ៉ាងទៀត ឈ្មោះថា **ពោជ្ឈង្គៈ** ព្រោះអង្គ របស់ព្រះអរិយសាវ័ក ដែលមានវោហារថា **ពោធិ** នោះ ដូចជាអង្គគឺ ចំណែក របស់កងទ័ព និងអង្គ គឺចំណែករបស់រថជាដើមដូច្នោះដែរ ។ ប្រការមួយទៀត គប្បីជ្រាបអត្ថថា **ពោជ្ឈង្គៈ** និងពោជ្ឈង្គៈទាំងឡាយ ដោយវិធីដែលលោកពោល ទុកក្នុងគម្ពីរបដិសម្ភិទាមគ្គយ៉ាងនេះថា សំនួរត្រង់ ពាក្យថា **ពោជ្ឈង្គៈ** តើ ពោជ្ឈង្គៈ ដោយអត្ថថាដូចម្តេច ? ឈ្មោះថា ពោជ្ឈង្គៈ ព្រោះហេតុប្រព្រឹត្តទៅ ព្រមក្នុងការត្រាស់ដឹង ឈ្មោះថាពោជ្ឈង្គៈ ព្រោះហេតុ ត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គៈ ព្រោះហេតុត្រាស់ដឹងតាម ឈ្មោះថាពោជ្ឈង្គៈ ព្រោះហេតុត្រាស់ដឹង ចំពោះ ឈ្មោះថាពោជ្ឈង្គៈ ព្រោះហេតុត្រាស់ដឹងព្រម[១] ។ ព្រះយោគាវចរ កាលចម្រើនធ្វើឱ្យច្រើននូវពោជ្ឈង្គៈ ៧ នេះ យ៉ាងនេះមិនយូរឡើយ នឹងជាអ្នក បានគុណ មានសេចក្តីទៀយណាយ ដោយចំណែកតែមួយជាដើម ព្រោះហេតុ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៧១ ទំព័រ ៦៤ ។

នោះ ទើបត្រាស់ថា រមែងធ្វើទីបំផុត ទុក្ខបានក្នុងបច្ចុប្បន្ន ។ សមដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុ ទាំងឡាយ ពោជ្ឈង្គៈទាំង ៧ នេះ ដែលបុគ្គលចម្រើនហើយ ធ្វើឱ្យរឿយៗ ហើយ រមែងប្រព្រឹត្តទៅដើម្បីនឿយ-ណាយដោយពិត ដើម្បីការប្រាសចាក រាគៈ ដើម្បីរំលត់ ដើម្បីចូលទៅជិតរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹងដើម្បីនិព្វាន"[១] ។

## អដ្ឋ នាម កិន្តិបញ្ហាវណ្ណនា

### ពណ៌នាបញ្ហាថា អ្វីទៅដែលឈ្មោះថា ៨ ?

ព្រះសាស្តាព្រះអង្គមានព្រះទ័យ គឺព្រះថេរៈធ្វើឱ្យទ្រង់ត្រេកអរ ដោយការព្យាករណ៍បញ្ហាសូម្បីយ៉ាងនេះហើយ ទើបត្រាស់សួរបញ្ហាបន្ថែមទៅថាអ្វីទៅ ដែលឈ្មោះថា ៨ ។ ព្រះថេរៈពោលនូវលោកធម៌ ៨ ទុកក្នុងការព្យាករណ៍ ក៏មែនពិតសូម្បីដូច្នោះ ភិក្ខុអ្នកមានចិត្តបានអប់រំ ហើយក្នុងធម៌ណាមួយ រមែងធ្វើទីបំផុតទុក្ខបាន ។ ព្រះថេរៈកាលសម្តែងធម៌ពួកនោះ មិនពោលថា អង្គអរិយមគ្គទាំង ៨ ព្រោះហេតុតែធម្មតាមគ្គដែលរួចផុតចាកអង្គ ៨មិនមាន ប៉ុន្តែមគ្គមានត្រឹមតែអង្គ ៨ ប៉ុណ្ណោះ

---

១-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ លេខ ៣៧ ទំព័រ ២១៥ ។

ព្រោះដូច្នោះ កាលនឹងឱ្យសម្រេចសេចក្តីនោះ ទើបទូលឆ្លើយដោយការវិចិត្រនៃទេសនាថា អរិយមគ្គអដ្ឋ ៨ ។ សេចក្តីនិងទេសនានយ័នេះ សូម្បីព្រះមានព្រះភាគក៏ទ្រង់យល់ព្រមទាំងអស់ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

“ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនី ជាអ្នកប្រាជ្ញ ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនីជាមនុស្សមានប្រាជ្ញាច្រើនមែន ម្នាលគហបតិទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ ចូលមករកតថាគត ហើយសួរនូវ សេចក្តីនោះ តថាគតក៏ដោះស្រាយសេចក្តីនោះយ៉ាងនោះ ដូចជាកជង្គលាភិក្ខុនី ដែលដោះស្រាយដែរ”[1] ។ កជង្គលាភិក្ខុនីនោះព្យាករណ៍ទុកយ៉ាងនេះថា “ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ឃើញនូវទីបំផុតដោយ ប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៨ រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌ ៨ គឺអ្វី ។ គឺ អដ្ឋង្គិកមគ្គដ៏ប្រសើរទាំង ៨ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ។ល។ ក្នុងធម៌ ៨ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះ ដ៏មានព្រះភាគ

---

[1] សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១២៨

សម្តែងថា បញ្ហា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ ពាក្យនោះ ព្រះដ៏មាន ព្រះភាគ សម្តែងហើយ ព្រោះអាស្រ័យហេតុនេះ"(១) ។ សេចក្តី និងទេសនាន័យនេះគប្បី ជ្រាបថា ព្រះមានព្រះភាគយល់ព្រមហើយដោយប្រការដូច្នេះ ។

បណ្តាបទទាំងនោះ បទថា អរិយោ ប្រែថា បុគ្គលត្រូវការព្រះនិព្វាន គប្បីសម្រេច ម្យ៉ាងទៀត មគ្គគប្បីជ្រាបថា **អរិយៈ** ព្រោះប្រព្រឹត្ត ទៅឆ្ងាយពីកិលេសទាំងឡាយ ព្រោះធ្វើឱ្យជាព្រះអរិយៈ និងសូម្បីព្រោះបាន អរិយផល ។ អង្គរបស់មគ្គនោះមាន ៨ ព្រោះហេតុនោះ មគ្គទើបឈ្មោះថា មានអង្គ ៨ ។ មគ្គនោះគប្បីជ្រាបថា មានត្រឹមតែអង្គប៉ុណ្ណោះ ព្រោះមគ្គមានសភាពដែលបុគ្គលនិងមិនគប្បីបានដោយបែកចាកអង្គចេញ ដូចជាកងទ័ព មានអង្គ ៤ និងតន្ត្រីមានអង្គ ៥ ។ បុគ្គលរមែងស្វែងរកព្រះនិព្វានដោយផ្លូវនេះ ឬស្វែងរក ដោយខ្លួនឯងហើយសម្លាប់កិលេសទៅ ព្រោះហេតុនោះ ផ្លូវ នេះទើបឈ្មោះថា មគ្គ ។ កិច្ចចម្រើនមគ្គមានប្រភេទ ៨ និងមានអង្គ ៨ នេះយ៉ាងនេះ រមែងទម្លុះអវិជ្ជា ញុំាងវិជ្ជាឱ្យកើតឡើង ធ្វើឱ្យជាក់ច្បាស់ព្រះនិព្វាន ព្រោះហេតុនោះ ទើបលោកពោលថាជាបុគ្គលធ្វើទីបំផុតទុក្ខបានក្នុងបច្ចុប្បន្ន សមដូចដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា ៖

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១២៥ ។

“ម្នាលភិក្ខុទាំងឡាយ ចុងគ្រាប់ស្រូវខ្សាយក្តី ចុងគ្រាប់ស្រូវជំណើបក្តី ដែលបុគ្គលរៀបចំត្រូវទំនង គឺធ្វើឱ្យមានចុងឡើងលើ បុគ្គលសង្កត់ដោយដៃ ឬជាន់ដោយជើង នឹងមុតដៃ ឬជើង នឹងធ្វើឈាមឱ្យផុលឡើងបាន ហេតុនេះ ទើបមានរឿងនោះ ព្រោះហេតុអ្វី ? ម្នាលភិក្ខុទាំងឡាយ ព្រោះចុងគ្រាប់ស្រូវ បុគ្គលរៀបចំត្រូវទំនង ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តតម្កល់ត្រូវនឹងទម្លាយអវិជ្ជា នឹងធ្វើវិជ្ជាឱ្យកើតឡើង នឹងធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ហេតុនេះ ទើបមានរឿងនោះ[១] ។

## ៨។ នាម កិច្ចិបញ្ហា វណ្ណនា

### ពណ៌នាបញ្ហាថា អ្វីទៅដែលឈ្មោះថា ៩ ?

ព្រះសាស្តាព្រះអង្គមានព្រះទ័យ គឺព្រះថេរៈធ្វើឱ្យទ្រង់ត្រេកអរ ដោយការព្យាករណ៍បញ្ហានេះ ទើបត្រាស់សួរបញ្ហាបន្តថា អ្វីទៅឈ្មោះថា ៩ ។ ព្រះថេរៈពោលបន្ថែមថា ៨។ ៩ ទើបទូលឆ្លើយថា សត្តាវាស ។ ក្នុងពាក្យនេះ ពាក្យថា ៨។ ជាការកំណត់ចំនួន ។ ពាក្យថា សត្វ បានដល់សត្វមានជីវិត លោកបញ្ញត្ត ទីកន្លែងអាស្រ័យខន្ធក្នុងជីវិតិន្ទ្រិយ ។ ពាក្យថា អាវាស បានដល់ ឈ្មោះថា អាវាស ព្រោះជាកន្លែងអាស្រ័យនៅ ។ កន្លែងនៅអាស្រ័យរបស់សត្វទាំងឡាយ ឈ្មោះថា

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ៤០ ទំព័រ ១៥ ។

សត្តាវាស ។ សត្តាវាសនោះជាវិធីនៃការទេសនា ។ ប៉ុន្តែកាលពោលតាមអត្ថន័យវិញ ពាក្យនេះជាឈ្មោះរបស់សត្វ ៩ ប្រភេទ ។ ដូចដែលព្រះសារីបុត្តដ៏មាន អាយុលោកពោលទុកថា ៖

"ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្សទេវតាពួកខ្លះ និងវិនិបាតិកៈពួកខ្លះ នេះជាសត្តាវាសទី ១ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់ព្រហ្មលោក ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជាសត្តាវាសទី ២ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកទេវតាក្នុងជាន់អាភស្សរៈ នេះជាសត្តាវាស ទី ៣ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់សុភកិណ្ហៈ នេះជាសត្តាវាស ទី ៤ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វឥតសញ្ញាមិនដឹងច្បាស់ (នូវអារម្មណ៍) ដូចពួកទេវតាជា អសញ្ញីសត្វ នេះជាសត្តាវាស ទី ៥ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុត ដូច្នេះ ព្រោះកន្លងបង់នូវពួករូបសញ្ញា ព្រោះវិនាសទៅនៃពួកបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញាដោយប្រការទាំងពួង នេះជាសត្តាវាស ទី ៦ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង

ហើយចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ដូច្នេះ នេះជាសត្តាវាស ទី ៧ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយ-តនជ្ឈាន ដោយបរិកម្មថា វត្ថុបន្តិចបន្តួចមិនមានដូច្នេះ នេះជាសត្តាវាស ទី ៨ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុនេះស្ងប់រម្ងាប់ វត្ថុនេះប្រសើរដូច្នេះ នេះជាសត្តាវាស ទី ៩[១] ។

ក៏ក្នុងទីនេះព្រះថេរៈពោលថាសត្តាវាស៩ក៏តាមន័យមុនៗនោះឯង មិនមែនពោលព្រោះមិនមានធម៌ ៩ យ៉ាងដទៃ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

“ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។លៗ ក្នុងធម៌ ៩ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌ ៩ គឺអ្វី ? គឺសត្តាវាសទាំង ៩ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយ ដោយប្រពៃ ។លៗ ក្នុងធម៌ ៩ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុង បច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ ដូច្នេះ ពាក្យនេះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ[២] ។

---

១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ២៣៥-២៣៧ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១១៨ ។

*ក៏ក្នុងបញ្ហានេះ ភិក្ខុលះបង់ការឃើញថា ទៀងល្អ សភាពជាខ្លួនសុខ ចេញដោយញាតបរិញ្ញាក្នុងសត្តាវាស ៩ ព្រោះព្រះបាលីថា“នវ ធម្មា បរិញ្ញេយ្យា កតមេ នវ, នវ សត្តាវាសា ធម៌ ៩ ដែលគួរកំណត់ដឹងតើដូចម្ដេចខ្លះ គឺ សត្តាវាស ៩[១] ជិនធ្អន់ដោយការឃើញត្រឹមតែជាគំនរសង្ខារសុទ្ធៗ ប្រាសចាកតម្រេក ដោយការឃើញអនិច្ចលក្ខណៈ ដោយតីរណបរិញ្ញា រួចផុតដោយការឃើញទុក្ខលក្ខណៈ ឃើញទីបំផុតដោយប្រពៃ ដោយការឃើញអនត្តលក្ខណៈ ត្រាស់ដឹងធម៌ដោយប្រពៃ ដោយបហានបរិញ្ញា រមែងធ្វើទីបំផុតទុក្ខបាន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបមានព្រះពុទ្ធតម្រាស់ថា ៖*

*“ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ ក្នុងធម៌ ៩ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌ ៩ គឺអ្វី? គឺសត្តាវាសៈទាំង ៩”[២] ។*

## ទស នាម កិន្តិបញ្ហាវណ្ណនា

## ពណ៌នាបញ្ហាដែលថា អ្វីទៅ ឈ្មោះថា ១០ ?

*ព្រះសាស្ដាព្រះអង្គមានព្រះទ័យ គឺព្រះថេរៈធ្វើឱ្យទ្រង់ត្រេកអរ ដោយការព្យាករណ៍សួម្បីយ៉ាងនេះ ហើយទើបត្រាស់សួរបញ្ហាថា អ្វីទៅដែលឈ្មោះថា១០*

---

*១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ៣៣០ ។*

*២-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១១៨ ។*

ក្នុងបញ្ហានោះ ព្រះមានព្រះភាគត្រាស់ដល់អកុសលកម្មបថ ១០ ទុកក្នុងការព្យាករណ៍ទាំងឡាយ ក្រៅពីការព្យាករណ៍បញ្ហានេះ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

"ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។ល។ ក្នុងធម៌ ១០ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌ ១០ គឺអ្វី ? គឺអកុសលកម្មបថទាំង ១០ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុ នឿយណាយដោយប្រពៃ ។ល។ ក្នុងធម៌ ១០ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដូច្នេះ ពាក្យនេះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ"[១] ។

មែនពិត សូម្បីយ៉ាងនោះ ក្នុងទីនេះ ព្រោះហេតុដែលព្រះថេរៈមិននាំខ្លួនឯងចូលទៅប្រាថ្នាតែព្យាករណ៍ព្រះអរហន្ត ឬព្រោះហេតុដែលបញ្ហាកម្ម ដែលព្រះថេរៈព្យាករណ៍ដោយបរិយាយនេះ ជាពាក្យព្យាករណ៍ល្អហើយ ព្រោះដូច្នោះ លោកប្រកបអង្គ ១០ ពួកណា លោកហៅថាព្រះអរហន្ត ព្រះថេរៈកាលសម្តែងការសម្រេចអង្គ ១០ ពួកនោះ ទើបទូលឆ្លើយដោយទេសនាជាបុគ្គលាធិដ្ឋានថា លោកប្រកបព្រមដោយអង្គ ១០ លោកហៅថា ព្រះអរហន្ត ។ ព្រោះក្នុងសេចក្តីនេះ លោកម្ចាស់ប្រកបព្រមដោយអង្គ ១០ ពួកណា លោកហៅថាព្រះអរហន្ត គប្បីជ្រាបថា អង្គ ១០ ពួកនោះ ព្រះថេរៈ ត្រូវត្រាស់សួរថា អ្វីទៅដែលឈ្មោះថា

១-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១១៨-១១៩ ។

*១០ ទើបទូលបង្ហាញប្រាប់ ។ ក៏អង្គ ១០ ពួកនោះ គប្បីជ្រាបតាមន័យដែលត្រាស់ទុកក្នុងព្រះសូត្រទាំងឡាយជា ដើមយ៉ាងនេះថា ៖*

*"(ភិក្ខុទូលសួរថា) បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ត្រាស់ថា អសេក្ខៈ អសេក្ខៈដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាអសេក្ខៈ តើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រកបដោយសម្មាទិដ្ឋិ ជាអសេក្ខៈ ប្រកបដោយសម្មាសង្កប្បៈ ជាអសេក្ខៈ ប្រកបដោយសម្មាវាចា ជាអសេក្ខៈ ប្រកបដោយសម្មាកម្មន្តៈ ជាអសេក្ខៈ ប្រកបដោយសម្មាអាជីវៈ ជាអសេក្ខៈ ប្រកបដោយសម្មាវាយាមៈ ជាអសេក្ខៈ ប្រកបដោយសម្មាសតិ ជាអសេក្ខៈ ប្រកបដោយសម្មាសមាធិ ជាអសេក្ខៈ ប្រកបដោយសម្មាញាណៈ ជាអសេក្ខៈ ប្រកបដោយសម្មាវិមុត្តិ ជាអសេក្ខៈ ។ ម្នាលភិក្ខុ (ភិក្ខុ)ជាអសេក្ខៈ យ៉ាងនេះឯង"[១] ។*

បរមត្ថជោតិកាយ ខុទ្ទកបាឋដ្ឋកថាយ

កុមារបញ្ហាវណ្ណនា និដ្ឋិតា

**ការពណ៌នាកុមារបញ្ហា**

**នៃ**

**អដ្ឋកថា ខុទ្ទកបាឋៈ ឈ្មោះ បរមត្ថជោតិកា ចប់ ២**

---

*១.សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥១ ទំព័រ ២៥-២៦ ។*

## ៥-មង្គលសុត្តវណ្ណនា

**ការពណ៌នាមង្គលសូត្រ**

## និក្ខេបប្បយោជនំ

**ប្រយោជន៍នៃការតាំងបទ**

ឥឡូវនេះ ដល់លំដាប់ការពណ៌នាសេចក្តីនៃមង្គលសូត្រ ដែលលើកជាបទបន្ទាប់អំពីកុមារបញ្ហា ។ ក្នុងទីនេះ ខ្ញុំនឹងពោលប្រយោជន៍នៃបទតាំងឡើង ហើយទើបនឹងពណ៌នាសេចក្តីនៃមង្គលសូត្រនោះ យ៉ាងណា ។ សេចក្តីពិតព្រះសូត្រនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ សូម្បីមិនបានត្រាស់តាមលំដាប់នេះ តែខ្ញុំពោលដើម្បីសម្តែងថាការរាប់អានព្រះសាសនា ដោយការដល់សរណៈ និងន័យតាមប្រភេទសីល សមាធិ បញ្ញា ទ្រង់សម្តែងទុកដោយសិក្ខាបទ ទុត្តិង្សាការៈ និងកុមារបញ្ហានេះណា សូម្បីទាំងអស់នោះ ក៏ជាមង្គលយ៉ាងក្រៃលែង ព្រោះអ្នកត្រូវការមង្គល ចាំបាច់ត្រូវធ្វើព្យាយាមយ៉ាងក្រៃលែងក្នុងមង្គលនោះ នុ៎ះឯង ។ ចំណែកការរាប់អានព្រះសាសនាជាដើមនោះជាមង្គលនោះ បណ្ឌិតគប្បីជ្រាបការតាមលំអាននៃព្រះសូត្រនេះ ។

នេះជាប្រយោជន៍នៃបទតាំងឡើងក្នុងមង្គលសូត្រនោះ ។

## បឋមមហាសង្គីតិកថា

**កថាពណ៌នាបឋមមហាសង្គាយនា**

ក៏ដើម្បីពណ៌នាសេចក្តីនៃមង្គលសូត្រនោះ ដែលលើកជាបទតាំងឡើងទុកយ៉ាងនេះ មានមាតិកាជាប្រធានដូច្នេះ ៖

ខ្ញុំនឹងពោលវិធីនេះយ៉ាងនេះថា ពាក្យនេះអ្នកណាពោល ពោលកាលណា

ពោលព្រោះហេតុណា កាលនឹងពណ៌នាសេចក្តីនៃបាឋៈមាន ឯវំ ជាដើម ក៏នឹងពោលសមុដ្ឋានដែលកើតមង្គលកំណត់មង្គលនោះ ហើយនឹងចង្អុលបង្ហាញសេចក្តីមង្គលនៃមង្គលសូត្រនោះ ។

ក្នុងមាតិកានោះ មុនដំបូងកន្លះគាថានេះថា វុត្តំ យេន យទា យស្មា ចេតំ វត្វា ឥមំ វិធឹ ។ លោកពោលសំដៅដល់ពាក្យគឺ ឯវម្មេ សុតំ ។ល។ ភគវន្តំ គាថាយ អជ្ឈភាសិ ។ មែនពិត ព្រះសូត្រនេះ លោកពោលដោយស្តាប់តៗ គ្នាមក ។ ក៏ព្រះដ៏មានព្រះភាគជាម្ចាស់នោះ ជាសយម្ភូ គឺជាព្រះពុទ្ធខ្លួនឯង មិនមានអាចារ្យ ព្រោះដូច្នោះ ពាក្យនេះ (និទានវចនៈ) ទើបមិនមែនព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គនោះ ។ ព្រោះហេតុដែលមានពាក្យ ពោលថា ពាក្យនេះ នរណាពោល ពោលកាលណា នឹងពោលព្រោះហេតុណា ។ ដូច្នោះ ទើបសូមពោលចង្អុលបង្ហាញដូច្នេះថា ពាក្យនេះព្រះអានន្ទពោល នឹងពោលក្នុងវេលាធ្វើមហាសង្គាយនាគ្រាដំបូង ។

សេចក្តីពិត ការធ្វើមហាសង្គាយនាគ្រាដំបូងនេះ គួរជ្រាបមកតាំងអំពីដើម ដើម្បីការឆ្លាតក្នុងនិទានវចនៈ ពាក្យដើមរបស់សូត្រទាំងពួងដូចតទៅនេះ ៖

កាលព្រះដ៏មានព្រះភាគព្រះអង្គជាទីពឹងរបស់លោក ទ្រង់បំពេញពុទ្ធកិច្ចចាប់ផ្តើមប្រកាសព្រះធម្មចក្រដរាបដល់ប្រោសសុភទ្ទបរិព្វាជក ហើយស្តេចបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ពេលទៀបភ្លឺថ្ងៃពេញបូរមីខែពិសាខ ចន្លោះដើម

សាលព្រឹក្សទាំងគូ ក្នុងសាលវនឧទ្យានជាកន្លែងលំហែរបស់មល្លក្សត្រ ជិតក្រុងកុសិនារា ។ ព្រះមហាកស្សបជាសង្ឃត្ថេររបស់ភិក្ខុប្រមាណ ៧០,០០០០ រូប ដែលបានប្រជុំគ្នា ក្នុងថ្ងៃចែកព្រះបរមសារីរិកធាតុរបស់ព្រះមានព្រះភាគ រឭកដល់ពាក្យភិក្ខុចាស់សុភទ្ទពោល ពេលព្រះមានព្រះភាគស្ដេចបរិនិព្វានបាន ៧ ថ្ងៃថា "ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ កុំសោយសោកឡើយ កុំខ្សឹកខ្សួលអណ្ដឺតអណ្ដកឡើយ យើងទាំងឡាយ ឈ្មោះថា ផុតស្រឡះហើយ អំពីព្រះមហា-សមណៈនោះ ព្រោះថា យើងទាំងឡាយ ព្រះមហាសមណៈ នោះតែងបៀតបៀនថា អំពើនេះ គួរដល់អ្នកទាំងឡាយ អំពើនេះ មិនគួរដល់អ្នកទាំងឡាយទេ ឥឡូវនេះស្រួលហើយ យើងរាល់គ្នា ចង់ធ្វើនូវអំពើណា នឹងធ្វើនូវអំពើនោះក៏បាន មិនចង់ធ្វើនូវអំពើណា នឹងមិនធ្វើនូវអំពើនោះ ក៏បាន"[១] ព្រះមហាកស្សបៈត្រិះរិះថា ពួកភិក្ខុអាក្រក់យល់ថា បាវចនៈ គឺ ធម្មវិន័យ មានសាស្ដាកន្លងហើយ បានបក្សពួកនឹងនាំគ្នាសង្កត់សង្កិន ធ្វើព្រះសទ្ធម្មឱ្យវិនាសទៅមិនយូរឡើយ ហេតុនេះរមែងប្រព្រឹត្តទៅបាន ។ ដរាបណា ធម្មវិន័យ ស្ថិតស្ថេរប្រាកដដរាបនោះ បាវចនៈ គឺ ធម្មវិន័យ ក៏មិនឈ្មោះថា មានសាស្ដាកន្លងទៅហើយដែរ ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ថាទុកថា៖

១-វិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ៣៥៨ ។

“យោ វោ អានន្ទ មាយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា ។ ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសំដែងហើយ បញ្ញត្តហើយដល់អ្នកទាំងឡាយ លុះអំណើះតតអំពីតថាគតទៅ ធម៌ និងវិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ”[១] ។

កុំដូច្នោះឡើយ ចាំយើង នឹងជួយគ្នាសង្គាយនាធម៌និងវិន័យ ដោយវិធីដែលព្រះសាសនាគប្បីស្ថិតនៅអស់កាលយូរ ។

ម្យ៉ាងទៀតសោត យើងកស្សបៈ គឺព្រះដ៏មានព្រះភាគទ្រង់អនុគ្រោះ ដោយសាធារណៈបរិភោគក្នុងចីវរទ្រង់ថា ៖

“ម្នាលកស្សបៈ អ្នកនឹងស្លៀកដណ្តប់សំពត់សម្បកធ្មៃ ជារបស់បង្សុកូលរបស់តថាគត ដែលតថាគតលែងប្រើប្រាស់ ឬទេ?”[២] ហើយទ្រង់អនុគ្រោះដោយទ្រង់ស្ថាបនាយើងទុកស្មើនឹងព្រះអង្គក្នុងឧត្តរិមនុស្សធម៌រឿយៗ ដោយអនុបុព្វវិហារធម៌ ៩[៣] និងអភិញ្ញា ៦ ដោយន័យជាដើមថា “ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដរាបណា ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលដល់បឋមជ្ឈាន ។បេ។ ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកបស្សបៈ

---

១-សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ លេខ ១៦ ទំព័រ ៣២១ ។

២-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លេខ ៣២ ទំព័រ ១៧២ ។

៣-សេចក្តីពិស្តារមានក្នុងគម្ពីរសុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ២៤០ ។

ប្រាថ្នាដរាបណា ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ។ល។ ចូលដល់បឋមជ្ឈាន ។ល។ ដរាបនោះ”[១] ។ យើងនោះនឹងមានបំណុលដទៃអ្វីសោតទៀត ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ភិក្ខុកស្សបៈនេះ នឹងជាអ្នកតម្កល់តម្កើងវង្សនៃព្រះសទ្ធម្មរបស់ព្រះតថាគត ទើបទ្រង់អនុគ្រោះយើង ដោយការអនុគ្រោះដែលមិនទូទៅ នេះហាក់ដូចជាព្រះរាជាទ្រង់អនុគ្រោះព្រះរាជឱរសដែលរក្សាត្រកូល ដោយទ្រង់ប្រគល់អាវក្រោះ និងព្រះរាជឥស្សរិយយសមិនមែនឬ ទើបធ្វើសេចក្ដីអនុគ្រោះឱ្យកើតដល់ភិក្ខុទាំងឡាយ ដើម្បីជួយគ្នាសង្គាយនាធម៌ និងវិន័យ ដូចដែលព្រះអានន្ទពោលទុកហើយថា ៖

“លំដាប់នោះឯង ព្រះមហាកស្សបៈមានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ សម័យមួយ ខ្ញុំគិតថានឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងបាវានេះ រួចហើយនឹងទៅកាន់ក្រុងកុសិនារា ហើយក៏ដើរទៅតាមផ្លូវឆ្ងាយជាមួយនឹងភិក្ខុសង្ឃជាច្រើនចំនួន ៥០០ រូប[២]” ។ សុភទ្ទក័ណ្ឌ គួរពោលឱ្យពិស្ដារទាំងអស់ ។ បន្ទាប់អំពីនោះមក ព្រះមហាកស្សបៈពោលថា ៖

“ម្នាលអាវុសោទាំងឡាយ ណ្ហើយចុះ យើងរាល់គ្នាសង្គាយនានូវធម៌

---

១-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លេខ ៣២ ទំព័រ ១៦៩ ។

២-វិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ៣៥៦ ។

និងវិន័យ តំណទៅមុខ អកុសលធម៌មុខជានឹងរុងរឿងឡើង កុសលធម៌មុខជានឹងសាបសូន្យទៅ សភាវៈមិនជាវិន័យមុខជានឹងរុងរឿងឡើង វិន័យមុខជានឹងសាបសូន្យទៅ តំណទៅមុខ ពួកបុគ្គលជាអធម្មវាទី នឹងមានកម្លាំងឡើង ពួកបុគ្គលជាធម្មវាទី នឹងថយកម្លាំងចុះ ពួកបុគ្គលជាអវិនយវាទី នឹងមានកម្លាំងឡើងពួកបុគ្គលជាវិនយវាទី នឹងថយកម្លាំងចុះ"[១] ។

ភិក្ខុទាំងឡាយពោលថា "បពិត្រព្រះថេរៈដ៏ចម្រើន បើយ៉ាងនោះ សូមព្រះថេរៈ ជ្រើសរើសភិក្ខុទាំងឡាយចុះ" ។ ព្រះថេរៈមិនយកភិក្ខុជាបុថុជ្ជន សោតាបន្ន សកទាគាមី អនាគាមី និងព្រះខីណាស្រពសុក្ខវិបស្សកៈ ដែលទ្រទ្រង់ព្រះបរិយត្តិ គឺនវង្គសត្ថុសាសន៍ទាំងអស់ ជាចំនួនច្រើនរយ ច្រើនពាន់រូប ជ្រើសរើសយកភិក្ខុជាព្រះអរហន្តប្រភេទវិជ្ជា ៣ ជាដើមប្រមាណ ៤៩៩ ដែលទ្រទ្រង់បរិយត្តិ គឺព្រះត្រៃបិដកទាំងអស់ បត្តបដិសម្ភិទា មានអានុភាពធំក្រៃលែងដោយច្រើន គឺព្រះដ៏មានព្រះភាគទ្រង់លើកតម្កើងជាឯតទគ្គៈ ដែលព្រះសង្គីតិកាចារ្យប្រាថ្នាពោលទុកថា "សម័យនោះឯង ព្រះមហាកស្សបៈដ៏មានអាយុជ្រើសរើសព្រះអរហន្ត ៤៩៩ រូប"[២] ។

សួរថា ហេតុអ្វីព្រះថេរៈទើបធ្វើឱ្យខ្វះមួយរូប ។ ឆ្លើយថា ដើម្បីទុកឱកាសដល់ព្រះអានន្ទដ៏មានអាយុ ព្រោះថា បើវៀរចាកព្រះអានន្ទដ៏មានអាយុចេញ

---

១- វិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ៣៥៨ ។

២- វិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ៣៥៩ ។

ហើយពុំអាចធ្វើសង្គាយនាធម៌បានទេ ។ ត្បិតថា ព្រះអានន្ទនោះជាព្រះសេក្ខៈនៅមានកិច្ចដែលត្រូវធ្វើ ព្រោះដូច្នោះ ទើបមិនអាចចូលរួមបាន តែព្រោះហេតុ នវង្គ-សត្ថុសាសន៍ មានសុត្តៈ និងគេយ្យៈជាដើមណាមួយ ដែលព្រះទសពល ទ្រង់សម្តែងហើយ ឈ្មោះថា ព្រះអានន្ទមិនបានទទួលចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគមិនមាន ព្រោះដូច្នោះ ទើបមិនអាចវៀរព្រះអានន្ទដកចេញបាន ។ ប្រសិនបើព្រះអានន្ទសូម្បីនៅជាសេក្ខៈបុគ្គលក៏ដោយ គួរតែព្រះថេរៈជ្រើសរើសយក ព្រោះជាអ្នកមានឧបការៈច្រើន ចំពោះការធ្វើសង្គាយនាធម៌ តែព្រោះហេតុអ្វី ទើបព្រះថេរៈមិនជ្រើសយក ។ ព្រោះដើម្បីជៀសវាងពីពាក្យតិះដៀល ។ មែនពិត ព្រះថេរៈមានការស្និទ្ធស្នាលលើសលប់ចំពោះព្រះអានន្ទ ។ ពិតយ៉ាងនោះមែន សូម្បីព្រះអានន្ទមានព្រះកេសាស្កូវហើយ ព្រះថេរៈនៅតែប្រៀនប្រដៅព្រះអានន្ទ ដោយវាទៈថាជាក្មេងថា "ក្មេងម្នាក់នេះមិនស្គាល់ប្រមាណសោះ"[១]។ ម្យ៉ាងទៀត ព្រះអានន្ទនេះ កើតក្នុងត្រកូលសក្យៈជាព្រះអនុជរបស់ព្រះតថាគត ជាឱរសរបស់ឪពុកមា ។ ក្នុងការជ្រើសរើសព្រះអានន្ទ ភិក្ខុទាំងឡាយ នឹងសម្គាល់លោកថា លំអៀងព្រោះស្រឡាញ់ គប្បីតិះដៀលថា ព្រះថេរៈមិនយកពួកភិក្ខុដែល សម្រេចអសេក្ខ-បដិសម្ភិទា បែរជាជ្រើសយកព្រះអានន្ទដែល សម្រេចជាសេក្ខបដិសម្ភិទាវិញ ។ ព្រះថេរៈ កាលនឹងជៀសវាងពាក្យតិះដៀលនោះ ទើបគិតថា "វៀរព្រះអានន្ទ

---

១-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លេខ ៣២ ទំព័រ ១៦៦ ។

ចេញហើយ ពុំអាចធ្វើសង្គាយនាកើត យើងនឹង ជ្រើសរើសយក ពេលភិក្ខុទាំងឡាយអនុមតិ(យល់ព្រម)ប៉ុណ្ណោះ ដូច្នេះហើយ ទើបមិនបានជ្រើសរើសយកដោយខ្លួនលោក ។

សម័យនោះ ភិក្ខុទាំងឡាយនាំគ្នាអង្វរព្រះថេរៈ ដើម្បីជ្រើសរើសព្រះអានន្ទខ្លួនឯង ដូចដែលព្រះអានន្ទពោលទុកថា ៖

"ភិក្ខុទាំងឡាយ និយាយពាក្យនឹងព្រះមហាកស្សបៈមានអាយុថា បពិត្រព្រះករុណាដ៏ចម្រើន ព្រះអានន្ទមានអាយុនេះ នៅជាសេក្ខបុគ្គលពិតមែន តែលោកអាចនឹងលុះដោយឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិទេ ធម៌ក្តីវិន័យក្តីព្រះអានន្ទបានសិក្សារៀនសូត្រ ក្នុងសម្នាក់ព្រះមានព្រះភាគជាច្រើន បពិត្រព្រះករុណាដ៏ចម្រើន បើដូច្នោះសូមព្រះថេរៈ ជ្រើសរើសយកព្រះអានន្ទមានអាយុផង"[១] ។ សម័យនោះឯង ព្រះមហាកស្សបៈ ទើបបានជ្រើសរើសព្រះអានន្ទចូលផង ។ ព្រះថេរៈទើបបានមានចំនួនគម្រប់ ៥០០ រូប រាប់ទាំងព្រះអានន្ទ ដែលព្រះថេរៈជ្រើសរើសយកដោយអនុមតិរបស់ភិក្ខុទាំងឡាយដោយប្រការដូច្នេះ ។

លំដាប់នោះ ភិក្ខុជាថេរៈទាំងឡាយពិភាក្សាគ្នាថា យើងនាំគ្នាសង្គាយនាធម៌វិន័យនៅទីកន្លែងណា ? បានសម្រេចគ្នាថា ទីក្រុងរាជគ្រឹះ មានទីគោចរអាហារ

---

១-វិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ៣៥៩ ។

*ច្រើនមានសេនាសនៈសម្បូរ បើដូច្នោះ យើងនឹងនៅចាំវស្សា នាំគ្នាធ្វើសង្គាយនា នៅទីក្រុងរាជគ្រឹះ ភិក្ខុពួកដទៃ (ដែលមិនបានជ្រើសរើស) មិនគប្បីចូលចាំវស្សា នៅទីក្រុងរាជគ្រឹះ ។ ព្រោះហេតុអ្វីទើបភិក្ខុថេរៈទាំងនោះ សម្រេចគ្នាដូច្នេះ ។ ព្រោះលោកគិតថា ការធ្វើសង្គាយនានេះជាថាវរកម្មរបស់យើង បុគ្គលជាវិសភាគ មិនត្រូវគ្នា គប្បីចូលមកកាន់កណ្ដាលជំនុំសង្ឃហើយរុះរើថាវរកម្មនោះបាន ។ សម័យនោះ ព្រះមហាកស្សបត្ថេរ ទើបប្រកាសដោយញត្តិទុតិយកម្ម ។ ពាក្យប្រកាសនោះ គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងសង្គីតិខន្ធកៈ[១]នោះឯង ។*

*សម័យនោះ រាប់តាំងពីព្រះមានព្រះភាគស្ដេចទ្រង់បរិនិព្វាន កាលសាធុកីឡា[២] កន្លងហួសទៅ ៧ ថ្ងៃ ការបូជាព្រះធាតុកន្លងទៅ ៧ ថ្ងៃទៀត ព្រះមហាកស្សបៈដឹងថា ពេលវេលាកន្លងទៅកន្លះខែហើយ នៅសល់ពេលមួយ ខែកន្លះទៀតនៃគិម្ហរដូវ ក៏ជិតតិចីចូលចាំវស្សា ទើបពោលថា អ្នកដ៏មានអាយុទាំងឡាយ*

---

*១-អដ្ឋកថានេះឃើញថា សង្គីតិខន្ធកៈ ប៉ុន្តែក្នុងវិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ៣៥៧ ឃើញថា បញ្ចសតិកក្ខន្ធកៈ ។*

*២-សាធុកីឡា ឬ... ក្រីឌា ការលេងសាធុ. ល្បែងសាធុ ការរីករាយសប្បាយ ដោយបញ្ចេញវាចាថា សាធុ ! ព្រមគ្នាឬខ្លាំងៗរឿយៗ ក្នុងវេលាកំពុងដើរហែព្រះពុទ្ធរូប ឬដើរប្រទក្សិណឧបោសថាគារជាដើម ដែលមានមនុស្សម្នាក់ស្រែកថា អនុមោទនាលោកអឺយ ! ( អ្ហើយ ) . . . អ្នកទាំងអស់ ទទួលព្រមគ្នាថា សាធុ ! ឬទទួលបីដងថា សាធុ ! សាធុ ! សាធុ ! ព្រមៗគ្នាឮខ្លាំង ។ ( វចនានុក្រមខ្មែរ សម្ដេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួន ណាត ទំព័រ ១៣៣០ )*

យើងនឹងនាំគ្នាទៅក្រុងរាជគ្រឹះ ក៏នាំពួកភិក្ខុពាក់កណ្តាលដើរតាមផ្លូវតែមួយ ។ សូម្បីព្រះអនុរុទ្ធត្ថេរ ក៏នាំភិក្ខុពាក់កណ្តាលទៅតាមផ្លូវមួយទៀត ។ ចំណែកព្រះអានន្ទកាន់បាត្រចីវររបស់ព្រះមានព្រះភាគ ដែលពួកភិក្ខុហែហមឆ្ពោះទៅក្រុងសាវត្ថីមុន ហើយទើបនឹងទៅក្រុងរាជគ្រឹះ ក៏បែកផ្លូវចារិកទៅក្រុងសាវត្ថី ។ ក្នុងទីកន្លែងដែលព្រះអានន្ទទៅដល់ៗ ក៏មានសំឡេងសោកសង្រេងយ៉ាងខ្លាំងថា បពិត្រលោកម្ចាស់អានន្ទ លោកម្ចាស់ទុកដាក់ព្រះសាស្តានៅទីណា ទើបនិមន្តមកតែមួយអង្គឯង ។ ពេលព្រះថេរៈដល់ទីក្រុងសាវត្ថីតាមលំដាប់ មានសំឡេងសោកសង្រេងកន្ទក់កន្ទេញក្រៃលែង ដូចក្នុងសម័យដែលព្រះមានព្រះភាគស្តេចបរិនិព្វាន។

បានឮថា សម័យនោះ លោកម្ចាស់អានន្ទបានលួងលោមមហាជននោះដោយធម្មីកថា ដែលប្រកបដោយអនិច្ចតា ការមិនទៀងជាដើម ទើបចូលទៅកាន់ព្រះវិហារជេតពន បើកទ្វារព្រះគន្ធកុដិ ដែលព្រះទសពលប្រថាប់ យកគ្រែតាំងមកគោះ ហើយបោសសម្អាតព្រះគន្ធកុដិ ចាក់ចោលសម្រាម គឺផ្កាឈើក្រៀមស្វិត នាំយកគ្រែតាំង ចូលទៅទុកតាមកន្លែងដើមវិញ បានធ្វើវត្តបដិបត្តិគ្រប់យ៉ាងដែលគួរធ្វើ ដូចជាសម័យព្រះមានព្រះភាគទ្រង់នៅព្រះជន្ម ។

ព្រះថេរៈទ្រាំធាន់ថ្នាំបញ្ចុះលាយជាមួយទឹកដោះក្នុងថ្ងៃទី ២ ដើម្បីធ្វើកាយដែលមានធាតុធ្ងន់ឱ្យស្រាល ព្រោះចាប់ផ្តើមអំពីព្រះមានព្រះភាគស្តេចបរិនិព្វានព្រះអានន្ទមានការឈរច្រើន អង្គុយច្រើន ទើបអង្គុយនៅតែក្នុងវិហារប៉ុណ្ណោះដែលលោកអាចដល់ ទើបពោលចំពោះបុរសដែលសុភមាណពប្រើទៅថា ៖

ម្នាលអ្នកកំលោះ ថ្ងៃនេះមិនទាន់សមគួរទេ ព្រោះអាត្មាឆាន់ថ្នាំបញ្ចុះ ចាំព្រឹកស្អែកនេះ អាត្មាទើបចូលទៅ ។

ថ្ងៃទី ២ ឡើង ព្រះថេរៈ មានព្រះចេតកត្ថេរៈ ជាបច្ឆាសមណៈជាប់តាមក្រោយទើបចូលទៅ ត្រូវសុភមាណព សួរបញ្ហាហើយបានពោលសូត្រទី ១០ ឈ្មោះសុភសូត្រ[១]ក្នុងទីឃនិកាយ ។ សម័យនោះ ព្រះថេរៈសុំឱ្យសុភមាណពជួយជួសជុលសន្ទះទ្វារដែលបាក់បែកក្នុងព្រះវិហារជេតពន សម័យជិតចូលវស្សាទើបនិមន្តទៅកាន់ក្រុងរាជគ្រឹះ ។ ព្រះមហាកស្សបត្ថេរ និងព្រះអនុរុទ្ធត្ថេរក៏យ៉ាងនោះដែរ ដឹកនាំពួកភិក្ខុទាំងអស់ទៅកាន់ក្រុងរាជគ្រឹះដូចគ្នា ។

សម័យនោះ ក្នុងទីក្រុងរាជគ្រឹះមានវត្តធំៗ ១៨ កន្លែង គ្រប់វត្តសុទ្ធតែមានសំរាមដែលគេទម្លាក់ចោលទៅ ។ ព្រោះក្នុងពេលដែលព្រះមានព្រះភាគស្តេចបរិនិព្វាន ភិក្ខុទាំងឡាយកាន់បាត្រចីវររបស់ខ្លួន បោះបង់វត្ត និងបរិវេណអស់ហើយទៅ ។ សម័យនោះ ព្រះថេរៈទាំងឡាយគិតគ្នាថា យើងនឹងជួយគ្នាជួសជុលវិហារទ្រុឌទ្រោម របូតអស់មួយខែដំបូងនៃវស្សា ដើម្បីបូជាព្រះពុទ្ធតម្រាស់ និងដោះសម្តីតិះដៀលរបស់ពួកតិរ្ថិយ ។ ត្បិតថា ពួកតិរ្ថិយនាំគ្នាតិះដៀលថា ពួកសាវករបស់ព្រះសមណគោតម កាលគ្រូនៅមានព្រះជន្មនាំគ្នាបម្រើ គ្រាដែលគ្រូបរិនិព្វានហើយនាំគ្នាបោះបង់ចោល ។ លោកអធិប្បាយថា

---

១-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៥ ទំព័រ ១៦០ ។

ព្រះថេរៈទាំងឡាយគិតគ្នា ដូច្នេះយើងក៏ដើម្បីដោះពាក្យតិះដៀលរបស់តិរ្ថិយពួកនោះ ។ សមដូចដែលលោកពោលទុកថា ៖

"គ្រានោះ ភិក្ខុទាំងឡាយជាថេរៈមានសេចក្តីរិះគិតដូច្នេះថា ម្នាលអាវុសោ បដិសង្ខរណកម្ម គឺការជួសជុលសេនាសនៈដែលដាច់ដាចធ្លុះធ្លាយ ព្រះមានព្រះភាគទ្រង់សរសើរហើយ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ គួរតែយើងរាល់គ្នាជួសជុលសេនាសនៈ ដែលដាច់ដាចធ្លុះធ្លាយអស់ខែជាដំបូងសិន ដល់មកខែជាកណ្តាល យើងនឹងប្រជុំគ្នាសង្គាយនានូវធម៌ និងវិន័យ"[១] ។

ថ្ងៃទី ២ ព្រះថេរៈពួកនោះ នាំគ្នាទៅឈរក្បែរទ្វារព្រះរាជនិវេសន៍របស់ព្រះបាទអជាតសត្រូវ ។ ស្តេចយាងមកទ្រង់ថ្វាយបង្គំហើយបវារណាថា បពិត្រលោកម្ចាស់ទាំងឡាយ ញោមនឹងធ្វើអ្វីបានខ្លះទេ លោកម្ចាស់ត្រូវការអ្វី ? ព្រះថេរៈទាំងឡាយថ្វាយព្រះពរសូមហត្ថកម្ម ដើម្បីត្រូវការជួសជុលវត្តធំៗ ១៨ កន្លែង ។ ព្រះរាជាទ្រង់ទទួលថា ប្រពៃណាស់លោកម្ចាស់ ហើយទើបព្រះរាជទានមនុស្សធ្វើការ ។ ព្រះថេរៈទាំងឡាយឱ្យការជួសជុលវិហារទាំងអស់ រហូតអស់មួយខែដំបូង ។ បន្ទាប់មក ទើបថ្វាយព្រះពរព្រះរាជាថា បដិសង្ខរណកម្ម ការជួសជុលសេនាសនៈដែលដាច់ដាចធ្លុះធ្លាយរួចស្រេចហើយ ឥឡូវនេះ អាត្មាភាពទាំងឡាយនឹងនាំគ្នាធ្វើសង្គាយនាធម៌ និងវិន័យ ។ ព្រះរាជាមានព្រះតម្រាស់ថា ប្រពៃណាស់លោកម្ចាស់ សូមព្រះគុណម្ចាស់មេត្តាធ្វើតាមសប្បាយចុះ ការងារ

១-វិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ៣៦១ ។

អាណាចក្រជាភារកិច្ចរបស់ខ្ញុំព្រះករុណា ការងារធម្មចក្រជាភារកិច្ចរបស់ព្រះគុណម្ចាស់ទាំងឡាយ ។ ព្រះរាជាត្រាស់សួរថា មេត្តាប្រោស តើលោកម្ចាស់ឱ្យខ្ញុំព្រះករុណាធ្វើអ្វីខ្លះ ។ ព្រះថេរៈទាំងឡាយថ្វាយព្រះពរទូលថា ថ្វាយព្រះពរ មេត្តាឱ្យសាងកន្លែងសម្រាប់អង្គុយប្រជុំភិក្ខុទាំងឡាយ ដែលជួយធ្វើសង្គាយនាធម៌ ។ ត្រាស់សួរថា នឹងធ្វើនៅកន្លែងណា លោកម្ចាស់ ។ ទូលឆ្លើយថា ថ្វាយព្រះពរមហាបពិត្រ ធ្វើជិតទ្វារល្អាងសត្តបណ្ណៈក្បែរភ្នំវេភារៈ គួរសម ។ ព្រះបាទ-អជាតសត្រូវ ទទួលថា ករុណាលោកម្ចាស់ ហើយប្រោសប្រទានឱ្យសាងមណ្ឌបដ៏ធំ មានជញ្ជាំង សសរ និងជណ្តើរ ដែលគេរៀបចំដ៏ល្អ វិចិត្រដោយក្បាច់ផ្កាឈើ និងក្បាច់ភ្ញីវល្លិ៍ ប្រភេទផ្សេងៗ ដូចជាវិស្សកម្មទេវបុត្រនិម្មិតទុក តាក់តែងមណ្ឌបដ៏ធំនោះ ឱ្យមានពិតានមាសលាយទ្បំ និងកម្រងផ្កាឈើបូជានានា ដែលសំយុង ភូមិភាគផ្ទៃដីក៏រៀបរយល្អស្រេច លម្អដោយផ្កាឈើបូជានានា ដូចជាភូមិភាគផែនដីដែលកែលម្អដោយកូនរាំង ដូចជាមណីរតនវិចិត្រ ហាក់ដូចជាវិមានព្រហ្ម ប្រោសប្រទានឱ្យក្រាលកម្រាលអាសនៈជាកប្បិយៈ ៥០០ មានតម្លៃរាប់មិនបាន ក្នុងមណ្ឌបដ៏ធំនោះ សម្រាប់ភិក្ខុ ៥០០ រូប ឱ្យក្រាលអាសនៈ ព្រះថេរៈបែរមុខទៅទិសខាងជើង បែរខ្នងទៅទិសខាងត្បូង ក្រាលធម្មាសនៈ សម្រាប់អង្គុយសម្តែងធម៌ដែលគួរជាអាសនៈសម្រាប់ព្រះមានព្រះភាគ បែរមុខទៅទិសខាងកើត កណ្តាលមណ្ឌប ដាក់ផ្ចិតធ្វើដោយភ្លុកដំរីទុកលើធម្មាសនៈនោះ ហើយបានបង្គាប់ឱ្យផ្តៀង ដល់ភិក្ខុសង្ឃថា កិច្ចកម្មរួចស្រេចហើយលោកម្ចាស់ ។

សម្រាប់ជាធម្មទាន

ភិក្ខុទាំងឡាយ ពោលចំពោះព្រះអានន្ទដ៏មានអាយុថា អាវុសោអានន្ទ ព្រឹកនេះ ជាថ្ងៃប្រជុំសង្ឃ ចំណែកខ្លួនលោកជាសេក្ខៈ នៅមានកិច្ចត្រូវធ្វើ ព្រោះហេតុនោះ លោកទើបគួរទៅប្រជុំ សូមលោកចូរកុំប្រមាទឡើយ ។ សម័យនោះ ព្រះអានន្ទត្រិះរិះថា ព្រឹកនេះជាថ្ងៃប្រជុំ ការដែលយើងនៅ ជាសេក្ខៈទៅប្រជុំពុំសមគួរឡើយដូច្នេះ ទើបនៅដោយកាយគតាសតិ រហូតអស់រាត្រីដ៏ច្រើន វេលាជិតភ្លឺ ទើបចុះចាកទីចង្ក្រមចូលទៅកាន់វិហារ នឹកដល់កាលប្រាថ្នានឹងសឹងសម្រាក ។ ជើងទាំងពីរផុតពីផ្ទៃដី និងព្រះសិសៈ មិនទាន់ដល់ខ្នើយ ក្នុងចន្លោះនោះ ចិត្តក៏មិនប្រកាន់មាំចិត្ត ក៏រួចផុតចាកអាសវៈទាំងឡាយ ។

មែនពិត លោកម្ចាស់នេះនៅខាងក្រៅ ដោយការចង្ក្រមមិន អាចធ្វើគុណវិសេសឱ្យកើតបាន ទើបត្រិះរិះថា ព្រះមានព្រះភាគបានត្រាស់ចំពោះអាត្មាអញទុកថា ម្នាលអានន្ទ អ្នកមានបុណ្យ ដែលធ្វើទុកហើយ ចូរប្រកបសេចក្តីព្យា-យាមរឿយ ៗ ក៏នឹងជាបុគ្គល ឥតមានអាសវៈ ចាប់រហ័សមិនដូច្នោះ ? ក៏ធម្មតាថា ព្រះពុទ្ធទាំងឡាយត្រាស់ទុកមិនខុស យើងប្រារព្ធសេចក្តីព្យាយាម ខ្លាំងក្លាពេក ព្រោះហេតុនោះ ចិត្តរបស់យើងទើបប្រព្រឹត្តទៅដោយសេចក្តីរាយ មាយណ្ហើយចុះ ចាំយើងប្រកបសេចក្តីព្យាយាមល្មម ទើបចុះចាកទីចង្ក្រម ឈរលាងព្រះបាទ លាងព្រះបាទរួចហើយ ក៏ចូលទៅកាន់វិហារ អង្គុយលើគ្រែ គិតនឹងសម្រាកបន្តិច ក៏បង្អោនកាយដាក់លើគ្រែ ។ ជើងទាំងពីរផុតពីផ្ទៃកម្រាល ហើយព្រះសិសៈ មិនទាន់ដល់ខ្នើយផង ក្នុងចន្លោះនោះ ចិត្តប្រកាន់មាំ ក៏រួចផុតចាកអាសវៈទាំងឡាយ ។

ព្រះអរហត្តរបស់ព្រះថេរៈ វៀរចាកឥរិយាបថ ៤ ព្រោះហេតុនោះ កាលសួរថា ព្រះសាសនានេះ ភិក្ខុរូបណា មិនអង្គុយ មិនដេក មិនឈរ មិនដើរ សម្រេច ព្រះអរហត្តក៏នឹងឆ្លើយថា ព្រះអានន្ទថេរៈ ។

ក្នុងថ្ងៃទី ២ ភិក្ខុថេរៈទាំងឡាយ ឆាន់ភត្តាហារ ទុកដាក់បាត្រ ចីវរហើយ ក៏ប្រជុំគ្នាក្នុងធម្មសភា ។ ចំណែកព្រះអានន្ទប្រាថ្នានឹងឱ្យសង្ឃដឹងការសម្រេចព្រះអរហត្តរបស់ខ្លួន ទើបមិននិមន្តទៅនិងភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយ កាលអង្គុយលើអាសនៈដែលដល់ខ្លួនៗ តាមលំដាប់ ក៏អង្គុយវៀរអាសនៈរបស់ព្រះអានន្ទត្ថេរ ។ ក្នុងទីនោះ កាលមានព្រះថេរៈពួកខ្លះសួរថា នោះជាអាសនៈរបស់នរណា ក៏មានសំឡេងឆ្លើយថា របស់ព្រះអានន្ទ ។ សួរថា ព្រះអានន្ទនិមន្តទៅទីណាហើយ ? សម័យនោះ ព្រះថេរៈរំពឹងថា ឥឡូវនេះជាពេលដែលយើងទៅបានហើយ ។ ដូច្នេះ កាលសម្តែងអានុភាពរបស់ខ្លួន ទើបជ្រែកផែនដីបង្ហាញខ្លួនលើអាសនៈរបស់ខ្លួន ។ អាចារ្យពួកខ្លះពោលថា និមន្តមកតាមអាកាសអង្គុយក៏មាន ។

កាលព្រះអានន្ទអង្គុយស្រួលបួលហើយ ព្រះមហាកស្សបត្ថេរទើបប្រឹក្សានឹងភិក្ខុទាំងឡាយថា "ម្នាលអាវុសោទាំងឡាយ យើងនឹងនាំគ្នាសង្គាយនាអ្វីមុន ធម៌ ឬវិន័យ" ។ ភិក្ខុទាំងឡាយទើបពោលថា បពិត្រព្រះមហាកស្សបៈ ធម្មតាវិន័យជាអាយុរបស់ព្រះពុទ្ធសាសនា កាលវិន័យស្ថិតស្ថេរនៅ ព្រះសាសនាក៏ឈ្មោះថា ស្ថិតស្ថេរនៅដែរ ព្រោះដូច្នោះ យើងនឹងសង្គាយនាវិន័យមុនចុះ ។ ព្រះថេរៈសួរថា នឹងប្រគល់ឱ្យនរណាសង្គាយនាព្រះវិន័យ ? ភិក្ខុទាំងឡាយពោលថា

ព្រះឧបាលិ ដ៏មានអាយុ ។ ព្រះថេរៈសួរជំទាស់ថា ព្រះអានន្ទពុំអាចឬ ? ភិក្ខុទាំងឡាយពោលថា មិនមែនដូច្នោះទេ ប៉ុន្តែថា ព្រះមានព្រះភាគកាលគង់ព្រះជន្មនៅឡើយ ទ្រង់អាស្រ័យការសិក្សាព្រះវិន័យ ទើបទ្រង់ស្ថាបនា ព្រះឧបាលីទុកក្នុងតំណែងឯតទគ្គថា“ ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ វិនយធរានំ យទិទំ ឧបាលិ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកទ្រទ្រង់វិន័យ ដែលជាសាវករបស់តថាគតស្រេចនឹងឧបាលិ”[១] ។ ព្រោះដូច្នោះ ខ្ញុំនឹងសួរព្រះឧបាលិត្ថេរ នាំគ្នាសង្គាយនាព្រះវិន័យ ។ បន្ទាប់អំពីនោះ ព្រះថេរៈ ទើបសម្មតិខ្លួន ដោយខ្លួនឯង ដើម្បីសួរវិន័យ ចំណែកព្រះឧបាលិត្ថេរវិញក៏សម្មតិខ្លួន ដើម្បីឆ្លើយព្រះវិន័យ ។ ក្នុងសេចក្តីនោះ មានបាលីដូច្នេះ

ព្រះមហាកស្សបៈផ្ទៀងថា ៖

“សុណាតុ មេ អាវុសោ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ ឧបាលឹ វិនយំ បុច្ឆេយ្យំ ។ ម្នាលអាវុសោ សង្ឃស្តាប់ខ្ញុំ បើសង្ឃតិកម្មនេះមានកាលគួរ ដល់សង្ឃហើយ ខ្ញុំគប្បីសួរវិន័យនឹងព្រះឧបាលិ”[២] ។

សូម្បីព្រះឧបាលិក៏ផ្ទៀងថា ៖

“សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អាយស្មតា មហាកស្សបេន វិនយំ បុដ្ឋោ វិសជ្ជេយ្យំ ។ បពិត្រព្រះសង្ឃដ៏

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ៤០ ទំព័រ ៥៥ ។

១-វិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ៣៦២ ។

ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃឹតិកម្មនេះ មានកាលគួរដល់សង្ឃហើយ ព្រះមហាកស្សបៈដ៏មានអាយុ ត្រូវសួរព្រះវិន័យចំពោះខ្ញុំៗ ក៏ត្រូវដោះស្រាយ (ក្នុងកាលឥឡូវនេះ)”[១]។

ព្រះឧបាលិ កាលសម្មតិខ្លួនដោយខ្លួនឯងយ៉ាងនេះហើយ ក៏ក្រោកចាកអាសនៈ គ្រងចីវរឆៀងស្មាម្ខាង សំពះភិក្ខុជាថេរៈ ហើយអង្គុយលើធម្មាសនៈ ចាប់ផ្លិតធ្វើដោយភ្លុក ។ តពីនោះ ព្រះមហាកស្សបត្ថេរ ទើបសួរវិន័យទាំងអស់តាំងតែពីបឋមបារាជិកជាដើមទៅនឹងព្រះឧបាលិត្ថេរ ។ ព្រះឧបាលិត្ថេរ ក៏ឆ្លើយនូវព្រះវិន័យ ភិក្ខុទាំង ៥០០ រូប ក៏សូត្រព្រមៗគ្នា តាំងអំពីបឋមបារាជិកសិក្ខាបទ ព្រមទាំងនិទាន សូម្បីសិក្ខាបទក្រៅនោះ ក៏សូត្រយ៉ាងនោះព្រោះហេតុនោះគប្បីកាន់យករឿងទាំងអស់តាមអដ្ឋកថាវិន័យ ។ ព្រះឧបាលិត្ថេរ កាលសង្គាយនាវិន័យបិដកទាំងអស់ ព្រមទាំងវិភង្គទាំង ២ (ភិក្ខុវិភង្គ ភិក្ខុនីវិភង្គ) ព្រមដោយគម្ពីរខន្ធកៈ និងបរិវារៈ ដោយន័យនេះហើយក៏ដាក់ផ្លិតភ្លុក ចុះចាកធម្មាសនៈ ថ្វាយបង្គំភិក្ខុចាស់ ហើយក៏អង្គុយលើអាសនៈដែលគួរដល់ខ្លួន ។

ព្រះមហាកស្សបត្ថេរ កាលសង្គាយនាវិន័យហើយ បំណងនឹងសង្គាយនាព្រះសូត្រ និងព្រះអភិធម្ម ទើបសួរភិក្ខុទាំងឡាយថា លោកទាំងឡាយកាលសង្គាយនាព្រះសូត្រ និងព្រះអភិធម្ម នឹងប្រគល់ធុរៈឱ្យដល់បុគ្គលណា សង្គាយនា

---

១-វិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ៣៦២ ។

ព្រះសូត្រ និងព្រះអភិធម្ម ។ ភិក្ខុទាំងឡាយប្រាប់ថា ប្រគល់ធុរៈឱ្យព្រះអានន្ទត្ថេរចុះ ។

កាលនោះ ព្រះមហាកស្សបៈទើបផ្តៀងសង្ឃថា ៖

“សុណាតុ មេ អាវុសោ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អានន្ទំ ធម្មំ បុច្ឆេយ្យំ ។ ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ បើសង្ឃតិកម្មមានកាលគួរ ដល់សង្ឃហើយ ខ្ញុំគប្បីសួរនូវធម៌ចំពោះព្រះអានន្ទ”[១] ។

កាលនោះ ព្រះអានន្ទក៏ផ្តៀងសង្ឃថា ៖

“សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អាយស្មតា មហាកស្សបេន ធម្មំ បុដ្ឋោ វិស្សជ្ជេយ្យំ ។ បពិត្រសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃតិកម្មមានកាលគួរដល់សង្ឃហើយ ព្រះមហាកស្សបៈមានអាយុ នឹងសួរធម៌ចំពោះខ្ញុំ”[២] ។

កាលនោះ ព្រះអានន្ទក្រោកចាកអាសនៈ គ្រងចីវរ ធៀងស្មាម្ខាងថ្វាយបង្គំភិក្ខុជាថេរៈហើយ ក៏អង្គុយលើធម្មាសនៈ កាន់យកផ្ចិតភ្លុក ។ លំដាប់នោះ **ព្រះមហាកស្សបត្ថេរ សួរព្រះសូត្រ និងព្រះអភិធម្មនឹងព្រះអានន្ទថា អាវុសោអានន្ទ** ព្រហ្មជាលសូត្រ ព្រះមានព្រះភាគត្រាស់ក្នុងទីណា ? ឆ្លើយថា ត្រាស់ក្នុងសំណាក់ព្រះរាជឧទ្យានឈ្មោះអម្ពលដ្ឋិកា ដែលនៅចន្លោះក្រុងរាជគ្រឹះ និងនគរនាលន្ទា ។ សួរថា ប្រារព្ធចំពោះអ្នកណា ? ឆ្លើយថា ទ្រង់ប្រារព្ធសុប្បិយបរិព្វាជក

១-វិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ៣៦៤ ។

២-វិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ៣៦៤ ។

និងព្រហ្មទត្តមាណព ។ លំដាប់នោះ ព្រះមហាកស្សបៈសួរព្រះអានន្ទ ដល់និទាននៃព្រហ្មជាលសូត្រ សួរទាំងបុគ្គល ។ សួរថា អាវុសោអានន្ទ ក៏សាមញ្ញផលសូត្រត្រាស់ក្នុងទីណា? ឆ្លើយថា នៅឯចម្ការស្វាយរបស់ពេទ្យជីវកក្រុងរាជគ្រឹះ ។ សួរថា ត្រាស់ចំពោះអ្នកណា ។ ឆ្លើយថា ចំពោះព្រះបាទអជាតសត្រូវវេទេហិបុត្រឱរសព្រះនាងវេទេហី ។ លំដាប់នោះ ព្រះមហាកស្សបៈទើបសួរព្រះអានន្ទដល់និទាននៃសាមញ្ញផលសូត្រ សួរដល់បុគ្គល ។ ព្រះមហាកស្សបៈសួរសូម្បីទាំង ៤ និកាយ ដោយឧបាយនេះនេះឯង ព្រះអានន្ទ ត្រូវព្រះមហាកស្សបៈសួរហើយសួរទៀតក៏ឆ្លើយបានទាំងអស់ ។ បឋមមហាសង្គីតិសង្គាយនាជំគ្រាដំបូងនេះព្រះថេរៈ ៥០០ រូបជួយគ្នាធ្វើ ។

សតេហិ បញ្ចហិ កតា តេន បញ្ចសតាតិ ច
ថេរេហេវ កតត្តា ច ថេរិកាតិ បវុច្ចតិ ។

បឋមសង្គីតិការធ្វើសង្គាយនាជំ គ្រាដំបូងដែលព្រះថេរៈ ៥០០ រូបធ្វើដោយហេតុនោះ ទើបលោកហៅថា បញ្ចសតា ហេតុតែកិច្ចទាំងនោះសុទ្ធ តែជាព្រះថេរៈទាំងអស់ ទើបហៅថា **ថេរិកា** (លទ្ធិថេរវាទ) ។

កាលបឋមសង្គីតិនេះកំពុងដំណើរការ កាលព្រះអានន្ទគឺព្រះមហាកស្សបៈកាលសួរគម្ពីរទីឃនិកាយនិងគម្ពីរមជ្ឈិមនិកាយជាដើមអស់ហើយ កាលនឹងសួរគម្ពីរខុទ្ទកនិកាយតាមលំដាប់ ក្នុងចុងពាក្យដែលលោកសួរជាដើម យ៉ាងនេះថាអាវុសោអានន្ទ មង្គលសូត្រព្រះមានព្រះភាគត្រាស់ក្នុងទីណា ដូច្នេះ ទើបសួរ

ដល់និទានក្នុងពាក្យនេះថា សួរទាំងនិទាន សួរទាំងបុគ្គល ។ ព្រះអានន្ទ បំណង នឹងពោលនិទាននោះឱ្យពិស្តារថា ត្រាស់យ៉ាងណា អ្នកណាស្តាប់មក ស្តាប់កាលណា ហើយអ្នកណាពោល ពោលនៅទីណា ពោលដល់អ្នកណា នឹងពោលសេចក្តីនោះឱ្យអស់ កាលនឹងសម្តែងសេចក្តីនោះថា ត្រាស់ទុកយ៉ាងនេះ ។ ខ្ញុំបានស្តាប់មក សម័យមួយ ព្រះមានព្រះភាគត្រាស់នៅឯក្រុងសាវត្ថី ត្រាស់ដល់ទេវតាដូច្នេះទើបពោលថា ឯវម្មេ សុតំ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ល។ ភគវន្តំ គាថាយ អជ្ឈភាសិ ។ ពាក្យនេះ ព្រះអានន្ទពោលទុកយ៉ាងនេះ ។ ក៏ឯពាក្យនោះ គប្បីជ្រាបថា លោកពោលទុកក្នុងវេលាធ្វើបឋមមហាសង្គីតិ ។

ឥឡូវនេះ នឹងអធិប្បាយសេចក្តីនេះថា ត្រាស់ព្រោះហេតុអ្វី ។ ព្រោះហេតុដែលព្រះមហាកស្សបៈសួរដល់និទានដូច្នោះ ទើបលោកពោលនិទាននោះពិស្តារតាំងតែពីដើម ម្យ៉ាងទៀត ព្រោះហេតុតែទេវតាពួកខ្លះ ឃើញព្រះអានន្ទអង្គុយលើធម្មាសនៈ ចោមរោមដោយគណៈអ្នកជំនាញ ទើបកើតចិត្តគិតថា ព្រះអានន្ទនេះជា ***ទេវេហមុនី***[១] សូម្បីដោយប្រក្រតី រាប់តាំងតែពីនៅក្នុងសក្យៈ

---

១-បណ្ឌិតោ ហិ ញាណសង្ខាតេន វេទេន ឦហតិ សព្វកិច្ចានិ ករោតិ តស្មា វេទេហោតិ វុច្ចតិ ។ វេទេហោ ច សោ មុនិ ចាតិ វេទេហមុនិ ។ *សេចក្តីថា បណ្ឌិត តែងព្យាយាម គឺថាតែងធ្វើនូវ សព្វកិច្ចដោយវេទ ពោលគឺញាណ(ប្រាជ្ញា) ព្រោះហេតុនោះ ទើបលោកហៅថា វេទហបុគ្គល ។ បុគ្គល ជាវេទហៈផង ជាអ្នកប្រាជ្ញផង ឈ្មោះថា វេទេហមុនី ។ សារត្ថប្បកាសិនី អដ្ឋកថា សំយុត្តនិកាយ ។*

*ត្រកូល ជាទាយាទរបស់ព្រះមានព្រះភាគ សូម្បីតែព្រះមានព្រះភាគក៏ទ្រង់លើកឡើងទុកក្នុងតំណែងឯតទគ្គៈដល់ទៅ ៥ ស្ថាន ជាអ្នកប្រកបដោយអច្ឆរិយអព្ភូតធម៌ ៤ ប្រការ ជាទីស្រឡាញ់ពេញចិត្តរបស់បរិស័ទ ៤ ឥឡូវនេះទំនងជាធម្មរាជទាយាទរបស់ព្រះមានព្រះភាគកើតជាអ្នកត្រាស់ដឹង ។ ដូច្នោះព្រះអានន្ទដឹងសព្វដល់បរិវិតក្កៈផ្លូវចិត្តរបស់ទេវតាទាំងនោះ ដោយចិត្តរបស់ខ្លួនឯង អត់ទ្រាំ ការលើកតំកើងគុណដែលមិនមានពិតនោះ មិនបានដើម្បីសម្ដែងភារៈ ដែលខ្លួន ត្រឹមជាសាវ័ក ទើបពោលថា ឯវម្មេ សុតំ ឯកំ សមយំ ភគវា ។ល។ អជ្ឈភាសិ ។ ក្នុងចន្លោះនេះ ព្រះអរហន្ត ៥០០ រូប និងទេវតាច្រើនពាន់ ក៏សរសើរព្រះអានន្ទថា សាធុ សាធុ ។ ផែនមហាប្រថពីក៏កម្រើក ភ្លៀងផ្កាឈើនានាក៏ជ្រុះអំពីអាកាស សេចក្ដីអស្ចារ្យយ៉ាងដទៃក៏ប្រាកដឡើងយ៉ាងច្រើន ហើយទេវតាទាំងឡាយក៏កើតសេចក្ដីសង្វេគថា ពាក្យណាខ្ញុំបានស្ដាប់អំពីព្រះភក្ត្រព្រះមានព្រះភាគ ពាក្យនោះ សូម្បីហេតុការណ៍កន្លងពីចក្ខុវិស័យហើយ ក៏កើតមកបាន ។ ពាក្យនេះ ព្រះអានន្ទសូម្បីនឹងពោលក្នុងការធ្វើបឋមមហាសង្គីតិ ក៏គប្បីជ្រាបថា លោកពោលព្រោះហេតុនេះ ដោយប្រការដូច្នេះ ។ ដោយការពណ៌នាត្រឹមតែប៉ុណ្ណេះ ក៏ជាការប្រកាសសេចក្ដីនៃកន្លះគាថានេះថា "វុត្តំ យេន យទា យស្មា ចេតំ វត្វា ឥមំ វិធឹ ពោលវិធីនេះថា អ្នកណាពោល ពោលក្នុង កាលណា ពោលព្រោះហេតុអ្វី " ។*

## ឯវមិច្ចាទិបាឋវណ្ណនា

**ពណ៌នាបាឋៈថា ឯវំ ជាដើម**

ឥឡូវនេះ ដើម្បីប្រកាសសេចក្ដីដែលសង្គ្រោះ ដោយចំណងជើងជាដើម យ៉ាងនេះថា ឯវមិច្ចាទិបាឋស្ស អត្ថំ ឆានប្បការតោ សេចក្ដីនៃបាឋៈថា ឯវំ ជាដើម ដោយប្រការផ្សេងៗ ឥឡូវនេះ សូមអធិប្បាយដូច្នេះ ស័ព្ទថា ឯវំ នេះ គប្បីយល់ថា ប្រើក្នុងអត្ថទាំងឡាយមានជាដើមថា ***សេចក្ដីប្រៀបធៀប សេចក្ដីណែនាំ សេចក្ដីលើកតម្កើង សេចក្ដីតិះដៀល ការទទួលពាក្យ អាការៈ ការពន្យល់ ការហាមសេចក្ដីដទៃ*** ។ ពិតដូច្នោះ ឯវំ ស័ព្ទនេះ ប្រើក្នុង***សេចក្ដីប្រៀបធៀប*** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា "ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ កុសលដែលសត្វកើតមកហើយ គួរធ្វើឱ្យច្រើនយ៉ាងនោះ"(១) ។ ប្រើក្នុង***សេចក្ដីណែនាំ*** ដូចក្នុងប្រយោគជាដើមថា "ឯវន្តេ អភិក្កមិតព្វំ ឯវន្តេ បដិគមិតព្វំ អ្នកត្រូវឈានដើរទៅមុខយ៉ាងនេះ អ្នកត្រូវថយក្រោយយ៉ាងនេះ"(២) ។ ប្រើក្នុង***សេចក្ដីសរសើរ*** ដូចក្នុងប្រយោគជាដើមថា " ឯវមេតំ ភគវា ឯវមេតំ សុគត បពិត្រព្រះដ៏មានព្រះភាគ ហេតុនុ៎ះយ៉ាងនេះឯង បពិត្រព្រះសុគត ហេតុនុ៎ះយ៉ាងនេះ "(៣) ។ ប្រើក្នុង***សេចក្ដីតិះដៀល*** ដូចក្នុងប្រយោគជាដើមថា " ឯវមេវំ បនាយំ វសលី យស្មឹ វា តស្ស មុណ្ឌកស្ស សមណកស្ស វណ្ណំ ភាសតិ ។ មេចង្រៃនេះ ធ្លាប់តែអញ្ចឹង ហ៊ានពោលសរសើរសមណៈត្រងោល ក្នុងទីផ្ទស

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៣២ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត លេខ ៤២ ទំព័រ ៣១០ ។

៣-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៤១ ទំព័រ ២២៧ ។

ផ្កាស ”[១] ។ ប្រើក្នុង**ការទទួលពាក្យ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ”[២] ។ ប្រើក្នុង**អាការៈ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “ ឯវំ ព្យា ខោ អហំ អាវុសោ[៣] ភគវតា ធម្មំ ទេសិតំ អាជានាមិ ម្នាលអាវុសោទាំងឡាយ ខ្ញុំក៏បានដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសម្តែងហើយយ៉ាងនោះឯង”[៤] ។ ប្រើក្នុង**ការពន្យល់** ដូចក្នុងប្រយោគជាដើមថា “ឯហិ ត្វំ មាណវក យេន សមណោ អានន្ទោ តេនុបសង្កម ឧបសង្កមិត្វា មម វចនេន សមណំ អានន្ទំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ សុភោ មាណវោ តោទេយ្យបុត្តោ ភវន្តំ អានន្ទំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ ឯវញ្ច វទេហិ សាធុ កិរ ភវំ អានន្ទោ យេន សុភស្ស មាណវស្ស តោទេយ្យបុត្តស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយ ។ ម្នាលមាណព ឯងចូរមកនេះ ឯងចូរទៅរកព្រះសមណៈ ឈ្មោះអានន្ទ លុះចូលទៅដល់ហើយ ចូរសួរនូវអាការៈមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន មានកម្លាំងនៅជាសុខសប្បាយនឹងព្រះសមណៈឈ្មោះ អានន្ទ តាម

---

១-សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ លេខ ៣០ ទំព័រ ៨៤ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក លេខ ២០ ទំព័រ ១ ។

៣-ក្នុងព្រះត្រៃបិដកច្បាប់ឆដ្ឋសង្គាយនា លោកប្រើពាក្យថា ភន្តេ ប៉ុន្តែក្នុងព្រះត្រៃបិដកភាសាខ្មែរ ឃើញ ពាក្យថា អាវុសោ វិញក្នុងទីនេះយកតាមច្បាប់ព្រះត្រៃបិដកភាសាខ្មែរ ។

៤-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក លេខ ២២ ទំព័រ ១៥១ ។

ពាក្យរបស់អញថា សុភមាណពជា កូនរបស់តោទេយ្យព្រាហ្មណ៍ផ្តាំឱ្យសួរនូវអាការៈ មានអាពាធតិច រោគតិច ក្រោកទៅមកបានរហ័សរហួនទឹងកម្លាំង និងអាការៈនៅជាសុខសប្បាយ ចំពោះព្រះអានន្ទដ៏ចម្រើន រួចហើយឯងចូរនិមន្តថា សូមព្រះអានន្ទជាម្ចាស់ អាស្រ័យនូវសេចក្តីអនុគ្រោះនិមន្តមកកាន់ទីលំនៅរបស់សុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ឱ្យទាន”[១] ។ ប្រើក្នុង***ការហាមសេចក្តីជឿ*** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “តំ កឹ មញ្ញថ កាលាមា ឥមេ ធម្មា កុសលា វា អកុសលា វាតិ ។ អកុសលា ភន្តេ ។ សាវជ្ជា វា អនវជ្ជា វាតិ ។ សាវជ្ជា ភន្តេ ។ វិញ្ញុគរហិតា វា វិញ្ញុប្បសត្ថា វាតិ ។ វិញ្ញុគរហិតា ភន្តេ ។ សមត្តា សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តិ នោ វា កថំ វា ឯត្ថ ហោតីតិ ។ សមត្តា ភន្តេ សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តិ ឯវំ នោ ឯត្ថ ហោតីតិ ។ ម្នាលកាលាមក្សត្រ អ្នកសម្គាល់ហេតុនោះដូចម្តេច ធម៌នេះជាកុសល ឬជាអកុសល ។ ជាអកុសល ព្រះអង្គ ។ ជាធម៌ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ ។ ជាធម៌ប្រកបដោយទោស ព្រះអង្គ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ព្រះអង្គ ។ ធម៌ទាំងនេះ ដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ឬមិនប្រព្រឹត្តទៅទេ ឬក៏ក្នុងដំណើរនោះដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះ ដែលបុគ្គលសមាទានបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ យើងខ្ញុំក៏

---

១-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៥ ទំព័រ ១៦០-១៦១ ។

យល់ក្នុងជំណើរនោះ ដូច្នេះដែរ”[១] ។ ប៉ុន្តែក្នុងទីនេះ គប្បីយល់ថា ឯវំ ស័ព្ទ ប្រើក្នុងអត្ថគឺ**អាការៈ ការពន្យល់ និងការហាមសេចក្ដីដទៃ** ។

បណ្ដាអត្ថទាំង ៣ នោះ ព្រះថេរៈសម្ដែងអត្ថនេះ ដោយ ឯវំ ស័ព្ទដែលមានអត្ថជាអាការៈថា ព្រះតម្រាស់របស់ព្រះមានព្រះភាគអង្គនោះ ល្អិតដោយន័យផ្សេងៗកើតឡើងដោយច្រើនអធ្យាស្រ័យសម្បូរដោយអត្ថនិងព្យញ្ជនៈ មានបដិហារិយផ្សេងៗ ជ្រាលជ្រៅដោយធម៌ អត្ថ ទេសនា និងបដិវេធ មានសភាពដ៏សមគួរដល់ភាសារបស់ខ្លួនៗ របស់សព្វសត្វទាំងឡាយ អ្នកណានឹងអាចដឹងបានដោយប្រការទាំងពួង ប៉ុន្តែខ្ញុំសូម្បីប្រើកម្លាំងទាំងអស់ឱ្យកើតការចង់ស្ដាប់ក៏បាន ស្ដាប់មកយ៉ាងនេះ គឺសូម្បីខ្ញុំក៏បានស្ដាប់មកហើយដោយអាការៈម្យ៉ាង ។

ដោយ ឯវំ ស័ព្ទ ដែលមានអត្ថជា**ការពន្យល់** ព្រះថេរៈ កាលនឹងដោះខ្លួនថា ខ្ញុំមិនមែនសយម្ភូ ព្រះសូត្រនេះ ខ្ញុំមិនបានធ្វើឱ្យជាក់ច្បាស់ ទើបសម្ដែងព្រះសូត្រទាំងអស់ ដែលគួរពោលក្នុងឥឡូវនេះថា ឯវម្មេ សុតំ សូម្បីខ្ញុំក៏បានស្ដាប់មកយ៉ាងនេះ ។

ដោយ ឯវំ-ស័ព្ទ ដែលមានស័ព្ទជាការហាមសេចក្ដីដទៃ ព្រះថេរៈកាលសម្ដែងកម្លាំងការចងចាំរបស់ខ្លួនដែលគួរដល់ការៈ ដែលព្រះមានព្រះភាគទ្រង់សរសើរយ៉ាងនេះថា “ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ពហុស្សុតានំ យទិទំ អានន្ទោ គតិមន្តានំ សតិមន្តានំ ធិតិមន្តានំ ឧបដ្ឋាកានំ យទិទំ

១-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៤១ ទំព័រ ២២០-២២១

សម្រាប់ជាធម្មទាន

អានន្ទ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកចេះដឹងច្រើន ដែលជាសាវក របស់តថាគត ស្រេចនឹងអានន្ទ ពួកភិក្ខុអ្នកមានស្មារតី ពួកភិក្ខុអ្នកមានគតិ ពួកភិក្ខុអ្នកមានប្រាជ្ញា ពួកភិក្ខុជាឧបដ្ឋាក ស្រេចនឹងអានន្ទដែរ"[១] រមែងឱ្យកើត ការលំបាកស្ដាប់ដល់សត្វទាំងឡាយ ដោយពោលថា ខ្ញុំបានស្ដាប់មកហើយ យ៉ាងនេះពាក្យនោះ មិនខ្វះ មិនលើស មិនពោលដោយអត្ថ ឬព្យញ្ជនៈ បណ្ឌិត គប្បីយល់យ៉ាងនេះប៉ុណ្ណោះ មិនគប្បីយល់យ៉ាងដទៃ ។

**កែបទថា មេ**

មេ-ស័ព្ទ ជួបនៅក្នុងសេចក្ដី ៣ យ៉ាង ។ ពិតដូច្នោះ មេ-ស័ព្ទ មាន សេចក្ដីថា មយា គឺខ្ញុំ ដូចក្នុងប្រយោគជាដើមថា "គាថាភិគីតម្មេ អភោ-ជនេយ្យំ ភោជន គឺតថាគតពោលហើយដោយគាថា ជាវត្ថុមិនគួរដល់ការ បរិភោគទេ"[២]។ មានសេចក្ដីថា មយ្ហំ ដល់ខ្ញុំ ដូចក្នុងប្រយោគជាដើមថា "សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ សូមអង្វរ សូមព្រះមានព្រះភាគសម្ដែងធម៌ដោយសង្ខេប ប្រោស(ដល់)ខ្ញុំព្រះអង្គ ផងចុះ"[៣] ។ មានសេចក្ដីថា មម របស់ខ្ញុំ ដូចក្នុងប្រយោគជាដើមថា "ធម្ម-ទាយាទា មេ ភិក្ខវេ ភវថ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកធម៌

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ៤០ ទំព័រ ៥៥ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ២៩ ។

៣-សុត្តន្តបិដក មជ្ឈិមនិកាយ សឡាយតនវគ្គ លេខ ៣៥ ទំព័រ ១៤០ ។

របស់តថាគតជាមតិក"[១] ។ តែក្នុងទីនេះ មេ-ស័ព្ទ រមែងត្រឹមត្រូវក្នុងសេចក្តីទាំង ២ គឺ មេ សុតំ គឺខ្ញុំស្តាប់មក មម សុតំ ការស្តាប់របស់ខ្ញុំ ។

**កែបទថា សុតំ**

***សុត***-ស័ព្ទនេះ មានឧបសគ្គ និងមិនមានឧបសគ្គ ផ្សេងគ្នាដោយសេចក្តីទាំងឡាយ ដូចមានសេចក្តីថា ***ទៅ ច្បាស់ តម្រេក សន្សំ ខ្វល់ខ្វាយ*** សម្តែងដែលដឹងតាមសោតៈ ហើយដឹងតាមសោតទ្វារជាដើម ។ ពិតដូច្នោះ ***សុត***-ស័ព្ទនោះ សេចក្តីថា ***ទៅ*** ដូចក្នុងប្រយោគជាដើមថា" សេនាយ បសុតោ បញ្ជូនទ័ពទៅ" ។ សេចក្តីថា ***ច្បាស់*** ដូចក្នុងប្រយោគជាដើមថា " សុតធម្មស្ស បស្សតោ (វិវេក) របស់បុគ្គលអ្នកមានធម៌ស្តាប់ហើយ បានឃើញច្បាស់ហើយ(ញាណចក្ខុ)"[២] ។ សេចក្តីថា ***តម្រេក*** ដូចក្នុងប្រយោគ ជាដើមថា "អវស្សុតា អវស្សុតស្ស ភិក្ខុនី មានតម្រេកត្រេកអរ ការដែលបុរស មានតម្រេកមកស្ទាបអង្អែលកាយ"[៣] ។ សេចក្តីថា ***សន្សំ*** ដូចក្នុងប្រយោគជាដើមថា "តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ បុណ្យឈ្មោះថា បានសន្សំទុក មិនមែនតិចឡើយផង"[៤] ។ សេចក្តីថា ***ខ្វល់ខ្វាយ*** ដូចក្នុងប្រយោគជាដើមថា "យេ ឈានប្បសុតា ធីរា អ្នកប្រាជ្ញទាំងឡាយណា

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក លេខ ២០ ទំព័រ ៣៩ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ឧទាន លេខ ៥២ ទំព័រ ១៣៤ ។

៣-វិនយបិដក ភិក្ខុនីវិភង្គ លេខ ៥ ទំព័រ ៨ ។

៤-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៥ ។

ជាអ្នកខ្វល់ខ្វាយក្នុងឈាន”[១] ។ សេចក្តីថា **សាម្ញេនដែលដឹងបានតាមសោតៈ** ដូចក្នុងប្រយោគជាដើមថា“ទិដ្ឋំ សុតំ មុតំ រូបបានឃើញ សំឡេងបានឮ អារម្មណ៍បានដឹង”[២] ។ សេចក្តីថា **ដឹងបានតាមសោតទ្វារ** ដូចក្នុងប្រយោគជាដើមថា “ សុតធរោ សុតសន្និចយោ ទ្រទ្រង់នូវពុទ្ធវចនៈ នូវពុទ្ធវចនៈនេះ”[៣] ។ តែក្នុងទីនេះ ស័ព្ទថា **សុតៈ** សេចក្តីថាចូលទៅទ្រទ្រង់ទុក ឬការចងចាំដោយវិថីវិញ្ញាណដែលមានសោតវិញ្ញាណជាប្រធាន ។ ក្នុងពាក្យនោះ កាលណា មេ-ស័ព្ទ មានសេចក្តីថា មយា គឺខ្ញុំ កាលនោះ ការប្រកបសេចក្តី គឺខ្ញុំស្តាប់មកហើយ គឺចងចាំបានដោយវិថីវិញ្ញាណ ដែលមានសោតវិញ្ញាណជាប្រធានយ៉ាងនេះ ។ កាលណា មេ-ស័ព្ទ មានសេចក្តីថា មម របស់ខ្ញុំ កាលនោះ ការប្រកបសេចក្តីថា ការស្តាប់របស់ខ្ញុំ គឺការចងចាំបាន ដោយវិថីវិញ្ញាណដែលមានសោតវិញ្ញាណជាប្រធាន ។

បណ្តាបទទាំង ៣ ពួកនោះ ដូចសេចក្តីពណ៌នាមកនេះ បទថា ឯវំ ជាបទពន្យល់ដល់កិច្ច គឺនាទីរបស់សោតវិញ្ញាណ ។ បទថា មេ ជាបទពន្យល់ បុគ្គលដែលប្រកបដោយសោតវិញ្ញាណ ដែលពោលហើយ ។ បទថា សុតំ ជាបទពន្យល់ដល់ការកាន់យកមិនខ្វះ មិនលើស មិនវិបរិត ព្រោះបដិសេធការមិនបានស្តាប់ ។

ន័យម្យ៉ាងទៀត បទថា ឯវំ ជាបទសម្តែងដល់ភាវៈដែលមានចិត្តគិត និង

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទ លេខ ៥២ ទំព័រ៦១

២-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តក លេខ ៥៣ ទំព័រ ១៥៤ ។

៣-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក លេខ ២២ ទំព័រ ២១ ។

ស្តាប់ជាដើម ប្រព្រឹត្តទៅក្នុងអារម្មណ៍ដោយប្រការផ្សេងៗ ។ បទថា មេ ជាបទសម្តែងដល់ខ្លួន ។ បទថា សុតំជាបទសម្តែងដល់ធម៌ ។

ន័យម្យ៉ាងទៀត បទថា ឯវំ ជាបទពន្យល់ធម៌ដែលគួរពន្យល់ ។ បទថា មេ ជាបទពន្យល់ដល់បុគ្គល ។ បទថា សុតំ ជាបទពន្យល់កិច្ច គឺនាទីរបស់តួបុគ្គល ។

ន័យម្យ៉ាងទៀត ស័ព្ទថា ឯវំ អធិប្បាយដល់ប្រការផ្សេងៗ របស់វិថីចិត្តទាំងឡាយដែលជាអាការបញ្ញត្ត ។ ស័ព្ទថា មេ អធិប្បាយដល់តួអ្នកធ្វើ ។ ស័ព្ទថា សុតំ អធិប្បាយដល់វិស័យ ។

ន័យម្យ៉ាងទៀត ស័ព្ទថា ឯវំ អធិប្បាយដល់កិច្ចនាទីរបស់បុគ្គល ។ ស័ព្ទថា សុតំ អធិប្បាយដល់កិច្ចនាទីរបស់វិញ្ញាណ ។ ស័ព្ទថា មេ អធិប្បាយថា ដល់បុគ្គល គួរដល់កិច្ចទាំងពីរ ។

ន័យម្យ៉ាងទៀត ស័ព្ទថា ឯវំ សម្តែងដល់ការៈ ។ ស័ព្ទថា មេ សម្តែងដល់បុគ្គល ។ ស័ព្ទថា សុតំ សម្តែងដល់កិច្ចរបស់បុគ្គលនោះ ។

បណ្តាបទទាំងនោះ បទថា ឯវំ ហើយនឹង មេ ជាអវិជ្ជមានបញ្ញត្តិ ដោយមានសច្ចិកត្ថបរមត្ថ ។ បទថា សុតំ ជាវិជ្ជមានបញ្ញត្តិ ។

ន័យម្យ៉ាងទៀត បទថា ឯវំ នឹង មេ ឈ្មោះថា ឧបាទាបញ្ញត្តិ ព្រោះពោលអាស្រ័យអារម្មណ៍នោះៗ ។ បទថា សុតំ ឈ្មោះថា ឧបនិធាបញ្ញត្តិ ព្រោះពោលអាងអារម្មណ៍ដែលឃើញហើយជាដើម ។

ក៏ក្នុងបទទាំង ៣ នោះ ព្រះថេរៈ សម្តែងមិនភ្លេចភ្លាំង ដោយបទថា ឯវំ ។ ការមិនភ្លេចភ្លាំងរឿងដែលស្តាប់មកហើយ ដោយបទថា សុតំ ម្យ៉ាងទៀត ព្រះថេរៈ សម្តែងការយកចិត្តទុកដាក់ដោយឧបាយត្រូវទំនង ដោយបទថា ឯវំ ព្រោះមិនមានការចាក់ធ្លុះដោយប្រការផ្សេងៗសម្រាប់អ្នកដាក់ចិត្ត ដោយមិនត្រូវទំនង ។ សម្តែងការមិនរាយមាយដោយបទថា សុតំ ព្រោះមិនមានការស្តាប់សម្រាប់អ្នកមានចិត្តរាយមាយ ។ ពិតដូច្នោះមែន បុគ្គលដែលមានចិត្តរាយមាយ សូម្បីលោកពោលគ្រប់យ៉ាង ក៏ពោលថា ខ្ញុំមិនបានឮ សូមនិយាយម្តងទៀត ។ ក៏ក្នុងសេចក្តីនេះ បុគ្គលឱ្យសម្រេចការតម្កល់ខ្លួនទុកដោយប្រពៃហើយ ភាពជាអ្នក ធ្វើបុណ្យទុកពីមុន ក៏ដោយការយកចិត្តទុកដាក់ដោយឧបាយត្រូវទំនងឱ្យសម្រេចការស្តាប់ធម៌របស់សប្បុរស និងការពឹងអាស្រ័យសប្បុរស ក៏ដោយការមិនរាយមា ។ ព្រះថេរៈសម្តែងការដល់ព្រមដោយចក្រធម៌ ២ សេចក្តីខាងក្រោយរបស់ខ្លួនដោយអាការៈដ៏ល្អដោយបទថា ឯវំ នេះ សម្តែងការដល់ព្រមដោយចក្រធម៌ ២ ខាងដើម ដោយការព្យាយាមស្តាប់ ដោយបទថា សុតំ ។ ម្យ៉ាងទៀត ព្រះថេរៈសម្តែងការបរិសុទ្ធនៃអជ្ឈាស្រ័យ និងការបរិសុទ្ធនៃសេចក្តីព្យាយាមយ៉ាងនោះ គឺសម្តែងការឆ្លាតក្នុងអធិគម ដោយការបរិសុទ្ធនៃអជ្ឈាស្រ័យ ទាំងសម្តែងការឆ្លាតក្នុងបរិយត្តិ ដោយសេចក្តីបរិសុទ្ធនៃសេចក្តីព្យាយាម ។

ម្យ៉ាងទៀត ព្រះថេរៈសម្តែងការដល់ព្រមដោយអត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទារបស់ខ្លួន ដោយពាក្យដែលសម្តែងបដិវេធមានប្រការផ្សេងៗ ដោយបទថា ឯវំ នេះ ។ សម្តែងការដល់ព្រមដោយធម្មប្បដិសម្ភិទា

និងនិរុត្តិប្បដិសម្ភិទាដោយពាក្យដែលសម្តែងបដិវេធ ដែលផ្សេងដោយសេចក្តីដែលគួរស្តាប់ដោយបទថា សុតំ នេះ ។ ម្យ៉ាងទៀត ព្រះថេរៈ កាលពោលពាក្យដែលសម្តែងដល់ការយកចិត្តទុកដាក់ដោយឧបាយត្រូវទំនងនេះ ក៏ប្រកាសឱ្យគេដឹងថាធម៌ទាំងនេះខ្ញុំសម្លឹងដោយចិត្ត ហើយដឹងធ្លុះធ្លាយដោយល្អដោយទិដ្ឋិដោយបទថា ឯវំ ។ កាលពោលពាក្យដែលសម្តែងដល់សេចក្តីព្យាយាមស្តាប់នេះ ក៏ប្រកាសឱ្យគេដឹងថា ធម៌ជាច្រើនខ្ញុំស្តាប់ហើយ ចងចាំហើយ ស្ទាត់មាត់ហើយ ដោយបទថា សុតំ ។ កាលសម្តែងសេចក្តីបរិបូណ៌នៃអត្ថ និងព្យញ្ជនៈ ឱ្យកើតការអើពើដែលនិងស្តាប់សូម្បីដោយពាក្យទាំង ២ នេះ ។

ម្យ៉ាងទៀត ព្រះអានន្ទដ៏មានអាយុ មិនញ៉ាំញីនូវធម៌ដែលព្រះតថាគតទ្រង់ប្រកាសហើយដើម្បីខ្លួន កន្លងនូវភូមិរបស់អសប្បុរស ដឹងខ្លួនថាជាសាវ័កទើបចុះកាន់ភូមិរបស់សប្បុរស ដោយពាក្យសូម្បីទាំងអស់ថា ឯវំ មេ សុតំ នេះ ។ ម្យ៉ាងទៀត ព្រះថេរៈឈ្មោះថា លើកចិត្តឡើងចាកអសទ្ធម្ម តាំងចិត្តទុកក្នុងព្រះសទ្ធម្ម ។ ម្យ៉ាងទៀត កាលសម្តែងថា ព្រះតម្រាស់របស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ខ្ញុំស្តាប់មកហើយតែម្យ៉ាង ឈ្មោះថា ដោះខ្លួនអាងព្រះសាស្តា អែបព្រះពុទ្ធវចនៈ តាំងការប្រៀបធៀបតាមបែបជាធម៌ទុក ។

ម្យ៉ាងទៀត ព្រះថេរៈ មិនព្រមទទួលបទថា ឯវំ មេ សុតំ ខ្លួនធ្វើឱ្យកើតឡើង កាលកើតការស្តាប់មកមុន អ្នកណាទើបគួរជ្រាបថា ឈ្មោះថា ទម្លាយការមិនជឿ ធ្វើឱ្យកើតសទ្ធាសម្បទា ការដល់ព្រមដោយការជឿក្នុងព្រះធម៌នេះ ដល់

ពួកនេះ ដល់ពួកទេវតានឹងមនុស្សថា ព្រះតម្រាស់នេះ ខ្ញុំទទួលមកពីព្រះភក្ត្រ របស់ព្រះមានព្រះភាគអង្គនោះ អ្នកក្លាវក្លាដោយចតុវេសារជ្ជញ្ញាណ ទ្រទ្រង់កម្លាំង ១០ ដែលតាំងនៅក្នុងតំណែងខ្ពស់បំផុត ដែលបន្លឺសីហនាទ ដែលទ្រង់កំពូលជាងសត្វទាំងពួង ទ្រង់ជាធំក្នុងធម៌ ទ្រង់ជាធម្មរាជ ជាអធិបតីនៃធម៌ ទ្រង់មានធម៌ជាទីពឹងអាស្រ័យ ទ្រង់ញ៉ាំងធម្មចក្រដ៏ប្រសើរ គឺព្រះសទ្ធម្មឱ្យប្រព្រឹត្តទៅ ទ្រង់ជាព្រះសម្មាសម្ពុទ្ធត្រាស់ដឹងដោយព្រះអង្គឯង ក្នុងពុទ្ធតម្រាស់នោះមិនគួរធ្វើសេចក្តីសង្ស័យក្នុងអត្ថ ឬធម៌ បទ ឬព្យញ្ជនៈឡើយ ។ ក៏ក្នុងសេចក្តីនោះមានពាក្យពោលថា ៖

វិនាសយតិ អស្សទ្ធិយំ សទ្ធំ វឌ្ឍេតិ សាសនេ
ឯវម្មេ សុតមិច្ចេវំ វទំ គោតមសាវកោ។

(ព្រះអានន្ទ) ជាសាវ័ករបស់ព្រះគោតមបរមសម្ពុទ្ធ កាលពោលពាក្យថា ឯវម្មេ សុតំ ឈ្មោះថា ទម្លាយអសទ្ធិយ (ការមិនជឿ ) ញ៉ាំងសទ្ធា (ការជឿ)ឱ្យចម្រើនឡើងក្នុងព្រះសាសនា ។

**អែអត្ថនៃបទ ឯកំ និងសមយំ**

ស័ព្ទថា ឯកំ សម្តែងការកំណត់ចំនួន ។ ស័ព្ទថា សមយំ សម្តែងកាលកំណត់ ។ ពីរបទថា ឯកំសមយំ សម្តែងកាលមិនពិតប្រាកដ ។ ក្នុងបទ **សមយ** ស័ព្ទនោះ មានសេចក្តីថា

សមវាយេ ខណេ កាលេ សមូហេ ហេតុទិដ្ឋិសុ
បដិលាភេ បហានេ ច បដិវេធេ ច ទិស្សតិ ។

***(ស័ព្ទថា សមយៈ) រមែងបំភ្លឺក្នុងបទថា ព្រមព្រៀង ខណៈ***
***កាល ប្រជុំ ហេតុ លទ្ធិ បានចំពោះ លះបង់ និងចាក់ធ្លុះ ។***

*ពិតដូច្នោះ* ***សមយ****-ស័ព្ទនោះ សេចក្តីថា* ***ព្រមព្រៀង*** *ដូចក្នុងប្រយោគមានជាដើមថា* “អប្បេវ នាម ស្វេបិ ឧបសង្កមេយ្យាម កាលញ្ច សមយញ្ច ឧទាយ *បើដូច្នោះចាំយើងពិចារណានូវកាល និងការព្រមព្រៀងសិនហើយសឹមទៅក្នុងថ្ងៃស្អែក*”[1] ។ *សេចក្តីថា* ***ខណៈ*** *ដូចក្នុងប្រយោគជាដើមថា* “ឯកោ វ ខោ ភិក្ខវេ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ *ម្នាលភិក្ខុទាំងឡាយ ខណៈ នងសម័យនៃការនៅប្រព្រឹត្តព្រហ្មចារ្យមានតែមួយ*”[2] ។ *សេចក្តីថា* ***កាល*** *ដូចក្នុងប្រយោគជាដើមថា* ឧណ្ហសមយោ បរិឡាហសមយោ *កាលក្តៅ កាលក្រវល់ក្រវាយ ។ សេចក្តីថា* ***ប្រជុំ*** *ដូចក្នុងប្រយោគជាដើមថា* មហាសមយោ បវនស្មិំ *ការប្រជុំធំក្នុងព្រៃធំ ។ សេចក្តីថា* ***ហេតុ*** *ដូចក្នុងប្រយោគជាដើមថា* “សមយោបិ ខោ តេ ភទ្ទាលិ អប្បដិវិទ្ធោ អហោសិ ភគវា ខោ សាវត្ថិយំ វិហរតិ ភគវាបិ មំ ជានិស្សតិ ភទ្ទាលិ នាម ភិក្ខុ សត្ថុ សាសនេ សិក្ខាយ

---

*១-សុត្តន្តបិដក ទីឃនិកាយ លេខ ១៥ ទំព័រ ១៦២ ។*

*២-សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត លេខ ៤៨ ទំព័រ ១៤១ ។*

អបរិបូរការីតិ អយម្បិ ខោ តេ ភទ្ទាលិ សមយោ អប្បដិវិទ្ធោ អហោសិ ។ ម្នាលភទ្ទាលិ អ្នកមិនបានដឹងហេតុថា ព្រះមានព្រះភាគគង់នៅក្នុងក្រុងសាវត្ថី តែព្រះមានព្រះភាគគង់ដឹងអាត្មាអញថាភិក្ខុឈ្មោះភទ្ទាលិ មិនបានបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តា ដូច្នេះឡើយ ម្នាលភទ្ទាលិ នេះឯងជាហេតុដែលអ្នកមិនបានដឹង”[១] ។ សេចក្តីថា **លទ្ធិ** ដូចក្នុងប្រយោគជាដើមថា “តេន ខោ បន សមយេន ឧគ្គាហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ សមយប្ប-វាទកេ តិណ្ឌុកាចីរេ ឯកសាលកេ មល្លិកាយ អារាមេ បដិវសតិ ។ សម័យនោះឯង បរិព្វាជកឈ្មោះ ឧគ្គាហមានៈ ជាសមណមុណ្ឌិកាបុត្រ អាស្រ័យនៅក្នុងអារាម របស់ព្រះនាងមល្លិកាទេវី ដែលមានសាលាមួយ មានជួរដើមទន្លាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវ**លទ្ធិ**”[២] ។ សេចក្តីថា **បានចំពោះ** ដូចក្នុងប្រយោគជាដើម ថា “ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយិកោ អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ ។ អ្នកមានប្រាជ្ញាព្រោះបានចំពោះប្រយោជន៍ទាំង ២ គឺ ប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ទើបលោកហៅថា បណ្ឌិត”[៣] ។ សេចក្តីថា **លះបង់** ដូចក្នុងប្រយោគជាដើម ថា

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក លេខ ២៣ ទំព័រ ២៨០ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក លេខ ២៤ ទំព័រ ១៨៨ ។

៣-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ លេខ ៥៣ ទំព័រ ២៣ ។

សម្មាមានាភិសមយា អន្តមកាសិ ទុក្ខស្ស ធ្វើនូវទីបំផុតកងទុក្ខ ព្រោះដោយហេតុ ដែលបានលះបង់នូវមានះចោលដោយប្រពៃ”[១] ។ សេចក្តីថា **ចាក់ដុះ** ដូចក្នុងប្រយោគជាដើមថា “ទុក្ខស្ស បីឡនដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ អភិសមយដ្ឋោ ប្រែថា ទុក្ខ មានអត្ថថាបៀតបៀន មានអត្ថថាបច្ច័យប្រជុំតាក់តែង មានអត្ថថាក្តៅក្រហាយ មានអត្ថថាប្រែប្រួល មានអត្ថថាចាក់ដុះចំពោះ”[២] ។ ប៉ុន្តែក្នុងទីនេះ ***សមយ***-ស័ព្ទនោះ មានសេចក្តីថា ***កាល*** ។ ព្រោះហេតុនោះ ព្រះថេរៈ ទើបសម្តែងថា ឯកំ សមយំ សម័យមួយ បណ្តាសម័យទាំងឡាយ ដែលហៅថា កាលជាដើមថា ឆ្នាំ រដូវ ខែ កន្លះខែ យប់ ថ្ងៃព្រឹក ថ្ងៃត្រង់ ល្ងាច បឋមយាម មជ្ឈិមយាម បច្ចិមយាម និងមួយស្របក់ ។

លោកអធិប្បាយថា សម័យរបស់ព្រះមានព្រះភាគនេះឯណា ដែលហៅថា កាល មានច្រើន ដែលប្រាកដយ៉ាងក្រៃលែងក្នុងពួកទេវតា និងមនុស្សជាដើម យ៉ាងនេះគឺ សម័យយាងចុះកាន់គភ៌ សម័យប្រសូត សម័យទ្រង់សង្វេគ សម័យយាងចេញសាងព្រះផ្នួស សម័យទ្រង់ធ្វើទុក្ករកិរិយា សម័យទ្រង់ឈ្នះមារ សម័យត្រាស់ដឹង សម័យប្រថាប់នៅជាសុខក្នុងបច្ចុប្បន្ន សម័យទេសនា សម័យបរិនិព្វាន ។ បណ្តាសម័យទាំងនោះ ព្រះថេរៈសម្តែងសម័យមួយ ពោល

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២០ ទំព័រ ៣៨ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៧១ ទំព័រ ៤៩ ។

គឺសម័យទេសនា ។

លោកអធិប្បាយថា បណ្ដាសម័យទ្រង់ធ្វើកិច្ចដោយព្រះញាណ និងព្រះករុណា យកសម័យទ្រង់ធ្វើកិច្ចដោយព្រះករុណា បណ្ដាសម័យទ្រង់បដិបត្តិដើម្បីប្រយោជន៍ដល់ព្រះអង្គ និងអ្នកដទៃ យកសម័យទ្រង់បដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ បណ្ដាសម័យទ្រង់បដិបត្តិករណីយកិច្ចទាំងពីរដល់បរិស័ទដែលប្រជុំគ្នា យកសម័យទ្រង់ពោលធម្មីកថា បណ្ដាសម័យទេសនា និងបដិបត្តិ យកសម័យទេសនា សូម្បីបណ្ដាសម័យទាំងនោះ ព្រះថេរៈ សម្ដែងថា ឯកំ សមយំ សម័យមួយ សំដៅយកសម័យណាមួយ ។

ក្នុងសេចក្ដីនេះ អ្នកសួរពោលថា ក៏ព្រោះហេតុអ្វី ក្នុងសូត្រនេះ លោកទើបធ្វើនិទ្ទេសជាទុតិយាវិភត្តិ មិនធ្វើដូចក្នុងអភិធម្មដែលធ្វើនិទ្ទេសសត្តមីវិភត្តិថា យស្មឹ សមយេ កាមាវចរំ ក្នុងសុត្តបទដទៃក្រៅពីអភិធម្មនេះថា យស្មឹ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ ដូចក្នុងវិន័យធ្វើនិទ្ទេសជាតតិយាវិភត្តិថា តេន សមយេន ពុទ្ធោ ភគវា សូមពោលពន្យល់ដូច្នេះ ព្រោះក្នុងព្រះអភិធម្ម និងព្រះវិន័យនោះ **សមយ**-ស័ព្ទ មានអត្ថយ៉ាងនោះ ចំណែកក្នុងព្រះសូត្រនេះ មានអត្ថយ៉ាងដទៃ ។ សេចក្ដីពិត បណ្ដាបិដកទាំង ៣ នោះ ក្នុងអភិធម្មបិដក **សមយ**-ស័ព្ទ មានអត្ថថា កំណត់ភាវៈ ។ មែនពិត អធិករណៈ ក៏គឺ **សមយ**-ស័ព្ទ ដែលមានសេចក្ដីថា កាល និងមានសេចក្ដីថា ប្រជុំ និងភាវៈនៃធម៌មានផស្សៈជាដើម នោះកំណត់ទុកបាន ដោយភាវៈនៃសម័យ គឺខណៈ សេចក្ដីព្រមព្រៀង និងហេតុនៃធម៌ទាំងឡាយ

មានផស្សៈជាដើម ដែលពោលហើយក្នុងអភិធម្មបិដក និងសុត្តបទដទៃនោះ ព្រោះហេតុដូច្នោះ ទើបលោកធ្វើនិទ្ទេសជាសត្តមីវិភត្តិ ក្នុងអភិធម្មបិដកនោះ ដើម្បីបំភ្លឺសេចក្តីនោះ ។

ចំណែកក្នុងវិន័យបិដក **សមយ**-ស័ព្ទ មានសេចក្តីថា ហេតុ មានសេចក្តីថា ករណៈ ។ មែនពិត សម័យទ្រង់បញ្ញត្តសិក្ខាបទនោះឯណា សូម្បីព្រះថេរៈមានព្រះសារីបុត្តជាដើម ដឹងបានដោយលំបាកដោយសម័យនោះជាហេតុ ហើយជាករណៈ ព្រះមានព្រះភាគកាលទ្រង់បញ្ញត្តសិក្ខាបទទាំងឡាយ ក៏ទ្រង់សម្លឹងដល់ហេតុនៃការបញ្ញត្តសិក្ខាបទ ទើបទ្រង់ប្រថាប់នៅក្នុងទីនោះៗ ព្រោះហេតុនោះ លោកទើបធ្វើនិទ្ទេសជាតតិយាវិភត្តិទុកក្នុងវិន័យបិដកនោះ ដើម្បីបំភ្លឺសេចក្តីនោះ ។

ចំណែកក្នុងសូត្រនេះ និងក្នុងបាឋៈនៃសុត្តន្តបិដក ដែលមានកំណើតយ៉ាងនេះដទៃៗ អំពី**សមយ**-ស័ព្ទ ដែលមានអត្ថថា អច្ចន្តសំយោគ គឺ ទុតិយា-វិភត្តិដែលប្រែថា អស់ ។ មែនពិត ព្រះមានព្រះភាគទ្រង់សម្តែងសូត្រនេះ ឬសូត្រដទៃអស់សម័យណា ក៏ប្រថាប់នៅដោយករុណាវិហារ គឺអស់សម័យនោះ ព្រោះហេតុដូច្នោះ **សមយ**-ស័ព្ទទើបគួរជ្រាបថា លោកធ្វើនិទ្ទេស ជាទុតិយាវិភត្តិទុកក្នុងសូត្រនេះ ក៏ដើម្បីបំភ្លឺសេចក្តីនោះ ។

ក្នុងសេចក្តីនេះ មានពាក្យពោលថា តំ តំ អត្ថមបេក្ខិត្វា ភុម្មេន ករណេន ច អញ្ញត្រ សមយោ វុត្តោ ឧបយោគេន សោ ឥធ ។ លោកពិចារណាអត្ថនោះៗ ពោល**សមយ**-ស័ព្ទ ក្នុងបិដកផ្សេងពីសត្តមីវិភត្តិ និងតតិយាវិភត្តិ តែក្នុងសុត្តន្តបិដកនេះ សម័យនោះលោកពោលដោយទុតិយាវិភត្តិ ។

សម្រាប់ជាធម្មទាន

**អធិប្បាយនៃបទថា** ភគវា

ពាក្យថាភគវា នេះជាពាក្យហៅព្រះមានព្រះភាគនោះ ដែលវិសេសដោយគុណ ជាកំពូលរបស់សត្វ ជាគ្រូហើយគួរគោរពដូចដែលលោកពោលទុកថា ៖

ភគវាតិ វចនំ សេដ្ឋំ ភគវាតិ វចនមុត្តមំ គរុ គារវយុត្តោ សោ ភគវា តេន វុច្ចតិ ។ បទថា ភគវា ជាពាក្យប្រសើរបំផុត បទថា ភគវា ជាពាក្យខ្ពស់បំផុត ព្រះអង្គទ្រង់ជាគ្រូ ហើយគួរដល់ការគោរព ព្រោះហេតុនោះបណ្ឌិតគប្បីហៅថា ភគវា ។

មែនពិត នាមគឺឈ្មោះមាន ៤ គឺអាវត្ថិកៈ ឈ្មោះតាមសម័យ លិង្គិកៈ ឈ្មោះតាមភេទ នេមិត្តកៈ ឈ្មោះតាមគុណ អធិច្ចសមុប្បន្ន ឈ្មោះតាមការបណ្តោយ ។ ឈ្មោះថា អធិច្ចសមុប្បន្ននាម លោកអធិប្បាយថា ជានាមដែលដាក់តាមការពេញចិត្ត ។ បណ្តានាមទាំង ៤ នោះ នាមជាដើមយ៉ាងនេះថា កូនគោ គោហ្វឹក គោការងារឈ្មោះថា **អាវត្ថិកនាម** ។ នាមជាដើមយ៉ាងនេះថា មនុស្សមានឈើច្រត់ (មនុស្សចាស់) មនុស្សមានឆត្រ (ព្រះរាជា) សត្វមានសិរ (ក្ងោក) សត្វមានប្រមោយ (ដំរី) ឈ្មោះថា **លិង្គិកនាម** ។ នាមជាដើមយ៉ាងនេះថា អ្នកមានវិជ្ជា ៣ អ្នកមានអភិញ្ញា ៦ ឈ្មោះថា **នេមិត្តកនាម** ។ នាមជាដើមយ៉ាងនេះថា អ្នកចម្រើនដោយសិរី អ្នកចម្រើនដោយទ្រព្យដែលប្រព្រឹត្តទៅ មិនសម្លឹងន័យ

របស់ពាក្យ ឈ្មោះថា **អធិច្ចសមុប្បន្ននាម**។ ចំណែកនាមថា ភគវា នេះជា នេមិត្តកនាមដោយព្រះគុណ មិនមែនព្រះនាងមហាមាយា ពុទ្ធមាតាដាក់ឱ្យ មិន មែនព្រះបាទសុទ្ធោទនមហារាជ ពុទ្ធបិតាដាក់ឱ្យ មិនមែនព្រះញាតិវង្ស ៨.៤០០០ ព្រះអង្គដាក់ឱ្យ មិនមែនទេវតាពិសេសមានសក្កទេវរាជ សន្តុសិត ជាដើមដាក់ឱ្យ ដូចដែលព្រះសារីបុត្រពោលថា ព្រះនាមថា ភគវា នេះ ព្រះពុទ្ធ មាតាមិនបាន ដាក់ឱ្យទេ ។ល។ ព្រះនាមគឺ ភគវា ជា**សច្ឆិកាបញ្ញត្តិ**[១] ។ ដើម្បីប្រកាសព្រះគុណ ទាំងឡាយ ដែលជាគុណ នេមិត្តកនាម ព្រះសង្គីតិកាចារ្យទាំងឡាយទើបពោល គាថានេះថា ៖

ភគី ភជី ភាគី វិភត្តវា ឥតិ អកាសិ ភគ្គន្តិ គរូតិ ភាគ្យវា
ពហូហិ ញាយេហិ សុភាវិតត្តនោ ភវន្តគោ សោ ភគវាតិ វុច្ចតិ

ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា ភគវា ព្រោះទ្រង់មានភគៈ គឺ ជោគៈ ព្រោះទ្រង់ជាអ្នកសេព (ទីស្ងាត់) ព្រោះទ្រង់មានភាគ (ចំណែកដែលគួរ បានទទួលចតុប្បច្ច័យ ឬមានចំណែកនៃធម៌) ព្រោះទ្រង់ជាអ្នកចែកធម៌ ព្រោះ ទ្រង់ជាអ្នកកាច់បំបាក់នូវបាបធម៌ ព្រោះទ្រង់ជាគ្រូ ព្រោះទ្រង់មានភាគយៈ គឺ បុណ្យ ព្រោះទ្រង់អប់រំព្រះអង្គដោយល្អ ដោយញាយធម៌ជាច្រើន ព្រោះទ្រង់ជា អ្នកដល់ទីបំផុតនៃភព ។

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ លេខ ៦៦ ទំព័រ ៥៥ ។

ក៏សេចក្ដីនៃព្រះគុណបទថា ភគវា នោះគប្បីយល់តាមន័យ ដែលពោលមកហើយក្នុងនិទ្ទេសជាដើមនោះឯង ។

ម្យ៉ាងទៀត បរិយាយដទៃទៀតមានដូច្នេះ

ភាគ្យវា ភគ្គវា យុត្តោ ភគេហិ ច វិភត្តវា
ភត្តវា វន្តគមនោ ភវេសុ ភគវា តតោ ។

ព្រះអង្គទ្រង់មានបុណ្យ ទ្រង់កាច់បំបាក់នូវកិលេស ទ្រង់ប្រកបដោយភគធម៌ ទ្រង់សេពធម៌ ទ្រង់ខ្ជាក់កិលេសជាហេតុទៅក្នុងភពទាំងឡាយបានហើយ ព្រោះហេតុដូច្នោះ ទើបទ្រង់ព្រះនាមថា ភគវា ។

បណ្ដាបទទាំងនោះ គប្បីជ្រាបថា លោកកាន់យកលក្ខណៈនៃនិរុត្តិ-សាស្ត្រ ដូច្នេះថា ចុះអក្សរថ្មី ផ្លាស់អក្សរជាដើម ឬកាន់យកលក្ខណៈការរួបរួមចូលក្នុងស័ព្ទមាន **បិសោទរ**-ស័ព្ទជាដើម តាមន័យនៃសទ្ទសាស្ត្រ កាលគួរហៅថា ព្រះភាគ្យវា ព្រោះព្រះអង្គមានភាគយៈ គឺបុញ្ញបារមី មានទាន និងសីលជាដើម ដ៏កំពូលដែលឱ្យកើតសេចក្ដីសុខទាំងលោកិយៈ និងលោកុត្តរៈ តែក៏ហៅថា ភគវា ។

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះអង្គទ្រង់កាច់បំបាក់កិលេស ដែលធ្វើការខ្វល់ខ្វាយ ក្ដៅផ្សាពប់សែនប្រភេទ គឺប្រភេទ លោភៈ ទោសៈ មោហៈ វិបរិត្តមនសិការ អហិរិកៈ អនោត្តប្បៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ តណ្ហា

អវិជ្ជា ។ អកុសលមូល ៣ ទុច្ចរិត ៣ សង្កិលេស ៣ មលៈ ៣ វិសមៈ ៣ សញ្ញា ៣ វិតក្កៈ ៣ បបញ្ចធម៌ ៣ ។ វិបរិយេសៈ ៤ អាសវៈ ៤ គន្ថៈ ៤ ឱឃៈ ៤ យោគៈ ៤ អគតិ ៤ តណ្ហុប្បាទ ៤ ។ ចេតោខីលៈ ៥ វិនិពន្ធៈ ៥ នីវរណៈ ៥ អភិនន្ទនៈ ៥ វិវាទមូល ៦ តណ្ហាកាយៈ ៦ អនុសយៈ ៧ មិច្ឆត្តៈ ៨ តណ្ហាមូលកៈ ៩ អកុសលកម្មបថ ១០ ទិដ្ឋិគត ៦២ តណ្ហាវិចរិត ១០៨ ឬ ពោលដោយសង្ខេប គឺមារ ៥ គឺ កិលេសមារ ខន្ធមារ អភិសង្ខារមារ មច្ចុមារ និងទេវបុត្តមារដូច្នោះ សមគួរនឹងហៅថា ភគ្គវា ក៏ហៅថា ភគវា ព្រោះទ្រង់កាច់បំបាក់អន្តរាយទាំងនោះចោលបាន ក្នុងសេចក្តីនេះ លោកពោលទុកថា ៖

ភគ្គរាគោ ភគ្គទោសោ ភគ្គមោហោ អនាសវោ
ភគ្គាស្ស   ចាបកា ធម្មា ភគវា តេន វុច្ចតិ ។

ទ្រង់កាច់បំបាក់រាគៈ កាច់បំបាក់ទោសៈ កាច់បំបាក់មោហៈ មិនមានអាសវៈ ទ្រង់កាច់បំបាក់បាបធម៌បានហើយ ព្រោះហេតុនោះ លោកទើបហៅថា ភគវា ។

ក៏ឯការដល់ព្រមនៃព្រះរូបកាយរបស់ព្រះអង្គ ដែលមានទូវព្រះបុញ្ញលក្ខណៈរាប់រយ គឺលោកសម្តែងដោយភាពដែលទ្រង់មាន **ភាគយៈ** គឺបុណ្យការដល់ព្រមនៃព្រះធម្មកាយ គឺលោកសម្តែងដោយភាវៈដែលទ្រង់កាច់បំបាក់ទោសៈហើយ ។ ភាវៈជាអ្នកដែលមនុស្សលោកនិងអ្នកជិតស្និទ្ធរាប់អានច្រើនក្តី ភាវៈជាអ្នកដែលគ្រហស្ថនិងបព្វជិតទាំងឡាយទៅមករកក្តី ភាវៈជាអ្នកអាចក្នុងការជួយកម្ចាត់ទុក្ខផ្លូវកាយនិងទុក្ខផ្លូវចិត្ត ដល់អ្នកទៅមកក្តី ភាវៈជាអ្នកធ្វើឧបការៈដល់គេ

ដោយអាមិសទាន និងធម្មទានក្តី ភាវៈជាអ្នកអាចក្នុងការប្រកបឱ្យគេទុក ដោយលោកិយសុខ និងលោកុត្តរសុខក្តី លោកសម្តែងដោយគុណពីរយ៉ាងនោះ ។

ម្យ៉ាងទៀត ព្រោះហេតុនោះ **ភគ**-ស័ព្ទ ក្នុងលោកប្រព្រឹត្តទៅក្នុងធម៌ ៦ គឺ ឥស្សរិយៈ ធម្មៈ យសៈ សិរិ កាមៈ បយត្តៈ ។ ក៏ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់មានឥស្សរិយៈ ភាពជាធំក្នុងចិត្តរបស់ព្រះអង្គខ្លួនឯងយ៉ាងក្រៃលែង ឬទ្រង់មានឥស្សរិយបរិបូណ៌ដោយអាការៈគ្រប់យ៉ាង ដែលសន្មតិថា ជាលោកិយៈមាន អណិមាធ្វើខ្លួនឱ្យតូច (សង្ខេប) លឃិមាធ្វើខ្លួនឱ្យស្រាល(ហោះ) ទ្រង់មានលោកុត្តរធម៌ក៏ដូចគ្នា ទ្រង់មានយសបរិសុទ្ធដ៏ក្រៃលែង ទ្រង់បានដោយគុណពិតប្រាកដគ្រប់លោកទាំង ៣ ទ្រង់មានព្រះសិរីដ៏ល្អគ្រប់ស្ថានសួគ៌ទាំងអស់បរិបូណ៌ ដោយអាការៈគ្រប់យ៉ាង ទ្រង់អាចឱ្យកើតសិរីសួស្តីដល់អ្នកខ្វល់ខ្វាយចូលមើលព្រះរូបគោមបាន ទ្រង់មានកាមៈដ៏ច្រើនដល់ការសម្រេចនៃប្រយោជន៍តាមទ្រង់បំណងព្រោះប្រយោជន៍ណាៗ ដែលទ្រង់បំណងហើយប្រាថ្នាហើយ និងជាប្រយោជន៍របស់ខ្លួនក្តី ប្រយោជន៍របស់អ្នកដទៃក៏ដោយប្រយោជន៍នោះ ។ ក៏សម្រេចសមតាមព្រះបំណងទាំងនោះ ហើយទ្រង់មានបយត្តៈ ពោលគឺ សម្មាវាយាមៈ ដែលជាហេតុឱ្យកើតភាពជាគ្រូរបស់លោកទាំងពួងដូច្នោះ ទើបលោកហៅថា ភគវា ដោយអត្ថនេះថា ទ្រង់មានភគ្គធម៌ ព្រោះតាមដែលទ្រង់ប្រកបដោយភគ្គធម៌ទាំងនោះ ។

**កែបទ** វិភត្តវា

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះមានព្រះភាគទ្រង់ជា វិភត្តវា លោកអធិប្បាយថា ទ្រង់ចែក បើកបង្ហាញ សម្តែងនូវធម៌ទាំងពួងដោយប្រភេទមានប្រភេទកុសលជាដើម ឬនូវធម៌មានកុសលធម៌ជាដើម ដោយប្រភេទមាន ខន្ធ អាយតនៈ ធាតុ សច្ចៈ ឥន្ទ្រិយ និងបដិច្ចសមុប្បាទជាដើម ឬនូវទុក្ខអរិយសច្ចៈដោយអត្ថគឺ បីឡនៈ (បៀតបៀន) សង្ខតៈ (បច្ច័យប្រជុំតាក់តែង) សន្តាបៈ (ដុតកម្តៅ) វិបរិណាម (ប្រែប្រួល) នូវសមុទយអរិយសច្ចៈ ដោយអត្ថ គឺអាយូហនៈ (ការប្រមូលទុក្ខមក) និទាន (ហេតុនៃទុក្ខ) សំយោគៈ (ចងទុក្ខជាប់) បលិពោធៈ (ទាញទុកមិនឱ្យដល់មគ្គ) នូវនិរោធអរិយសច្ចៈ ដោយអត្ថគឺ និស្សរណៈ (ចេញចាកទុក្ខ) វិវេកៈ (ស្ងប់ចាកទុក្ខ) អសង្ខតៈ (បច្ច័យមិនបានតាក់តែង) អមតៈ (ភាពមិនស្លាប់) នូវមគ្គអរិយសច្ចៈ ដោយអត្ថគឺនិយ្យានិកៈ (នាំចេញចាកទុក្ខ) ហេតុ (ហេតុនៃនិរោធ) ទស្សនៈ (ឃើញព្រះនិព្វាន) **អធិបតេយ្យ** (ភាពជាធំក្នុងការឃើញព្រះនិព្វាន) ដូច្នោះ កាលគួរនឹងហៅថា វិភត្តវា ប៉ុន្តែក៏ហៅថា ភគវា ។

**កែបទ** ភត្តវា

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះមានព្រះភាគនោះ ទ្រង់គប់រក ទ្រង់សេព ទ្រង់ធ្វើឱ្យច្រើន នូវធម៌ដែលជាទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ នូវកាយ-

វិវេក ចិត្តវិវេក និងឧបធិវិវេក នូវសុញ្ញតវិមោក្ខ អប្បណិហិតវិមោក្ខ និងអនិមិត្ត វិមោក្ខ នូវឧត្តរិមនុស្សធម៌ ទាំងលោកិយៈ និងលោកុត្តរៈដទៃៗដូច្នោះ កាលគួរ និងហៅថា ភគ្គវា ប៉ុន្តែក៏ហៅថា ភគវា ។

**តែបទ** ភវេសុ វន្តគមន

មួយវិញទៀត ព្រោះហេតុនៃការទៅ ពោលគឺតណ្ហាក្នុងភពទាំង ៣ ដែលព្រះអង្គទ្រង់ខ្ជាក់ចោលហើយ ដូច្នោះ កាលគួរនឹងហៅថា ភវេសុ វន្តគមន តែលោកកាន់យក ភ-អក្សរជា ភវ-ស័ព្ទ គ-អក្សរជា គមន-ស័ព្ទ ហើយវ-អក្សរពី វន្ត-ស័ព្ទ ហើយធ្វើឱ្យទីឃៈ ហៅថា ភគវា ដូចក្នុងផ្លូវលោកកាលគួរ និងលោក ថា មេហនស្ស ខស្ស មាលា ប៉ុន្តែអ្នកប្រាជ្ញ (កាន់យក មេ អំពី មេហនស្ស ១ អំពី ខស្ស លា ពី មាលា) ក៏ហៅថា មេខលា ដូច្នោះឯង ។

ក៏ព្រះអានន្ទត្ថេរ កាលសម្ដែងធម៌តាមដែលបានស្ដាប់មក និទានមកទើប ប្រកាសសរីរធម៌ (ខ្លួននៃធម៌) របស់ព្រះមានព្រះភាគឱ្យប្រចក្ស ដោយពាក្យថា ឯវម្មេ សុតំ ក្នុងព្រះសូត្រនេះដោយពាក្យត្រឹមតែប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះថេរៈទើបលួងលោមនូវជនអ្នកមានចិត្តរាយមាយ ព្រោះមិនបានជួបព្រះមាន ព្រះភាគថា បាវចនៈ (គឺព្រះធម្មវិន័យ)នេះ ឈ្មោះថា មានសាស្តាកន្លងទៅហើយ មិនបានឡើយ ធម្មវិន័យនេះជាសាស្ត្រារបស់អ្នកទាំងឡាយ ។

ដោយបទថា ឯកំ សមយំ ភគវា ព្រះថេរៈកាលសម្ដែងសេចក្ដីដែល ព្រះមានព្រះភាគ មិននៅក្នុងសម័យនោះ ឈ្មោះថា សម្ដែងដល់បរិនិព្វាននៃព្រះរូបកាយ ។ ដោយពាក្យនោះ ព្រះថេរៈរមែងញុំាងជនដែលស្រវឹង ព្រោះស្រវឹងក្នុងជីវិតឱ្យស្លុតចិត្ត ហើយញុំាងឧស្សាហ៍ក្នុងធម៌ឱ្យកើតឡើងដល់ជននេះថា ព្រះមានព្រះភាគសូម្បីព្រះអង្គនោះ ដែលទ្រង់សម្ដែងអរិយធម៌នេះយ៉ាងនោះ ទ្រទ្រង់ព្រះទសពលមានព្រះកាយដូចពេជ្រ ក៏នៅតែស្ដេចបរិនិព្វាន ក្នុងសេចក្ដីនោះ មនុស្សដទៃណាគប្បីឱ្យកើតក្ដីសង្ឃឹមក្នុងជីវិតបាន ។

ក៏ព្រះថេរៈកាលពោលថា ឯវំ ឈ្មោះថា សម្ដែងទេសនាសម្បត្តិ ការដល់ព្រមនៃទេសនា កាលពោលបទថា មេ សុតំ ឈ្មោះថា សម្ដែងសាវកសម្បត្តិ ការដល់ព្រមនៃសាវក ។ កាលពោលបទថា ឯកំ សមយំ ឈ្មោះថា សម្ដែងកាលសម្បត្តិ គឺការដល់ព្រមនៃកាល កាលពោលបទថា ភគវា ឈ្មោះថា ទេសកសម្បត្តិ ការដល់ព្រមនៃអ្នកសម្ដែង ។

### កែបទ សាវត្ថិយំ វិហរតិ

ពាក្យថា **សាវត្ថី** ក្នុងបទពាក្យថា សាវត្ថិយំ វិហរតិ នេះ បានដល់នគរដែលជាកន្លែងរស់នៅជាប្រចាំរបស់ឥសីឈ្មោះ **សវត្ថៈ** ដូចបទថា កាកន្ទី មាកន្ទី ដូច្នោះ ដូច្នេះទើបលោកពោលថា **សាវត្ថី** ជាស័ព្ទ ឥត្ថីលិង្គ (ភេទស្រី) អ្នកប្រាជ្ញផ្នែកអក្សរសាស្ត្រពោលយ៉ាងនេះ ។ ចំណែកព្រះអដ្ឋកថាចារ្យទាំង

ឡាយពោលថា គ្រឿងឧបភោគបរិភោគសម្រាប់មនុស្សមានគ្រប់យ៉ាងក្នុងនគរនោះ ព្រោះហេតុនោះ នគរនោះ ទើបឈ្មោះថា **សាវត្ថី** ។ តែក្នុងការប្រកបស័ព្ទ កាលសួរថា មានវត្ថុអ្វីទើបអាស្រ័យពាក្យគ្រប់យ៉ាង ប្រកបថា **សាវត្ថី** ។ តែក្នុងការប្រកបស័ព្ទ កាលសួរថា មានវត្ថុអ្វីទើបអាស្រ័យពាក្យគ្រប់យ៉ាង ប្រកបថា **សាវត្ថី** មានរបស់គ្រប់យ៉ាង ។

គ្រឿងឧបករណ៍គ្រប់យ៉ាង មានព្រមក្នុងក្រុងសាវត្ថី គ្រប់កាល ព្រោះហេតុដូច្នោះ សំដៅដល់របស់គ្រប់យ៉ាង ទើបហៅថា **សាវត្ថី** ។

រាជធានីនៃដែនកោសល គួររីករាយ គួរសរសើរ គួរត្រេកអរ មិនស្ងប់ចាកសំឡេងទាំង ១០ ដល់ព្រមដោយបាយទឹក ។

ក្រុងសាវត្ថីរាជធានី ដល់ការចម្រើនបរិបូណ៌ រុងរឿងគួររីករាយ ដូចក្រុងអាឡកមន្ទាទេវធានីរបស់ពួកទេវតា ដូច្នោះ ។

បទថា **សាវត្ថិយំ** នោះ បទនេះជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ។

បទថា វិហរតិ ជាពាក្យសម្ដែងការដល់ព្រមដោយវិហារ បណ្ដាឥរិយាបថវិហារ ទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ បែបណាមួយ ដោយមិនប្លែកគ្នា ប៉ុន្តែក្នុងព្រះសូត្រនេះ សម្ដែងការប្រកបព្រមដោយឥរិយាបថវិហារ បណ្ដាឥរិយាបថ ផ្សេងដោយការឈរ ដើរ អង្គុយ ដេក ឥរិយាបថមួយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគប្រថាប់ឈរក្ដី ទ្រង់យាងក្ដី ទ្រង់ប្រថាប់គង់ក្ដី ផ្ទុំក្ដី ក៏គប្បីជ្រាបថា វិហរតិ ទាំងនោះ ។ មែនពិត ព្រះមានព្រះភាគនោះ ទ្រង់កាត់ការ

លំបាកនៃឥរិយាបថតែមួយ ដោយឥរិយាបថដទៃទៀត (ផ្លាស់ប្តូរឥរិយាបថ) ទ្រង់បរិហារអត្តភាពឱ្យប្រព្រឹត្តទៅមិនលំបាក ព្រោះដូច្នោះ ទើបលោកហៅថា វិហរតិ ប្រថាប់នៅ ។

**កែបទ** ជេតវនេ

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា ជេតវនេ នេះដូច្នេះ ។ ព្រះរាជកុមារឈ្មោះថា **ជេតៈ** ព្រោះឈ្នះជនដែលជាសត្រូវរបស់ខ្លួន ឬថា **ជេតៈ** ព្រោះប្រសូត កាលព្រះរាជាទ្រង់ឈ្នះជនដែលជាសត្រូវ ឬថា **ជេតៈ** សូម្បីព្រះរាជាទ្រង់សម្រួលព្រះនាមយ៉ាងនេះ ដល់ព្រះរាជកុមារ ព្រោះមានព្រះរាជបំណងនឹងឱ្យជាមង្គល។ ដែលឈ្មោះថា **វនៈ** ព្រោះឱ្យគប់រក អធិប្បាយថា ព្រោះញ៉ាំងភក្តីភាពរបស់សត្វទាំងឡាយឱ្យដល់ខ្លួន ព្រោះការដល់ព្រមនៃខ្លួន ។ ម្យ៉ាងទៀត ឈ្មោះថា **វនៈ** ព្រោះអធិប្បាយថា ម្យ៉ាងទៀតថា អង្វរសូមសត្វទាំងឡាយថា សូមប្រើខ្ញុំមកចុះ ។ វនៈរបស់ជេតរាជកុមារ ឈ្មោះថា **ជេតវន** ។ មែនពិត **ជេតវន** នោះ គឺព្រះរាជ-កុមារព្រះនាមថា **ជេតៈ** ដាំដុះកសាងថែរក្សា ។ ជេតរាជកុមារនោះ ជាម្ចាស់របស់ជេតពននោះ ព្រោះហេតុដូច្នោះ ទើបលោកហៅថា **ជេតពន** ។ ក្នុង បទថា ជេតវនេ នោះ ( ជាសត្តមីវិភត្តិ )។

**កែបទ** អនាថបិណ្ឌិកស្ស អារាមេ

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា អនាថបិណ្ឌិកស្ស អារាមេ នេះដូច្នេះ គហបតីនោះឈ្មោះ **សុទត្តៈ** ដោយមាតាបិតា ដាក់ឈ្មោះឱ្យ ម្យ៉ាងទៀត លោកបានឱ្យដុំបាយជាទានដល់ជនអនាថាជាប្រចាំ ព្រោះលោកប្រាសចាកមន្ទិល គឺ

ការកំណាញ់ហើយ ព្រោះហេតុជាអ្នកដល់ព្រមដោយគុណមានករុណាជាដើម ព្រោះហេតុតែលោកជាអ្នកមានផង សម្បត្តិដែលគួរប្រាថ្នាគ្រប់យ៉ាងផង ហេតុនោះ ទើបលោកបានទទួលនាមថា **អនាថបិណ្ឌិក** ។ ប្រទេសដែលឈ្មោះថា **អារាម** ព្រោះជាទីដែលសត្វទាំងឡាយ ឬដោយវិសេស គឺបព្វជិតទាំងឡាយនាំគ្នាមកអភិរម្យ អធិប្បាយថា បព្វជិតទាំងឡាយមកពីទីនោះៗ ត្រេកអរក្រែ-លែង នៅមិននឿយណាយ ព្រោះវត្តជេតពននោះ លម្អដោយផ្កាឈើ ផ្លែឈើ ស្លឹកឈើទីជាដើម ហើយដល់ព្រមដោយអង្គរបស់សេនាសនៈ ៥ ប្រការ មានមិនឆ្ងាយពេក មិនជិតពេកជាដើម ។ ប្រការមួយទៀត ឈ្មោះថា **អារាម** ព្រោះនាំអ្នកដែលទៅក្នុងទីនោះៗ មកខាងក្នុងតាមលំដាប់ ហើយត្រេកអរ ព្រោះសម្បត្តិដូចពោលមកហើយ ។ មែនពិត អារាមនោះ គឺអនាថបិណ្ឌិកគហបតីទិញអំពីព្រះហស្ថរបស់ព្រះជេតរាជកុមារដោយក្រាលប្រាក់ ១៨ កោដិ ឱ្យកសាងសេនា-សនៈជាប្រាក់ ១៨ កោដិ ធ្វើបុណ្យឆ្លងវិហារជាប្រាក់ ១៨ កោដិ វេរថ្វាយព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានដោយបរិច្ចាគប្រាក់សរុបអស់ ៥៤ កោដិ យ៉ាងនេះ ព្រោះហេតុដូច្នោះ ទើបហៅថា អារាមរបស់លោកអនាថបិណ្ឌិក ។ ក្នុងបទថា អនាថបិណ្ឌិកស្ស អារាមេ នោះ (ជាសត្តមីវិភត្តិ) ។

ក៏បណ្តាបទទាំងនោះ បទថា ជេតវនេ បញ្ជាក់ដល់ម្ចាស់របស់ពីមុន បទថា អនាថបិណ្ឌិកស្ស អារាមេ បញ្ជាក់ដល់ម្ចាស់របស់ខាងក្រោយ ។ មានពាក្យសួរថា មានការបញ្ជាក់ដល់វត្តជេតពន និងអារាមទាំងនោះ មានប្រយោជន៍

អ្វី? សូមពន្យល់ដូច្នេះ ពោលដោយអធិការមុន ប្រយោជន៍ក៏គឺជាការធ្វើការកំណត់ (ឆ្លើយ) ពាក្យសួរដែលត្រាស់ទុកក្នុងទីណាមួយ ជាការប្រកបអ្នកដែលត្រូវការដោយបុណ្យដទៃទុកជាគំរូ មួយបែប ។ មែនពិត បណ្តាប្រយោជន៍ ២ យ៉ាងនោះ ទ្រព្យ ១៨ កោដិ ដែលបានមកពីការលក់ដី ក្នុងការកសាងប្រាសាទ ដែលមានទ្វារ បន្ទប់ និងដើមឈើទាំងឡាយ ដែលមានតម្លៃច្រើនកោដិ ជាការបរិច្ចាគរបស់ព្រះរាជកុមារជេត ទ្រព្យ ៥៤ កោដិ ជាការបរិច្ចាគរបស់អនាថ-បិណ្ឌិកគហបតី ។ ដោយការបញ្ជាក់ដល់ វត្តជេតពន និងអារាមនោះ ព្រះអានន្ទ-ដ៏មានអាយុ កាលសម្តែងថា អ្នកត្រូវការបុណ្យរមែងធ្វើ បុណ្យទាំងឡាយយ៉ាងនេះ ក៏រមែងប្រកបអ្នកត្រូវការបុណ្យដទៃៗ ទុកក្នុងការកាន់យកជាគំរូដោយប្រការណា ការប្រកបអ្នកត្រូវការបុណ្យទុកក្នុងការកាន់យកគំរូ ក៏គប្បីជ្រាបថាជាប្រយោជន៍ក្នុងសេចក្តីនេះ ដោយប្រការដូច្នោះ ។

ក្នុងសេចក្តីនេះ អ្នកជំទាស់ពោលថា ប្រសិនបើ ព្រះមានព្រះភាគប្រថាប់នៅជិតក្រុងសាវត្ថីជាមុន ព្រះអានន្ទដ៏មានអាយុក៏មិនគួរពោលថា ក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិកទេ ប៉ុន្តែបើព្រះអង្គប្រថាប់នៅក្នុងវត្តជេតពននោះហើយ ក៏មិនគួរពោលថា ជិតក្រុងសាវត្ថីដែរ ។ ព្រោះថា ព្រះមានព្រះភាគ មិនអាចប្រថាប់គង់នៅក្នុងកន្លែងពីរ ក្នុងវេលាតែមួយបានទេ ។ សូមពន្យល់ន័យដូច្នេះខ្ញុំពោលមកហើយពិតមែនឬ? ពាក្យថា **សាវត្ថិយំ** ជាសត្តមីវិភត្តិចុះក្នុងអត្ថ ថាជិត ព្រោះថា ប្រៀបដូចហ្វូងគោត្រាច់ទៅក្នុងទីជិតទន្លេគង្គា និងយមុនាជាដើម

គេហៅថា ត្រាច់ទៅក្នុងទីជិតទន្លេគង្គា ត្រាច់ទៅជិតទន្លេយមុនា មានឧបមាយ៉ាងណា ព្រះមានព្រះភាគកាលប្រថាប់នៅក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិក ជិតក្រុងសាវត្ថីក៏គប្បីជ្រាបនៅក្នុង វត្តជេតពន អារាមរបស់អនាថបិណ្ឌិក ជិតក្រុងសាវត្ថី សូម្បីក្នុងព្រះសូត្រនេះ ក៏មានឧបមេយ្យដូច្នោះ ។ មែនពិត ពាក្យថា **សាវត្ថី** របស់ព្រះថេរៈ ក៏ដើម្បីសម្តែងគោចរគ្រាម ពាក្យដ៏សេស ក៏ដើម្បីសម្តែងលំនៅជាប្រចាំដែលសមរម្យដល់បព្វជិត ។

ក្នុងពាក្យពីរនោះ ព្រះថេរៈទ្រង់សម្តែងការអនុគ្រោះគ្រហស្ថ របស់ព្រះមានព្រះភាគដោយការបញ្ជាក់ក្រុងសាវត្ថី សម្តែងការអនុគ្រោះដល់បព្វជិតដោយការបញ្ជាក់វត្តជេតពនជាដើម ។ ន័យម្យ៉ាងទៀត សម្តែងការស្ងប់ចាកអត្តកិលមថានុយោគ ព្រោះកាន់យកបច្ច័យ ដោយពាក្យសម្តែងឧបាយវៀរចាកកាមសុខល្លិកានុយោគ ព្រោះលះបង់វត្ថុកាមដោយពាក្យខាងក្រោយ ។ ម្យ៉ាងទៀត សម្តែងការព្យាយាមក្នុងទេសនាដោយពាក្យដើម សម្តែងការបង្អោនទៅក្នុងវិវេកៈ ដោយពាក្យក្រោយ សម្តែងការចូលទៅដោយករុណា ដោយពាក្យដើមហើយសម្តែងការចូលទៅដោយបញ្ញា ដោយពាក្យក្រោយ ។ សម្តែងសេចក្តីដែលព្រះមានព្រះភាគទ្រង់បង្អោន ទៅក្នុងទីដែលនិងឱ្យសម្រេចហិតសុខដល់សត្វទាំងឡាយ ដោយពាក្យដើម សម្តែងការនៅជាសុខទ្រង់មិនជាប់នៅក្នុងការបំពេញហិតសុខដល់អ្នកដទៃ ដោយពាក្យក្រោយ ។ សម្តែងការនៅជាសុខដែលមានការលះបង់សុខ ដែលប្រកបដោយធម៌ជានិមិត្ត ដោយពាក្យដើម សម្តែងការនៅជា

សុខដែលមានការប្រកបរឿយៗនូវឧត្តរិមនុស្សធម៌ជានិមិត្ត ដោយពាក្យក្រោយ ។ សម្ដែងការដែលទ្រង់មានឧបការៈច្រើនដល់មនុស្សទាំងឡាយ ដោយពាក្យដើម សម្ដែងការដែលទ្រង់មានឧបការៈច្រើនដល់ទេវតាទាំងឡាយ ដោយពាក្យក្រោយ ។ សម្ដែងការ ដែលព្រះមានព្រះភាគស្ដេចកើតឡើងក្នុងលោក ចម្រើនល្អលាស់ក្នុងលោក ដោយពាក្យដើម សម្ដែងការដែលលោកគ្រប់គ្រងព្រះអង្គមិនបាន ដោយពាក្យក្រោយមានដូចពោលមកនេះជាដើម ។

ពាក្យថា អថ ប្រើក្នុងអត្ថថា មិនដាច់រយៈ ស័ព្ទថា ខោ ជានិបាតប្រើក្នុងអត្ថថា សម្ដែងរឿងដទៃ ដោយពីរពាក្យនោះ ព្រះថេរៈសម្ដែងថា រឿងដទៃៗ នេះកើតឡើងក្នុងវិហាររបស់ព្រះមានព្រះភាគមិនដាច់រយៈឡើយ រឿងនោះគឺអ្វី ។ គឺរឿងទេវតាមួយអង្គជាដើម ។ បណ្ដាស័ព្ទទាំងនោះ ស័ព្ទថា អញ្ញតរា សម្ដែងការមិនពិតប្រាកដ ។ ពិតមែន ទេវតានោះ មិនប្រាកដនាម និងគោត្រ ព្រោះហេតុដូច្នោះ ទើបលោកពោលថា អញ្ញតរា ។ ទេវតាក៏គឺទេពនោះឯង បទថា អញ្ញតរា នេះជាសាធារណៈទូទៅដល់ស្ត្រី និងបុរស តែក្នុងទីនេះ បុរសប៉ុណ្ណោះ គឺទេវបុត្រ ។ ក៏ចាំបាច់និយាយទៅថា ដល់ទេវបុត្រដែលលោកពោលថា ទេវតា ដោយសាធារណនាម ។

## អភិក្កន្ត ស័ព្ទ

ក្នុងបទថា អភិក្កន្តាយ រត្តិយា នេះ អភិក្កន្ត-ស័ព្ទ ប្រើក្នុងសេចក្ដីទាំងឡាយ មាន**កន្លងទៅ ល្អ ស្អាត ត្រេកអរ** ជាដើមៗ បណ្ដាសេចក្ដីទាំងនោះ

ប្រើក្នុងសេចក្ដីថា **កន្លងទៅ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា "អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ បាដិមោក្ខំ ។ បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីបឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមាន-ព្រះភាគទ្រង់សម្ដែងបាតិមោក្ខដល់ភិក្ខុទាំងឡាយ"[១] ។

ប្រើក្នុងសេចក្ដីថា **ល្អ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា "អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច បណ្ដាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះ ល្អជាងផង ប្រសើរជាងផង "[២] ។

ក្នុងសេចក្ដីថា **ប្រសើរ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា " កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា អ្នកណាហ្ន៎ រុងរឿងដោយឫទ្ធិ ដោយយស ដោយសម្បុរដ៏ល្អ(ប្រសើរ) ញ៉ាំងទិសទាំងពួង មកថ្វាយបង្គំបាទានៃតថាគត"[៣] ។

ប្រើក្នុងសេចក្ដីថា **ច្បាស់** ដូចក្នុងប្រយោគជាដើមយ៉ាងនេះ ថា អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើនភាសិតរបស់ព្រះអង្គច្បាស់ណាស់"[៤] ។

តែក្នុងព្រះសូត្រនេះ ប្រើក្នុងសេចក្ដីថា អស់ទៅ ។ លោកអធិប្បាយថា

---

១-វិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ២០១ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត លេខ ៤២ ទំព័រ ២៥០ ។

៣-សុត្តន្តបិដក ខុទ្ទកនិកាយ វិមានវត្ថុ លេខ ៥៥ ទំព័រ ១១០ ។

៤-វិនយបិដក មហាវគ្គ លេខ ១ ទំព័រ ១៧ ។

បទថា អភិក្កន្តាយ រត្តិយា ប្រែថា ពេលរាត្រីកន្លងទៅហើយ ។

ក្នុងបទថា អភិក្កន្តវណ្ណា នេះ អភិក្កន្ត-ស័ព្ទ ក្នុងសេចក្តីថាល្អ ។ **វណ្ណ**-ស័ព្ទ ក្នុងសេចក្តីថា **សម្បុរ គុណ វណ្ណៈ ហេតុ ខ្នងខ្នស់ ខ្នាត រូបាយតនៈ**ជាដើម ។

ប្រើក្នុងសេចក្តីថា **សម្បុរ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “**សុវណ្ណ**-វណ្ណោសិ ភគវា បពិត្រព្រះមានបុណ្យព្រះអង្គមានសម្បុរដូចមាស”[១] ។

ប្រើក្នុងសេចក្តីថា **គុណ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “កទា សញ្ញូឡ្ហា បន តេ គហបតិ ឥមេ សមណស្ស គោតមស្ស វណ្ណា ម្នាលគហបតិ ចុះគុណរបស់សមណគោតមទាំងអម្បាលនេះ អ្នកប្រមូលមកអំពីកាលណា”[២] ។

ប្រើក្នុងសេចក្តីថា **វណ្ណៈ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “ចត្តារោ មេ ភោ គោតម វណ្ណា បពិត្រព្រះគោតមដ៏ចម្រើន វណ្ណៈ ៤ ទាំងនេះឯង” ។

ប្រើក្នុងសេចក្តីថា **ហេតុ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “ អថ កេន នុ វណ្ណេន គន្ធថេនោតិ វុច្ចតិ ព្រោះហេតុអ្វីទៅហ្ន៎ ទើបថាខ្ញុំជាអ្នកលួចក្លិន” ។

ប្រើក្នុងសេចក្តីថា **ខ្នងខ្នស់** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “ មហន្តំ ហត្ថិរាជវណ្ណំ អភិនិម្មិត្វា និម្មិតខ្នងខ្នស់ ជាស្តេចដំរី ” ។

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ លេខ ២៥ ទំព័រ ៤៦ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ លេខ ២៣ ទំព័រ ១៣៤ ។

ប្រើក្នុងសេចក្ដីថា **ខ្នាត** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “ តយោ បត្តស្ស វណ្ណា ខ្នាតរបស់បាត្រ ៣ ខ្នាត ” ។

ប្រើក្នុងសេចក្ដីថា **រូបាយតនៈ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “វណ្ណោ គន្ធោ រសោ ឱជា រូប ក្លិន រស ឱជា ” ។

វណ្ណ-ស័ព្ទនោះក្នុងសូត្រនេះ គប្បីយល់ថា ប្រើក្នុងសេចក្ដីថា សម្បុរ ព្រោះហេតុនោះ ទើបលោកអធិប្បាយថា បទថា អភិក្កន្តវណ្ណា ប្រែថា មានសម្បុរគួរស្រឡាញ់ ។

## **កែអត្ថនៃបទ** កេវលកប្បំ

កេវល-ស័ព្ទក្នុងបទថា កេវលកប្បំ នេះ មានអត្ថន័យជាអនេក ដូចជា **មិនមានចំណែកដ៏សេស ដោយច្រើន មិនលាយ**(សុទ្ធ) **មិនច្រើនពេក គង់វង់ មិនប្រកាន់ស្អិត** ។ ពិតដូច្នោះ កេវល-ស័ព្ទនោះ មានសេចក្ដីថា **មិនមានចំណែកដ៏សេស** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ព្រហ្មចរិយបរិសុទ្ធបរិបូណ៌ មិនមានចំណែកដ៏សេស ” ។

មានសេចក្ដីថា **ដោយច្រើន** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា កេវល-កប្បា ច អង្គមគធា បហូតំ ខាទនីយំ ភោជនីយំ អាទាយ ឧបសង្កមិ-ស្សន្តិ ជនអ្នកនៅក្នុងដែនអង្គៈ និងមគធៈទាំងអស់គ្នា និងចូលមកដោយនាំយកខាទនីយភោជនីយាហារមានប្រមាណច្រើនចូលមកបូជា ។

មានសេចក្តីថា **មិនលាយ**(សុទ្ធ) ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា កេវ-លស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ការកើតនៃទុក្ខក្ខន្ធសុទ្ធៗ រមែងមាន ។

មានសេចក្តីថា **មិនច្រើនពេក** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា កេវលំ សទ្ធាមត្តកំ នូន អយមាយស្មា លោកដ៏មានអាយុនេះ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្មៈ ព្រោះអាស្រ័យនូវគុណ គ្រាន់តែសេចក្តីជឿប៉ុណ្ណោះឯង(១)។

មានសេចក្តីថា **គង់វង្ស** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា អាយស្មតោ ភន្តេ អនុរុទ្ធស្ស វាហិយោ នាម សទ្ធិវិហារិកោ កេវលកប្បំ សង្ឃភេទាយ ឋិតោ បពិត្រព្រះអង្គដ៏ចម្រើន សទ្ធិវិហារិករបស់អនុរុទ្ធដ៏មានអាយុ ឈ្មោះវាហិយៈ នៅតែទទូចដើម្បីបំបែកសង្ឃឥតឈប់ឈរ(២) ។

មានសេចក្តីថា **ប្រកាន់ស្អិត** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា កេវលី វុសិត្វា ឧត្តមបុរិសោ វុច្ចតិ អ្នកមិនប្រកាន់ខ្ជាប់នូវព្រហ្មចរិយៈហើយលោកហៅថា បុរសខ្ពង់ខ្ពស់ ។

តែក្នុងសូត្រនេះ កេវល-ស័ព្ទនោះ លោកសង្គ្រោះយកសេចក្តីថា មិនមានចំណែកដ៏សេស ។

---

១-វិនយបិដក មហាវគ្គ លេខ ៧ ទំព័រ ១៦៧ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ លេខ ៤៣ ទំព័រ ២៤៩ ។

ចំណែក កប្ប-ស័ព្ទ មានន័យច្រើនជាដើមថា **ការជឿស៊ប់ វោហារ កាល បញ្ញត្ត កាត់ វិកប្ប លេស** និង**ដោយជុំវិញ** ។

ពិតដូច្នោះ កប្ប-ស័ព្ទនោះ មានសេចក្ដីថា **ជឿស៊ប់** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “ឱកប្បនីយមេតំ ភោតោ គោតមស្ស យថា តំ អរហតោ សម្មាសម្ពុទ្ធស្ស ពាក្យរបស់ព្រះគោតមដែលជាអរហន្តសម្មាសម្ពុទ្ធ នេះជាពាក្យគួរជឿហើយ”[1] ។ មានសេចក្ដីថា **វោហារ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា អនុជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុឆាន់ផ្លែឈើដោយសមណកប្បៈ ៥ យ៉ាង”[2] ។

មានសេចក្ដីថា **កាល** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា យេន សុទំ និច្ចកប្បំ វិហរាមិ បានឮថា តថាគតនឹងនៅអស់កាលជានិច្ច ដោយធម៌ណា ។

មានសេចក្ដីថា **បញ្ញត្ត** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា ឥច្ចាយស្មា កប្បោ លោកដ៏មានអាយុ ការបញ្ញត្តយ៉ាងនេះ ។

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក លេខ ២២ ទំព័រ ១៣១ ។

២-វិនយបិដក ចុល្លវគ្គ លេខ ១០ ទំព័រ ១៣៥ ។

*មានសេចក្ដីថា* ***កាត់****ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា អលង្កតោ កប្បិតកេសមស្សុ (បុណ្ណកយក្ខ) តាក់តែងខ្លួន កាត់កោរសក់ និងពុកមាត់ស្រេចហើយ ។*

*មានសេចក្ដីថា* ***គួរ*** *ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា កប្បតិ ទ្វង្គុលកប្បោ ការកំណត់ដោយស្រមោលព្រះអាទិត្យជ្រេទៅ ប្រមាណពីរធ្នាប់គួរ[១] ។*

*មានសេចក្ដីថា* ***លេស*** *ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា អត្ថិ កប្បោ និបជ្ជិតុំ ធ្វើលេសដើម្បីដេក ។*

*មានសេចក្ដីថា* ***ដោយជុំវិញ*** *ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា កេវលកប្បំ វេឡុវនំ ឱភាសេត្វា បញ្ចេញរស្មីជុំវិញវត្តវេឡុវន ។*

*តែក្នុងសូត្រនេះ* ***កប្ប****-ស័ព្ទនោះ លោកសង្គ្រោះយកសេចក្ដីថា ដោយជុំវិញ ដោយប្រការដូចក្នុងបទថា កេវលកប្បំ ជេតវនំ នេះគួរជ្រាបសេចក្ដីយ៉ាងនេះ បញ្ចាំងរស្មី ដោយជុំវិញវត្តជេតពន ដោយជុំវិញមិនមានសេសសល់ឡើយ ។*

*បទថា* ឱភាសេត្វា *បានដល់ ផ្សាយដោយរស្មី ។ អធិប្បាយថា ធ្វើរស្មីឱ្យតែមួយ រុងរោចន៍តែម្យ៉ាង ដូចព្រះចន្ទនិងព្រះអាទិត្យ ។*

*បទថា* យេន ភគវា តេនុបសង្កមិ *ជាតតិយាវិភត្តិចុះក្នុងអត្ថនៃសត្តមី-វិភត្តិ ។ ដោយប្រការដែលគប្បីយល់ក្នុងសេចក្ដីនៃពាក្យនេះដូច្នេះថា ព្រះមានព្រះភាគ*

---

*១-នេះជាពាក្យរបស់ពួកវជ្ជីបុត្តកភិក្ខុនៅក្នុងក្រុងវេសាលី បានពោលនៅពេលដែលព្រះមានព្រះភាគ ស្ដេចបរិនិព្វានទៅបាន ១០០ ឆ្នាំ មិនគួរកាន់យកទេ ។*

ប្រថាប់នៅក្នុងទីណា ទេវតាក៏ចូលទៅគាល់ក្នុងទីនោះ ។ គប្បីជ្រាបសេចក្តីក្នុងពាក្យនេះយ៉ាងនេះថា ព្រះមានព្រះភាគ គឺទេវតា និងមនុស្សទាំងឡាយ ទៅគាល់ដោយហេតុណា ទេវតាក៏ចូលទៅគាល់ដោយហេតុនោះនុ៎ះឯង ។ ក៏ព្រះមានព្រះភាគ គឺទេវតា និងមនុស្សនាំគ្នាចូលទៅគាល់ដោយហេតុអ្វី ។ ដោយបំណងត្រាស់ដឹងគុណវិសេសមានប្រការផ្សេងៗ ដូចដើមឈើធំដែលចេញផ្លែជានិច្ច គឺហ្វូងសត្វនាំគ្នាចូលទៅ ក៏ដោយបំណងនឹងបរិភោគផ្លែឈើ ដែលមានរសឆ្ងាញ់ដូច្នោះ ។ លោកអធិប្បាយថា បទថា ឧបសង្កមិ ប្រែថា ទៅហើយ បទថា ឧបសង្កមិត្វា ជាពាក្យពោលចុងបំផុតនៃការចូលទៅគាល់ ។ ម្យ៉ាងទៀត លោកអធិប្បាយថា ទេវតាចូលទៅយ៉ាងនោះហើយ តពីនោះក៏ទៅ កាន់កន្លែងតអំពីអាសនៈ ពោលគឺទីជិតព្រះមានព្រះភាគ ។ បទថា ភគវន្តំ អភិវាទេត្វា បានដល់ ការថ្វាយបង្គំបង្អោននមស្ការព្រះមានព្រះភាគ ។

បទថា ឯកមន្តំ សម្តែងដល់ភាពជានបុំសកលិង្គ ។ លោកអធិប្បាយថា ឱកាសមួយ ចំណែកមួយ ។ ន័យម្យ៉ាងទៀត ពាក្យនេះជាទុតិយាវិភត្តិ ចុះក្នុងអត្ថសត្តមីវិភត្តិ ។ បទថា អដ្ឋាសិ បដិសេធឥរិយាបថអង្គុយជាដើម អធិប្បាយថា សម្រេចការឈរ គឺបានឥរិយាបថឈរហើយ ។

សួរថា ក៏ទេវតានោះ ឈរយ៉ាងណា ទើបឈ្មោះថា បានជាអ្នកឈរដោយចំណែកមួយ ។

ឆ្លើយថា បុរាណាចារ្យពោលថា ៖

ន បច្ឆតោ ន បុរតោ នាបិ អាសន្នទូរតោ

ន កច្ចនោបិ បដិវាតេ ន ចាបិ ឱណតុណ្ណតេ
ឥមេ ទោសេ វិវជ្ជេត្វា ឯកមន្តំ ឋិតា អាហុ។

វៀរចាកទោសនៃកិរិយាឈរ (៦) យ៉ាងគឺ មិនឈរខាងក្រោយ មិនឈរខាងមុខ មិនឈរក្នុងទីជិតនិងឆ្ងាយពេក មិនឈរក្នុងទីសើម មិនឈរលើខ្យល់ មិនឈរក្នុងទីខ្ពស់និងទីទាប ។

សួរថា ព្រោះហេតុអ្វី ទេវតាអង្គនេះ ទើបឈរតែម្យ៉ាង មិនអង្គុយ ។

ឆ្លើយថា ព្រោះទេវតាមានបំណងនឹងត្រឡប់ទៅវិញដោយរហ័ស ។ ពិតណាស់ ទេវតាទាំងឡាយ អាស្រ័យប្រយោជន៍អ្វីម្យ៉ាង ទើបមកកាន់មនុស្សលោក ដូចបុរសដ៏ស្អាតចូលមកអង្គុយ ។ ក៏ដោយប្រក្រតីមនុស្សលោក រមែងជារបស់បដិកូល ព្រោះជារបស់ស្អុយសម្រាប់ទេវតាទាំងនោះ រាប់តាំងតែរយយោជន៍ឡើងទៅ ទេវតាទាំងឡាយ មិនចូលចិត្តមនុស្សលោកនោះឡើយ ព្រោះហេតុនោះ ទេវតាអង្គនោះ ទើបមិនអង្គុយ ព្រោះបំណងនឹងធ្វើកិច្ច ដែលមកហើយប្រញាប់ត្រឡប់ទៅវិញ ។ ក៏មនុស្សទាំងឡាយ រមែងអង្គុយដើម្បីបន្ថយការលំបាកនៃឥរិយាបថមានដើរជាដើម យ៉ាងណា ការលំបាកនោះសម្រាប់ទេវតាមិនមាន ព្រោះហេតុនោះ ទេវតាទើបមិនអង្គុយ ។ ម្យ៉ាងទៀត ព្រះមហាសាវកពួកណា ឈរចោមរោមព្រះមានព្រះភាគ ព្រះមានព្រះភាគ ក៏ទ្រង់រាប់អានឆ្លើយតបព្រះមហាសាវកទាំងនោះ (គឺប្រថាប់ឈរ) សូម្បីព្រោះហេតុនោះទេវតា ទើបមិនអង្គុយ ។

ម្យ៉ាងទៀត ទេវតាមិនអង្គុយក៏ព្រោះគោរពព្រះមានព្រះភាគ ។ ពិតណាស់ ទីអង្គុយរមែងកើតឡើងដល់ទេវតាទាំងឡាយ ដែលមានបំណងនឹងអង្គុយទេវតានោះ មិនប្រាថ្នាទីអង្គុយនោះ មិនគិតសូម្បីនឹងអង្គុយ ទើបឈរក្នុងចំណែកម្ខាង ។

បទថា ឯកមន្តំ ឋិតា ខោ សា ទេវតា សេចក្តីថា ទេវតាអង្គនោះ ឈរក្នុងចំណែកម្ខាង ដោយហេតុទាំងនេះយ៉ាងនេះ ។ បទថា ភគវន្តំ គាថាយ អជ្ឈភាសិ សេចក្តីថា បានទូលព្រះមានព្រះភាគដោយពាក្យជាគាថា ដែលកំណត់ដោយអក្ខរបទ ។ ថាដូចម្តេច ។ ថាយ៉ាងនេះថា

ពហូ ទេវា មនុស្សា ច ។បេ។ ព្រូហិ មង្គលមុត្តមំ ។

## មង្គលបញ្ហាសមុដ្ឋានកថា

### **ពោលអំពីមូលហេតុកើតមង្គលបញ្ហា**

ក្នុងការពណ៌នាមង្គលសូត្រនោះ ព្រោះហេតុដែលខ្ញុំតាំងមាតិកាទុកថា កាលនឹងពណ៌នាសេចក្តីនៃបាឋៈមានអាទិថា ឯវំ ដោយប្រការផ្សេងៗ និងពោលដល់សមុដ្ឋានមូលហេតុដូច្នេះ នេះជាឱកាសដែលនឹងពោលដល់សមុដ្ឋានមូលហេតុនោះដូច្នោះ នឹងពោលដល់សមុដ្ឋានមូលហេតុកើតមង្គលបញ្ហាជាមុនសិន ខាងក្រោយទើបនឹង ពោលពណ៌នាសេចក្តីនៃបទគាថាទាំងនោះ ។ តើសមុដ្ឋានមូលហើយឱ្យកើតមង្គលប្បញ្ហាយ៉ាងដូចម្តេច ។

បានឮមកថា ក្នុងជម្ពូទ្វីប មហាជនជុំទុំគ្នាក្នុងទីនោះៗ ដូចជា ជិតទ្វារនគរ សភានៃកន្លែងរាជការជាដើម ប្រគល់ទ្រព្យសម្បត្តិ មាស ប្រាក់ឱ្យគេនិទានរឿងផ្សេងៗ ដូចជារឿងនាំនាងសីតាមកជាដើម ។ រឿងមួយៗ និទានដល់ទៅ ៤ ខែទើបចប់ ។ ក្នុងទីនោះ ថ្ងៃមួយរឿង មង្គលបញ្ហាក៏កើតឡើងថា អ្វីហ្ន៎ជាមង្គល ។ វត្ថុដែលឃើញឬជាមង្គល រឿងដែលបានឮឬជាមង្គល ឬថារឿងដែលដឹងជាមង្គល អ្នកណាហ្ន៎ ដឹងនូវមង្គលដូច្នេះ ។

កាលនោះ បុរសម្នាក់ ឈ្មោះ**ទិដ្ឋមង្គលិកៈ** (កាន់យកវត្ថុដែលឃើញជាមង្គល) ពោលថា ខ្ញុំស្គាល់ច្បាស់នូវមង្គល ។ វត្ថុដែលឃើញ ជាមង្គលក្នុងលោក ។ រូបដែលសន្មតិថា ជាមង្គលដ៏ក្រៃលែង ឈ្មោះថា **ទិដ្ឋៈ** ។ រូបដូចម្តេចទៅ មនុស្សពួកខ្លះក្នុងលោកនេះ ភ្ញាក់ពីព្រឹក ឃើញសត្វកន្ធែនខ្លះ ឃើញដើមព្នៅខ្ចីខ្លះ ឃើញស្ត្រីមានគភ៌ខ្លះ ឃើញកូនក្មេងតាក់តែងប្រដាប់កាយទូលក្អមពេញដោយទឹកខ្លះ ត្រីឆ្អិនក្រហមស្រស់ខ្លះ សេះអាជានេយ្យខ្លះ រថទឹមដោយសេះខ្លះ គោឈ្មោលខ្លះ គោញីខ្លះ គោក្រហមខ្លះ ឬក៏ឃើញសូម្បីរូបដទៃឯណាប្រាកដដូច្នោះ ដែលសន្មតិថាជាមង្គលដ៏ក្រៃលែង រូបសូម្បីឃើញនេះហៅថា **ទិដ្ឋមង្គល** ។ មនុស្សពួកខ្លះ ក៏រមែងទទួលពាក្យរបស់គេ ពួកខ្លះក៏មិនព្រមទទួល ក៏បដិសេធនឹងគេ ។

កាលនោះ បុរសម្នាក់ឈ្មោះ **សុតមង្គលិកៈ** ក៏ពោលថា អ្នកអើយ ឈ្មោះថា ភ្នែក រមែងឃើញរបស់ស្អាតខ្លះ មិនស្អាតខ្លះ របស់ល្អខ្លះ មិនល្អខ្លះ របស់ពេញចិត្តខ្លះ របស់មិនពេញចិត្តខ្លះ ប្រសិនបើ រូបដែលអ្នកនោះ ឃើញគប្បីជា

មង្គលពិត ក៏នឹងគប្បីជាមង្គលទាំងអស់ដែរ ព្រោះហេតុនោះ រូបដែលឃើញមិនជាមង្គល ។ ក៏ប៉ុន្តែ សម្លេងដែលបានឮឯណាទេជាមង្គល ។ សម្លេងដែលគេសន្មតិថា ជាមង្គលក្រៃលែង ។ ឈ្មោះថា **សុតៈ** ដូចម្តេចទៅ ។ មនុស្សពួកខ្លះក្នុងលោកនេះ ក្រោកឡើងពីព្រឹក បានឮសំឡេងដូច្នេះថា ចម្រើនហើយ កំពុងចម្រើន ពេញ ស ត្រេកអរ សិរី ចម្រើនដោយសិរី ថ្ងៃនេះ ឫក្សល្អ យាមល្អ ថ្ងៃល្អ មង្គលល្អ ឬសំឡេងដែលសន្មតិថា មង្គលដ៏ក្រៃលែង ។ សំឡេងដែលបានឮនេះ ហៅថា **សុតមង្គល** ។ ពួកខ្លះក៏រមែងព្រម ទទួលពាក្យរបស់គាត់ ពួកខ្លះ ក៏មិនព្រមទទួល ពួកដែលមិនព្រមទទួល ក៏ជំទាស់ជាមួយគាត់ ។

កាលនោះ បុរសម្នាក់ឈ្មោះ **មុតមង្គលិកៈ** ពោលថា អ្នកអើយ ពិតណាស់ ឈ្មោះថា ត្រចៀក រមែងបានឮសំឡេងល្អខ្លះ មិនល្អខ្លះ ពេញចិត្តខ្លះ មិនពេញចិត្តខ្លះ ប្រសិនបើសំឡេងអ្នកនោះបានឮ គប្បីជាមង្គលពិត ក៏នឹងជាមង្គលទាំងអស់ ។ ព្រោះហេតុដូច្នោះ សំឡេងដែលបានឮ ទើបជាមង្គល ។ ក៏ប៉ុន្តែថារឿងដែលជ្រាបហើយឯណោះទេជាមង្គល ។ ក្លិន រស និងផោដ្ឋព្វៈវត្ថុដែលគប្បីពាល់ត្រូវ ឈ្មោះថា **មុតៈ** ។ យ៉ាងដូចម្តេចទៅ ។ មនុស្សពួកខ្លះ ក្រោកពីព្រឹកហិតក្លិនផ្កា មានក្លិនផ្កាបទុមជាដើមខ្លះ ទំពាឈើស្ទន់ខ្លះ ចាប់ពាល់ផែនដីខ្លះ ចាប់ពាល់សំណាបខៀវខ្លះ អាចម៍គោស្រស់ខ្លះ អណ្តើកខ្លះ ល្ងខ្លះ ផ្កាឈើខ្លះ ផ្លែឈើខ្លះ បូកលាបដោយដីសដែលល្អខ្លះ ស្លៀកសំពត់ខ្លះ ទទូរសំពត់ខ្លះ ឬក៏ហិតក្លិនលិទ្ធរស ឬពាល់ត្រូវផោដ្ឋព្វៈ ដែលសន្មតិថាជាមង្គលដ៏ក្រៃលែងយ៉ាងដទៃណា

ប្រាកដដូច្នោះ វត្ថុដូចពោលមកនេះ ហៅថា **មុតមង្គល** ។ បុគ្គលពួកខ្លះ ក៏ព្រមទទួលពាក្យសូម្បីរបស់គាត់ បុគ្គលពួកខ្លះក៏មិនព្រមទទួល ។

បណ្តា ៣ ពួកនោះ ទិដ្ឋមង្គលិកបុរស ក៏មិនអាចធ្វើឱ្យសុតមង្គលិកបុរស និងមុតមង្គលិកបុរសយល់ព្រមបានទាំង ៣ ចំណែកនេះ ចំណែកណាមួយ ក៏ធ្វើចំណែកពីរទៀតឱ្យយល់ព្រមមិនបាន បណ្តាមនុស្សទាំងនោះ ពួកណាព្រមទទួលពាក្យរបស់ទិដ្ឋមង្គលិកបុរស ពួកនោះក៏ប្រកាន់ថា រូបដែលឃើញហើយប៉ុណ្ណោះជាមង្គល ។ ពួកណាព្រមទទួលពាក្យរបស់សុតមង្គលិកបុរស និងមុត-មង្គលិកបុរស ពួកនោះក៏ប្រកាន់ថា សំឡេងដែលបានឮប៉ុណ្ណោះជាមង្គល រឿងដែលបានដឹងប៉ុណ្ណោះជាមង្គល ។ រឿងមង្គលបញ្ហានេះ ប្រាកដទូទាំងជម្ពូទ្វីបដោយប្រការដូច្នេះ ។

កាលនោះ មនុស្សទូទាំងជម្ពូទ្វីបប្រកាន់គ្នាជាពួកៗ នាំគ្នាគិតរក មង្គលទាំងឡាយថា អ្វីហ្ន៎ជាមង្គល ។ អារក្ខទេវតារបស់មនុស្សពួកនោះ ស្តាប់រឿងនោះហើយ ក៏នាំគ្នាគិតរក្សាមង្គលទាំងឡាយដូចគ្នា ។ ពួកភុម្មទេវតាជាមិត្ររបស់ទេវតាទាំងនោះ ស្តាប់រឿងអំពីអារក្ខទេវតា នោះហើយក៏នាំគ្នាគិតរកមង្គលយ៉ាងនោះដូចគ្នា ។ អាកាសដ្ឋកទេវតាជា មិត្ររបស់ទេវតានោះ ចតុម្មហារាជិកទេវតាជាមិត្ររបស់អាកាសដ្ឋកទេវតាទាំងនោះ ដោយឧបាយនេះ ដរាបដល់អកនិដ្ឋទេវតាជាមិត្ររបស់សុទស្សីទេវតា ស្តាប់រឿងអំពីសុទស្សីទេវតានោះហើយក៏ប្រកាន់គ្នាជាពួកៗ នាំគ្នាគិតរកមង្គលទាំងឡាយ ដោយឧបាយយ៉ាងនេះ ។ ការ

គិតរកមង្គលក៏កើតឡើងក្នុងទីគ្រប់កន្លែងរហូតដល់ម៉ឺនចក្រវាឡ ។ ក៏ការគិតរកមង្គលកើតឡើងហើយ សូម្បីវិនិច្ឆ័យថានេះជាមង្គល នេះជាមង្គល ក៏មិនទាន់ដាច់ស្រេចទើបតាំងនៅអស់ ១២ ឆ្នាំ ។ ទាំងមនុស្ស ទាំងទេវតា ទាំងព្រហ្ម ទាំងអស់គ្នាវៀរតែព្រះអរិយសាវកចេញបែកគ្នាជា ៣ ពួក គឺ **ទិដ្ឋមង្គលិកៈ សុតមង្គលិកៈ មុតមង្គលិកៈ** សូម្បីតែមួយពួក ក៏មិនបានយល់តាម ការពិតថានេះប៉ុណ្ណោះជាមង្គល ។ មង្គលកោលាហល ការបែករឿងមង្គលកើតឡើងហើយក្នុងលោក ។

ឈ្មោះថា **កោលាហលមាន ៥** គឺ**កប្បកោលាហល ចក្កវត្តិកោលាហល ពុទ្ធកោលាហល មង្គលកោលាហល មោនេយ្យកោលាហល** ។ បណ្ដាកោលាហលទាំង ៥ នោះ ពួកទេវតាជាន់កាមាវចរ បណ្ដោយសិរសា រំសាយសក់ យំសោកយកដៃជូតទឹកភ្នែក ស្លៀកសំពត់ពណ៌ក្រហម ទ្រទ្រង់ភេទប្លែកៗ យ៉ាងក្រៃលែង ត្រាច់ទៅតំបន់មនុស្សស្រែកប្រាប់ថា កន្លងទៅសែនឆ្នាំកប្បនឹងប្រាកដ លោកនេះនឹងវិនាស មហាសមុទ្រនឹងរីងស្ងួត មហាប្រឋពីនេះ និងស្ដេចភ្នំឈ្មោះសិនេរុ នឹងត្រូវភ្លើងឆេះ នឹងវិនាស លោកនឹងវិនាស និងដល់ទៅព្រហ្មលោក ។ ម្នាលអ្នកនិទុក្ខ សូមអ្នកទាំងឡាយនាំគ្នាចម្រើនមេត្តាចុះ ចូរនាំគ្នាចម្រើនករុណា មុទិតា ឧបេក្ខាចុះ ម្នាលអ្នកនិទុក្ខ ចូរបម្រើមាតាបិតា ចូរធ្វើការកោតក្រែងអ្នកជារាមច្បងក្នុងត្រកូល ដាស់តឿនគ្នា កុំប្រមាទឡើយ ។ នេះឈ្មោះថា **កប្បកោលាហល** ។

ទេវតាជាន់កាមាវចរនោះឯង ត្រាច់ទៅតំបន់មនុស្សប្រកាសថា កន្លងទៅរយឆ្នាំ ស្ដេចចក្រពត្តិនឹងកើតឡើងក្នុងលោក ។ នេះឈ្មោះថា **ចក្កវត្តិកោលាហល** ។

ចំណែកទេវតាជាន់សុទ្ធាវាស ប្រដាប់អង្គដោយអាភរណព្រហ្ម ជួតសំពត់របស់ព្រហ្មនៅលើក្បាល កើតបីតិបាមោជ្ជៈ ពោលព្រះពុទ្ធគុណ ត្រាច់ទៅក្នុងតំបន់មនុស្សពោលថា កន្លងទៅពាន់ឆ្នាំ ព្រះពុទ្ធនឹងកើតឡើងក្នុងលោក ។ នេះឈ្មោះថា **ពុទ្ធកោលាហល** ។

ទេវតាជាន់សុទ្ធាវាសនោះឯង ស្គាល់ចិត្តរបស់ពួកមនុស្ស និងទេវតាទាំងឡាយ ត្រាច់ទៅក្នុងតំបន់ពួកមនុស្សប្រកាសថា កន្លងទៅ ១២ ឆ្នាំ ព្រះសម្មាសម្ពុទ្ធជាម្ចាស់នឹងត្រាស់សម្ដែងមង្គល ។ នេះឈ្មោះថា **មង្គលកោលាហល** ។

ទេវតាជាន់សុទ្ធាវាសនោះឯង ត្រាច់ទៅក្នុងតំបន់ពួកមនុស្សប្រកាសថា កន្លងទៅ ៧ ឆ្នាំ ភិក្ខុមួយអង្គសមាគមជាមួយព្រះដ៏មានព្រះភាគនឹងទូលសួរ **មោនេយ្យបដិបទា**[១] ។ នេះឈ្មោះថា **មោនេយ្យកោលាហល** ។ បណ្ដា

---

១-ក្នុងអដ្ឋកថា **សុត្តនិបាត** ឈ្មោះ **បរមត្ថជោតិកា** ត្រង់នាឡកសុត្តវណ្ណនា បានសម្ដែងអំពីបុគ្គលអ្នកបដិបត្តិនូវមោនេយ្យបដិបទា មានសេចក្ដីយ៉ាងនេះថា៖ បានឮមកថា តាបសមួយរូប ឈ្មោះ **នាឡកៈ** ត្រូវជាក្មួយរបស់ឥសី ឈ្មោះ អសិតៈ បានបំពេញបារមីអស់មួយសែនកប្ប ចាប់តាំងពីបានឃើញនូវសាវ័ករបស់ព្រះមានព្រះភាគបទុមុត្តរៈ អ្នកបដិបត្តិនូវមោនេយ្យបដិបទាហើយក៏បានប្រាថ្នានូវភាពយ៉ាងនោះ បានចូលទៅសួរព្រះមានព្រះភាគនូវមោនេយ្យបដិបទា ក្នុងថ្ងៃទី ៧ អំពីថ្ងៃសម្ដែងធម្មចក្កប្បវត្តនសូត្រ ដោយគាថាទាំងឡាយពីរយ៉ាងនេះថា "**អញ្ញាតមេតំ**"ដូច្នេះជាដើម ។ នេះជាសេចក្ដីផ្ដើមនៃនាឡកសូត្រដែលមានក្នុងអដ្ឋកថា ។ ហើយខាងចុង លោកបានសម្ដែងបន្តសម្រាប់ជាធម្មទាន

ទៀតថា ព្រះនាឡកត្ថេរ ក្រោយពីបានស្តាប់នូវនាឡកសូត្រនេះហើយ លោកជាអ្នកប្រាថ្នាតិចក្នុងឋានៈបី គឺ**ការមើល ការស្តាប់ និងការសួរ** ។ មែនពិត ក្នុងកាលជាទីបំផុតនៃទេសនា ព្រះថេរៈអង្គនោះ មានចិត្តជ្រះថ្លាបានថ្វាយបង្គំព្រះមានព្រះភាគ ចូលទៅកាន់ព្រៃ មិនបានញ៉ាំងចិត្តលោកឱ្យកើតឡើងយ៉ាងនេះថា "ឱហ្ន៎! អាត្មាអញនឹងមកគាល់ព្រះមានព្រះភាគម្តងទៀតទេ" ។ នេះជាការប្រាថ្នាតិចក្នុងការឃើញរបស់ព្រះថេរៈអង្គនោះ ។ លោកមិនបានញ៉ាំងចិត្តលោកឱ្យកើតឡើងយ៉ាងនេះថា "ឱហ្ន៎! អាត្មាអញ នឹងស្តាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគម្តងទៀតទេ" ។ តរទៅទំព័រមុខ នេះការប្រាថ្នាតិចក្នុងការស្តាប់របស់លោក ។ លោកមិនបានញ៉ាំងចិត្តលោកឱ្យកើតឡើងយ៉ាងនេះថា "ឱហ្ន៎! អាត្មាអញនឹងសាកសួរនូវមោនេយ្យបដិបទានឹងព្រះមានព្រះភាគម្តងទៀតទេ" ។ នេះជាការប្រាថ្នាតិច ក្នុងការសាកសួររបស់លោក ។ ក៏ព្រះថេរៈអង្គនោះ ជាអ្នកប្រាថ្នាតិច បាននិមន្តទៅកាន់ជើងភ្នំ មិនអាស្រ័យនៅក្នុងដងព្រៃតែមួយ ចំនួនពីរថ្ងៃឡើយ មិនគង់ទៀបគល់ឈើមួយដើមចំនួនពីរថ្ងៃឡើយ មិននិមន្តចូលទៅបិណ្ឌបាតក្នុងស្រុកមួយចំនួនពីរថ្ងៃឡើយ ។ ព្រោះដូច្នោះ ព្រះថេរៈ តែងនិមន្តពីដងព្រៃមួយ ទៅកាន់ដងព្រៃមួយ ពីដើមឈើមួយទៅដើមឈើមួយ ពីស្រុកមួយទៅកាន់ស្រុកមួយ បដិបត្តិនូវបដិបទាតាមសមគួរ តាំងនៅក្នុងផលដ៏ប្រសើរ ។ ព្រោះថា ភិក្ខុ អ្នកបដិបត្តិឱ្យបរិបូណ៌នូវមោនេយ្យបដិបត្តិយ៉ាងឧក្រិដ្ឋ មានព្រះជន្ម ត្រឹមតែ ៧ ខែ, បដិបត្តិយ៉ាងកណ្តាល មានព្រះជន្មត្រឹមតែ ៧ ឆ្នាំ, បដិបត្តិយ៉ាងថូរ មានព្រះជន្មត្រឹមតែ ១៦ ឆ្នាំ ចំណែកព្រះនាឡកត្ថេរអង្គនេះ បានបដិបត្តិឱ្យបរិបូណ៌យ៉ាងឧក្រិដ្ឋ ព្រោះហេតុនោះ លោកមានព្រះជន្មត្រឹមតែ ៧ ខែ បានដឹងនូវការបរិនិព្វានរបស់ខ្លួន ក៏ស្រង់ទឹក ស្លៀកសំពត់កាសាយៈ ចងកាយពន្ធន៍ ដណ្តប់នូវសង្ឃាដិពីរជាន់ មានព្រះភក្ត្រឆ្ពោះទៅរកព្រះទសពល ថ្វាយបង្គំដោយបញ្ចង្គប្រដិស្ឋាន ផ្គងអញ្ជលី អាស្រ័យនូវហិង្គុលកបព៌ត ឈរបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ។ ព្រះមានព្រះភាគទ្រង់ជ្រាបនូវការបរិនិព្វានរបស់ព្រះថេរៈ បានយាងទៅកាន់ទីនោះ ជាមួយនឹងភិក្ខុសង្ឃ ធ្វើនូវសរីរកិច្ច ឱ្យភិក្ខុទាំងឡាយកាន់យកនូវធាតុទុកដាក់ក្នុងព្រះចេតិយ ហើយនិមន្ត

សម្រាប់ជាធម្មទាន

កោលាហលទាំង ៥ នោះ មង្គលកោលាហលរបស់ទេវតា និងមនុស្សទាំងឡាយ កើតឡើងហើយក្នុងលោក ។

កាលនោះ ទេវតា និងមនុស្សទាំងឡាយ នាំគ្នាជ្រើសយក ក៏មិនបានមង្គលទាំងឡាយ កន្លងទៅ ១២ ឆ្នាំ ទេវតាជាន់តាវត្តិង្សសមាគមគ្នា ក៏ជួយគ្នាគិតយ៉ាងនេះថា ម្ចាស់ផ្ទះ ក៏ជាប្រធានរបស់មនុស្សក្នុងផ្ទះ មេស្រុក ក៏ជាប្រធានរបស់អ្នកស្រុក ព្រះរាជា ក៏ជាប្រធានរបស់មនុស្សទាំងឡាយ សក្កទេវរាជ ជាកំពូលនៃទេវតាអង្គនេះ ក៏ជាអ្នកប្រសើរបំផុតរបស់ពួកយើង គឺអធិបតីរបស់ទេវលោកទាំងពីរ (ជាន់ចាតុម្មហារាជិកា និងជាន់តាវត្តិង្ស) ដោយបុណ្យ តេជះ ឥស្សរិយៈ និង បញ្ញា ។ ប្រសិនបើហេតុនោះមាន យើងគប្បីនាំគ្នា ទៅទូលសួរសេចក្តីនេះនឹងសក្កទេវរាជ ជាកំពូលនៃពួកទេវតាចុះ ។ ទេវតាទាំងនោះ ក៏នាំគ្នាទៅកាន់សម្នាក់ទេវរាជ ថ្វាយបង្គំសក្កទេវរាជជាកំពូលរបស់ទេវតា ដែលមានសរីរៈមានអាភរណៈប្រចាំព្រះអង្គ ដែលសមរម្យដល់ខណៈនោះ មានពួកអប្សរ ២៥០ កោដិចោមរោមប្រថាប់លើបណ្ឌុកម្ពលសិលាសនៈដ៏ប្រសើរ ក្រោមដើមបារិច្ឆត្តកៈ ហើយឈរក្នុងទីសមគួរទូលថា សូមប្រទានព្រះវរោកាស ព្រះអង្គអ្នកនិរទុក្ខ សូមទ្រង់ជ្រាបចុះ ឥឡូវនេះ មង្គលបញ្ហាកើតឡើងហើយ មួយពួកដែលពោល

---

យានជៀសចេញទៅ ឲចំណែកសេចក្តីរបស់ព្រះសូត្រនេះ មានសម្តែងក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ២៣៥ ។

ថា រូបដែលឃើញហើយជាមង្គល មួយពួកពោលថា សំឡេងដែលបានឮជាមង្គល មួយពួកពោលថា រឿងដែលបានដឹងហើយជាមង្គល បណ្ដាអ្នកទាំងនោះ ពួកខ្ញុំព្រះអង្គ និងពួកអ្នកឯទៀត មិនទាន់បានសម្រេចយកមួយណាទេ សូមព្រះអង្គមេត្តាព្យាករណ៍តាមការពិត ដល់ពួកខ្ញុំព្រះអង្គផងចុះ ។ សក្កទេវរាជ សូម្បីដោយប្រក្រតី ទ្រង់មានបញ្ញាទើបត្រាស់ថា រឿងមង្គលនេះកើតឡើងពីទីណាមុនគេ ។ ទូលថា បពិត្រសក្កទេវរាជ ពួកខ្ញុំព្រះអង្គស្ដាប់ពាក្យរបស់ទេវតាជាន់ចាតុម្មហារាជិកា តពីនោះពួកទេវតាជាន់ចាតុម្មហារាជិកា ក៏បានស្ដាប់ពាក្យរបស់អាកាសដ្ឋកទេវតា ពួកអាកាសដ្ឋកទេវតា បានស្ដាប់ពាក្យរបស់ភុម្មទេវតា ពួកភុម្មទេវតា ស្ដាប់ពាក្យរបស់ទេវតារក្សាមនុស្ស ពួកទេវតារក្សាមនុស្សពោលថា រឿងមង្គលកើតឡើងពីមនុស្សលោក ។

លំដាប់នោះ សក្កទេវរាជជាកំពូលនៃទេវតាត្រាស់សួរទេវតាទាំងនោះថា ព្រះសម្មាសម្ពុទ្ធ ប្រថាប់នៅទីណា ។ ទេវតាទាំងឡាយទូលថា ប្រថាប់នៅក្នុងមនុស្សលោក ។ ត្រាស់សួរថា មានអ្នកណាទូលសួរព្រះមានព្រះភាគអង្គនោះហើយឬ ។ ទូលថា មិនមានទេ ព្រះអង្គ ។ ត្រាស់ថា ម្នាលអ្នកនិរទុក្ខ ហេតុអ្វីហ្ន៎អ្នកទាំងឡាយ ទើបបោះបោលជុំភ្លើង ហើយមកតាមរកជុំភ្លើងអំពីអំពិលអំពែក ព្រោះហេតុអ្វី? អ្នកទាំងឡាយ ទើបកន្លងព្រះមានព្រះភាគ ដែលសម្ដែងមង្គលមិនមានសេសសល់ បែរជាយល់ថា គួរមកសាកសួរខ្ញុំ មកអ្នកនិរទុក្ខទាំងឡាយយើងនឹងទូលសួរព្រះមានព្រះភាគអង្គនោះ ពួកយើងប្រហែលបានការព្យាករណ៍បញ្ហា ដែល

មានសិរីពិតប្រាកដ ទើបមានទេវឱង្ការប្រើទេវបុត្រមួយអង្គថា អ្នកចូលទៅទូល សួរព្រះមានព្រះភាគចុះ ។ ទេវបុត្រអង្គនោះ ប្រដាប់ដោយគ្រឿងអលង្ការដ៏ សមរម្យដល់ខណៈនោះ រុងរោចន៍ដូចផ្លេកបន្ទោរ មានពួកទេវតាចោមរោម ទៅ កាន់វត្តជេតពនមហាវិហារ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរក្នុងទីសមគួរមួយ កាលទូលសួរមង្គលបញ្ហា ទើបពោលជាគាថាថា ពហូ ទេវា មនុស្សា ច ជាដើម។ នេះជាមូលហេតុឱ្យកើតមង្គលបញ្ហា ។

## ពហូ ទេវាតិ គាថា វណ្ណនា

## ការពណ៌នាគាថា ថា ពហូ ទេវា

ឥឡូវនេះ នឹងពណ៌នាសេចក្ដីនៃបទគាថា ។ សព្ទថា ពហូ សម្ដែងចំនួន មិនពិតប្រាកដ ព្រោះហេតុនោះ លោកទើបអធិប្បាយថា ច្រើនរយ ច្រើនពាន់ ច្រើនសែន ។ ឈ្មោះថា **ទេវៈ** ព្រោះលេង អធិប្បាយថា លេងជាមួយនឹងកាម គុណ ៥ ឬស្វាងស្វែងដោយពន្លឺរបស់ខ្លួន ។ ន័យម្យ៉ាងទៀត បទថា ទេវា បានដល់ **ទេវៈ**ទាំង ៣ គឺ សម្មតិទេព ឧបត្តិទេព និងវិសុទ្ធិទេព ដូចដែលលោកពោលថា ៖

បទថា ទេវា បានដល់ ទេព ៣ គឺ **សម្មតិទេព ឧបត្តិទេព វិសុទ្ធិទេព** ។ បណ្ដាទេពទាំង ៣ នោះ ព្រះរាជា ព្រះរាជនី ព្រះរាជកុមារ ឈ្មោះថា **សម្មតិទេព** ។ ទេពតាំងពីជាន់ចាតុម្មហារាជិកា និងខ្ពស់ជាងនោះ ឈ្មោះ **ឧបត្តិទេព** ។ ព្រះអរហន្ត តែម្យ៉ាងប៉ុណ្ណោះ ឈ្មោះ **វិសុទ្ធិទេព** ។

បណ្ដាទេពទាំង ៣ នោះ ក្នុងសូត្រនេះ លោកបំណងយកឧបត្តិទេព ។ ឈ្មោះថា មនុស្ស ព្រោះជាពូជរបស់មនុស្ស ។ ប៉ុន្តែ បុរាណាចារ្យពោលថា ឈ្មោះថា មនុស្ស ព្រោះជាអ្នកមានចិត្តខ្ពស់ ។ មនុស្សទាំងឡាយ នោះមាន ៤ គឺ អ្នកជម្ពូទ្វីប អ្នកអបរគោយានទ្វីប[១] អ្នកឧត្តរកុរុទ្វីប អ្នកបុព្វវិទេហទ្វីប ក្នុងសូត្រនេះ លោកបំណងយកមនុស្សអ្នកជម្ពូទ្វីប ។ ឈ្មោះថា មង្គល ព្រោះសត្វចម្រើនរុងរឿងដោយគុណទាំងនេះ អធិប្បាយថា សត្វដល់សេចក្ដី សម្រេច និងសេចក្ដីចម្រើន ។ បទថា អចិន្តយុំ ប្រែថា គិតហើយ ។ បទថា អាកង្ខមានា បានដល់បំណងប្រាថ្នាការចង់បាន ។ បទថា សោត្ថានំ ប្រែថា សិរីសួស្ដី លោកអធិប្បាយថា សេចក្ដីនៃធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងបរលោក ស្អាតស្រស់ល្អ ។ បទថា ព្រូហិ បានដល់ សម្ដែងប្រកាស ប្រាប់ បង្ហើប ចែក ធ្វើឱ្យងាយ ។ បទថា មង្គលំ បានដល់ ហេតុនៃការសម្រេច ហេតុនៃសេចក្ដីចម្រើន ហេតុនៃសម្បត្តិគ្រប់យ៉ាង ។ បទថា ឧត្តមំ បានដល់ វិសេសប្រសើរ នាំប្រយោជន៍សុខមកឱ្យដល់លោកទាំងពួង ដូចពោលមកនេះ ជាការពណ៌នាតាមលំដាប់ នៃបទគាថាទាំងឡាយ ។

---

១-ឈ្មោះទ្វីបធំមួយ ក្នុងមហាទ្វីបទាំង ៤ (សរសេរជា-គោយានៈក៏បាន ច្រើនហៅក្លាយជាអមរគោយាន សរសេរជាអមរគោយានៈក៏បាន) ។ វចនានុក្រមខ្មែរ ទំព័រ ១៦៤៤ ។

ចំណែកសេចក្ដីរួមមានដូច្នេះ ។ ទេវបុត្រនោះឯង ឃើញទេវតាក្នុងម៉ឺនចក្រវាឡ ជំនុំគ្នាក្នុងចក្រវាឡនេះ ព្រោះប្រាថ្នានឹងស្ដាប់មង្គលបញ្ហា នាំគ្នានិម្មិតអត្តភាពដ៏ល្អិត ១០ ខ្វះ ២០ ខ្វះ ៣០ ខ្វះ ៤០ ខ្វះ ៥០ ខ្វះ ៦០ ខ្វះ ៧០ ខ្វះ ៨០ ខ្វះ ឱ្យតូចឱកាសប៉ុនចុងខ្សាច់មួយ ឈរចោមរោមព្រះមានព្រះភាគដែលប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរ ដែលគេរៀបចំទុក បញ្ចេញរស្មីគ្របដណ្ដប់ទេវតាមានព្រហ្មទាំងអស់ ដោយសិរី និងតេជះ ហើយនិងបរិវិតក្កៈនៃចិត្តរបស់ពួកមនុស្សក្នុងជម្ពូទ្វីប ដែលមិនបានមកប្រជុំក្នុងសម័យនោះ ដោយចិត្តព្រះអង្គឯង ទើបពោលគាថា ដើម្បីដកកូនសរ គឺសេចក្ដីសង្ស័យរបស់ទេវតា និងមនុស្សទាំងពួងថា ៖

ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ ។

ទេវតា និងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសេចក្ដីសួស្ដី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រាប់នូវមង្គលដ៏ឧត្ដម[១] ។

បពិត្រព្រះមានព្រះភាគ ព្រះអង្គត្រូវពួកខ្ញុំព្រះអង្គទូលសួរហើយ ដោយអនុមតិរបស់ទេវតាទាំងនោះ និងអនុគ្រោះមនុស្សទាំងឡាយ មង្គលឯណាដែល

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ៤ ។

ខ្ពង់ខ្ពស់បំផុត ព្រោះនាំមកនូវប្រយោជន៍សុខដល់ខ្ញុំព្រះអង្គទាំងអស់គ្នា ដោយចំណែកមួយសូមព្រះមានព្រះភាគសម្តែងមង្គលនោះ ដល់ពួកខ្ញុំព្រះអង្គទាំងឡាយផង ។

អសេវនាចាតិ គាថាវណ្ណនា

**ពណ៌នាគាថា ថា អសេវនា ច**

ព្រះមានព្រះភាគ ទ្រង់ស្តាប់ពាក្យទេវបុត្រនោះ យ៉ាងនេះហើយ ទើបត្រាស់ព្រះគាថាថា អសេវនា ច ពាលានំ ជាដើម ។ ក្នុងគាថានោះ បទថា អសេវនា បានដល់ ការមិនសេពគប់ មិនចូលទៅជិត ។

បទថា ពាលានំ សេចក្តីថា ឈ្មោះថា ពាល ព្រោះជាទីនៅដកដង្ហើម អធិប្បាយថា នៅដោយត្រឹមតែដកដង្ហើមចូល-ចេញ មិននៅដោយភាព ជាអ្នកនៅដោយបញ្ញា ឈ្មោះថា ពាលទាំងអស់ ។

បទថា បណ្ឌិតានំ សេចក្តីថា ឈ្មោះថា បណ្ឌិត ព្រោះធ្វើដំណើរទៅ អធិប្បាយថា ធ្វើដំណើរទៅដោយគតិ គឺការស្គាល់នូវប្រយោជន៍ ដែលជាបច្ចុប្បន្ន និងបរលោក ឈ្មោះថា បណ្ឌិតទាំងអស់ ។

បទថា សេវនា បានដល់ ការគប់ ការចូលជិត ការមានបណ្ឌិតនោះជាសំឡាញ់ មានបណ្ឌិតនោះជាមិត្ត ការព្រមព្រៀងដោយបណ្ឌិតនោះ ។

បទថា បូជា បានដល់ សក្ការៈ គោរពរាប់អាន ការថ្វាយបង្គំ ។

បទថា បូជនេយ្យានំ ប្រែថា អ្នកគួរបូជា ។

*បទថា* ***ឯតម្មង្គលមុត្តមំ*** *សេចក្តីថា ព្រះមានព្រះភាគទ្រង់ប្រមូលការមិនសេពគប់បុគ្គលពាល ១ ការបុគ្គលគប់បណ្ឌិត ១ ការបូជាអ្នកដែលគួរបូជា ១ ទាំងអស់ទើបត្រាស់ថា* ***ឯតម្មង្គលមុត្តមំ*** *ៗ លោកអធិប្បាយថា ពាក្យណាលោកសួរថា សូមទ្រង់សម្តែងនូវមង្គលដ៏ឧត្តម ទើបលោកកាន់យកពាក្យនោះថា មង្គលដ៏ឧត្តម ក្នុងសេចក្តីមុន ៗ នេះជាការពណ៌នាបទនៃគាថានេះ ៗ*

*ចំណែកការពណ៌នាសេចក្តីនៃបទនោះ គប្បីជ្រាបដូច្នេះ ព្រះមានព្រះភាគទ្រង់ស្តាប់ពាក្យរបស់ទេវបុត្រនោះយ៉ាងនេះហើយ ទើបត្រាស់ព្រះគាថា នេះថា* អសេវនា ច ពាលានំ ជាដើម ៗ

*ក្នុងគាថានោះ គាថាមាន ៤ គឺ* ***បុច្ឆិតគាថា អបុច្ឆិតគាថា សានុសន្ធិកគាថា អននុសន្ធិកគាថា*** *ៗ*

*បណ្តាគាថាទាំង ៤ នោះ គាថាដែលត្រូវអ្នកសួរ សួរហើយ ទើបត្រាស់ឈ្មោះថា* ***បុច្ឆិតគាថា*** *ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា* “បុច្ឆាមិ តំ គោតម ភូរិបញ្ញ កថង្ករោ សាវកោ សាធុ ហោតិ *បពិត្រព្រះគោតម ទ្រង់មានព្រះបញ្ញាដូចជាផែនដី ខ្ញុំសូមក្រាបទូលសួរព្រះអង្គ បុគ្គលដែលចេញចាកផ្ទះ.... ប្រតិបត្តិ*

ដូចម្តេចទើបហៅថាសាវកល្អ”[១] ។ ហើយនឹងប្រយោគថា “កាថំ នុ ត្វំ មារិស ឱឃមតរិ បពិត្រព្រះអង្គអ្នកនិរទុក្ខ ព្រះអង្គឆ្លងអន្លង់ដោយហេតុដូចម្តេចហ្ន៎”។

គាថាដែលព្រះអង្គមិនមានគេសួរ ប៉ុន្តែត្រាស់ដោយអធ្យាស្រ័យរបស់ព្រះអង្គឯងឈ្មោះថា **អបុច្ឆិតគាថា** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “យំ បរេ សុខតោ អាហុ តទរិយា អាហុ ទុក្ខតោ ពួកជនពាលដទៃពោលនូវវត្ថុកាមណាថាជាសុខ ព្រះអរិយៈទាំងឡាយពោលនូវវត្ថុកាមនោះថាជាទុក្ខ”[២] ។ គាថារបស់ព្រះពុទ្ធ ទាំងឡាយសូម្បីទាំងអស់ ឈ្មោះថា **សានុសន្ធិកគាថា** ព្រោះបាលីថា សនិទានាហំ ភិក្ខវេ ធម្មំ ទេសេស្សាមិ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែង ធម៌សមតាមហេតុ ។ ដែលឈ្មោះថា អននុសន្ធិកគាថា គាថាមិនមានហេតុ មិនមានក្នុងសាសនានេះ ។ ក៏បណ្តាគាថាទាំងនេះ ដូចពោលមកនេះគាថា នេះឈ្មោះថា បុច្ឆិតគាថា ព្រោះជាគាថាដែលព្រះមានព្រះភាគ ត្រូវទេវបុត្រទូលសួរហើយ ទើបត្រាស់ឆ្លើយ ។ ក៏គាថានេះ ប្រាប់មនុស្ស ដែលមិនគួរសេពគប់ បណ្តាមនុស្សដែលគួរសេពគប់ និងមិនគួរសេពគប់ ហើយទើបប្រាប់មនុស្សដែលគួរសេពគប់ ប្រៀបដូចបុរសដែលឆ្លាតស្គាល់ផ្លូវស្គាល់ ទាំងមិនមែនផ្លូវត្រូវគេសួរដល់ផ្លូវ ទើបប្រាប់ផ្លូវដែលគួរវៀរចាកជាដំបូងហើយប្រាប់ផ្លូវ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ១២២ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ២៦៣ ។

ដែលគួរកាន់យកជាខាងក្រោយយ៉ាងនេះថា ក្នុងទីត្រង់នោះមានផ្លូវបំបែកពីរ ។ បណ្ដាផ្លូវបំបែកពីរនោះ ពួកអ្នកចូរវៀរចាកផ្លូវខាងឆ្វេង ហើយកាន់យកផ្លូវខាងស្ដាំ ដូច្នោះ។ ក៏ព្រះមានព្រះភាគប្រៀបដូចបុរសដ៏ឆ្លាតក្នុងផ្លូវ ដូចដែលត្រាស់ទុកថា៖

ម្នាលតិស្ស: ពាក្យថាបុរសដែលឆ្លាតក្នុងផ្លូវនេះជាឈ្មោះ របស់តថាគត អរហន្តសម្មាសម្ពុទ្ធ មែនពិត តថាគតអរហន្តសម្មាសម្ពុទ្ធនោះ ដឹងលោកនេះ លោកដទៃ ដឹងទីមានមច្ចុ ទាំងដឹងទីដែលមិនមានមច្ចុ ស្គាល់បណ្ដាញនៃមារ ទាំងស្គាល់ទីដែលមិនមានបណ្ដាញនៃមារ ។

ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគកាលត្រាស់ប្រាប់ដល់បុគ្គលដែលមិនគួរសេពគប់ជាមុន ទើបត្រាស់ថា ការមិនសេពគប់បុគ្គលពាល ការសេពគប់បណ្ឌិត តាមពិត បុគ្គលពាលទាំងឡាយ មិនគួរសេពគប់ មិនគួរចូលទៅជិត ដូចផ្លូវដែលគួរវៀរបង់ តពីនោះ ក៏គួរសេពគប់ គួរចូលទៅជិតបណ្ឌិត ដូចផ្លូវដែលគួរកាន់យក ។ មានអ្នកសួរពោលថា ក៏ព្រោះហេតុអ្វី ? ព្រះមានព្រះភាគកាលត្រាស់មង្គល ទើបត្រាស់ការមិនសេពគប់បុគ្គលពាល និងការសេពគប់បណ្ឌិតជាមុន សូមពន្យល់ដូច្នេះ ព្រោះហេតុតែពួកទេវតា និងមនុស្សប្រកាន់ការយល់ឃើញថា មង្គលក្នុងវត្ថុដែលឃើញហើយជាដើមនេះ ដោយការសេពគប់បុគ្គលពាល ទាំងការសេពគប់បុគ្គលពាលនោះ ក៏មិនមែនជាមង្គលដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់តិះដៀលការសេពគប់នឹងបុគ្គល ដែលមិនមែនជាកល្យាណមិត្ត ដែលបំបាក់ប្រយោជន៍លោកនេះ និងលោកខាងមុខ ហើយទ្រង់

សរសើរការសេមាគមជាមួយកល្យាណមិត្ត ដែលឱ្យសម្រេចប្រយោជន៍ ក្នុងលោកទាំងពីរ ទើបត្រាស់ការមិនសេពគប់បុគ្គលពាល និងការសេពគប់បណ្ឌិតជាមុនដល់ទេវតានិងមនុស្សទាំងឡាយ ។

បណ្តាបុគ្គលពាល និងបណ្ឌិតទាំងឡាយនោះ សត្វទាំងឡាយណាដែលប្រកបដោយអកុសលកម្មបថ មានបាណាតិបាតជាដើម ឈ្មោះថា **ពាល** ។ បុគ្គលពាលទាំងនោះ គប្បីជ្រាបបានដោយអាការៈទាំង ៣ ដូចដែលព្រះមានព្រះភាគត្រាស់ទុកក្នុងព្រះសូត្រថា "ម្នាលភិក្ខុទាំងឡាយ ពាលលក្ខណៈ របស់បុគ្គលពាលនេះ មាន ៣ យ៉ាង"[១] ។ម្យ៉ាងទៀត គ្រូទាំង ៦ មានបូរណកស្សបជាដើម និងសត្វដទៃ ប្រាកដដូច្នោះទាំងនេះគឺ ទេវទត្ត កោកាលិកៈ កដមោទកៈ តិស្ស-ខណ្ឌាទេវីបុត្រ សមុទ្ទទត្ត នាងចិញ្ចមាណវិកាជាដើម និងបងប្រុសរបស់ទីឃវិទៈ កាលពីអតីតគប្បីជ្រាបថា **ពាល** ។

ពាលទាំងនោះ រមែងញុំាងខ្លួនឯងនិងបុគ្គលដែលធ្វើតាមពាក្យរបស់ខ្លួនឱ្យវិនាសដោយទិដ្ឋិគតៈ ការយល់ឃើញដែលខ្លួនកាន់យកមិនល្អ ដូចផ្ទះដែលត្រូវភ្លើងឆេះ។ដូចបងប្រុសរបស់ទីឃវិទៈ ដួលដេកផ្ងារ ដោយអត្តភាពប្រមាណ ៦០ យោជន៍ ឆេះនៅក្នុងមហានរកដល់ទៅ ៤ ពុទ្ធន្តរ ហើយដូចត្រកូល ៥០០ ត្រកូល ដែលពេញចិត្តទិដ្ឋិ ការយល់ឃើញរបស់បងប្រុសរបស់ទីឃវិទៈនោះ

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៤១ ទំព័រ ៤ ។

ចូលទៅនៅរួមជាសម្លាញ់របស់បង ប្រសទីយវិទៈនោះឯង តេះនៅក្នុងមហានរក ដូច្នោះ ។ សមដូចព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា ៖

"ម្នាលភិក្ខុទាំងឡាយ ភ្លើងតែងឆេះរាលអំពីផ្ទះបបុស ឬផ្ទះស្មៅមកឆេះផ្ទះកំពូលទាំងឡាយ ដែលគេលាបទាំងខាងក្នុងទាំងខាងក្រៅ មិនមានខ្យល់ចូល មានសន្ទះទ្វារដ៏ជិតស្និទ្ធ មានបង្អួចបិទជិតបាន ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភ័យទាំងឡាយណាមួយកើតឡើង ភ័យទាំងអស់នោះតែងកើតឡើងអំពីជនពាល មិនមែនកើតបណ្ឌិតទេ ឧបទ្រពទាំងឡាយណាមួយកើតឡើង ឧបទ្រពទាំងអស់នោះតែងកើតឡើង អំពីជនពាលមិនមែនកើតអំពីបណ្ឌិតទេ ឧបស័គ្គទាំងឡយណាមួយកើតឡើង ឧបស័គ្គទាំងអស់នោះ តែងកើតអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ក៏ដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ជនពាលប្រកបដោយភ័យដ៏ពន្លឹក បណ្ឌិតមិនមានភ័យដ៏ពន្លឹកទេ ជនពាលប្រកបដោយឧបទ្រពបណ្ឌិតមិនមានឧបទ្រពទេ ជនពាលប្រកបដោយឧបស័គ្គ បណ្ឌិតមិនមានឧបស័គ្គទេ"[១] ។

មយ៉ាងទៀត ពាលប្រៀបដូចត្រីស្អុយ អ្នកដែលសេពគប់ពាលនោះ ក៏ប្រៀបដូចកញ្ចប់ស្លឹកឈើដែលខ្ចប់ត្រីស្អុយ រមែងប្រទះនឹងភាវៈដែលវិញ្ញូជនបោះបង់ចោល និងស្អប់ខ្ពើម ។

សមដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៤១ ទំព័រ ២ ។

ឫតិមច្ឆំ កុសគ្គេន យោ នរោ ឧបនយ្ហតិ
កុសាបិ ឫតី វាយន្តិ ឯវំ ពាលូបសេវនា ។

*ជនណាខ្ចប់ត្រីស្អុយដោយស្បូវក្លាំង ស្បូវក្លាំងរបស់ជននោះទៅជាមានក្លិនស្អុយផ្សាយទៅ យ៉ាងណាមិញ ការសេពនឹងបុគ្គលពាលក៏យ៉ាងនោះដែរ[១] ។*

*ម្យ៉ាងទៀត កាលស្តេចសក្កៈកំពូលអស់ពួកទេព ប្រទានពរដល់អកិត្តិបណ្ឌិត ក៏ពោលយ៉ាងនេះថា ៖*

ពាលំ ន បស្សេ ន សុណេ ន ច ពាលេន សំវសេ
ពាលេនល្លាបសល្លាបំ ន ករេ ន ច រោចយេ ។

*អាត្មាសូមកុំឱ្យជួបនឹងមនុស្សពាល សូមកុំឱ្យឮដំណឹងមនុស្សពាល សូមកុំឱ្យនៅរួមនឹងមនុស្សពាល សូមកុំឱ្យបានធ្វើ ទាំងកុំឱ្យពេញចិត្តនឹងការចរចាទៅមកនឹងមនុស្សពាល[២] ។*

*សក្កទេវរាជត្រាស់សួរថា ៖*

កិន្នុ តេ អករំ ពាលោ វទ កស្សប ការណំ
កេន កស្សប ពាលស្ស ទស្សនំ នាភិកង្ខសិ ។

*មនុស្សពាលបានធ្វើអ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោកមិនប្រាថ្នាជួបមនុស្សពាល[១] ។*

---

*១-សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក លេខ ៦៣ ទំព័រ ១៧ ។*

*២-២-៣- សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក លេខ ៥៩ ទំព័រ ២៨៧ ។*

កិត្តិបណ្ឌិតឆ្លើយថា ៖

អនយំ នយតិ ទុម្មេធោ អធុរាយំ និយុញ្ជតិ
ទុន្នយោ សេយ្យសោ ហោតិ សម្មា វុត្តោ បកុប្បតិ
វិនយំ សោ ន ជានាតិ សាធុ តស្ស អទស្សនំ ។

បុគ្គលពាល រមែងណែនាំនូវអំពើមិនគួរណែនាំ រមែងប្រកបក្នុងកិច្ចមិនមែនជាធុរៈ ការណែនាំទៅរកអាក្រក់ជាការប្រសើរ (របស់បុគ្គលពាលនោះ) បុគ្គលពាលបើទុកជាគេនិយាយត្រូវក៏នៅតែខឹង បុគ្គលពាលរមែងមិនដឹងច្បាប់អ្វីទេ ការមិនជួបប្រទះនឹងបុគ្គលពាលនោះជាការប្រពៃ(២) ។

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់តិះដៀលការសេពគប់បុគ្គលពាល ដោយអាការៈទាំងពួងយ៉ាងនេះ ទើបត្រាស់ថាការមិនសេពគប់បុគ្គលពាលជាមង្គល ឥឡូវនេះកាលនឹងទ្រង់សរសើរការសេពគប់បណ្ឌិត ទើបត្រាស់ថា ការសេពគប់បណ្ឌិតទើបជាមង្គល ។

បណ្ដាសត្វទាំងឡាយ សត្វទាំងឡាយណាប្រកបដោយកុសលកម្មបថ ១០ មានចេតនា វៀរចាកបាណាតិបាតជាដើម ឈ្មោះថា **បណ្ឌិត** ។

បណ្ឌិតទាំងឡាយនោះគឺគេគប្បីដឹងបានដោយអាការៈទាំង ៣ ដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ទុកក្នុងព្រះសូត្រថា “ម្នាលភិក្ខុទាំងឡាយ

លក្ខណៈ នៃបណ្ឌិតមាន ៣ ពួកនេះ" ។ ម្យ៉ាងទៀត ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអសីតិមហាសាវក ព្រះសាវកឯទៀតរបស់តថាគត និងបណ្ឌិត មានសុនេត្តសាស្តា មហាគោវិន្ទសាស្តា ព្រះវិធុរបណ្ឌិត សរភង្គតាបស ព្រះមហោសថ សុតសោមបណ្ឌិត ព្រះបាទនេមិរាជ អយោឃរកុមារ និងអកិត្តិបណ្ឌិតជាដើម គប្បីជ្រាបថាជា **បណ្ឌិត** ។

បណ្ឌិតទាំងឡាយនោះ ជាអ្នកកម្ចាត់ភ័យឧបទ្រព និងឧបស័គ្គបាន ក្នុងវេលាមានភ័យ បីដូចជាដួងប្រទីបក្នុងវេលាងងឹត ហាក់បីដូចជាបានបាយទឹកជាដើមក្នុងវេលាត្រូវទុក្ខមានការស្រេកឃ្លានជាដើមគ្របសង្កត់ ។ ពិតមែនហើយ ព្រោះការអាស្រ័យព្រះតថាគត ទើបពួកទេវតា និងមនុស្សរាប់មិនបានប្រមាណ មិនកើត នាំគ្នាសម្រេចធម៌ជាទីអស់ទៅនៃអាសវៈ ស្ថិតនៅក្នុងព្រហ្មលោក ស្ថិតនៅក្នុងទេវលោក កើតក្នុងសុគតិសួគ៌ ។ ត្រកូល ៨ ម៉ឺនត្រកូល ធ្វើចិត្តឱ្យជ្រះថ្លាក្នុងព្រះសារីបុត្តត្ថេរៈ និងផ្គត់ផ្គង់ព្រះថេរៈដោយបច្ច័យ ៤ ក៏ទៅកើតក្នុងឋានសួគ៌ ។ ត្រកូលទាំងឡាយធ្វើចិត្តឱ្យជ្រះថ្លាក្នុងព្រះមហាសាវកទាំងឡាយ រាប់តាំងពីព្រះមោគ្គល្លាន ព្រះមហាកស្សបៈជាដើមទៅ យ៉ាងនោះដូចគ្នា ។ សាវកទាំងឡាយរបស់សុនេត្តសាស្តា អ្នកខ្លះក៏កើតក្នុងព្រហ្មលោក អ្នកខ្លះក៏បានជាសម្លាញ់របស់ទេវតា ជាន់បរនិម្មិតវសវត្តី ។ល។ អ្នកខ្លះក៏បានជាសម្លាញ់នៃគហបតិមហាសាល ។ សូម្បីព្រះដ៏មានព្រះភាគជាម្ចាស់ ក៏បានត្រាស់ទុកដូច្នេះថា

“ម្នាលភិក្ខុទាំងឡាយ ភ័យមិនមានអំពីបណ្ឌិត ឧបទ្រពមិនមានអំពីបណ្ឌិត ឧបស័គ្គមិនមានអំពីបណ្ឌិតទេ”[១] ។ ម្យ៉ាងវិញទៀត បណ្ឌិតដូចជារបស់ក្រអូប មាន ក្រឹស្នានិងផ្កាឈើជាដើម អ្នកដែលសេពគប់បណ្ឌិតក៏ដូចជាកញ្ចប់ស្លឹកឈើ ដែលខ្ចប់របស់ក្រអូប មានក្រស្នា និងផ្កាឈើជាដើម ថែមទាំងប្រសព្វភាវៈដែលវិញ្ញូជនកោតសរសើរ និងពេញចិត្ត ។

សូម្បីព្រះដ៏មានព្រះភាគជាម្ចាស់ក៏ត្រាស់ទុកដូច្នេះថា ៖

តគរញ្ច បលាសេន យោ នរោ ឧបនយ្ហតិ
បត្តាបិ សុរភី វាយន្តិ ឯវំ ធីរូបសេវនា ។

នរជនណាខ្ចប់ក្រស្នាដោយស្លឹកឈើ ស្លឹកឈើរបស់នរជននោះទៅជាមានក្លិនប្រអូបផ្សាយទៅ យ៉ាងណាមិញ ការសេពបុគ្គលជាអ្នកប្រាជ្ញ ក៏យ៉ាងនោះដែរ[២] ។

ម្យ៉ាងទៀត កាលស្តេចសក្កៈជាកំពូលអស់ពួកទេពប្រទានពរដល់អកិត្តិបណ្ឌិតក៏ពោលថា ៖

ធីរំ បស្សេ សុណេ ធីរំ ធីរេន សហ សំវសេ
ធីរេនល្លាបសល្លាបំ តំ ករេ តញ្ច រោចយេ ។

អាត្មាសូមឱ្យជួបប្រទះអ្នកប្រាជ្ញ សូមឱ្យស្តាប់អ្នកប្រាជ្ញ
សូមឱ្យនៅរួមជាមួយនឹងអ្នកប្រាជ្ញ សូមឱ្យបានធ្វើ ទាំងសូម

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៤១ ទំព័រ ២ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក លេខ ៦៣ ទំព័រ ១៧ ។

ឱ្យបានចូលចិត្តនឹងការចរចាទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ[១] ។

ស្តេចសក្កៈកំពូលអស់ទេវតាត្រាស់សួរថា ៖

កិន្នុ តេ អករំ ធីរោ  វទកស្សប ការណំ
កេន កស្សប ធីរស្ស  ទស្សនំ អភិកង្ខសិ ។

អ្នកប្រាជ្ញបានធ្វើប្រយោជន៍អ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វីបានជាលោកចង់ជួបប្រទះអ្នកប្រាជ្ញ [២] ។

អកិត្តិបណ្ឌិតឆ្លើយថា ៖

នយំ នយតិ មេធាវី  អធុរាយំ នយុញ្ជតិ
សុនយោ សេយ្យសោ ហោតិ  សម្មាវុត្តោ នកុប្បតិ
វិនយំ សោ បជានាតិ  សាធុ តេន សមាគមោ។

អ្នកប្រាជ្ញ រមែងណែនាំនូវហេតុ ដែលគួរដឹកនាំ រមែងមិនប្រកបក្នុងកិច្ចដែលមិនមែនជាធុរៈ ការដឹកនាំល្អ ជាការប្រសើរ ( របស់អ្នកប្រាជ្ញនោះ ) អ្នកប្រាជ្ញ បើគេនិយាយត្រូវហើយរមែងមិនក្រោធ អ្នកប្រាជ្ញនោះ រមែងចេះដឹងច្បាប់ ការសេពគប់ជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃ[៣] ។

---

១-៣-សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក លេខ ៥៩ ទំព័រ ២៨៨ ។

៣-សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក លេខ ៥៩ ទំព័រ ២៨៨ ។

កាលដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សរសើរការសេពគប់បណ្ឌិតដោយធម៌ទាំងពួងយ៉ាងនេះហើយ ទើបទ្រង់ត្រាស់ថា ការសេពគប់បណ្ឌិត ជាមង្គល ។ ឥឡូវនេះ កាលនឹងទ្រង់សរសើរការបូជាបុគ្គលដែលចូលដល់ភាពជាបុគ្គលដែលគួរបូជាតាមលំដាប់ ដោយការមិនសេពគប់បុគ្គលពាល និងការសេពគប់បណ្ឌិតនោះ ទើបទ្រង់ត្រាស់ថា បូជា ច បូជនេយ្យានំ មង្គលំ ការបូជា អ្នកដែលគួរបូជាជាមង្គល ។ ព្រះដ៏មានព្រះភាពជាម្ចាស់ ឈ្មោះថា បូជនេយ្យ ព្រោះទ្រង់វៀរចាកទោសគ្រប់យ៉ាង និងទ្រង់ប្រកបដោយគុណគ្រប់យ៉ាងហើយ បន្ទាប់ពីនោះ គឺព្រះបច្ចេកពុទ្ធ និងព្រះអរិយសាវកទាំងឡាយ ឈ្មោះថា បូជនេយ្យ ។ ពិតហើយ ការបូជាបូជនេយ្យបុគ្គលទាំងឡាយនោះ សូម្បីតិចតួចក៏ជាប្រយោជន៍សុខរហូតអស់កាលវែង ។ ក៏ក្នុងសេចក្តីនេះ មានរឿងសុមនមាលាការ និងនាងមល្លិកាជាដើមជាឧទាហរណ៍ ។ ក្នុងពីររឿងនោះ នឹងពោលតែរឿងមួយ ល្មមទុកជាឧទាហរណ៍ ៖

មានសេចក្តីថា ព្រឹកថ្ងៃមួយព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ស្លៀកស្បង់ និងចីវរប្រដាប់ដោយបាត្រ ស្តេចយាងចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ខណៈនោះនាយមាលាការឈ្មោះសុមនៈកំពុងដើរកាន់ផ្កា សម្រាប់ថ្វាយព្រះបាទពិម្ពិសារមគធសេនយរាជ បានឃើញព្រះដ៏មានព្រះភាគយាងដល់ទ្វារក្រុង ឃើញសម្បុរផូរផង់គួរឱ្យជ្រះថ្លា ដែលប្រកបដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០ ប្រការ រុងរឿងដោយពុទ្ធសិរី ពេលដែលឃើញហើយក៏គិតថា

ព្រះរាជាទ្រង់ទទួលផ្កាឈើនេះហើយ ក៏នឹងគប្បីប្រទានទ្រព្យ ១០០ ឬក៏ ១០០០ ក៏ការធ្វើដូច្នោះ គឺគប្បីបានសេចក្តីសុខត្រឹមតែលោកនេះប៉ុណ្ណោះ តែការបូជាព្រះដ៏មានព្រះភាគជាម្ចាស់ រមែងមានផលរាប់មិនបានប្រមាណមិនកើត នាំប្រយោជន៍សុខមកឱ្យរហូតអស់កាលវែង ណ្ហើយចុះយើងនឹងបូជាព្រះដ៏មាន-ព្រះភាគជាម្ចាស់ ដោយផ្កាឈើទាំងឡាយនេះ ដូច្នេះហើយ គាត់ក៏មានចិត្តជ្រះថ្លាចាប់ផ្កាឈើមួយក្តាប់បាចទៅចំពោះមុខព្រះដ៏មានព្រះភាគ ផ្កាឈើទាំងឡាយនោះអណ្តែតទៅលើអាកាស ប្រតិស្ឋានជាពិដាននៅលើព្រះដ៏មានព្រះភាគជាម្ចាស់ ។ នាយមាលាការឃើញអានុភាពនោះ ក៏មានចិត្តជ្រះថ្លាក្រៃលែងឡើង ទើបបាចផ្កាឈើទៅមួយក្តាប់ទៀត សូម្បីផ្កាឈើទាំងនោះក៏ទៅប្រតិស្ឋាន ជារនាំងបាំង ។ នាយមាលាការបាចផ្កាឈើទៅ ៤ ក្តាប់ យ៉ាងនេះ សូម្បីផ្កាឈើទាំងអស់នោះ ក៏ទៅប្រតិស្ឋានជាផ្ទះកំពូលបាំងជុំវិញព្រះដ៏មានព្រះភាគ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ប្រថាប់នៅក្នុងផ្ទះកំពូលនោះ មហាជនក៏មកប្រជុំគ្នា ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទតព្រះនេត្រឃើញនាយមាលាការ ក៏ទ្រង់ធ្វើអាការៈញញឹមឱ្យប្រាកដឡើង ។ ព្រះអានន្ទត្ថេរ ក៏ទូលសួរអំពីហេតុ ដែលទ្រង់ញញឹមដោយគិតថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយ មិនមានហេតុ មិនមានបច្ច័យនឹងមិនទ្រង់ញញឹមឱ្យប្រាកដទេ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ថា អានន្ទ នាយមាលាការម្នាក់នេះនឹងត្រាច់រង្គត់ទៅក្នុងឋានទេវលោក និងមនុស្សលោកអស់សែនកប្ប ដោយអានុភាពនៃការបូជានេះ ហើយក្នុងទីបំផុតក៏បានជា

*ព្រះបច្ចេកពុទ្ធ ព្រះនាមថា* ***សុមនិស្សរៈ*** *។ ត្រាស់ចប់ ក៏ត្រាស់ព្រះគាថានេះដើម្បីទ្រង់សម្ដែងធម៌ថា ៖*

តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ

*បុគ្គលធ្វើកម្មណាហើយ រមែងមិនក្ដៅក្រហាយ ឬដល់នូវ*
*សេចក្ដីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា*
*កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អ[១] ។*

*ចប់គាថានោះសត្វ ៨៤.០០០ បានសម្រេចធម៌ ។ ការបូជាបូជនេយ្យបុគ្គលទាំងអស់នោះសូម្បីបន្តិចបន្តួចក៏គប្បីជ្រាបថា មានប្រយោជន៍សុខអស់កាលជាយូរអង្វែង ដោយប្រការដូច្នេះ ។*

*ក៏ការបូជានោះជាអាមិសបូជា នឹងចាំបាច់ពោលទៅថ្វីក្នុងបដិបត្តិបូជា ព្រោះកុលបុត្រណា បូជាព្រះដ៏មានព្រះភាគជាម្ចាស់ ដោយការទទួលសរណគមន៍ និងសិក្ខាបទ ដោយការសមាទានអដ្ឋង្គឧបោសថ និងដោយគុណទាំងឡាយរបស់ខ្លួនមានបារិសុទ្ធិសីល ៤ ជាដើម នរណាទៅហ្ន៎នឹងពណ៌នាផលនៃការបូជារបស់កុលបុត្រនោះបាន ។ ត្បិតថា កុលបុត្រទាំងអស់នោះលោកពោលថា បូជាព្រះតថាគតដោយការបូជាយ៉ាងក្រៃលែង ដូចជាព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា៖*

---

*១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៣៥ ។*

"យោ ខោ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ ។ ម្នាលអានន្ទ បុគ្គលណាមួយទោះបីភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែងប្រតិបត្តិតាមធម៌ បុគ្គលនោះឈ្មោះថា ធ្វើសក្ការៈ គោរពរាប់អានបូជាតថាគតដោយ គ្រឿងបូជាដ៏ឧត្តម"[១] ។

សូម្បីភាពនៃការបូជាព្រះបច្ចេកពុទ្ធ និងព្រះអរិយសាវក ក៏នាំមកនូវប្រយោជន៍សុខ គប្បីជ្រាបតាមន័យនេះ ។

ម្យ៉ាងទៀត គ្រហស្ថគប្បីជ្រាបបូជនេយ្យបុគ្គលក្នុងសេចក្តីនេះយ៉ាងនេះគឺ អ្នកចម្រើនដោយវ័យ ទាំងបងប្រុសទាំងស្រី ឈ្មោះថា បូជនេយ្យបុគ្គល របស់ប្អូន មាតាបិតាជាបូជនេយ្យបុគ្គលរបស់បុត្រ ស្វាមី ឪពុកក្មេក ម្តាយក្មេកជាបូជនេយ្យ-បុគ្គលរបស់ស្រ្តីមានប្តីទាំងឡាយ ដ្បិតថា ការបូជាបូជនេយ្យបុគ្គលទាំងអស់នោះជាមង្គលទាំងអស់ ព្រោះរាប់ថាជាកុសលធម៌ និងព្រោះជាហេតុនៃការចម្រើនអាយុជាដើម ព្រះដ៏មានព្រះភាគជាម្ចាស់ មានព្រះពុទ្ធតម្រាស់ទុកដូច្នេះថា៖

១-សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ លេខ ១៦ ទំព័រ ២៩១ ។

"សត្វទាំងនោះក៏ជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ និងជាអ្នកប្រព្រឹត្តកោតក្រែងត្រកូលរៀបច្បង ប្រព្រឹត្តសមាទាននូវកុសលធម៌នេះ ក៏បានចម្រើនអាយុ ចម្រើនពណ៌សម្បុរឡើងវិញ"[១] ។

ឥឡូវនេះ ព្រោះហេតុដែលខ្ញុំតាំងមាតិកាទុកថា សម្ពដ្ឋានជាកន្លែងកើតមង្គល ហើយកំណត់មង្គលនោះនឹងពន្យល់សេចក្តីនៃមង្គលនោះដូច្នោះ ទើបសុំពន្យល់ដូច្នេះ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់មង្គលនៃគាថានេះទុក ៣ មង្គលគឺ ការមិនសេពគប់បុគ្គលពាល ការសេពគប់បុគ្គលជាបណ្ឌិត និងការបូជាចំពោះបុគ្គលដែលគួរបូជា ដោយប្រការដូច្នេះ ។ បណ្តាមង្គលទាំង ៣ នោះ គប្បីជ្រាបថាការមិនសេពគប់បុគ្គលពាល ឈ្មោះថាជាមង្គល ព្រោះជាហេតុនៃប្រយោជន៍របស់លោកទាំង ២ ហេតុការពារភ័យមានភ័យកើតពីការសេពគប់បុគ្គលពាលជាបច្ច័យជាដើម ការសេពគប់បណ្ឌិត និងការបូជាបុគ្គលដែលគួរបូជា ឈ្មោះថាជាមង្គល ព្រោះជាហេតុនៃនិព្វាន និងសុគតិ តាមន័យដែលពោលទុកហើយក្នុងការពណ៌នាសេចក្តីបន្ថែម នៃផលរបស់ការសេពគប់បណ្ឌិត និងការបូជាបុគ្គលដែលគួរបូជានោះឯង ។ ប៉ុន្តែខ្ញុំនៅ មិនទាន់បានសម្តែងមាតិកា តពីនេះទៅនឹងកំណត់សេចក្តីដែលជាមង្គលយ៉ាងនេះ ទើបនឹងពន្យល់សេចក្តីនោះ ដែលជាមង្គល ។

---

១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៨ ទំព័រ ១៥០ ។

**ចប់ការពណ៌នាសេចក្ដីនៃគាថានេះថា** អសេវនា ច ពាលានំ ៗ

បដិរូបទេសវាសោចាតិ គាថាវណ្ណនា

**ពណ៌នាគាថា ថា** បដិរូបទេសវាសោ ច

ព្រះមានព្រះភាគជាម្ចាស់ កាលត្រូវទេវបុត្រអារាធនាមង្គលតែម្យ៉ាងថា ព្រូហិ មង្គលមុត្តមំ សូមមេត្តាត្រាស់ប្រាប់នូវមង្គលដ៏ឧត្តម ប៉ុន្តែក៏ត្រាស់ដល់ទៅ ៣ មង្គល ដោយគាថាតែមួយ ប្រៀបបីដូចជាមនុស្សចិត្តទូលាយ ត្រូវសូមតែបន្តិច តែឱ្យច្រើន ជាពិសេសទៅទៀតនោះ ថែមទាំងទ្រង់ចាប់ផ្ដើមត្រាស់មង្គលជាច្រើនទៀត ដោយគាថាទាំងឡាយមាន បដិរូបទេសវាសោ ច ជាដើម ក៏ព្រោះទេវតាទាំងឡាយចង់ស្ដាប់ ព្រោះមង្គលទាំងឡាយមានហើយ និងព្រោះមង្គលណា ៗ ជួយសង្គ្រោះដល់សត្វណា ទ្រង់មានពុទ្ធបំណងនឹងទ្រង់ប្រកបសត្វនោះ ទុកក្នុងមង្គលនោះៗ បណ្ដាគាថាទាំងអស់នោះ នឹងពោលក្នុងគាថាដំបូងសិន ។ បទថា បដិរូបោ ប្រែថា សមគួរ ។ ឱកាសជាទីនៅអាស្រ័យរបស់សត្វទាំងឡាយគ្រប់កន្លែងមិនថាជាស្រុកក្ដី និគមក្ដី នគរក្ដី ជនបទក្ដី ឈ្មោះថា **ទេស:** ។ ការរស់នៅក្នុងទេស:នោះ ឈ្មោះថា **វាស:** ។ បទថា បុព្វេ ប្រែថា ពីមុន គឺក្នុងជាតិដែលកន្លងមកហើយ ។ ភាពជាអ្នកមានកុសល ដែលសន្សំហើយ ឈ្មោះថា ភាពជាអ្នកមានបុណ្យធ្វើទុកហើយ ។ ចិត្ត ឬអត្តភាពទាំងអស់ ហៅថា អត្ត: ។ការប្រកបទុក គឺការតាំងសេចក្ដីប្រាថ្នារបស់ខ្លួនទុកប្រពៃហើយ ឈ្មោះថា

សម្មាបណិធិ ។ លោកអធិប្បាយថា ការតាំងខ្លួនដោយប្រពៃឈ្មោះថា សម្មា-បណិធិ ការតាំងទុកដោយប្រពៃ ។ ពាក្យក្រៅអំពីនោះ មានន័យពោលទុកហើយទាំងអស់ ។ នេះជាការពណ៌នាបាឋៈក្នុងគាថាដំបូងនោះ ។

ចំណែកសេចក្ដីនៃការពណ៌នាគប្បីជ្រាបដូច្នេះ ។ ក្នុងប្រទេសណាបរិស័ទទាំង ៤ នៅត្រាច់ទៅ នៅបំពេញបុញ្ញកិរិយាវត្ថុ មានទានជាដើមនៅឡើយ នវង្គ-សត្ថុសាសនា នៅរុងរឿងនៅឡើយ ប្រទេសនោះឈ្មោះ បដិរូបទេស ។ ការរស់ នៅក្នុងបដិរូបទេសនោះ ទ្រង់ត្រាស់ថាជាមង្គល ព្រោះជាបច្ច័យដល់ការធ្វើបុណ្យរបស់សត្វទាំងឡាយ ។ ក្នុងសេចក្ដីនេះ មានអ្នកនេសាទដែលចូលទៅកាន់កោះសីហឡៈជាដើម ជាឧទាហរណ៍ ។

ន័យមួយទៀត ប្រទេសដែលជាកន្លែងត្រាស់ដឹងពោធិញាណ (កន្លែងត្រាស់ដឹងជាព្រះពុទ្ធ ហៅថា ពោធិមណ្ឌល ) ប្រទេសដែលទ្រង់ប្រកាសសម្ដែងព្រះធម្មចក្រ ប្រទេស គឺគល់ដើមស្វាយរបស់នាយគណ្ឌៈ ដែលទ្រង់សម្ដែងយមកប្បាដិហារិយបំផ្លាញសេចក្ដីស្រវឹងរបស់ពួកតិត្ថិយទាំងឡាយ ក្នុងកណ្ដាលចំណោមបរិស័ទប្រមាណ ១២ យោជន៍ ប្រទេសដែលស្ដេចយាងចុះពីទេវលោក ឬក៏ប្រទេសដទៃណា ដែលជាកន្លែងប្រថាប់នៅរបស់ព្រះពុទ្ធជាម្ចាស់ មានក្រុងសាវត្ថី ក្រុងរាជគ្រឹះជាដើម ប្រទេសនោះឈ្មោះថា **បដិរូបទេសៈ** ការនៅ

អាស្រ័យក្នុង**បដិរូបទេស**នោះ ទ្រង់ត្រាស់ថាជាមង្គល ព្រោះជាបច្ច័យដល់ការបានអនុត្តរិយៈ ៦ របស់សត្វទាំងឡាយ ។

ន័យម្យ៉ាងទៀតថា "ក្នុងទិសខាងកើតមាននិគមឈ្មោះកជង្គលៈ ខាងនាយកជង្គលនិគមនោះ មាននិគមឈ្មោះ មហាសាលា ខាងនាយនិគមឈ្មោះមហាសាលានោះ ហៅថាបច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសអាគ្នេយ៍មានស្ទឹងឈ្មោះ **សល្លវតី** ខាងនាយស្ទឹងសល្លវតីនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងត្បូងមាននិគមឈ្មោះសេតកណ្ណិកៈ ខាងនាយសេតកណ្ណិកនិគមនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងលិចមានស្រុកព្រាហ្មណ៍ ឈ្មោះថូនគ្រាម ខាងអាយស្រុកថូនគ្រាមនោះ ហៅថាបច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងជើងមានភ្នំឈ្មោះឧសីរធជៈ ខាងនាយភ្នំនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ"[១] ។ នេះជាមជ្ឈិមប្រទេសបណ្តោយ ៣០០ យោជន៍ ទទឹង ២៥០ យោជន៍ ដោយជុំវិញ ៩០០ យោជន៍ ។ មជ្ឈិមប្រទេស នេះឈ្មោះថា **បដិរូបទេសៈ** ។

ស្តេចចក្កពត្តិទាំងឡាយ ដែលគ្រប់គ្រងឥស្សរិយាធិបតេយ្យនៃទ្វីបធំទាំង ៤ ទ្វីប ទ្វីបតូច ២.០០០ ទ្វីប រមែងកើតក្នុងបដិរូបទេសនោះ ។ ព្រះសាវកទាំង

---

១-វិនយបិដក មហាវគ្គ លេខ ៧ ទំព័រ ២១៤-២១៥ ។

ឡាយមានព្រះសារីបុត្ត និងព្រះមោគ្គល្លានជាដើម បំពេញបារមីមកមួយអសង្ខេយ្យ និងមួយសែនកប្ប ក៏កើតក្នុងបដិរូបទេសនោះ ព្រះបច្ចេកពុទ្ធទាំងឡាយបំពេញបារមីមកពីរអសង្ខេយ្យ និងមួយសែនកប្ប ក៏កើតក្នុងបដិរូបទេសនោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយ បំពេញបារមីមកបួនអសង្ខេយ្យ និងមួយសែនកប្បខ្លះ ប្រាំបីអសង្ខេយ្យ និងមួយសែនកប្បខ្លះ ដប់ប្រាំមួយអសង្ខេយ្យ និងមួយសែនកប្បខ្លះ ក៏យាងមកឧបត្តិក្នុងបដិរូបទេសនោះ ។ បណ្ដាលោកទាំងអស់នោះ សត្វទាំងឡាយទទួលឱវាទរបស់ស្ដេចចក្កពត្តិតាំងនៅក្នុងសីល ៥ ហើយក៏មានឋានសួគ៌នៅខាងមុខ តាំងនៅក្នុងឱវាទរបស់ព្រះបច្ចេកពុទ្ធក៏ដូចគ្នា ។ ចំណែក សត្វទាំងឡាយតាំងនៅក្នុងឱវាទរបស់ព្រះពុទ្ធជាម្ចាស់ របស់សាវកនៃព្រះពុទ្ធជាម្ចាស់ រមែងមានឋានសួគ៌នៅខាងមុខ មានព្រះនិព្វាននៅខាងមុខ ព្រោះដូច្នោះ ការនៅក្នុងបដិរូបទេសនោះទើបត្រាស់ថាជាមង្គល ព្រោះជាបច្ច័យនៃសម្បត្តិទាំងអស់នោះ ។

ភាពជាអ្នកប្រារព្ធព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពសន្សំកុសលទុកក្នុងជាតិដែលកន្លងមកហើយឈ្មោះថា ភាពជាអ្នកបានធ្វើបុណ្យទុកក្នុងកាលមុន ។ សូម្បីភាពជាអ្នកបានធ្វើបុណ្យទុកក្នុងកាលមុន ក៏ជាមង្គល ។ ព្រោះហេតុអ្វី មានអធិប្បាយថា ភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន រមែងឱ្យសម្រេចព្រះអរហត្ត កាលចប់គាថាសូម្បី ៤ បទ ដែលសម្ដែងចំពោះព្រះភក្ត្រ

របស់ព្រះពុទ្ធជាម្ចាស់ និងព្រះបច្ចេកពុទ្ធ ឬដែលស្តាប់ចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធជាម្ចាស់ ឬសាវករបស់ព្រះពុទ្ធជាម្ចាស់ ។ អ្នកណាកសាងបារមីទុក មានកុសលមូលដ៏ក្រាស់ណែនមកពីមុន អ្នកនោះធ្វើវិបស្សនាឱ្យកើតហើយ រមែងសម្រេចធម៌ដែលអស់ទៅនូវអាសវៈ ដោយកុសលមូលនោះឯង ដូចព្រះមហាកប្បិន និងអគ្គមហេសី ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទើបត្រាស់ថា ភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុនជាមង្គល ។

មនុស្សពួកខ្លះក្នុងលោកនេះ រមែងធ្វើខ្លួនដែលទ្រុស្តសីល ឱ្យតាំងនៅក្នុងសីលសម្បទា ខ្លួនដែលមិនមានសទ្ធា ឱ្យតាំងនៅក្នុងសទ្ធាសម្បទា ខ្លួនដែលកំណាញ់ ឱ្យតាំងនៅក្នុងចាគសម្បទា ការតម្កល់ខ្លួនដូចពោលមកនេះ ឈ្មោះថាការតម្កល់ខ្លួនទុកដោយប្រពៃ ។ ការតម្កល់ខ្លួនទុកដោយប្រពៃនេះ ហៅថា អត្តសម្មាបណិធិ ។ អត្តសម្មាបណិធិនេះឯង ជាមង្គល ។ ព្រោះហេតុអ្វី ព្រោះជាហេតុលះពៀរដែលប្រព្រឹត្តក្នុងបច្ចុប្បន្ន និងក្នុងបរលោក ព្រមទាំងបានសម្រេចអានិសង្សផ្សេងៗ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់មង្គលនៃគាថានេះទុក ៣ មង្គលគឺ ការរស់នៅក្នុងប្រទេសដ៏សមគួរ ១ ភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន ១ និងការដម្កល់ខ្លួនទុកដោយប្រពៃ ១ ដោយប្រការដូច្នេះ ។ ក៏សេចក្តីនៃមង្គលពួកនោះ ជាមង្គល ក៏បានត្រាស់ទុកក្នុងមង្គលនោះៗ ហើយទាំងអស់ ។

**ចប់ការពណ៌នាសេចក្តីនៃគាថាថា** បដិរូបទេសវាសោ ច ៗ

ពាហុសច្ចញ្ចាតិ គាថាវណ្ណនា

**ពណ៌នាគាថា ថា** ពាហុសច្ចញ្ច

*ឥឡូវនេះ ភាពជាពហុស្សូត ឈ្មោះថា ពាហុសច្ច ក្នុងបទនេះថា ពាហុសច្ចញ្ច ។ សេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មគ្រប់យ៉ាង ឈ្មោះថា សិល្ប ។ ការហ្វឹកហាត់កាយវាចាចិត្ត ឈ្មោះថា **វិន័យ** ។ បទថា **សុសិក្ខិតោ** ប្រែថា ដែលគេសិក្សាដោយល្អ ។ បទថា សុភាសិតា ប្រែថា ដែលគេពោលដោយល្អ ។ ស័ព្ទថា យា បង្ហាញពីភាពមិនពិតប្រាកដ ។ ពាក្យបន្ទីគឺ ពាក្យនិយាយ ឈ្មោះថា វាចា ។ ពាក្យដ៏សេស មានន័យដូចដែលពោលមកហើយនោះឯង ។ នេះជាការពណ៌នាបទក្នុងគាថាថា ពាហុសច្ចញ្ច នេះ ។*

*ចំណែកការពណ៌សេចក្តីគប្បីជ្រាបដូចតទៅនេះ ភាពជាអ្នកទ្រទ្រង់ទុកនូវសត្ថុសាសនា ដែលទ្រង់ពណ៌នាទុកដោយន័យជាដើមយ៉ាងនេះថាជា"អ្នកទ្រទ្រង់សុត្តៈ សន្សំសុត្តៈ"[១] និងថា"ភិក្ខុរូបខ្លះក្នុងធម្មវិន័យនេះ មានសុត្តៈច្រើន គឺសុត្តៈគេយ្យៈ វេយ្យាករណៈ"[២] ជាដើមឈ្មោះថា ភាពជាពហុស្សូត ។ ភាពជាពហុស្សូតនោះ ទ្រង់ត្រាស់ថាជាមង្គល ព្រោះជាហេតុលះអកុសល បានសម្រេច*

---

*១-សុត្តន្តបិដកអង្គុត្តរនិកាយ ចតុក្កនិបាត លេខ ៤២ ទំព័រ ៥៥ ។*

*២-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត លេខ ៤២ ទំព័រ ១៦ ។*

នូវកុសលតែម្យ៉ាង និងព្រោះជាហេតុធ្វើឱ្យជាក់ច្បាស់បរមត្ថសច្ចៈតាមលំដាប់សមដូច ដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកដូច្នេះថា

“ម្នាលភិក្ខុទាំងឡាយ អរិយសាវក មានការចេះដឹង ទុកជាអាវុធ រមែងលះបង់នូវអកុសល ចម្រើននូវកុសល លះបង់នូវអំពើមានទោស ចម្រើននូវអំពើមិនមានទោស រមែងរក្សាខ្លួនឱ្យបរិសុទ្ធ”[១] ដូច្នេះ ។

មួយព្រះតម្រាស់ទៀតថា ៖

“ពិចារណានូវសេចក្តីនៃធម៌ទាំងឡាយដែលខ្លួនទ្រទ្រង់ហើយ កាលបើពិចារណានូវសេចក្តីហើយក៏ចូលចិត្តនូវធម៌ និងគំនិត កាលមានសេចក្តីចូលចិត្តនូវធម៌ និងគំនិតហើយ ក៏មានឆន្ទៈកើតឡើង លុះមានឆន្ទៈកើតឡើងហើយ ក៏ប្រឹង-ប្រែង លុះប្រឹងប្រែងហើយក៏ត្រិះរិះ លុះត្រិះរិះហើយ ក៏តម្កល់(នូវសេចក្តីព្យាយាមដើម្បីមគ្គ) ជាអ្នកមានចិត្តបញ្ជូលទៅកាន់ព្រះនិព្វាន ទើបធ្វើឱ្យជាក់ច្បាស់នូវបរមត្ថសច្ចៈដោយនាមកាយផង បានចាក់ធ្លុះឃើញច្បាស់នូវបរមត្ថសច្ចៈនោះដោយបញ្ញាផង”[(២)] ។

ម្យ៉ាងទៀត សូម្បីពាហុសច្ចៈ ភាពជាពហុស្សូតរបស់គ្រហស្ថណា ដែលមិនមានទោស យ៉ាងនោះក៏គប្បីជ្រាបថាជាមង្គល ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំងពីរ ។

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ សត្តកនិបាត លេខ ៤៧ ទំព័រ ២០១ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ លេខ ២៥ ទំព័រ ១៣៩ ។

សិល្បៈរបស់គ្រហស្ថ និងសិល្បៈរបស់បព្វជិត ឈ្មោះថា **សិល្បៈ** ។ បណ្ដាសិល្បៈទាំងពីរនោះ កិច្ចមានការងាររបស់ជាងមណី ជាងមាសជាដើម ដែលវៀរចាកការបំផ្លាញជីវិតសត្វ វៀរចាកអកុសល ឈ្មោះថា **អគារិកសិប្បៈ** សិល្បៈរបស់គ្រហស្ថ ។ អគារិកសិប្បៈនោះ ឈ្មោះថាជាមង្គល ព្រោះនាំមកនូវប្រយោជន៍ក្នុងលោកនេះ ។

ការរៀបចំធ្វើសមណបរិក្ខារ មានការប៉ះ និងដេរចីវរជាដើម ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់សរសើរទុកក្នុងទីនោះៗ ដោយន័យជាដើមថា "ម្នាលភិក្ខុទាំងឡាយ អំពើណាដ៏ខ្ពស់ និងទាប ដែលពួក សព្រហ្មចារីបុគ្គលត្រូវសួរគ្នីគ្នាហើយទើបធ្វើ ភិក្ខុជាអ្នកឈ្លាសវៃ ក្នុងអំពើនោះ"(១) ដែលទ្រង់ត្រាស់ថាជានាថករណធម៌ ធម៌ធ្វើទីពឹង ឈ្មោះថា **អនាគារិកសិល្បៈ** សិល្បៈ-របស់បព្វជិត ។ សិល្បៈរបស់បព្វជិតនោះគប្បីជ្រាបថាជាមង្គល ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំងពីរដល់ខ្លួនឯង និងអ្នកដទៃ ។

វិន័យរបស់គ្រហស្ថ និងវិន័យរបស់បព្វជិតឈ្មោះថា **វិន័យ** ។ បណ្ដាវិន័យទាំងពីរនោះ ការវៀរចាកអកុសលកម្មបថ ១០ ឈ្មោះថា វិន័យរបស់គ្រហស្ថ ។ វិន័យរបស់គ្រហស្ថនោះ គ្រហស្ថសិក្សាល្អហើយក្នុងវិន័យនោះ ឈ្មោះថាជាមង្គល ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំងពីរ ដោយការមិនត្រូវសង្កិលេស គឺសេចក្ដីសៅហ្មង និងដោយការកំណត់គុណ គឺអាចារៈ ។

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ៥៣ ។

ការមិនត្រូវអាបត្តិ ៧ កង ឈ្មោះថា វិន័យរបស់បព្វជិត ។ សូម្បីវិន័យរបស់បព្វជិតនោះ គឺបព្វជិតសិក្សាល្អហើយ តាមន័យដែលពោលមកហើយ ឬបារិសុទ្ធិសីលទាំង ៤ ឈ្មោះថា **វិន័យរបស់បព្វជិត** ។ វិន័យរបស់ បព្វជិតនោះ គឺបព្វជិតសិក្សាល្អហើយ ដោយការសិក្សាតាមប្រការដែលតាំងនៅក្នុងបារិសុទ្ធិ-សីលទាំង ៤ នោះហើយនឹងសម្រេចព្រះអរហត្តបាន គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុប្រទះនឹងសេចក្តីសុខទាំងលោកិយៈ និងលោកុត្តរៈ ។

វាចាដែលវៀរចាកទោស មានមុសាវាទជាដើម ឈ្មោះថា វាចាជាសុភា-សិត ដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ ជាវាចាសុភាសិត"[១] ។ ឬថា វាចាដែលចរចាមិនផ្តេសផ្តាស ក៏ឈ្មោះថា វាចាជាសុភាសិត ។ ដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា៖

"សុភាសិតំ ឧត្តមមាហុ សន្តោ
ធម្មំ ភណេ ន អធម្មំ តំ ទុតិយំ
បិយំ ភណេ ន អប្បិយំ តំ តតិយំ
សច្ចំ ភណេ នាលិកន្តំ ចតុត្ថំ ។

ពួកសប្បុរសបានពោលនូវវាចាសុភាសិតដ៏ឧត្តម (នោះជាទី ១) ពោលនូវវាចាជាធម៌ មិនពោលនូវវាចាមិនមែនជាធម៌ នោះជាទី ២ ពោលវាចាគួរ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ១៤០ ។

ស្រឡាញ់ មិនពោលវាចាដែលមិនគួរស្រឡាញ់ នោះជាទី ៣ ពោលពាក្យពិត មិន ពោលពាក្យឡេះឡោះ នោះជាទី ៤"[១] ។

សុភាសិតវាចាជាសុភាសិតនេះ ក៏គប្បីជ្រាបថាជាមង្គល ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំងពីរ ប៉ុន្តែព្រោះហេតុដែលវាចាជាសុភាសិតនេះ រាប់បញ្ចូលក្នុងវិន័យ កាលបើដូច្នោះ វាចាមានការសម្ដែងធម៌ដល់អ្នកដទៃជាដើម គប្បីជ្រាបថា វាចាជាសុភាសិតក្នុងទីនេះ ដោយភាពស្មាក់ស្មើរនេះឬ ។ ការពិតវាចាជាសុភាសិតទ្រង់ត្រាស់ថាជាមង្គល ក៏ព្រោះជាហេតុប្រសព្វនឹងសេចក្ដីសុខក្នុងលោកទាំងពីរ និងព្រះនិព្វានរបស់សត្វទាំងឡាយ ក៏ដូចការរស់នៅក្នុងបដិរូបទេសដែរ ។ ព្រះវង្គីសត្ថេរពោលទុកថា ៖

យំ ពុទ្ធោ ភាសតិ វាចំ ខេមំ និព្វានបត្តិយា
ទុក្ខស្សន្តកិរិយាយ សា វេ វាចានមុត្តមា។

ព្រះពុទ្ធទ្រង់ត្រាស់នូវព្រះវាចា ជាគ្រឿងក្សេមដើម្បីដល់នូវព្រះនិព្វាន
ដើម្បីធ្វើនូវទីបំផុតនៃទុក្ខវាចានេះឯង ឈ្មោះថា ជាវាចាដ៏ឧត្តម[២] ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់មង្គលនៃគាថានេះទុក ៤ មង្គលគឺ ពាហុសច្ចៈ១ សិប្បៈ ១ វិន័យដែលសិក្សាល្អហើយ ១ និងវាចាជាសុភាសិត ១ ដោយ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ១៤១ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ១៤៣ ។

ប្រការដូច្នេះ ។ ក៏សេចក្តីនៃមង្គលពួកនោះជាមង្គល ក៏បានពន្យល់ទុកក្នុងមង្គលនោះៗ ហើយទាំងអស់នោះឯង ។

**ចប់ការពណ៌នាសេចក្តីនៃគាថាថា** ពាហុសច្ចញ្ច **ជាដើម ។**

## មាតាបិតុឧបដ្ឋានត្តិ គាថាវណ្ណនា

## **ពណ៌នាគាថា ថា** មាតាបិតុឧបដ្ឋានំ

ឥឡូវនេះ នឹងពណ៌នាក្នុងគាថានេះថា មាតាបិតុឧបដ្ឋានំ ។ មាតា និងបិតា ហេតុនោះឈ្មោះថា មាតានិងបិតា ។ បទថា ឧបដ្ឋានំ ប្រែថា ការទំនុកបម្រុង ។ បុត្រទាំងឡាយផង ភរិយាទាំងឡាយផង ឈ្មោះថា បុត្រ និងភរិយា ។ ការសង្គ្រោះ ឈ្មោះថា សង្គហៈ។ ការមិនច្របូកច្របល់ ឈ្មោះថា អនាកុលា ។ ការងារទាំងឡាយឈ្មោះថា កម្មន្តា ។ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយទាំងនោះឯង ។ នេះជាការពណ៌នាសេចក្តីថាបទ ។ ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូចតទៅ ។ ស្ត្រីដែលញុំាងបុត្រឱ្យកើត ហៅថា **មាតា** បិតាក៏ន័យដូចគ្នា ។ ការធ្វើឧបការៈដោយការលាងជើង គក់ច្របាច់ គ្រឿងអប់ មុជទឹកឱ្យ និងឧបត្ថម្ភឱ្យនូវបច្ច័យ ៤ ឈ្មោះថា ការទំនុកបម្រុង ។ ក្នុងការទំនុកបម្រុងនោះ ព្រោះហេតុដែលមាតាបិតាមានឧបការៈច្រើន ប្រាថ្នាប្រយោជន៍ អនុគ្រោះដល់បុត្តទាំងឡាយ មាតាបិតាណាក្រឡេកឃើញបុត្រទាំងឡាយលេងនៅខាងក្រៅ ដើរមកមានខ្លួនប្រឡាក់ដោយធូលី ក៏ជូតធូលីឱ្យ ថើបជញ្ចក់បបោសអង្អែល កើតសេចក្តីស្រឡាញ់អាណិតអាសូរបុត្រទាំងឡាយ ប្រើសីសៈទូលមាតាបិតាទុកដល់ទៅ ១០០ ឆ្នាំ ក៏មិនអាចធ្វើបដិការៈស្នងគុណរបស់មាតា-

បិតានោះបាន និងព្រោះហេតុដែលមាតាបិតានោះជាអ្នកទំនុកបម្រុង ចិញ្ចឹមថែរក្សាបង្ហាញនូវលោកនេះហើយ ទើបសន្មតថាជាព្រហ្ម សន្មតថាជាបុព្វាចារ្យ ដូច្នេះ ការទំនុកបម្រុងមាតាបិតានោះ រមែងនាំមកនូវការសរសើរក្នុងលោកនេះ និងលះលោកនេះទៅហើយ ក៏នឹងនាំមកនូវសេចក្តីសុខក្នុងឋានសួគ៌ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថាជាមង្គល សមដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖

"មាតាបិតាទាំងឡាយដែលហៅថា ព្រហ្មក្តី បុព្វាចារ្យក្តី អាហុនេយ្យក្តី ( សុទ្ធតែ ) ជាអ្នកអនុគ្រោះដល់ពួកសត្វគឺកូន ។ ព្រោះហេតុនោះឯង អ្នកប្រាជ្ញគួរនមស្ការ គួរធ្វើសក្ការៈដល់មាតាបិតាទាំងនោះដោយបាយ ទឹក សំពត់ គ្រឿងដេក គ្រឿងអប់ គ្រឿងផ្ងូតទឹក និងទឹកសម្រាប់លាងជើង ។ ព្រោះការដែលបានទំនុកបម្រុងមាតាបិតានោះហើយ បានជាអ្នកប្រាជ្ញទាំងឡាយសរសើរនូវបុគ្គលនោះក្នុងលោកនេះឯង បុគ្គលនោះ លុះលះលោកនេះទៅហើយ រមែងរីករាយក្នុងឋានសួគ៌"[១] ។

ន័យម្យ៉ាងទៀត គួនាទី ៥ យ៉ាង មានការចិញ្ចឹមថែរក្សាលោក ធ្វើកិច្ចការងាររបស់លោក និងការថែរក្សាវង្សត្រកូលជាដើម ឈ្មោះថា ការទំនុកបម្រុង ។ ការទំនុកបម្រុងនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុនៃប្រយោជន៍សុខក្នុងបច្ចុប្បន្ន ៥ យ៉ាងមានការហាមមិនឱ្យធ្វើបាបជាដើម ។ សមដូចព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកដូច្នេះថា ៖

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ លេខ ៥៣ ទំព័រ ១៤២ ។

"ម្នាលគហបតិបុត្រ មាតាបិតាជាទិសខាងកើត កូនត្រូវទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងគឺ កូនត្រូវតាំងចិត្តថា អាត្មាអញមាតាបិតាបានចិញ្ចឹមរក្សាមកហើយ នឹងចិញ្ចឹមមាតាបិតាវិញ ១ នឹងជួយធ្វើការងាររបស់មាតាបិតា ១ ទាំងតម្កល់វង្សត្រកូល ១ ប្រតិបត្តិជាអ្នកសមគួរទទួលទ្រព្យមត៌កបាន ១ មួយទៀតឧទ្ទិសទក្ខិណាទានដល់មាតាបិតា ដែលធ្វើកាលកិរិយាទៅកាន់បរលោក ហើយ ១ ។ ម្នាលគហបតិបុត្រ មាតាបិតាជាទិសខាងកើត ដែលកូនទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងវិញដូច្នេះ គឺហាមឃាត់កូនចាកអំពើអាក្រក់ ១ ឱ្យកូនតម្កល់នៅតែក្នុងអំពើល្អ ១ ឱ្យកូនរៀនសូត្រសិល្បសាស្ត្រ ១ ដណ្តឹងភរិយាស្វាមីសមគួរឱ្យ ១ ចែកទ្រព្យឱ្យកូនក្នុងសម័យគួរ ១" [(១)] ។

ម្យ៉ាងទៀត អ្នកណាទំនុកបម្រុងមាតាបិតា ដោយឱ្យកើតសេចក្តីជ្រះថ្លាក្នុងវត្ថុទាំង ៣ (រតនៈទាំង ៣ ) ដោយឱ្យដល់ព្រមដោយសីល ដោយការបព្វជ្ជា អ្នកនេះជាកំពូលរបស់អ្នកដែលទំនុកបម្រុងមាតាបិតា ។ ការទំនុកបម្រុងមាតាបិតារបស់អ្នកនោះ ជាការតបស្នងឧបការគុណ ដែលមាតាធ្វើមកហើយទ្រង់ត្រាស់ថាជាមង្គល ព្រោះជាបទដ្ឋាននៃប្រយោជន៍ទាំងឡាយ ទាំងបច្ចុប្បន្នទាំងលោកខាងមុខជាច្រើន ។

ទាំងបុត្រធីតា ដែលកើតអំពីខ្លួន ក៏រាប់ថាជាកូនទាំងអស់ ក្នុងពាក្យថា **បុត្តទារស្ស** នេះ ។ បទថា **ទារា** បានដល់ភរិយា ២០ ជំពូក ជំពូកណាមួយ ។

---

១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ៨៤-៨៥ ។

បុត្រ និងភរិយា ឈ្មោះថា បុត្តទារ (បុត្រនិងភរិយានោះ) ។ បទថា សង្គហោ បានដល់ ការធ្វើឧបការៈដោយការលើកតំកើងជាដើម ។ ភាវៈនៃឧបការៈនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុនៃប្រយោជន៍សុខក្នុងបច្ចុប្បន្នមានភាព ជាអ្នកចាត់ការងារល្អជាដើម ។ មែនពិត ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សង្គ្រោះបុត្រ និងភរិយា ដែលទ្រង់លើកឡើងសម្តែងថា ទិសខាងក្រោយ គប្បីជ្រាបថាជាបុត្រភរិយា ទុកដោយ ភរិយា ស័ព្ទ ទើបទ្រង់ត្រាស់ទុកថា ៖

ម្នាលគហបតិបុត្ត ភរិយាជាទិសខាងលិច ស្វាមីត្រូវទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងគឺ ដោយការរាប់អានជាភរិយាពេញទី ១ ដោយមិនមើលងាយ ១ ដោយមិនប្រព្រឹត្តក្បត់ចិត្ត ១ ដោយប្រគល់ឱ្យជាធំ ( ក្នុងការផ្ទះ ) ១ ដោយការឱ្យគ្រឿងតែងខ្លួន ១ ។ ម្នាលគហបតិបុត្ត ភរិយាជាទិសខាងលិច ដែលស្វាមីទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងនេះហើយរមែង អនុគ្រោះស្វាមីដោយស្ថានទាំងឡាយ ៥ យ៉ាងវិញគឺ ចាត់ចែងការងារដោយល្អ ១ សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ ១ មិនប្រព្រឹត្តក្បត់ចិត្ត ១ ថែទាំទ្រព្យដែលស្វាមីរកបានមក ១ ឈ្លាសមិនខ្ជិលច្រអូសក្នុងកិច្ចការសព្វគ្រប់ ១[១] ។ ឬមានន័យមួយទៀត ដូច្នេះ បទថា សង្គហោ បានដល់ ការសង្គ្រោះដោយការឱ្យទានបិយវាចា សំដីគួរឱ្យស្រឡាញ់ អត្ថចរិយាការបំពេញ ប្រយោជន៍ដែលជាធម៌ ។ ការសង្គ្រោះនោះគឺអ្វី គឺការឱ្យស្បៀងក្នុងថ្ងៃឧបោសថ ការឱ្យមើលការ

---

១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ៨៦-៨៧ ។

ងារជានក្ខត្តប្ញក្សក្នុងថ្ងៃនក្ខប្ញក្ស ធ្វើមង្គលក្នុងថ្ងៃមង្គល ការឱ្យ ឱវាទប្រៀនប្រដៅក្នុងប្រយោជន៍ទាំងឡាយដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និង ប្រព្រឹត្តទៅក្នុងពេលខាងមុខ ការសង្គ្រោះនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុនៃប្រយោជន៍ក្នុងបច្ចុប្បន្ន ព្រោះជាហេតុនៃប្រយោជន៍ក្នុងពេលខាងមុខ និង ព្រោះជាហេតុនៃភាពជាអ្នកដែលទេវតាទាំងឡាយគប្បីនមស្ការ ។ ដូចដែល សក្កៈជាកំពូលអស់ពួកទេវតាត្រាស់ថា ៖

យេ គហដ្ឋា បុញ្ញករា សីលវន្តោ ឧបាសកា
ធម្មេន ទារំ បោសេន្តិ តេ នមស្សាមិ មាតលិ

ពួកគ្រហស្ថណាជាអ្នកធ្វើបុណ្យ ជាឧបាសកមានសីល ចិញ្ចឹមកូនប្រពន្ធដោយធម៌ ម្នាលមាតលិ ខ្ញុំក៏ថ្វាយបង្គំចំពោះពួកនោះដែរ[១] ។

ការងារទាំងឡាយ មានកសិកម្ម ធ្វើស្រែចំការ គោរក្ខកម្ម ចិញ្ចឹមគោ និងពាណិជ្ជកម្ម លក់ដូរជាដើម វៀរចាកភាវៈច្របូកច្របល់ មានការបណ្តែតបណ្តោយវេលា ការធ្វើមិនសមរម្យ និងការធ្វើបន្ធូរបន្ថយជាដើម ព្រោះជាអ្នកដែលស្គាល់កាល ព្រោះជាអ្នកដែលធ្វើសមរម្យ ព្រោះជាអ្នកមិនខ្ជិលច្រអូស និងព្រោះមិនគួរវិនាស ហេតុដល់ព្រមដោយការឧស្សាហ៍ព្យាយាម ឈ្មោះថាការងារមិនច្របូកច្របល់ ។ ការងារមិនច្របូកច្របល់ទាំងអស់នោះ ដែលបុគ្គល

១-សុត្តន្តបិដក មជ្ឈិមនិកាយ សគាថវគ្គ លេខ ៣០ ទំព័រ ២៨៩ ។

ធ្វើបានយ៉ាងនេះ ក៏ព្រោះខ្លួន បុត្តភរិយា ឬទាសកម្មករ បុគ្គលជាអ្នកឆ្លាត ត្រាស់ថាជាមង្គល ព្រោះជាហេតុឱ្យបានទ្រព្យ ស្រូវ និងសេចក្ដីចម្រើនក្នុងបច្ចុប្បន្ន ។ សមដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកដូច្នេះថា ៖

បុគ្គលមានការងារដ៏សមគួរ មានធុរៈមានព្យាយាមប្រឹងប្រែងរមែងបាននូវទ្រព្យ ។ ហើយព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងថា ៖

“បុគ្គលដេកក្នុងវេលាថ្ងៃជាប្រក្រតី មិនក្រោកឡើងពីយប់ជាប្រក្រតីជាអ្នកស្រវឹងជានិច្ច ជាអ្នកលេងល្បែងមិនអាចនឹងគ្រប់គ្រងផ្ទះសម្បែងបាន ។ ប្រយោជន៍ទាំងឡាយតែងកន្លងហួស មនុស្សដែលលះបង់ចោលនូវការងារដោយពោលអាងថា វេលានេះត្រជាក់ណាស់ ក្ដៅណាស់ ល្ងាចណាស់ ។ ជនណាមួយធ្វើនូវកិច្ចការរបស់បុរសមិនអើពើនូវត្រជាក់នឹងក្ដៅ ក្រៃលែងជាងស្មៅ ( ទៅទៀត ) ជននោះរមែងមិនសាបសូន្យចាកសេចក្ដីសុខឡើយ”[១] ។ ហើយព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងបន្តទៀតថា ៖

“កាលបុគ្គលសន្សំទ្រព្យរមែងធ្វើទ្រព្យឱ្យជាគំនរ ដូចជាឃ្មុំដូច្នោះឯង ។ ភោគៈទាំងឡាយ តែងដល់នូវការពូនជាគំនរ ដូចដំបូកដែលកណ្ដៀរកពូនដូច្នោះឯង”[២] ។ យ៉ាងនេះជាដើម ។

---

១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ៧៧-៧៨ ។

២-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ៨៣ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់មង្គលនៃគាថានេះទុក ៤ មង្គល គឺការទំនុកបម្រុងមាតា ១ ការទំនុកបម្រុងបិតា ១ ការសង្គ្រោះបុត្រនិងភរិយា ១ និងការងារមិនច្របូកច្របល់ ១ ឬ ៥ មង្គល ព្រោះបំបែកការសង្គ្រោះបុត្រនិងភរិយាចេញជា ២ ឬ ៣ មង្គល ព្រោះរួមការទំនុកបម្រុងមាតានិងបិតា ជាសេចក្តីតែមួយ ។ ក៏សេចក្តីនៃមង្គលទាំងអស់នោះជាមង្គល បានពន្យល់ទុកក្នុងមង្គលនោះ ៗ ហើយទាំងអស់នោះឯង ។

**ចប់ការពណ៌នាសេចក្តីនៃគាថាថា** មាតាបិតុឧបដ្ឋានំ **ឆ**

## ទានញ្ច គាថាវណ្ណនា

**ពណ៌នាគាថា ថា** ទានញ្ច

ឥឡូវនេះ នឹងពណ៌នាក្នុងគាថានេះថា ទានញ្ច ។ ឈ្មោះថា ទាន ព្រោះគេឱ្យដោយវត្ថុនេះ លោកអធិប្បាយថា គេប្រគល់ទ្រព្យដែលមាននៅរបស់ខ្លួនឱ្យដល់អ្នកដទៃ ។ ការប្រព្រឹត្តធម៌ ឬសេចក្តីប្រព្រឹត្តដែលមិនប្រាសចាកធម៌ ឈ្មោះថា ធម្មចរិយា ។ ឈ្មោះថា ញាតិ ព្រោះនរណា ៗ ក៏ដឹងថា អ្នកនេះពួករបស់យើង ។ មិនមានទោស ឈ្មោះថា អនវជ្ជ លោកអធិប្បាយថា នរណា ៗ និន្ទាមិនបាន តិះដៀលមិនបាន ។ ពាក្យដ៏សេសមានន័យដូចដែល ពោលមកហើយទាំងអស់នោះឯង ។ នេះជាការពណ៌នាសេចក្តីនៃបទ ។

ចំណែកការពណ៌នាសេចក្តីគប្បីជ្រាបដូច្នេះ ។ ចេតនាជាហេតុបរិច្ចាគទានវត្ថុ ១០ មានបាយជាដើម ដែលមានការដឹងច្បាស់ជាប្រធានចំពោះអ្នកដទៃ ឬសេចក្តីមិនលោភ ដែលប្រកបដោយចេតនានោះ ឈ្មោះថា ទាន ។ មែនពិត បុគ្គលរមែងប្រគល់ឱ្យនូវវត្ថុនោះដល់អ្នកដទៃ ដោយសេចក្តីមិនលោភ ។ ព្រោះ

ហេតុនោះ ខ្ញុំទើបពោលថា ឈ្មោះថា ទាន ព្រោះគេឱ្យទានដោយវត្ថុនេះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុសម្រេចនូវផលវិសេស ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅពេលខាងមុខ មានភាពជាអ្នកដែលជនជាច្រើនស្រឡាញ់និងពេញចិត្តជាច្រើន ។ ក្នុងរឿងទាននេះ គប្បីរលឹកដល់សូត្រទាំងឡាយ ជាដើមយ៉ាងនេះថា

"ម្នាលសីហៈ ទាយកជាម្ចាស់ទាន ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន"[១]។

ន័យម្យ៉ាងទៀត ឈ្មោះថា ទាន មាន ២ គឺអាមិសទាន និងធម្មទាន បណ្ដាទានទាំងពីរនោះ អាមិសទាន បានពោលមកហើយទាំងអស់ ។ ចំណែក ការសម្ដែងធម៌ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ប្រកាសហើយ ដែលនាំមកនូវការអស់ទៅនៃទុក្ខនិងសុខ ក្នុងលោកនេះ និងលោកខាងមុខ ព្រោះបំណងនឹងឱ្យជាប្រយោជន៍ដល់ជនដទៃ ៗ ឈ្មោះថា ធម្មទាន ។ ម្យ៉ាងទៀត បណ្ដាទានទាំងពីរនេះ ធម្មទាននេះតែម្យ៉ាងជាកំពូល ដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖

**សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ**

**សព្វរតឹ ធម្មរតិ ជិនាតិ តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ**

ធម្មទានឈ្នះអាមិសទានទាំងពួង ធម្មរសឈ្នះរសទាំងពួង សេចក្ដីត្រេកអរក្នុងធម៌ឈ្នះត្រេកអរទាំងពួង ការអស់តណ្ហាឈ្នះទុក្ខទាំងពួង[២] ។

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិកាយ លេខ ៤៤ ទំព័រ ៧៦ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ គាថាធម្មបទ លេខ ៥២ ទំព័រ ៩៦ ។

សម្រាប់ជាធម្មទាន

ក្នុងព្រះសូត្រនិងគាថានោះ ក៏ទ្រង់ត្រាស់តាមសេចក្ដីដែលអាមិសទានជាមង្គលប៉ុណ្ណោះ ចំណែកធម្មទាន ទ្រង់ត្រាស់ថាជាមង្គល ព្រោះជាបទដ្ឋាននៃគុណទាំងឡាយ មានភាពជាអ្នកយល់ជ្រួតជ្រាបអត្ថជាដើម សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកដូច្នេះថា ៖

"ម្នាលភិក្ខុទាំងឡាយ ព្រះសាស្ដា ឬភិក្ខុជាសព្រហ្មចារីណាមួយ ក្នុងសាសនានេះ ជាគរុដ្ឋានីយបុគ្គល (បុគ្គលគួរគោរព) សម្ដែងធម៌ដល់ភិក្ខុនោះយ៉ាងណាៗ ភិក្ខុនោះ រមែងដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផងក្នុងធម៌នោះយ៉ាងនោះៗ យ៉ាងនេះជាដើម"[១] ។

ការប្រព្រឹត្តកុសលកម្មបថ ១០ ឈ្មោះថា ធម្មចរិយា ដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកជាដើមថា ម្នាលគហបតិទាំងឡាយ ការប្រព្រឹត្តធម៌ ការប្រព្រឹត្តជានិច្ចជាកាលមាន ៣ យ៉ាង ។ ក៏ការប្រព្រឹត្តធម៌នោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុចូលដល់ទេវលោក ។ សមដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកដូច្នេះថា "ម្នាលគហបតិទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺ

១-សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត លេខ ៤៤ ទំព័រ ៤០ ។

មនុស្ស សុគតិ ឋានសួគ៌ ព្រោះហេតុតែកិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌យ៉ាងនេះឯង"[១] ។

ជនដែលជាខ្សែស្រឡាយខាងមាតា ឬខាងបិតា រហូតដល់ ៧ ជួរតាយាយ ឈ្មោះថា ញាតិ ។ ការសង្គ្រោះញាតិទាំងនោះ ដែលត្រូវសេចក្ដីវិនាសភោគៈ ត្រូវសេចក្ដីវិនាសព្រោះជំងឺគ្របសង្កត់ហើយ មករកខ្លួនដោយអាហារ គ្រឿងស្លៀកពាក់ និងស្រូវអង្ករជាដើម តាមកម្លាំង ទ្រង់ត្រាស់ថា ជាមង្គល ព្រោះជាហេតុបាននូវផលវិសេស ដែលជាបច្ចុប្បន្ន មានការសរសើរជាដើម និងដែលពេលខាងមុខមានទៅសុគតិជាដើម ។ ការងារដែលជាសុចរិតផ្លូវកាយ វាចា ចិត្ត មានការសមាទានអដ្ឋឧបោសថ ការធ្វើសេចក្ដីខ្វល់ខ្វាយ ការដាំ សួន និងព្រៃ និងសាងស្ពានជាដើម ឈ្មោះថា ការងារមិនមានទោស ។ ការងារមិនមានទោសទាំងអស់នោះ ទ្រង់ត្រាស់ថា ជាមង្គល ព្រោះជាហេតុ ឱ្យជួបប្រយោជន៍សុខនានាច្រើនប្រការ ។ គប្បីរលឹកដល់ព្រះសូត្រទាំងឡាយ មានជាដើមយ៉ាងនេះថា "ម្នាលវិសាខា ហេតុនេះរមែងមានត្រង់ដែលស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះ ចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកចាតុម្មហារាជិកទេវតា"[២] ។

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២២ ទំព័រ ២៤០ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត លេខ ៤៨ ទំព័រ ១៩៩ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់មង្គលនៃគាថានេះទុក ៤ មង្គល គឺ ទាន ១ ធម្មចរិយា ១ ការសង្គ្រោះញាតិ ១ ការងារមិនមានទោស ១ ដោយប្រការ ដូច្នោះ ។ ក៏សេចក្តីនៃមង្គលទាំងអស់នោះជាមង្គល ក៏បានពន្យល់ ទុកក្នុងមង្គល នោះ ៗ ហើយទាំងអស់នោះឯង ។

**ចប់ការពណ៌នាសេចក្តីនៃគាថា ថា ទានញ្ច ។**

អារតីតិ គាថាវណ្ណនា

**ពណ៌នាគាថា ថា** អារតី

ឥឡូវនេះនឹងពណ៌នាគាថាថា អារតី វិរតី នេះ ។ ឈ្មោះថា អារមណៈ ព្រោះលះបង់ ។ ឈ្មោះថា វិរមណៈ ព្រោះវៀរ ។ ន័យម្យ៉ាងទៀត ចេតនា ឈ្មោះថា **វិរតិ** ព្រោះជាគ្រឿងដែលសត្វវៀរចាក ។ បទថា ធាធា បានដល់ចាក អកុសល ។ ឈ្មោះថា **មជ្ជៈ** ព្រោះអត្ថថា ជាទីតាំងនៃសេចក្តីស្រវឹង ។ ការផឹក មជ្ជៈ ឈ្មោះថា **មជ្ជបានៈ** ។ សង្រួមចាក់មជ្ជបាននោះ។ការប្រុងប្រយ័ត្ន ឈ្មោះថា **សំយមៈ** ។ សេចក្តីមិនប្រមាទ ឈ្មោះថា **អប្បមាទៈ** ។ បទថា ធម្មេសុ បានដល់ ក្នុងកុសលទាំងឡាយ ។ ពាក្យដ៏សេស មានន័យដូចដែលពោលមកហើយទាំង នោះឯង នេះជាការពណ៌នាសេចក្តីនៃបទ ។

ចំណែកការពណ៌នាសេចក្តីគប្បីជ្រាបដូច្នេះ ។ ការមិនត្រេកអរតាមផ្លូវចិត្ត តែម៉្យាងរបស់បុគ្គល ដែលឃើញទោសក្នុងបាប ឈ្មោះថា អារតិ ។ ការវៀរចាកផ្លូវកាយវាចា តាមកម្ម និងទ្វារ ឈ្មោះថា វិរតិ ។ ក៏ធម្មតាវិរតិនោះមាន ៣ គឺ សម្បត្តវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទវិរតិ ១ ។ បណ្តាវិរតិទាំង ៣ នោះ វិរតិចេតនាវៀរចាកវត្ថុ ដែលប្រសប់យ៉ាងណារបស់កុលបុត្រ ដោយន័យជាដើមយ៉ាងនេះថា ការដែលយើងសម្លាប់សត្វនេះ នឹងលួចទ្រព្យនេះជាដើម កាលរលឹកដល់ជាតិត្រកូល ឬគោត្ររបស់ខ្លួន ក៏មិនសមគួរដល់យើងទេ វិរតិចេតនាវៀរចាកយ៉ាងនេះ ឈ្មោះថា **សម្បត្តវិរតិ** ។ កុលបុត្រមិនធ្វើបាប មានបាណាតិបាតជាដើម តាំងតែប្រព្រឹត្តវិរតិយ៉ាងណា វិរតិយ៉ាងនោះ ប្រព្រឹត្តដោយការសមាទានសិក្ខាបទ ឈ្មោះថា **សមាទានវិរតិ** ។ ក័យ ៥ ពៀរវេរា ៥ របស់អរិយសាវករម្ងាប់ទៅ តាំងតែប្រព្រឹត្តវិរតិណា វិរតិនោះប្រកបដោយអរិយមគ្គ ឈ្មោះថា **សមុច្ឆេទវិរតិ** ។ បាបអកុសលនោះ មាន ៤ យ៉ាងគឺ កម្មក្កិលេស ដែលព្រះដ៏មានព្រះភាគត្រាស់ទុកពិស្តារយ៉ាងនេះថា "ម្នាលគហបតិបុត្ត កម្មក្កិលេសគឺ បាណាតិបាត កម្មក្កិលេសគឺ អទិន្នាទាន កម្មក្កិលេសគឺ កាមេសុមិច្ឆាចារៈ កម្មក្កិលេសគឺ មុសាវាទ" ដូច្នេះ ហើយទ្រង់សង្ខេបទុកដោយគាថាយ៉ាងនេះថា ៖

"បាណាតិបាតោ អទិន្នាទានំ មុសាវាទោ ច វុច្ចតិ

បរទារគមនញ្ចេវ ន បសំសន្តិ បណ្ឌិតា ។

ការសម្លាប់សត្វ ១ លួចទ្រព្យគេ ១ និយាយកុហក ១ សេពកិរិយា បុគ្គលដទៃ ១ ហៅថា (កម្មក្កិលេស) បណ្ឌិតទាំងឡាយ មិនសរសើរឡើយ[១] ។

ការវៀរចាកបាបអកុសលនោះ ការវៀរចាកសូម្បីទាំងអស់នោះ ទ្រង់ត្រាស់ថាជាមង្គល ព្រោះជាហេតុប្រសប់នឹងផលវិសេសនានាច្រើនប្រការ មានការលះភ័យនឹងពៀរវេរា ដែលជាបច្ចុប្បន្ន និងលោកខាងមុខជាដើម ។ ក៏ក្នុងសេចក្តីនេះ គប្បីរលឹកដល់ព្រះសូត្រទាំងឡាយដោយន័យជាដើមថា ម្នាលគហបតិបុត្ត អរិយសាវកវៀរស្រឡះចាកបាណាតិបាតហើយ ។

នឹងពោលពណ៌នាការសង្រួមចាកការផឹកគ្រឿងស្រវឹង ។ ពាក្យនេះ ជាឈ្មោះរបស់ចេតនាវៀរចាកពីទីតាំងនៃសេចក្តីប្រមាទ គឺការផឹកគ្រឿងស្រវឹង គឺសុរា និងមេរ័យ ដែលពោលទុកពីមុនហើយ ។ ក៏ព្រោះហេតុ ដែលអ្នកផឹកគ្រឿងស្រវឹង រមែងមិនដឹងអត្ថ មិនដឹងធម៌ រមែងធ្វើអន្តរាយដល់មាតា ធ្វើអន្តរាយដល់បិតា ដល់ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធ និងព្រះសាវករបស់ព្រះតថាគត រមែងជួបការតិះដៀលក្នុងភពបច្ចុប្បន្ន ជួបទុគ្គតិក្នុងភពខាងមុខ និងជួបប្រសប់ភាពជាមនុស្សឆ្កួតក្នុងភពតៗទៅ ។ ចំណែកការសង្រួមពីការផឹកគ្រឿងស្រវឹង រមែងសម្រេចការរម្ងាប់ទោសទាំងអស់នោះ និងការដល់ព្រម

១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ៧០ ។

ដោយគុណផ្ទុយគ្នាពីទោសនោះ ។ ដូច្នោះ ការសង្រួមចាក់ការផឹកគ្រឿងស្រវឹង នេះ គប្បីជ្រាបថាជាមង្គល ។

ការរស់នៅមិនប្រាសចាកសតិក្នុងកុសលធម៌ទាំងឡាយ តាមអត្ថគប្បី ជ្រាបដោយភាពជាបដិបក្ខចំពោះការប្រមាទ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ៖ "ការធ្វើដោយមិនគោរព ការធ្វើមិនឱ្យរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្ត ទំរន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រកការមិនអប់រំ ការមិន ធ្វើឱ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយៗ ការធ្វេសប្រហែសក្នុង ការ ចម្រើននូវពួកធម៌ជាកុសល ការធ្វេសប្រហែសភាពនៃសេចក្ដីធ្វេសប្រហែស មាន សភាពយ៉ាងនេះណា នេះហៅថា សេចក្ដីប្រមាទ"[១] ។ ឈ្មោះថាការមិន ប្រមាទ ក្នុងកុសលធម៌ទាំងឡាយ ។ ការមិនប្រមាទក្នុងកុសលធម៌ទាំងឡាយនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាមង្គល ព្រោះជាហេតុ បាននូវកុសលធម៌ នានាច្រើនប្រការ និងព្រោះជាហេតុសម្រេចអមតធម៌ ។ ក្នុងសេចក្ដីនោះ គប្បី រលឹកដល់ពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដាជាដើម យ៉ាងនេះថា " ភិក្ខុជាអ្នក មិនប្រមាទ មានសេចក្ដីព្យាយាមដុតកម្ដៅ"[២] និង"សេចក្ដីមិនប្រមាទ ជាផ្លូវនៃ សេចក្ដីមិនស្លាប់"ដូច្នេះ[៣] ។

---

១-អភិធម្មបិដក វិភង្គ លេខ ៨២ ទំព័រ ១៥២ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២៣ ទំព័រ ៣១ ។

៣-សុត្តន្តបិដក ខុទ្ទកនិកាយ គាថាធម្មបទ លេខ ៥២ ទំព័រ ២៥ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់មង្គលនៃគាថានេះទុក ៣ មង្គល គឺ ការវៀរចាកបាប ១ ការសង្រួមចាកការផឹកគ្រឿងស្រវឹង ១ ការមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយ ១ ដោយប្រការដូច្នេះ ។ ក៏សេចក្តីនៃមង្គលទាំងអស់ជាមង្គល ក៏បានពន្យល់ទុកក្នុងមង្គលនោះ ៗ ហើយទាំងអស់នោះឯង ។

**ចប់ការពណ៌នាសេចក្តីនៃគាថា ថា អារតី ៗ**

គារវោ ចាតិ គាថាវណ្ណនា

**ពណ៌នាគាថា ថា** គារវោ ច

ឥឡូវនេះ នឹងពណ៌នាក្នុងគាថាថា គារវោ ច នេះ ។ បទថា គារវោ បានដល់ ភាពជាអ្នកធ្ងន់ (ការគោរព) ។ បទថា និវាតោ បានដល់ ការប្រព្រឹត្តបន្ទាបខ្លួន ។ បទថា សន្តុដ្ឋិ ប្រែថា ការសន្តោស ។ ការដឹងឧបការគុណដែលលោកធ្វើទុក ឈ្មោះថា **កតញ្ញុតា** ។ បទថា កាលេន ប្រែថា ខណៈ បានដល់ សម័យ ។ ការស្តាប់ធម៌ ឈ្មោះថា ធម្មស្សវនំ ។ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយទាំងនោះឯង ។ នេះជាការពណ៌នាសេចក្តីនៃបទ ។ ចំណែកការ ពណ៌នាសេចក្តីគប្បីជ្រាបដូចតទៅនេះ សេចក្តីគោរព ការធ្វើសេចក្តីគោរព ភាព ជាអ្នកមានសេចក្តីគោរព តាមសមគួរក្នុង ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ សាវករបស់ព្រះតថាគត អាចារ្យ ឧបជ្ឈាយ៍ មាតាបិតា បងប្រុស បងស្រី

ជាដើម ជាអ្នកដែលគួរប្រកបសេចក្តីគោរព ឈ្មោះថា **គារវៈ** ។ គារវៈនេះ ព្រោះជាហេតុ នៃការទៅកាន់សុគតិជាដើម ដូចដែលព្រមានព្រះភាគទ្រង់ត្រាស់ទុកថា ៖

"បុគ្គលធ្វើសក្ការៈដល់បុគ្គលដែលគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរពដល់បុគ្គលដែលគួរគោរព រាប់អានបុគ្គលដែលគួររាប់អាន បូជាដល់បុគ្គលដែលគួរបូជា ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅរមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក បើបុគ្គលនោះ ទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅមិនទៅកើតក្នុងសុគតិទេវលោកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្សកើតក្នុងទីណា ៗ រមែងជាអ្នកមានត្រកូលខ្ពង់ខ្ពស់"[១] ។ នឹងដូចដែលទ្រង់ត្រាស់ទុកយ៉ាងនេះថា ៖

"ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ ប្រការនេះ តែងប្រព្រឹត្តទៅដើម្បីសាបសូន្យដល់ភិក្ខុ ។ ធម៌ ៧ ប្រការតើដូចម្តេចខ្លះ ។ គឺសេចក្តីគោរពព្រះសាស្តាដូច្នេះជាដើម"[២] ។ ទើបទ្រង់ត្រាស់ថា ជាមង្គល ។

ភាពជាអ្នកមានចិត្តទាប ភាពជាអ្នកមិនប្រព្រឹត្តក្អេងក្អេង ឈ្មោះថា ការបន្ទាបខ្លួន ។ បុគ្គលប្រកបដោយភាពជាអ្នកបន្ទាបខ្លួនយ៉ាងណា កម្ចាត់មានៈ

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក លេខ ២៨ ទំព័រ ៦៦ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ សត្តកនិបាត លេខ ៤៧ ទំព័រ ៥៣ ។

បាន កម្ចាត់ភាពរឹងទទឹងបាន ដូចជាក្រណាត់ជូតជើង ស្មើដោយគោឧសភៈបាក់ស្នែង និងស្មើដោយពស់ដែលត្រូវដកចង្កូមហើយ រមែងជាអ្នកលំអុតលំអោន ល្វត់ល្វន់ទន់ភ្លន់ បរិសុទ្ធដោយសេចក្ដីសុខ ភាពជាអ្នកបន្ទាបខ្លួន យ៉ាងនេះជានិវាតៈ និវាតៈនេះទ្រង់ត្រាស់ថាជាមង្គល ព្រោះជាហេតុបាននូវគុណមានយសជាដើម ។ម្យ៉ាងទៀត ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទុកថា "(បណ្ឌិត) មានកិរិយាប្រព្រឹត្តឱនលំទោនជាប្រក្រតី មិនរឹងត្អឹង បុគ្គលមានសភាពដូច្នោះ រមែងបានយស"[១] ដូច្នេះ ជាដើម ។

ការសន្ដោសដោយបច្ច័យតាមមានតាមបាន ឈ្មោះថា **សន្តុដ្ឋី** ។ សន្ដោសនោះមាន ១២ យ៉ាង គឺក្នុងចីវរ ៣ យ៉ាងគឺ **យថាលាភសន្ដោស** សន្ដោសតាមដែលបាន **យថាពលសន្ដោស** សន្ដោសតាមកម្លាំង **យថាសារុប្បសន្ដោស** សន្ដោសតាមសមគួរ ។ ក្នុងបិណ្ឌបាតជាដើម ក៏យ៉ាងនេះដែរ ។

នឹងពណ៌នាប្រភេទនៃសន្ដោសនោះ ដូចតទៅនេះ ។ ភិក្ខុក្នុងធម្មវិន័យនេះបានចីវរល្អ ឬមិនល្អ ភិក្ខុនោះក៏ញ៉ាំងអត្តភាពឱ្យ ប្រព្រឹត្តដោយចីវរនោះប៉ុណ្ណោះ មិនប្រាថ្នាចីវរដទៃ កាលបាន ក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្ដោស** ក្នុងចីវររបស់ភិក្ខុនោះ ។

---

១- សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ៩១ ។

ម្យ៉ាងទៀត ភិក្ខុអាពាធកាលដណ្តប់ចីវរធ្ងន់ រមែងត្រូវកោងខ្នងចុះ ឬលំបាក លោកទើបប្តូរចីវរនោះជាមួយភិក្ខុដែលត្រូវគ្នា ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយចីវរស្រាលនោះ ក៏នៅជាអ្នកដែលសន្តោសដដែល នេះឈ្មោះថា **យថាពល-សន្តោស** ក្នុងចីវររបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត ជាអ្នកបានបច្ច័យដ៏ប្រណីត លោកបានចីវរ បណ្តាចីវរថ្នាក់ល្អជាដើមយ៉ាងណាមួយ ដែលមានតម្លៃច្រើន គិតថាចីវរនេះសមរម្យដល់ព្រះថេរៈដែលបួសមកយូរ និងលោកពហុស្សូត ទើបប្រគេនដល់ព្រះភិក្ខុទាំងឡាយនោះ ខ្លួនឯងក៏ជ្រើសរើសយកកម្ទេចក្រណាត់ពីគំនរសំរាម ឬពីទីណាៗដទៃទៀត ធ្វើសង្ឃាដិគ្រង ក៏នៅតែជាអ្នកសន្តោសដដែលនោះឯង នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងចីវររបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានបិណ្ឌបាតកខ្វក់ ឬប្រណីតក៏ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះ មិនប្រាថ្នាបិណ្ឌបាតដទៃ ។ សូម្បីកាលបានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។ ម្យ៉ាងទៀត ភិក្ខុអាពាធឆាន់បិណ្ឌបាតសៅហ្មង រោគនឹងរើធ្ងន់ លោកទើបប្រគេនបិណ្ឌបាតនោះដល់ភិក្ខុដែលមានសភាពដូចគ្នា ឆាន់ទឹកដោះថ្លា ទឹកឃ្មុំ និង ទឹកដោះស្រស់ជាដើម ពីដៃរបស់ភិក្ខុនោះ សូម្បីធ្វើសមណធម៌នៅឡើយ ក៏នៅតែជាអ្នកសន្តោសនេះជា **យថាពលសន្តោស** ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត បានបិណ្ឌបាតដ៏ប្រណីត លោកគិតថា បិណ្ឌបាតនេះសមរម្យចំពោះព្រះថេរៈ ភិក្ខុដែលបួសមកយូរ និងសូម្បីដល់សព្រហ្មចារីដទៃទៀត ជាអ្នកវៀរចាកបិណ្ឌបាតដ៏ប្រណីតនោះហើយ ក៏ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅមិនបាន ទើបបានប្រគេនដល់ភិក្ខុទាំងអស់នោះ ខ្លួនឯងក៏ត្រាច់ទៅបិណ្ឌបាតទៀត សូម្បីឆាន់អាហារដែលលាយឡំគ្នា ក៏នៅតែជាអ្នកសន្តោសដដែល នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត សេនាសនៈមកដល់ភិក្ខុក្នុងធម្មវិន័យនេះ លោកក៏សន្តោសដោយសេនាសនៈនោះទុំះឯង មិនព្រមទទួលសេនាសនៈដទៃទៀត សូម្បីល្អជាងនេះឈ្មោះថា **យថាលាភសន្តោស** ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។ ម្យ៉ាងវិញទៀត ភិក្ខុអាពាធ នៅក្នុងសេនាសនៈដែលហប់ខ្យល់ រមែងនឹងអន្ទះអន្ទែងយ៉ាងខ្លាំង ដោយរោគប្រមាត់ជាដើម លោកទើបប្រគេនសេនាសនៈ ដល់ភិក្ខុដែលមានសភាពដូចគ្នា ហើយនៅប្រាសចាកពីសេនាសនៈដ៏ត្រជាក់មានខ្យល់ ទោះបីជាមានដល់ភិក្ខុនោះកាលធ្វើសមណធម៌ ក៏នៅតែជាអ្នកសន្តោសដដែល នេះឈ្មោះថា **យថាពលសន្តោស** ក្នុងសេនាសនៈរបស់ ភិក្ខុនោះ ។ ភិក្ខុមួយរូបទៀត មិនព្រមទទួលសេនាសនៈដ៏ល្អដែលមកដល់ដោយគិតថា សេនាសនៈល្អជាទីតាំងនៃសេចក្តីប្រមាទ កាលភិក្ខុអង្គុយក្នុងទីសេនាសនៈនោះ ថីនមិទ្ធៈរមែងគ្របសង្កត់ កាលដេកលក់ហើយភ្ញាក់ឡើងមក កាមវិតក្កៈរមែងដុះដាលឡើង លោកទើបបដិសេធសេនាសនៈនោះចេញ នៅកណ្តាលវាល គល់ឈើ និងកុដិដែលប្រក់

ដោយស្លឹកឈើ កន្ទេលណាមួយក៏នៅតែជាអ្នកសន្តោសដដែល នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានភេសជ្ជៈមិនថាផ្លែស្រម៉ ឬកន្ទួតព្រៃ លោកក៏ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយភេសជ្ជៈនោះ មិនប្រាថ្នាភេសជ្ជៈដទៃ-ទៀត មានទឹកដោះស្រស់ ទឹកឃ្មុំ ទឹកអំពៅជាដើម ដែលបានហើយ សូម្បីកាល បានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុអាពាធត្រូវការប្រេង តែបានទឹកអំពៅ លោកក៏ប្រគេន ទឹកអំពៅនោះដល់ភិក្ខុដែលមានសភាពដូចនោះ ប៉ុន្តែធ្វើថ្នាំដោយប្រេងបានមកពី ដៃភិក្ខុនោះវិញ សូម្បីកាលធ្វើសមណធម៌ ក៏នៅតែជាអ្នកសន្តោសដដែល នេះ ឈ្មោះថា **យថាពលសន្តោស** ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។ ភិក្ខុមួយរូប ទៀត ដាក់ស្រម៉ត្រាំជាមួយនឹងទឹកមូត្រក្នុងកាជនៈមួយ ដាក់របស់មានរសឆ្ងាញ់ ៤ យ៉ាងក្នុងកាជនៈមួយ កាលត្រូវភិក្ខុជាមិត្តប្រាប់ថា លោកត្រូវការវត្ថុណា ក៏ កាន់យកចុះ បើថាអាពាធរបស់ភិក្ខុនោះ រម្ងាប់ទៅដោយស្រម៉ ត្រាំទឹកមូត្រ និង រសឆ្ងាញ់ទាំងពីរនោះ យ៉ាងណាមួយសោត កាលបើជាដូច្នោះ លោកគិតថា ធម្មតាស្រម៉ត្រាំដោយទឹកមូត្រ ព្រះពុទ្ធជាម្ចាស់ជាដើមទ្រង់សរសើរហើយ និង ព្រះអង្គត្រាស់ថា "បព្វជ្ជាអាស្រ័យភេសជ្ជៈ ដែលត្រាំដោយទឹកមូត្រស្អុយ អ្នក

ត្រូវធ្វើការឧស្សាហ៍ក្នុងភេសជ្ជៈនោះអស់មួយជីវិត"[១] បដិសេធភេសជ្ជៈ មានរសច្ងាញ់ ៤ យ៉ាង សូម្បីធ្វើភេសជ្ជៈដោយការត្រាំផ្លែស្រម៉ជាមួយទឹកមូត្រស្អុយ ក៏ជាអ្នកដែលសន្តោសយ៉ាងក្រៃលែង នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។

សន្តោសសូម្បីទាំងអស់នោះ មានប្រភេទយ៉ាងនេះ ក៏ហៅថា **សន្តុដ្ឋី** ។ សន្តុដ្ឋីនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុបានសម្រេចនូវការលះបាបធម៌ទាំងឡាយមានការប្រាថ្នាហួសប្រមាណ ការចង់បានច្រើននិងការប្រាថ្នាលាមកជាដើម ព្រោះជាហេតុនៃសុគតិ ព្រោះជាគ្រឿងអប់រំនូវអរិយមគ្គ ព្រោះជាហេតុនៃភាពជាអ្នករស់នៅបានយ៉ាងស្រួលក្នុងទិសទាំង ៤ ដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា៖

"ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ សន្តុស្សមានោ ឥតរីតរេន

បុគ្គលជាអ្នកនៅជាសុខក្នុងទិសទាំង ៤ មិនលំបាកត្រេកអរដោយបរិក្ខារតាមមានតាមបាន"[២] ដូច្នេះជាដើម ។

ការដឹងនូវឧបការៈគុណដែលអ្នកណាមួយធ្វើមកហើយ មិនថាច្រើន ឬក៏តិច ដោយការរលឹកដល់រឿយៗ ឈ្មោះថា **កតញ្ញុតា** ។ម្យ៉ាងទៀត បុណ្យ

---

១-វិនយបិដក មហាវគ្គ លេខ ៦ ទំព័រ ៣១៦ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ១៥ ។

ទាំងឡាយនោះឯង មានឧបការៈច្រើនដល់សត្វទាំងឡាយ ព្រោះការពារនូវទុក្ខ មានទុក្ខក្នុងនរកជាដើមបាន ។ដូច្នេះ ការរលឹកដល់ឧបការៈរបស់បុណ្យទាំងអស់នោះ ក៏គប្បីជ្រាបថាជា កតញ្ញុតា ។ កតញ្ញុតានោះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថាជាមង្គល ព្រោះជាហេតុបានសម្រេចនូវគុណវិសេសមានប្រការផ្សេងៗ មានភាពជាអ្នក ដែលសប្បុរសទាំងឡាយគប្បីសរសើរជាដើម ។ ដូចព្រះមានព្រះភាគជាម្ចាស់ក៏ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ រកបានដោយកម្រក្នុងលោក ។ បុគ្គលពីរពួកតើដូចម្តេច ។ គឺបុគ្គលដែលធ្វើ ឧបការៈទុកមុន ១ បុគ្គលដឹងឧបការៈដែលគេធ្វើហើយ ធ្វើតបវិញ ១" [១] ។

ការស្តាប់ធម៌ ដើម្បីបន្ទយវិតក្កៈក្នុងកាលដែលចិត្តប្រកបដោយឧទ្ធច្ចៈ ឬចិត្តត្រូវវិតក្កៈទាំងឡាយ មានកាមវិតក្កៈជាដើមយ៉ាងណាមួយគ្របសង្កត់ ឈ្មោះថា ការស្តាប់ធម៌តាមកាល ។ អាចារ្យមួយពួកទៀតពោលថា ការស្តាប់ធម៌គ្រប់ៗ ៥ ថ្ងៃ ឈ្មោះថា ការស្តាប់ធម៌តាមកាល ដូចព្រះអនុរុទ្ធដ៏មានអាយុ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គអង្គុយប្រជុំគ្នា ដោយធម្មីកថាពីយប់ទល់ព្រឹកគ្រប់ ៥ ថ្ងៃ ។

ម្យ៉ាងទៀត ក្នុងកាលណា ភិក្ខុចូលទៅរកកល្យាណមិត្តហើយ អាចស្តាប់ធម៌ដើម្បីបន្ទោបង់នូវភាពសង្ស័យរបស់ខ្លួនបាន ការស្តាប់ធម៌សូម្បីក្នុង

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ៤០ ទំព័រ ១៩៥ ។

កាលនោះ ក៏គប្បីជ្រាបថា ការស្តាប់ធម៌តាមកាលដែរ ដូចព្រះដ៏មានព្រះភាគ ត្រាស់ទុកថា "បុគ្គលបានចូលទៅសាកសួរពិគ្រោះនឹងគ្រូសព្រហ្មចារី បុគ្គលទាំង នោះតាមកាលដ៏គួរ[១]" ។ ការស្តាប់ធម៌តាមកាលនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុ បានសម្រេចនូវផលវិសេសនានាច្រើនប្រការ មានការលះ នីវរណៈ បានអានិសង្ស ៤ និងសម្រេចធម៌ជាទីអស់ទៅនូវអាសវៈជាដើម ។

សមដូចព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា៖

"ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវកធ្វើឱ្យជាប្រយោជន៍ធ្វើទុក ក្នុងចិត្ត ផ្ចង់ចិត្តទាំងអស់ផ្ទៀងសោតប្រសាទស្តាប់ធម៌ សម័យនោះ នីវរណធម៌ ទាំង ៥ មិនមានដល់ភិក្ខុនោះឡើយ"[២] ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ៖

"ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៤ ប្រការនៃធម៌ដែលចូលទៅកាន់ត្រចៀក រឿយៗ ជាធម៌ដែលបុគ្គលចាំស្ទាត់រត់មាត់ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយ ទិដ្ឋិគឺ បញ្ញារមែងកើតប្រាកដ"[៣] ។

ម្យ៉ាងវិញទៀត ព្រះមានព្រះភាគទ្រង់ត្រាស់ថា ៖

---

១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ៣០៥ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មហាវារវគ្គ លេខ ៣៧ ទំព័រ ២៤៣ ។

៣-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត លេខ ៤៣ ទំព័រ ១០៧ ។

“ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ពួកនេះ ដែលភិក្ខុអប់រំដោយប្រពៃ ដែលប្រព្រឹត្តទៅដោយប្រពៃ រហូតកាល តាមកាលរមែងឱ្យដល់ធម៌ជាទីអស់ទៅនូវអាសវៈដោយលំដាប់ធម៌ ៤ ប្រការ គឺការស្តាប់តាមកាល” យ៉ាងនេះជាដើម ។

ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់មង្គលនៃគាថានេះទុក ៥ មង្គលគឺ ការគោរព ១ ការបន្ទាបខ្លួន ១ សន្តោស ១ កតញ្ញុតា ១ និងការស្តាប់ធម៌តាមកាល ១ ដោយប្រការដូច្នេះ ។ សេចក្តីនៃមង្គលទាំងអស់នោះ ជាមង្គល ក៏បានពន្យល់ទុកក្នុងមង្គលនោះ ៗ ហើយទាំងអស់នោះឯង ។

**ចប់ការពណ៌នាសេចក្តីនៃគាថាថា** គារវោ ច ។

## ខន្តិ ចាតិ គាថាវណ្ណនា

## ពណ៌នាគាថាថា ខន្តិ ច

ឥឡូវនេះ នឹងពណ៌នាគាថាថា ខន្តិ ច ដូចតទៅនេះ ៖ សេចក្តីអត់ធន់ឈ្មោះថា ខន្តិ ។ ឈ្មោះថា សុវច ព្រោះមានការប្រដៅងាយ ព្រោះជាអ្នកប្រកាន់ដោយខាងស្តាំ ។ កម្មរបស់អ្នកដែលប្រដៅងាយ ឈ្មោះថា សោវចស្សំ ។ ភាវៈនៃការប្រដៅងាយ ឈ្មោះថា សោវចស្សតា ។ ឈ្មោះថា សមណៈ ព្រោះរម្ងាប់កិលេសទាំងឡាយបាន ។ បទថា ទស្សនំ បានដល់ ការរំពៃមើល ។ ការសន្ទនាធម៌ ឈ្មោះថា ធម្មសាកច្ឆា ។ ពាក្យដ៏សេសមានន័យ ដូចពោលមកហើយ ទាំងអស់នោះឯង ។ នេះជាការពណ៌នាសេចក្តីនៃបទ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូចតទៅនេះ **អធិវាសនខន្តី** ឈ្មោះថា ខន្តី ។ កាលដែលកិក្ខុប្រកបដោយខន្តីនោះហើយ រមែងមិនមានការខុសប្រក្រតី ជាអ្នកដូចជាមិនបានឮបុគ្គលដែលជេរដោយអក្កោសវត្ថុ ១០ និងដូចជាមិនឃើញបុគ្គលដែលបៀតបៀនដោយការសម្លាប់ និងការធ្វើទោសជាដើម ដូចជា ខន្តិវាទីតាបសដូច្នេះ ។ ដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ថា ៖

អហុ អតីតមទ្ធានេ[១] សមណោ ខន្តិទីបនោ

តំ ខន្តិយាយេវ ឋិតំ កាសិរាជា អឆេទយិ ។

សមណៈជាអ្នកសម្តែងនូវខន្តី មានហើយក្នុងអតីតកាល ព្រះបាទកាសីទ្រង់ត្រាស់ឱ្យចោរឃាតកបុរសសម្លាប់សមណៈនោះ អ្នកតាំងនៅក្នុងខន្តី[២] ។

ឬរមែងជាប់ចិត្តថាគេធ្វើល្អហើយ ព្រោះមិនមានកំហុសក្រៃលែងទៅជាងនោះ ដូចព្រះបុណ្ណៈក្រាបបង្គំទូលថា ៖

“បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងជេរគម្រាមខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះយ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្ត ជនបទនេះជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុង

---

១-ច្បាប់ឆដ្ឋសង្គាយនាថា **អតីតមទ្ធានំ** ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក លេខ ៥៨ ទំព័រ ១៩៩ ។

សុនាបរន្តជនបទនេះ ល្អណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះមិនប្រហារអាត្មា-អញដោយបាតដៃ”⁽¹⁾ ។

នឹងកាលដែលភិក្ខុប្រកបដោយខន្តីនោះហើយ រមែងជាអ្នកដែលសូម្បីតែឥសីទាំងឡាយក៏សរសើរ ។ ដូចដែលសរភង្គឥសីពោលទុកថា ៖

“កោធំ វធិត្វា ន កទាចិ សោចតិ
មក្ខប្បហានំ ឥសយោ វណ្ណយន្តិ
សព្វេសំ វុត្តំ ផរុសំ ខមេថ
ឯតំ ខន្តឹ ឧត្តមមាហុ សន្តោ ។

បុគ្គលសម្លាប់សេចក្ដីក្រោធ រមែងមិនក្រៀមក្រំក្នុងកាលណាមួយឡើយ ឥសីទាំងឡាយ រមែងសរសើរនូវការលះបង់នូវសេចក្ដីលុបគុណគេ បុគ្គលគប្បីអត់ធន់ចំពោះពាក្យអាក្រក់ ដែលបុគ្គលទាំងពួងពោលហើយ ពួកសប្បុរសពោលនូវសេចក្ដីអត់ធន់នុ៎ះ ថាជាគុណជាតិដ៏ឧត្ដម”⁽²⁾ ។

រមែងជាអ្នកដែលសូម្បីទេវតាទាំងឡាយក៏គប្បីសរសើរ ដូចដែលស្ដេចសក្កៈជាកំពូលអស់ពួកទេព ពោលទុកថា ៖

“យោ ហវេ ពលវា សន្តោ ទុព្វលស្ស តិតិក្ខតិ

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក លេខ ២៨ ទំព័រ ២៦៤ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក លេខ ៦០ ទំព័រ២៣៥ ។

តមាហុ បរមំ ខន្តិំ និច្ចំ ខមតិ ទុព្វលោ ។

អ្នកណាមានកម្លាំងជាអ្នកស្ងប់ហើយ អត់ឱនចំពោះបុគ្គលមានកម្លាំងខ្សោយ បណ្ឌិតទាំងឡាយសរសើរបុគ្គលនោះថា មានសេចក្ដីអត់ធ្មត់ដ៏ក្រៃលែង"[១] ។

រមែងជាអ្នកដែលសូម្បីតែព្រះពុទ្ធជាម្ចាស់ទាំងឡាយ ក៏គប្បីសរសើរ ដូចព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា៖

"អក្កោសំ វធពន្ធញ្ច អទុដ្ឋោ យោ តិតិក្ខតិ

ខន្តិពលំ ពលានីកំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណាមិនប្រទូស្ត អត់សង្កត់ពាក្យជេរផង ការវាយតប់បៀនទីងការចងផងបាន ទើបតថាគតហៅបុគ្គលដែលមានខន្តិជាពលៈ មានខន្តិជាកងពលនោះឯងថា ជាព្រាហ្មណ៍"[២] ។

ក៏ខន្តិនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុជួបប្រទះគុណទាំងអស់នោះ និងគុណឯទៀតៗ ដែលទ្រង់សរសើរទុកក្នុងទីនេះ ។

កាលបើត្រូវសព្រហ្មចារីពោលដោយធម៌ ក៏ដល់នូវភាពវាយមាយភាពរោកង៉ក់ ឬគិតអំពីគុណនិងទោស តម្កល់នូវការទំនុកបម្រុង ការគោរព និងការមានចិត្តដាក់ចុះទាបជាខាងមុខយ៉ាងក្រៃលែងហើយ បន្លឺពាក្យពេចន៍ថា ល្អហើយ ដូច្នេះ ឈ្មោះថា សោវចស្សតា ភាពជាអ្នកប្រដៅងាយ ។ សោវចស្សតា នោះ

១-សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ លេខ ៣០ ទំព័រ ២៥២ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ គាថាធម្មបទ លេខ ៥២ ទំព័រ ១០៥ ។

ទ្រង់ត្រាស់ថាជាមង្គល ព្រោះជាហេតុបាននូវឱវាទនិងអនុសាសន៍ពីសំណាក់មិត្ត សព្រហ្មចារីទាំងឡាយ និងព្រោះជាហេតុលះទោស និងបាននូវគុណ ។

ការចូលទៅរកការទំនុកបម្រុង ការរឭក ការស្តាប់ និងការឃើញបព្វជិតទាំងឡាយដែលរម្ងាប់កិលេសហើយ អប់រំកាយវាចាចិត្ត និងបញ្ញាហើយប្រកបដោយកាពស្ងប់យ៉ាងខ្ពស់ ឈ្មោះថា ការឃើញសមណៈទាំងឡាយ ។ ការឃើញសមណៈទាំងអស់ លោកពោលថា **ទស្សនៈ** ដោយទេសនាយ៉ាងទាប ។ ការឃើញសមណៈនោះ គប្បីជ្រាបថាជាមង្គល ។ ព្រោះហេតុអ្វី? ព្រោះមានឧបការៈច្រើន ។ ពិតហើយ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយតថាគត ពោលនូវការជួបប្រទះនូវភិក្ខុទាំងនោះថាមានឧបការៈច្រើន"[១] ។ ព្រោះថា កុលបុត្រត្រូវការដោយប្រយោជន៍ ឃើញភិក្ខុទាំងឡាយដែលមានសីល មកដល់ទ្វារផ្ទះ ប្រសិនបើទេយ្យធម៌មាន ក៏គប្បីរាប់អានដោយទេយ្យធម៌តាមកម្លាំង ប្រសិនបើមិនមាន ក៏គប្បីថ្វាយបង្គំ ដោយបញ្ចង្គប្រតិស្ឋាន កាលបើការថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន នៅមិនទាន់គ្រប់សព្វ ក៏គប្បីប្រណមអញ្ជលីនមស្ការ កាលបើការឱនលំទោននៅមិនទាន់គ្រប់សព្វ ក៏មានចិត្តជូរផង់ ក្រឡេកមើលដោយចក្ខុដែលគួរឱ្យស្រឡាញ់ ។ មែនពិត បុណ្យដែលមានការក្រឡេកមើលយ៉ាងនេះ រោគ ឬទោស កន្ទុយថ្ងៃន បាយក្អែក ឬរលកកែវនឹងមិនមានក្នុងចក្ខុនោះ រហូតអស់កាលច្រើនពាន់ជាតិ ចក្ខុទាំងពីរក៏នឹងស្រស់ថ្លា មានសិរី មាន

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ លេខ ៥៣ ទំព័រ ១៣៩ ។

វណ្ណៈ ៥ ប្រៀបដូចជាបន្ទះទ្វារកែវមណី ដែលបើកក្នុងរតនវិមាន នឹងបាន សម្បត្តិក្នុងទេវតា និងមនុស្សប្រមាណសែនកប្ប ។ កាលដែលគេកើតជាមនុស្ស ជាអ្នកមានបញ្ញា គប្បីសោយវិបាកសម្បត្តិដូច្នេះ ក៏ដោយបុណ្យដែលសម្រេច មកពីការឃើញសមណៈ ដែលគេប្រព្រឹត្តធ្វើមកដោយប្រពៃ តែមិនគួរឱ្យអស្ចារ្យ ឡើយ សូម្បីសម្រាប់សត្វតិរច្ឆាន បណ្ឌិតទាំងឡាយក៏ពណ៌នាវិបាកសម្បត្តិនៃ ការឃើញសមណៈ ដែលត្រឹមតែធ្វើសទ្ធាឱ្យកើតហើយតែម្យ៉ាងទុកយ៉ាងនេះ ។ សមដូចពាក្យដែលលោកពោលថា ៖

សត្វមៀមក្អែកមូល អាស្រ័យនៅវេទិយកបព៌តមកអស់កាលយូរ សត្វមៀម នេះសុខពិតហ្ន៎ ព្រោះបានឃើញព្រះពុទ្ធជាម្ចាស់ដ៏ប្រសើរ អំពីព្រឹក ព្រលឹម ។

សត្វមៀមនោះ វាញ៉ាំងចិត្តឱ្យជ្រះថ្លាក្នុងតថាគត និងភិក្ខុសង្ឃដ៏ក្រៃលែង មិនបានទៅទុគតិអស់សែនកប្ប ។ សត្វមៀមនោះ វាចុតិពីទេវលោក ដោយ កុសលកម្មគាំទ្រ ហើយនឹងបានជាព្រះពុទ្ធដែលមានអនន្តញ្ញាណ ប្រាកដព្រះនាម ថា **សោមនស្ស** ដូច្នេះ ។

ក្នុងវេលាយប់ព្រលប់ ឬក្នុងវេលាព្រឹកព្រលឹម ភិក្ខុជាអ្នកទ្រទ្រង់នូវព្រះ សូត្រ ២ រូប រមែងសន្ទនាព្រះសូត្រគ្នា ចំណែកភិក្ខុជាអ្នកទ្រទ្រង់នូវព្រះវិន័យ ក៏ សន្ទនាព្រះវិន័យគ្នា ចំណែកភិក្ខុជាអ្នកទ្រទ្រង់នូវព្រះអភិធម្ម ក៏សន្ទនាព្រះអភិធម្មគ្នា ចំណែកភិក្ខុជាអ្នកទ្រទ្រង់នូវជាតក ក៏សន្ទនាជាតកគ្នា ចំណែកភិក្ខុជាអ្នក ទ្រទ្រង់នូវអដ្ឋកថា ក៏សន្ទនាអដ្ឋកថាគ្នា ឬសន្ទនាក្នុងកាលនោះ ៗ ដើម្បីជម្រះចិត្ត

ដែលត្រូវភាពតក់ស្លុត ភាពរាយមាយ និងភាពសង្ស័យឱ្យអស់ទៅ ការសន្ទនាតាមកាលនេះ ឈ្មោះថា ការសន្ទនាធម៌តាមកាល ។ ការសន្ទនាធម៌តាមកាលនោះ ទ្រង់ត្រាស់ថា ជាមង្គល ព្រោះជាហេតុនៃគុណទាំងឡាយ មានការឆ្លាតក្នុងមន្តគឺ និកាយទាំង ៥ ជាដើម ។

ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់មង្គលនៃគាថានេះទុក ៤ មង្គលគឺ សេចក្ដីអត់ធន់ ១ ភាពជាអ្នកប្រដៅងាយ ១ ការឃើញសមណៈ ១ និងការសន្ទនាធម៌តាមកាល ១ ដោយប្រការដូច្នេះ ។ ក៏សេចក្ដីនៃមង្គលទាំងអស់នោះជាមង្គល បានពន្យល់ទុកក្នុងមង្គលនោះ ៗ ហើយទាំងអស់នោះឯង ។

**ចប់ការពណ៌នាសេចក្ដីនៃគាថា ថា ខន្តី ច ៗ**

## តបោ ចាតិ គាថាវណ្ណនា

**ពណ៌នាគាថា ថា តបោ ច**

ឥឡូវនេះ នឹងពណ៌នាក្នុងគាថាថា តបោ ច នេះ ។ ឈ្មោះថា តបៈ ព្រោះដុតបាបធម៌ ។ ការប្រព្រឹត្តដូចព្រហ្ម ឬការប្រព្រឹត្តរបស់ព្រហ្ម ឈ្មោះថា ព្រហ្មចរិយៈ លោកអធិប្បាយថា ការប្រព្រឹត្តដ៏ប្រសើរ ។ ការឃើញអរិយសច្ចៈទាំងឡាយ ឈ្មោះថា អរិយសច្ចាន ទស្សនំ ។ អាចារ្យពួកខ្លះពោលថា អរិយសច្ចានិ ទស្សនំ ដូច្នេះក៏មាន បទថា អរិយសច្ចានិ ទស្សនំ ពាក្យនេះមិនពីរោះសោះ ។ ឈ្មោះថា និព្វាន ព្រោះចេញចាកវានៈ គឺតណ្ហាជាគ្រឿងរួបរឹត ។ ការធ្វើឱ្យជាក់ច្បាស់ ឈ្មោះថា សច្ឆិកិរិយា ។ ការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន

ឈ្មោះថា និព្វានសច្ឆិកិរិយា ។ ពាក្យដ៏សេស មានន័យដូចដែលពោល ទាំងនោះឯង ។ នេះជាការពណ៌នាសេចក្តីនៃបទ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ ឥន្ទ្រិយសំវរៈ ឈ្មោះថា តបៈ ព្រោះដុតអភិជ្ឈា និងទោមនស្សជាដើម ។ ម្យ៉ាងទៀត សេចក្តីព្យាយាម ឈ្មោះថា តបៈ ព្រោះដុតសេចក្តីខ្ជិលច្រអូស ។ បុគ្គលដែលប្រកបដោយតបៈ នោះ លោកហៅថា អាតាបី ។ តបៈនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុ លះអភិជ្ឈាជាដើម និងការបានចំពោះនូវឈានជាដើម ។

ឈ្មោះថា **ព្រហ្មចរិយៈ** ជាឈ្មោះរបស់ មេថុនវិរតិ សមណធម៌ សាសនា និងមគ្គ ។ ពិតយ៉ាងនោះមែន មេថុនវិរតិ លោកហៅថា ព្រហ្មចរិយៈ ដូចក្នុង ប្រយោគជាដើមថា "អព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ ភិក្ខុលះបង់ អព្រហ្មចរិយៈជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ"[១] ។សមណធម៌ ហៅថា ព្រហ្មចរិយៈ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា "ភគវតិ នោ អាវុសោ ព្រហ្មចរិយំ វុស្សតិ ម្នាលអាវុសោ លោកដ៏មានអាយុ ប្រព្រឹត្តសមណធម៌ក្នុងសំណាក់ព្រះដ៏មាន- ព្រះភាគរបស់យើងដែរឬ"[២] ។ សាសនា ហៅថា ព្រហ្មចរិយៈ ដូចក្នុងប្រយោគ ជា ដើមយ៉ាងនេះថា "ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ឥទំ

១-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៤ ទំព័រ ១៥៧ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក លេខ ២១ ទំព័រ ៨៧ ។

ព្រហ្មចរិយំ ន ឥទ្ធញ្ចេវ ភវិស្សតិ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ ម្នាលមារ មានចិត្តបាប ព្រហ្មចារ្យ(សាសនា)របស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នានឹងមិនទាន់ពេញបរិបូណ៌ដរាបណា មួយទៀត ពួកទេវតានឹងមនុស្សមិនទាន់បេះសម្ដែងបាន ដោយប្រពៃដរាបណា តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះដូច្នេះ”[១] ។ មគ្គ ហៅថា ព្រហ្មចរិយៈ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “អយមេវ ខោ ភិក្ខុ អរិយោ អដ្ឋង្គិកោ មគ្គោ ព្រហ្មចរិយំ ។សេយ្យថីទំ សម្មាទិដ្ឋិ ម្នាលភិក្ខុ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯងហៅថា ព្រហ្មចរិយៈ ។ មគ្គទាំង ៨ តើដូចម្ដេច ។ គឺសម្មាទិដ្ឋិជាដើម”[២] ។ តែក្នុងទីនេះ ព្រហ្មចរិយៈ សូម្បីទាំងអស់ រមែងគួរ ព្រោះមគ្គលោកសង្គ្រោះដោយ អរិយសច្ចានទស្សនៈ ខាងមុខហើយ ។ ក៏ព្រហ្មចរិយៈនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុ សម្រេចនូវគុណវិសេសនានា មានប្រការផ្សេងៗ ខាងលើៗ ។ ការឃើញអរិយមគ្គ ដោយអំណាចនៃការចាក់ធ្លុះនូវអរិយសច្ចៈទាំង ៤ តាមដែលបានពោលមកហើយ ក្នុងកុមារបញ្ហាឈ្មោះថា

---

១-សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ លេខ ១៦ ទំព័រ ២២៤ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មហាវារវគ្គ លេខ ៣៧ ទំព័រ ១៦ ។

អរិយសច្ចានទស្សនៈ ។ អរិយសច្ចានទស្សនៈនោះ ព្រះដ៏មានព្រះភាគត្រាស់ថា ជាមង្គល ព្រោះជាហេតុកន្លងបង់នូវសង្សារទុក្ខបាន ។

អរហត្តផល លោកបំណងយកព្រះនិព្វាន ក្នុងទីនេះ ។ ឈ្មោះថា **និព្វានសច្ឆិកិរិយា** ការធ្វើឱ្យជាក់ច្បាស់ក្នុងព្រះនិព្វាន ។ មែនពិត អរហត្តផល នោះ លោកពោលថានិព្វាន ព្រោះចេញចាកតណ្ហា ដែលសត្វសម្គាល់ថា **វានៈ** ព្រោះចងទុកក្នុងគតិ ៥[១] ។ការដល់ ឬការពិចារណាព្រះនិព្វាននោះ ហៅថា **សច្ឆិកិរិយា** តែការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ក្រៅពីនេះសម្រេចបានដោយការឃើញ អរិយសច្ចៈ ៤ នោះឯង ។ ព្រោះហេតុនោះ ការឃើញអរិយសច្ចៈនោះ ទើបលោកមិនបំណងទុកក្នុងទីនេះ ។ ការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាននោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុនៅជាសុខក្នុងបច្ចុប្បន្នជាដើម ដោយប្រការដូច្នេះ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់មង្គលនៃគាថានេះទុក ៤ មង្គល គឺ តបៈ ១ ព្រហ្មចរិយៈ ១ អរិយសច្ចានទស្សនៈ ១ និងនិព្វានសច្ឆិកិរិយា ១ ដោយប្រការដូច្នេះ ។ ក៏សេចក្តីនៃមង្គលទាំងអស់នោះ ជាមង្គល បានពន្យល់ទុកក្នុងមង្គលនោះ ៗ ហើយទាំងអស់នោះឯង ។

**ចប់ការពណ៌នាសេចក្តីនៃគាថា ថា តបោច ៗ**

---

១-គតិ ៥ យ៉ាងគឺ និរយៈ ១ តិរច្ឆាន១ បេត្តិវិស័យ ១ មនុស្ស ១ ទេវតា ១ ។ បិដកលេខ ២០ ទំព័រ ២៧៨ ។

## ផុដ្ឋស្ស លោកធម្មេហីតិ គាថាវណ្ណនា

## ពណ៌នាគាថា ថា ផុដ្ឋស្ស លោកធម្មេហិ

ឥឡូវនេះ នឹងពណ៌នាក្នុងគាថាថា ផុដ្ឋស្ស លោកធម្មេហិ ដូចតទៅនេះ បទថា ផុដ្ឋស្ស បានដល់ ពាល់ហើយ ត្រូវហើយ ប្រសព្វហើយ ។ ធម៌ទាំងឡាយក្នុងលោក ឈ្មោះថា លោកធម៌ ។ លោកអធិប្បាយថា ធម៌ទាំងឡាយនឹងមិនវិលត្រឡប់ដរាបណា លោកនៅមិនទាន់ដំណើរការទៅដរាបនោះ ។ បទថា ចិត្តំ បានដល់ មនោគឺ មានសៈ ។ បទថា យស្ស បានដល់ របស់ភិក្ខុថ្មី ភិក្ខុកណ្តាល ឬភិក្ខុថេរៈ ។ បទថា ន កម្បតិ បានដល់ មិនកម្រើកគឺ មិនញាប់ញ័រ ។ បទថា អសោកំ បានដល់ គ្មានសេចក្តីសោក គឺដកសេចក្តីសោកអាឡោះអាល័យចេញហើយ ។ បទថា វិរជំ បានដល់ ប្រាសចាកធូលីគឺកិលេស គឺថាកម្ចាត់លំអងគឺកិលេសហើយ ។ បទថា ខេមំ បានដល់ មិនមានភ័យ គ្មានឧបទ្រព ។ ពាក្យដ៏សេសមានន័យដូចដែលពោលទុកហើយនោះឯង ។ នេះជាការពណ៌នាសេចក្តីនៃបទ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូចតទៅនេះ ។ ចិត្តរបស់អ្នកណាដែលលោកធម៌ ៨ ប្រការ មានលាភ មិនមានលាភជាដើម ពាល់ត្រូវ គ្របសង្កត់ហើយ រមែងមិនកម្រើក មិនរង្គើ គឺថាមិនញាប់ញ័ររបស់បុគ្គលនោះ គប្បីជ្រាបថាជាមង្គល ព្រោះនាំមកនូវភាពជាអ្នកខ្ពង់ខ្ពស់លើលោក ដែលធម៌ណាមួយ ឱ្យ

កម្រើកញាប់ញ័រមិនបាន ឈ្មោះថា ចិត្តរបស់បុគ្គលនោះ ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយមិនកម្រើកញាប់ញ័រ ។

សួរថា ក៏ចិត្តរបស់អ្នកណា ត្រូវលោកធម៌ទាំងអស់នោះប៉ះហើយ មិនញាប់ញ័រ? ឆ្លើយថា ចិត្តរបស់ព្រះអរហន្តខីណាស្រព មិនមែនចិត្តរបស់អ្នកណាឯទៀតទេ ។ ពិតហើយ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកដូច្នេះថា ៖

"សេលោ យថា ឯកឃនោ វាតេន ន សមីរតិ
ឯវំ រូបា រសា សទ្ទា គន្ធា ផស្សា ច កេវលា
ឥដ្ឋា ធម្មា អនិដ្ឋា ច នប្បវេធេន្តិ តាទិនោ
ឋិតំ ចិត្តំ វិប្បមុត្តំ វយញ្ចស្សានុបស្សតិ ។

ថ្មដែលតាន់សុទ្ធ មិនបានរំជួយដោយខ្យល់ យ៉ាងណាមិញ រូប សំឡេង ក្លិន រស ផស្សៈ និងធម្មារម្មណ៍ទាំងអស់ ដែលជាទីគាប់ចិត្តក្តី មិនជាទីគាប់ចិត្តក្តី ក៏ញុំាងចិត្តរបស់ភិក្ខុដែលជាតាទិបុគ្គល[១] ឱ្យញាប់ញ័រមិនបាន យ៉ាងនោះដែរ ចិត្តរបស់ភិក្ខុនោះ ជាចិត្តឋិតនៅខ្ជាប់ខ្ជួន ជាចិត្តផុតស្រឡះចាកកិលេសហើយ លោកពិចារណានូវសេចក្តីកើត និងសេចក្តីរលត់នៃចិត្តនោះ"[២] ។

---

១-តាទិនោតិ ឥដ្ឋានិដ្ឋេ អនុនយបដិឃេហិ អកម្បិយត្តា ពាក្យថា **តាទិបុគ្គល** មានន័យថា បុគ្គលដែលមិនញាប់ញ័រដោយសេចក្តីត្រេកអរ និងសេចក្តីអន់ចិត្ត ក្នុងអារម្មណ៍ជាទីគាប់ ចិត្តនិងអារម្មណ៍មិន ជាទីគាប់ចិត្ត ។ សមន្តប្បាសាទិកា អដ្ឋកថា មហាវគ្គ ។

២-វិនយបិដក មហាវគ្គ លេខ ៧ ទំព័រ ១៧៣ ។

ចិត្តរបស់ព្រះខីណាស្រពប៉ុណ្ណោះ ឈ្មោះថា **អសោកៈ** មិនសោកសៅ ។ មែនពិត ចិត្តរបស់ព្រះខីណាស្រពនោះ ឈ្មោះថា **អសោកៈ** ព្រោះមិនមានការសោកសៅ ដែលលោកពោលដោយន័យជាដើមថា ការសោកសៅ ភាពជាអ្នកសោកសៅ ការរីងរៃ ការរីងស្ងួតខាងក្នុង ភាពនៃចិត្តដែលត្រូវសេចក្តីសោកសៅដុតរោល ។ អាចារ្យពួកខ្លះ ពោលអំពីព្រះនិព្វាន ពាក្យនោះ ភ្ជាប់សេចក្តីមិនបានជាមួយបទដើម ។ ចិត្តរបស់ព្រះខីណាស្រពប៉ុណ្ណោះ ឈ្មោះថា **អសោកៈ** យ៉ាងណា ឈ្មោះថា **វិរជៈ ខេមៈ** ក៏យ៉ាងនោះដែរ ។ មែនពិត ចិត្តរបស់ព្រះខីណាស្រពនោះ ឈ្មោះថា **វិរជៈ** ព្រោះប្រាសចាកធូលីគឺ កិលេសមាន រាគៈ ទោសៈ មោហៈ ឈ្មោះថា **ខេមៈ** ព្រោះរួចពីយោគៈទាំង ៤ ។ ព្រោះថា ចិត្តទាំង ៣ យ៉ាងនោះ តាមដែលលោកប្រកាន់យកហើយ ក្នុងខណៈចិត្តប្រព្រឹត្តទៅក្នុងអារម្មណ៍នោះ ៗ ដោយអាការៈនោះៗ គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវ ភាពជាអ្នកខ្ពង់ខ្ពស់លើលោក មានភាពជាអ្នកមានខន្ធមិនប្រព្រឹត្តទៅហើយ (មិនកើតទៀត) និង ព្រោះនាំមកនូវភាពជាអាហុនេយ្យបុគ្គលជាដើម ។

ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់មង្គលនៃគាថានេះទុក ៤ មង្គលគឺ ចិត្តដែលមិនញាប់ញ័រដោយលោកធម៌៨ ១ ចិត្តមិនសោកសៅ ១ ចិត្តប្រាសចាកធូលីគឺរាគៈ ១ ចិត្តក្សេម ១ ដោយប្រការដូច្នេះ ។ ក៏សេចក្តីនៃមង្គលទាំងអស់នោះជាមង្គល ក៏បានពន្យល់ទុកក្នុងមង្គលនោះ ៗ ហើយទាំងអស់នោះឯង ។

**ចប់ការពណ៌នាសេចក្តីនៃគាថា ថា ផុដ្ឋស្ស លោកធម្មេហិ ។**

## ឯតានិសានីតិ គាថាវណ្ណនា

### **ពណ៌នាគាថា ថា ឯតានិសានិ**

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលត្រាស់មង្គល ៣៨ ប្រការ ដោយ ១០ គាថា មានថា អសេវនា ច ពាលានំ ការមិនសេពបុគ្គលគប់ពាលជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សរសើរមង្គលដែលព្រះអង្គត្រាស់ទាំងអស់នេះឯង ទើបបានត្រាស់គាថាចុងក្រោយថា ឯតានិសានិ កត្វាន ជាដើម ។

ពណ៌នាសេចក្តីនៃគាថាចុងក្រោយនោះដូច្នេះ បទថា ឯតានិសានិ ប្រែថា ដូចនេះ ពួកនេះ គឺមានការមិនសេពបុគ្គលគប់ពាលជាដើម មានប្រការដូចដែលតថាគតពោលមកហើយ ។ បទថា កត្វាន ប្រែថា ធ្វើហើយ ។ មែនពិត ពាក្យនេះ មិនក្រៅអ្វីទៅពីសេចក្តីថា កត្វាន កត្វា ករិត្វា ( ដែលប្រែថា ធ្វើហើយដូចគ្នា) ។ បទថា សព្វត្ថមបរាជិតា មានសេចក្តីថា សត្វទាំងឡាយធ្វើមង្គលដូច្នេះពួកនេះ ដែលសត្រូវ ៤ ប្រភេទគឺ ខន្ធមារ កិលេសមារ អភិសង្ខារមារ និងទេវបុត្តមារ សូម្បីតែប្រភេទណាក៏ធ្វើឱ្យចុះចាញ់មិនបានក្នុងទីទាំងពួង លោកអធិប្បាយថា ញុំាងមារទាំង ៤ នោះ ឱ្យចុះចាញ់ដោយខ្លួនឯង ។ ក៏ ម-អក្សរក្នុងបទថា សព្វត្ថមបរាជិតានេះ គប្បីជ្រាបថា ត្រឹមតែជាការតបទ ។

បទថា សព្វត្ថ សោត្ថឹ គច្ឆន្តិ សេចក្តីថា សត្វទាំងឡាយ ធ្វើមង្គលដែលពោលមកហើយនេះ ជាអ្នកដែលមារទាំង ៤ ធ្វើឱ្យចុះចាញ់មិនបានហើយ រមែងដល់នូវសិរីសួស្តីក្នុងទីទាំងពួងគឺ ក្នុងលោកនេះ និងលោកខាងមុខ និងកន្លែងឈរ

និងកន្ទែងដើរជាដើម អាសវៈទាំងឡាយណា ដែលធ្វើសេចក្តីចង្អៀតចង្អល់ និង អន្ទះអន្ទែង គប្បីកើតឡើងព្រោះការសេពគប់ពាលជាដើម ហេតុមិនមាន អាសវៈទាំងអស់នោះ ទើបដល់នូវសិរីសួស្តី លោកអធិប្បាយថា ជាអ្នកដែល ឧបទ្រពមិនរារាំង ដែលឧបស័គ្គមិនជំទាស់ ក្សេមក្សាន្តគ្រប់ មិនមានភ័យ ចំពោះមុខ ។ ក៏និគ្គហិតក្នុងបទថា សព្វត្ថ សោត្ថឹ គច្ឆន្តិ នេះ គប្បីជ្រាបថា ត្រាស់ដើម្បីងាយស្រួលដល់ការចងគាថា ។

ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់បញ្ចប់ទេសនា ដោយបទនៃគាថាថា តំ តេសំ មង្គលមុត្តមំ ។ ទ្រង់បញ្ចប់ដូចម្តេច? ទ្រង់បញ្ចប់ថា "ម្នាលទេវបុត្ត ព្រោះ ហេតុនៃជនអ្នកធ្វើមង្គលដូចដែលពោលនេះ រមែងដល់នូវសិរីសួស្តី ក្នុងទីទាំង ពួងយ៉ាងនេះ"ដូច្នេះ ព្រោះហេតុនោះ ទើបលោកកាន់យកមង្គលទាំង ៣៨ ប្រការ មានការមិនសេពគប់បុគ្គលពាលជាដើមនោះថា ខ្ពង់ខ្ពស់បំផុត ប្រសើរបំផុត ល្អ ជាទីបំផុត សម្រាប់ជនទាំងអស់នោះ អ្នកដែលធ្វើមង្គលដូចដែលពោលមកនេះ ។

ទីបញ្ចប់នៃទេសនា ដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់បញ្ចប់យ៉ាងនេះ ទេវតាសែនកោដិសម្រេចព្រះអរហត្ត ។ ចំនួនដែលសម្រេចសោតាបត្តិផល សកទាគាមិផល អនាគាមិផល រាប់ប្រមាណមិនបាន ។ គ្រានោះ ពេលព្រឹកឡើង ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ហៅព្រះអានន្ទថេរៈមកត្រាស់ថា "ម្នាលអានន្ទ កាលពីយប់មិញ ទេវតាមួយអង្គចូលមកសួរមង្គលបញ្ហា កាលនោះតថាគតបាន ពោលមង្គល ៣៨ ប្រការ ដល់ទេវតាអង្គនោះ ម្នាលអានន្ទ អ្នកចូររៀនមង្គល-

បរិយាយនេះ កាលរៀនហើយ ចូរបង្រៀនភិក្ខុទាំងឡាយ"។ ព្រះថេរៈរៀនហើយ ក៏បង្រៀនភិក្ខុទាំងឡាយ ។ មង្គលសូត្រនេះ អាចារ្យនាំបន្តៗ គ្នាមកប្រព្រឹត្តទៅរហូតដល់សព្វថ្ងៃនេះ គប្បីជ្រាបថា សាសនព្រហ្មចរិយៈនេះ គង់វង្សចម្រើនផ្សព្វផ្សាយនាំគ្នាដឹងច្រើន ក្រាស់ណែនឡើង ដរាបដែលទេវតា និងមនុស្សប្រកាសល្អហើយ ។

ដើម្បីភាពច្បាស់ ក្នុងការសន្សំចំណេះដឹងក្នុងមង្គលពួកនេះ នោះឯង ឥឡូវនេះ នឹងប្រកបសេចក្តីតាំងតែពីដើមដូច្នេះ ។ សត្វទាំងឡាយ ប្រាថ្នាសុខក្នុងលោកនេះ លោកខាងមុខ និងលោកុត្តរសុខទាំងអស់នេះ លះបង់ការសេពគប់បុគ្គលពាលចេញ អាស្រ័យបណ្ឌិត បូជាអ្នកដែលគួរបូជា ការដែលរស់នៅក្នុងប្រទេសដ៏សមគួរ និងភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន ដាស់តឿនក្នុងការបំពេញកុសល តម្កល់ខ្លួនទុកដោយប្រពៃ មានអត្តភាពដែលប្រដាប់ដោយពាហុសច្ចៈ សិល្បៈ និងវិន័យ ពោលសុភាសិតដែលសមរម្យដល់វិន័យ នៅមិនទាន់លះភេទជាគ្រហស្ថដរាបណា ក៏គប្បីជម្រះបំណុលចាស់ ដោយការទំនុកបម្រុងមាតាបិតា ដាក់បំណុលថ្មី ដោយការសង្គ្រោះបុត្រ និងភរិយា ដល់នូវភាពគង់វង្សដោយទ្រព្យ និងស្រូវអង្ករ ដោយភាពជាអ្នកមានការងារមិនច្របូកច្របល់ រើសអូសយកសារៈនៃភោគៈដោយទាន និងសារៈនៃជីវិតដោយការប្រព្រឹត្តធម៌ ធ្វើប្រយោជន៍អនុគ្រោះដល់ជនរបស់ខ្លួន ដោយការសង្គ្រោះញាតិ និងប្រយោជន៍អនុគ្រោះដល់ជនដទៃៗ ដោយភាពជាអ្នកមានការងារ ដែលមិនមានទោស វៀរ

ចាកការធ្វើបាបអ្នកដទៃ ដោយការវៀរចាកបាប ការធ្វើបាបខ្លួនឯង ដោយការសង្រួមចាកការផឹកទឹកស្រវឹង ក-ពូនចំណែកកុសលដោយការមិនប្រមាទក្នុងធម៌ទាំងឡាយ លះភេទគ្រហស្ថ ដោយភាពជាដែលអ្នកក-ពូនកុសល សូម្បីតែតាំងក្នុងភាវៈជាបព្វជិត ក៏ញ៉ាំងវត្តសម្បទាឱ្យសម្រេច ដោយការគោរពក្នុងព្រះពុទ្ធជាម្ចាស់ សាវករបស់ព្រះពុទ្ធជាម្ចាស់ និងឧបជ្ឈាចារ្យជាដើម និងដោយការបន្ទាបខ្លួន លះសេចក្តីល្មោភក្នុងបច្ច័យ ដោយការសន្តោស តាំងនៅក្នុងសប្បុរិសភូមិ ដោយភាពជាអ្នកកតញ្ញូ លះភាពជាអ្នកមានការតក់ស្លុត ដោយការស្តាប់ធម៌ គ្របសង្កត់អន្តរាយគ្រប់យ៉ាងដោយខន្តិ ធ្វើខ្លួនឱ្យមានទីពឹង ដោយភាពជាអ្នកប្រដៅងាយ មើលការប្រកបការបដិបត្តិ ដោយការឃើញសមណៈ កាត់បន្ថយភាពសង្ស័យក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីសង្ស័យ ដោយការសន្ទនាធម៌ ញ៉ាំងសីលវិសុទ្ធិឱ្យកើតដោយតបៈ គឺឥន្ទ្រិយសំវរៈ ញ៉ាំងចិត្តវិសុទ្ធិឱ្យបរិសុទ្ធដោយព្រហ្មចរិយៈ គឺសមណធម៌ និងញ៉ាំងវិសុទ្ធិ ៤ ក្រៅអំពីនោះឱ្យដល់ព្រម ញ៉ាំងញាណទស្សនវិសុទ្ធិ ដែលជាបរិយាយនៃការឃើញអរិយសច្ចៈឱ្យកើតឡើងដោយបដិបទានេះ ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលរាប់បានថាអរហត្តផល កាលដែលធ្វើឱ្យជាក់ច្បាស់ហើយ ជាអ្នកដែលមានចិត្តមិនញាប់ញ័រដោយលោកធម៌ ៨ ដូចភ្នំសិនេរុ មិនញាប់ញ័រដោយខ្យល់ និងភ្លៀង រមែងជាអ្នកមិនសោកសៅ ប្រាសចាកធូលីគឺកិលេស មានភាពក្សេមត្រេះត្រចង់ និងភាពក្សេមត្រេះត្រចង់ រមែងជាសភាវៈសូម្បីតែសត្រូវមួយនាក់ឱ្យចុះចាញ់មិនបាន

ក្នុងទីទាំងពួង ទើបបានដល់នូវសិរីសួស្ដីក្នុងទីគ្រប់ស្ថាន ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទើបត្រាស់ថា ៖

ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា

សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ ។

*ទេវតានិងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះហើយ ជាអ្នក មិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្ដីក្នុង ទីទាំងពួង ( ម្នាល ទេវតាអ្នកចូរប្រកាន់ជឿថា) មង្គលទាំង ៣៨ ប្រការ មានកិរិយាមិនសេពគប់បុគ្គល ពាលជាដើមនោះរបស់ទេវតា និងមនុស្សទាំងអម្បាលនោះ ជាមង្គលដ៏ឧត្តម ។*

បរមត្ថជោតិកាយ ខុទ្ទកបាឋដ្ឋកថាយ

មង្គលសុត្តវណ្ណនា និដ្ឋិតា ។

**ការពណ៌នាមង្គលសូត្រ**

**នៃ**

**អដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះ បរមត្ថជោតិកា ចប់ ។**

## ៦-រតនសុត្តវណ្ណនា

## **ពណ៌នារតនសូត្រ**

## និក្ខេបប្បយោជន៍

## **ប្រយោជន៍នៃការតាំងបទ**

*ឥឡូវនេះ ជាលំដាប់នៃការពណ៌នារតនសូត្រ ដែលតាំងឡើងតាមលំដាប់អំពីមង្គលសូត្រនោះ ដោយន័យជាដើមថា យានីធ ភូតានិ ។ ខ្ញុំនឹងពោលប្រយោជន៍នៃការតាំងរតនសូត្រនោះ ទុកក្នុងទីនេះ បន្ទាប់អំពីនោះ កាលសម្ដែងញុំាងការចុះកាន់សេចក្ដីនៃព្រះសូត្រនេះ ដោយនិទានវចនៈដ៏បរិសុទ្ធិល្អ ដូចជាការចុះកាន់ទឹកក្នុងស្ទឹង និងបឹងជាដើម ផ្លូវកំពង់ទឹកដែលហ្មត់ចត់ល្អ ប្រកាសន័យនេះថា "សូត្រនេះអ្នកណាពោល ពោលពេលណា ពោលក្នុងទីណា ពោលព្រោះហេតុអ្វី ហើយធ្វើការពណ៌នាសេចក្ដីនៃរតនសូត្រនេះ" ។*

*បណ្ដាសូត្រទាំងពីរនោះ ព្រោះហេតុដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សម្ដែងការរក្សាខ្លួនឯង និងការកម្ចាត់អាសវៈទាំងឡាយដែលមានការធ្វើមិនល្អ និងការមិនធ្វើនូវអំពើល្អជាបច្ច័យដោយមង្គលសូត្រ ចំណែកសូត្រនេះឱ្យសម្រេចការរក្សាអ្នកដទៃ និងការកម្ចាត់អាសវៈទាំងឡាយដែលមានអមនុស្សជាដើម ជាបច្ច័យ ដូច្នេះ សូត្រនេះ ទើបជាទីតាំងទុកក្នុងលំដាប់តអំពីមង្គលសូត្រនោះឯង ។*

*ប្រយោជន៍នៃការតាំងរតនសូត្រនោះទុកក្នុងទីនេះប៉ុណ្ណោះសិន ។*

# វេសាលីវត្ថុ

## រឿងក្រុងវេសាលី

ឥឡូវនេះ ក្នុងពាក្យថា យេន វុត្តំ យទា យត្ថ យស្មា ចេតំ នេះ អ្នកជំទាស់ពោលថា ក៏សូត្រនេះអ្នកណាពោល ពោលកាលណា ពោលនៅទីណា និងពោលព្រោះហេតុអ្វី ។ សូមពន្យល់ច្បាស់ដូចនេះ ការពិតសូត្រនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ព្រះអង្គត្រាស់មួយព្រះអង្គឯង ព្រះសាវកជាដើម មិនពោលទេ ។ ត្រាស់កាលណា ត្រាស់កាលក្រុងវេសាលីត្រូវឧបទ្រវៈទាំងឡាយមានទុរ្ភិក្សភ័យជាដើម ចូលទៅរកាំង ព្រះមានព្រះភាគជាម្ចាស់ ដែលពួកស្ដេចលិច្ឆវីនៃក្រុងវេសាលីចូលអង្វរ យាងព្រះអង្គអំពីក្រុងរាជគ្រឹះទៅកាន់ក្រុងវេសាលី កាលនោះរតនសូត្រនោះ ព្រះអង្គក៏ត្រាស់ដើម្បីបំបាត់ឧបទ្រវៈទាំងនោះក្នុងក្រុងវេសាលី ។ ការវិសជ្ជនាបញ្ហាទាំងនោះ ដោយសង្ខេបមានប៉ុណ្ណោះ ។ ចំណែកសេចក្ដីពិស្ដារ បូរាណាចារ្យទាំងឡាយពណ៌នាទុកចាប់តាំងពីរឿងក្រុងវេសាលីជាដើមទៅ ។

បានឮមកថា ព្រះមហេសីរបស់ព្រះបាទក្រុងពារាណសី ទ្រង់ព្រះគភ៌ ។ ព្រះនាងទ្រង់ជ្រាបហើយ ក៏ក្រាបទូលព្រះរាជាឱ្យទ្រង់ជ្រាប ។ ព្រះរាជា ក៏ទ្រង់ព្រះរាជទានគ្រឿងការពារព្រះគភ៌ ។ ព្រះនាងបានទទួលគ្រឿងការពារ

ព្រះគភ៌មកយ៉ាងល្អ ក៏ស្តេចទៅកាន់ផ្ទះប្រសូតក្នុងវេលាព្រះគភ៌ចាស់ ។ ពួកលោកអ្នកមានបុណ្យ រមែងប្រសូតអំពីគភ៌ក្នុងវេលាជិតភ្លឺ ។ ក៏បណ្តាលោកអ្នកមានបុណ្យទាំងនោះ ព្រះមហេសីព្រះអង្គនោះ ក៏ជាអ្នកមានបុណ្យមួយព្រះអង្គ ព្រោះហេតុនោះ វេលាជិតភ្លឺព្រះនាងក៏ប្រសូតដុំសាច់ ដូចជាផ្កាចម្ប៉ា មានត្របកពណ៌ក្រហមដូចជ័រ ។ តអំពីនោះ ព្រះនាងទ្រង់ត្រិះរិះថា “ព្រះនាងទេវីព្រះអង្គដទៃៗ ក៏ប្រសូត ព្រះឱរសដូចរូបមាស ព្រះអគ្គមហេសីប្រសូតដុំសាច់ដូចនោះ សំឡេងតិះទៀននឹងគប្បីមានដល់យើងចំពោះព្រះភ័ក្ត្រព្រះរាជា ព្រោះទ្រង់ខ្លាចការតិះទៀននោះ” ទើបទ្រង់បញ្ជាឱ្យដាក់ដុំសាច់នោះចុះក្នុងភាជន៍មួយ យកភាជន៍មួយទៀតគ្របបិទទុកហើយ ប្រថាប់ត្រារបស់ព្រះរាជា ឱ្យបណ្តែតទៅតាមក្រសែស្ទឹងគង្គា ។ គ្រាន់តែព្រះរាជឱរស គឺរាជបុរសទាំងឡាយដាក់ចុះទៅ ទេវតាទាំងឡាយ ក៏ចាត់ការរក្សា ព្រមទាំងយកជ័រមហាហិង្គុ(១)ចារិកផែនមាសចងជាប់នឹងភាជនៈនោះថាព្រះរាជឱរស-ធីតារបស់ព្រះអគ្គមហេសី នៃព្រះបាទក្រុងពារាណសី ។ បន្ទាប់ពីនោះ ភាជនៈមិនត្រូវបានភ័យ គឺរលកទឹកបោកបក់ ក៏អណ្តែតទៅតាមក្រសែស្ទឹងគង្គា ។

---

១-ឈ្មោះជ័រស្ងួមួយប្រភេទ មានក្លិនស្អុយធួលហឹរក្តៅភាស សម្រាប់ប្រើផ្សំជាគ្រឿងឱសថខ្មែរតាំងពីក្នុងបុរាណកាលរៀងមកហៅថាថ្នាំមហាហិង្គុ ។ (វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជោតញាណោ ជួន ណាត)

សម័យនោះ តាបសមួយរូបអាស្រ័យក្នុងត្រកូលរបស់អ្នកគង្វាលគោ នៅជិតប្រាំងស្ទឹងគង្គា ។ ព្រឹកឡើង តាបសរូបនោះ ក៏ចុះកាន់ស្ទឹងគង្គា ក្រឡេកឃើញកាជន៍នោះអណ្តែតមក ក៏កាន់យកដោយបង្សុកូលសញ្ញា ដោយយល់ថា ជារបស់ដែលគេបោះចោលហើយ ។ បន្ទាប់ពីនោះក៏ឃើញ ផែនអក្សរ និងត្រារបស់ព្រះរាជា ក៏ស្រាយចេញឃើញដុំសាច់នោះ កាលឃើញហើយ តាបសក៏គិតថាទំនងជាសត្វកើតក្នុងគភ៌ដូច្នោះ ទើបមិនស្អុយ ក៏នាំដុំសាច់នោះទៅកាន់អាស្រម ដាក់ទុកក្នុងកន្លែងស្អាត ។ កន្លងទៅកន្លះខែ ដុំសាច់នោះក៏បែកជាពីរដុំ តាបសឃើញហើយក៏ដាក់ទុកយ៉ាងល្អ ។ តអំពីនោះ កន្លងទៅកន្លះខែទៀត ដុំសាច់មួយដុំក៏កើតជាពកមួយដុំៗ ជាប្រាំ សាខាដូចជា ដៃ ជើង និងក្បាល តាបសក៏ផ្ចិតផ្ចង់ទុកដាក់ដោយល្អ ។ បន្ទាប់អំពីនោះ កន្លះខែទៀត ដុំសាច់មួយដុំ ក៏កើតជាទារកប្រាកដជារូបមាស ដុំសាច់មួយដុំទៀតក៏កើតជាទារិកា តាបសកើតសេចក្តីស្រឡាញ់ដូចបុត្រក្នុងទារកទាំងពីរនោះ ។ ទឹកដោះក៏កើតអំពីមេដៃរបស់តាបសនោះ តាំងអំពីនោះមក តាបសបានទឹកដោះ និងអាហារ ក៏បរិភោគអាហារបន្តក់ទឹកដោះទៅក្នុងមាត់ទារកទាំងពីរនោះ ។ វត្ថុណាៗ ចូលទៅក្នុងពោះរបស់ទារកនោះ វត្ថុនោះៗ ទាំងអស់ក៏នឹងឃើញដូចចូលទៅក្នុងកាជន៍ធ្វើដោយកែវមណី ។ ទារកទាំងពីរនោះ មិនមានស្បែកយ៉ាងនេះ ។ តែអាចារ្យពួកដទៃៗ ពោលថា ស្បែករបស់ទារកទាំងពីរនោះថា្វ ដូចគ្នាដូចត្រូវស្នាមអំបោះដេរទុក ។ ទារកទាំងនោះ ទើប

ប្រាកដឈ្មោះថា **លិច្ឆវី** ព្រោះមិនមានស្បែក ឬព្រោះមានស្បែកថ្លា ដោយប្រការដូចនេះ ។

តាបសចិញ្ចឹមទារក គ្រាន់តែព្រះអាទិត្យរះឡើង ក៏ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត វេលាថ្ងៃក៏ត្រឡប់មកវិញ ។ អ្នកគង្វាលគោទាំងឡាយ ដឹងដល់ការខ្វល់ខ្វាយរបស់តាបសនោះ ក៏ពោលថា លោកម្ចាស់ ការចិញ្ចឹមទារកជាកង្វល់របស់អ្នកបួស សូមមេត្តាប្រោសឱ្យទារកដល់ពួកយើងចុះ ពួកយើងនឹងជួយចិញ្ចឹម សូមលោកម្ចាស់ធ្វើកិច្ចរបស់លោកចុះ តាបសក៏ព្រមទទួល លុះព្រឹកឡើង ពួកអ្នកគង្វាលគោ ក៏ជួយគ្នាធ្វើថ្នល់ឱ្យរាប ហើយរោយផ្កា លើកទង់ មានតន្ត្រីបទ្ទី នាំគ្នាមកកាន់អាស្រម ។ តាបសពោលថា ទារកទាំងពីរមានបុណ្យច្រើន ពួកលោកចូរជួយគ្នាចិញ្ចឹមឱ្យចម្រើនវ័យដោយការមិនប្រមាទចុះ កាលឱ្យចម្រើនវ័យហើយ ចូររៀបចំអាពាហ៍ពិពាហ៍ជាមួយគ្នា ឱ្យព្រះរាជាទ្រង់ត្រេកអរ ដោយបញ្ចគោរស ចូរជ្រើសរើសប្រទេសជួយគ្នាសាងនគរឡើង ចូរអភិសេកកុមារក្នុងទីនោះ ហើយប្រគល់ទារកឱ្យ ។ ពួកអ្នកគង្វាលគោទទួលពាក្យថា ប្រពៃហើយលោកម្ចាស់ ក៏នាំទារកទៅចិញ្ចឹម ។

ទារកទាំងពីរ ក៏ចម្រើនវ័យធំធាត់ឡើង ក៏លេងដោយការប្រើដៃខ្លះ ជើងខ្លះ វាយតប់ពួកក្មេងរបស់អ្នកគង្វាលគោដទៃៗទៀត ក្នុងកន្លែងឈ្លោះគ្នា កូនក្មេងអ្នកគង្វាលគោទាំងនោះក៏ស្រែកយំ ត្រូវមាតាបិតាសួរថា ស្រែកយំព្រោះអ្វី

ហើយប្រាប់ថា ក្មេងមិនមានមាតាបិតា ដែលតាបសចិញ្ចឹមនេះ គំរាមខ្ញុំ ។ បន្ទាប់ពីនោះ មាតាបិតារបស់ក្មេងពួកនោះ ក៏ពោលថា ទារកពីរនាក់នេះតែងបៀតបៀនធ្វើបាបក្មេងដទៃៗ និងមិនសង្គ្រោះវាលះបង់វាចោល ។ បានឮថា តាំងតែពីពេលនោះមកប្រទេសនោះហៅថា **វជ្ជី** ចម្ងាយប្រមាណ ៣០០ យោជន៍ ។ គ្រានោះ អ្នកគង្វាលគោ ញ៉ាំងព្រះរាជាឱ្យត្រេកអរហើយ ជ្រើសរើសយកប្រទេសនោះ សាងព្រះនគរទុកក្នុងប្រទេសនោះ ហើយអភិសេកព្រះរាជកុមារ ដែលមានព្រះជន្មបាន ១៦ ព្រះវស្សា តាំងជាព្រះរាជា បានធ្វើការវិវាហមង្គលជាមួយទារិការបស់ព្រះអង្គ បានដាក់កតិកាទុកថា នឹងមិននាំទារិកាមកអំពីខាងក្រៅ នឹងមិនឱ្យទារិកាអំពីទីនេះ ដល់នរណាៗទេ ។ ដោយការនៅរួមគ្នា គ្រាដំបូងនៃព្រះកុមារកុមារីនោះ ក៏កើតទារកមួយគូរជាធីតា ១ ជាឱរស ១ ដោយអាការៈយ៉ាងនេះ ក៏កើតជាគូរៗ ដល់១៦ដង ។ បន្ទាប់អំពីនោះ កាលទារកពួកនោះ ចម្រើនវ័យដោយលំដាប់ នគរក៏មិនល្មមដែលនឹងដាក់ អារាម ឧទ្យាន ស្ថានទីនៅ បរិវារ និងសម្បត្តិ ទើបឡោមព័ទ្ធជុំវិញដោយប្រការ ៣ ជាន់ ចន្លោះ១គាវុតៗ ព្រោះនគរនោះ ត្រូវពង្រីកចេញញយៗ ទើបកើតនាមថា វេសាលី នេះឯង ។

ឥទំ វេសាលិវត្ថុ និដ្ឋិតំ

**ចប់រឿងក្រុងវេសាលី**

សម្រាប់ជាធម្មទាន

## ភគវតោ និមន្តនំ

## ការនិមន្តមករបស់ព្រះដ៏មានព្រះភាគ

កាលព្រះមានព្រះភាគកើតឡើង ក្រុងវេសាលីនេះ បានជាទីស្តុកស្តម្ភមានសភាពរីងមាំ ។ ព្រោះថា ក្នុងក្រុងវេសាលីនោះមានស្តេច ៧៧០៧ ព្រះអង្គ ។ ព្រះយុវរាជសេនាបតិ និងភណ្ឌាគារិកជាដើមក៏ដូចគ្នា ដូចដែលលោកពោលទុកថា "សម័យនោះឯង ក្រុងវេសាលីក៏ស្តុកស្តម្ភទូលាយមានជនច្រើន មានមនុស្សមីរដេរដាស មានអាហារ ផ្ទះកំពូល ចំណីក៏សម្បូណ៌ មានប្រាសាទ ៧ ពាន់ ៧ រយ ៧ ប្រាសាទ មានផ្ទះកំពូល ៧ ពាន់ ៧ រយ ៧ ផ្ទះ មានសួនច្បារ ៧ ពាន់ ៧ រយ ៧ សួនច្បារ មានស្រះបោក្ខរណី ៧ ពាន់ ៧ រយ ៧ ស្រះ"[១] ។

សម័យក្រោយមក ក្រុងវេសាលីនោះ កើតទុរ្ភិក្សភ័យ រាំងភ្លៀងដាច់សន្ទូង ។ មនុស្សក្រីក្រស្លាប់មុនគេ គេបោះសាកសពទាំងនោះទៅក្រៅនគរ ។ ពួកអមនុស្សធុំក្លិន មនុស្សស្លាប់ ក៏នាំគ្នាចូលព្រះនគរ ។ បន្ទាប់ពីនោះ មនុស្សក៏ស្លាប់មន្ទ្រមច្រើនឡើង ។ ព្រោះភាពបដិកូលនោះ អហិវាតករោគ[២]ក៏កើតដល់

---

១-វិនយបិដក មហាវគ្គ លេខ ៨ ទំព័រ ៦១ ។

២-រោគកើតអំពីខ្យល់មានពិស ដូចជាពិសពស់ គឺជំងឺខ្យល់ដែលបណ្តាលឱ្យចុះផង ក្អួត ផង ។ ពាក្យធម្មតាច្រើនហៅថា អាសន្នរោគ ឬជំងឺខ្យល់ ឬជំងឺខ្យល់ព្យុះ ។ (វចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួន ណាត) ។

សត្វទាំងឡាយ ។ អ្នកស្រុកក្រុងវេសាលីត្រូវភ័យ ៣ យ៉ាងគឺ ទុព្ភិក្សភ័យ អមនុស្សភ័យ និងរោគភ័យគ្របសង្កត់ហើយ ក៏ចូលទៅគាល់ព្រះរាជាក្រាបទូលថា បពិត្រមហារាជ ភ័យ ៣ យ៉ាងកើតមាន ក្នុងព្រះនគរនេះហើយ ខ្ញុំព្រះអង្គមុននេះតំណនៃរាជត្រកូល ៧ មិនធ្លាប់កើតភ័យដូច្នេះឡើយ ទំនងជាព្រះអង្គទ្រង់មិនតាំងនៅក្នុងធម៌ ឥឡូវនេះ ភ័យនោះ ទើបកើតឡើង ។ ព្រះរាជាទ្រង់ប្រជុំស្តេចលិច្ឆវីគ្រប់ព្រះអង្គក្នុងកន្លែងរាជការត្រាស់ថា "សូមអ្នកទាំងឡាយ ពិចារណានូវភាពមិនតាំងនៅក្នុងធម៌របស់យើងឡើងវិញ" ។ ស្តេចលិច្ឆវីទាំងនោះ ពិចារណាសារឡើងវិញដល់ប្រពៃណីគ្រប់យ៉ាង ក៏ទ្រង់មិនឃើញការគ្រប់គ្រងដែលមិនប្រកបដោយធម៌យ៉ាងណាមួយ បន្ទាប់ពីនោះ មនុស្សទាំងឡាយពិចារណាមិនឃើញទោសរបស់ព្រះរាជា ទើបនាំគ្នាគិតថា ភ័យរបស់យើងនេះនឹងរម្ងាប់ទៅបានយ៉ាងណា ក្នុងទីប្រជុំនោះ ស្តេចលិច្ឆវីពួកខ្លះ អាងដល់សាស្តាទាំង ៦ ថា គ្រាន់តែសាស្តាពួកនេះ ឈានជើងចុះប៉ុណ្ណោះ ភ័យក៏រម្ងាប់ទៅ ។ ពួកខ្លះពោលថា បានឮថា ព្រះពុទ្ធជាម្ចាស់ កើតឡើងហើយក្នុងលោក ព្រះមានព្រះភាគជាម្ចាស់អង្គនោះ ទ្រង់សម្តែងធម៌ ដើម្បីប្រយោជន៍អនុគ្រោះដល់ពួកសត្វ ទ្រង់មានឫទ្ធិច្រើន មានអានុភាពច្រើន គ្រាន់តែព្រះអង្គដាក់ព្រះបាទចុះប៉ុណ្ណោះ ភ័យគ្រប់យ៉ាងក៏នឹងរម្ងាប់ទៅ ។ ព្រោះហេតុនោះ ស្តេចលិច្ឆវីទាំងនោះ ទើបមានព្រះទ័យត្រេកអរ ហើយត្រាស់ថា ក៏ព្រះមានព្រះភាគជាម្ចាស់ព្រះអង្គនោះ ឥឡូវនេះ គង់នៅទីណា? ពួកយើងនឹងបញ្ជូនមនុស្សទៅយាង ទោះបីព្រះអង្គមិនយាងមកក៏ដោយចុះ ។

ស្តេចលិច្ឆវីដទៃទៀតត្រាស់ថា ធម្មតាព្រះពុទ្ធទ្រង់អាណិតសត្វ ហេតុអ្វីទ្រង់មិនយាងមក ។ ក៏ព្រះមានព្រះភាគជាម្ចាស់ព្រះអង្គនោះ ឥឡូវនេះ គង់នៅក្នុងក្រុងរាជគ្រឹះ ព្រះបាទពិម្ពិសារទ្រង់ឧបដ្ឋាក ក្រែងព្រះបាទពិម្ពិសារនឹងទ្រង់មិនឱ្យយាងមក ។ ស្តេចលិច្ឆវីត្រាស់ថា បើយ៉ាងនោះ យើងនឹងទូលព្រះបាទពិម្ពិសារ ឱ្យទ្រង់យល់ព្រះទ័យ ហើយយាងព្រះមានព្រះភាគមក ហើយទ្រង់ប្រគល់គ្រឿងបណ្ណាការដ៏ច្រើន បញ្ជូនទៅឱ្យស្តេចលិច្ឆវីពីរព្រះអង្គ ព្រមដោយកងកម្លាំងថ្នាក់ធំ ទៅកាន់រាជដំណាក់ព្រះបាទពិម្ពិសារដោយបញ្ជាថា “សូមទូលព្រះបាទពិម្ពិសារ ឱ្យយល់ព្រះទ័យ ហើយយាងព្រះមានព្រះភាគជាម្ចាស់មក” ។ ស្តេចលិច្ឆវីទាំងពីរព្រះអង្គទៅថ្វាយគ្រឿងបណ្ណាការដល់ព្រះបាទពិម្ពិសារ ហើយប្រាប់ឱ្យទ្រង់ជ្រាបរឿងរ៉ាវ ហើយទូលថា “បពិត្រមហារាជ ព្រះអង្គទ្រង់ព្រះករុណាប្រោស យាងព្រះមាន-ព្រះភាគជាម្ចាស់ ស្តេចមកកាន់នគររបស់ខ្ញុំព្រះអង្គផងចុះ” ។ ព្រះរាជា មិនទទួលត្រាស់ថា ពួកលោកដឹងដោយព្រះអង្គឯងចុះ ។ ស្តេចលិច្ឆវី ក៏ទូលព្រមថាប្រពៃហើយព្រះអង្គ ហើយចូលទៅគាល់ព្រះមានព្រះភាគជាម្ចាស់ ថ្វាយបង្គំហើយក្រាបទូលយ៉ាងនេះថា “បពិត្រព្រះអង្គដ៏ចម្រើន ភ័យ ៣ យ៉ាងកើតឡើងក្នុងនគររបស់ខ្ញុំព្រះអង្គ បើព្រះមានព្រះភាគជាម្ចាស់គប្បីយាងមកសោត សេរីសួស្តី ក៏នឹងគប្បីមានដល់ពួកខ្ញុំព្រះអង្គ” ។ ព្រះមានព្រះភាគទ្រង់ពិចារណាថា “កាលត្រាស់**រតនសូត្រ** ក្នុងក្រុងវេសាលី ការរក្សានឹងផ្សាយចេញទៅសែនកោដិចក្កវាឡ ចប់ព្រះសូត្រ សត្វ ៨ ម៉ឺន ៤ ពាន់នឹងត្រាស់ដឹងធម៌” ហើយទើបទ្រង់ទទួលការយាង ។

គ្រានោះ ព្រះបាទពិម្ពិសារទ្រង់ត្រាស់ជំណឹង ព្រះមានព្រះភាគទ្រង់ទទួលការយាងហើយ មេត្តាទ្រង់ឃោសនាក្នុងព្រះនគរថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់ទទួលការយាងទៅកាន់ក្រុងវេសាលី ហើយស្ដេចចូលទៅគាល់ព្រះមានព្រះភាគជាម្ចាស់ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ទទួលយាងទៅកាន់ក្រុងវេសាលី ឬព្រះអង្គ? ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ ។ ស្ដេចទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើយ៉ាងនោះ មេត្តាទ្រង់រង់ចាំរហូតដល់ខ្ញុំព្រះអង្គចាត់ចែងផ្លូវថ្វាយរួចរាល់សិនព្រះអង្គ ។

គ្រានោះ ព្រះបាទពិម្ពិសារទ្រង់ធ្វើដី ៥ យោជន៍ ចន្លោះក្រុងរាជគ្រឹះ និងស្ទឹងគង្គាឱ្យរាបស្មើ ហើយញុំាងគេឱ្យកសាងវិហារក្នុងយោជន៍នោះៗ ហើយក្រាបទូលដល់ព្រះមានព្រះភាគជាម្ចាស់ ដល់វេលាដែលយាងទៅ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រមទាំងភិក្ខុ ៥០០ រូបជាបរិវារ យាងទៅ ព្រះរាជាទ្រង់យកផ្កាឈើ ៥ពណ៌រោយផ្លូវ ៥ យោជន៍ ត្រឹមក្បាលជង្គង់ ឱ្យលើកទង់សំពត់ ឆ្នាំងទឹក ដើមចេកជាដើម ឱ្យកាន់ស្វេតច្ឆត្រពីរជាន់សម្រាប់ព្រះដ៏មានព្រះភាគជាម្ចាស់ មួយជាន់សម្រាប់ភិក្ខុសង្ឃមួយរូបៗ ទ្រង់ធ្វើការបូជាដោយផ្កាឈើ និងរបស់ក្រអូបជាដើម ព្រមទាំងរាជបរិពាររបស់ព្រះអង្គ ឱ្យព្រះមានព្រះភាគជាម្ចាស់គង់នៅក្នុងវិហារមួយខ្នងៗ ថ្វាយមហាទាន ទ្រង់នាំស្ដេចយាងកាន់ប្រាំងស្ទឹងគង្គាប្រាំថ្ងៃ ។ ក្នុងទីនោះ ទ្រង់ប្រដាប់ទូកដោយគ្រឿងប្រដាប់គ្រប់យ៉ាង ហើយទ្រង់បញ្ជូនរាជសារទៅថ្វាយស្ដេចលិច្ឆវីក្រុងវេសាលីថា "ព្រះមានព្រះភាគជាម្ចាស់យាងមក

ហើយ សូមស្តេចលិច្ឆវីគ្រប់ព្រះអង្គរៀបចំផ្លូវថ្វាយការយាងមករបស់ព្រះមានព្រះភាគចុះ" ។ ស្តេចលិច្ឆវីទាំងអស់ទទួលព្រមគ្នាថា នឹងធ្វើការបូជាទ្វេគុណ ធ្វើដី ៣ យោជន៍ចន្លោះក្រុងវេសាលី និងស្ទឹងគង្គាឱ្យរៀបរយ និងចាត់ចែងស្វេតច្ឆត្រ ៤ ជាន់ សម្រាប់ព្រះមានព្រះភាគជាម្ចាស់ សម្រាប់ភិក្ខុមួយរូបៗពីរជាន់ ធ្វើការបូជាស្តេច យាងមកសន្សឹមៗ ។

គ្រានោះ ព្រះបាទពិម្ពិសារ ទ្រង់ញ៉ាំងគេឱ្យធ្វើទូក ២ ហើយធ្វើមណ្ឌបប្រដាប់ដោយកួងផ្កា ក្រាលកម្រាលពុទ្ធាសនៈធ្វើដោយរតនៈសុទ្ធក្នុងមណ្ឌបនោះ ។ ព្រះមានព្រះភាគជាម្ចាស់ គង់លើពុទ្ធាសនៈនោះ ។ សូម្បីភិក្ខុ ៥០០ រូបក៏ឡើងកាន់ទូក គង់តាមលំដាប់ ។ ព្រះរាជាកាលទៅតាមព្រះមានព្រះភាគជាម្ចាស់ ក៏ចុះទឹកត្រឹម-កក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ នៅក្បែរមាត់ច្រាំងស្ទឹងគង្គានេះឯង រហូតព្រះមានព្រះភាគជាម្ចាស់ នឹងយាងត្រឡប់មកហើយ ក៏យាងត្រឡប់ទៅវិញ ។ ទេវតាខាងលើរហូតដល់អកនិដ្ឋកភព បាននាំគ្នាធ្វើការបូជា នាគរាជទាំងឡាយ កម្ពលនាគ និងអស្សតរនាគជាដើម ដែលអាស្រ័យនៅក្រោមស្ទឹងគង្គា ក៏នាំគ្នាធ្វើការបូជា ។ ដោយការបូជាធំយ៉ាងនេះ ព្រះមាន-ព្រះភាគជាម្ចាស់ យាងទៅកាន់ស្ទឹងគង្គាអស់ចម្ងាយផ្លូវយ៉ាងឆ្ងាយប្រមាណ ១ យោជន៍ ក៏ចូលដែនរបស់ពួកស្តេចលិច្ឆវី ។

ពេលនោះ ពួកស្តេចលិច្ឆវីធ្វើការបូជាទ្វេគុណ ដូចព្រះបាទពិម្ពិសារទ្រង់ធ្វើការបូជាដែរ ចេញទៅទទួលព្រះមានព្រះភាគជាម្ចាស់ ដល់ក្នុងទឹកប្រមាណត្រឹម-ក ។ ខណៈនោះឯង មួយរំពេចនោះមហាមេឃ ដែលមានកំពូលរុំព័ទ្ធដោយភាពងងឹត មានពន្លឺផ្លេកបន្ទោរបណ្តែតខ្លួនទៅ សំឡេងគឹកកងរំពង ក៏បន្លឺឡើងក្នុងទិសទាំង ៤ ។ លំដាប់នោះ ព្រះមានព្រះភាគជាម្ចាស់ លើកព្រះបាទដាក់ចុះត្រង់មាត់ច្រាំងនៃស្ទឹងគង្គាជំបូង ភ្លៀងបោក្ខពស្រ្តក៏បង្អុរមក ជនពួកណាត្រូវការទទឹក ជនពួកនោះប៉ុណ្ណោះក៏ទទឹក អ្នកមិនត្រូវការទទឹកក៏មិនទទឹក ។ គ្រប់ទីកន្លែង ទឹករមែងហូរទៅត្រឹមក្បាលជង្គង់ ត្រឹមជើង ត្រឹមចង្កេះ ត្រឹម-ក សាកសពទាំងពួងត្រូវហូរនាំទៅកាន់ស្ទឹងគង្គាផែនដីក៏ស្អាតស្អំ ។

ពួកស្តេចលិច្ឆវី អារាធនាព្រះមានព្រះភាគគង់នៅគ្រប់ៗ កន្លែង ១ យោជន៍ត្រង់ចន្លោះផ្លូវ ថ្វាយមហាទាន ទ្រង់ធ្វើការបូជាជាទ្វិគុណ ៣ ថ្ងៃ ទើបនាំស្តេចទៅក្រុងវេសាលី ។ កាលព្រះមានព្រះភាគជាម្ចាស់យាងដល់ក្រុងវេសាលី ស្តេចសក្កៈជាកំពូលនៃពួកទេវតា ដែលពួកទេវតាចោមរោមហើយ ក៏យាងមកដល់ ។ អមនុស្សទាំងឡាយ ត្រូវទេវតាអ្នកមានស័ក្តិធំប្រជុំគ្នាហើយ នាំគ្នារត់ទៅដោយច្រើន ។ ព្រះមានព្រះភាគជាម្ចាស់ ប្រថាប់ឈរក្បែរទ្វារនគរ ទ្រង់ហៅព្រះអានន្ទមកថា "ម្នាលអានន្ទ! អ្នកចូររៀនរតនសូត្រនេះ គឺគ្រឿងប្រកបពលិកម្ម

ដើរទៅក្នុងចន្លោះកំពែង ៣ ជាន់នៃក្រុងវេសាលី ជាមួយពួកស្តេចលិច្ឆវីរាជកុមារ ធ្វើព្រះបរិត្តហើយបានត្រាស់រតនសូត្រ” ។ ការវិស្សជ្ជនា បញ្ហាទាំងនេះថា ក៏ព្រះសូត្រនេះ អ្នកណាពោល ពោលពេលណា ពោលក្នុងទីណា ពោលព្រោះហេតុអ្វី ? បូរាណាចារ្យទាំងឡាយពណ៌នាទុកហើយដោយពិស្តារ តាំងតែពីរឿងក្រុងវេសាលីជាដើមទៅដោយប្រការដូច្នេះ ។

ព្រោះដូច្នោះ ក្នុងថ្ងៃដែលព្រះមានព្រះភាគជាម្ចាស់ ស្តេចយាងដល់ក្រុង-វេសាលីនោះឯង រតនសូត្រនេះ គឺព្រះមានព្រះភាគជាម្ចាស់ត្រាស់ ជិតទ្វារក្រុងវេសាលី ដើម្បីកម្ចាត់ឧបទ្រពទាំងនោះ ព្រះអានន្ទដ៏មានអាយុក៏រៀនយកកាលនឹងសម្តែងដើម្បីជាបរិត្ត (ការពារឧបទ្វវៈ) ទើបយកបាត្រព្រះមានព្រះភាគដួសទឹកមកដើរប្រោះព្រំទូទាំងព្រះនគរ ។ គ្រាន់តែព្រះថេរៈសម្តែងថា យង្កិញ្ចិ ប៉ុណ្ណោះ ពួកអមនុស្សដែលអាស្រ័យនឹងគំនរសំរាមហើយ និងជញ្ជាំងផ្ទះជាដើមដែលនៅមិនទាន់គេចទៅពេលដំបូង ក៏នាំគ្នាគេចទៅផ្លូវទ្វារទាំង ៤ ។ ទ្វារទាំងឡាយ ក៏មិនមានកន្លែងទំនេរ អមនុស្សពួកខ្លះ កាលមិនបានកន្លែងទំនេរ ក៏ទម្លាយកំពែងក្រុងគេចទៅ ។ គ្រាន់តែពួកអមនុស្សនាំគ្នាចេញទៅហើយ រោគក្នុងខ្លួនរបស់មនុស្សទាំងឡាយក៏ស្ងប់ទៅ ពួកមនុស្សទាំងឡាយ ក៏នាំគ្នាចេញ

មកបូជាព្រះថេរៈ ដោយផ្កាភ្ញីគ្រឿងក្រអូបជាដើមគ្រប់យ៉ាង មហាជនយកគ្រឿងក្រអូបគ្រប់យ៉ាងបូកលាបសណ្ឋាគារ ដែលប្រជុំកណ្តាលព្រះនគរ ធ្វើពិតានវិចិត្រដោយរតនៈ ប្រដាប់ដោយគ្រឿងប្រដាប់ទាំងពួង ក្រាលពុទ្ធាសនៈ ក្នុងទីនោះ ហើយអារាធនាព្រះមានព្រះភាគមក ។

ព្រះមានព្រះភាគ ស្តេចចូលកាន់សណ្ឋាគារ ប្រថាប់គង់លើអាសនៈដែលគេក្រាលទុក ។ ទាំងភិក្ខុសង្ឃ ទាំងព្រះរាជា និងមនុស្សទាំងឡាយ ក៏អង្គុយលើអាសនៈដ៏សមគួរ ។ សូម្បីស្តេចសក្កៈកំពូលជាងពួកទេព្តា ក៏ប្រថាប់អង្គុយជិតជាមួយទេវបរិស័ទក្នុងទេវលោកទាំងពីរ ទាំងទេវតាដទៃៗផង ។ សូម្បីព្រះអានន្ទត្ថេរ ក៏ត្រាច់និមន្តទៅក្រុងវេសាលី ធ្វើអារក្ខាហើយក៏មកព្រមជាមួយអ្នកក្រុងវេសាលីអង្គុយ ក្នុងទីដ៏សមគួរមួយចំណែក ។ ក្នុងទីនោះ ព្រះមានព្រះភាគក៏បានត្រាស់រតនសូត្រនោះ នុ៎ះឯងដល់មនុស្សគ្រប់រូប ។

ក៏មាតិកាពាក្យណា ខ្ញុំបានតាំងទុកថាខ្ញុំនឹងប្រកាសន័យនេះថា "រតនសូត្រនេះ អ្នកណាពោល ពោលកាលណា ពោលក្នុងទីណា និងពោលព្រោះហេតុណា" មាតិកានោះដែលខ្ញុំពោលទុកពិស្តារហើយ ដោយប្រការទាំងឡាយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

យានីធាតិ គាថាវណ្ណនា

**ពណ៌នាគាថា ថា យានីធ**

ឥឡូវនេះ នឹងបន្ថែមសេចក្តី ព្រោះខ្ញុំបានពោលទុកថានឹងពណ៌នាសេចក្តីនៃរតនសូត្រនោះ តែអាចារ្យមួយពួកទៀតពោលថា ព្រះមានព្រះភាគត្រាស់ ៥ គាថា ដើមដ៏សេស ព្រះអានន្ទត្ថេរពោលនឹងយ៉ាងណាក្តី ប្រយោជន៍អ្វីរបស់យើងដោយគាថាបន្តិចបន្តួច ដែលនៅមិនបានត្រួតត្រានេះ ខ្ញុំនឹងពណ៌នាសេចក្តីនៃរតនសូត្រនេះ សូមរៀបដោយប្រការទាំងពួង ។

នឹងពណ៌នាគាថាដំបូងថា យានីធ ភូតានិ ជាដើម ។ ក្នុងគាថាដំបូងនោះ បទថា យានិ បានដល់ យ៉ាងម៉េច មិនថានឹងមានស័ក្តិតិច ឬស័ក្តិច្រើន ។ បទថា ឥធ ប្រែថា ក្នុងប្រទេសនេះ ព្រះដ៏មានព្រះភាគត្រាស់សំដៅដល់ស្ថានទីប្រជុំក្នុងខណៈនោះ ។ ក្នុងបទថា ភូតានិ ភូត-ស័ព្ទ ប្រើសំដៅដល់វត្ថុដែលមាននៅ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា ភូតស្មឹ ចាចិត្តិយំ ជាអាបត្តិបាចិត្តិយ ព្រោះភូតគាម ។ ប្រើសំដៅដល់ខន្ធបញ្ចកៈ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា "ភូតមិទន្តិ ភិក្ខវេ សមនុបស្សថ ម្នាលភិក្ខុ ទាំងឡាយ ពួកលោកចូរពិចារណាឃើញខន្ធបញ្ចកៈនេះ" ។ សំដៅដល់រូប មានបឋវីធាតុជាដើម ៤ យ៉ាង ដូចក្នុង

ប្រយោគជាដើមយ៉ាងនេះថា ចត្តារោ ខោ ភិក្ខុ មហាភូតា ហេតុ ម្នាលភិក្ខុ មហាភូតរូប ៤ ជាហេតុ ។ សំដៅដល់ព្រះខីណាស្រព ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា យោ ច កាលឃសោ ភូតោ ក៏ព្រះខីណាស្រពណាស៊ីកាលវេលា ។ ប្រើសំដៅដល់សត្វ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា សព្វេវ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ សព្វសត្វនឹងបោះបង់ផ្ទះរាងទុក ក្នុងលោក ។ ប្រើសំដៅ ដល់ដើមឈើជាដើម ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា ភូតគាមចាតព្យតាយ ព្រោះប្រាសចាក ភូតគាម ។ ប្រើសំដៅដល់ពួកសត្វខាងក្រោម ទេវតាជាន់ចាតុម្មហារាជកា ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា ភូតំ ភូតតោ សញ្ជានាតិ បានដល់ ពួកសត្វដែលជាពួកសត្វ ក៏ពិតដល់ដូច្នោះ ភូត-ស័ព្ទ គប្បីជ្រាបថា ប្រើក្នុង អត្ថថា អមនុស្សដោយមិនផ្សេងគ្នា ។

បទថា សមាគតានិ ប្រែថា ប្រជុំហើយ ។ បទថា ភុម្មានិ បានដល់ដែលកើតត្រង់ផែនដី ។ ស័ព្ទថា វា ប្រើក្នុងសេចក្ដីថា មិនពិតប្រាកដ ។ ដោយវា-ស័ព្ទនោះ ព្រះមានព្រះភាគទ្រង់ធ្វើវិកប្បតែមួយនេះថា យានីធ ភុម្មានិ វា ភូតានិ សមាគតានិ ហើយត្រាស់ថា យានិ វ អន្តលិក្ខេ ដើម្បីទ្រង់ធ្វើវិកប្បទីពីរទៀត ។ សេចក្ដីថា សត្វពួកណា កើតហើយក្នុងអាកាស សត្វពួកនោះទាំងអស់មកប្រជុំហើយក្នុងទីនេះ ។ ក្នុងសេចក្ដីនេះ សត្វទាំងឡាយដែលកើត

ហើយតាំងអំពីទេវតាជាន់យាមា រហូតដល់ជាន់អកនិដ្ឋ គប្បីជ្រាបថា មានហើយ (កើតហើយ) ក្នុងអាកាសព្រោះជាសត្វ ដែលកើតក្នុងវិមាន ដែលប្រាកដក្នុងអាកាស ។ សត្វទាំងឡាយខាងក្រោម អំពីនោះ តាំងអំពីភ្នំសិនេរុ រហូតដល់ពួកដែលរស់នៅក្នុងដើមឈើ និងវល្លិ៍ជាដើម និងពួកដែលកើតហើយ មានហើយត្រង់ផែនដី សត្វពួកនោះទាំងអស់ គប្បីជ្រាបថា សត្វកើតត្រង់ផែនដី ព្រោះជាសត្វ ដែលកើតក្នុងផ្ទៃដី និងក្នុងដើមឈើ វល្លិ៍ និងភ្នំជាដើម ដែលជាប់អាស្រ័យជាមួយផែនដី ។

ព្រះដ៏មានព្រះភាគ គ្រាទ្រង់កំណត់ពួកសត្វអមនុស្សគ្រប់ពួក ដោយពីរបទថា ភុម្មានិ វា យានិ វ អន្តលិក្ខេ ទ្រង់ក្តោបក្តាប់ដោយបទមួយទៀតទើបត្រាស់ថា សព្វេវ ភូតា សុមនា ភវន្តុ ។ បទថា សព្វេ បានដល់ មិននៅសល់ឡើយ ។សព្ទថា ឯវ ចុះក្នុងអត្ថថា អវធារណៈហាមសេចក្តីដទៃ អធិប្បាយថា មិនលះសូម្បីដល់អ្នកតែម្តង ។ បទថា ភូតា បានដល់ ពួកអមនុស្ស ។ បទថា សុមនា ភវន្តុ បានដល់ រហូតជាអ្នកកើត បីតិសោមនស្ស ។ បទថា អថោបិ ជានិបាតទាំងពីរពាក្យចុះក្នុងអត្ថ គឺការទាញភាសា (ប្រយោគ) ដើម្បីប្រកបទុកក្នុងកិច្ច គឺមុខនាទីអ្នកដទៃ ។ បទថា សក្កច្ច សុណន្តុ ភាសិតំ បានដល់ ធ្វើឱ្យ

ជាប្រយោជន៍ធ្វើទុកក្នុងចិត្ត រួបរួមដោយចិត្តទាំងអស់ ហើយចូរស្តាប់ទេសនារបស់តថាគត ដែលនឹងនាំមកដល់ទិព្វសម្បត្តិ និងលោកុត្តរសុខ ។

ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់បញ្ជាក់ពួកភូត ដោយព្រះតម្រាស់ដែលមិនពិតប្រាកដថា យានីធ ភូតានិ សមាគតានិ ហើយទើបទ្រង់កំណត់ជាពីរចំណែកទៀតថា ភុម្មានិ វា យានិ វ អន្តលិក្ខេ តពីនោះ ក៏ត្រាស់រួមទៀតថា សព្វេវ ភូតា ទ្រង់ប្រកបសត្វទុកក្នុងអាសយសម្បត្តិ ដោយព្រះតម្រាស់នេះថា សុមនា ភវន្តុ ទ្រង់ប្រកបសត្វក្នុងប្រយោគសម្បត្តិ ដោយព្រះតម្រាស់ថា សក្កច្ច សុណន្តុ ភាសិតំ ទ្រង់ប្រកបសត្វទុកក្នុងសម្បត្តិគឺយោនិសោមនសិការៈ និងក្នុងសម្បត្តិ គឺការយោសនាអំពីអ្នកដទៃ ក៏ដូចគ្នាទ្រង់ប្រកបសត្វ ទុកក្នុងសម្បត្តិ គឺការតាំងខ្លួនទុកដោយប្រពៃ និងគប់រកសប្បុរស និងក្នុងសម្បត្តិ គឺហេតុនៃសមាធិនិងបញ្ញាក៏ដូចគ្នា ទើបទ្រង់បញ្ចប់ព្រះគាថា ។

តស្មាហីតិ គាថាវណ្ណនា

**ពណ៌នាគាថា ថា តស្មា ហិ**

នឹងពោលគាថាទី២ ថា តស្មា ហិ ភូតា ជាដើម ។ ក្នុងគាថានោះ បទថា តស្មា ជាពាក្យពោលហេតុ ។ បទថា ភូតា ជាពាក្យអញ្ជើញ ។ បទថា

ឆិសាមេឋ បានដល់ ចូរស្តាប់ ។ បទថា សព្វេ បានដល់ មិនសល់ឡើយ ។ លោកអធិប្បាយថា ព្រោះហេតុដែលលោកទាំងឡាយលះទិព្វស្ថាន និងសេចក្តីពាសពេញនៃគ្រឿងឧបភោគបរិភោគក្នុងទិព្វស្ថាននោះ មកប្រជុំក្នុងទីនេះ ក៏គប្បីស្តាប់ធម៌មិនមែនដើម្បីមើលការរាំការច្រៀងជាដើម ដូច្នេះឯង សូមលោកទាំង-ឡាយដែលជាភូតទាំងអស់មេត្តាតាំងចិត្តស្តាប់ ។

ម្យ៉ាងទៀត ដោយព្រះតម្រាស់ថា សុមនា ភវន្តុ សក្កច្ចំ សុណន្តុ ព្រះមានព្រះភាគទ្រង់ឃើញថា ភូតទាំងនោះមានចិត្តល្អ នឹងប្រាថ្នាស្តាប់ដោយគោរពទើបត្រាស់ថា ព្រោះហេតុដែលលោកទាំងឡាយប្រកបដោយភាពជាអ្នកមានចិត្តល្អ ដោយអត្តសម្មាបណិធិ យោនិសោមនសិការៈ និងអាសយសុទ្ធិ ដោយភាពជាអ្នកប្រាថ្នាស្តាប់ដោយគោរព និងដោយបយោគសុទ្ធិ ជាបទដ្ឋាននៃការចូលមករកសប្បុរស និងឃោសនាអំពីអ្នកដទៃដូច្នេះឯង សូមភូតទាំងឡាយទាំងអស់មេត្តាតាំងចិត្តស្តាប់ចុះ ។

ម្យ៉ាងទៀត ពាក្យណាត្រាស់ថា ភាសិតំ ចុងគាថាដើម ទ្រង់អាងពាក្យនោះជាតួហេតុ ទើបត្រាស់ថា ព្រោះហេតុដែលធម្មតា ភាសិតរបស់តថាគត រកបានដោយលំបាក ព្រោះខណៈដែលវៀរចាកខណៈ ៨ ប្រការរកបានដោយក្រ[១]

---

១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ទសុត្តរសូត្រ លេខ ១៩ ទំព័រ ៣១៨-៣២២ ។

និងមានអានិសង្សច្រើន ព្រោះបដិបត្តិដោយព្រះគុណ មានបញ្ញាគុណ និងករុណាគុណ ទាំងតថាគតក៏បំណងនឹងពោលភាសិតនោះ ទើបបានពោលថា **សុណន្តុ ភាសិតំ** ដូច្នោះឯង សូមលោកទាំងឡាយមេត្តាតាំងចិត្តស្តាប់ចុះ ។ ព្រះតម្រាស់នេះជាការទ្រង់អធិប្បាយ ដោយបទនៃគាថានេះ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់លើកហេតុនេះយ៉ាងនេះ ទ្រង់ប្រកបភូតទាំងឡាយទុកក្នុងការតាំងចិត្តស្តាប់ភាសិតរបស់ព្រះអង្គ ទើបទ្រង់ត្រាស់បន្ថែមភាសិតដែលគប្បីតាំងចិត្តស្តាប់ថា មេត្តំ ករោថ មានុសិយា បជាយ ។ ភាសិតនោះមានសេចក្តីថា ពួកមនុស្សណា ត្រូវឧបទ្រវៈទាំង ៣ ជំទាស់ហើយ សូមលោកទាំងឡាយចូលទៅតាំងមេត្តាជាមិត្ត មានអធ្យាស្រ័យ មានប្រយោជន៍ដល់មនុស្សនោះចុះ ។ តែអាចារ្យពួកខ្លះពោលថា មានុសិកំ បជំ ពាក្យនោះមិនត្រូវព្រោះភូតនៅផែនដីមិនលើកើត ។ អាចារ្យពួកដទៃពណ៌នា សេចក្តីសូម្បីយ៉ាងណា សូម្បីសេចក្តីយ៉ាងនោះក៏មិនត្រូវ ។ ចំណែកក្នុងទីនេះអធិប្បាយថា យើងមិនពោលដោយកម្លាំងភាពជាធំថាជាពុទ្ធៈ ។ តែថាវត្ថុណាជាប្រយោជន៍គាំទ្រដល់ពួកលោក និងដល់មនុស្សទាំងឡាយនេះ យើងនឹងពោលវត្ថុនោះថា មេត្តំ ករោថ មានុសិយា បជាយ សូមពួកលោកធ្វើមេត្តាដល់មនុស្សទាំង-ឡាយចុះ ។

សម្រាប់ជាធម្មទាន

ម្យ៉ាងទៀតក្នុងសេចក្តីនេះ មេត្តា គប្បីជ្រាបថា ជាប្រយោជន៍គាំទ្រដល់អ្នកធ្វើមេត្តាដោយសូត្រទាំងឡាយជាដើមយ៉ាងនេះថា ៖

“ជនទាំងឡាយណា ឈ្នះផែនដីដ៏ដេរដាសទៅដោយសត្វ ជនទាំងឡាយនោះជាធម្មិករាជ ប្រហែលដោយឥសី ហើយញ៉ាំងការបូជាឱ្យប្រព្រឹត្តទៅ (គឺទ្រង់ឈ្លាសវៃក្នុងការទំនុកបម្រុងធញ្ញាហារ គឺស្រែស្រូវឱ្យសម្បូណ៌ក្នុងព្រះរាជាណាចក្រ ១ ទ្រង់ឈ្លាសវៃក្នុងការសង្គ្រោះរាជបុរស ១ ទ្រង់ប្រកបដោយឧបាយចង់ចិត្តមនុស្សឱ្យចូលចិត្ត ១ ទ្រង់មានព្រះបន្ទូលផ្អែមល្ហែម ១ ជាហេតុឱ្យស្រុកទេសរាបទាបសាន្តត្រាណ គ្មានចោរ មិនបាច់ដាក់គន្លឹះចាក់សោរទ្វារផ្ទះ ១) ការបូជាទាំងឡាយនោះ មិនដល់មួយចំណិតនៃ បុគ្គលអ្នកចម្រើនមេត្តាចិត្តដែល ចែកឱ្យជាចំណែក១៦ៗ ដល់ឡើយ”[១] នៃមេត្តាចិត្តដែលអប់រំល្អហើយ ប្រសិនបើថាបុគ្គលមិនមានចិត្តប្រទុស្តរាយ រមែងផ្សាយមេត្តាទៅកាន់សត្វសូម្បីមួយនាក់ ព្រោះហេតុនោះ កុសលទើបមាន អ្នកមានចិត្តគាំទ្រចំពោះសត្វទាំងពួងជាអ្នកប្រសើរធ្វើបុណ្យទុកច្រើន ។

និងដោយអានិសង្ស ១១ ប្រការ[២] ។ មេត្តា គប្បីជ្រាបថាជាប្រយោជន៍សូម្បីដល់សត្វទាំងឡាយដែលគេធ្វើមេត្តា ដោយព្រះសូត្រជាដើមយ៉ាង នេះថា

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ លេខ ៥៣ ទំព័រ ២៩ ។

២-អានិសង្ស មេត្តា ១១ ប្រការ គឺ មេត្តាវិហារិបុគ្គល រមែងដេកលក់ស្រួល ១ ភ្ញាក់ឡើងស្រួល ១ មិនឃើញនូវសុបិនអាក្រក់ ១ ជាទីស្រឡាញ់របស់ពួងមនុស្ស ១ ជាទីស្រឡាញ់របស់ពួក

សម្រាប់ជាធម្មទាន

ទេវតានុកម្បិតោ បោសោ សទា ភទ្រានិ បស្សតិ ។ បុគ្គលដែលទេវតាអនុគ្រោះហើយ រមែងឃើញសេចក្តីចម្រើនគ្រប់កាល ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងថាមេត្តាមានប្រយោជន៍គាំទ្រដល់សូម្បីទាំងពីរចំណែកយ៉ាងនេះ ទើបត្រាស់ថា មេត្តំ ករោថ មានុសិយា បជាយ ដូច្នេះ កាលនឹងទ្រង់សម្តែងសូម្បីឧបការៈទើបត្រាស់ថា ទិវា ច រត្តោ ច ហរន្តិ យេ ពលឹ តស្មា ហិ នេ រក្ខថ អប្បមត្តា ។ ព្រោះដូច្នោះឯងសូមលោកទាំងឡាយជា អ្នកមិនប្រមាទ ជួយបិទបាំងរក្សាពួកមនុស្សដែលនាំពលីមកបូជាទាំងថ្ងៃទាំងយប់ផងចុះ ។ ភាសិតនោះ មានសេចក្តីថា មនុស្សពួកណាសាងរូបទេវតា ដោយគួររូបភាព និងរូបចម្លាក់សត្វចៀមដោយឈើជាដើម ហើយចូលទៅកាន់រុក្ខចេតិយជាដើម ធ្វើពលីកម្មសែនទេវតាក្នុងវេលាថ្ងៃ និងធ្វើពលីកម្មក្នុងវេលាយប់ថ្ងៃ ខាងរនោចជាដើម ឧទ្ទិសដល់ទេវតាទាំងឡាយ ឬថ្វាយសលាកភត្តជាដើម ធ្វើពលីកម្មក្នុងវេលាថ្ងៃ ដែលអាស្រ័យបត្តិទានឱ្យចំណែកបុណ្យដល់អារក្ខទេវតា រហូតដល់ព្រហ្ម និងទេវតាទាំងឡាយ និងធ្វើពលីកម្មក្នុង

---

អមនុស្ស ១ ពួកទេវតាតែងរក្សា ១ ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី មិនចូលទៅក្នុងកាយរបស់មេត្តាវិហារិបុគ្គលនោះ ១ ចិត្តរមែងតាំងនៅមាំធាប់ ១ សម្បុរមុខថ្លាស្រស់បស់ ១ ជាអ្នកមិនវង្វេងហើយធ្វើមរណកាល ១ កាលបើមិនទាន់ត្រាស់ដឹងនូវអរហត្តដ៏ក្រៃលែងជាងមេត្តាសមាបត្តិទេ រមែងបានទៅកើតក្នុងព្រហ្មលោក ១ ។ សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥១ ២៩៧ ។

សម្រាប់ជាធម្មទាន

វលាយប់ ដោយការលើកឆ័ត្រតាំងប្រទីបប្រដាប់កម្រងផ្កា និងដោយចាត់ឱ្យមានការស្តាប់ធម៌រហូត ពេញមួយយប់ជាដើម ដោយអាស្រ័យបត្តិទាន មនុស្សពួកនោះ ពួកលោកនឹងមិនគប្បីរក្សាបានយ៉ាងណា ។ ព្រោះហេតុ ដែលមនុស្សពួកណា ធ្វើពលីកម្មឧទ្ទិសដល់លោកទាំងថ្ងៃទាំងយប់យ៉ាងនេះដូច្នេះ ពួកលោកមេត្តារក្សាមនុស្សពួកនោះចុះ ។ អធិប្បាយថាដូច្នោះ ពួកលោកចូរគ្រប់គ្រងរក្សាមនុស្សពួកនោះ គឺជាអ្នកមិនប្រមាទ ធ្វើភាពជាអ្នកកតញ្ញូនោះ ទុកក្នុងដួងចិត្តរលឹកដល់ជានិច្ច ចូរនាំវត្ថុដែលមិនជាប្រយោជន៍ ចូរនាំចូលទៅនូវវត្ថុដែលជាប្រយោជន៍ដល់ពួកគេ ។

## យង្កិញ្ចីតិ គាថាវណ្ណនា

## ពណ៌នាគាថា ថា យង្កិញ្ចិ

ព្រះមានព្រះភាគ គ្រាទ្រង់ត្រាស់សម្តែងថា មនុស្សមានឧបការៈក្នុងទេវតាទាំងឡាយយ៉ាងនេះហើយ ទើបទ្រង់បន្ថែមប្រកបសច្ចវចនៈ ដោយន័យថា យង្កិញ្ចិ វិត្តំ ដូច្នេះជាដើម ដើម្បីរម្ងាប់ឧបទ្វវៈរបស់មនុស្សទាំងនោះ និងដើម្បីការស្តាប់ធម៌របស់ទេវតា និងមនុស្សទាំងឡាយ ដោយការប្រកាសគុណរបស់ព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម ។ ក្នុងសច្ចវចនៈនោះ បទថា យង្កិញ្ចិ សេចក្តីថា លោកកាន់យកមិនសល់ឡើយ ដោយមិនកំណត់ទុក គឺវត្ថុណាមួយ

ដែលគួរធ្វើការផ្លាស់ប្តូរបានក្នុងកន្លែងនោះៗ ។ បទថា វិត្តំ បានដល់ទ្រព្យ ។ មែនពិត ទ្រព្យនោះឈ្មោះថា វិត្តំ ព្រោះឱ្យកើតសេចក្តីសប្បាយចិត្ត ។ ទ្រង់សម្តែងមនុស្សលោកដោយបទថា ឥធ វា ។ ទ្រង់សម្តែងលោកដ៏សេស ក្រៅអំពីមនុស្សលោកនេះ ដោយបទថា ហុរំ វា ។ ដោយពីរបទនោះ គប្បីជ្រាបថា មាននាគ និងគន្ធព្វជាដើមដ៏សេស វៀរមនុស្ស និងទេវតាទាំងឡាយ ព្រោះកាលព្រមដែលនឹងកាន់យកលោកទាំងពួង វៀរមនុស្សទាំងឡាយ ក៏បានត្រាស់ទុកខាងមុខថា សគ្គេសុ វា ។

ទ្រព្យជាគ្រឿងសប្បាយចិត្តយ៉ាងណា សម្រាប់មនុស្សដែលជាទ្រព្យប្រើផ្លាស់ប្តូរនិងដែលប្រើជាគ្រឿងឧបភោគបរិភោគមាន មាស ប្រាក់ កែវមុក្តា កែវមណី កែវពិទូរ្យ កែវប្រវាឡ កែវទទឹម និងកែវផ្ទៃកជាដើម និងទ្រព្យជាគ្រឿងសប្បាយចិត្តយ៉ាងណា សម្រាប់នាគនិងគ្រុឌជាដើម ដែលកើតឡើងក្នុងភពទាំងឡាយ ដែលមានទទឹងជាច្រើនរយយោជន៍ក្នុង វិមានរតនៈ ត្រង់ផែនដីដែលក្រាលដោយខ្សាច់កែវមុក្តានិងកែវមណី ទ្រព្យជាគ្រឿងសប្បាយចិត្តយ៉ាងនោះ ក៏ជាការសម្តែងហើយដោយបទទាំងពីរនេះ ដោយប្រការដូច្នេះ ។

បទថា សគ្គេសុ វា បានដល់ ទេវលោក ជាកាមាវចរៈ និងរូបាវចរៈ ។ ទេវលោកទាំងនោះ ឈ្មោះថា **សគ្គៈ** ស្ថានសួគ៌ ព្រោះដំណើរទៅ គឺបានដល់ ដោយ

កម្មស្អាត ។ ម្យ៉ាងទៀត ឈ្មោះថា **សគ្គៈ** ព្រោះមានអារម្មណ៍ល្អ ។ បទថា យំ បានដល់ ដែលមានម្ចាស់របស់ ឬមិនមានម្ចាស់របស់យ៉ាងណា ។ បទថា រតនំ បានដល់ រតនៈព្រោះជាវត្ថុ នាំឱ្យកើតសេចក្តីរីករាយនៃចិត្ត ។ ពាក្យ ថា រតនៈ នេះ ជាឈ្មោះរបស់គ្រប់វត្ថុដែលធ្វើឱ្យស្អាត មានតម្លៃច្រើន ថ្លឹងមិនបាន ឃើញបាន ដោយលំបាក និងជារបស់បរិភោគប្រើប្រាស់នៃសត្វអ្នកមិនថោកទាប ដូចដែល លោកពោល ទុកថា ចិត្តីកតំ មហគ្ឃញ្ច អតុលំ ទុល្លភទស្សនំ អនោម- សត្តបរិភោគំ រតនំ តេន វុច្ចតិ ។ វត្ថុធ្វើឱ្យគេរីករាយ មានតម្លៃច្រើន ថ្លឹងមិន បានឃើញបានដោយលំបាក ជាគ្រឿងប្រើប្រាស់របស់សត្វអ្នកមិនថោកទាប ដោយហេតុនោះ ទើបហៅថា រតនៈ ។

បទថា បណីតំ បានដល់ ខ្ពស់បំផុត ប្រសើរបំផុត មិនតិចឡើយ គួរចូល ចិត្ត ។ រតនៈណាក្នុងស្ថានសួគ៌ទាំងឡាយ តាំងអំពីដើមវិមានសុធម្មសភា វិមាន ប្រាសាទដែលជារតនៈសុទ្ធ ច្រើនយោជន៍មានម្ចាស់ និងរតនៈណាដែលទាក់ ទងនៅក្នុងវិមានដែលទទេក្នុងឋានសួគ៌ទាំងឡាយ ដែលធ្វើអបាយប៉ុណ្ណោះឱ្យ ពេញប្រៀប ព្រោះមិនមែនជាសម័យព្រះពុទ្ធជាម្ចាស់ទ្រង់ឧប្បត្តិ មិនមានម្ចាស់ ឬក៏ជារតនៈសូម្បីដទៃណា ដែលអាស្រ័យនៅក្នុងផែនដី មហាសមុទ្រ និង ភ្នំ

ហេមវន្តជាដើមមិនមានម្ចាស់ រតនៈដទៃនោះ ក៏ទ្រង់សម្ដែងហើយដោយបទនៃគាថានេះ ដោយប្រការដូច្នេះ ។ ស័ព្ទថា ន ក្នុងបាទគាថាថា ន នោ សមំ អត្ថិ តថាគតេន ចុះក្នុងអត្ថសេចក្ដីបដិសេធ ។ ស័ព្ទថា នោ ចុះក្នុងសេចក្ដីហាមសេចក្ដីដទៃ ។ បទថា សមំ បានដល់ ប្រៀបធៀប ។ បទថា អត្ថិ ប្រែថាមាន ។ បទថា តថាគតេន បានដល់ ដោយព្រះពុទ្ធជាម្ចាស់ ។ លោកអធិប្បាយទុកយ៉ាងណា ។ អធិប្បាយទុកដូច្នេះ ទ្រព្យជាគ្រឿងសប្បាយចិត្ត និងរតនៈយ៉ាងណា ដែលព្រះដ៏មានព្រះភាគទ្រង់ប្រកាសទុកហើយ បណ្ដាទ្រព្យជាគ្រឿងសប្បាយចិត្ត និងរតនៈនោះ រតនៈសូម្បីត្រឹមតែមួយ៉ាង ដែលស្មើដោយពុទ្ធរតនៈមិនមានឡើយ មែនពិត ទ្រព្យជាគ្រឿងសប្បាយចិត្តសូម្បីនោះណា ឈ្មោះថារតនៈ ព្រោះអត្ថថា ធ្វើឱ្យកើតសេចក្ដីរីករាយនៃចិត្តទ្រព្យ ជាគ្រឿងសប្បាយចិត្តនោះ គឺអ្វី គឺរតនៈ និងមណីរតនៈរបស់ស្ដេចចក្រពត្តិ ដែលកាលកើតឡើងហើយមហាជននឹងមិនធ្វើការរីករាយនៃចិត្តក្នុងទីដទៃ នរណាៗកាន់យកផ្កា និងរបស់ក្រអូបជាដើម ហើយនឹងមិនទៅទីនៅរបស់យក្ខ ឬទីនៅរបស់ភូត ជនសូម្បីគ្រប់គ្នានឹងធ្វើសេចក្ដីគោរព បូជាចំពោះចក្ករតនៈ និងមណីរតនៈប៉ុណ្ណោះ ប្រាថ្នាពរនោះៗ និងពរខ្លះដែលប្រាថ្នាហើយៗ របស់គេក៏សម្រេចផលបាន រតនៈសូម្បីនោះស្មើដោយពុទ្ធរតនៈរមែងមិនមាន ។ ក៏ប្រសិនបើថា ទ្រព្យជាគ្រឿងសប្បាយចិត្ត

ឈ្មោះថា រតនៈ ព្រោះអត្ថថា ធ្វើឱ្យកើតសេចក្ដីគោរពព្រះតថាគតប៉ុណ្ណោះ ក៏ឈ្មោះថា រតនៈ ។ មែនពិតកាល ព្រះតថាគតស្ដេចឧប្បត្តិហើយ ទេវតា និងមនុស្សអ្នកមានស័ក្តិច្រើនគ្រប់ពួក ទាំងទេវតា និងមនុស្សពួកនោះៗ រមែងមិនធ្វើសេចក្ដីគោរពក្នុងរតនៈដទៃ រមែងមិនបូជារតនៈណាៗដទៃ ។ ពិតយ៉ាងនោះ សហបតីព្រហ្ម ក៏បូជាព្រះតថាគត ដោយកម្រងរតនៈ ខ្នាតប៉ុនភ្នំសិនេរុ ។ ទេវតាពួកដទៃ និងមនុស្សទាំងឡាយ មានព្រះបាទពិម្ពិសារ ព្រះបាទកោសល និងអនាថបិណ្ឌិកៈជាដើម ក៏បូជាតាមកម្លាំង ។ ព្រះបាទអសោកមហារាជទ្រង់លះព្រះរាជទ្រព្យ ៩៦ កោដិ ទ្រង់សាងវិហារ ៨៤.០០០ ខ្នង ទូទាំងជម្ពូទ្វីប ឧទ្ទិសថ្វាយព្រះមានព្រះភាគ សូម្បីព្រះអង្គបរិនិព្វានហើយ ។ ក៏នឹងពោលទៅថ្វីដល់ពួកមនុស្ស ដែលគោរពបូជាហើយធ្វើចិត្តឱ្យរីករាយ ។ ម្យ៉ាងទៀត កាលព្រះពុទ្ធព្រះអង្គ សូម្បីទ្រង់បរិនិព្វានហើយ ការធ្វើសេចក្ដីគោរពឧទ្ទិសស្ថានទីប្រសូត ទីត្រាស់ដឹង ទីប្រកាសព្រះធម្មចក្ក និងស្ថានទីបរិនិព្វាន ឬចេតិយ គឺព្រះបដិមា (ព្រះពុទ្ធរូប) ក៏ប្រព្រឹត្តទៅដូចជាការគោរពព្រះមានព្រះភាគដែរ ។ រតនៈដែលស្មើដោយព្រះតថាគត សូម្បីព្រោះ អត្ថថា ធ្វើឱ្យកើតសេចក្ដីគោរព រមែងមិនមាន ដោយប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងសប្បាយចិត្ត សូម្បីនោះឯណា ឈ្មោះថា រតនៈ ព្រោះ អត្ថ

ថា មានតម្លៃច្រើនក៏ដូចគ្នា ទ្រព្យជាគ្រឿងសប្បាយចិត្តនោះ គឺអ្វី? គឺសំពត់ដែនកាសី ដូចដែលព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកទោះចាស់មានពណ៌ល្អ មានសម្ផស្សក៏ស្រួល ទាំងមានតម្លៃក៏ច្រើន"(១) ។ ទ្រព្យជាគ្រឿងសប្បាយចិត្តសូម្បីនោះ ស្មើដោយពុទ្ធរតនៈ រមែងមិនមាន ។ ក៏បើថាទ្រព្យជាគ្រឿងសប្បាយចិត្ត ឈ្មោះថា រតនៈ ព្រោះអត្ថថាមានតម្លៃច្រើន ។ ព្រះតថាគតប៉ុណ្ណោះឈ្មោះថា រតនៈ មែនពិត ព្រះតថាគតទ្រង់ទទួលបង្សុកូលចីវររបស់ជនពួកណា ទាននោះរបស់ជនទាំងនោះ រមែងមានផលច្រើន មានអានិសង្សច្រើន ទាំងនេះក៏ព្រោះព្រះតថាគតនោះមានតម្លៃច្រើន ប្រៀបដូចជាទានរបស់អសោកមហារាជដូច្នេះដែរ ។ ដោយពាក្យពោលដល់សេចក្តីដែលព្រះតថាគតទ្រង់មានតម្លៃច្រើនយ៉ាងនេះ គប្បីជ្រាបបទនៃព្រះសូត្រ ដែលជាសាធកៈ សេចក្តីមិនមានទោសក្នុងសេចក្តីនេះ ដូច្នេះថា ៖

"ប្រសិនបើ បុគ្គលនោះទទួលចីវរ បិណ្ឌបាត សេនាសនៈ នឹងគិលានប្បច្ចយភេសជ្ជបរិក្ខាររបស់ជនពួកណា ការទទួលនោះ រមែងមានផលច្រើន មានអានិសង្សច្រើនដល់ពួកជនទាំងនោះ បានជាតថាគតពោលយ៉ាងនេះ ព្រោះបុគ្គល

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៤១ ទំព័រ ៣៦៥ ។

នោះមានតម្លៃច្រើន ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានតម្លៃច្រើនយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ[១] ។ រតនៈស្មើដោយព្រះតថាគត សូម្បីព្រោះអត្ថថាមានតម្លៃច្រើន រមែងមិនមានដោយប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងសប្បាយចិត្ត សូម្បីនោះណា ឈ្មោះថារតនៈ ព្រោះអត្ថថាប្រឹងមិនបានក៏ដូចគ្នា ។ ទ្រព្យជាគ្រឿងសប្បាយចិត្តនោះគឺអ្វី គឺចក្ករតនៈរបស់ស្តេចចក្រពត្តិ មានផ្ចិតដែលសម្រេចអំពីមណីឥន្ទនិល មានចំរៀកដែលសម្រេចអំពីរតនៈ ៧០០ ចំរៀក មានខ្នងកង់ដែលសម្រេចអំពីកែវប្រវាឡ មានទី-តសម្រេចដោយមាសពណ៌ក្រហមកើតឡើង ដែលចំរៀកមួយដាក់លើកាំ ១០ៗកាំកាលត្រូវខ្យល់ហើយនឹងធ្វើសំឡេង ដូចជាសំឡេងតន្ត្រីដែលប្រកបដោយអង្គ ៥ ដែលអ្នកជំនាញប្រគំហើយ មានមុខរាជសីហ៍ពីរត្រង់ចំណែកទាំងពីរនៃផ្ចិតរបស់កង់ត្រង់ប្រហោងនៃកង់របស់រថ ។ ការមិនមានមនុស្សធ្វើ ឬមនុស្សឱ្យធ្វើ វាក៏តាំងឡើងអំពីឧតុ មានកម្មជាបច្ច័យ ។ ដែលព្រះរាជាទ្រង់បំពេញចក្កពត្តិវត្ត ១០[២] ប្រការ ហើយថ្ងៃឧបោសថ ១៥ រោចទ្រង់ស្រង់ទឹកកក់ព្រះសីសៈហើយ ទ្រង់

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៤១ ទំព័រ ៣៦៦ ។

២-ទានំ សីលំ បរិច្ចាគំ អជ្ជវំ មទ្ទវំ តបំ អក្កោធំ អវិហឹសញ្ច ខន្តិញ្ច អវិរោធនំ **ទសពិធរាជធម៌ ១០ យ៉ាង គឺទាន ១ សីល ១ បរិច្ចាគ ១ ភាពនៃចិត្តត្រង់ ១ ការនៃចិត្តទន់ ១ តបៈ ១ ការមិន**

*កាន់ឧបោសថ ស្តេចឡើងលើមហាប្រាសាទ ទ្រង់ជម្រះសីល ប្រថាប់គង់ហើយ និងទតព្រះនេត្រឃើញចក្ករតនៈប្រាកដឡើង ប្រៀបដូចព្រះចន្ទពេញបូណ៌មី និងព្រះអាទិត្យ និងទ្រង់បានឮសំឡេងមានតាំងអំពី ១២ យោជន៍ ឃើញពណ៌ បែងចែកមកអំពី ៣ យោជន៍ ដែលមហាជនឃើញនឹងនាំគ្នាក័យយ៉ាងលើសលប់ថា ទំនងជាព្រះចន្ទពីរ ឬព្រះអាទិត្យពីរប្រាកដឡើងហើយ ក៏នាំគ្នារត់មក ខាងជើងព្រះនគរមិនខ្ពស់ មិនទាប ចំណែកទិសខាងកើតខាងក្នុងព្រះរាជនិវេសន៍ ហើយឈប់នៅ ដូចវេលាកាត់បន្ទយ ក្នុងទីដែលមហាជនគួរបូជាដោយរបស់ក្រអូបនិងផ្កាឈើជាដើម ។*

---

***ក្រោធ ១ ការមិនបៀតបៀន ១ ខន្តិ ១ កិរិយាមិនភ្ញាត់ ១ ។ សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក លេខ ៦១ ទំព័រ ១២៨ ។ ក្នុង*** អដ្ឋកថា មហាហំសជាតក ***បានពន្យល់ថា*** ទានាទីសុ ទសវត្ថុកា ចេតនា ទានំ បញ្ចសីលទសសីលានិ សីលំ ទេយ្យធម្មចាគោ បរិច្ចាគោ ឧជុភាវោ អជ្ជវំ មុទុភាវោ មទ្ទវំ ឧបោសថកម្មំ តបោ មេត្តាបុព្វភាគោ អក្កោធោ ករុណាបុព្វភាគោ អវិហឹសា អធិវាសនា ខន្តិ អវិរោធោ អវិរោធនំ ***។ បណ្តាវត្ថុទាំងឡាយមានទានជាដើម ចេតនាជាគ្រឿងឱ្យនូវវត្ថុទាំង១០ ឈ្មោះ ទាន, សីល៥ និង សីល ១០ ឈ្មោះថា សីល, ការចែករំលែកនូវទេយ្យធម៌ ឈ្មោះថា បរិច្ចាគ, ភាពស្មោះត្រង់ (មិនមានអគតិ ៤ យ៉ាង) ឈ្មោះថា អជ្ជវៈ, ភាពទន់ភ្លន់ ឈ្មោះថា មទ្ទវៈ, ឧបោសថកម្ម ឈ្មោះថា តបៈ, ចំណែកខាងដើមនៃមេត្តា ឈ្មោះថា អក្កោធ, ចំណែកខាងដើមនៃករុណា ឈ្មោះថា អវិហឹង្សា, ការអត់ធន់ ឈ្មោះថា ខន្តិ, ការមិនប្រព្រឹត្តិខុស ឈ្មោះថា អវិរោធៈ ។***

*សម្រាប់ជាធម្មទាន*

**ហត្ថិរតនៈ** ដំរីកែវក៏កើតឡើងជាប់តាមចក្ករតន៍នោះនុ៎ះឯង គឺជាដំរីសមាន ជើងក្រហម មានកម្លាំងស្មើដំរីសារ ៧ មានឫទ្ធិអាចទៅផ្លូវអាកាសបាន មក អំពីដំរីត្រកូលឧបោសថក៏មាន អំពីត្រកូលដំរីឆទ្ទន្តក៏មាន បើមកអំពីត្រកូលដំរី ឧបោសថ ក៏ជាដំរីបងគេទាំងអស់ បើមកអំពីដំរីត្រកូលឆទ្ទន្ត ក៏ជាដំរីប្អូនគេទាំង អស់ ជាសត្វមានការហ្វឹកហាត់ល្អហើយ ទូន្មានល្អហើយ នាំបរិស័ទប្រមាណ ១២ យោជន៍ ដើរយាមល្បាតជម្ពូទ្វីប ទៅហើយត្រឡប់មកកាន់រាជធានីរបស់ខ្លួនឯង មុនអាហារព្រឹកនុ៎ះឯង ។

**អស្សរតនៈ** ក៏កើតជាប់តាមហត្ថិរតន៍សូម្បីនោះនុ៎ះឯងគឺសេះសមានជើង ក្រហមក្បាល ដូចសត្វក្អែក មានសក់ដូចស្មៅជំណោកទន្សាយ មកអំពីត្រកូលស្តេច សេះពលាហកស្សៈ ។ ក្នុងសេចក្តីនេះពាក្យដ៏សេស ក៏ដូចដូចគ្នានឹងហត្ថិរតន៍នុ៎ះឯង ។

**មណីរតនៈ** ក៏កើតជាប់តាមអស្សរតន៍នោះ ។ មណីនោះជាកែវពិទូរ្យ ស្អាតដោយធម្មជាតិប្រាំពីរជាន់ ត្បូងចរណៃយ៉ាងល្អ ដោយបណ្តាយក៏ស្រដៀង ដុំនៃចក្កមកអំពីវេបុល្លបព៌ត ។ មណីនោះ សូម្បីអាការៈងងឹតដែលប្រកបដោយ អង្គ ៤ នៅដល់កំពូលទង់របស់ព្រះរាជា ក៏ចាំងពន្លឺភ្លឺទៅអស់យោជន៍ ដោយពន្លឺ របស់មណីរតនៈ ពួកមនុស្សសម្គាល់ថា កណ្តាលថ្ងៃក៏ប្រកបការងារ ដោយ ហោចទៅសូម្បីតែស្រមោចខ្មៅ ស្រមោចក្រហមក៏មើលឃើញដែរ ។

***ឥត្ថីរតនៈ*** *ក៏កើតតាមមណីរតន៍នោះឯង គឺស្ត្រីដែលជាព្រះអគ្គមហេសី ដោយប្រក្រតីឬមកអំពីឧត្តរកុរុទ្វីប ឬមកអំពីរាជត្រកូលមទ្ទរាជ វៀរចាកទោស ៦ មានខ្ពស់ពេកជាដើម កន្លងវណ្ណៈរបស់មនុស្ស តែមិនដល់វណ្ណៈទិព្វ ដែលសម្រាប់ព្រះរាជា ក៏នឹងមានកាយក្តៅក្នុងរដូវត្រជាក់ នឹងមានកាយត្រជាក់ក្នុងរដូវក្តៅ មានសម្ផស្សដូចសំឡីគរដែលជាន់ហើយ ៧ ជាន់ ក្លិនចន្ទន៍នឹងបក់ចេញអំពីកាយ ក្លិនឧប្បលនឹងបក់ចេញអំពីមាត់ និងជាអ្នកប្រកបដោយគុណសម្បត្តិជាច្រើន មានភ្ញាក់មុនជាដើម ។*

***គហបតិរតនៈ*** *ក៏កើតជាប់តាមឥត្ថីរតន៍នោះឯង ក៏គឺសេដ្ឋី អ្នកធ្វើការងារដោយប្រក្រតីរបស់ព្រះរាជា កាលចក្ករតន៍កើតឡើង ក៏ប្រាកដទិព្វចក្ខុឃើញកំណប់ទ្រព្យបានប្រមាណមួយយោជន៍ដោយជុំវិញ ទាំងដែលមិនមានម្ចាស់ ទាំងដែលមានម្ចាស់ ក៏ចូលគាល់ព្រះរាជាទូលសេចក្តីប្រាថ្នាថា "បពិត្រទេវរាជ សូមព្រះអង្គមេត្តាប្រោស ទ្រង់ដាក់ព្រះរាជភារកិច្ចចុះ ខ្ញុំព្រះអង្គនឹងធ្វើកិច្ចដែលគួរធ្វើជាប់ទាក់ទងនឹងទ្រព្យរបស់ព្រះអង្គ" ។*

***បរិនាយករតនៈ*** *ក៏កើតជាប់តាមគហបតិរតន៍នោះឯង ដោយប្រក្រតីក៏ជាព្រះរាជបុត្រច្បងរបស់ព្រះរាជាកាលចក្ករតនៈកើតឡើង បរិនាយកៈក៏ជាអ្នកប្រកបដោយបញ្ញាឆ្លៀសវៃយ៉ាងក្រៃលែង អាចកំណត់ដឹងចិត្តរបស់បរិស័ទប្រមាណ ១២ យោជន៍ ដោយចិត្តខ្លួនឯង ហើយធ្វើការអាចដាក់ទោស និងលើក*

សរសើរបរិនាយកៈនោះក៏ចូលគាល់ព្រះរាជាទូលប្រាថ្នាថា "បពិត្រទេវរាជ សូមព្រះអង្គមេត្តាទ្រង់ដាក់ព្រះរាជភារកិច្ចចុះ ខ្ញុំព្រះអង្គនឹងចាត់ចែងរាជកិច្ចដោយខ្លួនឯង"។ ក៏ឬថាទ្រព្យគ្រឿងសប្បាយចិត្តសូម្បីដទៃណា ឃើញបែបនោះ ឈ្មោះថា រតនៈ ព្រោះអត្ថថា ថ្លៃមិនបាន ទ្រព្យជាគ្រឿងសប្បាយចិត្តយ៉ាងណា មិនអាចពិនិត្យពិច័យវាយតម្លៃថា មានតម្លៃមួយរយ មួយពាន់ ឬមួយកោដិ ។ ក្នុងទ្រព្យជាគ្រឿងសប្បាយចិត្តនោះសូម្បីរតនៈត្រឹមតែម្យ៉ាង ដែលស្មើដោយពុទ្ធរតនៈ មិនមានឡើយ ។ ប្រសិនបើថា ទ្រព្យគ្រឿងសប្បាយចិត្តឈ្មោះថា រតនៈ ព្រោះអត្ថថា ថ្លៃមិនបាន ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា រតនៈ ។ មែនពិត ព្រះតថាគតអង្គណា ក៏មិនអាចពិនិត្យពិច័យដោយសីល ដោយសមាធិ ឬដោយបញ្ញាជាដើមយ៉ាងណាមួយហើយកំណត់ថា ទ្រង់មានព្រះគុណប៉ុណ្ណោះ ទ្រង់ស្មើឬប្រៀបធៀបនិងអ្នកដទៃ ។ រតនៈស្មើដោយព្រះតថាគត សូម្បីព្រោះអត្ថថា ថ្លៃមិនបាន មិនមានឡើយ ដោយប្រការដូច្នេះ ។ ទ្រព្យជាគ្រឿងសប្បាយចិត្តសូម្បីយ៉ាងណា ឈ្មោះថា រតនៈ ព្រោះអត្ថថា ឃើញបានដោយលំបាកក៏ដូចគ្នា ។ ទ្រព្យជាគ្រឿងសប្បាយចិត្តនេះ ក៏គឺជារបស់ប្រាកដបានដោយលំបាក បានដល់ស្ដេចចក្រពត្តិនិងរតនៈ ៧ ប្រការរបស់ស្ដេចចក្រពត្តិ រតនៈសូម្បីនោះ ដែលស្មើដោយពុទ្ធរតនៈមិនមាន ។ ក៏ប្រសិនបើថា ទ្រព្យជាគ្រឿងសប្បាយចិត្ត ឈ្មោះថា រតនៈ ព្រោះអត្ថថា ឃើញបានលំបាកហ្នឹ ព្រះតថាគតប៉ុណ្ណោះឈ្មោះថា រតនៈ ។ សេចក្តី

ថាជារតនៈរបស់ស្តេចចក្រពត្តិជាដើម និងឃើញបានលំបាកមកអំពីទីណាហ្ន៎ ។ មែនពិត រតនៈប៉ុណ្ណោះ រមែងកើតឡើងក្នុងកប្បសូម្បីជាមួយគ្នាប៉ុណ្ណោះ ព្រោះហេតុតែលោកសោះសូន្យចាកព្រះតថាគត រាប់ជាអសង្ខេយ្យកប្បដូច្នោះ ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា ឃើញបានដោយលំបាក ព្រោះកើតឡើងក្នុងកាលខ្វះ ។ សមពិត ដូចដែលព្រះមានព្រះភាគត្រាស់ទុកក្នុងសម័យបរិនិព្វានដូច្នេះថា ៖

"ម្នាលអានន្ទ ពួកទេវតាពោលទោសថា ពួកយើងមកអំពីចម្ងាយ ដើម្បីឃើញព្រះតថាគតៗ ជាព្រះអរហន្តសម្មាសម្ពុទ្ធកើតឡើងក្នុងលោកមានម្តងៗ ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះឯង បរិនិព្វាននឹងមានដល់ព្រះតថាគត ក៏ភិក្ខុមានសក្តិធំនេះ មកឈរវាំងនៅចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ពួកយើងមិនបានឃើញព្រះតថាគតក្នុងបច្ឆិមកាលឡើយ"(១) ។

រតនៈដែលស្មើដោយព្រះតថាគត សូម្បីព្រោះអត្ថថា ឃើញបានដោយលំបាក រមែងមិនមាន ដោយប្រការដូច្នេះ ។ ទ្រព្យជាគ្រឿងសប្បាយចិត្តសូម្បីនោះ បាន ឈ្មោះថា រតនៈ ព្រោះអត្ថថា ជាគ្រឿងបរិភោគប្រើប្រាស់របស់សត្វអ្នកមិនថោកទាប ក៏ដូចគ្នា ។ ទ្រព្យជាគ្រឿងសប្បាយចិត្តនោះគឺអ្វី គឺរតនៈជាដើមរបស់ស្តេចចក្រពត្តិ ។ មែនពិត រតនៈនោះមិនមែនកើតឡើងដើម្បីជាគ្រឿង

---

១-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៦ ទំព័រ ២៩២-២៩៣ ។

បរិភោគ សូម្បីដោយសេចក្តីយល់សប្តិរបស់បុរសថោកទាប អ្នកមានត្រកូលថោកទាប ដូចមនុស្សចណ្ឌាលជាងតម្បាញ ព្រាន ជាងរថ និងមនុស្សចាក់សំរាមជាដើម ដែលមានទ្រព្យតាំងមួយសែនកោដិក្តី នៅលើប្រាសាទ ៧ ជាន់ក្តី តែជាគ្រឿងបរិភោគរបស់សត្វអ្នកមិនថោកទាប ព្រោះកើតដើម្បីជាគ្រឿងបរិភោគរបស់ព្រះរាជា អ្នកជាឧកតោសុជាតិ បំពេញចក្កវត្ត ១០ ប្រការបរិបូណ៌ សូម្បីរតនៈនោះ ដែលស្មើនឹងពុទ្ធរតនៈមិនមានឡើយ ។ ក៏ប្រសិនបើ ទ្រព្យជាគ្រឿងសប្បាយចិត្ត ឈ្មោះថា រតនៈ ព្រោះអត្ថថា ជាគ្រឿងបរិភោគរបស់សត្វអ្នកមិនថោកទាប ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា រតនៈ ។ មែនពិត ព្រះតថាគត មិនមែនជាគ្រឿងបរិភោគសូម្បីដោយការយល់សប្តិរបស់គ្រូទាំង ៦ មានបូរណកស្សបៈជាដើម ដែលសម្មតិគ្នាថាជាសត្វថោកទាប អ្នកមិនដល់ព្រមដោយឧបនិស្ស័យ មានទស្សនៈដែលវិបរិត និងរបស់សត្វពួកដទៃបែបនោះ ។ តែជាគ្រឿងបរិភោគរបស់ពួកលោកអ្នកដល់ព្រមដោយឧបនិស្ស័យ អ្នកអាចសម្រេចព្រះអរហត្តកាលចប់គាថាសូម្បី ៤ បទ អ្នកមានញាណទស្សនៈទម្លាយកិលេស មានព្រះពាហិយទារុចីរិយៈជាដើម និងរបស់ព្រះមហាសាវកទាំងឡាយដទៃៗ អ្នកជាបុត្ររបស់ត្រកូលធំ ។ មែនពិត ពួកសត្វអ្នកមិនថោកទាបទាំងនោះ កាលញុំាងទស្សនានុត្តរិយៈ សវនានុត្តរិយៈ និងបារិចរិយានុត្តរិយៈជាដើមឱ្យសម្រេច ឈ្មោះថាបរិភោគប្រើប្រាស់ព្រះតថាគត ។ រតនៈដែលស្មើដោយ ព្រះតថាគត សូម្បីអត្ថថា

ជាគ្រឿងបរិភោគរបស់សត្វអ្នកមិនថោកទាបមិនមានឡើយ ដោយប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងសប្បាយចិត្តសូម្បីនោះណា ដោយមិនវិសេសឈ្មោះថា រតនៈ ព្រោះអត្ថថា ឱ្យកើតសេចក្តីត្រេកអរ ទ្រព្យជាគ្រឿងសប្បាយចិត្តនោះ គឺអ្វី គឺចក្ករតនៈរបស់ស្តេចចក្រពត្តិ ។ មែនពិត ស្តេចចក្រពត្តិទ្រង់ឃើញរតនៈសូម្បីនោះហើយក៏ទ្រង់សប្បាយព្រះរាជហឫទ័យ ចក្ររតន៍នោះនាំសេចក្តីត្រេកអរមកឱ្យដល់ព្រះរាជាសូម្បីដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ស្តេចចក្រពត្តិ ទ្រង់ចាប់ព្រះសុវណ្ណភិង្គារ[1]ដោយព្រះហស្តឆ្វេងទ្រង់ប្រោះព្រំដោយព្រះហស្តស្តាំ មានព្រះ-រាជឱង្ការថា ចក្ររតន៍ចូរដំណើរទៅ ចក្ររតន៍ចូរមានជ័យជម្នះ ។ តអំពីនោះ ចក្ករតន៍ក៏បន្លឺសំឡេងយ៉ាងពីរោះដូចតន្ត្រីប្រកបដោយ ៥ ហោះទៅទិសបូព៌ ។ ស្តេចចក្រពត្តិ ទ្រង់លើកចតុរង្គសេនាពង្រីកទទឹងប្រមាណ ១២ យោជន៍ ជាប់តាមទៅដោយអានុភាពរបស់ចក្ររតន៍ មិនខ្ពស់ មិនទាប ភាគផែនដីយ៉ាងទាបត្រឹមតែដើមឈើខ្ពស់ យ៉ាងខ្ពស់ត្រឹមតែដើមឈើទាប ទ្រង់ទទួលគ្រឿងបណ្ណាការអំពីដៃរបស់ពួកអ្នកកាន់បណ្ណាការ មានផ្កាឈើ និងត្រួយឈើជាដើមមកថ្វាយចំណែកព្រះរាជាដែលធ្លាប់ជាបដិបក្សដែលមកគាល់ ដោយសេចក្តីគោរពយ៉ាងក្រៃលែងថា “បពិត្រមហារាជ សូមព្រះអង្គមកចុះ” ក៏ទ្រង់បញ្ជូលរាជសារដោយ

---

១-**សុវណ្ណភិង្គារ**= កុណ្ឌីមាស ទីកោមាស។ **កុណ្ឌី** = ប្រដាប់សម្រាប់ទឹកប្រូច ។ **ទីកោ** = ប្រដាប់សម្រាប់ដាក់ទឹក មានសណ្ឋានស្រដៀងនឹងកំសៀវ ។ (វចនានុក្រមខ្មែរ)

ន័យថា“មិនគួរសម្លាប់សត្វមានជីវិត”ដូច្នេះជាដើម ទើបស្តេចយាងទៅ ។ ក៏ក្នុងទីណាព្រះរាជាមានព្រះរាជបំណងនិងសោយ ឬបំណងនិងផ្ទុំវេលាថ្ងៃ ក្នុងទីនោះចក្ករតន៍ក៏នឹងចុះអំពីអាកាសហើយឈប់ ដូចរទេះបាក់ភ្លៅក្នុងផែនដី ដែលរៀបស្មើចំពោះកិច្ចដល់កិច្ចគ្រប់យ៉ាង មានកិច្ចទាក់ទងនឹងទឹកជាដើម កាលព្រះរាជាកើតចិត្តគិតនឹងស្តេចទៅទៀត ចក្ករតន៍ក៏នឹងធ្វើសំឡេងដោយន័យមុនទុំះឯងទើបលែងទៅ ។ ចំណែកបរិស័ទ (ក្បួនទ័ព) ទំហំ ១២ យោជន៍ បានឮសំឡេងនោះក៏នាំគ្នាហោះទៅ ។ ចក្ករតន៍ចុះកាន់មហាសមុទ្រទិសបូព៌ ដោយលំដាប់កាលចក្ររតន៍នោះចុះកាន់សមុទ្រ ទឹកក៏ថយទៅប្រមាណមួយយោជន៍ ឈប់ស្ងៀមដូចធ្វើសេចក្តីស្រឡាញ់ភក្តី ។ មហាជនក៏កាន់រតនៈទាំង ៧ តាមសេចក្តីត្រូវការព្រះរាជាទ្រង់ចាប់សុវណ្ណភិង្ការទៀត ទ្រង់ប្រោះព្រំដោយទឹកថា រាជកិច្ចរបស់យើងដំណើរតាំងអំពីដើមនេះទៅ ហើយស្តេចត្រឡប់មកវិញ ។ កងទ័ពទៅខាងមុខចក្ររតន៍នៅខាងក្រោយព្រះរាជានៅកណ្តាល ។ ទឹកចូលពេលដែលរហូតដល់ស្ថានទីដែលចក្ករតន៍ថយទៅ ។ ចក្ករតន៍ក៏ទៅក្នុងសមុទ្រផ្នែកទិសទក្សិណ ទិសបច្ចិម និងទិសឧត្តរដោយឧបាយនេះនេះឯង ។

ចក្ររតន៍ដើរយោមល្បាតទៅរហូត ៤ ទិសយ៉ាងនេះហើយ ក៏ឡើងកាន់អាកាសប្រមាណ ៣០០ យោជន៍ ។ ព្រះរាជាប្រថាប់ឈរលើចក្ករតន៍នោះ ទ្រង់ឈ្នះដោយអានុភាពចក្ករតនៈ ទ្រង់ត្រួតត្រាមួយចក្រវាឡ ដែលប្រដាប់ដោយទ្វីប

សម្រាប់ជាធម្មទាន

ធំ ៤ និងទ្វីបតូច ២.០០០ ពោរពេញដោយផ្កាឈូកបុណ្ឌរិកៈដែលលាតពេញហើយ យ៉ាងនេះ គឺ បុព្វវិទេហទ្វីប ប្រដាប់ដោយទ្វីបតូច ៥០០ មានបរិមណ្ឌល ៧.០០០ យោជន៍ ឧត្តរកុរុទ្វីបក៏ដូចគ្នា មានបរិមណ្ឌល ៨.០០០ យោជន៍ អបរគោយានទ្វីប មានបរិមណ្ឌល ៧.០០០ យោជន៍ដូចគ្នា និងជម្ពូទ្វីប មានបរិមណ្ឌល ១.០០០ យោជន៍ ។ ស្ដេចចក្រពត្តិព្រះអង្គនោះ ទ្រង់កំពុងត្រួតត្រាមើលយ៉ាងនេះ ក៏ទ្រង់កើតសេចក្ដីត្រេកអរ មិនមែនតិចតួចឡើយ ចក្ររតន៍នោះ ឱ្យកើតសេចក្ដីត្រេកអរដល់ព្រះរាជា សូម្បីដោយអាការៈយ៉ាងនេះ ។ ចក្ករតនៈសូម្បីនោះ ដែលស្មើដោយពុទ្ធរតនៈទេ ។ ប្រសិនបើថា ឈ្មោះថា រតនៈ ព្រោះអត្ថថា ឱ្យកើតសេចក្ដីត្រេកអរ ព្រះតថាគតប៉ុណ្ណោះឈ្មោះថា រតនៈ ចក្ររតន៍តែម្យ៉ាង និងធ្វើអ្វីបាន ។

មែនពិត សេចក្ដីត្រេកអរក្នុងចក្រពត្តិ ដែលរតនៈ សូម្បីគ្រប់យ៉ាងមានចក្ររតន៍ជាដើមធ្វើឱ្យកើត ក៏នូវមិនរាប់មិនស្មើចំរៀក សូម្បីចំណែករបស់សេចក្ដីត្រេកអរដែលជាទេព្យណា ព្រះតថាគតទ្រង់ធ្វើឱ្យកើតសេចក្ដីត្រេកអរក្នុងបឋមឈាន សេចក្ដីត្រេកអរក្នុងបឋមឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន និងបញ្ចមជ្ឈាន សេចក្ដីត្រេកអរក្នុងអាកាសានញ្ចាយតនជ្ឈាន វិញ្ញាណញ្ចាយតនជ្ឈាន អាកិញ្ចញ្ញាយតនជ្ឈាន និងនេវសញ្ញានាសញ្ញាយតនជ្ឈាន សេចក្ដីត្រេកអរក្នុង

សោតាបត្តិមគ្គ សេចក្ដីត្រេកអរក្នុងសោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ និងអរហត្តផល ដល់ទេវតា និងមនុស្ស រាប់ចំនួនមិនបាន អ្នកទទួលព្រះឱវាទរបស់ព្រះអង្គ ក្រៃលែង ជាងប្រណិតជាង ។ សេចក្ដីត្រេកអរសូម្បីយ៉ាងនោះ រតនៈស្មើដោយព្រះតថាគត សូម្បីព្រោះអត្ថថា ឱ្យកើតសេចក្ដីត្រេកអរ មិនមានដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ធម្មតារតនៈនេះមាន ២ យ៉ាងគឺ សវិញ្ញាណករតនៈ និង អវិញ្ញាណករតនៈ ។ បណ្ដារតនៈទាំងពីរនោះ អវិញ្ញាណករតនៈ បានដល់ ចក្ករតនៈ និងមណីរតនៈ ឬក៏រតនៈ សូម្បីដទៃណា មានមាស និងប្រាក់ជាដើម ដែលមិនទាក់ទង ដោយឥន្ទ្រិយ ។ សវិញ្ញាណករតនៈ បានដល់ រតនៈ មានហត្ថិរតន៍ ជាដើម មានបរិនាយករតន៍ជាទីបំផុត ឬថារតនៈសូម្បីដទៃណាបែបនោះ ដែលទាក់ ទងដោយឥន្ទ្រិយ ។ កាលបើដូច្នោះ បណ្ដារតនៈទាំងពីរយ៉ាង សវិញ្ញាណករតនៈ ពោលថា ប្រសើរជាងក្នុងសេចក្ដីនេះ ។ ព្រោះហេតុអ្វី? ព្រោះថា រតនៈ មាន មាស ប្រាក់ កែវមណី កែវមុក្តាជាដើម ជាអវិញ្ញាណករតនៈ ត្រូវនាំទៅប្រើជា គ្រឿងប្រដាប់របស់ហត្ថិរតន៍ជាដើម ដែលជាសវិញ្ញាណករតនៈ ។

សូម្បី សវិញ្ញាណករតនៈ ក៏មាន ២ យ៉ាង គឺរតនៈជាសត្វតិរច្ឆាន និង

រតនៈជាមនុស្ស ។ បណ្តាសវិញ្ញាណករតនៈ ២ យ៉ាងនោះ រតនៈ ជាមនុស្ស ពោលថា ជារតនៈប្រសើរជាង ព្រោះហេតុអ្វី ។ ព្រោះហេតុថា រតនៈជាសត្វតិរច្ឆាន រមែងជាពាហនៈរបស់រតនៈជាមនុស្ស ។ សូម្បីមនុស្សក៏មាន ២ យ៉ាងគឺ ឥត្ថីរតនៈ និងបុរិសរតនៈ ។ បណ្តាមនុស្សរតនៈទាំងពីរនោះ បុរិសរតនៈ ពោលថាជារតនៈប្រសើរជាង ។ ព្រោះហេតុអ្វី ព្រោះហេតុថា ឥត្ថីរតនៈត្រូវជាបរិចារិកៈ(ស្ត្រីអ្នកបម្រើ)របស់បុរិសរតនៈ ។ សូម្បីបុរិសរតនៈក៏មាន ២ គឺ អគារិករតនៈ និងអនគារិករតនៈ ។ បណ្តាបុរិសរតនៈទាំង ២ នោះ អនគារិករតនៈ ពោលថាជារតនៈប្រសើរជាង ។ ព្រោះហេតុអ្វី ព្រោះហេតុថា អនគារិករតនៈ សូម្បីស្តេចចក្រពត្តិដ៏ប្រសើរ ក៏សំពះអនគារិករតនៈ អ្នកប្រកបដោយគុណ មានសីលជាដើមដោយបញ្ចង្គប្រតិស្ឋាន ចូលទៅអង្គុយជិត បាននូវទិព្វសម្បត្តិ មនុស្សសម្បត្តិ និងសម្រេចនិព្វានសម្បត្តិក្នុងទីបំផុត ។

សូម្បីអនគារិករតនៈ ក៏មាន ២ យ៉ាង គឺអរិយរតនៈ និង បុថុជ្ជនរតនៈ ។ អរិយរតនៈក៏មាន ២ យ៉ាងគឺ សេក្ខរតនៈ និងអសេក្ខរតនៈ ។ សូម្បីអសេក្ខរតនៈ ក៏មាន ២ យ៉ាងគឺ សុក្ខវិបស្សករតនៈ និងសមថយានិករតនៈ ។ សូម្បីសមថយានិករតនៈ ក៏មាន ២ យ៉ាងគឺ ដែលសម្រេចសាវកបារមី និងមិនសម្រេច ។

បណ្ដាសមថយានិករតនៈទាំងពីរនោះ សមថយានិករតនៈដែលសម្រេចសាវកបារមីពោលគ្នាថា ប្រសើរជាង ។ ព្រោះហេតុអ្វី? ព្រោះហេតុថាមានគុណច្រើន ។ បច្ចេកពុទ្ធរតនៈ ពោលថាប្រសើរជាង សូម្បីសាវកបារមីបត្តរតនៈ ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា មានគុណច្រើន ។ ព្រះសាវកច្រើនរយ សូម្បីដូចព្រះសារីបុត្រ ព្រះមោគ្គល្លាន ក៏មិនដល់សូម្បីចំណែករយនៃគុណទាំងឡាយរបស់ព្រះបច្ចេកពុទ្ធ ១ អង្គ ។ សម្មាសម្ពុទ្ធរតនៈ ពោលថាប្រសើរជាង សូម្បីជាងបច្ចេកពុទ្ធរតនៈ ព្រោះហេតុអ្វី ? ព្រោះហេតុថា មានគុណច្រើន ។ ក៏ប្រសិនបើព្រះបច្ចេកពុទ្ធទាំងឡាយគង់សមាធិជិតគ្នា ទូទាំងជម្ពូទ្វីប ក៏មិនស្មើចំរៀកចំណែកនៃព្រះគុណទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ ។ សមពិត ដូចដែលព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា ៖

"ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលសត្វមិនមានជើងក្ដី ។ល។ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរជាងពួកសត្វទាំងនោះ"[១] ។ រតនៈ ដែលស្មើដោយព្រះតថាគត មិនមានឡើយ ដោយបរិយាយយ៉ាងមួយ ដោយប្រការដូច្នេះ ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ឆនោ សមំ អត្ថិ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ លេខ ៥៣ ទំព័រ ១១៦ ។

តថាគតនោះទ្រព្យនឹងរតនៈវត្ថុទាំងនោះឯង ស្មើដោយព្រះតថាគតមិនមានឡើយ ។

ព្រះមានព្រះភាគ ត្រាស់សេចក្តីនៃព្រះពុទ្ធរតនៈ ដែលរតនៈដទៃៗ ប្រៀបមិនបាន យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីរម្ងាប់ឧបទ្រវៈដែលកើតដល់ពួកសត្វនោះ មិនទ្រង់អាស្រ័យជាតិ មិនទ្រង់អាស្រ័យគោត្រ មិនទ្រង់អាស្រ័យភាពជាកុលបុត្រ មិនទ្រង់អាស្រ័យភាពជាអ្នកមានវណ្ណៈស្អាតជាដើម ប្រសិនបើទ្រង់អាស្រ័យសេចក្តីដែលព្រះពុទ្ធរតនៈ មិនមានអ្វីប្រៀបធៀបបាន ដោយគុណទាំងឡាយ មានសីលខន្ធ និងសមាធិខន្ធជាដើម ក្នុងលោកដែលមានអវិចីជាខាងដើម មានភវគ្គព្រហ្មជាទីបំផុត ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ ពុទ្ធេ រតនំ បណីតំ ឯតេន សច្ចេន សុវត្ថិ ហោតុ** រតនៈគឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ដោយសច្ចៈនេះ សូមមានសិរីសួស្តី ។

សច្ចវចនៈនោះមានសេចក្តីដូច្នេះថា ព្រះសម្ពុទ្ធមិនមាននរណាប្រៀបបាន ដោយព្រះគុណទាំងឡាយនោះៗ ជាមួយនឹងទ្រព្យជាគ្រឿងសប្បាយចិត្ត ឬរតនៈគ្រប់យ៉ាងដែលមានក្នុងលោកនេះ ឬលោកដទៃ ឬក្នុងស្ថានសួគ៌ទាំងឡាយ សូម្បីយ៉ាងនេះ ឈ្មោះថាជារតនៈដ៏ប្រណីតក្នុងព្រះពុទ្ធ។ ក៏ប្រសិនបើថា សេចក្តីនេះជាសច្ចៈ កាលបើដូច្នោះ ដោយសច្ចៈនេះ សូមសិរីសួស្តីចូរមាន សូមវត្ថុដែល

ល្អស្អាតទាំងឡាយ មានសេចក្តីមិនមានរោគ ការប្រាសចាកឧបទ្រវៈ ចូរមានដល់សត្វទាំងនេះ ។ ក៏ក្នុងសេចក្តីនេះ គប្បីជ្រាបថា រតនៈប្រណីត បានដល់សេចក្តីជារតនៈប្រណីត គឺការៈនៃព្រះពុទ្ធជារតនៈប្រណីត ដូចសេចក្តីថា ព្រោះជាខ្លួន ឬព្រោះអាស្រ័យនៅជាមួយខ្លួន ក្នុងប្រយោគជាដើមយ៉ាងនេះថា "ចក្ខុំ ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វា ម្នាលអានន្ទ ចក្ខុហ្នឹងឯងសូន្យចាកខ្លួន ឬចាកបរិក្ខាររបស់ខ្លួន" ។ មែនពិត ក្រៅអំពីនេះ ចក្ខុក៏ជា ការបដិសេធមិនបានថាខ្លួន ឬវត្ថុដែលនៅអាស្រ័យជាមួយខ្លួនដូច្នោះ ។ បទថា រតនំ បណីតំ បានសេចក្តីថា ភាពនៃរតនៈជារបស់ប្រណីត អធិប្បាយថា សភាពនៃរតនៈជា របស់ប្រសើរ ។ ពិតប្រាកដ ដោយប្រការក្រៅអំពីនេះ ព្រះពុទ្ធរមែងមិនសម្រេច ជារតនៈ ដោយថារតនៈមិនមាននៅក្នុងវត្ថុណាវត្ថុនោះ ក៏រមែងមិនសម្រេចជារតនៈ ។ តែថារតនៈដែលជាប់ដោយវិធីណាៗក្តី ដែលរាប់ថាជាប្រយោជន៍ មានអ្នកធ្វើសេចក្តីគោរពកោតក្រែងជាដើម មាននៅក្នុងវត្ថុណា ព្រោះហេតុដែលវត្ថុនោះលោកប៉ងសំដៅយកសេចក្តីជារតនៈ ទើបបញ្ញត្តថារតនៈ ដូច្នោះ ព្រះពុទ្ធ ទើបសម្រេចថារតនៈ ព្រោះរតនៈនោះនៅមាន ។ ម្យ៉ាងទៀត បទថា ឥទម្បិ ពុទ្ធេ រតនំ បណីតំ គប្បីជ្រាបសេចក្តីយ៉ាងនេះថា ព្រះពុទ្ធជារតនៈ ដោយប្រការ

ដូច្នេះ ។ គ្រាន់តែព្រះមានព្រះភាគត្រាស់ ព្រះគាថា សិរីសួស្ដីក៏កើតដល់រាជត្រកូល ភ័យក៏រម្ងាប់ទៅ ពួកអមនុស្សក្នុងសែនកោដិចក្រវាឡ ក៏នាំគ្នាព្រមទទួលអាជ្ញានៃព្រះគាថានេះឯង ។

## ខយំ វិរាគន្តិ គាថាវណ្ណនា

## ពណ៌នាគាថា ថា ខយំ វិរាគំ

ព្រះមានព្រះភាគ គ្រាត្រាស់សច្ចវចនៈដោយពុទ្ធគុណយ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ត្រាស់បន្ថែមថា **ខយំ វិរាគំ** ជាដើមដើម្បីប្រារព្ធការពោលនូវធម្មគុណ គឺព្រះនិព្វាន ។ ក្នុងពាក្យនោះ កិលេសទាំងឡាយមានរាគៈជាដើមអស់ទៅ គឺថាសូន្យទៅ ព្រោះធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ឬព្រោះដែលព្រះនិព្វាននោះ គ្រាន់តែកិលេសទាំងនោះអស់ទៅ រលត់ទៅ និងមិនមានការកើត និងព្រោះហេតុដែលព្រះនិព្វាននោះ មិនប្រកបដោយកិលេសមានរាគៈជាដើម ដោយការជួបនិងដោយអារម្មណ៍ ឬព្រោះហេតុដែលកាលបុគ្គលធ្វើឱ្យជាក់ច្បាស់ព្រះនិព្វាននោះហើយ កិលេសទាំងឡាយមានរាគៈជាដើម ក៏ស្រាយចេញទៅអស់ ប្រាសចាកទៅ ត្រូវកម្ចាត់ទៅ ដូច្នោះ ព្រះនិព្វានទើបលោកហៅថា **ខយៈ** ថា **វិរាគៈ** ។ តែព្រោះហេតុ ដែលព្រះនិព្វាននោះ សេចក្ដីកើតមិនប្រាកដ សេចក្ដីសាបសូន្យមិនប្រាកដ សេចក្ដីដែលចិត្តប្រែប្រួលមិនមាន ដូច្នោះ ព្រះនិព្វាននោះ លោកទើបធ្វើឱ្យមិនកើត

មិនចាស់ មិនស្លាប់ ហៅថា អមតៈ ។ តែ(ក្នុងទីនេះ) លោកហៅថា ប្រណីត ព្រោះអត្ថថា ខ្ពង់ខ្ពស់ និងព្រោះអត្ថថា មិនដទៃ។ បទថា យទជ្ឈគា បានដល់សម្រេចជួប បានធ្វើឱ្យជាក់ច្បាស់ដោយកម្លាំងញាណរបស់ខ្លួន ដល់ព្រះនិព្វាននោះ។ បទថា សក្យមុនី បានដល់ ឈ្មោះថា សក្យៈព្រោះទ្រង់ជាឱរសរបស់ត្រកូលសក្យៈ ឈ្មោះថាមុនីព្រោះប្រកបដោយមោនេយ្យធម៌ មុនីគឺសក្យៈ ឈ្មោះថា ព្រះសក្យ-មុនី ។ បទថា សមាហិតោ បានដល់ អ្នកមានចិត្តតាំងមាំហើយ ដោយសមាធិដែលជាអរិយមគ្គ ។ បទថា ន តេន ធម្មេន សមត្ថិ កិញ្ចិ សេចក្តីថា ធម្មជាតិណាៗដែលស្មើដោយធម៌ ដែលព្រះសក្យមុនី ទ្រង់សម្រេចហើយមាននាមថា ខយៈជាដើមនោះមិនមាន ។ ព្រោះដូច្នោះ សូម្បីក្នុងព្រះសូត្រដទៃ ព្រះមានព្រះភាគក៏ត្រាស់ទុកជាដើមថា ៖

"ម្នាលភិក្ខុទាំងឡាយ ធម៌ប៉ុន្មានដែលជាសង្ខតធម៌ (ធម៌ដែលមាន បច្ច័យប្រជុំតាក់តែង) ក្តី ជាអសង្ខតធម៌ (ធម៌ដែលមិនមានបច្ច័យប្រជុំតាក់តែង) ក្តី វិរាគៈ (ការប្រាសចាកតម្រេក) ប្រាកដជាប្រសើរជាងធម៌ទាំងនោះ"[១] ។

ព្រះមានព្រះភាគ កាលត្រាស់សេចក្តីដែលព្រះនិព្វាន ដែលធម៌ដទៃ ៗ ប្រៀបមិនបានយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីរម្ងាប់ឧបទ្រវៈដែលកើតដល់សត្វ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ លេខ ៥៣ ទំព័រ ១១៦ ។

ទាំងនោះ ទ្រង់អាស្រ័យសេចក្តីដែលរតនៈ គឺនិព្វានធម៌ មិនមានធម៌ដទៃទឹងដូច ដោយគុណទាំងឡាយ គឺភាពជាធម៌ដែលអស់កិលេស សម្រេកកិលេស ជាអមតធម៌ និងធម៌ដ៏ប្រណីត ទើបទ្រង់ប្រកបសច្ចវចនៈថា ឥទម្បិ ធម្មេ រតនំ បណីតំ ឯតេន សច្ចេន សុវត្ថិ ហោតុ រតនៈ គឺព្រះធម៌នេះឯងជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។ សេចក្តីរបស់សច្ចវចនៈនោះ គប្បីជ្រាបតាមន័យ ដែលពោលមកហើយក្នុងគាថាដើមនុ៎ះឯង ។ ពួកអមនុស្ស ក្នុងសែនកោដិចក្រវាឡ ក៏នាំគ្នាព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថាសូម្បីនេះឯង ។

## យម្ពុទ្ធសេដ្ឋោតិ គាថាវណ្ណនា

### ពណ៌នាគាថា ថា យម្ពុទ្ធសេដ្ឋោ

ព្រះមានព្រះភាគ ត្រាត្រាស់សច្ចវចនៈ ដោយគុណនៃនិព្វានធម៌យ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ត្រាស់បន្ថែមដោយព្រះគុណនៃមគ្គធម៌ថា យម្ពុ-ទ្ធសេដ្ឋោ ជាដើម ។ ក្នុងពាក្យនោះ ឈ្មោះថា ពុទ្ធៈ ដោយន័យជាដើមថា ត្រាស់ដឹងសច្ចៈទាំងឡាយ ។ ឈ្មោះថា សេដ្ឋៈ ព្រោះជាអ្នកខ្ពង់ខ្ពស់ និងគួរសរសើរ ឈ្មោះថា ពុទ្ធសេដ្ឋៈ ព្រោះជាអ្នកត្រាស់ដឹងដ៏អ្នកខ្ពង់ខ្ពស់ និងគួរសរសើរ ។ ន័យម្យ៉ាងទៀត ឈ្មោះថា ពុទ្ធសេដ្ឋៈ ព្រោះជាអ្នកប្រសើរបំផុតក្នុងព្រះពុទ្ធទាំងឡាយ

ដែលហៅថាអនុពុទ្ធ បច្ចេកពុទ្ធនិងសុតពុទ្ធ ។ ព្រះពុទ្ធអ្នកប្រសើរបំផុត ព្រះអង្គនោះទ្រង់សរសើរប្រកាសសមាធិធម៌ណាទុកក្នុងបាលីនោះៗ ដោយន័យជាដើមថា “មគ្គប្រកបដោយអង្គ ៨ ដ៏ក្សេមក្សាន្តជាងមគ្គទាំងឡាយ សម្រាប់ដំណើរទៅកាន់ព្រះនិព្វានឈ្មោះ អមតៈ”[១] ។ មគ្គមានអង្គ៨ ប្រសើរបំផុតនៃមគ្គទាំងឡាយក្សេមដើម្បីសម្រេចព្រះនិព្វាននិងថា “ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវអរិយសម្មាសមាធិ ដែលប្រកបដោយបច្ច័យ ប្រកបដោយបរិក្ខារដល់អ្នកទាំងឡាយ”[២] ។ បទថា **សុចិ** បានដល់ ការបរិសុទ្ធ ព្រោះធ្វើការកាត់មន្ទិល គឺកិលេសបានដាច់ខាត ។ បទថា **សមាធិមានន្តរិកញ្ញមាហុ** សេចក្ដីថា បណ្ឌិតទាំងឡាយពោលដល់សមាធិយ៉ាងណាថាជា **អនន្តរិកសមាធិ** កើតក្នុងលំដាប់ព្រោះអំណាចផលពិតប្រាកដ ក្នុងលំដាប់ដែលប្រព្រឹត្តទៅដោយខ្លួន ។ ព្រោះថានាកាលមគ្គសមាធិកើតឡើងហើយ អន្តរាយណាមួយដែលហាមការកើតនូវផលនៃអនន្តរិកសមាធិនោះ រមែងមិនមាន ដូចដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ៖

“បុគ្គលនេះ ជាអ្នកប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ទុក

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក លេខ ២៤ ទំព័រ ៨៣ ។

២-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ លេខ ៣៧ ទំព័រ ៤៤ ។

*ជាវេលាភ្លើងឆេះកប្បនឹងមាន បើបុគ្គលនេះ មិនទាន់ធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផលដរាបណា ភ្លើងក៏មិនគប្បីឆេះកប្បដរាបនោះដែរ នេះហៅថាបុគ្គល ដែលព្រមព្រៀងដោយមគ្គទាំងអស់ ក៏ឈ្មោះថា ឋិតកប្បីដែរ"[១] ។*

*បទថា* **សមាធិនា តេន សមោ ន វិជ្ជតិ** *សេចក្តីថា រូបាវចរសមាធិ ឬអរូបាវចរសមាធិណាមួយ ដែលស្មើដោយអនន្តរិកសមាធិដ៏ស្អាត ដែលព្រះពុទ្ធប្រសើរបំផុត សរសើរហើយនោះមិនមានឡើយ ។ ព្រោះហេតុអ្វី ព្រោះសត្វសូម្បីកើតក្នុងព្រហ្មលោកនោះៗ ដោយការអប់រំសម្បត្តិទាំងនោះហើយ ក៏នៅមានការកើតក្នុងអបាយ មាននរកជាដើមទៀតបាន និងព្រោះព្រះអរិយបុគ្គលកាត់ការកើតឡើងទាំងអស់ ដោយការអប់រំនូវអរហត្តសមាធិនោះ ។ ព្រោះដូច្នោះសូម្បីសូត្រដទៃ ព្រះដ៏មានព្រះភាគក៏ពោលទុកថា ៖*

*"ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មានដែលជាសង្ខតធម៌ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ល។ នេះប្រាកដជាប្រសើរជាងធម៌ទាំងនោះ"[២] ។*

*ព្រះមានព្រះភាគ កាលត្រាស់សេចក្តីនៃអនន្តរិកសមាធិ ដែលសមាធិដទៃៗប្រៀបមិនបានយ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់អាស្រ័យដែលរតនៈ*

---

*១-អភិធម្មបិដក បុគ្គលប្បញ្ញត្តិ លេខ ៨៣ ទំព័រ ២៣៦ ។*

*២-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ លេខ ៥៣ ទំព័រ ១១៧ ។*

គឺមគ្គធម៌ ដែលរតនៈដទៃប្រៀបមិនបាន ដោយន័យប៉ុណ្ណោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ ធម្មេ រតនំ បណីតំ ឯតេន សច្ចេន សុវត្ថិ ហោតុ ។** រតនៈ គឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្តមដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។ សេចក្តីនៃសច្ចវចនៈនោះ គប្បីជ្រាបដោយន័យ ដែលបានពោលហើយនុ៎ះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាឡ នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## យេ បុគ្គលាតិ គាថាវណ្ណនា

## **ពណ៌នាគាថា** ថា យេ បុគ្គលា

ព្រះមានព្រះភាគ លុះត្រាស់សច្ចវចនៈ សូម្បីដោយគុណនៃមគ្គធម៌យ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ត្រាស់បន្ថែមដោយសង្ឃគុណថា យេ បុគ្គលា ជាដើម ។ ក្នុងពាក្យនោះ ស័ព្ទថា យេ ជានិទ្ទេសមិនប្រាកដ ។ បទថា បុគ្គលា បានដល់ សត្វទាំងឡាយ ។ ស័ព្ទថា អដ្ឋ ជាការកំណត់ចំនួនសត្វទាំងនោះ ។ មែនពិត សត្វទាំងនោះមាន ៨ គឺ អ្នកបដិបត្តិមគ្គ ៤ និងអ្នកតាំងនៅក្នុងផល ៤ ។ បទថា **សតំ បសដ្ឋា** បានដល់ សប្បុរសទាំងឡាយគឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ សាវកពុទ្ធ ទេវតា និងមនុស្សដទៃ សរសើរហើយ ។ ព្រោះហេតុអ្វី ព្រោះប្រកបដោយគុណមានសីលដែលកើតរួមគ្នាជាដើម ។ សេចក្តីពិត គុណទាំងឡាយ

របស់សប្បុរសទាំងនោះ មានសីល សមាធិជាដើមកើតរួមគ្នា ដូចពណ៌ និងក្លិនជាដើម ដែលកើតរួមគ្នារបស់ផ្កាចម្ប៉ា និងផ្កាចំប៉ីជាដើម ព្រោះហេតុនោះបុគ្គលទាំងនោះ ទើបជាទីស្រឡាញ់ពេញចិត្ត ដែលគួរសរសើររបស់សប្បុរសទាំងឡាយ ដូចផ្កាឈើទាំងឡាយ ដែលព្រមដោយពណ៌ និងក្លិនជាដើម ជាទីស្រឡាញ់ គួរជាទីពេញចិត្ត សរសើររបស់មនុស្ស និងទេវតាទាំងឡាយ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទើបត្រាស់ថា យេ បុគ្គលា អដ្ឋ សតំ បសដ្ឋា ។

ម្យ៉ាងទៀត ស័ព្ទថា យេ ជានិទ្ទេសមិនពិតប្រាកដ ។ បទថា បុគ្គលា បានដល់ សត្វទាំងឡាយ ។ ស័ព្ទថា អដ្ឋសតំ ជាការកំណត់ចំនួនសត្វទាំងនោះ ។ មែនពិត សត្វពួកនោះ បានដល់ព្រះសោតាបន្ន ៣ ពួក គឺឯកពីជី កោលំកោលៈ និងសត្តក្ខត្តុំបរមៈ ។ ព្រះសកទាគាមី ៣ ពួក អ្នកសម្រេចផលក្នុងកាមភព រូបភព និងអរូបភព ។ ព្រះសោតាបន្ន និងព្រះសកទាគាមី ពួកនោះទាំងអស់មាន ២៤ ពួក ដោយអំណាចបដិបទា ៤[១] ។ ព្រះអនាគាមី ក្នុងទេវតាជាន់អវិហា មាន

---

១- អដ្ឋសតម្បិ បុរិសបុគ្គលាតិ តត្ថ ឯកពីជី កោលំកោលោ សត្តក្ខត្តុំបរមោតិ តយោ សោតាបន្នា ។ កាមរូបារូបភវេសុ អធិគតផលា តយោ សកទាគាមិនោតិ តេ សព្វេបិ ទុក្ខាបដិបទា ទន្ធាភិញ្ញំ ទុក្ខាបដិបទា ខិប្បាភិញ្ញំ សុខាបដិបទា ទន្ធាភិញ្ញំ សុខាបដិបទា ខិប្បាភិញ្ញន្តិ ចតុន្នំ បដិបទានំ វសេន ចតុវីសតិ ។ ក្នុងបទថា អដ្ឋសតម្បិ បុរិសបុគ្គលា

៥ ពួកគឺ អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី សសង្ខារបរិនិព្វាយី អសង្ខារ-បរិនិព្វាយី និងឧទ្ធំសោតោអកនិដ្ឋគាមី ។ ព្រះអនាគាមី ក្នុងទេវតាជាន់អតប្បា សុទស្សា សុទស្សី ក៏មួយជាន់ៗ មាន ៥ ពួកដូចគ្នា ។ ចំណែកទេវតាជាន់អកនិដ្ឋ មាន ៤ ពួក វៀរតែឧទ្ធំសោតោចេញ រួមព្រះអនាគាមី ២៤ ពួក ។ ព្រះអរហត្ត មាន ២ ពួក គឺសុក្ខវិបស្សក: និងសមថយានិក: ។ ព្រះអរិយបុគ្គល អ្នកតាំងនៅក្នុងមគ្គមាន ៤ ពួក រួមត្រូវជាព្រះអរិយបុគ្គល ៥៤ ពួក ។ ព្រះអរិយបុគ្គលពួកនោះគុណនឹងពីរពួក គឺដោយអំណាចនៃសទ្ធាធុរ: និងបញ្ញាធុរ:ត្រូវជា ១០៨ ពួក (៥៤ x ២ = ១០៨) ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយនោះឯង ។

---

សេចក្ដីថា សោតាបន្នបុគ្គល មានបីពួក គឺ ឯកពីជី ១ កោលំកោល ១ សត្តក្ខត្តុបរម: ១ ។ សកទាគាមិបុគ្គល មានបីពួក ជាអ្នកមានផល សម្រេចហើយក្នុងកាមភព រូបភព និង អរូបភព សរុបបុគ្គលទាំងនោះមាន ២៤ ដោយអំណាចនៃ បដិបទាបួន គឺ ទុក្ខាបដិបទា ទន្ធាភិញ្ញា (បុគ្គលប្រតិបត្តិដោយលំបាក ត្រាស់ដឹងដោយយឺតយូរ) ១ ទុក្ខបដិបទា ខិប្បាភិញ្ញា (បុគ្គលប្រតិបត្តិដោយលំបាកត្រាស់ដឹងឆាប់រហ័ស) ១ សុខាបដិបទា ទន្ធាភិញ្ញា (បុគ្គលប្រតិបត្តិស្រួល ត្រាស់ដឹងយឺតយូរ) ១ សុខាបដិបទា ខិប្បាភិញ្ញា (បុគ្គលប្រតិបត្តិស្រួល ត្រាស់ដឹងឆាប់រហ័ស) ១ ។ គម្ពីរសីមវិសោធនី ត្រង់សមសីសិកណ្ឌ ពណ៌នាអំពីព្រះសង្ឃ ដែលរចនាដោយព្រះសាគរពុទ្ធិត្ថេរ ។

សម្រាប់ជាធម្មទាន

បទថា ចត្តារិ ឯតានិ យុគានិ ហោន្តិ សេចក្តីថា បុគ្គលដែលទ្រង់លើកឧទ្ទេសទុកដោយពិស្តារថា ព្រះអរិយបុគ្គលពួកនោះទាំងអស់មាន ៨ ពួកក្តី ១០៨ ពួកក្តី ពោលដោយសង្ខេប អ្នកតាំងនៅក្នុងសោតាបត្តិមគ្គ អ្នកតាំងនៅក្នុងសោ-តាបត្តិផល រួមជាគូ១ យ៉ាងនេះរហូតដល់អ្នកតាំងនៅក្នុងអរហត្តមគ្គ អ្នកតាំងនៅក្នុងអរហត្តផលរួមជាគូ ១ រួមទាំងអស់ជា ៤ គូ ។ ស័ព្ទថា តេ ក្នុងបទថា តេ ទក្ខិណេយ្យា ជាស័ព្ទនិទ្ទេស អធិប្បាយថា កំណត់ពិតប្រាកដដល់បទឧទ្ទេសដែលលើកតាំងទុកមិនពិតប្រាកដ ។ បុគ្គលដែលព្រះមានព្រះភាគត្រាស់ទុកដោយពិស្តារថា មាន ៨ ពួក ឬ ១០៨ ពួក ដោយសង្ខេបថាមាន ៤ គូ សូម្បីទាំងអស់រមែងគួរដល់ទក្ខិណា ព្រោះហេតុនោះ ទើបឈ្មោះថា ទក្ខិណេយ្យ ។ ទេយ្យធម៌ដែលបុគ្គលជឿកម្មនិងផលនៃកម្មមិនសម្លឹងទោសដោយគំនិតយ៉ាងនេះថា ភិក្ខុរូបនេះនឹងធ្វើវេជ្ជកម្ម ឬជាអ្នកទទួលបម្រើគ្រហស្ថដូច្នេះជាដើម ហើយថ្វាយឈ្មោះថា ទក្ខិណា ។ បុគ្គលអ្នកប្រកបដោយគុណមានសីលគុណជាដើម និងបុគ្គលអ្នកមានសភាពដូច្នេះ (ភិក្ខុអ្នកប្រកបនូវវេជ្ជកម្ម និងបម្រើគ្រហស្ថជាដើម) ឈ្មោះថា រមែងគួរដល់ទក្ខិណានោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ថា តេ ទក្ខិណេយ្យា ។

បទថា សុគតស្ស សាវកា សេចក្ដីថា ព្រះមានព្រះភាគឈ្មោះថា សុគត ព្រោះទ្រង់ប្រកបដោយដំណើរល្អ ព្រោះព្រះអង្គយាងទៅកាន់ស្ថានទីដែលស្អាត ព្រោះព្រះអង្គទៅដោយល្អ និងព្រោះត្រាស់ល្អ ។ ជាសាវករបស់ព្រះសុគតព្រះអង្គនោះ ។ បុគ្គលទាំងនោះ ឈ្មោះថា សាវក ព្រោះស្ដាប់ព្រះតម្រាស់ ។ បុគ្គលដទៃស្ដាប់ គ្រាន់តែធ្វើនូវកាតព្វកិច្ចរបស់ខ្លួនប៉ុណ្ណោះ ។ ចំណែកសាវកពួកនេះ ស្ដាប់ហើយធ្វើកិច្ចដែលគួរធ្វើ គឺបដិបត្តិធម៌សមគួរដល់ធម៌ សម្រេចមគ្គផល ព្រោះដូច្នោះ ទើបត្រាស់ហៅថា សាវក ។

បទថា ឯតេសុ ទិន្នានិ មហប្ផលានិ សេចក្ដីថា ទានទាំងឡាយសូម្បីបន្តិចបន្តួចដែលថ្វាយក្នុងសាវករបស់ព្រះតថាគតទាំងនេះ ឈ្មោះថា ជាទានមានផលច្រើន ព្រោះជាទានដែលចូលដល់ការសម្រេចជាទក្ខិណាបរិសុទ្ធិ ចំពោះបដិគ្គាហកៈ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ទុកក្នុងសូត្រដទៃថា ៖

“ម្នាលភិក្ខុទាំងឡាយ សង្ឃក្ដី គណៈក្ដីទាំងប៉ុន្មាន សង្ឃជាសាវករបស់ព្រះតថាគតដែលចាត់ជាគូនៃបុរសមាន ៤ គូ ចាត់ជាបុរសបុគ្គលរៀងគ្នាមាន ៨ នេះប្រាកដជាប្រសើរជាង សង្ឃនិងគណៈទាំងនោះ”[១] ។

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ លេខ ៥៣ ទំព័រ ១១៧ ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈ ដោយអ្នកតាំងនៅក្នុងមគ្គ អ្នកតាំងនៅក្នុងផលទាំងអស់យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះនុ៎ះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា ឥទម្បិ សង្ឃេ ដូច្នេះ ។ សេចក្តីរបស់សច្ចវចនៈក៏គប្បីជ្រាប តាមន័យដែលពោលមកមុននុ៎ះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាឡ នាំគ្នាព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថាសូម្បីនេះឯង ។

## យេ សុប្បយុត្តាតិ គាថាវណ្ណនា

## ពណ៌នាគាថា ថា យេ សុប្បយុត្តា

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ ដោយគុណរបស់សង្ឃរតនៈ ដោយអ្នកតាំងនៅក្នុងមគ្គ និងអ្នកតាំងនៅក្នុងផលយ៉ាងនេះហើយ ឥឡូវនេះ ទើបត្រាស់បន្ថែមដោយគុណរបស់ព្រះខីណាស្រវបុគ្គលទាំងឡាយ អ្នកសោយសុខក្នុងផលសមាបត្តិពួកខ្លះប៉ុណ្ណោះថា យេ សុប្បយុត្តា ជាដើម ។ ក្នុងបទនោះ បទថា យេ ជាបទឧទ្ទេសដែលមិនពិតប្រាកដ ។ បទថា សុប្បយុត្តា ប្រែថា ប្រកបល្អហើយ អធិប្បាយថា លះអនេសនៈ ការស្វែងរកដែលមិនសមគួរច្រើនយ៉ាង ហើយអាស្រ័យការចិញ្ចឹមជីវិតដែលបរិសុទ្ធ បន្ថែមប្រកបខ្លួនទុកក្នុងវិបស្សនា ។ ម្យ៉ាងទៀត បទថា សុប្បយុត្តា បានដល់ ប្រកបដោយកាយប្រយោគ និងវចីប្រយោគដ៏ម៉ត់ចត់ល្អ ព្រះអង្គទ្រង់សម្តែងសីលខន្ធរបស់

ព្រះខីណាស្រវបុគ្គលនោះ ដោយបទថា សុប្បយុត្តា នោះ ។ បទថា មនសា ទឡ្ហេន បានដល់ ដោយចិត្តដែលពិតប្រាកដ អធិប្បាយថា ដោយចិត្តដែលប្រកបដោយសមាធិដ៏មាំ ។ ព្រះមានព្រះភាគទ្រង់សម្តែង សមាធិខន្ធរបស់ព្រះខីណាស្រវបុគ្គលទាំងនោះដោយបទថា មនសា ទឡ្ហេន នោះ ។ បទថា និក្កាមិនោ បានដល់ ជាអ្នកមិនអាល័យក្នុងកាយ និងជីវិត មានសេចក្តីព្យាយាមចេញចាកកិលេសទាំងពួង ដែលមានបញ្ញា ជាធុរៈ ធ្វើហើយដោយសេចក្តីព្យាយាម។ ព្រះមានព្រះភាគ ទ្រង់សម្តែងបញ្ញាខន្ធដែលប្រកបដោយសេចក្តី ព្យាយាមរបស់ព្រះខីណាស្រវបុគ្គលទាំងនោះដោយបទថា និក្កាមិនោ នោះ ។

បទថា គោតមសាសនម្ហិ បានដល់ ក្នុងសាសនារបស់ព្រះតថាគតអ្នកមានព្រះនាមថា **គោតម** ដោយគោត្រនុ៎ះឯង ។ ដោយបទថា គោតម-សាសនម្ហិ នោះ ទ្រង់សម្តែងថា សត្វមនុស្សក្រៅសាសនានេះ អ្នកធ្វើតបៈដើម្បីទេព្តាជាម្ចាស់ សូម្បីមានប្រការផ្សេងៗ ក៏មិនមានសេចក្តីព្យាយាមចេញចាកកិលេសទាំងឡាយ ព្រោះមិនមានគុណមានការប្រកបយ៉ាងល្អជាដើម ។ បទថា តេ ជាបទអធិប្បាយឧទ្ទេសដែលតាំងទុកមុន ។ ក្នុងពាក្យថា បត្តិបត្តា នេះ ជាគុណជាតិគួរសម្រេច ហេតុនោះទើបឈ្មោះថា បត្តិ គុណដែលគួរសម្រេចគឺ

បុគ្គលសម្រេចហើយ និងជាអ្នកក្សេមផុតចាកយោគៈទាំងអស់ ឈ្មោះថា បត្តព្វា ។ ពាក្យនេះ ជាឈ្មោះរបស់ព្រះអរហត្តផល ។ អ្នកសម្រេចគុណដែលគួរសម្រេចមុនគេនោះ ហេតុនោះទើប ឈ្មោះថា បត្តិបត្តា ។ បទថា អមតំ បានដល់ ព្រះនិព្វាន ។ បទថា វិគយ្ហ បានដល់ ចូលដល់ដោយអារម្មណ៍។បទថា លទ្ធា ប្រែថា បានហើយ ។ បទថា មុធា បានដល់ ដោយមិនមានតម្លៃ គឺមិនធ្វើតម្លៃសូម្បីត្រឹមតែកាកណិក[១]មួយ ។ បទថា និព្វុតឹ បានដល់ ផលសមាបត្តិដែលរម្ងាប់សេចក្តីខ្វល់ខ្វាយ គឺកិលេសចេញហើយ ។ បទថា ភុញ្ជមានា បានដល់ កាលសោយ ។ លោកអធិប្បាយ ទុកយ៉ាងណា ។ លោកអធិប្បាយ ទុកថា ពួកជនណា ក្នុងសាសនារបស់ព្រះគោតមនេះ ឈ្មោះថា ប្រកបល្អហើយ ព្រោះដល់ព្រមដោយសីល ឈ្មោះថា មានចិត្តពិតប្រាកដ ព្រោះដល់ព្រមដោយសមាធិ ឈ្មោះថា សេចក្តីមិនមានអាល័យ ព្រោះដល់ព្រមដោយបញ្ញា, ជនពួកនោះ ក៏ចូលដល់អមតៈ ដោយសម្មាបដិបត្តិនេះ ជាអ្នកមិនទទេៗ សោយសេចក្តីរំលត់ពោល គឺផលសមាបត្តិ ឈ្មោះថា ជាអ្នកសម្រេចគុណដែលគួរសម្រេច ។

---

១-ឈ្មោះប្រាក់បុរាណដែលគេប្រើក្នុងមជ្ឈិមប្រទេស ។ ( វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួន ណាត ) ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈ ដោយអំណាចព្រះខីណាសវបុគ្គល ដែលសោយផលសមាបត្តិជាសុខយ៉ាងនេះហើយ ឥឡូវនេះ ព្រះអង្គទ្រង់អាស្រ័យគុណនុ៎ះឯង ទើបទ្រង់ប្រកាសសច្ចវចនៈថា **ឥទម្បិ សង្ឃេ រតនំ បណីតំ** រតនៈគឺព្រះសង្ឃនេះឯងជារតនៈដ៏ឧត្តម ។ គប្បីជ្រាបតាមន័យ ដែលពោលមុនហើយ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាឡ ក៏នាំគ្នាព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថាសូម្បីនេះឯង ។

## យថិន្ទខីលោតិ គាថាវណ្ណនា

## ពណ៌នាគាថា ថា យថិន្ទខីលោ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំង ដោយព្រះខីណាសវបុគ្គលយ៉ាងនេះហើយ ឥឡូវនេះព្រះអង្គទ្រង់ត្រាស់បន្ថែមដោយគុណរបស់ព្រះសោតាបន្នប៉ុណ្ណោះ ដោយការធ្វើឱ្យជាក់ច្បាស់ដល់ជនច្រើនគ្នាថា យថិន្ទខីលោ ជាដើម ។ ក្នុងពាក្យនោះ ពាក្យថា យថា ជាពាក្យឧបមា ។ បទថា **ឥន្ទខីលោ** នេះជាឈ្មោះរបស់សសរឈើខ្លឹមដែលជាប់នឹងដី ៨ ហត្ថ ឬ១០ ហត្ថ ខាងក្នុងធរណីទ្វារ ដើម្បីការពារទ្វារព្រះនគរ ។ បទថា បឋវឹ ប្រែថា ផែនដី ។ បទថា សិតោ បានដល់ ចូលទៅអាស្រ័យនៅខាងក្នុង ។ បទថា សិយា ប្រែថា គប្បី

មាន ។ បទថា ចតុព្ភិ វាតេហិ ប្រែថា ដែលខ្យល់បក់មកអំពីទិសទាំង ៤ ។ បទថា អសម្បកម្បិយោ បានដល់ មិនឱ្យកម្រើក គឺមិនឱ្យញាប់ញ័រ ។ បទថា តថូបមំ ប្រែថា មានសភាពដូច្នោះ ។ បទថា សប្បុរិសំ បានដល់ បុរសខ្ពង់ខ្ពស់ ។ បទថា វទាមិ ប្រែថា ពោល ។ ច្រើនបទថា យោ អរិយសច្ចានិ អវេច្ច បស្សតិ ប្រែថា បុគ្គលឯណាឃើញអរិយសច្ចៈទាំងឡាយ ៤ ដោយបញ្ញា ។ ក្នុងសេចក្តីនោះ អរិយសច្ចៈទាំងឡាយគឺបណ្ឌិត គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងកុមារបញ្ហានុ៎ះឯង ។

ចំណែកសេចក្តីសង្ខេបក្នុងពាក្យនេះ មានដូច្នេះ ដូចសសរខឿនដែលគេបោះភ្ជាប់នឹងដី ព្រោះមានឫសជ្រៅ ខ្យល់បក់មកអំពីទិសទាំង៤ ក៏គប្បីឱ្យកម្រើកមិនបានយ៉ាងណា អ្នកណាពិចារណាឃើញនូវអរិយសច្ចៈ តថាគតហៅអ្នកនោះថាជាសប្បុរសសូម្បីនេះ ឧបមាយ៉ាងនោះដូចគ្នា ។ ព្រោះហេតុអ្វី ព្រោះថាសប្បុរសសូម្បីនោះ ជាអ្នកដែលខ្យល់ គឺវាទៈរបស់តិរ្ថិយទាំងពួង ធ្វើឱ្យកម្រើកមិនបានគឺនរណាៗ ក៏មិនអាចឱ្យកម្រើក ឬកក្រើកចាកទស្សនៈនោះបាន ដូចសសរខឿន ដែលខ្យល់បក់មកអំពីទិសទាំង ៤ ទិស ធ្វើឱ្យកម្រើកមិនបានដូច្នោះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ទុកសូម្បីក្នុងសូត្រដទៃថា ៖

"ម្នាលភិក្ខុទាំងឡាយដូចសសរដែកក្ដី សសរគោលក្ដី ដែលមានរណ្ដៅដ៏ជ្រៅ គេដាំស៊ប់សួនល្អ ឥតមានករម្រើក ឥតមានញាប់ញ័រ បើទុកជាភ្លៀងលាយដោយខ្យល់ដ៏ខ្លាំងមកអំពីទិសខាងកើតក៏មិនធ្វើសសរនោះឱ្យកម្រើក មិនធ្វើឱ្យរញ្ជួយ មិនធ្វើឱ្យញាប់ញ័រ បើទុកជាខ្យល់បក់មកអំពីខាងលិចក្ដី ។ ល ។ អំពីខាងជើងក្ដី ភ្លៀងដែលលាយដោយខ្យល់ដ៏ខ្លាំងមកអំពីទិសខាងត្បូងក្ដី ក៏មិនធ្វើឱ្យសសរនោះកម្រើករញ្ជួយញាប់ញ័រឡើយ ។ ដំណើរនេះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះរណ្ដៅជ្រៅ ព្រោះសសរគេដាំស៊ប់សួនល្អ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ណាទីមួយ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមសេចក្ដីពិតថា នេះបដិបទាជា ដំណើរទៅកាន់ទីរំលត់ទុក្ខ សមណៈ ឬព្រាហ្មណ៍ទាំងនោះ មិនក្រឡេកមើលមុខ សមណៈ ឬព្រាហ្មណ៍ដទៃថា លោកដ៏ចម្រើន កាលបើដឹងក៏ដឹងហើយពិត កាលបើឃើញក៏ឃើញដោយពិត ។ ដំណើរនោះព្រោះហេតុអ្វី ? ម្នាលភិក្ខុទាំងឡាយ ព្រោះថា បានឃើញនូវអរិយសច្ចៈ ៤ ដោយប្រពៃ"[១] ។

---

១-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ លេខ ៣៩ ទំព័រ ២៨៤-២៨៥ ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈ ដោយអំណាចសោតាបន្ន ដែលប្រចក្សដល់មនុស្សជាច្រើនប៉ុណ្ណោះ យ៉ាងនេះហើយ ឥឡូវនេះទ្រង់អាស្រ័យគុណនុ៎ះឯង ទើបទ្រង់ប្រកាសសច្ចវចនៈថា ឥទម្បិ សង្ឃេ រតនំ បណីតំ រតនៈ គឺព្រះសង្ឃនេះឯងជារតនៈដ៏ឧត្តម ។ សេចក្តីរបស់សច្ចវចនៈនោះគប្បីជ្រាបតាមន័យដែលពោលមកមុនហើយនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាឡក៏នាំគ្នាព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថាសូម្បីនេះឯង ។

## យេ អរិយសច្ចានីតិ គាថាវណ្ណនា

## ពណ៌នាគាថា ថា យេ អរិយសច្ចានិ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ ដែលមានសង្ឃរតនៈជាទីតាំង ដោយគុណរបស់ព្រះសោតាបន្ន ដោយមិនប្លែកគ្នាយ៉ាងនេះហើយ ព្រះសោតាបន្នទាំងឡាយបីនេះ គឺឯកពីជី កោលំកោលៈ សត្តក្ខត្តុំបរមៈ ឥឡូវនេះ ទើបព្រះមាន-ព្រះភាគ ទ្រង់ត្រាស់បន្ថែមថា យេ អរិយសច្ចានិ ជាដើម ដោយគុណរបស់ព្រះសោតាបន្នជាសត្តក្ខត្តុំបរមៈថ្នាក់ទាបបំផុត ដូចដែលត្រាស់ទុកថា ៖

"បុគ្គលខ្លះក្នុងលោកនេះ ដល់នូវសោតៈ ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ ...បុគ្គលនោះ កើតក្នុងភពជាមនុស្សម្តងទៀត ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះហៅថា បុគ្គលជាឯកពីជី ។ ក៏ដូចគ្នាដែរ បុគ្គលនោះ ស្ទុះទៅ អន្ទោលទៅកាន់ត្រកូលពីរ ឬបីធ្វើនូវទីបំផុតនៃវដ្តទុក្ខនេះ ហៅថា បុគ្គលជាកោលំកោលៈ ។ មួយវិញទៀត បុគ្គលនោះ ស្ទុះទៅអន្ទោលទៅក្នុងទេវតា និងមនុស្ស អស់វារៈ ៧

ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះហៅថា សត្តក្ខត្តុំបរមៈ"[១] ។

បណ្ដាបទទាំងនោះ បទថា យេ អរិយសច្ចានិ នេះ មានន័យដែលពោលមកហើយនោះឯង ។ បទថា វិភាវយន្តិ បានដល់ កម្ចាត់សេចក្ដីងងឹតគឺកិលេសដែលបិទបាំងសច្ចៈហើយ ធ្វើឱ្យជាក់ច្បាស់ប្រាកដដល់ខ្លួន ដោយពន្លឺគឺនៃបញ្ញា ។ បទថា គម្ភីរបញ្ញេន បានដល់ ព្រះមានព្រះភាគ ព្រះអង្គមានបញ្ញាជាកម្លាំងដែលនរណាៗ មិនមានដោយញាណរបស់លោកនេះ ព្រមទាំងទេវលោក ព្រោះបញ្ញាដែលរកប្រមាណមិនបាន លោកអធិប្បាយថា ជាសព្វញ្ញូ ។

បទថា សុទេសិតានិ បានដល់ ទ្រង់សម្ដែងដោយល្អ ដោយន័យនោះៗ មានសមាសន័យ អព្យាសន័យ សាកល្យន័យ វេកល្យន័យជាដើម ។ បទថា កិញ្ចាបិ តេ ហោន្តិ ភុសប្បមត្តា សេចក្ដីថា បុគ្គលទាំងឡាយ អ្នកអប់រំអរិយសច្ចៈទាំងនោះហើយ អាស្រ័យឋានៈនៃសេចក្ដីប្រមាទ មានភាពជាទេវរាជ និងស្ដេចចក្រពត្តិជាដើម ជាអ្នកប្រមាទយ៉ាងខ្លាំងក្លាក៏ពិតហើយ ក៏ប៉ុន្តែថា នាមរូបណាគប្បីតាំងនៅ ព្រោះវិញ្ញាណដែលសោតាបត្តិមគ្គញាណកាត់តែងរំលត់ទៅហើយ កើតក្នុងសង្សារវដ្តដែលមានខាងដើម និងខាងចុងតាមកំណត់មិនបានហើយក្នុង

---

១-អភិធម្មបិដក បុគ្គលប្បញ្ញត្តិ លេខ ៨៣ ទំព័រ ២៤១-២៤២ ។

ភពទី ៧ ក៏មិនកាន់យកភពទី ៨ ព្រោះនាមរូបនោះរលត់ទៅ ព្រោះតាំងនៅបាន តែក្នុងភពទី ៧ នុ៎ះឯង ក៏ចម្រើនវិបស្សនាហើយសម្រេចព្រះអរហត្ត ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈ ដោយព្រះសោតាបន្នសត្តក្ខត្តុំបរមៈយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះនុ៎ះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា ឥទម្បិ សង្ឃេ រតនំ បណីតំ រតនៈ គឺព្រះសង្ឃនេះឯងជារតនៈដ៏ឧត្តម ។ សេចក្តីរបស់សច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលមកមុនហើយនុ៎ះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាឡ ក៏នាំគ្នាព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## សហាវស្សាតិ គាថាវណ្ណនា

### ពណ៌នាគាថា ថា សហាវស្ស

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំង ដោយគុណគឺការមិនកាន់យកភពទី ៨ របស់ព្រះសោតាបន្នសត្តក្ខត្តុំបរមៈយ៉ាងនេះហើយ ឥឡូវនេះ ទើបត្រាស់បន្ថែមថា សហាវស្ស ជាដើម ដោយគុណរបស់ព្រះសោតាបន្នសត្តក្ខត្តុំបរមនោះនុ៎ះឯង សូម្បីទីងទៅកាន់ភពទី ៧ ដែលប្លែកចាកបុគ្គលដទៃៗ ដែលមិនទាន់លះភពបាន ។ ក្នុងពាក្យនោះ បទថា សហាវ ប្រែថា ព្រមគ្នា ។ បទថា អស្ស បានដល់ បណ្តាព្រះសោតាបន្ន ដែលត្រាស់ថា

ព្រះសោតាបន្នទាំងនោះ មិនកាន់យកភពទី ៨ ភពណាមួយ ។ បទថា ទស្សន-សម្បទាយ បានដល់ ការដល់ព្រមនៃសោតាបត្តិមគ្គ ។ មែនពិត សោតាបត្តិមគ្គ ឃើញព្រះនិព្វានហើយ លោកទើបហៅថា ទស្សនៈ ព្រោះឃើញព្រះនិព្វានមុន ធម៌ទាំងពួង ដោយការដល់ព្រមនៃកិច្ចដែលគួរធ្វើ ។ សេចក្តីប្រាកដនៃសោតាបត្តិ-មគ្គនោះនៅក្នុងខ្លួន ឈ្មោះថា ទស្សនសម្បទា ។ ព្រោះការដល់ព្រមដោយ ទស្សនសម្បទានោះនុ៎ះឯង ។ ស័ព្ទថា សុ ក្នុងបទថា "តយស្សុ ធម្មា ជហិតា ភវន្តិ នេះជានិបាត ចុះក្នុងអត្ថដើម្បីបំពេញបទ ដូចក្នុងប្រយោគជាដើម ថា ឥទំ សុ មេ សារិបុត្ត មហាវិកដភោជនស្មឹ ហោតិ ម្នាលសារីបុត្ត នេះឯងជាវត្ត ខាងភោជនយ៉ាងចម្លែកធំ របស់តថាគត"[១] ។ ក្នុងសេចក្តីនេះ មានសេចក្តីយ៉ាង នេះថា ព្រោះហេតុថាធម្មតា (សំយោជនកិលេស ៣ យ៉ាង) រមែងជាធម៌គឺ ព្រះសោតាបន្នលះបង់បានហើយ ជាការលះបង់ហើយ ព្រមដោយទស្សនសម្បទា របស់ព្រះសោតាបន្ននោះ ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងធម៌ដែលព្រះសោតាបន្នលះបង់ហើយ ទើប ត្រាស់ថា សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច សីលព្វតំ វាបិ យទត្ថិ កិញ្ចិ បណ្តា ធម៌ ៣ យ៉ាងនោះ កាលកាយនេះមាន ទិដ្ឋិមានវត្ថុ ២០ ដែលរាប់បញ្ចូល

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក លេខ ២០ ទំព័រ ២៩៧ ។

ឧបាទានខន្ធ ៥ ឈ្មោះថា សក្កាយទិដ្ឋិ ឬថាទិដ្ឋិក្នុងកាយនោះ ព្រោះហេតុនោះ ឈ្មោះថា សក្កាយទដ្ឋិ អធិប្បាយថា ទិដ្ឋិក្នុងកាយតាមដែលពោលមកហើយ ។ ម្យ៉ាងវិញទៀត ទិដ្ឋិដែលមានក្នុងកាយនោះប៉ុណ្ណោះឈ្មោះថា សក្កាយទិដ្ឋិ អធិប្បាយថា ទិដ្ឋិដែលប្រព្រឹត្តដោយគំនិតយ៉ាងនេះថា ខ្លួន ពោលគឺ រូបជាដើម មានក្នុងកាយ តាមន័យដូចដែលពោលហើយ ។ ទិដ្ឋិទាំងពួង រមែងជាការដែល ព្រះសោតាបន្នលះហើយ ព្រោះលះសក្កាយទិដ្ឋិនោះបានហើយ ព្រោះថា សក្កាយទិដ្ឋិនោះជាឫសគល់របស់ធម៌គឺកិលេសទាំងនោះ ។ បញ្ញាលោកហៅថា ចិកិច្ឆិតៈ ព្រោះរំងាប់ព្យាធិ គឺកិលេសទាំងពួង ។ បញ្ញាចិកិច្ឆិតៈនោះ ទៅប្រាស ហើយចាកវត្ថុនោះ ឬវត្ថុនេះទៅប្រាសហើយចាកបញ្ញាចិកិច្ឆិតៈនោះ ព្រោះហេតុ នោះ ទើបឈ្មោះថា វិចិកិច្ឆិតៈ ។ ពាក្យនេះ ជាឈ្មោះសេចក្តីសង្ស័យដែលមាន វត្ថុ ៨ ដែលត្រាស់ទុកដោយន័យជាដើមថា សង្ស័យក្នុងព្រះសាស្តា[១] ។ សេចក្តី សង្ស័យសូម្បីទាំងអស់ ជាការលះបានហើយ ក៏ព្រោះលះវិចិកិច្ឆានោះបានហើយ មែនពិត សេចក្តីសង្ស័យនោះជាឫសគល់របស់ កិលេសទាំងនោះ ។ សីល មានប្រភេទផ្សេងៗ ដូចជាគោសីល (សីលគោ) កុក្កុរសីល (សីលសុនខ)ជាដើម និងវត្តទាំងឡាយមានគោវត្ត និងកុក្កុរវត្តជាដើម ដែលមានមកក្នុងបាលីយ៉ាងនេះ

---

១-អភិធម្មបិដក វិភង្គ លេខ ៨២ ទំព័រ ១៩៣ ។

ថា "ពួកសមណព្រាហ្មណ៍ខាងក្រៅអំពីសាសនានេះ(ប្រការថា) សេចក្តីបរិសុទ្ធដោយសីល បរិសុទ្ធដោយវត្ត"[១] ហៅថា សីលវត្ត ។ ប្រព្រឹត្តតបៈដើម្បីទេពមានការអាក្រាតកាយ ការមានក្បាលត្រងោលជាដើម សូម្បីគ្រប់យ៉ាងជាការលះបានហើយ ក៏ព្រោះលះសីលវត្តនោះ ។ មែនពិត សីលវត្តនោះ ជាឫសគល់របស់តបៈនោះ ។ ព្រោះហេតុនោះឯង ព្រះមានព្រះភាគទើបត្រាស់ទុកខាងចុងគាថាទាំងអស់ថា យទត្ថិ កិញ្ចិ យ៉ាងនេះជាដើម ។ គប្បីជ្រាបថា បណ្តាសំយោជនៈថ្នាក់ទាប ៣ នោះ សក្កាយទិដ្ឋិ នឹងលះបានក៏ដោយសេចក្តីដល់ព្រមដោយការឃើញសេចក្តីទុក្ខ វិចិកិច្ឆា នឹងលះបានក៏ដោយសេចក្តីដល់ព្រមដោយការឃើញសមុទយៈ សីលវត្ត (បរាមាសៈ) នឹងលះបានក៏ដោយសេចក្តីដល់ព្រមដោយការឃើញមគ្គ និងការឃើញព្រះនិព្វាន ។

## ចតូហបាយេហីតិ គាថាវណ្ណនា

## ពណ៌នាគាថា ថា ចតូហបាយេហិ

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការលះកិលេសវដ្តរបស់ព្រះសោតាបន្ននោះយ៉ាងនេះហើយ ឥឡូវនេះ កាលកិលេសវដ្តនោះមាននៅវិបាកវដ្ត ក៏គប្បីមាន

១-អភិធម្មបិដក ធម្មសង្គណី លេខ ៧៩ ទំព័រ ១៩៣ ។

កាលទ្រង់សម្រេចការលះវិបាកវដ្តទាំងនោះ ព្រោះលះកិលេសវដ្តនោះ បាន ទើបត្រាស់ថា ចតូហាបាយេហិ ច វិប្បមុត្តោ ។ ក្នុងពាក្យនោះ ឈ្មោះថា អបាយមាន ៤ គឺ និរយៈ តិរច្ឆាន បេត្តិវិស័យ និងអសុរកាយ ។ អធិប្បាយថា ព្រះសោតាបន្ននោះ សូម្បីទៅកាន់ភព ៧ ក៏រួចផុតចាកអបាយទាំង ៤ នោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការលះវិបាកវដ្តរបស់ព្រះសោតាបន្ននោះ យ៉ាងនេះហើយ ឥឡូវនេះ កម្មវដ្តជាឫសគល់របស់វិបាកវដ្តនេះ កាលទ្រង់សម្តែងការលះកម្មវដ្តសូម្បីនោះ ទើបត្រាស់ថា ឆ ចាភិឋានានិ អភព្វោ កាតុំ (ទីងមិនគួរធ្វើ អភិឋានៈ ៦ ) ។ ក្នុងពាក្យនោះ បទថា អភិឋានានិ បានដល់ឋានៈដ៏អាក្រក់ ។ ព្រះសោតាបន្ននោះ មិនគួរធ្វើអភិឋានៈ ៦ យ៉ាងនោះ ។ ក៏អភិឋានៈ ទាំងនោះគប្បីជ្រាបថាកម្ម គឺ មាតុឃាត ( សម្លាប់មាតា ) បិតុឃាត ( សម្លាប់បិតា) អរហន្តឃាត (សម្លាប់ព្រះអរហន្ត ) លោហិតុប្បាទ (ធ្វើលោហិតរបស់ព្រះពុទ្ធឱ្យពុរពង) សង្ឃភេទ (ធ្វើសង្ឃឱ្យបែកគ្នា) អញ្ញសត្ថារុទ្ទេស ចូលទៅកាន់សាស្តាដទៃ ដូចដែលព្រះមានព្រះភាគត្រាស់ទុកក្នុងអង្គុត្តរនិកាយឯកនិបាត ដោយន័យជាដើមថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលដែល បរិបូណ៌ដោយទិដ្ឋិគប្បីផ្តាច់បង់ ជីវិតមាតាដោយហេតុឯណា ហេតុនុ៎ះ មិនមែនជាហេតុ មិនមែនជា

បច្ច័យឡើយ”[១] ។ មែនពិត អរិយសាវ័ក អ្នកដល់ព្រមដោយទិដ្ឋិ មិនគប្បីដាក់ចុះជីវិត សូម្បីតែស្រមោចខ្មៅ ស្រមោចក្រហម ក៏ពិតយ៉ាងនោះ អភិឋាន: ៦ នោះ ព្រះមានព្រះភាគត្រាស់ទុក ក៏ដើម្បីតិះដៀលភាវៈនៃបុថុជ្ជន ។ ពិតណាស់ បុថុជ្ជនរមែងធ្វើ សូម្បីអភិឋានដែលមានទោសច្រើនយ៉ាងនេះបាន ក៏ព្រោះមិនដល់ព្រមដោយទិដ្ឋិ ចំណែកព្រះសោតាបន្ន អ្នកដល់ព្រមដោយទិដ្ឋិ មិនគួរនឹងធ្វើអភិឋាន:ទាំងនោះឡើយ ។ ចំណែកការប្រើ អភព្វ-ស័ព្ទក្នុងទីនេះ ក៏គប្បីសម្តែងថា ព្រះសោតាបន្នមិនធ្វើសូម្បីក្នុងភពដទៃ ។ សេចក្តីពិត សូម្បីក្នុងភពដទៃ ព្រះសោតាបន្ន មិនដឹងថាខ្លួនជាអរិយសាវ័កដោយធម្មតាទុំះឯង ក៏មិនធ្វើអភិឋាន: ៦ យ៉ាងនោះ ឬធ្វើនូវបញ្ចវេរ ៥ មានបាណាតិបាតជាដើម ឬដល់ឋាន: ៦ ព្រមដោយការចូលកាន់សាសនាដទៃ ដែលអាចារ្យពួកខ្លះសំដៅដល់ហើយពោលថា ឆ ឋាភិឋានានិ ដូច្នេះក៏មាន ក៏ព្រះអរិយសាវ័ក និងក្មេង អ្នកស្រុក អ្នកចាប់ត្រីសម្លាប់ជាដើមជាតួយ៉ាងក្នុងសេចក្តីនេះ ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់អរិយសាវ័ក សូម្បីនៅកាន់កពទ ៧ ដែលជាសង្ឃរតនៈ ដោយគុណដែលប្លែកពីបុគ្គលដទៃៗ ដែលនៅលះការកាន់កពមិន បានយ៉ាងនេះហើយ ឥឡូវនេះទ្រង់អាស្រ័យគុណនោះទុំះឯង ទើប

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯកនិបាត លេខ ៤០ ទំព័រ ៦០ ។

ទ្រង់ប្រកាសសច្ចវចនៈថា ឥទម្បិ សង្ឃេ រតនំ បណីតំ រតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ។ សេចក្តីរបស់សច្ចវចនៈនោះ គប្បីជ្រាបដោយន័យ ដែលពោលមកមុនហើយនុ៎ះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាឡ ក៏នាំគ្នាព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## កិញ្ចាបិ សោតិ គាថាវណ្ណនា

## **ពណ៌នាគាថា ថា** កិញ្ចាបិ សោ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈនេះ មានសង្ឃរតនៈជាទីតាំង ប្លែកពីបុគ្គលដទៃ ដែលនៅមិនទាន់លះការកាន់កព ព្រះសោតាបន្នសូម្បីនៅកាន់កព ៧ យ៉ាងនេះ ។ ព្រះសោតាបន្នដល់ព្រមដោយទស្សនៈ មិនមែនមិនគួរធ្វើអភិឋាន: ៦ ប៉ុណ្ណោះក៏ទេ ទាំងមិនគួរធ្វើបាបកម្មសូម្បីតិចតួច ហើយបិទបាំងបាបកម្មនោះដូច្នោះ ឥឡូវនេះទើបទ្រង់ត្រាស់បន្ថែម ដោយគុណគឺព្រះសោតាបន្នអ្នកដល់ព្រមដោយទស្សនៈ សូម្បីនៅដោយសេចក្តីប្រមាទ ក៏មិនមានការបិទបាំងកម្ម ដែលធ្វើមកហើយថា កិញ្ចាបិ សោ កម្មំ ករោតិ ចាបកំ ប្រសិនបើសោតាបន្ននោះ ធ្វើនូវបាបកម្មដោយកាយ វាចា ឬដោយចិត្តក៏ដោយ (ព្រោះការភ្លាំងភ្លាត់) ។

ព្រះតម្រាស់នោះ មានសេចក្តីដូច្នេះ សូម្បីព្រះសោតាបន្ននោះដល់ព្រម ដោយទស្សនៈ អាស្រ័យនៅដោយការប្រមាទ ព្រោះភ្លេចភ្លាំងសតិ វៀរចាក សិក្ខាបទដែលជាលោកវជ្ជៈ ដែលព្រះមានព្រះភាគទ្រង់សំដៅដល់ប្រព្រឹត្តកន្លង ត្រាស់ទុកថា "សិក្ខាបទណា ដែលតថាគតបានបញ្ញត្តដល់សាវកទាំងឡាយហើយ ពួកសាវកនៃតថាគត សូម្បីមានហេតុដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទ នោះឡើយ"[១] រមែងធ្វើបាបកម្មយ៉ាងដទៃតាមផ្លូវកាយ ដែលព្រះពុទ្ធទ្រង់វេៀស ពោលគឺការកន្លងល្មើសសិក្ខាបទ ដែលជាបណ្ណត្តិវជ្ជៈ មានកុដិការសិក្ខាបទ និង សហសេយ្យសិក្ខាបទជាដើមក្តី ធ្វើបាបកម្មផ្លូវវាចា មានបង្រៀនធម៌ដល់ អនុបសម្បន្នជាព្រមគ្នា សម្តែងធម៌ដល់មាតុគ្រាមលើស ពី ៥ ឬ ៦ ម៉ាត់ ការ និយាយផ្តេសផ្តាស និយាយពាក្យអាក្រក់ជាដើមក្តី ធ្វើបាបកម្មផ្លូវចិត្ត មិនថាក្នុង ទីណាៗ គឺការធ្វើឱ្យកើតលោភៈ ទោសៈ ការត្រេកអរចំពោះមាសជាដើម ការមិន ពិចារណាជាដើម ក្នុងការបរិភោគប្រើប្រាស់ចីវរជាដើមក្តី ព្រះសោតាបន្ននោះ ក៏ មិនគួរបិទបាំងបាបកម្មនោះ គឺព្រះសោតាបន្ននោះ ដឹងថា កម្មនេះមិនសមគួរ មិន គួរធ្វើ ក៏មិនបិទបាំងបាបកម្មនោះ សូម្បីតែក្នុងគ្រាមួយ រំពេចនោះឯង ក៏ធ្វើឱ្យ

---

១-វិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ២១០ ។

ជាក់ច្បាស់ ដល់ព្រះសាស្តា ឬក្នុងមិត្តសព្រហ្មចារី ឬអ្នក ជាវិញ្ញូជន ធ្វើតាមធម៌ ឬប្រុងប្រយ័ត្នយ៉ាងនេះថា ខ្ញុំនឹងមិនធ្វើទៀត ។ ព្រោះហេតុ អ្វី? ព្រោះហេតុថា ព្រះមានព្រះភាគត្រាស់ដល់ភាពព្រះសោតាបន្នអ្នកឃើញបទ គឺព្រះនិព្វានហើយ មិនគួរបិទបាំងបាបកម្ម សូម្បីដូច្នេះហើយបិទបាំងបាបកម្មនោះទុក ។ ព្រះមាន-ព្រះភាគត្រាស់ទុកយ៉ាងនេះថា ៖

"ម្នាលភិក្ខុទាំងឡាយ ដូចជាកុមារជាកូនខ្ចីនៅដេកផ្ងារនៅឡើយ ប៉ះពាល់រងើកភ្លើងដោយដៃក្តី ដោយជើងក្តី ក៏ដកមកវិញជាប្រញាប់ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ធម្មតារបស់បុគ្គលដែលប្រកបដោយទិដ្ឋិ គឺការចេញចាក អាបត្តិមានសភាពយ៉ាងណា ភិក្ខុក៏គង់ត្រូវអាបត្តិមានសភាពយ៉ាងនោះខ្លះដែរ តែថា ភិក្ខុនោះសម្តែង បើកធ្វើឱ្យច្បាស់ឡើងនូវអាបត្តិនោះ ក្នុងសំណាក់សាស្តា ឬក្នុងពួកសព្រហ្មចារី បុគ្គលជាអ្នកប្រាជ្ញដោយឆាប់រហ័ស លុះសម្តែងបើកធ្វើឱ្យច្បាស់ហើយ ក៏ដល់នូវកិរិយាសង្រួមតទៅ យ៉ាងនេះដែរ"[១] ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈ ដោយគុណរបស់ព្រះសោតាបន្នសូម្បីនៅដោយប្រមាទ តែក៏ដល់ព្រមដោយទស្សនៈមិនមានការបិទបាំងបាបកម្មដែលធ្វើហើយយ៉ាងនេះឡើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណ

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២២ ទំព័រ ៣៥៦ ។

នោះនុ៎ះឯង ទើបទ្រង់ប្រកាសសច្ចវចនៈថា **ឥទម្បិ សង្ឃេ រតនំ បណីតំ** រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្ដម ។ សេចក្ដីរបស់សច្ចវចនៈនោះ គប្បីជ្រាបតាមន័យ ដែលពោលមកមុនហើយទាំងនោះ ។ ពួកអមនុស្សក្នុងសែនកោដិ-ចក្រវាឡ ក៏នាំគ្នាព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## វនប្បគុម្ពេតិ គាថាវណ្ណនា

## ពណ៌នាគាថា ថា វនប្បគុម្ពេ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំង ដោយប្រការនៃគុណនោះៗរបស់បុគ្គលទាំងឡាយ ដែលអាស្រ័យនៅក្នុងព្រះសង្ឃយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យព្រះបរិយត្តិធម៌ ដែលព្រះមានព្រះភាគកាលទ្រង់សម្ដែងគុណព្រះរតនៈត្រ័យ ក៏ទ្រង់សម្ដែងយ៉ាងសង្ខេបក្នុងទីនេះ និងទ្រង់សម្ដែងទុកពិស្ដារក្នុងទីដទៃ ទើបត្រាស់បន្ថែមសច្ចវចនៈ មានព្រះពុទ្ធរតនៈជាទីតាំងទៀតថា **វនប្បគុម្ពេ យថា ផុស្សិតគ្គេ** ។ ក្នុងសច្ចវចនៈនោះ គុម្ពឈើដែលកំណត់ដោយទីនៅប្រចាំ ទីជិត ឈ្មោះថា **វនៈ** ព្រៃ ។ គម្ពោតឈើដែលមានពន្លកល្អដោយឫសវិមស្រាយ សំបកមែកនិងស្លឹក ឈ្មោះថា **បគុម្ពៈ** ។ គម្ពោតឈើដែលមានពន្លកល្អរបស់ព្រៃ ឬក្នុងព្រៃ ឈ្មោះថា **វនប្បគុម្ពោ** ។ គម្ពោតឈើដែលមានពន្លកល្អក្នុងព្រៃទីនោះ លោកហៅថា **វនប្បគុម្ពេ** កាលបើដូច្នោះ ក៏ហៅបានថា **វនសណ្ឌៈ** ដងព្រៃ ដូចក្នុងប្រយោគជាដើមថា អត្ថិ

សវិតក្កសវិចារេ អត្ថិ អវិតក្កាវិចារមត្តេ សុខេ ទុក្ខេ ជីវេ ប្រែថា មានវិតក្កៈ មានវិចារៈក៏មាន មិនមានវិតក្កៈមានវិចារៈក៏មាន ជីវិតជាសុខ ជាទុក្ខ ។ ពាក្យថា យថា ជាពាក្យឧបមា ។ ត្រួយរបស់គម្ពោតឈើនោះលូតលាស់ហើយ ព្រោះហេតុនោះ គម្ពោតឈើនោះ ទើបឈ្មោះថា មានត្រួយលូតលាស់ ។ អធិប្បាយថា ផ្កាឈើ ដែលកើតដោយខ្លួនឯង ត្រង់មែកធំ មែកតូច គ្រប់មែក ។ ផ្កាឈើនោះ លោកពោលថា មានត្រួយលូតលាស់ហើយ តាមន័យដែលពោលមកហើយនោះឯង ។ បទថា គិម្ហានមាសេ បឋមស្មឹ គិម្ហេ សេចក្ដីថា ក្នុងខែមួយនៃខែក្នុងគិម្ហន្តរដូវ ៤ ខែ ។ បើនឹងសួរថា ក្នុងខែណា ។ ឆ្លើយថា ក្នុងគិម្ហន្តរដូវ ខែដើម អធិប្បាយថា ក្នុងខែចិត្រមាស (ខែទី៥) ។ មែនពិត ខែចិត្រមាសនោះ លោកហៅថា ខែដើមគិម្ហន្តរដូវ និងថាវស្សានរដូវទន់ៗ ។ ពាក្យក្រៅពីនោះ ប្រាកដច្បាស់ដោយអត្ថនៃបទទាំងនោះ ។

ចំណែកសេចក្ដីរួមក្នុងពាក្យនេះមានដូច្នេះថា គុម្ពឈើដែលពន្លកល្អមាននាម ហៅថា ជង្គត់ឈើ ត្រួយមែក មានផ្ការីកចម្រើន រមែងល្អហ្នត់ហ្នងយ៉ាងលើស ក្នុងព្រៃដែលរុក្ខជាតិដុះរាត់រាយដោយដើមឈើនានាប្រភេទក្នុងវស្សន្ត-រដូវទន់ៗ ដែលមានឈ្មោះថា ខែដើមគិម្ហន្តរដូវយ៉ាងណា ព្រះមានព្រះភាគ មិនមែនទ្រង់សម្ដែងព្រោះឃើញដល់លាភ មិនមែនទ្រង់សម្ដែងព្រោះឃើញដល់សក្ការៈជាដើម ប្រសិនបើតែជាព្រះហឫទ័យដែលប្រកបដោយព្រះមហាករុណា

ឱ្យទ្រង់ខ្នះខ្នែងតែម្យ៉ាង បានទ្រង់សម្តែងព្រះបរិយត្តិធម៌ដ៏ប្រសើរ ដែលឈ្មោះថា មានឧបមាដូចយ៉ាងនោះ ព្រោះល្អហ្មត់ហ្មងយ៉ាងក្រៃលែងដោយផ្កាឈើ គឺប្រភេទនៃអត្ថនានា មានខន្ធ និងអាយតនៈជាដើមក៏មាន មានសតិប្បដ្ឋាននិងសម្មប្បធានជាដើមក៏មាន មានសីលខន្ធ សមាធិខន្ធជាដើមក៏មាន ឈ្មោះថាឱ្យដល់ព្រះនិព្វាន ព្រោះសម្តែងមគ្គដែលឱ្យដល់ព្រះនិព្វាន ដើម្បីជាប្រយោជន៍យ៉ាងក្រៃលែងដល់សត្វទាំងឡាយ យ៉ាងនោះដូចគ្នា ចំណែកក្នុងពាក្យថា បរមំ ហិតាយ លោកចុះនិគ្គហិត ក៏ដើម្បីងាយស្រួលដល់ការចងគាថា ។ ចំណែកសេចក្តីមានដូច្នេះថា ទ្រង់សម្តែងដើម្បីប្រយោជន៍យ៉ាងក្រៃលែង គឺដើម្បីព្រះនិព្វាន ។

ព្រះមានព្រះភាគ កាលត្រាស់ព្រះបរិយត្តិធម៌ ដែលស្រដៀងគុម្ពឈើស្អាតក្នុងព្រៃ ត្រង់ត្រួយមែកចេញផ្ការីកចម្រើនយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យ ព្រះបរិយត្តិធម៌នោះនុ៎ះឯង ទើបទ្រង់ប្រកបសច្ចវចនៈ ដែលមានពុទ្ធរតនៈជាទីតាំងថា **ឥទម្បិ ពុទ្ធេ រតនំ បណីតំ** រតនៈ គឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ។ សេចក្តីនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោល មកមុនហើយនុ៎ះឯង ។ តែគប្បីប្រកបសេចក្តីតែម្យ៉ាងយ៉ាងនេះថា គុណជាតិ ពោលគឺព្រះបរិយត្តិធម៌មានប្រការតាមដែលពោលមកហើយ សូម្បីនេះក៏ជារតនៈដ៏

ប្រណីតក្នុងព្រះពុទ្ធ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាឡ ក៏នាំគ្នាព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## វរោ វរញ្ញូតិ គាថាវណ្ណនា

## ពណ៌នាគាថា ថា វរោ វរញ្ញូ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ ដែលមានពុទ្ធរតនៈជាទីតាំងដោយបរិយត្តិធម៌យ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ត្រាស់បន្ថែមដោយលោកុត្តរធម៌ថា វរោ វរញ្ញូ ។ ក្នុងពាក្យនោះ បទថា វរោ សេចក្តីថា ព្រះពុទ្ធអ្នកមានអធ្យាស្រ័យ បង្អោនចិត្តជឿដោយប្រណីតប្រាថ្នាថា "ឱហ្ន៎! សូម្បីតថាគតក៏មានសភាពដូច្នោះ" ។ ឬព្រះពុទ្ធ អ្នកប្រសើរខ្ពង់ខ្ពស់ ប្រសើរបំផុតព្រោះប្រកប ដោយព្រះគុណដ៏ប្រសើរ ។ បទថា វរញ្ញូ បានដល់ ព្រះអង្គជាអ្នកដឹងនូវព្រះនិព្វាន ។ មែនពិត ព្រះនិព្វាន ឈ្មោះថាប្រសើរ ព្រោះអត្ថថា ខ្ពង់ខ្ពស់ជាងធម៌ទាំងពួង ។ ក៏ព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ត្រាស់ដឹងច្បាស់ដល់ព្រះនិព្វាននោះ ត្រង់គល់ ពោធិព្រឹក្សដោយព្រះអង្គឯង ។ បទថា វរទោ សេចក្តីថា ប្រទានធម៌ដ៏ប្រសើរ ដែលជាចំណែកត្រាស់ដឹង និងចំណែកដែលអប់រំសន្សំបារមីដល់សាវកទាំងឡាយ មានបញ្ចវគ្គិយ ភទ្ទវគ្គិយភិក្ខុ និងជដិលជាដើម និង

ដល់ទេវតានិង មនុស្សដទៃៗ ។ បទថា វរាហរោ ដែលលោកហៅថា វរាហរោ ព្រោះទ្រង់នាំមកនូវមគ្គដ៏ប្រណីត ។ មែនពិត ព្រះមានព្រះភាគអង្គនោះ ទ្រង់បំពេញបារមី ៣០ មកតាំងតែព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់នាំមកនូវមគ្គដ៏ប្រសើរ ជាធម៌បុរាណ ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយព្រះអង្គមុនៗ ទ្រង់ធ្វើមកហើយ ។ ព្រោះហេតុនោះ ព្រះអង្គទើបត្រូវហៅថា វរាហរោ អ្នកនាំមកនូវមគ្គដ៏ប្រសើរ ។

ម្យ៉ាងទៀត ព្រះពុទ្ធ ឈ្មោះថា វរោ អ្នកប្រសើរ ព្រោះទ្រង់បានព្រះសព្វញ្ញុតញ្ញាណ ។ ឈ្មោះថា វរញ្ញូ អ្នកដឹងធម៌ដ៏ប្រសើរ ព្រោះទ្រង់ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ឈ្មោះថា វរទោ អ្នកប្រទានធម៌ដ៏ប្រសើរ ព្រោះប្រទានវិមុត្តិសុខដល់សត្វទាំងឡាយ ឈ្មោះថា វរាហរោ អ្នកនាំមកដល់មគ្គដ៏ប្រសើរ ព្រោះទ្រង់នាំមកនូវបដិបទាខ្ពង់ខ្ពស់ ឈ្មោះថា អនុត្តរោ សម្បូរបែប ព្រោះមិនមានគុណអ្វីៗ ដែលក្រៃលែងជាងលោកុត្តរគុណទាំងនោះ ។

មានន័យដទៃទៀតថា ឈ្មោះថា វរោ ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋានធម៌គឺ ឧបសមៈ សេចក្តីស្ងប់រម្ងាប់ ។ ឈ្មោះថា វរញ្ញូ ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋាន គឺបញ្ញាសេចក្តីយល់ដឹង ។ ឈ្មោះថា វរទោ ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋានធម៌គឺ ចាគៈ សេចក្តីលះបង់ ។ ឈ្មោះថា វរាហរោ ព្រោះទ្រង់

បរិបូណ៌ដោយអធិដ្ឋានធម៌ គឺសច្ចៈ សេចក្ដីពិតត្រង់ ។ ទ្រង់នាំមកដល់មគ្គសច្ចៈប្រសើរ ។ ម្យ៉ាងទៀត ឈ្មោះថា វរោ ព្រោះទ្រង់អាស្រ័យបុណ្យ ឈ្មោះថា វរញ្ញូ ក៏ព្រោះទ្រង់អាស្រ័យបុណ្យដែរ ឈ្មោះថា វរទោ ព្រោះទ្រង់ដាក់ឧបាយនៃបុណ្យនោះដល់អ្នកត្រូវការជាព្រះពុទ្ធ ។ ឈ្មោះថា វរាហរោ ព្រោះទ្រង់នាំមកនូវឧបាយនៃបុណ្យនោះ ដល់អ្នកត្រូវការភាពជាព្រះបច្ចេកពុទ្ធ ។ ឈ្មោះថា អនុត្តរោ ព្រោះមិនមានអ្នកស្មើក្នុងធម៌នោះៗ ឬព្រោះជាអ្នកមិនមានអាចារ្យ តែត្រឡប់ជាអាចារ្យរបស់មនុស្សដទៃៗ ដោយព្រះអង្គឯង បានទ្រង់សម្ដែងធម៌ដ៏ប្រសើរ ព្រោះទ្រង់សម្ដែងធម៌ដ៏ប្រសើរ ដែលប្រកបដោយគុណមានធម៌ ដែលត្រាស់ល្អហើយជាដើម ដើម្បីផលនោះ អ្នកត្រូវការភាពជាសាវក ។ ពាក្យដ៏សេសមានន័យ ដូចដែលពោលមកហើយយ៉ាងនោះឯង ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់ព្រះអង្គដោយលោកុត្តរធម៌ ៩ ប្រការយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះនុ៎ះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា ឥទម្បិ ពុទ្ធេ ជាដើម សេចក្ដីរបស់សច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលមកមុនហើយនុ៎ះឯង ។ តែគប្បីប្រកបសេចក្ដីតែម្យ៉ាងយ៉ាងនេះថា ព្រះពុទ្ធ ព្រះអង្គនោះបានត្រាស់ដឹងលោកុត្តរធម៌ដ៏ប្រសើរផង បានប្រទានលោកុត្តរធម៌ផង បាននាំមកនូវលោកុត្តរធម៌ផង សំដែងនូវលោកុត្តរធម៌

*ផង ព្រោះដូច្នោះ រតនៈគឺព្រះពុទ្ធនេះ ជារតនៈដ៏ប្រសើរ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាឡក៏នាំគ្នាព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថា នេះឯង ។*

**ខីណន្តិ គាថាវណ្ណនា**

**ពណ៌នាគាថា ថា ខីណំ**

*ព្រះមានព្រះភាគ ទ្រង់អាស្រ័យបរិយត្តិធម៌ និងលោកុត្តរធម៌ ហើយត្រាស់សច្ចវចនៈ មានពុទ្ធរតនៈជាទីតាំង ដោយពីរគាថាយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណ គឺការសម្រេចអនុបាទិសេសនិព្វានរបស់សាវកទាំងឡាយ ដែលបានស្តាប់ព្រះបរិយត្តិធម៌នោះ និងបដិបត្តិតាមលំអានដែលបានស្តាប់មកហើយ បានសម្រេចលោកុត្តរធម៌ទាំង ៩ ប្រការ ទើបទ្រង់ត្រាស់បន្ថែមសច្ចវចនៈ មានសង្ឃរតនៈ ជាទីតាំងទៀតថា* **ខីណំ** *បុរាណំ ។ ក្នុងសច្ចវចនៈនោះ បទថា* **ខីណំ** *បានដល់ ការដាច់ស្រឡះ ។ បទថា បុរាណំ ប្រែថា ចាស់ ។ បទថា នវំ បានដល់ កម្មថ្មី ដែលកំពុងប្រព្រឹត្តទៅ គឺបច្ចុប្បន្ន ។ បទថា នត្ថិ សម្ភវំ បានដល់ សេចក្តីប្រាកដ(កើត) មិនមាន ។ បទថា វិរត្តចិត្តា បានដល់ មានចិត្តប្រាសចាករាគៈ ។ បទថា អាយតិកេ ភវស្មឹ បានដល់ ក្នុងភពថ្មី ក្នុងអនាគតកាល ។ បទថា តេ បានដល់ ភិក្ខុជាខីណាស្រពដែលអស់ទៅនូវកម្មក្នុងភពចាស់ មិនមានកម្មក្នុងភពថ្មី និងជាអ្នកមានចិត្តប្រាសសចាករាគៈ ។ បទថា* **ខីណាពីជា** *បានដល់*

អ្នកមានពូជដកចេញហើយ ។ បទថា អវិរុឡ្ហិឆន្ទា បានដល់ អ្នកវៀរចាកឆន្ទៈដែលដុះបាន ។ បទថា និព្វន្តិ បានដល់ អស់ទៅ ។ បទថា ធីរា បានដល់ អ្នកដល់ព្រមដោយបញ្ញាឈ្មោះ ធិតិ ។ បទថា យថាយម្បទីបោ ប្រែថា ដូចប្រទីបនេះ ។

លោកអធិប្បាយទុកយ៉ាងណា ។ លោកអធិប្បាយទុកថា កម្មនោះណារបស់សត្វទាំងឡាយកើតហើយរលត់ទៅ ជាកម្មចាស់ ជាអតីតកាល រមែងនៅមិនអស់ទៅ ព្រោះអាចនាំមកនូវការបដិសន្ធិ ព្រោះលះសិនេហៈគឺតណ្ហាទៅមិនបាន កម្មចាស់នោះរបស់ភិក្ខុជាខីណាស្រពពួកណា ឈ្មោះថាអស់ទៅ ក៏ព្រោះមិនអាចឱ្យវិបាកតទៅ ដូចពូជដែលភ្លើងឆេះហើយ ព្រោះសិនេហៈ គឺតណ្ហារីងស្ងួតទៅដោយព្រះអរហត្តមគ្គ ។ កម្មណារបស់ភិក្ខុជាខីណាស្រពពួកណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ដោយអំណាចពុទ្ធបូជាជាដើម ហៅថា កម្មថ្មី ។ ក៏កម្មថ្មីនោះ របស់ភិក្ខុជាខីណាស្រពពួកណា មិនបន្តភពបាន ព្រោះមិនអាចឱ្យផលបន្តទៅ ដូចផ្ការបស់ដើមឈើដែលមានឫសដាច់ហើយ ព្រោះលះតណ្ហាបាននោះឯង ។ ម្យ៉ាងទៀត ភិក្ខុជាខីណាស្រពពួកណាមានចិត្តណាយហើយក្នុងភពតទៅ ព្រោះលះតណ្ហាបានទុំះឯង ភិក្ខុជាខីណាស្រពពួកនោះ ឈ្មោះថាមានពូជអស់ហើយព្រោះបដិសន្ធិវិញ្ញាណ ដែលលោកពោលទុកក្នុងពាក្យថា កម្មគឺស្រែ វិញ្ញាណ

*គឺពូជអស់ទៅ ព្រោះអស់កម្មនុ៎ះឯង ។ ឆន្ទៈសូម្បីយ៉ាងណា របស់ការកើត ពេលគឺភពថ្មី បានមានមកហើយអំពីកាលមុន ។ ភិក្ខុ ជាខីណាស្រពទាំងឡាយ ឈ្មោះថា មានឆន្ទៈមិនដុះ ព្រោះមិនកើតក្នុងចុតិកាល ដូចកាលមុន ព្រោះឆន្ទៈ សូម្បីយ៉ាងនោះ លះបានហើយ ព្រោះលះសមុទយៈនុ៎ះឯង ឈ្មោះថា អ្នកប្រាជ្ញ ព្រោះដល់ព្រមដោយធិតិ(បញ្ញា) រមែងរលត់ ដូចប្រទីបនេះ រលត់ទៅដូច្នោះ ព្រោះចរិមវិញ្ញាណរលត់ទៅ[1] រមែងកន្លងផ្លូវនៃបញ្ញត្តជាដើមយ៉ាងនេះថាមានរូបឬ*

---

១- ចរិមវិញ្ញាណស្ស និរោធេនាតិ ឯត្ថ អស្សាសបស្សាសានំ និរោធវសេន ។ តយោ ចរិមា ភវចរិមោ ឈានចរិមោ ចុតិចរិមោតិ ។ ភវេសុ ហិ កាមភវេ អស្សាសបស្សាសា បវត្តន្តិ រូបារូបភវេសុ នប្បវត្តន្តិ ។ តស្មា សោ ភវចរិមោ ។ ឈានេសុ បុរិមឈានត្តយេវ បវត្តន្តិ ចតុត្ថេ នប្បវត្តន្តិ ។ តស្មា សោ ឈានចរិមោ ។ យេ បន ចុតិចិត្តស្ស បុរតោ សោឡសមេន ចិត្តេន សហុប្បន្នា តេ ចុតិចិត្តេន សហ និរុជ្ឈន្តិ ។ សោ ចុតិចរិមោ នាម ។ អយំ ឥធ ចរិមោតិ អធិប្បេតោ ។ យេ ហិ កេចិ ពុទ្ធា វា បច្ចេកពុទ្ធា វា អរិយសាវកា វា អន្តមសោ កុន្ថកិបិល្លិកំ ឧចាទាយ សព្វេ ភវង្គចិត្តេនេវ អព្យាកតេន ទុក្ខសច្ចេន កាលំ ករោន្តិ ។ តស្មា ចរិមវិញ្ញាណស្ស និរោធេនាតិ ចុតិចិត្តស្ស និរោធេនាតិ អត្ថោ ។ *គប្បីជ្រាបសេចក្តីវិនិច្ឆ័យក្នុងបទថា* ចរិមវិញ្ញាណស្ស និរោធេន *នេះដូចតទៅ ដោយអំណាចការរំលត់នូវអស្សាស-បស្សាសៈ ឈ្មោះថារំលត់នូវចរិមវិញ្ញាណ ។ ចរិមៈ មានបីយ៉ាង គឺ ភវចរិមៈ ឈានចរិមៈ ចុតិចរិមៈ ។ មែនពិត បណ្តាភពទាំងឡាយ អស្សាសបស្សាស រមែងប្រព្រឹត្តទៅក្នុងកាមភព មិនប្រព្រឹត្តទៅក្នុងរូបភព និងអរូបភពឡើយ ។ ព្រោះដូច្នោះ ចរិមនោះ ឈ្មោះថា ភវចរិមៈ ។ បណ្តា*

មិនមានរូបទៀត ។ បានឮថា បណ្ដាប្រទីបច្រើនដើម ដែលគេដុតទុក ដើម្បីបូជាទេវតាប្រចាំក្រុង ក្នុងសម័យនោះប្រទីបមួយដើមរលត់ទៅហើយ ព្រះមានព្រះភាគកាលទ្រង់ចង្អុលប្រទីបដើមនោះ ទើបត្រាស់ថា យថាយម្បទីបោ ដូចប្រទីបនេះ ។

ព្រះមានព្រះភាគ កាលត្រាស់គុណ គឺការសម្រេចអនុបាទិសេសនិព្វានរបស់ព្រះខីណាស្រព ដែលស្ដាប់បរិយត្តិធម៌ ដែលត្រាស់ដោយ ២ គាថាមុននោះ ទាំងបដិបត្តិតាមលម្អានបរិយត្តិធម៌ដែលស្ដាប់ហើយ សម្រេចលោកុត្តរ-ធម៌ទាំង ៩ ប្រការ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះនុ៎ះឯង

---

ឈានទាំងឡាយ អស្សាសបស្សាសៈ រមែងប្រព្រឹត្តទៅក្នុងឈានបីខាងដើម មិនប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈានឡើយ ។ ព្រោះហេតុនោះ ចរិមៈនោះ ឈ្មោះថា ឈានចរិមៈ ។ មួយវិញទៀត ធម៌ឯណាកើតព្រមជាមួយនឹងចិត្តទី ១៦ មុនចុតិចិត្ត ធម៌នោះរមែងរលត់ជាមួយនឹង ចុតិចិត្ត ។ ចរិមៈនោះឈ្មោះថា ចុតិចរិមៈ ។ ក្នុងទីនេះ ព្រះមានព្រះភាពព្រះអង្គបំណងយកចុតិចរិមៈ ។ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរិយសាវកទាំងឡាយ ដោយហោចទៅសូម្បីស្រមោចខ្មៅស្រមោចក្រហមទាំងអស់ រមែងធ្វើកាលកិរយា ដោយភវង្គចិត្តនុ៎ះឯង ដែលជាអព្យាក្រឹត ជាទុក្ខសច្ចៈសូម្បីទាំងអស់ ។ ព្រោះដូច្នោះ បទថា **ចរិមវិញ្ញាណស្ស និរោធេន** គឺកិរិយារំលត់ចុតិចិត្ត ។ គម្ពីរ **សទ្ធម្មប្បជ្ជោតិកា** អដ្ឋកថា ចូឡនិទ្ទេស នៃគម្ពីរខុទ្ទកនិកាយ ត្រង់អជិតមាណវសុត្តវណ្ណនា ក្នុងបារាយនវគ្គនិទ្ទេស ។ ក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ ចូឡនិទ្ទេស លេខ ៦៧ ទំព័រ ៣៤ លោកប្រើពាក្យថា **បុរិមវិញ្ញាណស្ស និរោធេន** ប្រែថា ព្រោះថាកិរិយារំលត់វិញ្ញាណមុន ។

សម្រាប់ជាធម្មទាន

កាលទ្រង់ប្រកបសច្ចវចនៈ មានសង្ឃរតនៈជាទីតាំង ទើបទ្រង់បញ្ចប់ទេសនាថា ឥធម្បិ សង្ឃេ ជាដើម សេចក្ដីរបស់សច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលមកមុនហើយនុ៎ះឯង ។ តែគប្បីប្រកបសេចក្ដីតែម្យ៉ាងយ៉ាងនេះថា គុណពោល គឺព្រះនិព្វានដ៏ប្រណីតរបស់ភិក្ខុជាខីណាស្រព ដោយប្រការតាម ដែលពោលមកហើយ សូម្បីយ៉ាងនេះក៏ជារតនៈដ៏ប្រណីតក្នុងព្រះសង្ឃ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាឡ ក៏នាំគ្នាព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

ក្នុងកាលជាទីបញ្ចប់នៃទេសនា សេចក្ដីសួស្ដីក៏បានមានដល់រាជត្រកូល ។ ឧបទ្រវៈទាំងពួងក៏ រម្ងាប់ទៅ សត្វ ៨៤០០០ ក៏បានត្រាស់ដឹងធម៌ ។

## យានីធាតិគាថាត្តយវណ្ណនា

### **ពណ៌នា ៣ គាថា ថា យានីធ ជាដើម**

គ្រានោះ ស្ដេចសក្កទេវរាជ ទ្រង់ព្រះតម្រិះថា ព្រះមានព្រះភាគទ្រង់អាស្រ័យគុណព្រះរតនត្រ័យ ប្រកបសច្ចវចនៈ ទ្រង់ធ្វើសិរីសួស្ដីដល់អ្នកនគរ សូម្បីយើងក៏គប្បីពោលអ្វីម្យ៉ាង អាស្រ័យគុណព្រះរតនត្រ័យ ដើម្បីសិរីសួស្ដីដល់អ្នកនគរ ដូច្នេះហើយទើបត្រាស់ ៣ គាថាចុងថា យានីធ ភូតានិ ជាដើម ។ បណ្ដា ៣ គាថានោះ ព្រោះហេតុដែលព្រះពុទ្ធ លោកហៅថាតថាគត ព្រោះស្ដេច

មកត្រង់មនុស្សទាំងឡាយៗ ត្រូវខ្វល់ខ្វាយនាំគ្នាមកដើម្បីប្រយោជន៍ទំនុកបម្រុងព្រះអង្គ ព្រោះស្ដេចទៅកន្លែងមនុស្សទាំងនោះ និងគប្បីទៅ ព្រោះទ្រង់ដឹងទូទៅដល់មនុស្សទាំងនោះ និងគប្បីដឹងទូទៅ ព្រោះទ្រង់ដឹងដល់មនុស្សទាំងនោះ និងគប្បីដឹង ព្រោះទ្រង់ជួបវត្ថុដែលមានយ៉ាងនោះ ។ ម្យ៉ាងទៀត ព្រោះហេតុតែព្រះពុទ្ធអង្គនោះ គឺទេវតា និងមនុស្សទាំងឡាយបូជាដ៏ប្រសើរ ដោយផ្កាឈើ និងគ្រឿងក្រអូបជាដើម ដែលកើតខាងក្រៅជាឧបករណ៍ និងកើតក្នុងខ្លួន មានការបដិបត្តិធម៌សមគួរដល់ធម៌ជាដើមដូច្នោះ ។ សក្កទេវរាជ ទ្រង់ប្រមូលទេវបរិស័ទទាំងអស់ជាមួយព្រះអង្គ ហើយត្រាស់ថា តថាគតំ ទេវមនុស្សបូជិតំ ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ សូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់មកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមមានសិរីសួស្ដី ។

ម្យ៉ាងទៀត ព្រោះហេតុដែលក្នុងព្រះធម៌ មគ្គធម៌ចាប់ផ្ដើមទៅហើយជាទីពឹងចាប់ផ្ដើមទៅ ដោយការដកចំណែកកិលេស ដោយកម្លាំងសមថវិបស្សនា ដែលជាធម៌គូគ្នា ។ សូម្បីនិព្វានធម៌ដែលព្រះពុទ្ធជាដើម ទ្រង់សម្រេចហើយ គឺចាក់ធ្លុះហើយដោយបញ្ញា ព្រមដោយការកម្ចាត់ទុក្ខទាំងឡាយដូច្នោះ លោកទើបហៅថា តថាគត ។ ម្យ៉ាងទៀត ព្រោះហេតុដែលសូម្បីព្រះសង្ឃចាប់ផ្ដើមទៅហើយ ជាអ្នកបដិបត្តិដើម្បីប្រយោជន៍ដល់ខ្លួន គប្បីទៅដោយមគ្គនោះៗ ព្រោះហេតុនោះ

លោកទើបហៅ តថាគត ។ ដូច្នោះ សូម្បី ក្នុង ២ គាថាដ៏សេស ស្តេចសក្កទេវរាជ ទើបពោលថា ពួកយើងគោរព**តថាគតធម៌** សូមសិរីសួស្តីចូរមាន ពួកយើង គោរព**តថាគតសង្ឃ** សូមសិរីសួស្តីចូរមានដូច្នេះ ។ ពាក្យដ៏សេសមានន័យ ដូច ពោលមកហើយទាំងនោះ ។

ស្តេចសក្កទេវរាជត្រាត្រាស់ ៣ គាថានោះ យ៉ាងនេះហើយ ទ្រង់ធ្វើ ប្រទក្សិណ ព្រះមានព្រះភាគស្តេចត្រឡប់ទៅកាន់ទេវបុរី ព្រមដោយទេវបរិស័ទ ។ ចំណែកព្រះមានព្រះភាគទ្រង់សម្តែងរតនសូត្រនោះនុ៎ះឯង សូម្បីក្នុងថ្ងៃទី ២ សត្វ ៨៤.០០០ ក៏បានត្រាស់ដឹងធម៌ ។ ទ្រង់សម្តែងយ៉ាងនេះដល់ថ្ងៃទី ៧ ។ ការ ត្រាស់ដឹងធម៌ក៏មានតាមលំដាប់យ៉ាងនោះនុ៎ះឯង គ្រប់ៗ ថ្ងៃ ។ ព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងក្រុងវេសាលីកន្លះខែហើយ ទើបទ្រង់ប្រាប់ដល់ពួកស្តេច លិច្ឆវីថា នឹងត្រឡប់វិញ ។ តពីនោះ ពួកស្តេចលិច្ឆវីក៏នាំព្រះមានព្រះភាគ យាង ទៅកាន់ច្រាំងស្ទឹងគង្គា ដោយសក្ការៈជាទ្វេគុណទៀតអស់រយៈពេល ៣ ថ្ងៃ ។ ពួកស្តេចនាគដែលកើតនៅ ក្នុងស្ទឹងគង្គា គិតគ្នាថា ពួកមនុស្សធ្វើសក្ការៈដល់ ព្រះតថាគត ពួកយើងនឹងមិនធ្វើ ការបូជាខ្លះឬ ទើបសាងទូកយ៉ាងច្រើន ដែល សម្រេចអំពីមាសប្រាក់ និងកែវមណី បល្ល័ង្កធ្វើដោយមាស ប្រាក់ និងកែវមណី ធ្វើទឹកឱ្យគ្របដណ្តប់ដោយឈូក ៥ ពណ៌ ទូលអង្វរសូមព្រះមានព្រះភាគជា

ម្ចាស់ថា សូមព្រះអង្គទ្រង់ធ្វើសេចក្ដីអនុគ្រោះ ដល់ពួកខ្ញុំព្រះអង្គផងចុះ ។ ព្រះមានព្រះភាគទ្រង់ទទួល ស្ដេចយាងឡើងកាន់ទូកកែវ ចំណែកភិក្ខុ ៥០០ រូប ក៏ឡើងកាន់ទូករបស់ខ្លួនៗ ។ ពួកស្ដេចនាគ នាំព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃចូលទៅកាន់ពិភពនាគ ។ បានឮថា ក្នុងទីនោះ ព្រះមានព្រះភាគទ្រង់សម្ដែងធម៌ដល់នាគបរិស័ទរហូតមួយយប់ ។ ថ្ងៃទី ២ ពួកស្ដេចនាគនាំគ្នាថ្វាយមហាទានដោយខាទនីយភោជនីយាហារជាទិព្វ ។ ព្រះមានព្រះភាគទ្រង់អនុមោទនា ហើយស្ដេចចេញចាកពិភពនាគ ។

ពួកភុម្មទេវតា នាំគ្នាគិតថាពួកមនុស្ស និងនាគនាំគ្នាធ្វើសក្ការៈដល់ព្រះតថាគតពួកយើងនឹងមិនធ្វើការបូជាខ្វះឬ ទើបជួយគ្នាយកឆ័ត្រធំតូច ត្រង់ទីមានគុម្ពឈើ ដងព្រៃ ដើមឈើ និងភ្នំ ។ ដោយឧបាយនោះនុ៎ះឯង សក្ការៈវិសេសដ៏ធំក៏កើតឡើងដរាបដល់ភពរបស់អកនិដ្ឋព្រហ្ម ។ សូម្បីព្រះបាទពិម្ពិសារ ក៏ទ្រង់បានធ្វើជាទ្វេគុណជាងសក្ការៈ ដែលពួកស្ដេចលិច្ឆវីទ្រង់ធ្វើ ។ កាលដែលព្រះមានព្រះភាគស្ដេចយាងមក ព្រះបាទពិម្ពិសារទ្រង់នាំព្រះមានព្រះភាគមកដល់ក្រុងរាជគ្រឹះ អស់រយៈពេល ៥ ថ្ងៃ ដោយន័យដូចដែលពោលមកអំពីមុនហើយ ។

ព្រះមានព្រះភាគ ស្ដេចយាងដល់ក្រុងរាជគ្រឹះហើយ ខាងក្រោយភត្ត ពួកភិក្ខុ ដែលអង្គុយប្រជុំគ្នាក្នុងមណ្ឌលសាលា និយាយគ្នានិងគ្នាយ៉ាងនេះថា ឱហ្ន៎!

អានុភាពរបស់ព្រះមានព្រះភាគ ដែលភូមិភាគ ៨ យោជន៍ ទាំងប្រាំងក្នុងទាំងប្រាំង ក្រៅនៃស្ទឹងគង្គា ត្រូវធ្លោះតម្រង់កែតម្រូវទីទាបទីខ្ពស់ឱ្យរាបហើយ រោយខ្សាច់ គ្របដណ្តប់ដោយផ្កាឈើទាំងឡាយ ស្ទឹងគង្គាប្រមាណមួយយោជន៍ក៏ត្រូវគ្រប- ដណ្តប់ដោយឈូកពណ៌ផ្សេងៗ ឆត្រធំតូចត្រូវលើកឡើងដរាបដល់កពរបស់ អកនិដ្ឋព្រហ្ម ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបរឿងនោះហើយ យាងចេញចាក ព្រះគន្ធកុដិ ស្តេចទៅកាន់មណ្ឌលសាលា ដោយបាដិហារិយៈ តាមសមគួរដល់ ខណៈនោះ ប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរដែលគេតាក់តែងទុកក្នុងមណ្ឌល- សាលា។ កាលប្រថាប់គង់ហើយ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា "ម្នាលភិក្ខុទាំងឡាយ កាលអម្បាញ់មិញ អ្នកទាំងឡាយអង្គុយប្រជុំគ្នានិយាយ រឿងអ្វី" ។ ភិក្ខុទាំងឡាយក៏ក្រាបទូលរឿងទាំងអស់ ។ ព្រះមានព្រះភាគ បាន ត្រាស់ដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ ការបូជាវិសេសនេះ មិនបានកើតឡើង ព្រោះពុទ្ធានុភាពរបស់តថាគត ទាំងមិនមែនព្រោះអានុភាពរបស់នាគ ទេវតា និង ព្រហ្មទេ តាមពិត កើតឡើង ព្រោះអានុភាពរបស់ការបរិច្ចាគមានប្រមាណតិច អំពីមុន" ។ ពួកភិក្ខុទើបក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គ មិន ដឹងការបរិច្ចាគមាន ប្រមាណតិចនោះ សូមព្រះមានព្រះភាគមេត្តាត្រាស់ប្រាប់ ពួកខ្ញុំព្រះអង្គ ដែលពួកខ្ញុំព្រះអង្គ នឹងដឹងការបរិច្ចាគមានប្រមាណតិចនោះ

ផងចុះ” ។ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមក ហើយក្នុងនគរតក្កសិលា មានព្រាហ្មណ៍ម្នាក់ឈ្មោះ សង្ខ: ។ គាត់មានបុត្រ ឈ្មោះ សុសីមមាណព ។ មាណពនោះ អាយុ ១៦ ឆ្នាំដោយវ័យ ថ្ងៃមួយចូល ទៅរកបិតាហើយ ឈរក្នុងទីដ៏សមគួរ ។ បិតាសួរគេថា នែបាសុសីម:! (អ្នកគិត) អ្វី ។ សុសីម:ឆ្លើយថា កូនប្រាថ្នាទៅក្រុងពារាណសីដើម្បីរៀនសិល្ប: ។ ព្រាហ្មណ៍ ពោលថា បាសុសីម: បើយ៉ាងនោះ ពុកមានសម្លាញ់ជាព្រាហ្មណ៍ ឈ្មោះឯណោះ បាចូរទៅរកគេឱ្យបង្រៀនចុះ ហើយប្រគល់ទ្រព្យឱ្យមួយពាន់ កហាបណ: ។ សុសីមមាណពនោះ ទទួលទ្រព្យហើយក៏ថ្វាយបង្គំមាតាបិតា ដើរផ្លូវទៅក្រុងពារាណសីដោយលំដាប់ ចូលទៅរកអាចារ្យ ដោយវិធីជាគ្រឿង ចូលទៅជិត ។ សុសីម:បានប្រកាសខ្លួន ឱ្យអាចារ្យដឹងថាជាកូនរបស់សម្លាញ់ៗ ក៏ទទួលយកមាណពទុក បានធ្វើការទទួលយ៉ាងល្អគ្រប់យ៉ាង ។ មាណពនោះ មានសេចក្តីនឿយហត់ក្នុងការដើរផ្លូវឆ្ងាយហើយ ក៏ដាក់កហាបណ:នោះ ទៀប ជើងអាចារ្យ សូមឱកាសរៀនសិល្ប: ។ អាចារ្យក៏បើកឱកាសបង្រៀន គេរៀន បានរហ័សនិងរៀនបានច្រើន ទាំងទ្រទ្រង់ចាំសិល្ប:ដែលទទួលទុក បានមិនសាប សូន្យ ដូចប្រេងដែលដាក់ចុះក្នុងភាជន:មាស គេរៀនសិល្ប:ដែលគួររៀនរៀន ដល់ ១២ ឆ្នាំ ប៉ុន្តែមាណពរៀនឱ្យសម្រេចត្រឹមតែ ២-៣ ខែប៉ុណ្ណោះ ។ មាណព នោះ ស្វាធ្យាយឃើញតែខាងដើម និងកណ្តាលប៉ុណ្ណោះ មិនឃើញនូវទីបំផុត

ទើបចូលទៅរកអាចារ្យសួរថា លោកអាចារ្យ ខ្ញុំឃើញតែខាងដើម និងកណ្តាលរបស់សិល្បៈនេះប៉ុណ្ណោះ មិនឃើញនូវទីបំផុតឡើយ ។ អាចារ្យក៏ពោលថា យើងក៏ឃើញយ៉ាងនោះដូចគ្នា ។ គេទើបសួរថា លោកអាចារ្យ កាលបើដូច្នោះ នរណាដឹងនូវទីបំផុតរបស់សិល្បៈនេះ ។ អាចារ្យពោលថា បាអើយ ឯព្រៃឥសិបតនៈ មានឥសីច្រើនអង្គ ឥសីទាំងនោះគង់តែដឹង ។ គេប្រាប់ថា អាចារ្យ ខ្ញុំនឹងចូលទៅសួរឥសីទាំងនោះដោយខ្លួនឯង ។ អាចារ្យប្រាប់ថា ទៅសួរតាមសប្បាយចុះ បាអើយ ។ គេក៏ទៅកាន់ព្រៃឥសិបតនៈ ចូលទៅរកព្រះបច្ចេកពុទ្ធទាំងឡាយ សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ដឹងនូវទីបំផុតនៃសិល្បៈខ្លះទេ ។ ព្រះបច្ចេកពុទ្ធពោលថា នែអាវុសោ អាត្មាដឹង ។ មាណពអង្វរថា លោកម្ចាស់ មេត្តាបង្រៀននូវទីបំផុតនៃសិល្បៈនេះខ្ញុំផង ។ ព្រះបច្ចេកពុទ្ធ ពោលថា បើដូច្នោះ អ្នកចូរបួសសិនចុះ បើមិនបួសមិនអាចរៀនបានផល ។ មាណពនោះ ទទួលពាក្យថាសាធុ សូមលោកម្ចាស់ មេត្តាបំបួសខ្ញុំចុះ ។ លោកម្ចាស់ប្រាថ្នាយ៉ាងណា សូមធ្វើយ៉ាងនោះចុះ ហើយញ៉ាំងខ្ញុំឱ្យដឹងនូវទីបំផុតនៃសិល្បៈ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ឱ្យមាណពបួសហើយ ក៏មិនអាចប្រកបលោកទុកក្នុងកម្មដ្ឋានបាន ឱ្យសិក្សានៅ ក្នុងអភិសមាចារដោយន័យជាដើមថា លោកគប្បីអន្ទុយយ៉ាងនេះ គប្បីដណ្តប់យ៉ាងនេះ ។ គេសិក្សានៅក្នុងសេចក្តីនោះ តែព្រោះ

ជាអ្នកដល់ព្រមដោយឧបនិស្ស័យ មិនយូរប៉ុន្មានក៏ត្រាស់ដឹងបច្ចេកពោធិញ្ញាណ ។ ព្រះបច្ចេកពុទ្ធអង្គនោះជាអ្នកដល់ព្រមដោយលាភ យស និងបរិវារ ក៏ប្រាកដនាមទូទាំងក្រុងពារាណសីថា សុសីមបច្ចេកពុទ្ធ ។ ត្រាស់ដឹងជាព្រះបច្ចេកពុទ្ធមិនយូរប៉ុន្មានលោកក៏បរិនិព្វាន ព្រោះធ្វើកម្មដែលជាហេតុឱ្យអាយុខ្លីទុក ។ ព្រះ-បច្ចេកពុទ្ធទាំងឡាយ និងពួកមហាជន ជួយគ្នាធ្វើឈាបនកិច្ចសរីរៈរបស់លោកទុកជាតុសាងព្រះស្តូបទុកជិតទ្វារព្រះនគរ ។

ចំណែកសង្ខព្រាហ្មណ៍គិតថា កូនរបស់យើងទៅតាំងពីយូរហើយ នៅមិនដឹងដំណឹងរបស់គេឡើយ បំណងនឹងជួបបុត្រ ទើបចេញចាកនគរតក្កសិលា ដើរផ្លូវ ទៅតាមលំដាប់ក៏ដល់ក្រុងពារាណសី ឃើញពួកមហាជនប្រជុំគ្នា គិតថាបណ្តាជនជាច្រើន សូម្បីត្រឹមតែម្នាក់ គង់នឹងដឹងដំណឹងកូនរបស់យើងពិតប្រាកដទើបចូលទៅកន្លែងប្រជុំជន សួរថា មាណពឈ្មោះសុសីមៈមកក្នុងទីនេះទេ ? លោកដឹងដំណឹងរបស់គេខ្លះឬទេ ? ជនទាំងនោះពោលថា នែព្រាហ្មណ៍ ពួកយើងដឹងលោករៀនចប់ត្រៃវេទ ក្នុងសម្នាក់ព្រាហ្មណ៍ក្នុងនគរនេះហើយ បួសក្នុងសម្នាក់របស់ព្រះបច្ចេកពុទ្ធទាំងឡាយ បានជាព្រះបច្ចេកពុទ្ធ បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុហើយ នេះព្រះស្តូប យើងសាងទុកសម្រាប់លោក ។ សង្ខព្រាហ្មណ៍នោះយកដៃគប់ផែនដី យំត្រង់លានចេតិយនោះ ដកស្មៅហើយ

យកសំពត់ជណ្តប់ខ្ចប់ខ្សាច់នាំទៅត្រង់ទីលានចេតិយព្រះបច្ចេកពុទ្ធ យកទឹកក្នុងក្អមទៅប្រោះព្រំ ធ្វើការបូជាដោយផ្កាឈើព្រៃ យកសំពត់ជណ្តប់លើកឡើងធ្វើជាទង់ ចងឆត្ររបស់ខ្លួនទុកលើស្តូបហើយចៀសចេញទៅ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងរឿងអតីតយ៉ាងនេះហើយ កាលទ្រង់បន្តជាតកនោះជាមួយនឹងបច្ចុប្បន្ន ទើបត្រាស់ធម៌ដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកលោកនឹងគប្បីមានការគិតថា អ្នកដទៃជាសង្ខព្រាហ្មណ៍ សម័យនោះពិតប្រាកដ តែពួកលោកមិនគប្បីឃើញយ៉ាងនេះ សម័យនោះ តថាគតជាសង្ខព្រាហ្មណ៍ តថាគតដកស្មៅត្រង់លានចេតិយរបស់ព្រះសុសីមបច្ចេកពុទ្ធ ដោយផលកម្មរបស់តថាគតនោះ ជនទាំងឡាយទើបធ្វើផ្លូវ ៨ យោជន៍ប្រាស-ចាកគល់ឈើ និងបន្លា ធ្វើផ្ទៃដីឱ្យរាបស្អាត តថាគតរោយខ្សាច់ត្រង់លានចេតិយព្រះសុសីមបច្ចេកពុទ្ធនោះ ដោយផលកម្មរបស់តថាគតនោះ ជនទាំងឡាយទើបរោយខ្សាច់ត្រង់ផ្លូវ ៨ យោជន៍ តថាគត ធ្វើការបូជាត្រង់ព្រះស្តូបនោះ ដោយផ្កាឈើព្រៃ ដោយផលកម្មរបស់តថាគតនោះ ជនទាំងឡាយទើបបានធ្វើគ្រឿងក្រាលផ្កាឈើដោយផ្កាឈើព្រៃនានា ទាំងលើគោក ទាំងក្នុងទឹក ក្នុងផ្លូវ ៩ យោជន៍ តថាគតប្រោះព្រំផ្ទៃដីដោយទឹកក្នុងក្អមទឹកត្រង់ព្រះសថូបនោះ ដោយផលកម្មរបស់តថាគតនោះ ភ្លៀងបោក្ខរព័ស្សទើបធ្លាក់ចុះត្រង់ក្រុងវេសាលី តថាគតលើកទង់ផែនសំពត់ និងចងឆត្រត្រង់ព្រះចេតិយនោះ ដោយផលកម្មរបស់តថាគតនោះ ជនទាំងឡាយទើបលើកទង់ផែនសំពត់ និងឆត្រធំតូច រហូតដល់ភពអកនិដ្ឋ ។ ម្នាលភិក្ខុទាំងឡាយ ដូច្នោះ ការបូជាវិសេសនេះ មិនមែនកើតឡើង

*ព្រោះពុទ្ធានុភាពរបស់តថាគត មិនមែនព្រោះអានុភាពរបស់នាគ ទេវតា និងព្រហ្មពិតណាស់ កើតឡើងព្រោះអានុភាពរបស់ការបរិច្ចាគមានប្រមាណតិចប៉ុណ្ណោះ ។ ចប់ធម្មកថាបានត្រាស់ព្រះគាថានេះថា ៖*

“មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ
ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ[១] ។
*បើឃើញសេចក្ដីសុខដ៏ធំទូលាយ ព្រោះលះបង់សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញសុខធំទូលាយ គប្បីលះសុខល្មមប្រមាណចេញ*”[២] ។

បរមត្ថជោតិកាយ ខុទ្ទកបាឋដ្ឋកថាយ

រតនសុត្តវណ្ណនា និដ្ឋិតា ។

**ចប់អដ្ឋកថារតនសូត្រ**

**នៃ**

**អដ្ឋកថាខុទ្ទកបាឋ ឈ្មោះ បរមត្ថជោតិកា ៥**

---

*១-វិបុលំ សុខន្តិ ឱឡារំ សុខំ និព្វានសុខំ វុច្ចតិ តំ ចេ បស្សេយ្យាតិ អត្ថោ អធិប្បាយថា បទថា វិបុលំ សុខំ បានសេចក្ដីថា ព្រះមានព្រះភាពទ្រង់ត្រាស់នូវសុខ ដ៏ក្រៃលែង គឺនិព្វានសុខ ព្រោះដូច្នោះ បុគ្គលទាំងឡាយ គប្បីឃើញយ៉ាងនេះ ។ អដ្ឋកថា ធម្មបទ ឈ្មោះ ធម្មបទដ្ឋកថា ភាគ៧ ទំព័រ ១៤៧ ។*

*២-សុត្តន្តបិដក ខុទ្ទកនិកាយ គាថាធម្មបទ លេខ ៥២ ទំព័រ ៨១ ។*

### ៧-តិរោកុឌ្ឌសុត្តវណ្ណនា

### **ពណ៌នាតិរោកុឌ្ឌសូត្រ**

### និក្ខេបប្បយោជនំ

### **ប្រយោជន៍នៃការតាំងព្រះសូត្រ**

ឥឡូវនេះ ដល់លំដាប់ការពណ៌នាសេចក្ដីនៃតិរោកុឌ្ឌសូត្រ ដែលកើតឡើងជាលំដាប់អំពីរតនសូត្រដោយន័យថា តិរោកុឌ្ឌេសុ តិដ្ឋន្តិ ជាដើម នឹងពោលប្រយោជន៍នៃការតាំងតិរោកុឌ្ឌសូត្រនោះទុកក្នុងទីនេះ ហើយទើបពណ៌នាសេចក្ដី ។

ក្នុងសេចក្ដីនោះ ការពិតតិរោកុឌ្ឌសូត្រនេះ សូម្បីព្រះមានព្រះភាគក៏មិនត្រាស់តាមលំដាប់នេះ ប៉ុន្តែក៏ទ្រង់សម្ដែងការបដិបត្តិកុសលកម្មនេះ បានដោយប្រការផ្សេងៗទុកមុន ព្រះសូត្រនេះ ព្រោះហេតុដែលបុគ្គលប្រមាទក្នុងការបដិបត្តិកុសលកម្មនោះ កាលកើតក្នុងឋានៈ ដែលរមែងសោកសៅជាងនរក ហើយនឹងកំណត់សត្វតិរច្ឆាន ក៏រមែងកើតក្នុងប្រេតវិស័យប្រាកដដូចនោះ ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់រតនសូត្រ ដើម្បីសម្ដែងថា បុគ្គលមិនគួរធ្វើសេចក្ដីប្រមាទក្នុងការបដិបត្តិកុសលកម្មនោះ ហើយដើម្បីរម្ងាប់ឧបទ្រពនៃក្រុងវេសាលី ដែលពួកភូតឯណាបានបៀតបៀនហើយ ឬត្រាស់ដើម្បី សម្ដែងថា បណ្ដាភូតទាំងអស់នោះ មានភូតពួកខ្លះ មានរូបប្រាកដដូច្នោះ គប្បីជ្រាបប្រយោជន៍នៃការតាំងតិរោកុឌ្ឌសូត្រនេះ ក្នុងទីនេះ ។

អនុមោទនាគាថា

**គាថាអនុមោទនា**

ក៏ការពណ៌នាសេចក្ដីនៃតិរោកុឌ្ឌសូត្រមានដូច្នេះ ព្រោះហេតុតែតិរោកុឌ្ឌសូត្រ អ្នកណាប្រកាស ប្រកាសក្នុងទីណា ប្រកាសពីកាលណា ហើយប្រកាសព្រោះហេតុអ្វី ការពណ៌នាសេចក្ដីនៃតិរោកុឌ្ឌសូត្រនោះទាំងអស់ហើយ កាលធ្វើតាមលំដាប់ ឈ្មោះថាធ្វើល្អហើយដូច្នោះ ខ្ញុំក៏នឹងធ្វើការពណ៌នាសេចក្ដីនោះ យ៉ាងនោះដូចគ្នា ។

សេចក្ដីថា ក៏តិរោកុឌ្ឌសូត្រនេះអ្នកណាប្រកាស ប្រកាសក្នុងទីណា ប្រកាសពេលណា ហើយប្រកាសព្រោះហេតុអ្វី ។ សេចក្ដីពន្យល់ដូច្នេះ តិរោកុឌ្ឌសូត្រព្រះមានព្រះភាគទ្រង់ប្រកាស ក៏តិរោកុឌ្ឌសូត្រនោះទ្រង់ប្រកាសដើម្បីទ្រង់អនុមោទនាចំពោះព្រះបាទមគធរដ្ឋក្នុងថ្ងៃព្រឹកឡើង ។ ដើម្បីធ្វើសេចក្ដីនេះ ឱ្យជាក់ច្បាស់ គួរពោលរឿងពិស្ដារក្នុងតិរោកុឌ្ឌសូត្រនោះដូចតទៅនេះ ៖

ក្នុងកប្បទី ៩២ រាប់អំពីកប្បនេះ មាននគរឈ្មោះកាសី ។ ក្នុងនគរនោះ មានព្រះរាជាព្រះនាមថា ***ជយសេន*** ព្រះទេវីរបស់ព្រះរាជានោះ ព្រះនាមថា ***សិរិមា*** ព្រះពោធិសត្វព្រះនាមថា ***បុស្សៈ*** កើតក្នុងគភ៌របស់ព្រះនាងត្រាស់ដឹងនូវព្រះសម្មាសម្ពោធិញាណតាមលំដាប់ ។ ព្រះរាជាជយសេនទ្រង់កើតការ

ក្រាបទូលជាការៈព្រះអង្គថា ឱរសរបស់យើងទ្រង់ចេញសាងផ្នួស ហើយត្រាស់ដឹងជាព្រះពុទ្ធ ព្រះពុទ្ធក៏ជារបស់យើង ព្រះធម៌ក៏ជារបស់យើង ព្រះសង្ឃក៏ជារបស់យើង ទ្រង់ឧបដ្ឋាកដោយព្រះអង្គឯងរហូតគ្រប់វេលា រមែងមិនប្រទានឱកាសដល់មនុស្សដទៃ ។

បងប្អូនរបស់ព្រះមានព្រះភាគ ព្រះមាតាផ្សេងៗគ្នាមាន ៣ ព្រះអង្គ នាំគ្នាត្រិះរិះថា ធម្មតាព្រះពុទ្ធទាំងឡាយ រមែងទ្រង់ឧប្បត្តិឡើងដើម្បីជាប្រយោជន៍ជួយដល់សត្វលោកទាំងពួង មិនមែនដើម្បីប្រយោជន៍ដល់បុគ្គលតែម្នាក់ តែព្រះបិតារបស់យើង មិនទ្រង់ប្រទានឱកាសដល់យើង និងមនុស្សដទៃៗឡើយ យើងនឹងបានការឧបដ្ឋាកយ៉ាងណាហ្ន៎ ។ ព្រះរាជឱរសពួកនោះទើបគិតយ៉ាងនេះថា ចាំយើងនឹងធ្វើឧបាយណាមួយ ។ ព្រះរាជបុត្រទាំង ៣ ព្រះអង្គទើបឱ្យមេស្រុកជាយដែន ធ្វើការប៉ះបោរ ។ អំពីនោះ ព្រះរាជាទ្រង់ជ្រាបដំណឹងថា មេស្រុកជាយដែនប៉ះបោរ ទើបទ្រង់បញ្ជូនព្រះរាជឱរសទាំង ៣ ព្រះអង្គឱ្យចេញទៅបង្ក្រាប ។ ព្រះរាជឱរសទាំងនោះបង្ក្រាបស្រេចហើយក៏ស្តេចត្រឡប់មកវិញ ព្រះរាជាទ្រង់រីករាយព្រះរាជហឫទ័យ ព្រះរាជាទើបប្រទានពរថា បុត្រប្រាថ្នាវត្ថុណា ក៏ចូរទទួលវត្ថុនោះ ។ ព្រះរាជឱរសទាំង ៣ ព្រះអង្គក្រាបទូលថា ខ្ញុំព្រះអង្គប្រាថ្នានឹងឧបដ្ឋាកព្រះមានព្រះភាគ ព្រះរាជាត្រាស់ថា លើកលែងពរនោះចេញ ចូរបុត្រប្រាថ្នាពរផ្សេង

ទៀតចុះ ។ ព្រះរាជឱរសក្រាបទូលថា ពួកខ្ញុំព្រះអង្គមិនប្រាថ្នាពរដទៃឡើយ ។ ព្រះរាជាត្រាស់ថា ប្រសិនបើយ៉ាងនោះ បុត្រកំណត់វេលាមកហើយទទួលចុះ ។ ព្រះរាជឱរសទូលសុំ ៧ ឆ្នាំ ។ ព្រះរាជាមិនព្រះរាជទានឱ្យ ព្រះរាជឱរសទើបក្រាបទូលសុំថយចុះយ៉ាងនេះគឺ ៦.៥.៤.៣.២.១ ឆ្នាំ ៧.៦.៥.៤ខែ រហូតដល់ត្រឹម៣មាស ព្រះរាជាទើបទ្រង់ព្រះរាជទានថា បើដូច្នោះអ្នកចូរទទួលយកចុះ ។ ព្រះរាជឱរសទាំងនោះ បានទទួលពរហើយ ក៏ទ្រង់ត្រេកអរយ៉ាងក្រៃលែង ចូលគាល់ព្រះដ៏មាន-ព្រះភាគ ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គប្រាថ្នានឹងឧបដ្ឋាកព្រះដ៏មានព្រះភាគគ្រប់ ៣ ខែ សូមព្រះដ៏មានព្រះភាគទ្រង់ទទួលចាំវស្សា ៣ ខែដើម្បីជាប្រយោជន៍ដល់ខ្ញុំព្រះអង្គផងចុះ ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ទទួលនិមន្តដោយតុណ្ហីភាពគឺ អាការៈស្ងៀម ។ បន្ទាប់ពីនោះមក ព្រះរាជឱរសទាំង ៣ ព្រះអង្គ ក៏ទ្រង់បញ្ជូនព្រះរាជសារ ឡាយព្រះហស្ថទៅប្រាប់ដល់រាជបុរសអ្នកនាំសួយសារអាករ ក្នុងជនបទរបស់ព្រះអង្គថា យើងនឹងបម្រើព្រះដ៏មានព្រះភាគអស់ ៣ ខែនេះ អ្នកចូលរៀបចំសម្ភារៈ ប្រកបការទំនុកបម្រុងព្រះដ៏មានព្រះភាគទុក ឱ្យសព្វគ្រប់ ផ្ដើមពីការកសាងព្រះវិហារជាដើម ។ អ្នកនាំសួយអាករនោះ ចាត់ការសព្វគ្រប់យ៉ាងហើយក៏បញ្ជូនបញ្ជីរបាយការណ៍ ឱ្យទ្រង់ជ្រាប ។ ព្រះរាជឱរសទាំងនោះ ក៏ទ្រង់ស្លៀកដណ្ដប់សំពត់កាសាយៈ ទ្រង់

ឧបដ្ឋាកព្រះដ៏មានព្រះភាគដោយគោរព ដោយបុរសជាវេយ្យាវច្ចករចំនួន ២.៥០០ នាក់នាំព្រះដ៏មានព្រះភាគឆ្ពោះទៅកាន់ជនបទ វេរថ្វាយព្រះវិហារឱ្យទ្រង់គង់ចាំព្រះវស្សា ។

គហបតិបុត្តម្នាក់ ជាអ្នករក្សាឃ្លាំងរបស់ព្រះរាជឱរសទាំងនោះ ព្រមទាំងភរិយា ជាបុគ្គលមានបសាទសទ្ធាបានចូលទៅបដិបត្តិថ្វាយទានដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធានដោយគោរព ។ អ្នកនាំសួយសារអាករជនបទ នាំគហបតិបុត្តនោះ ឱ្យដំណើរការថ្វាយទាន ដោយគោរពព្រមដោយអ្នកស្រុកជនបទប្រមាណ ១១.០០០ នាក់ ។ បណ្ដាមនុស្សទាំងនោះ ជនពួកខ្លះមានចិត្តឥស្សាមច្ឆរិយៈគ្របសង្កត់ ពួកគេក៏នាំគ្នាធ្វើអន្តរាយដល់ទាន បរិភោគទេយ្យវត្ថុដោយខ្លួនឯងខ្លះ ឱ្យដល់ពួកកូនៗខ្លះ ហើយយកភ្លើងដុតសាលាទានខ្លះ ។ គ្រាបវារណាចេញព្រះវស្សា ព្រះរាជឱរសទាំងឡាយ ក៏ទ្រង់ធ្វើសក្ការៈយ៉ាងក្រៃលែង ចំពោះព្រះដ៏មានព្រះភាគ តាមព្រះដ៏មានព្រះភាគចូលទៅគាល់ព្រះរាជបិតា ។ ព្រះដ៏មានព្រះភាគស្ដេចទៅក្នុងទីនោះហើយក៏បរិព្វាន ។ ព្រះរាជាផង ព្រះរាជឱរសផង អ្នកនាំសួយសារអាករក្នុងជនបទផង និងអ្នករក្សាឃ្លាំងផង ធ្វើកាលកិរិយាទៅជាបន្តបន្ទាប់ ក៏កើតក្នុងស្ថានសួគ៌ព្រមដោយបរិស័ទជាបរិវារ ។

ចំណែក ពួកជនដែលមានចិត្តឥស្សាមច្ឆរិយៈគ្របសង្កត់ ក៏ទៅកើតក្នុងស្ថាននរក បណ្តាមនុស្សទាំង ២ ក្រុមនោះ មួយក្រុមស្លាប់ពីស្ថានសួគ៌ ទៅកើតស្ថានសួគ៌ ចំណែកមួយក្រុមទៀត ស្លាប់ពីនរកចូលទៅកាន់នរក ដោយអាការៈយ៉ាងនេះ កប្បក៏កន្លងផុតទៅអស់ ៩២ កប្ប ។

បន្ទាប់មក ក្នុងកទ្ទកប្បនេះ កាលព្រះពុទ្ធព្រះនាមថា **កស្សបៈ** ជនអ្នកមានចិត្តឥស្សា និងមច្ឆរិយៈគ្របសង្កត់ទាំងនោះ ក៏កើតជាប្រេត ។ កាលនោះ មនុស្សទាំងឡាយថ្វាយទាន ឧទ្ទិសដើម្បីប្រយោជន៍ដល់ពួកប្រេតដែលជាញាតិ របស់ខ្លួនថា សូមទាននេះចូរមានដល់ពួកញាតិរបស់យើង ។ ប្រេតទាំងនោះ ក៏បាននូវសម្បត្តិ ។ ខណៈនោះ ប្រេតពួកនេះឃើញដូច្នោះ ក៏ចូលទៅគាល់ព្រះមានព្រះភាគព្រះនាមកស្សបៈ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធ្វើយ៉ាងណាហ្ន៎ ពួកខ្ញុំព្រះអង្គទើបនឹងបានសម្បត្តិយ៉ាងនេះ ។ ព្រះមានព្រះភាគត្រាស់ថា ឥឡូវនេះ ពួកអ្នកទាំងឡាយនូវមិនបានសម្រេចទេ តែជាក្នុងអនាគត ព្រះពុទ្ធព្រះនាមថា **គោតម** ក្នុងកាលនៃព្រះដ៏មានព្រះភាគអង្គនោះ នឹងមានព្រះរាជាព្រះនាមថា ពិម្ពិសារ ព្រះរាជាអង្គនោះ ជាញាតិរបស់អ្នកកាលពី ៩២ កប្បមុន ។ ព្រះរាជានឹងថ្វាយទានដល់ព្រះពុទ្ធ

ឧទ្ទិសចំណែកកុសលដល់ពួកអ្នកទាំងឡាយ គ្រានោះ ពួកអ្នកទាំងឡាយនឹងបាន ។ បានឮថា កាលព្រះពុទ្ធ មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ព្រះពុទ្ធតម្រាស់នោះ បានប្រាកដដល់ប្រេតទាំងនោះ ហាក់បីដូចត្រាស់ថា ពួកអ្នកទាំងឡាយ នឹងបានក្នុងថ្ងៃស្អែកនេះ ។

តមក ពេលកន្លងទៅចន្លោះ ១ ពុទ្ធន្តរ ព្រះមានព្រះភាគរបស់ពួកយើង ក៏ស្តេចឧប្បត្តិឡើងក្នុងលោក ។ ព្រះរាជឱរសទាំង ៣ ព្រះអង្គនោះ ក៏ចុតិពីទេវលោកព្រមដោយបរិវារចំនួន ២.៥០០ នាក់ ទាំងនោះ ទៅកើតក្នុងត្រកូលព្រាហ្មណ៍ទាំងឡាយក្នុងដែនមគធៈបួសជាឥសីដោយលំដាប់ បានជាជដិល ៣ នាក់ ក្នុងគយាសីសប្រទេស ។រាជបុរសអ្នកនាំសួយសារអាករ ក្នុងជនបទបានជាព្រះបាទពិម្ពិសារ បុត្រគហបតិជាអ្នករក្សាឃ្លាំង បានជាមហាសេដ្ឋីឈ្មោះ វិសាខៈ ភរិយារបស់អ្នករក្សាឃ្លាំងនោះបានជាសេដ្ឋីធីតាឈ្មោះ ធម្មទិន្នា ។ បរិស័ទដែលនៅសល់ កើតជារាជបរិវាររបស់ព្រះបាទពិម្ពិសារទាំងអស់ ។

ព្រះដ៏មានព្រះភាគរបស់យើងស្តេចឧប្បត្តិឡើងក្នុងលោក កន្លងទៅ ៧ សប្តាហ៍ក៏ស្តេចមកកាន់ក្រុងពារាណសីដោយលំដាប់ ប្រកាសព្រះធម្មចក្រ ប្រោស

បញ្ចវគ្គិយជាដើម រហូតដល់ទ្រង់ណែនាំជដិល ៣ នាក់ ដែលមានបរិវារ ២.៥០០ នាក់[១] ទើបស្តេចទៅកាន់ក្រុងរាជគ្រឹះ ។ ក្នុងក្រុងរាជគ្រឹះនោះ ព្រះដ៏មានព្រះភាគទ្រង់ប្រោសព្រះបាទពិម្ពិសារ ដែលស្តេចចូលទៅគាល់ក្នុងថ្ងៃនោះឯង ឱ្យតាំងនៅក្នុងសោតាបត្តិផលព្រមដោយព្រាហ្មណ៍និងគហបតិអ្នកមគធៈ ១១ នវុតិ[២] ។ គ្រានោះ

---

១-តិរោកុឌ្ឌបេតវត្ថុវណ្ណនា ក្នុងគម្ពីរបរមត្ថទីបនី អដ្ឋកថានៃគម្ពីរបេតវត្ថុ បានសម្តែងថា អម្ហាកម្បិ ភគវា លោកេ ឧប្បជ្ជិត្វា សត្តសត្តាហំ អតិក្កមិត្វា អនុបុព្វេន ពារាណសឹ អាគម្ម ធម្មចក្កំ បវត្តេត្វា បញ្ចវគ្គិយេ អាទឹ កត្វា យាវ សហស្សបរិវារេ តយោ ជដិលេ វិនេត្វា រាជគហំ អគមាសិ ព្រះមានព្រះភាគជាម្ចាស់នៃយើង ទ្រង់ឧប្បត្តិឡើងក្នុងលោក កន្លងទៅអស់កាល ៧ សប្តាហ៍ ព្រះអង្គអាស្រ័យនូវក្រុងពារាណសី ដោយលំដាប់ ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តិទៅ ធ្វើនូវបញ្ចវគ្គិយជាខាងដើម ដរាបដល់ព្រះអង្គទ្រង់ណែនាំនូវជដិលទាំងបី មានបរិវារមួយ ១.០០០ នាក់ ហើយព្រះអង្គយាងទៅកាន់ក្រុងរាជគ្រឹះ ។ ក្នុងគម្ពីរបរម្ថទីបនីនេះ ជដិលទាំងបីនាក់ មានបរិវារតែមួយ ១.០០០ នាក់ ប៉ុណ្ណោះ ហើយដូចគ្នានឹងគម្ពីរឯទៀត ប៉ុន្តែក្នុងគម្ពីរបរមត្ថជោតិកានេះ លោកសំដែងថា មានបរិវារ ២៥.០០ ដោយសព្ទបាលីថា អឌ្ឍតេយ្យសហស្សបរិវារេ តយោ ជដិលេ វិនេត្វា សេចក្តីថា ព្រះមានព្រះភាគ ព្រះអង្គទ្រង់ណែនាំជដិលទាំងបីនាក់ មានបរិវារ ២៥.០០ រូប ។

២-ក្នុងបាលីអដ្ឋកថាខុទ្ទកបាឋ បរមត្ថជោតិកា សំដែងថា “តត្ថ ច តេនហុបសង្កមន្តំយេវ រាជានំ ពិម្ពិសារំ សោតាបត្តិផលេ បតិដ្ឋាបេសិ ឯកាទសនវុតេហិ មគធកេហិ ព្រាហ្មណ-គហបតិកេហិ សទ្ធឹ ប្រែថា ព្រះសម្មាសម្ពុទ្ធទ្រង់ញ៉ាំងព្រះបាទពិម្ពិសារ ដែលស្តេចទ្រង់ចូលទៅគាល់ព្រះមានព្រះភាគក្នុងថ្ងៃនោះ ឱ្យតាំងនៅក្នុងសោតាបត្តិផល រួមនឹងព្រាហ្មណ៍ព្រមទាំងគហបតិ អ្នករស់នៅក្នុងដែនមគធ ចំនួន ១១ នវុតិ (៩០x១១ = ៩៩០នាក់) ។ ប៉ុន្តែសេចក្តីនេះ

សម្រាប់ជាធម្មទាន

ដូចមិនត្រូវនឹងកន្លែងដទៃទៀត ដូចជាក្នុងគម្ពីរមនោរថបូរណី អដ្ឋកថា-អង្គុត្តរនិកាយ ត្រង់ឧរុវេលកស្សបត្ថេរវត្ថុ សេចក្តីថា ទេសនាបរិយោសានេ រាជា ឯកាទសនហុតេហិ ព្រាហ្មណគហបតិកេហិ សទ្ធឹ សោតាបត្តិផលេ បតិដ្ឋិតោ ឯកនហុតំ ឧបាសកត្តំ បដិវេទេសិ ប្រែថា ក្នុងទីបំផុតនៃទេសនា ព្រះបាទពិម្ពិសារមួយអន្លើដោយព្រាហ្មណ៍គហបតិ ១១ នហុតិ តាំងនៅក្នុងសោតាបត្តិផល, ១ នហុតិ បានប្រកាសខ្លួន ថាជាឧបាសក ។ ក្នុងគម្ពីរបរមត្ថទីបនី អដ្ឋកថាបេតវត្ថុ ត្រង់តិរោកុឌ្ឌបេតវត្ថុវណ្ណនាមានសេចក្តីថា តត្ថ ច តទហុបសន្នមត្តំយេវ រាជានំ ពិម្ពិសារំ សោតាបត្តិផលេ បតិដ្ឋាបេសិ សទ្ធឹ ឯកាទសនហុតេហិ អង្គមគធវាសីហិ ព្រាហ្មណគហបតិកេហិ ប្រែថា ព្រះសម្មាសម្ពុទ្ធទ្រង់ញុំាង ព្រះបាទពិម្ពិសារ ដែលស្តេចទ្រង់ចូលទៅគាល់ព្រះមានព្រះភាគក្នុងថ្ងៃនោះ ឱ្យតាំងនៅក្នុងសោតាបត្តិផលរួមនឹងព្រាហ្មណ៍ព្រមទាំងគហបតិ អ្នករស់នៅក្នុងដែនមគធៈ ចំនួន ១១ នហុតិ ។ គម្ពីរមធុរត្ថវិលាសិនី អដ្ឋកថា ពុទ្ធវំស ត្រង់រតនចង្កមនកណ្ឌវណ្ណនា មានសេចក្តីថា តតោ សត្ថុ ធម្មកថំ សុត្វា រាជា ពិម្ពិសារោ ឯកាទសនហុតេហិ សទ្ធឹ សោតាបត្តិផលេ បតិដ្ឋាសិ ឯកនហុតំ ឧបាសកត្តំ បដិវេទេសិ ។ ប្រែថា បន្ទាប់ពីនោះ ព្រះរាជាព្រះបាទពិម្ពិសារលុះទ្រង់ស្តាប់ធម្មកថា របស់ព្រះមានព្រះភាគហើយ តាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយជន ១១ នហុតិ និង ១ នហុតិទៀត ប្រកាសខ្លួនជាឧបាសក ។ បន្តទៀតសូមពន្យល់អំពីពាក្យ **នហុតិ** តទៅ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យ ត្រង់ពិម្ពិសារសមាគមកថា ថា ទ្វាទសនហុតេហីតិ ឯត្ថ ឯកំ នហុតំ ទសសហស្សានិ ប្រែថា ១ នហុតិ ស្មើ ១ ម៉ឺន (១០.០០០) ក្នុងបទថា ទ្វាទសនហុតេហិ នោះ ។ ក្នុងគម្ពីរនិរុត្តិទីបនី ពោលថា សហស្សំ កាសិ នាម ទសសហស្សំ នហុតំ នាម សតសហស្សំ លក្ខំ នាម ប្រែថា មួយពាន់ (១.០០០) ឈ្មោះ កាសិ, មួយម៉ឺន(១០.០០០) ឈ្មោះថា មួយនហុតិ, មួយសែន (១០០.០០០)

---

ឈ្មោះថា មួយលក្ខៈ ។ គម្ពីរបយោគសិទ្ធិ បានពន្យល់ថា **ទសទសកំ សតំ នាម ទសសតំ សហស្សំ នាម ទសសហស្សំ នហុតំ ទសនហុតំ លក្ខំ សតសហស្សន្តិបិ វុច្ចតិ** ។ ប្រែថា "ដប់គុណនឹងដប់ស្មើមួយរយ (១០x១០=១០០), ដប់គុណនឹងមួយរយស្មើមួយពាន់ (១០x១០០=១.០០០), ដប់គុណនឹងមួយពាន់ស្មើមួយម៉ឺន គឺ១ នហុតិ (១០x១.០០០=១០.០០០), ដប់គុណនឹងមួយម៉ឺន ស្មើនឹងមួយលក្ខ គឺមួយសែន (១០x១០.០០០=១០០.០០០) ។ ក្នុងអភិធានប្បទីបិកាដីកា លោកប្រើពាក្យ និយុតំ ប្រែថា មួយម៉ឺន (១០.០០០) ។ ចំណែកបាឋៈថា នហុតិនោះ ជាពាក្យមិនត្រូវ ព្រោះទាក់ទងដោយភាពលាយគ្នា គឺសន្ធិវិសេស ពោលគឺ នហុតិ ។

ចំណែកសេចក្ដីមួយទៀត ដែលលោកសំដែងពីពាក្យថា នហុតិ ប្រែថា ១០០ សែនកោដិបកោដិ ។ ដូចក្នុងគម្ពីរនេត្តិប្បករណ-អដ្ឋកថា, គម្ពីរសារត្ថប្បកាសិនី អដ្ឋកថានៃសំយុត្តនិកាយ, គម្ពីរមនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ, ដីការបស់អដ្ឋកថាមនោរថបូរណី, គម្ពីរកច្ចាយនព្យាករណ៍ជាដើម បានពោលថា "**សតំសតសហស្សានំ កោដិបកោដិយោ នហុតំ** ប្រែថា មួយរយសែនកោដិបកោដិ ស្មើមួយនហុត" ។

សរុបសេចក្ដីមកវិញ បទ **ឯកាទសនវុតេហិ** ប្រែថា ៩៩០ ។ សេចក្ដីដូចជាមិនត្រឹមត្រូវទេ ហើយចំនួននេះ ឃើញមានតែក្នុងអដ្ឋកថា ខុទ្ទកបាឋ តែម្នាក់ឯង ។ ចំណែកបទ ***ឯកាទស-នហុតេហិ*** វិញ មានសេចក្ដីដូចគ្នាច្រើនកន្លែង ដូចដែលបាននាំមកពន្យល់ខាងលើ ។ ហើយពាក្យថា***ឯកាទសនហុតេហិ*** នេះគួរតែប្រែតាមការបញ្ជាក់របស់គម្ពីរសមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យថា **ឯកំ នហុតំ ទសសហស្សានិ** ប្រែថា មួយនហុតិ ស្មើមួយម៉ឺន ។ ចំណែកមួយនហុតិស្មើមួយរយសែនកោដិបកោដិនោះ មិនគួរយកពន្យល់ក្នុងទីនេះទេ ។

ស្អែក ។ លុះដល់ថ្ងៃព្រឹកឡើង ដែលស្តេចសក្កទេវរាជកំពូលលើពពួកទេព្តា ទ្រង់សរសើរដោយគាថាទាំងឡាយជាដើមយ៉ាងនេះថា ៖

"ទន្តោ ទន្តេហិ សហ បុរាណជដិលេហិ វិប្បមុត្តោ វិប្បមុត្តេហិ សិង្គីនិក្ខសុវណ្ណោ រាជគហំ បាវិសិ ភគវា ។ ព្រះដ៏មានព្រះភាគ ព្រះអង្គទូន្មានហើយ ( នូវឥន្ទ្រិយ) មានព្រះហឫទ័យផុតស្រឡះហើយ (ចាកអាសវធម៌) ព្រះអង្គមានពណ៌ល្អដូចជុំមាសឈ្មោះ សិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើ ដោយពួកបុរាណជដិលដែលជាអ្នកទូន្មានហើយ (នូវឥន្ទ្រិយ)ដែរ ជាអ្នកមានចិត្តផុតស្រឡះហើយ (ចាកអាសវធម៌)"[១] ។

ស្តេចយាងត្រោះទៅក្រុងរាជគ្រឹះទ្រង់ទទួលមហាទាន ក្នុងព្រះរាជនិវេសន៍របស់ព្រះបាទពិម្ពិសារ ។ ប្រេតទាំងនោះឈរចោមរោមដោយសង្ឃឹមថា ពេលនេះព្រះរាជាចាត់ចែងទ្រង់នឹងឧទ្ទិសទានដល់ពួកយើង កាលនេះទ្រង់ចាត់ចែងទានឧទ្ទិសដល់ពួកយើង ។

ចំណែកព្រះបាទពិម្ពិសារថ្វាយទានហើយទ្រង់ព្រះតម្រិះថា ព្រះដ៏មានព្រះភាគនឹងគប្បីទ្រង់គង់ប្រថាប់នៅក្នុងទីណាហ្ន៎ ព្រះតម្រិះចំពោះតែរឿងដែលប្រថាប់នៅរបស់ព្រះដ៏មានព្រះភាគប៉ុណ្ណោះ ទើបទ្រង់មិនបានឧទ្ទិសទាននោះដល់នរណាៗ ។

---

១-វិនយបិដក មហាវគ្គ លេខ ៦ ទំព័រ ១១៥ ។

ប្រេតទាំងឡាយអស់សង្ឃឹម នៅពេលពាក់កណ្តាលយប់ ទើបនាំគ្នាធ្វើសំឡេងប្លែកៗគួរឱ្យតក់ស្លុតពន់ពេក ក្នុងព្រះរាជនិវេសន៍ ។ ព្រះរាជា ទ្រង់ស្លុតព្រះហឫទ័យខ្លាចក្រែង ដល់ពេលព្រឹកឡើងទើបក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮសំឡេងដូចនេះ តើអ្វីនឹងមានដល់ខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ សូមទ្រង់កុំខ្លាចឡើយ មិនមានរឿងអន្តរាយអ្វីៗដល់មហាបពិត្រទេ ក៏ប៉ុន្តែពួកព្រះញាតិចាស់ៗ របស់មហាបពិត្រកើតជាប្រេតរមែងមាន ប្រេតទាំងនោះត្រាច់ទៅអស់ ១ ពុទ្ធន្តរ សង្ឃឹម ចំពោះមហាបពិត្រថា ទ្រង់នឹងថ្វាយទានដល់ព្រះពុទ្ធ ហើយទ្រង់នឹងឧទ្ទិសចំណែកកុសលដល់ពួកយើង ។ កាលពីថ្ងៃម្សិល មហាបពិត្រទ្រង់មិនបានឧទ្ទិសចំណែកកុសលដល់ប្រេតពួកនោះ ប្រេតពួកនោះអស់សង្ឃឹម ទើបនាំគ្នាធ្វើសំឡេងខុសប្លែកដូច្នេះ ។

ព្រះបាទពិម្ពិសារក្រាបទូលថា ខ្ញុំព្រះអង្គកាលនេះ ពេលខ្ញុំព្រះអង្គថ្វាយទាន ពួកគេក៏គួរនឹងបានឬទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ថ្វាយព្រះពរមហាបពិត្របាន ។ ព្រះបាទពិម្ពិសារក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ប្រសិនបើដូច្នោះ សូមព្រះដ៏មានព្រះភាគទ្រង់ប្រោសទទួលនិមន្ត សោយភត្តាហារវេលាព្រឹកនេះរបស់ខ្ញុំព្រះអង្គផង ខ្ញុំព្រះអង្គនឹងចាត់ចែងឧទ្ទិសទានដល់ប្រេតពួកនោះ ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ព្រះរាជាស្តេចចូលទៅកាន់ព្រះរាជនិវេសន៍ ចាត់ចែងមហាទានហើយឱ្យក្រាបទូលវេលាភត្តាហារដល់ព្រះដ៏

មានព្រះភាគ ។ ព្រះដ៏មានព្រះភាគស្តេចយាងទៅកាន់ព្រះរាជនិវេសន៍ ប្រថាប់ខាងលើពុទ្ធាសនៈដែលគេចាត់ចែងទុក ព្រមដោយភិក្ខុសង្ឃ ។ ប្រេតពួកនោះនាំគ្នាទៅឈរនៅក្រៅជញ្ជាំងផ្ទះជាដើម ដោយសង្ឃឹមថា ថ្ងៃនេះពួកយើងគង់នឹងបានអ្វីខ្លះ ។ ព្រះដ៏មានព្រះភាគ ទ្រង់ញ៉ាំងព្រះរាជាឱ្យបានឃើញពពួកប្រេតទាំងអស់ ។ ព្រះរាជាថ្វាយទឹកទក្ខិណោទក ហើយទ្រង់ឧទ្ទិសថា សូមទាននេះចូរមានដល់ពួកញាតិរបស់យើង ។ នៅពេលនោះឯង ស្រះបោក្ខរណីដេរដាសទៅដោយឈូក ក៏កើតដល់ប្រេតពួកនោះ ។ ប្រេតពួកនោះក៏ងូតទឹក និងផឹកទឹកស្រះបោក្ខរណីនោះរម្ងាប់សេចក្តីក្រវល់ក្រវាយ សេចក្តីលំបាកនឹងស្រេកឃ្លានបានហើយមានពណ៌សម្បុរដូចមាស ។ លំដាប់នោះ ព្រះរាជាថ្វាយយាគូ របស់ទំពាស៊ី របស់បរិភោគជាដើមហើយទ្រង់ឧទ្ទិសក្នុងខណៈពេលនោះឯង បាយ យាគូ របស់ទំពាស៊ី និងរបស់បរិភោគដែលជារបស់ទិព្វ ក៏កើតដល់ពួកប្រេតនោះ ។ ប្រេតពួកនោះ ក៏នាំគ្នាបរិភោគរបស់ជាទិព្វទាំងនោះ មានឥន្ទ្រិយស្រស់បស់ ។ លំដាប់នោះ ព្រះរាជាថ្វាយសំពត់ និងសេនាសនៈជាដើម ទ្រង់ឧទ្ទិសចំណែកបុណ្យឱ្យ ស្រាប់តែពេលនោះគ្រឿងអលង្ការផ្សេងៗ មានសំពត់ទិព្វ យានទិព្វ ប្រាសាទទិព្វ គ្រឿងកម្រាលនិងទីដេកជាដើមជាទិព្វ ក៏កើតដល់ប្រេតពួកនោះ ។ សូម្បីទ្រព្យសម្បត្តិរបស់ប្រេតពួកនោះ ប្រាកដគ្រប់យ៉ាងដោយប្រការណា ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់

*ក៏អធិដ្ឋាន (ឱ្យព្រះរាជាទ្រង់ឃើញ) ដោយប្រការនោះ ។ ព្រះរាជាក៏ទ្រង់សប្បាយព្រះរាជហឫទ័យយ៉ាងខ្លាំង ។ បន្ទាប់ពីនោះ ព្រះដ៏មានព្រះភាគ សោយស្រេចហើយទ្រង់ហាមភត្តាហារហើយ បានត្រាស់ព្រះគាថាទាំងនេះថា* តិរោកុឌ្ឌេសុ តិដ្ឋន្តិ *ជាដើម ដើម្បីទ្រង់អនុមោទនាដល់ព្រះបាទមគធរដ្ឋ ។ ដោយពាក្យមានប្រមាណប៉ុណ្ណោះ មាតិកានេះថា* យេន យត្ថ យទា យស្មា តិរោកុឌ្ឌំ បកាសិតំ បកាសយិត្វា តំ សព្វំ *ក៏ជាចំណែកនៃអត្ថហើយ ទាំងដោយសង្ខេប ទាំងដោយពិស្តារ ។ ឥឡូវនេះ នឹងពោលពណ៌នាសេចក្តីនៃតិរោកុឌ្ឌសូត្រនេះ តាមលំដាប់ទៅ*

## បឋមគាថាវណ្ណនា

## **ពណ៌នាគាថា ទី ១**

*នឹងពណ៌នាសេចក្តីក្នុងគាថាដំបូងសិន ។ ចំណែកខាងក្រៅនៃជញ្ជាំងទាំងឡាយហៅថា* តិរោកុឌ្ឌ *។ បទថា* តិដ្ឋន្តិ *ជាបទពោលអំពីឥរិយាបថឈរ ព្រោះហាមឥរិយាបថអង្គុយជាដើម ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទើបត្រាស់ អំពីពួកប្រេតដែលឈរនៅត្រង់ចំណែកដទៃនៃជញ្ជាំងផ្ទះ ទុកក្នុងទីនេះថា* តិរោកុឌ្ឌេសុ តិដ្ឋន្តិ *នាំគ្នាឈរ នៅត្រង់ខាងក្រៅជញ្ជាំងផ្ទះ ដូចដែលលោកពោលអំពីលោកដែលសម្តែងឫទ្ធិផ្សេងៗ ដែលទៅក្នុងចំណែកដទៃនៃកំពែង*

និងចំណែកដទៃនៃក្តុំថា ទៅក្រៅកំពែង ក្រៅភ្នំមិនរាំងស្ទះដូច្នេះ ។ ក្នុងបទថា សន្ធិសឹឃាដកេសុ ច នោះ ផ្លូវបែកជា ៤ ឬសូម្បីត្រង់ទីតនៃផ្ទះទីតនៃជញ្ជាំង និងស៊ុមបង្អួច លោកហៅថា សន្ធិ ។ ផ្លូវបែកជា ៣ លោកហៅថា សឹឃាដកៈ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើពាក្យនោះ ទុកក្នុងកន្លែងតែមួយ ភ្ជាប់ជាមួយនឹងពាក្យដើម ទើបត្រាស់ថា សន្ធិសិង្ឃាដកេសុ ច ។ បទថា ទ្វារពាហាសុ តិដ្ឋន្តិ បានដល់ ឈរផ្អែកមាត់ទ្វារនគរ និងទ្វារផ្ទះ ។ ផ្ទះញាតិអំពីមុនក្តី ផ្ទះរបស់ខ្លួន ដែលធ្លាប់គ្រប់គ្រងជាម្ចាស់របស់ក្តី ឈ្មោះថា ផ្ទះរបស់ខ្លួន ក្នុងពាក្យថា អាគន្ត្វាន សកំ ឃរំ នេះ ។ ព្រោះហេតុដែលប្រេតពួកនោះនាំគ្នាមក ដោយត្រឹមតែសញ្ញា យល់ថា ជាផ្ទះរបស់ខ្លួន ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ដល់ផ្ទះពីរនោះ ថា អាគន្ត្វាន សកំ ឃរំ មកកាន់ផ្ទះរបស់ខ្លួន ។

## ទុតិយគាថាវណ្ណនា

### ពណ៌នាគាថាទី ២

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងចំពោះព្រះរាជា អំពីប្រេតជាច្រើនដែលនាំគ្នាមកកាន់ព្រះរាជនិវេសន៍របស់ព្រះបាទពិម្ពិសារ ដែលជាញាតិអំពីមុនក៏ដោយ សូម្បីខ្លួនមិនធ្លាប់គ្រប់គ្រងមកអំពីមុន ដោយសម្គាល់ថាជាផ្ទះរបស់ខ្លួន នាំគ្នាឈរនៅខាងក្រៅជញ្ជាំង ត្រង់ផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ និងមាត់ទ្វារ សោយផលនៃសេចក្តីប្រណែនឫស្យា និងសេចក្តីកំណាញ់ ពួកខ្លះមាន

ពុកមាត់ និងសក់វែង មុខខ្មៅ មានអវយវៈតូចធំចងសំយុង និងយារ ស្គមកំព្រឹង មានពណ៌ខ្មៅដូចដើមត្នោតត្រូវភ្លើងឆេះ ឈរនៅក្នុងទីនោះៗ ពួកខ្លះមានរាង កាយ ត្រូវអណ្តាតភ្លើងដែលតាំងឡើងពីក្នុងពោះលៀនចេញតាមមាត់ ព្រោះការ កកិតគ្នានៃឈើកកិតភ្លើង គឺការស្រេកឃ្លានឆេះរោលរាល ពួកខ្លះមិនអាចបរិភោគ បានតាមត្រូវការ ព្រោះមានបំពង់-កមានទំហំតូចប៉ុនរន្ធគូថម្ជុល និងព្រោះមាន ពោះធំដូចភ្នំ ពួកខ្លះមានរាងកាយមិនគួរឱ្យចង់មើល ប្លែកៗ និងគួរឱ្យព្រឺខ្លាចណាស់ មានឈាមខ្ទុះទឹករម្អិលជាដើមដែលហូរចេញពីដំបៅបូស ដែលបែករបស់គ្នា និង គ្នាឬរបស់សត្វពួកដទៃក្រេបជញ្ជក់ដូចទឹកអម្រឹត ទើបត្រាស់ថា ៖

“តិរោកុឌ្ឌេសុ តិដ្ឋន្តិ សន្ធិសិង្ឃាដកេសុ ច
ទ្វារពាហាសុ តិដ្ឋន្តិ អាគន្ត្វាន សកំ ឃរំ ។

ប្រេតទាំងឡាយ មកកាន់ផ្ទះនៃញាតិ ដោយគិតថា ផ្ទះរបស់ខ្លួនហើយឈរ នៅជិតខាងក្រៅជញ្ជាំងទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ទាំងឡាយ ខ្លះ ជិតទ្វារក្រុងនឹងទ្វារផ្ទះ ទាំងឡាយខ្លះ”[១] ។

កាលទ្រង់សម្តែងសេចក្តីនៃកម្មដែលប្រេតទាំងអស់នោះធ្វើមកហើយ ជា កម្មទារុណ ទើបត្រាស់គាថាទី ២ ថា បហុតេ អន្នបានម្ហិ ជាដើម ។ បណ្តាបទ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១២ ។

ទាំងនោះ បទថា បហុតេ បានដល់ មិនតិច ។ លោកអធិប្បាយថា ច្រើនទាល់តែល្មមត្រូវការ ។ យក ត ជា ហ ដូចក្នុងប្រយោគជាដើមថា បហុ សន្តោ ន ភរតិ បុគ្គលជាអ្នកស្តុកស្តម្ភ តែមិនចិញ្ចឹម ( មាតាក្តី បិតាក្តី )[១] ។ តែអាចារ្យពួកខ្លះសូត្រ ថា បហូតេ ក៏មាន ពហូកេ ក៏មាន ។ បាលីទាំងពីរនេះមិនត្រឹមត្រូវទេ ។ បាយផង ទឹកផង ឈ្មោះថា បាយនិងទឹក ។ របស់ទំពាស៊ីផង របស់បរិភោគផង ឈ្មោះថា របស់ទំពាស៊ីនិងរបស់បរិភោគ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សម្តែងអាហារ ៤ យ៉ាង គឺរបស់បរិភោគ របស់ផឹក របស់ទំពាស៊ី របស់ភ្លក្ស ដោយបទនេះ ។ បទថា ឧបដ្ឋិតេ បានដល់ ចូលទៅតាំងទុក ។ លោកអធិប្បាយថា រៀបចំតុបតែងរួបរួម ។ បទទាំងឡាយថា ន តេសំ កោចិ សរតិ សត្តានំ សេចក្តីថា កាលសត្វទាំងអស់នោះ កើតក្នុងបេត្តិវិស័យ គឺនរណាមួយមិនថាជាមាតាបិតា ឬបុត្រ ក៏មិនរឭកដល់ ។ ព្រោះហេតុអ្វី ព្រោះកម្មជាបច្ច័យ គឺសេចក្តីកំណាញ់ ដែលខ្លួនធ្វើ ព្រមទាំងដោយការបដិសេធការទទួល និងការឱ្យជាដើមជាបច្ច័យ ។ ព្រោះថា កម្មរបស់សត្វពួកនោះ មិនឱ្យញាតិនឹកដល់ ។

## តតិយគាថាវណ្ណនា

### ពណ៌នាគាថាទី ៣

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងថាមិនមានញាតិណាៗ ដែលគួរនឹងរលឹកដល់ព្រោះកម្មដែលមានវិបាកជាទុក្ខក្តៅក្រហាយ ដែលសត្វទាំង

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ៣៧ ។

អស់នោះ ធ្វើទុកជាបច្ច័យដល់សត្វដែលប្រេតទាំងឡាយនោះ ដែលត្រាច់ទៅបំណងចំពោះញាតិទាំងឡាយថា កាលបាយទឹកជាដើមដ៏ច្រើន ដែលញាតិចូលទៅតាំងទុក(ក្នុងសង្ឃ)ញាតិទាំងឡាយ នឹងគប្បីឱ្យអ្វីៗឧទ្ទិសដល់ពួកយើងខ្លះ យ៉ាងនេះទើបព្រះមានព្រះភាគត្រាស់ថា ៖

បហុតេ អន្នបានម្ហិ ខជ្ជភោជ្ជេ ឧបដ្ឋិតេ
ន តេសំ កោចិ សរតិ សត្តានំ កម្មបច្ចយា ។

កាលបើបាយទឹក បង្អែម និងចម្អាបមានគ្រប់គ្រាន់ ដែលពួកញាតិតាក់តែងទុកហើយ មិនមានញាតិណាមួយ នឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយ ជាបច្ច័យ[១] ។

កាលទ្រង់សរសើរទាន ដែលព្រះរាជាថ្វាយ ឧទ្ទិសដល់ពួកព្រះញាតិសាលោហិត របស់ព្រះរាជា ដែលកើតក្នុងបេត្តិវិស័យ (កើតជាប្រេត) ទៀតទើបត្រាស់ព្រះគាថាទី៣ ថា ឯវំ ទទន្តិ ញាតីនំ ជាដើម ។

បណ្តាបទនោះ សព្ទថា ឯវំ ជាពាក្យឧបមា ។ ពាក្យថា ឯវំ នោះ សម្ពន្ធសេចក្តីជា ២ ន័យគឺ

១-ជនទាំងឡាយណាដែលអាណិត ជនទាំងឡាយនោះ រមែងឱ្យបាយទឹកជាដើម ដើម្បីញាតិទាំងឡាយ កាលញាតិណាៗ សូម្បីរឭកមិនឃើញព្រោះកម្មរបស់សត្វពួកនោះជាបច្ច័យយ៉ាងនេះ ។

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៣ ។

២-ថ្វាយព្រះពរមហារាជ ជនទាំងឡាយណាជាអ្នកអាណិត ជនទាំងឡាយ នោះរមែងឱ្យបាយទឹកដ៏ស្អាត ប្រណីត ជាកប្បិយៈរបស់គួរតាមកាល ដើម្បីញាតិទាំងឡាយ ដូចជាមហាបពិត្រថ្វាយទានដូច្នោះ ។

បទថា ទេន្តិ បានដល់ ឱ្យ ឧទ្ទិស ប្រគល់ឱ្យ ។ បទថា ញាតីនំ បានដល់ អ្នកដែលទាក់ទិនខាងមាតា និងខាងបិតា ។ បទថា យេ បានដល់ ពួកណាមួយ មិនថា បុត្រ ធីតា ឬបងប្អូន ។ បទថា ហោន្តិ ប្រែថា រមែងមាន ។ បទថា អនុកម្បកា បានដល់ ដែលប្រាថ្នាប្រយោជន៍ ដែលស្វែងរកប្រយោជន៍ អនុគ្រោះ ។ បទថា សុចឹ បានដល់ គ្មានមន្ទិល គួរសរសើរ ស្រស់ថ្លាប្រកប ដោយធម៌បាន មកដោយធម៌ ។ បទថា បណីតំ បានដល់ ខ្ពស់បំផុត ប្រសើរបំផុត ។ បទថា កាលេន បានដល់ តាមកាលដែលពួកប្រេតដែលជាញាតិមកឈរនៅខាងក្រៅ ជញ្ជាំងផ្ទះជាដើម ។ បទថា កប្បិយំ បានដល់ គួរ សមរម្យ សមគួរដល់ការបរិភោគរបស់ព្រះអរិយៈទាំងឡាយ ។ បទថា បានភោជនំ បានដល់ ទឹក និងបាយ ។ ក្នុងទីនេះ លោកបំណងយកទេយ្យវត្ថុគ្រប់យ៉ាង ដោយលើកយកបាយ និងទឹកជាប្រធាន ។

## ចតុត្ថគាថាបុព្វានុវណ្ណនា

### ពណ៌នាគាថាទី ៤ សម្ព័ន្ធជាមួយគាថាទី ៣

*ព្រះដ៏មានព្រះភាគដែលទ្រង់សរសើរបាយ និងទឹក ដែលព្រះបាទមគធរដ្ឋទ្រង់ថ្វាយដើម្បីអនុគ្រោះក្រុមញាតិសាលោហិតដែលជាប្រេត យ៉ាងនេះ ទើបត្រាស់ថា ៖*

ឯវំ ទទន្តិ ញាតីនំ យេ ហោន្តិ អនុកម្បកា
សុចឹ បណីតំ កាលេន កប្បិយំ បានភោជនំ ។

*ញាតិទាំងឡាយណា ជាអ្នកអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឱ្យនូវទឹក និងភោជនដ៏ហ្មត់ចត់ដ៏ប្រសើរ ជារបស់គួរតាមកាលដល់ញាតិទាំងឡាយ[១] ។*

*កាលព្រះមានព្រះភាគទ្រង់សម្តែងឧបការៈនៃទាន ដែលឱ្យហើយ ជាការឱ្យដើម្បីញាតិពួកនោះទៀត ទើបត្រាស់ពាក់កណ្តាលដើមនៃគាថាទី ៤ ថា* ឥទំ វោ ញាតីនំ ហោតុ *ជាដើម ។ គប្បីសម្ព័ន្ធសេចក្តីជាមួយនឹងពាក់កណ្តាលដើមនៃគាថាទី ៣ ថា ៖*

ឯវំ ទទន្តិ ញាតីនំ យេ ហោន្តិ អនុកម្បកា
ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ។

---

*១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៣ ។*

ញាតិទាំងឡាយណា ជាអ្នកអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឱ្យនូវបាយ និងទឹកយ៉ាងនេះថា ទាននេះចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយបានដល់នូវសេចក្តីសុខ ។

ព្រោះហេតុនោះ ដូចអាការៈដែលគប្បីឱ្យដែលទ្រង់ធ្វើហើយដោយ ឯវំ ស័ព្ទ ដែលមានអត្ថថា អាការៈក្នុងពាក្យនេះថា ជនទាំងឡាយនោះ រមែងឱ្យដោយអាការៈយ៉ាងនេះថា សូមទាននេះឯង ចូរមានដល់ញាតិទាំងឡាយ មិនមែនដោយអាការៈយ៉ាងដទៃ ។

បណ្តាបទទាំងនោះ បទថា ឥទំ ជាបទសម្តែងដូចទេយ្យធម៌ ។ បទថា វោ គ្រាន់តែជានិបាតតែម្យ៉ាង មិនមែនឆដ្ឋីវិភត្ត ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា កច្ចិ បន វោ អនុរុទ្ធា សមគ្គា សម្មោទមានា ។ ឬថា យេហិ វោ អរិយា ។ បទថា ញាតីនំ ហោតុ សេចក្តីថា ចូរមានដល់ញាតិ ទាំងឡាយដែលកើតក្នុងបេត្តិវិស័យ ។ បទថា សុខិតា ហោន្តុ ញាតយោ សេចក្តីថា សូមពួកញាតិ ដែលចូលដល់បិត្តិវិស័យនោះ ចូរជាអ្នកសោយនូវផលទាននេះ ចូរមានសេចក្តីសុខចុះ ។

សម្រាប់ជាធម្មទាន

## ចតុត្ថគាថាបរិទីបនា បញ្ចមគាថាបុព្វទ្ធវណ្ណនា

### ពណ៌នាវគ្គខាងចុងនៃគាថាទី ៤

### សម្ព័ន្ធជាមួយវគ្គខាងដើមនៃគាថាទី ៥

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងឧបការៈនៃទាន ដែលបុគ្គលគប្បីឱ្យដល់ញាតិទាំងឡាយ ដែលចូលដល់បិត្តិវិស័យទើបត្រាស់ថា សូមទាននេះឯង ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ ចូរជាអ្នកដល់នូវសេចក្ដីសុខចុះ ព្រោះហេតុ ដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ថា សូមទាននេះឯងចូរមានដល់ញាតិទាំងឡាយ កម្មដែលបុគ្គលម្នាក់ធ្វើហើយរមែងមិនឱ្យផលដល់បុគ្គលម្នាក់ទៀត ប៉ុន្តែវត្ថុនោះ ដែលញាតិឧទ្ទិសឱ្យយ៉ាងនោះតែម្យ៉ាង រមែងជាបច្ច័យដល់កុសលកម្មរបស់ញាតិទាំងឡាយ ។ ព្រោះហេតុនោះ កាលទ្រង់សម្ដែងឧបការៈនៃកុសលកម្មដែលឱ្យកើតផលភ្លាមៗ ព្រោះវត្ថុនោះនុ៎ះឯងទៀត ទើបត្រាស់ពាក់កណ្ដាលក្រោយនៃគាថាទី ៤ ថា តេ ច តត្ថ និងពាក់កណ្ដាលដើមនៃគាថាទី ៥ ថា បហុតេ អន្នបានម្ហិ ។

ពាក់កណ្ដាលខាងដើម និងពាក់កណ្ដាលខាងចុងនៃគាថានោះ មានសេចក្ដីអធិប្បាយទុកថា ប្រេតដែលជាញាតិទាំងអស់នោះមកជុំវិញ មករួមគ្នា ប្រជុំនៅ

ក្នុងកន្លែងជាមួយគ្នា ក្នុងទីដែលញាតិឱ្យទាននោះ ។ លោកអធិប្បាយទុកថា ប្រេតទាំងអស់នោះមកដោយប្រពៃមករួមគ្នា មកព្រមគ្នាដើម្បីសេចក្តីត្រូវការយ៉ាងនេះថា ញាតិទាំងឡាយរបស់យើងនឹងឧទ្ទិសទាននេះ ដើម្បីប្រយោជន៍ដល់យើងទាំងឡាយ ។ បទថា បហុតេ អន្នបានម្ហិ សេចក្តីថា ក្នុងបាយទឹក ដែលញាតិឧទ្ទិសឱ្យដើម្បីខ្លួនមានច្រើននោះ ។ បទថា សក្កច្ចំ អនុមោទរេ សេចក្តីថា ប្រេតទាំងឡាយនោះជឿជាក់ផលកម្ម មិនលះសេចក្តីគោរពកោតក្រែង មានចិត្តមិនកន្ទក់កន្ទេញ រមែងត្រេកអរអនុមោទនា កើតបីតិរីករាយថា ទាននេះ ចូរមានផលដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងទាំងឡាយ ។

បញ្ចមគាថាបរទ្ធជដ្ឋគាថាបុព្វទ្ធវណ្ណនា

**ពណ៌នាវគ្គខាងចុងនៃគាថាទី ៥**

**សម្ព័ន្ធជាមួយវគ្គខាងដើមនៃគាថាទី ៦**

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងឧបការៈនៃកុសលកម្មឱ្យផលភ្លាមៗ ដល់ញាតិទាំងឡាយដែលចូលដល់បិត្តិវិស័យយ៉ាងនេះ ទើបត្រាស់ថា

តេ ច តត្ថ សមាគន្ត្វា ញាតិបេតា សមាគតា
បហុតេ អន្នបានម្ហិ សក្កច្ចំ អនុមោទរេ ។

ចំណែក ប្រេតជាញាតិ ជាអ្នកមកប្រជុំគ្នាទាំងនោះ មកជួបជុំគ្នាហើយក្នុងមន្ទីរឱ្យទាននោះ កាលបើបាយ និងទឹក មានល្មមគ្រាន់ ក៏អនុមោទនាដោយ

គោរព ។ កាលទ្រង់សម្ដែងអាការៈសរសើរប្រាកដដល់ញាតិទាំងឡាយ របស់ប្រេតទាំងអស់នោះ ដែលសោយផលនៃកុសលកម្ម ដែលកើតព្រោះអាស្រ័យពួកញាតិទៀត ទើបត្រាស់ពាក់កណ្ដាលក្រោយនៃគាថាទី ៥ ថា ចិរំ ជីវន្តុ និងពាក់កណ្ដាល ដើមនៃគាថាទី ៦ ថា អម្ហាកញ្ច កតា បូជា ។ ពាក់កណ្ដាលខាងក្រោយ និងពាក់កណ្ដាលខាងដើមនៃគាថាទាំងអស់នោះមានសេចក្ដីថា បទថា ចិរំ ជីវន្តុ បានដល់ មានជីវិតរស់នៅយឺនយូរមានអាយុវែង ។ បទថា  យេសំ ញាតី ប្រែថា ញាតិទាំងឡាយរបស់ពួកយើង ។ បទថា យេសំ ហេតុ បានដល់ ព្រោះអាស្រ័យញាតិពួកណា ព្រោះហេតុនៃញាតិពួកណា ។ បទថា លភាមសេ ប្រែថា បាន ។ ពួកប្រេតពោលនូវសម្បត្តិដែលខ្លួនបានក្នុងខណៈនោះ ។ មែនពិត ទក្ខិណារមែងសម្រេចផលគឺ ឱ្យកើតផលក្នុងខណៈនោះ បានដោយអង្គ ៣ គឺ ៖

១-បេតានំ អត្តនោ អនុមោទនេន = ដោយការអនុមោទនាដោយខ្លួនឯង របស់ប្រេតទាំងឡាយ ។

២-ទាយកានំ ឧទ្ទិសេន = ដោយការឧទ្ទិសរបស់ទាយកទាំងឡាយ ។

៣-ទក្ខិណេយ្យសម្បទាយ = ដោយការដល់ព្រមដោយទក្ខិណេយ្យបុគ្គល ។ បណ្ដាអង្គ ៣ នោះ ទាយកទាំងឡាយជាអង្គពិសេស ព្រោះហេតុនោះ

ប្រេតទាំងឡាយទើបពោលថា យេសំ ហេតុ លភាមសេ រមែងបានព្រោះហេតុនៃញាតិ (ដែលជាទាយក) ពួកនោះ ។ បទថា អម្ហាកញ្ច កតា បូជា សេចក្តីថា ញាតិទាំងឡាយ ដែលឧទ្ទិសទាននេះយ៉ាងនេះថា សូមទាននេះចូរមានដល់ញាតិរបស់យើង ដូច្នេះ ឈ្មោះថា ធ្វើការបូជាដល់ពួកយើងហើយ ។ បទថា ទាយកា ច អនិប្ផលា សេចក្តីថា កម្មដែលសម្រេចមកអំពីការបរិច្ចាគដែល ទាយកធ្វើហើយក្នុងសន្តានណា ទាយកទាំងឡាយឈ្មោះថា មិនឥតផល ក៏ព្រោះកម្មនោះឱ្យផល ក្នុងសន្តាននោះប៉ុណ្ណោះ ។ ក្នុងសេចក្តីនេះអ្នកជំទាស់ពោលថា ញាតិទាំងឡាយ ដែលចូលដល់បេត្តិវិស័យបានប៉ុណ្ណោះឬ ឬថាសូម្បីអ្នកដទៃៗ ក៏បាន ។ សូមពន្យល់ដូច្នេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រូវព្រាហ្មណ៍ ឈ្មោះថា ជាណុស្សោណិ ទូលសួរហើយ ក៏ទ្រង់ព្យាករណ៍សេចក្តីនេះទុកដូច្នេះថា ក្នុងសេចក្តីនេះ តថាគតនឹងគប្បីពោលពាក្យអ្វី ។ សមដូចដែលព្រះសង្គីតិកាចារ្យពោលទុកដូច្នេះថា

ជាណុស្សោណិព្រាហ្មណ៍ទូលសួរថា ៖

“បពិត្រព្រះគោតមដ៏ចម្រើន យើងជាព្រាហ្មណ៍ តែងឱ្យទាន តែងធ្វើអំពើដែលគេគប្បីធ្វើ ដោយសទ្ធាហើយឧទ្ទិសថា ទាននេះសូមឱ្យសម្រេចផលដល់ប្រេតទាំងឡាយ ជាញាតិសាលោហិត ពួកប្រេតទាំងឡាយ ជាញាតិសាលោហិត

សូមបរិភោគនូវទាននេះ បពិត្រព្រះគោតមដ៏ចម្រើន ចុះទាននោះនឹងសម្រេចផលដល់ប្រេតទាំងឡាយ ជាញាតិសាលោហិតដែរទេ ប្រេតទាំងឡាយ ជាញាតិសាលោហិតនោះ នឹងបរិភោគនូវទាននោះបានដែរឬទេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ទាននោះ សម្រេចផលក្នុងទីគួរ មិនសម្រេចផលក្នុងទីមិនគួរ ។ បពិត្រព្រះគោតមដ៏ចម្រើន ទីដែលគួរ តើដូចម្តេច ទីដែលមិនគួរតើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះជាអ្នកសម្លាប់សត្វ ។ ល ។ មានសេចក្តីយល់ឃើញខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅក៏ទៅកើតក្នុងនរក អាហារណាជាអាហារសម្រាប់សត្វទាំងឡាយ កើតក្នុងនរកសត្វនរកនោះ តែញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងនរកនោះ ដោយសារអាហារនោះសត្វនរកនោះ ស្ថិតនៅក្នុងនរកនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ទាននោះ មិនសម្រេចផល ដល់សត្វដែលស្ថិតនៅក្នុងទីណា ទីនោះឯង ហៅថាទីមិនគួរ ម្នាល ព្រាហ្មណ៍មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ ល ។ មានសេចក្តីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅក៏ទៅកើត ក្នុងកំណើតនៃតិរច្ឆាន អាហារណា ជាអាហារ សម្រាប់សត្វទាំងឡាយដែលកើតក្នុងកំណើតតិរច្ឆាន សត្វតិរច្ឆាននោះ ក៏ញុំាងអត្តភាព ឱ្យប្រព្រឹត្តទៅ ក្នុងទីនោះ ដោយអាហារនោះ សត្វតិរច្ឆាននោះ ស្ថិតនៅក្នុងទីនោះ ដោយសារអាហារ

នោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផល ដល់សត្វដែលស្ថិតនៅក្នុងទីណា ទីនេះឯង ហៅថាទីមិនគួរ ។ ម្នាលព្រាហ្មណ៍ ចំណែកឯបុគ្គលខ្វះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត ។ល។ មានសេចក្តី យល់ត្រូវ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងពួកមនុស្ស អាហារណា ជាអាហារសម្រាប់ ពួកមនុស្ស ។ ល ។ ក៏ទៅកើតក្នុង ពួកទេវតា អាហារណា ជាអាហារសម្រាប់ពួក ទេវតា ទេវតានោះ ក៏ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ទេវតានោះស្ថិតនៅ ក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផល ដល់សត្វដែលស្ថិតនៅក្នុងទីណា ទីនោះឯងហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្វះក្នុងលោកនេះ ជាសម្លាប់សត្វ ។ ល ។ មានសេចក្តីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតក្នុងបេត្តិវិស័យ អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយដែលកើតក្នុងបេត្តិវិស័យ ប្រេតនោះក៏ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ ក្នុងទីនោះដោយអាហារនោះ ស្ថិតនៅក្នុងទីនោះ ដោយសារអាហារនោះ ឬក៏ពួកមិត្រអាមាត្យក្តី ជនជាញាតិសាលោហិតក្តី ឧទ្ទិសឱ្យនូវទានណា ដល់ប្រេតនោះ អំពីលោកនេះប្រេតនោះ ក៏ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះប្រេតនោះស្ថិត នៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ទាននោះ

សម្រេចផល ដល់សត្វដែលស្ថិតនៅ ក្នុងទីណា ទីនេះឯង ហៅថា ទីគួរ ។ ជាណុស្សោណិព្រាហ្មណ៍ ក្រាបទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើប្រេតជាញាតិ សាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ តើអ្នកណា បរិភោគទាននោះ ។ អើព្រាហ្មណ៍ ពួកប្រេត ដែលជាញាតិសាលោហិតដទៃទៀតរបស់គេ គង់ទៅកើតក្នុងទីនោះមិនខាន ប្រេតទាំងនោះឯងបរិភោគទាន ។ បពិត្រព្រះគោត្តមដ៏ចម្រើន ចុះប្រសិនបើប្រេត ជាញាតិសាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ ទាំងពួកប្រេតជាញាតិសាលោហិតដទៃទៀតរបស់គេក៏មិនបានទៅកើតក្នុងទីនោះដែរ តើអ្នកណា បរិភោគទាននោះ ។ នែព្រាហ្មណ៍ ទីណាដែលស្ងាត់ ចាកប្រេតទាំងឡាយជា ញាតិសាលោហិត ដោយកាលជាយូរអង្វែងនេះ ទីនោះ មិនមែនជាហេតុ មិនមែនជាឱកាស គឺថាមិនធ្លាប់មានឡើយ ម្នាលព្រាហ្មណ៍ មួយទៀត ធម្មតាអ្នក ឱ្យទាន មិនមែនជាគ្មានផលទេ[១] ។

១-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥១ ទំព័រ ១៣៥-១៣៩ ។

## ឆដ្ឋគាថាបរទុសត្តមគាថាវណ្ណនា

### ពណ៌នាវគ្គខាងចុងនៃគាថាទី ៦

### សម្ព័ន្ធជាមួយគាថាទី ៧

*ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សរសើរព្រះរាជា ព្រោះទ្រង់អាស្រ័យសម្បត្តិរបស់ក្រុមព្រះញាតិវង្សានុវង្ស ក្នុងជាតិមុនរបស់ព្រះបាទមគធរដ្ឋ ដែលចូលដល់បេត្តិវិស័យ ទើបទ្រង់សម្ដែងថា ថ្វាយព្រះពរមហាបពិត្រ ព្រះញាតិវង្សានុវង្សរបស់មហាបពិត្រទាំងអស់នេះ ត្រេកអរនាំគ្នាសរសើរ ក្នុងទានសម្បទានេះទើបព្រះមានព្រះភាគត្រាស់ថា ៖*

ចិរំ ជីវន្តុ នោ ញាតី យេសំ ហេតុ លភាមសេ
អម្ហាកញ្ច កតា បូជា ទាយកា ច អនិប្ផលា ។

*យើងទាំងឡាយ បានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយណា សូមពួកញាតិរបស់យើងទាំងឡាយនោះ រស់នៅយឺនយូរ ការបូជាដែលញាតិទាំងឡាយធ្វើហើយ ដល់យើងទាំងឡាយក្ដី ញាតិទាំងឡាយ ជាអ្នកឱ្យទានក្ដី*

មិនមែនជាឥតផលឡើយ[១] ។ កាលទ្រង់សម្ដែងការមិនមានហេតុ ដែលឱ្យបាន សម្បត្តិយ៉ាងដទៃមានកសិកម្មនិង គោរក្ខកម្មជាដើម របស់ពួកប្រេត ដែលចូល ដល់បេត្តិវិស័យនោះ និងការដែលពួកប្រេតនោះញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅ ដោយ ទាន ដែលញាតិឱ្យអំពីមនុស្សលោកនេះ ទើបត្រាស់ពាក់កណ្ដាលក្រោយ នៃ គាថា ទី ៦ ថា ន ហិ តត្ថ កសិ អត្ថិ និង គាថាទី ៧ នេះថា វណិជ្ជា តាទិសី ជាដើម ។ ក្នុងគាថានោះ ពណ៌នាសេចក្ដី ដូច្នេះ ថ្វាយព្រះពរមហា បពិត្រ ក៏ក្នុងបេត្តិវិស័យនោះ មិនមានកសិកម្មដែលពួកប្រេតទាំងអស់នោះ នឹង អាស្រ័យហើយបានសម្បត្តិ ។ បទថា គោរក្ខេត្ថ ន វិជ្ជតិ សេចក្ដីថា មិន មែនមិនមានកសិកម្មតែម៉្យាងប៉ុណ្ណោះទេ សូម្បីក្នុងបេត្តិវិស័យនោះ ក៏មិនមាន គោរក្ខកម្មដែរ ដែលពួកប្រេតទាំងអស់នោះនឹងអាស្រ័យហើយបានសម្បត្តិ ។ បទ ថា វណិជ្ជា តាទិសី នត្ថិ សេចក្ដីថា មិនមានសូម្បីការលក់ដូរ ដែលនឹងជា ហេតុឱ្យបានសម្បត្តិរបស់ពួកប្រេតទាំងអស់នោះ ។ បទថា ហិរញ្ញេន កយា- កយំ សេចក្ដីថា ក្នុងបេត្តិវិស័យនោះ មិនមានសូម្បីតែការលក់ទិញដូរ ដោយប្រាក់ ដែលជាហេតុបានសម្បត្តិរបស់ប្រេតទាំងអស់នោះ ។ បទថា ឥតោ ទិន្នេន

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៣ ។

យាបេន្តិ បេតា កាលកតា តហឹ សេចក្តីថា ពួកប្រេតរមែងញ៉ាំងជីវិត ឱ្យប្រព្រឹត្តទៅ ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយទានដែលពួកញាតិ ឬពួកមិត្តសំឡាញ់ឱ្យទៅអំពីមនុស្សលោកនេះតែម្យ៉ាង ។ បទថា បេតា បានដល់ ពួកសត្វ ដែលចូលដល់បិត្តិវិស័យ ។ បទថា កាលគតា បានដល់ ទៅតាមវេលាស្លាប់របស់ខ្លួន ។ ឬបាលីថា កាលកតា មានសេចក្តីអធិប្បាយថា ធ្វើកាលៈ គឺមរណកាល ។ បទថា តហឹ បានដល់ ក្នុងបេត្តិវិស័យនោះ ។

អដ្ឋមនវមគាថាទ្វយវណ្ណនា

**ពណ៌នាពីរគាថាគឺគាថាទី ៨ និងគាថាទី ៩**

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់ត្រាស់ថា អ្នកដែលធ្វើកាលកិរិយាលះលោកទៅហើយ រមែងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងបេត្តិវិស័យនោះ ដោយទានដែលពួកញាតិមិត្តសំឡាញ់ឱ្យហើយអំពីមនុស្សនេះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ប្រកាសសេចក្តីនោះ ដោយសេចក្តីឧបមាទាំងឡាយទើបត្រាស់ ២ គាថានេះថា ឧន្នតេ ឧទកំ វុដ្ឋំ ជាដើម ។

គាថានោះ មានសេចក្តីថា ទឹកដែលជុំពពុះឱ្យធ្លាក់ចុះលើទីទួល លើគោកលើភូមិភាគដែលខ្ពស់ រមែងហូរចុះទីទំនាប គឺហូរទៅដល់ភូមិភាគ យ៉ាងណា ទានដែលពួកញាតិមិត្តឱ្យអំពីមនុស្សលោកនេះ រមែងសម្រេចផលដល់ប្រេតទាំង-

ឡាយនោះ អធិប្បាយថា បង្កើតផលប្រាកដផលដល់ក្រុមប្រេតយ៉ាងនោះដូចគ្នា ។ មែនពិត បេតលោក ឈ្មោះថា ឋាន: ទីតាំងនៃសេចក្ដីសម្រេចផលនៃទាន ដូចទីទំនាបជាឋាន:ដែលទប់ទឹក ដែលហូរមក ។ ដូចដែលទ្រង់ត្រាស់ទុកថា "ឥធម្បិ ខោ ព្រាហ្មណ ឋានំ យត្ថ ឋិតស្ស តំ ទានំ ឧបកប្បតិ ម្នាលព្រាហ្មណ៍ ទាននោះ សម្រេចផលដល់សត្វ ដែលស្ថិតនៅក្នុងទីណា ទីនោះឯងជាឈ្មោះថាទីគួរ"[១] ដូច្នេះ ។ ដូចជាទឹកដែលហូរចុះមកពីទីទួលមាន ជ្រោះ ចន្លោះភ្នំ ប្រឡាយ ព្រែក បឹង ជាទន្លេធំពេញហូរចូល ក៏ធ្វើឱ្យសាគរ គឺសមុទ្រពេញ ប្រៀបយ៉ាងណា ទាន ដែលញាតិមិត្តឱ្យទៅហើយអំពីលោកនេះ រមែងសម្រេច ផលដល់ក្រុមប្រេត តាមន័យដែលពោលមកមុនហើយដូច្នោះ ។

## ឧសមគាថាវណ្ណនា

### ពណ៌នាគាថាទី ១០

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់ប្រកាសសេចក្ដីនេះថា អ្នកដែលធ្វើកាលកិរិយាលះលោកនេះទៅហើយ រមែងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងបេត្តិវិស័យនោះ ដោយទានដែលញាតិមិត្តឱ្យអំពីលោកនេះ ដោយសេចក្ដីឧបមាដូច្នេះហើយ កាលទ្រង់សម្ដែងទៀតថា ព្រោះហេតុដែលប្រេតពួកនោះ សង្ឃឹមយ៉ាងខ្លាំង

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥១ ទំព័រ ១៣៨ ។

ថា ពួកយើងនឹងបានអ្វីៗ អំពីលោកនេះ ក៏នាំគ្នាមកកាន់ផ្ទះនៃញាតិហើយ ក៏មិនអាចនឹងស្រែកសូមថា សូមលោកទាំងឡាយ មេត្តាឱ្យរបស់ឈ្មោះនេះដល់ពួកយើងចុះ ព្រោះហេតុនោះ កុលបុត្រកាលរឭកដល់រឿងដែលគួររលឹកទាំងអស់នេះ គប្បីឱ្យទក្ខិណាដើម្បីពួកប្រេតទាំងអស់នោះ ទើបត្រាស់គាថានេះថា អទាសិ មេ ជាដើម ។

គាថានោះមានសេចក្ដីថា កុលបុត្រ កាលរឭកឃើញយ៉ាងនេះថា លោកបានឱ្យទ្រព្យ ឬធញ្ញាហារឈ្មោះនេះដល់យើង លោកបានប្រឹងប្រែងដោយខ្លួនឯងបាន ធ្វើកិច្ចឈ្មោះនេះដល់យើង អ្នកនោះជាញាតិ ព្រោះជាប់ទាក់ទងខាងមាតា ឬខាងបិតារបស់យើង អ្នកនោះជាមិត្ត ព្រោះអាចជួយសង្គ្រោះ ដោយសេចក្ដីស្រឡាញ់ និងអ្នកនោះជាមិត្តលេងដីជាមួយយើង ដូច្នេះគប្បីឱ្យទក្ខិណា គឺគប្បីឱ្យទក្ខិណាទាន ឱ្យដល់ប្រេតដែលលះលោកទៅហើយ ។ មានបាលីដទៃទៀតថា បេតានំ ទក្ខិណា ទជ្ជា ។ បាលីនោះ មានសេចក្ដីថា ឈ្មោះថា ទជ្ជា ព្រោះជារបស់ដែលគប្បីឱ្យ ។ របស់ដែលគប្បីឱ្យនោះគឺជាអ្វី ក៏គឺទក្ខិណាដើម្បីអ្នកដែលលះលោកទៅហើយ ។ ព្រោះហេតុនោះ កុលបុត្រកាលរឭកដល់លោកអធិប្បាយថា កាលនឹកដល់កិច្ច ដែលលោកធ្វើមកពីមុន ដោយន័យថា លោកបានឱ្យវត្ថុនេះ ដល់យើង ដូច្នេះជាដើម ។ ពាក្យនេះ គប្បីជ្រាបថា ជាបឋមាវិភត្តិ ចុះក្នុងអត្ថបំណងជាតតិយាវិភត្តិ ។

ឯកាទសមគាថាវណ្ណនា

**ពណ៌នាគាថាទី ១១**

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងអនុស្សរណវត្ថុ ដែលជាហេតុក្នុងការឱ្យនូវទក្ខិណាដើម្បីក្រុមប្រេតទាំងឡាយយ៉ាងនេះ ទើបត្រាស់ថា ៖

អទាសិ មេ អកាសិ មេ ញាតិ មិត្តា សខា ច មេ
បេតានំ ទក្ខិណំ ទជ្ជា បុព្វេ កតមនុស្សរំ ។

បុគ្គលកាលរឭកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួន ក្នុងកាលមុនថា អ្នកនេះបានឱ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះដល់អញ ជនទាំងឡាយនោះ ជាញាតិមិត្រ ជាសំឡាញ់របស់អញ ដូច្នេះហើយគួរឱ្យទក្ខិណាទានចំពោះប្រេតទាំងឡាយ[១] ។

កាលទ្រង់សម្តែងទៀតថា ជនទាំងឡាយណា មានការយំស្រែក និងសោកសៅជាដើមជាខាងមុខ ព្រោះសេចក្តីស្លាប់របស់ញាតិ ដែលរស់នៅដែលលះលោកទៅហើយ រមែងមិនឱ្យអ្វីៗ គប្បីប្រយោជន៍ដល់ជនអស់នោះ ការយំ និងការសោកសៅជាដើមនោះ របស់ជនទាំងអស់នោះ មានតែធ្វើខ្លួនឱ្យក្តៅក្រហាយ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៤ ។

តែម៉្យាងប៉ុណ្ណោះ រមែងមិនញុំាងប្រយោជន៍អ្វីៗ ឱ្យសម្រេចដល់អ្នក ដែលលះលោកទៅហើយទេ ទើបត្រាស់គាថានេះថា ន ហិ រុណ្ណំ វា ជាដើម ។

បណ្ដាបទទាំងនោះ បទថា រុណ្ណំ បានដល់ ការយំ ការទួញសោក ការដែលទឹកភ្នែកស្រក់ ទ្រង់សម្ដែងសេចក្ដីលំបាកកាយដោយបទនេះ ។ បទថា សោកោ បានដល់ សេចក្ដីព្រួយ សេចក្ដីសោកសៅ ។ ទ្រង់សម្ដែងសេចក្ដីលំបាកចិត្តដោយ បទនេះ ។ បទថា យាវញ្ញា បានដល់ ការយំសោកសៅណានីមួយ ។ បទថា បរិទេវនា បានដល់ ការពណ៌នារៀបរាប់អំពីគុណ ដោយន័យថា ឱ! កូនតែម្នាក់គត់ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត នៅកន្លែងដូច្នេះជាដើម របស់អ្នកដែលត្រូវសេចក្ដីវិនាស ចាកញាតិគ្រប់សន្ដតហើយ ។ ទ្រង់សម្ដែងសេចក្ដីលំបាកវាចា ដោយបទនេះ ។

## ទុតិយគាថាវណ្ណនា

### ពណ៌នាគាថាទី ១២

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែង ការយំជាដើម មិនជាប្រយោជន៍ថា ការយំរៀបរាប់យ៉ាងនេះយ៉ាងនោះសូម្បីទាំងអស់មិនមាន ដើម្បីប្រយោជន៍ដល់អ្នកដែលលះលោកទៅហើយ ការពិតមានតែធ្វើខ្លួនឱ្យក្ដៅក្រហាយតែម៉្យាងប៉ុណ្ណោះ ញាតិទាំងឡាយក៏ប្រហែលជារស់នៅ យ៉ាងនោះដូច្នេះ កាល

ទ្រង់សម្តែងភាពនៃទក្ខិណា ដែលព្រះបាទមគធរដ្ឋ ទ្រង់ថ្វាយហើយមានប្រយោជន៍ ទើបត្រាស់គាថានេះថា អយញ្ច ខោ ទក្ខិណា ដូច្នេះជាដើម ។

គាថានោះ មានសេចក្តីថា ថ្វាយព្រះពរមហារាជ ទក្ខិណានេះឯង មហាបពិត្រ ថ្វាយឧទ្ទិសដល់ក្រុមព្រះញាតិវង្សានុវង្សរបស់មហាបពិត្រក្នុងថ្ងៃនេះ ព្រោះហេតុនៃព្រះសង្ឃជាស្រែបុណ្យដ៏កំពូលនៃលោក ព្រោះហេតុនោះ ទក្ខិណានោះគប្បីជាទក្ខិណាដែលទ្រង់តម្កល់ទុកល្អហើយក្នុងសង្ឃ ទើបសម្រេចផល លោកអធិប្បាយថា បង្កើតផល ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់បេតជនអស់កាលយូរ ។ ក៏បទថា ឋានសោ ឧបកប្បតិ បានដល់ សម្រេចផលដោយឋានៈ គឺបង្កើតផលក្នុងខណៈនោះភ្លាម មិនយូរឡើយ ។ ដូចជាជាក់ស្តែងភ្លាមមួយរំពេចនោះ ក៏ត្រាស់ថា ក៏សេចក្តីនោះជាក់ស្តែងដល់តថាគតដោយឋានៈយ៉ាងណា ទក្ខិណាដែលសម្រេច ផលភ្លាមមួយរំពេចនោះ សូម្បីក្នុងទីនេះក៏ត្រាស់ថា សម្រេចផលដោយ ឋានៈក៏យ៉ាងនោះ ។ ឋានៈណាទ្រង់ត្រាស់ទុកថា ម្នាលព្រាហ្មណ៍ ទាននោះ រមែងសម្រេចផលដល់សត្វដែលរស់នៅក្នុងបេត្តិវិស័យណា បេត្តិវិស័យនោះឯង ជាឋានៈដូច្នេះ ។ ទក្ខិណាដែលសម្រេចផលក្នុងឋានៈ នោះដែលផ្សេងដោយប្រភេទមាន **ខុប្បិបាសិកប្រេត** (ប្រេតដែលបៀតបៀន ដោយសេចក្តីស្រេកឃ្លាន) **វន្តាសប្រេត** (ប្រេតដែលស៊ីទឹកមាត់ ស្ទស្ម៍ កំអួតជាអាហារ)

**បរទត្តុបជីវិកប្រេត** (ប្រេតដែលចិញ្ចឹមជីវិត ដោយអាស្រ័យអាហារ ដែលអ្នកដទៃឱ្យ) និង**និជ្ឈាមតណ្ហិកប្រេត** (ប្រេតដែលត្រូវភ្លើងឆេះពេលឱ្យក្តៅជាប់ជានិច្ច) ជាដើម ក៏ត្រាស់ថា រមែងសម្រេចផលដោយឋានៈ ដូចជាអ្នកឱ្យកហាបណៈក្នុងលោក គេក៏ហៅថា អ្នកនោះឱ្យកហាបណៈ ដូច្នោះ ។ ប៉ុន្តែនៅក្នុងអត្ថវិកប្បនេះ បទថា ឧបកប្បតិ បានដល់ ប្រាកដផលលោកអធិប្បាយថា រមែងកើតផល ។

តេរសមគាថាវណ្ណនា

**ពណ៌នាគាថាទី ១៣**

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងភាពនៃទក្ខិណាដែលព្រះរាជាថ្វាយហើយមានប្រយោជន៍យ៉ាងនេះ ទើបត្រាស់ថា ៖

អយញ្ច ខោ ទក្ខិណា ទិន្នា សង្ឃម្ហិ សុបតិដ្ឋិតា
ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ ។

លុះតែទក្ខិណាទាននេះ ដែលបុគ្គលបានឱ្យហើយ តម្កល់ទុកប្រពៃហើយក្នុងសង្ឃ ទើបសម្រេចផលដោយរួសរាន់ ដើម្បីប្រយោជន៍ដល់ ប្រេតនោះ អស់កាលជាអង្វែង[១] ។ ព្រោះហេតុនៃញាតិធម៌ ដែលព្រះរាជាទ្រង់ថ្វាយទក្ខិណាទាន

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៥ ។

នេះ ទ្រង់សម្តែងហើយ ដោយទ្រង់ធ្វើកិច្ចដែលក្រុមញាតិគួរធ្វើដល់ក្រុមញាតិ ទ្រង់ធ្វើឱ្យប្រាកដដល់ជនជាច្រើន ឬទ្រង់លើកដូចជាថា ញាតិធម៌ សូម្បីលោកទាំងឡាយក៏គប្បីបំពេញ ដោយការធ្វើកិច្ចដែលក្រុមញាតិគប្បីធ្វើយ៉ាងនោះ ដូចគ្នា មិនគប្បីធ្វើខ្លួនឱ្យក្តៅ ក្រហាយដោយការយំជាដើម ដែលឥតប្រយោជន៍ការបូជាដល់ប្រេតដែលព្រះរាជា ទ្រង់ញ៉ាំងក្រុមប្រេតទាំងអស់នោះឱ្យប្រសព្វទិព្វសម្បត្តិ ដែលទ្រង់ធ្វើហើយយ៉ាង ឱឡារិក និងកម្លាំងរបស់ភិក្ខុសង្ឃមាន ព្រះពុទ្ធជាប្រធាន ឱ្យឆ្អែតស្កប់ស្កល់ ដោយបាយទឹកជាដើម ឈ្មោះថាទ្រង់បំពេញឱ្យហើយ និងបុណ្យមិនមែនតិចទេ កាលដែលព្រះរាជាទ្រង់ញ៉ាំងចាគចេតនា មានគុណគឺសេចក្តីអនុគ្រោះជាដើមជាបរិវារ ឱ្យកើតក៏ទ្រង់ប្រសព្វហើយដូច្នេះ ទើបព្រះមានព្រះភាគទ្រង់ញ៉ាំងព្រះរាជាឱ្យទ្រង់ រីករាយដោយគុណ តាមសេចក្តីពិតទាំងអស់នេះទៀត ទើបទ្រង់បញ្ចប់ទេសនា ដោយព្រះគាថានេះថា ៖

សោ ញាតិ ធម្មោ ច អយំ និទស្សិតោ
បេតានបូជា ច កតា ឧឡារា
ពលញ្ច ភិក្ខូនមនុប្បទិន្នំ
តុម្ហេហិ បុញ្ញំ បសុតំ អនប្បកន្តិ ។

ញាតិធម៌នោះឈ្មោះថា មហាបពិត្រ បានសម្តែងជាបែបយ៉ាងហើយ ការបូជាដ៏ ថ្លៃថ្លា ចំពោះប្រេតទាំងឡាយ ឈ្មោះថា បានធ្វើហើយផង កម្លាំងកាយនៃភិក្ខុទាំងឡាយ ឈ្មោះថា បានបំពេញឱ្យហើយផង បុណ្យឈ្មោះថា បានសន្សំទុក មិនមែនតិចឡើយផង[១] ។

ន័យមួយទៀត ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ពន្យល់ព្រះរាជា ដោយធម្មីកថា ដោយបទគាថានេះថា សោ ញាតិធម្មោ ច អយំ និទស្សិតោ ។ មែនពិត ការសម្តែងញាតិធម៌នេះឯង ជាការពន្យល់ញ៉ាំងញាប់ក្នុងសេចក្តីនេះ ។ ទ្រង់ប្រកបដោយបទគាថានេះថា បេតាន បូជា ច កតា ឧឡារា មែនពិត ការសរសើរថា ឧឡារា ក៏ជាការប្រកបដោយការបូជារឿយៗ ក្នុងសេចក្តីនេះ ។ ព្រះមានព្រះភាគទ្រង់ផ្តល់ភាពអង់អាច ដោយបទគាថានេះថា ពលញ្ច ភិក្ខូន-មនុប្បទិន្នំ ។ មែនពិត ការបំពេញកម្លាំងដល់ភិក្ខុទាំងឡាយ ក៏ជាទាន ម្យ៉ាងក្នុងសេចក្តីនេះ ។ ពាក្យថា ពលានុប្បទានតា ជាការដាស់ឱ្យអង់អាច ដោយការបំពេញសេចក្តីឧស្សាហ៍ដល់ព្រះរាជានោះ ។ ទ្រង់រីករាយដោយបទ គាថានេះ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៥ ។

ថា តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ ។ មែនពិត ការបញ្ចាក់អំពីការជួប បុណ្យនោះឯង គប្បីជ្រាបថា ជាការឱ្យកើតសេចក្ដីរីករាយ ដោយការពណ៌នា គុណតាម សេចក្ដីពិត ដល់ព្រះរាជានោះក្នុងសេចក្ដីនេះ ។

ក្នុងទីបញ្ចប់នៃទេសនា ការសម្រេចធម៌បានកើតមានដល់សត្វ ៨៤.០០០ ដែលស្លុតចិត្តព្រោះការពណ៌នាទោសនៃការ ចូលដល់បេត្តិវិស័យ ហើយតាំងសេចក្ដីព្យាយាមដោយរឹងមាំ ។ សូម្បីដល់ថ្ងៃស្អែកឡើង ព្រះដ៏មានព្រះភាគជាម្ចាស់ក៏ទ្រង់សម្ដែង តិរោកុឌ្ឌសូត្រនេះឯង ដល់ពួកទេវតា និងមនុស្សទាំងឡាយ ការត្រាស់ដឹងធម៌យ៉ាងនោះ កើតមានដល់ ៧ ថ្ងៃដោយប្រការដូច្នេះ ។

បរមត្ថជោតិកាយ ខុទ្ទកបាឋដ្ឋកថាយ

តិរោកុឌ្ឌសុត្តវណ្ណនា និដ្ឋិតា

**ចប់អដ្ឋកថាតិរោកុឌ្ឌសូត្រ**

**នៃ**

**អដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះ បរមត្ថជោតិកា ។**

## ៨-និធិកណ្ឌសុត្តវណ្ណនា

## **ពណ៌នានិធិកណ្ឌសូត្រ**

### និក្ខេបការណំ

### **ហេតុនៃការតាំងឡើងនៃព្រះសូត្រ**

និធិកណ្ឌសូត្រនេះ ខ្ញុំនឹងលើកឡើងដោយន័យថា និធឹ និធេតិ បុរិសោ ជាដើម បន្ទាប់អំពីតិរោកុឌ្ឌសូត្រ ឥឡូវនេះខ្ញុំនឹងពោលហេតុដែលតាំងឡើង និង សម្ដែងហេតុដែលកើតឡើងនៃនិធិកណ្ឌសូត្រទុកក្នុងទីនេះ ហើយទើបធ្វើការ ពណ៌នាសេចក្ដីនៃនិធិកណ្ឌសូត្រនោះ ។

បណ្ដាហេតុទាំងពីរនោះ ក្នុងទីនេះគប្បីជ្រាប ហេតុតាំងនៃនិធិកណ្ឌសូត្រ នោះជាដំបូង ។ មែនពិត និធិកណ្ឌសូត្រនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ មិនបាន ត្រាស់ទុកតាមលំដាប់ទេ ព្រោះហេតុដែលជាសូត្រគូនឹងតិរោកុឌ្ឌសូត្រ ដែល ព្រះអង្គត្រាស់សម្ដែងដោយការអនុមោទនា ព្រោះដូច្នោះ ខ្ញុំទើបលើកឡើងតាំង ទុកក្នុងទីនេះ ។ ឬថា គប្បីជ្រាបថា ខ្ញុំកាលនឹងសម្ដែងវិបត្តិរបស់ពួកជន ដែល ប្រាសចាកបុណ្យដោយតិរោកុឌ្ឌសូត្រហើយ ទើបលើកនិធកណ្ឌសូត្រនេះ សម្ដែង ទុកក្នុងទីនេះ ក៏ដើម្បីសម្ដែងសម្បត្តិរបស់ ពួកជនដែលធ្វើបុណ្យទុក ដោយ

សូត្រនេះ ។ ហេតុនៃការតាំងឡើងរបស់និធិកណ្ឌសូត្រនោះ ទុកក្នុងទីនេះ មានប្រមាណប៉ុណ្ណេះ ។

## សុត្តុប្បត្តិ

### ហេតុកើតឡើងនៃព្រះសូត្រ

និធិកណ្ឌសូត្រនោះ មានហេតុកើតឡើងដូច្នេះ ៖

បានឮមកថា នៅក្នុងក្រុងសាវត្ថី មានកុដុម្ពិកម្នាក់ ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន ហើយគាត់ជាមនុស្សមានសទ្ធា មានសេចក្តីជ្រះថ្លា មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ។ ថ្ងៃមួយ គាត់ថ្វាយទានដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ សម័យនោះ ព្រះរាជាជាអ្នកត្រូវការដោយទ្រព្យ ទើបទ្រង់បញ្ជូនរាជបុរសម្នាក់ ទៅទីសម្នាក់របស់គាត់ ដោយព្រះរាជតម្រាស់ថា នែនាយ ឯងចូរទៅនាំកុដុម្ពិកឈ្មោះនេះមក ។ រាជបុរសនោះទៅនិយាយនឹងកុដុម្ពិកនោះថា លោកគហបតិ ព្រះរាជាសូមឱ្យអញ្ជើញលោក ។ កុដុម្ពិកនោះ មានចិត្តប្រកបដោយគុណ មានសទ្ធាជាដើម កំពុងអង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ទើបពោលថា ទៅមុនសិនចុះរាជបុរស ខ្ញុំនឹងទៅតាមក្រោយ ខ្ញុំកំពុងកប់កំណប់ទ្រព្យក្នុងខណៈនេះសិន ។ លំដាប់នោះ ព្រះដ៏មាន-

ព្រះភាគជាម្ចាស់ សោយរួចហើយ ទ្រង់ដកព្រះហស្តចេញពីបាត្រ ដើម្បីទ្រង់សម្តែងនូវបុញ្ញសម្បទាថា នោះជានិធិដោយបរមត្ថ បានត្រាស់ព្រះគាថាទាំងនេះថា និធឹ និធេតិ បុរិសោ ជាដើម ដើម្បីអនុមោទនាដល់កុដុម្ពិកនោះ ។ និធិកណ្ឌសូត្រនោះ មានហេតុកើតឡើងដូចពោលមកនេះ ។ ព្រោះដូច្នោះ ខ្ញុំនឹងពោលហេតុតាំងឡើង និងសម្តែងហេតុកើតឡើងរបស់និធិកណ្ឌសូត្រទុកក្នុងទីនេះ នឹងធ្វើការពណ៌នាសេចក្តីរបស់និធិកណ្ឌសូត្រនោះ ដូចតទៅនេះ ៖

## បឋមគាថាវណ្ណនា

### ពណ៌នាគាថាទី ១

បណ្តាបទទាំងនោះ បទថា និធឹ និធេតិ បុរិសោ សេចក្តីថា ឈ្មោះថា **និធិ** ព្រោះកប់ទុក អធិប្បាយថា តម្កល់ទុក រក្សាទុក គ្រប់គ្រងទុក ។ និធិនោះមាន ៤ យ៉ាងគឺ **ថាវរនិធិ ជង្គមនិធិ អង្គសមនិធិ អនុគាមិកនិធិ** ។ បណ្តានិធិ ៤ នោះ ទ្រព្យដែលជាប់នឹងផែនដីក្តី ទ្រព្យដែលតាំងនៅក្នុងអាកាសក្តី ប្រាក់ក្តី មាសក្តី ស្រែក្តី ដីធ្លី(ធ្វើផ្ទះ)ក្តី ឬក៏ទ្រព្យដូច្នោះ សូម្បីដទៃណា ដែលវៀរចាកការកម្រើកចាកទីដោយខ្លួនឯង ឈ្មោះថា **ថាវរនិធិ** ។ ទាសី ទាសា ដំរី គោ សេះ លា ពពែ ចៀម មាន់ ជ្រូក ឬក៏ថា ទ្រព្យដូច្នោះ សូម្បីដទៃណា ដែលប្រកបដោយការ

កម្រើកចាកទីដោយខ្លួនឯងបាន ឈ្មោះថា **ជង្គមនិធិ** ។ ពាហុសច្ចៈ ភាពជាពហុស្សូត្រ ដែលជាអណ្តូងកើតការងារ អណ្តូងកើតសិល្បៈ ទីតាំងនៃវិទ្យាការ ឬក៏ថាពាហុសច្ចៈយ៉ាងនោះ សូម្បីវិជ្ជាដទៃដែលសិក្សាហើយសិក្សាទៀត ជំនាញជាប់ខ្លួន ប្រដូចនឹងអវយវៈតូចធំ ឈ្មោះថា **អង្គសមនិធិ** ។ បុណ្យដែលសម្រេចដោយទាន ដែលសម្រេចដោយសីល ដែលសម្រេចដោយភាវនា ដែលសម្រេចដោយការស្តាប់ធម៌ ដែលសម្រេចដោយការសម្តែងធម៌ ឬក៏ថាបុណ្យយ៉ាងដូច្នោះ សូម្បីដទៃណា មានផលដែលគួរឱ្យប្រាថ្នា ហាក់បីដូចជាជាប់តាមទៅក្នុងទីនោះៗ ឈ្មោះថា **អនុគាមិកនិធិ** ។ ចំណែកក្នុងទីនេះទ្រង់បំណងយក **ថាវរនិធិ** ។

បទថា និធេតិ បានដល់ តម្កល់ទុក លាក់ទុក រក្សាទុក ។ បទថា បុរិសោ បានដល់ មនុស្ស ។ បុរសក្តី ស្ត្រីក្តី បណ្ឌកៈក្តី រមែងកប់កំណប់ទ្រព្យបានក៏ពិតមែន ទោះបីដូច្នោះ ក្នុងទីនេះទ្រង់ធ្វើទេសនាដោយបុរសជាសំខាន់ តែថាដោយអត្ថ គប្បីជ្រាបថា ទ្រង់ប្រមូលមនុស្សសូម្បីទាំងអស់នោះទុកក្នុងទីនេះ ។ បទថា គម្ភីរេ ឧទកន្តិកេ សេចក្តីថា ដែលឈ្មោះថា **គម្ភីរៈ** ព្រោះអត្ថថា ស្ទង់ជម្រៅបាន ឈ្មោះថា **ឧទកន្តិកៈ** ព្រោះជា កន្លែងដែលមានទឹកជាទីបំផុត ។ ទីជ្រៅ ប៉ុន្តែ

មិនមានទឹកជាទីបំផុត ក៏មានដូចជាអណ្តូងជម្រៅ ១០០ ជួរបុរសនៅក្នុងផ្ទៃដីខ្ពស់ ។ ទីដែលមានទឹកជាទីបំផុត ប៉ុន្តែមិនជ្រៅក៏មាន ដូចជាអណ្តូងជម្រៅ ១ ហត្ថ ២ ហត្ថ នៅក្នុងកន្លែងរណ្តៅមានភក់ ។ ទាំងទីជ្រៅទាំងមានទឹកជាទីបំផុតក៏មាន ដូចជាអណ្តូងដែលគេជីកនៅក្នុងផ្ទៃដីខ្ពស់ ទាល់តែទឹកប្រាកដហូរមកនៅក្នុងឥឡូវនេះ ។ បទថា គម្ភីរេ ឱទកន្តិកេ នេះ ត្រាស់សំដៅដល់ កន្លែងជ្រៅ និងមានទឹកជាទីបំផុតនោះ ។ បទថា អត្ថេ កិច្ចេ សមុប្បន្នេ មានន័យថា ឈ្មោះថា អត្ថ ព្រោះមិនប្រាសចាកប្រយោជន៍ ។ លោកអធិប្បាយថា នាំមកនូវប្រយោជន៍ នាំមកនូវប្រយោជន៍គាំទ្រ ។ ឈ្មោះថា **កិច្ច** ព្រោះគួរធ្វើ ។ លោកអធិប្បាយថា បានដល់ ករណីណាមួយ ។ ហេតុដែលកើតឡើងហើយនោះឯង ឈ្មោះថា **សមុប្បន្ន** ។ លោកអធិប្បាយថា ដែលកើតឡើងហើយដោយភាពជាកិច្ចគួរធ្វើ ។ កាលបើកិច្ចកើតឡើង ទ្រព្យនេះ នឹងបានជាប្រយោជន៍ ។ បទថា អត្ថាយ មេ ភវិស្សតិ បទនេះដើម្បីសម្តែងនូវប្រយោជន៍នៃកប់ទុក ។ មែនពិត បុរសនោះ កាលកប់កំណប់ទ្រព្យទុកក៏ដើម្បីប្រយោជន៍យ៉ាងនេះថា កាលករណីណាមួយ ដែលនាំមកនូវប្រយោជន៍កើតឡើង កំណប់ទ្រព្យនឹងបានជាប្រយោជន៍ដល់យើង នឹងមានដើម្បីសេចក្តីសម្រេចនៃកិច្ចរបស់យើងនោះ ។ ព្រោះថា សេចក្តីសម្រេច

នៃកិច្ចនោះឯង គប្បីជ្រាបថាជាប្រយោជន៍នៃកំណប់ទ្រព្យនោះ កាលកិច្ចកើតឡើង ។

## ទុតិយគាថាវណ្ណនា

**ពណ៌នាគាថាទី ២**

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងប្រយោជន៍នៃការកប់កំណប់ទ្រព្យយ៉ាងនេះ កាលទ្រង់សម្តែងភាពនៃការបានន្ទូវប្រយោជន៍ ឥឡូវនេះ ដើម្បីទ្រង់សម្តែងភាពនៃការជៀសវាងវត្ថុដែលមិនជាប្រយោជន៍ ទើបទ្រង់ត្រាស់ថា ៖

រាជតោ វា ទុរុត្តស្ស ចោរតោ បីឡិតស្ស វា
ឥណស្ស វា បមោក្ខាយ ទុព្ភិក្ខេ អាបទាសុ វា

កាលដែលត្រូវពួកបច្ចាមិត្រពោលបង្កាច់ នឹងបានដោះខ្លួនចេញពីស្តេច ឬត្រូវចោរបៀតបៀន នឹងបានដោះខ្លួនចេញពីចោរ នឹងបានដោះបំណុល ឬក្នុងពេលទុរ្ភិក្ស ឬក៏ក្នុងកាលអន្តរាយទាំងឡាយ[១] ។

គាថានោះ គប្បីប្រកបសេចក្តី តាមដំណើរស័ព្ទជាមួយនឹងបទថា ភវិស្សតិ បមោក្ខាយ ដែលត្រាស់ក្នុងពាក្យនេះថា អត្ថាយ មេ ភវិស្សតិ និងថា

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៥ ។

**ឥណាស្ស វា បមោក្ខាយ** ទើបនឹងជ្រាបសេចក្ដីបាន ។ ក្នុងសេចក្ដីនោះ មានការប្រកបសេចក្ដីយ៉ាងនេះថា បុរសកប់កំណាប់ទ្រព្យ មិនមែនតែបំណងថានឹងជាប្រយោជន៍ដល់យើងតែម្យ៉ាងប៉ុណ្ណោះទេ ។ គឺមានអ្វីទៀតហ្ន៎! ។ គឺបុរសកប់កំណាប់ទ្រព្យ ក៏ដោយបំណងថានឹងជួយដោះយើងឱ្យរួចផុតពីរាជភ័យ ដែលត្រូវពួកសត្រូវ ក្រុមបច្ចាមិត្ត មួលបង្កាច់ ដោយន័យយ៉ាងនេះថា អ្នកនេះជាចោរខ្លះ ជាសាហាយស្មន់ខ្លះ គេចអំពីការបង់ពន្ធខ្លះ ដូច្នេះជាដើម នឹងជួយដោះយើងរួចផុតពីចោរភ័យ ដែលត្រូវពួកចោរបៀតបៀន ដោយការលួចទ្រព្យដោយវិធីចោះប្រហោងខ្លះ ដោយការចាប់បង្ខំទារតម្លៃថា ឯងចូរឱ្យមាសប្រាក់ប៉ុណ្ណោះៗខ្លះ ។ ម្ចាស់បំណុលនឹងទារឱ្យយើងជម្រះបំណុល ក៏នឹងជួយរំដោះយើងឱ្យផុតពីបំណុលដែលម្ចាស់បំណុលទាំងអស់នោះទារខ្លះ ។ សម័យដែលកើតទុព្ភិក្សភ័យ ស្រូវសំណាបខូច អាហាររកបានដោយលំបាក ក្នុងសម័យនោះ នឹងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយទ្រព្យតិចតួច ដែលធ្វើមិនបាន ដោយស្រួលៗ កំណាប់ទ្រព្យនោះក៏នឹងជួយបានក្នុងគ្រាទុព្ភិក្សភ័យដូច្នោះ ចូលមកដល់ដូច្នេះខ្លះ នឹងជួយបានក្នុងគ្រាទ័លក្រដែលកើតពីអគ្គិភ័យ ឧទកភ័យ ទាយាទដែលមិនជាទីស្រឡាញ់ដូច្នេះខ្លះ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងប្រយោជន៍នៃការទុកដាក់ទ្រព្យ ២ យ៉ាង ដោយគាថានេះ គឺ សេចក្ដីបំណាងដែលនឹងឱ្យជួយប្រយោជន៍ និងសេចក្ដីបំណាង ដែលឱ្យជៀសវាងពីវត្ថុដែលមិនជាប្រយោជន៍យ៉ាងនេះ ហើយឥឡូវនេះ កាលនឹងទ្រង់ត្រាស់បញ្ជាក់ ប្រយោជន៍ទាំង ២ នោះឯងដល់កុដុម្ពិក៍នោះ ទើបត្រាស់ថា ឯតទត្ថាយ លោកស្មឹ និធិ នាម និធិយ្យតិ កំណាប់ទ្រព្យដែលគេកប់ទុកក្នុងលោកក៏ដើម្បីប្រយោជន៍យ៉ាងនេះ ។ គាថានោះ មានសេចក្ដីថា ប្រយោជន៍នេះណា គឺការជួបប្រយោជន៍ និងការជៀសវាងពីវត្ថុ ដែលមិនជាប្រយោជន៍ ទ្រង់សម្ដែងទុកដោយន័យជាដើមយ៉ាងនេះថា នឹងជាប្រយោជន៍ដល់យើង និងថានឹងជួយរំដោះយើងដែលត្រូវមួលបង្កាច់ឱ្យផុតពីរាជភ័យ ។ ធម្មតាកំណាប់ទ្រព្យផ្សេង ពីមាសប្រាក់ជាដើមយ៉ាងណាមួយ គេកប់ទុក តម្កល់ទុករក្សាគ្របទុក ក្នុងឱកាសលោកនេះ ក៏ដើម្បីប្រយោជន៍នោះ គឺដើម្បីធ្វើកិច្ចទាំងអស់ នោះឱ្យសម្រេចបាន ។

## តតិយគាថាវណ្ណនា

## ពណ៌នាគាថាទី ៣

ឥឡូវនេះ ព្រោះហេតុដែលកំណាប់ទ្រព្យនោះ សូម្បីគេកប់ទុកល្អ ហើយយ៉ាងនេះ រមែងឱ្យសម្រេចប្រយោជន៍ដែលប៉ងដល់អ្នកដែលមានបុណ្យប៉ុណ្ណោះ

មិនសម្រេចប្រយោជន៍ដល់អ្នកដទៃដូច្នោះ កាលទ្រង់សម្ដែងប្រយោជន៍ ទើបត្រាស់ថា ៖

តាវស្សុ និហិតោ សន្តោ គម្ភីរេ ឧទកន្តិកេ

ន សព្វោ សព្វទាយេវ តស្ស តំ ឧបកប្បតិ ។

កំណប់ដែលបុគ្គលកប់ ក្នុងទីជ្រៅ មានទីបំផុតទល់នឹងទឹក ដល់ម្ល៉ោះ កំណប់ទ្រព្យទាំងអស់នោះ ក៏មិនសម្រេចដល់បុគ្គលនោះសព្វកាលទេ[១] ។

គាថានោះ មានសេចក្ដីថា សូម្បីកំណប់ទ្រព្យនោះគេកប់ទុកល្អ ដល់ថ្នាក់នោះ លោកអធិប្បាយថា សូម្បីគេជីករណ្ដៅទុកដាក់យ៉ាងល្អ ត្រឹមនោះ គេកប់ទុកល្អយ៉ាងណា ។ គេកប់ទុកក្នុងទីជ្រៅមានទឹកជាទីបំផុត លោកអធិប្បាយថា ល្អដរាប ស្មើនឹងរាប់បានថា កប់ទុកក្នុងទីជ្រៅមានទឹកជាទីបំផុត ។ គន្ធះគាថាថា ន សព្វោ សព្វទាយេវ តស្ស តំ ឧបកប្បតិ មានសេចក្ដីថា កំណប់ទ្រព្យរមែងមិនសម្រេចជាប្រយោជន៍ មិនសម្រេចជាផលទាំងអស់ លោកអធិប្បាយថា មិនអាចធ្វើកិច្ចតាមដែលពោលមកហើយដល់បុរស ដែលកប់ទុកបានគ្រប់វេលា ។ គឺយ៉ាងម៉េចទៅ គឺថាគ្រាខ្លះ សម្រេចជាប្រយោជន៍ គ្រាខ្លះក៏មិនសម្រេច

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទបាឋ លេខ ៥២ ទំព័រ ១៦ ។

ជាប្រយោជន៍ទេ ។ ស័ព្ទថា តំ ក្នុងគាថានោះ គប្បីជ្រាបថាជានិបាត ចុះក្នុងអដ្ឋកថា បទបូរណៈ ធ្វើបទឱ្យពេញ ដូចក្នុងប្រយោគជាដើមយ៉ាង នេះថា យថា តំ អប្បមត្តស្ស អាតាបិនោ ។ ឬថាលោកធ្វើលិង្គ (ភេទ-ស័ព្ទ) ឱ្យផ្សេងគ្នា កាលគួរនឹង ពោលថា សោ ក៏ពោលថា តំ ។ ពិតហើយកាល ពោលយ៉ាងនោះ សេចក្តីនោះ ក៏ដឹងបានស្រួល ។

## ចតុត្ថបញ្ចមគាថាវណ្ណនា

### ពណ៌នាគាថាទី ៤ និងទី ៥

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់ត្រាស់ថា ន សព្វោ សព្វទាយេវ តស្ស តំ ឧបកប្បតិ យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងហេតុ ដែលមិនសម្រេចប្រយោជន៍ ទើបត្រាស់ថា ៖

និធិ វា ឋានា ចវតិ សញ្ញា វាស្ស វិមុយ្ហតិ
នាគា វា អបនាមេន្តិ យក្ខា វាបិ ហរន្តិ នំ
អប្បិយា វាបិ ទាយាទា ឧទ្ធរន្តិ អបស្សតោ ។

ដ្បិតថា កំណប់ទ្រព្យ រមែងឃ្លាតទៅចាកទីខ្លះ សេចក្តីចំណាំរបស់បុគ្គលនោះ រមែងវង្វេងទៅខ្លះ នាគទាំងឡាយ រមែងនាំជញ្ជូនទៅខ្លះ ពុំនោះសោត ពួក

យក្សនាំយកទ្រព្យនោះទៅខ្លះ អ្នកទទួលមត៌កដែលមិនជាទីស្រឡាញ់ រមែងគាស់យកនូវកំណាប់ទ្រព្យនោះ កាលខ្លួនមិនបានឃើញខ្លះ[១] ។

គាថានោះមានសេចក្តីថា កំណាប់ទ្រព្យនោះ កម្រើកចេញទៅចាកទី ដែលគេកប់ទុកល្អហើយ គឺសូម្បីមិនមានចេតនាក៏ទៅទីដទៃបាន ដោយម្ចាស់របស់អស់បុណ្យខ្លះ ។ ការចងចាំរបស់គេភ្លាំងភ្លាត់ គឺគេចាំមិនបាននូវកន្លែង ដែលកប់កំណាប់ទ្រព្យខ្លះ ពួកនាគកាលបើភាពជាអ្នកអស់បុណ្យរបស់ម្ចាស់ទ្រព្យជាស់តឿនហើយ ក៏បំបែកកំណាប់ទ្រព្យនោះ យកទៅទីដទៃខ្លះ ។ ពួកយក្ស លួចនាំយកទៅតាមការពេញចិត្តខ្លះ ។ ពួកទាយាទអ្នកទទួលមត៌ក ដែលមិនចូលចិត្តគ្នា ជីកផែនដីលើកយកកំណាប់ទ្រព្យនោះទៅ កាលគេមិនឃើញខ្លះ ។ កំណាប់ទ្រព្យនោះ មិនសម្រេចប្រយោជន៍ដល់គេ ព្រោះហេតុមានការកម្រើក ចាកទីជាដើមនោះ ដោយប្រការដូច្នេះ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់ត្រាស់ហេតុដែលមិនសម្រេចប្រយោជន៍ដែលលោកសន្មតមានការកម្រើកចាកទីជាដើម យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងហេតុ ដែលនាំគ្នាយល់ថា ការអស់បុណ្យយ៉ាង

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទបាឋ លេខ ៥២ ទំព័រ ១៦ ។

ណាមួយដែលជាមូលហេតុទាំងអស់ ទើបត្រាស់ថា យទា បុញ្ញក្ខយោ ហោតិ សព្វមេតំ វិនស្សតិ កាលបើបុគ្គលអស់បុណ្យទៅវេលាណា កំណប់ទ្រព្យទាំងអស់នោះ រមែងវិនាសបាត់បង់ទៅក្នុងវេលានោះ ។

គាថានោះមានសេចក្តីថា សម័យណា បុណ្យដែលធ្វើភោគៈឱ្យសម្រេចអស់ទៅក៏នឹងធ្វើវត្ថុដែលមិនមែនបុណ្យ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសនៃភោគសម្បត្តិ មានឱកាសតាំងនៅ សម័យនោះ ធនជាតណា មានមាស និងប្រាក់ជាដើម ដែលអ្នកកប់កំណប់ទុកហើយ ធនជាតនោះទាំងអស់ ក៏វិនាសអស់ទៅ ។

## ឆដ្ឋគាថាវណ្ណនា

## ពណ៌នាគាថាទី ៦

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់ត្រាស់អំពីកំណប់ទ្រព្យ ដែលបុគ្គលកប់ទុកហើយ ដោយបំណងនោះៗ តែក៏មិនសម្រេចប្រយោជន៍តាមបំណង សូម្បីលោកសន្មតក៏ត្រូវមានការវិនាសទៅជាធម្មតាដោយប្រការផ្សេងៗ រួចហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងបុញ្ញសម្បទាប៉ុណ្ណោះថា ជាកំណប់ទ្រព្យដោយបរមត្ថ កាលទ្រង់សម្តែងនិធិកណ្ឌសូត្រនេះ ដែលទ្រង់ចាប់ផ្តើម ដើម្បីអនុមោទនាដល់កុដុម្ពិក៍នោះទើបត្រាស់ថា ៖

យស្ស ទានេន សីលេន សញ្ញមេន ទមេន ច
និធិ សុនិហិតោ ហោតិ ឥត្ថិយា បុរិសស្ស វា ។

*កំណប់ទ្រព្យដែលស្ត្រី ឬបុរសណា បានកប់ទុកល្អហើយ ដោយទាន ដោយសីល ដោយការសង្រួម នឹងដោយការទូន្មានខ្លួន ។*

*បណ្តាបទទាំងនោះ បទថា ទានំ គប្បីកាន់យកតាមន័យដែលពោលទុកហើយក្នុងមង្គលសូត្រថា ទានញ្ច ធម្មចរិយា នោះ ។ បទថា សីលំ បានដល់ការមិនកន្លងល្មើសផ្លូវកាយនិងវាចា គឺសីល៥ សីល ៨ សីល ១០ និងបាតិមោក្ខសំវរសីលជាដើម ។ សីលគ្រប់យ៉ាងលោកបំណងយកសីលក្នុងទីនេះ ។ បទថា សញ្ញមោ បានដល់ ការសង្រួម លោកអធិប្បាយថា ការហាមចិត្តទៅក្នុងអារម្មណ៍ផ្សេងៗ ពាក្យនេះ ជាឈ្មោះរបស់សមាធិ ។ បុគ្គលប្រកបព្រមហើយដោយការសង្រួម ឈ្មោះថា សង្រួមខ្ពស់បំផុត ក្នុងព្រះបាលីនេះថា ហត្ថសញ្ញតោ បាទសញ្ញតោ វាចាសញ្ញតោ សញ្ញតុត្តមោ អ្នកដែលសង្រួមដៃ សង្រួមជើង សង្រួមវាចា ឈ្មោះថា អ្នកសង្រួមខ្ពស់បំផុត ។ អាចារ្យមួយពួកទៀត ពោលថា ការសង្រួម លោកអធិប្បាយថា ការប្រយ័ត្ន ការសង្រួម ពាក្យនេះជាឈ្មោះរបស់ឥន្ទ្រិយសំវរៈ ។ ការហ្វឹកហាត់ ឈ្មោះថា ទម លោកអធិប្បាយ*

ថា ការរម្ងាប់កិលេស ពាក្យនេះជាឈ្មោះរបស់បញ្ញា ។ មែនពិត បញ្ញាក្នុងបាលីកន្លែងខ្លះហៅថា **បញ្ញា** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា សុស្សូសំ លភតេ បញ្ញំ ស្ដាប់ដោយគោរព ជាអ្នកមិនប្រមាទ មានបញ្ញាពិចារណា រមែងបាននូវប្រាជ្ញា[១] ។ កន្លែងខ្លះលោកហៅថា **ធម្មៈ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា សច្ចំ ធម្មោ ធិតិ ចាគោ សច្ចៈ ធម្មៈ (បញ្ញា) ធិតិ (ព្យាយាម) ចាគៈ (ការបរិច្ចាគ)[២] ។ ក្នុងកន្លែងខ្លះលោក ហៅថា **ទមៈ** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា យទិ សច្ចា ទមា ចាគា ខន្ត្យាភិយ្យោ ន វិជ្ជតិ បើមានធម៌ដទៃទៀត ក្នុងលោកនេះ ឱ្យក្រៃលែងជាងសច្ចៈ ទមៈ ចាគៈ ខន្តិ ទៅទៀត[៣] ។

បណ្ឌិតស្គាល់ទានជាដើមយ៉ាងនេះហើយ គប្បីប្រមូលមក ដោយជ្រាបសេចក្ដីនៃគាថានេះ យ៉ាងនេះថា កំណប់ទ្រព្យដែលសម្រេចដោយបុណ្យរបស់បុគ្គលណា ដែលជាស្រីក៏ដោយ ប្រុសក៏ដោយ គេនឹងយកធម៌ ៤ ពួកនេះគឺ ទាន សីល សញ្ញមៈ ទមៈ ដែលកប់ទុកល្អហើយ ដោយការប្រព្រឹត្តនូវធម៌ទាំង ៤ មានទានជាដើមនោះទុកដោយល្អ ក្នុងសន្ដានចិត្តតែមួយ ឬក្នុងវត្ថុមានចេតិយជាដើម

---

១-២-៣-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ៦៣-៦៤ ។

ដូចកំណប់ទ្រព្យដែលសម្រេចអំពីធនជាត គេក៏យក ប្រាក់ មាស មុក្តា មណី កប់ទុក ដោយការដាក់មាសប្រាក់ជាដើមនោះ ចុះក្នុងកន្ទែងតែមួយ ជាមួយគ្នាដូច្នោះ ។

សត្តមគាថាវណ្ណនា

**ពណ៌នាគាថា ទី ៧**

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងអំពីបុញ្ញសម្បទា ជាកំណប់ទ្រព្យដោយបរមត្ថ ដោយគាថានេះថា យស្ស ទានេន ជាដើម យ៉ាងនេះហើយ កាលទ្រង់សម្តែងអំពីវត្ថុកំណប់ទ្រព្យដែលបុគ្គលកប់ទុកហើយ ឈ្មោះថា កប់ទុកយ៉ាងល្អ ទើបត្រាស់ថា ៖

ចេតិយម្ហិ ច សង្ឃេ វា បុគ្គលេ អតិថីសុ វា
មាតរិ បិតរិ វាបិ អថោ ជេដ្ឋម្ហិ ភាតរិ ។

(ទ្រព្យដែលបុគ្គលគប់ទុកដោយល្អ) ក្នុងចេតិយ ឬក្នុងសង្ឃ ឬក្នុងបុគ្គល ឬក្នុងពួកភ្ញៀវ ឬមួយក្នុងមាតា ក្នុង បិតា ឬថា ក្នុងបងប្រុស-ស្រីដែលច្បង[១] (ឈ្មោះថាគប់ទុកល្អហើយ)។

ក្នុងគាថានោះ ឈ្មោះថា ចេតិយ ព្រោះគួរកសាង លោកអធិប្បាយថា គួរបូជា ។ ឈ្មោះថា ចេតិយ ព្រោះវិចិត្រហើយ ។ ចេតិយ នោះមាន ៣ យ៉ាងគឺ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៦ ។

***បរិភោគចេតិយ ឧទ្ទិសកចេតិយ ធាតុចេតិយ*** ។ បណ្ដាចេតិយទាំង ៣ នោះ ដើមពោធិព្រឹក្ស ឈ្មោះថា ***បរិភោគចេតិយ*** ។ ព្រះពុទ្ធបដិមា ឈ្មោះថា ***ឧទ្ទិសកចេតិយ*** ។ ព្រះបរមសារីរិកធាតុ ឈ្មោះថា ***ធាតុចេតិយ*** ។ បទថា សង្ឃេ បានដល់ បុគ្គលណាម្នាក់ក្នុងក្រុមសង្ឃ ដែលមានព្រះពុទ្ធជាម្ចាស់ជាប្រធាន ។ បទថា បុគ្គលោ បានដល់ អ្នកណាម្នាក់ ក្នុងក្រុមគ្រហស្ថ និងបព្វជិតជាដើម ។ ឈ្មោះថា អតិថិ (ភ្ញៀវ) ព្រោះគេមិនមានតិថីគឺ មកក្នុងថ្ងៃណាក៏បាន ពាក្យនេះជា ឈ្មោះរបស់ភ្ញៀវ ដែលមកក្នុងខណៈនោះ ។ ពាក្យដ៏សេសមានន័យដូចដែលពោលទុកហើយទាំងអស់នោះ ។

បណ្ឌិតស្គាល់ចេតិយជាដើមយ៉ាងនេះហើយ ឥឡូវនេះ គប្បីជ្រាប សេចក្ដីនៃគាថានេះយ៉ាងនេះ កំណប់ទ្រព្យនោះទ្រង់ត្រាស់ថា ជាការកប់ទុកល្អហើយ ព្រោះហេតុដូចម្ដេច ព្រោះអាចអំណោយផល ដែលគួរឱ្យប្រាថ្នាបានអស់កាលយូរ ។ ពិតដូច្នោះ ជនទាំងឡាយថ្វាយក្នុងព្រះចេតិយសូម្បីបន្តិចបន្តួច រមែងជាអ្នកបានផលដែលគួរប្រាថ្នាអស់កាលយូរ ដូចដែលទ្រង់ត្រាស់ទុកថា៖

ឯកបុប្ផំ យជិត្វាន អសីតិកប្បកោដិយោ
ទុគ្គតឹ នាភិជានាមិ បុប្ផទានស្សិទំ ផលំ

តថាគត ថ្វាយផ្កាឈើតែមួយទងប៉ុណ្ណោះ ក៏មិនដែលស្គាល់ទុគ្គតិដល់ទៅ ៨០ កោដិកប្ប នេះជាផលនៃការថ្វាយផ្កាឈើ ។ និងព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់សម្ដែងថា៖

មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ ។

បើបុគ្គលគប្បីឃើញសុខដ៏ធំទូលាយ ព្រោះលះសុខមានប្រមាណតិចចេញ[១] ។

គប្បីជ្រាបការចែកផលទាន សូម្បីក្នុងវត្ថុមានព្រះសង្ឃជាដើម តាមន័យដូចដែលពោលទុកហើយក្នុងទក្ខិណាវិសុទ្ធិសូត្រ និងវេលាមសូត្រជាដើម ដោយប្រការដូច្នេះ ។ម្យ៉ាងទៀត ទ្រង់សម្ដែងការប្រព្រឹត្តទៅ និងសេចក្ដីចម្រើនផលនៃទាន ក្នុងវត្ថុមានចេតិយជាដើមដោយប្រការណា ក៏គប្បីប្រារព្ធគុណនោះៗ ក្នុងទីទាំងពួងតាមសេចក្ដីប្រកបហើយ ទើបជ្រាបការប្រព្រឹត្តិទៅ និងសេចក្ដីចម្រើនផលនៃសីល ដោយអំណាចនៃចារិតសីល និងវារិតសីល, ជ្រាបការប្រព្រឹត្តិទៅ និងសេចក្ដីចម្រើនផលនៃសញ្ញម: ដោយអំណាចនៃពុទ្ធានុស្សតិជាដើម, និងជ្រាបការប្រព្រឹត្តិទៅ ព្រមទាំងសេចក្ដីចម្រើននៃទម: ដោយអំណាចនៃវិបស្សនាមនសិការ: និងបច្ចវេក្ខណ:ក្នុងវត្ថុនោះ ដោយប្រការយ៉ាងនេះ ។

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ គាថាធម្មបទ លេខ ៥២ ទំព័រ ៨១ ។

អដ្ឋមគាថាវណ្ណនា

**ពណ៌នាគាថា ទី ៨**

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងវត្ថុផ្សេងគ្នាដោយចេតិយជាដើមនៃកំណាប់ទ្រព្យដែលសម្រេចដោយបុណ្យ ដែលគេកប់ទុក ដោយទានជាដើមយ៉ាងនេះហើយ ឥឡូវនេះកាលទ្រង់សម្តែង សេចក្តីផ្សេងគ្នានៃកំណាប់ទ្រព្យនោះ ដែលគេកប់ក្នុងវត្ថុទាំងអស់នោះ ពីកំណាប់ទ្រព្យ ដែលកប់ក្នុងទីដ៏ជ្រៅ មានទឹកជាទីបំផុត ទើបត្រាស់ថា ៖

ឯសោ និធិ សុនិហិតោ អជេយ្យោ អនុគាមិកោ
បហាយ គមនីយេសុ ឯតំ អាទាយ គច្ឆតិ ។

កំណាប់ទ្រព្យនុ៎ះ ចាត់ជាកំណាប់ទ្រព្យដែលកប់ទុកប្រពៃហើយ នរណាៗមិនគប្បីផ្ចាញ់បានជាកំណាប់ទ្រព្យ ដែលជាប់តាមខ្លួនទៅ កាលភោគៈទាំងឡាយដែលខ្លួនត្រូវលះបង់ហើយទៅ ខ្លួនរមែងយកនូវកំណាប់ទ្រព្យគឺបុណ្យនុ៎ះទៅ[១] ។

ក្នុងគាថានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សម្តែងអំពីកំណាប់ទ្រព្យដែលកប់ទុកល្អហើយដោយទានជាដើមនោះ ដោយបទដើមថា កំណាប់ទ្រព្យ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៦ ។

ដែលគេកប់ទុកហើយនោះ ។ បទថា អជេយ្យ បានដល់ អ្នកដទៃមិនអាច បំផ្លាញហើយយកទៅបាន ។ បាលីថា អជយ្យោ ក៏មាន ។ អធិប្បាយថា ដែល នរណាៗ មិនគប្បីឈ្នះ មិនគួរឈ្នះ គឺអ្នកដែលត្រូវការប្រយោជន៍សុខគួរបង្កើត ឡើងដោយខ្លួនឯង ។ ក៏ក្នុងបាលីនេះ ទ្រព្យនេះ នរណាៗ បំផ្លាញមិនបាន ហើយ សម្តែងពាក្យសួរទៀតថា ព្រោះហេតុអ្វី ទើបសម្ពន្ធសេចក្តីថា ព្រោះហេតុនៃ កំណប់ទ្រព្យដែលកប់ទុកល្អហើយ រមែងជាប់តាមទៅបាន ។ ប៉ុន្តែសេចក្តីនៃ កំណប់ទ្រព្យដែលកប់ទុកល្អហើយ ដោយប្រការក្រៅអំពីនេះ ជារបស់ដែល នរណាៗឈ្នះបាន ក៏គប្បីជ្រាបដូចដែលលោកពោលទុកហើយ ក៏ប៉ុន្តែ មិនបាន ពោលទុកទៀតទេ ។ មែនពិត កំណប់ទ្រព្យនោះដែលកប់ទុកល្អហើយ ដែល នរណាៗ យកឈ្នះមិនបាន គឺមិនមាននរណាយកឈ្នះបានទេ ។ កំណប់ទ្រព្យ ឈ្មោះថា **អនុគាមិកៈ** ព្រោះជាប់តាមទៅបាន អធិប្បាយថា មិនលះបង់បុគ្គលនោះ ទោះបីជាកំពុងទៅបរលោក ដោយការឱ្យផលក្នុងភពនោះៗ ។

បានឮថា បទថា បហាយ គមនីយេសុ ឯតំ អាទាយ គច្ឆតិ នេះ មាន សេចក្តីយ៉ាងនេះថា ពេលមរណកាលប្រាកដឡើង បណ្តាភោគៈទាំងឡាយ គឺត្រូវ តែលះបង់ទៅ គេក៏នាំទៅបានតែកំណប់ទ្រព្យ គឺបុណ្យនេះ ។ សេចក្តីនេះមិនត្រូវ

ព្រោះហេតុអ្វី ព្រោះភោគៈទាំងឡាយទៅមិនបាន ការពិតភោគៈនោះៗ ដែលមច្ចុអ្នកដែលត្រូវស្លាប់ គប្បីលះទៅប៉ុណ្ណោះ ទៅមិនបានទេ ប៉ុន្តែគតិវិសេសនោះៗ ឯណោះទៅវិញទេ ចាំបាច់ត្រូវទៅ ។ ព្រោះហេតុនៃសេចក្តីគប្បីមានយ៉ាងនេះ សោត ក៏គប្បីពោលបានថា បណ្តាគតិវិសេសទាំងឡាយដែលចាំបាច់ត្រូវលះភោគៈទាំងឡាយទៅដូច្នោះ ទើបគួរជ្រាបសេចក្តីក្នុងសេចក្តីនេះថា កាលភោគៈទាំងឡាយ ត្រូវតែលះមច្ចុអ្នកដែលស្លាប់ទៅ ដោយប្រការជាដើមយ៉ាងនេះថា និធិ វា ឋានា ចវតិ កំណប់ទ្រព្យកម្រើកទៅចាកទីខ្លះ មច្ចុអ្នកដែលត្រូវស្លាប់ក៏នាំទៅបានតែកំណប់ទ្រព្យគឺបុណ្យ ព្រោះថា កំណប់ទ្រព្យ គឺបុណ្យនោះ មិនលះមច្ចុនោះ ព្រោះជាទ្រព្យជាប់តាមទៅបាន ។

ក្នុងគាថានោះ អ្នកដែលជំទាស់ពោលថា ក្នុងបទថា គមនីយេសុ នេះ គប្បីមានសេចក្តីថា គន្តព្វេសុ មិនមែនសេចក្តីថា គច្ឆន្តេសុ ពាក្យនោះ មិនគប្បីកាន់យកដោយចំណែកតែមួយទេ ។ មានសេចក្តីអធិប្បាយថា តែងចេញទៅ ដូចក្នុងពាក្យថា អរិយា និយ្យានិកា នេះ មិនមែនពាក្យថា និយ្យាតព្វា ទេ យ៉ាងណា សូម្បីសេចក្តីថា គច្ឆន្តេសុ មិនមែនមានសេចក្តីថា គន្តព្វេសុ ក៏ដូចគ្នាដែរ ។

ម្យ៉ាងទៀត ព្រោះហេតុដែលអ្នកនេះ បំណងនឹងឱ្យដល់នរណាៗ ក្នុងវេលា

ជិតស្លាប់ក៏ចាប់ភោគៈឱ្យមិនបាន ដូច្នោះភោគៈនោះ ដែលគេចាំបាច់ត្រូវលះបង់ទៅតាមផ្លូវកាយមុន ខាងក្រោយមក ទើបចាំបាច់ត្រូវបរិច្ចាគ ទៅតាមផ្លូវចិត្ត ដែលអស់សង្ឃឹម លោកអធិប្បាយថា គប្បីកន្លងហួសទៅ ។ ព្រោះដូច្នោះ ទើបគួរជ្រាបសេចក្តីក្នុងទីនេះ យ៉ាងនេះថា បណ្តាភោគៈទាំងឡាយចាំបាច់ត្រូវលះទៅតាមផ្លូវកាយមុន ទើបត្រូវលះទៅតាមផ្លូវចិត្តជាខាងក្រោយ ។ ក្នុងសេចក្តីខាងដើម សត្តមីវិភត្តិ ចុះក្នុងនិទ្ធារណៈថា បណ្តាភោគៈទាំងឡាយ ដែលចាំបាច់ត្រូវលះទៅ គេក៏នាំភោគ គឺបុញ្ញនិធិ នោះតែម្យ៉ាងប៉ុណ្ណោះ ចេញចាកភោគៈទាំងឡាយហើយនាំទៅ ។ ក្នុងសេចក្តីខាងក្រោយ សត្តមីវិភត្តិ ចុះក្នុងភាវលក្ខណៈដោយភាវៈថា ដោយភាវៈដែលភោគៈទាំងឡាយ ជាប់តាមទៅក៏រមែងកំណត់ភាវៈ គឺកំណត់ទ្រព្យនាំទៅផងបាន ។

## នវមគាថាវណ្ណនា

## **ពណ៌នាគាថា ទី ៩**

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងសេចក្តីផ្សេងគ្នានៃបុញ្ញនិធិនេះពីកំណប់ទ្រព្យដែលគេកប់ទុកក្នុងទីជ្រៅ មានទឹកជាទីបំផុត កាលទ្រង់ញ៉ាំងសេចក្តីឧស្សាហ៍ឱ្យកើតឡើងដល់ទេវតា និងមនុស្សទាំងឡាយ ក្នុងបុញ្ញនិធិនោះដោយការពណ៌នាគុណបុញ្ញនិធិ ដែលទ្រង់សម្តែងដោយព្រះអង្គទៀត ដូចឈ្មួញ

ដែលលក់ទំនិញដ៏សម្បើម ញ៉ាំងសេចក្តីឧស្សាហ៍ឱ្យកើតឡើងដល់អ្នកទិញ ដោយការពណ៌នាគុណនៃទំនិញរបស់ខ្លួន ដូច្នោះទើបត្រាស់ថា ៖

អសាធារណមញ្ញេសំ អចោរហរណោ និធិ ។

កយិរាថ ធីរោ បុញ្ញានិ យោ និធិ អនុគាមិកោ ។

កំណប់ទ្រព្យ គឺបុណ្យ មិនទូទៅ ដល់ពួកជនដទៃ ជារបស់ដែលចោរលួចទៅមិនបាន ។ កំណប់ទ្រព្យ គឺបុណ្យណាជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញគួរធ្វើនូវកំណប់ទ្រព្យ គឺបុណ្យនោះ[១] ។

បណ្តាបទទាំងនោះ បទថា អសាធារណមញ្ញេសំ ប្រែថា មិនទូទៅដល់ជនពួកដទៃ ។ ម អក្សរ ធ្វើបទសន្ធិ ដូចក្នុងប្រយោគជាដើមថា អទុក្ខម-សុខាយ វេទនាយ សម្បយុត្តា ប្រកបដោយវេទនាដែលមិនមែន ទុក្ខមិនមែនសុខ ។ **និធិ** ដែលចោរទាំងឡាយលួចយកទៅមិនបាន ឈ្មោះថា អចោរ-ហរណោ ។ អធិប្បាយថា រមែងជានិធិដែលចោរទាំងឡាយលួចយកទៅមិនបាន ។ ឈ្មោះថា និធិ ព្រោះគេកប់ទុក ។ ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់ពណ៌នាគុណរបស់បុញ្ញនិធិ ដោយពីរបទដើមយ៉ាងនេះហើយ ពីនោះក៏ទ្រង់ញ៉ាំង

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៧ ។

សេចក្ដីឧស្សាហ៍ឱ្យកើតបុញ្ញនិធិនោះ ដោយពីរបទក្រោយទើបត្រាស់ថា កាយិកាដ ធីរោ បុញ្ញានិ យោ និធិ អនុគាមិកោ កំណប់ទ្រព្យ គឺបុណ្យណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញគួរធ្វើនូវកំណប់ទ្រព្យ គឺបុណ្យនោះ ។ គាថានោះមានសេចក្ដីថា ព្រោះហេតុជាធម្មតា បុញ្ញនិធិមិនសាធារណៈដល់ជនពួកដទៃ និងជានិធិដែលចោរលួចទៅមិនបាន ។ ប៉ុន្តែ ក៏មិនមែននិធិដែលមិនសាធារណៈ និងចោរលួចទៅមិនបានតែម្យ៉ាងទេ ការពិតទៅជានិធិដែលទ្រង់ត្រាស់ទុកយ៉ាងនេះថា និធិនោះកប់ទុកល្អហើយ សូម្បីនរណាៗបំផ្លាញក៏មិនបាន ជាប់តាមខ្លួនទៅបាន ។ និធិណាជាប់តាមខ្លួនទៅបាន ព្រោះហេតុដែលនិធិនោះ ជាបុញ្ញនិធិតែម្យ៉ាងដូច្នោះ អ្នកប្រាជ្ញ គឺបុគ្គលដែលដល់ព្រមដោយពុទ្ធិ ដល់ព្រមដោយធិតិ គឺបញ្ញា គប្បីបំពេញនូវបុណ្យទាំងឡាយ ។

## ទសមគាថាវណ្ណនា

## ពណ៌នាគាថា ទី ១០

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់ញ៉ាំងសេចក្ដីឧស្សាហ៍ឱ្យកើតឡើងដល់ទេវតា និងមនុស្សទាំងឡាយក្នុងបុញ្ញនិធិ ដោយការពណ៌នាគុណយ៉ាងនេះហើយ ឥឡូវនេះ ជនពួកណាញ៉ាំងឧស្សាហ៍ឱ្យកើត ហើយធ្វើឧស្សាហ៍នោះឱ្យ

សម្រេចផល ដោយការធ្វើបុញ្ញនិធិៗរបស់ជនទាំងអស់នោះ រមែងឱ្យផលយ៉ាងណា កាលទ្រង់សម្តែងផលនោះដោយសង្ខេប ទើបត្រាស់ថា ៖

ឯស ទេវមនុស្សានំ សព្វកាមទទោ និធិ ។

កំណាប់ គឺបុណ្យនុ៎ះ ឱ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងដល់ទេវតានឹងមនុស្សទាំងឡាយ ។

ឥឡូវនេះ ព្រោះហេតុដែលបុញ្ញនិធិទាក់ទងដោយសេចក្តីប្រាថ្នា គ្រឿងឱ្យសម្រេចវត្ថុតាមប្រាថ្នា ទើបនឹងវៀរសេចក្តីប្រាថ្នាចេញមិនបាន ដូចដែលព្រះដ៏-មានព្រះភាគត្រាស់ទុកថា ៖

“ម្នាលគហបតិទាំងឡាយ បុគ្គលប្រព្រឹត្តិស្មើ ពោលគឺប្រព្រឹត្តិតាមធម៌ បើប្រាថ្នាថា ឱ!ខ្លួនអាត្មាអញ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឱ្យបានទៅកើតជាមួយនឹងពួកខត្តិយមហាសាល ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ លុះទម្លាយរាងកាយខាងមុខ បន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកខត្តិយមហាសាលមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តិស្មើ ពោលគឺប្រព្រឹត្តិតាមធម៌[១]។

“បុគ្គលសម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈដោយ

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២២ ទំព័រ ២៥០ ។

ប្រាជ្ញាចំពោះខ្លួនឯងក្នុងបច្ចុប្បន្ននេះ ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបាន សម្រេច ព្រោះថា បុគ្គលនោះនឹងអស់អាសវៈទាំងឡាយ ហើយធ្វើឱ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិដែលមិនមានអាសវៈ ដោយប្រាជ្ញាចំពោះខ្លួន ឯងក្នុងបច្ចុប្បន្នមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្តិស្មើ ពោលគឺប្រព្រឹត្តិតាមធម៌"(១) ។

ពិតយ៉ាងនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ជាដើមយ៉ាងនេះថា ៖

"ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកប្រកបប្រកបសទ្ធា ប្រកបដោយសីលៈ ប្រកបដោយសុតៈ ប្រកបដោយចាគៈ ប្រកបដោយបញ្ញា ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញ លុះដល់រំលាងខន្ធ បន្ទាប់ អំពីមរណៈទៅសូមឱ្យទៅកើតជាមួយនឹងពួកខត្តិយមហាសាល ។ ភិក្ខុនោះ តម្កល់ ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះទុក ។ ធម៌ទាំង ៥ មាន សទ្ធាជាដើម នោះ ឈ្មោះថា សង្ខារផង ឈ្មោះថា វិហារធម៌ផង ដែលភិក្ខុនោះ ចម្រើនហើយ យ៉ាងនេះ ធ្វើឱ្យរឿយៗ ហើយយ៉ាងនេះ តែងប្រព្រឹត្តទៅដើម្បីកើតជាមួយនឹង ខត្តិយមហាសាលនោះមែន ។ ម្នាលភិក្ខុទាំងឡាយ នេះផ្លូវ នេះបដិបទា ប្រព្រឹត្តទៅ

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២២ ទំព័រ ២៥៣ ។

ដើម្បីកើតជាមួយនឹងខត្តិយមហាសាលនោះ[១] ។

ព្រោះដូច្នោះ កាលទ្រង់សម្ដែងបរិយាយនៃសេចក្ដីប្រាថ្នាយ៉ាងនោះៗ សេចក្ដីប្រាថ្នាដែលមានអធិដ្ឋានការនៅ ដោយការតាំងចិត្តជាបរិក្ខារ ហេតុក្នុងកាលដែលបុញ្ញនិធិនោះ ឱ្យផលដែលគួរឱ្យប្រាថ្នាគ្រប់យ៉ាងនោះ ទើបត្រាស់ថា ៖

**យំ យំ ទេវាភិបត្ថេន្តិ សព្វមេតេន លព្ភតិ** ពួកទេវតា នឹងមនុស្សទាំងឡាយប្រាថ្នាណាស់នូវផលណាៗ ផលទាំងពួងនោះ ៗ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។

## ឯកាទសមគាថាវណ្ណនា

## ពណ៌នាគាថា ទី ១១

ឥឡូវនេះ ផលគ្រប់យ៉ាងនោះ ដែលទេវតា និងមនុស្ស រមែងបានដោយបុញ្ញនិធិនោះ កាលទ្រង់សម្ដែងផលនោះជាចំណែកៗ ទើបត្រាស់គាថាយ៉ាងនេះថា ការមានវណ្ណៈល្អ ការមានសំឡេងពីរោះជាដើម ។

បណ្ដាគាថាទាំងអស់នោះ នឹងវិនិច្ឆ័យក្នុងគាថាទី ១ សិនថា **សុវណ្ណតា** ភាពជាអ្នកមានពណ៌សម្បុរល្អ ការមានសម្បុរស្បែកស្រដៀងមាសឈ្មោះថា ការមានវណ្ណៈល្អនោះ បុគ្គលរមែងបានដោយបុញ្ញនិធិនោះ ។ ដូចដែលព្រះមានព្រះភាគ ត្រាស់ទុកថា៖

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ លេខ ២៦ ទំព័រ ៤០១-៤០២ ។

*"ម្នាលភិក្ខុទាំងឡាយ កាលតថាគត (អាស្រ័យ)នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកមិនមានសេចក្ដីក្រោធ មិនច្រើនដោយសេចក្ដីចង្អៀតចង្អល់ចិត្ត សូម្បីជនច្រើនអ្នកនាំគ្នាស្ដីថាឱ្យ ក៏មិនឈឺចិត្ត មិនក្រោធ មិនចងកំហឹងទុក មិនតម្កល់ទុកនូវសេចក្ដីក្រោធ ទាំងមិនបានធ្វើនូវសេចក្ដីក្រោធ នូវប្រទូស និងសេចក្ដីតូចចិត្តឱ្យប្រាកដឡើង (ដោយកាយវិការ ឬវចីវិការ)ឡើយ ព្រះតថាគតជាអ្នកបានឱ្យនូវកម្រាល និងសំពត់ដណ្ដប់មានសាច់ល្អិតទន់ល្មៃ គឺសំពត់ធ្វើពីសម្បកឈើមានសាច់ម៉ដ្ឋ សំពត់ធ្វើពីកប្បាសមានសាច់ម៉ដ្ឋ សំពត់ធ្វើពីសូត្រមានសាច់ម៉ដ្ឋ សំពត់ធ្វើពីរោមសត្វមានសាច់ម៉ដ្ឋ ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំនូវកុសលកម្មនោះ ។ល។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានពណ៌សម្បុរ (លឿងភ្លឺបំព្រង) ដូចជាសម្បុរនៃមាសនឹងមានស្បែកស្អិទល្អ ដូចជាមាស"[១] ។ ភាពជាអ្នកមានសម្ដេង ដូចព្រហ្ម ភាពជាអ្នកនិយាយសំឡេងដូច សត្វករវិកឈ្មោះថាភាពជាអ្នកមានសំឡេងពីរោះ ភាពជាអ្នកមានសំឡេងពីរោះយ៉ាងនោះ ដែលបុគ្គលរមែងបានក៏ដោយបុញ្ញនិធិនេះ ដូចដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ៖*

---

*១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ៣១ ។*

“ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ)នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកបានលះបង់នូវផរុសវាចា វៀរស្រឡះហើយចាកផរុសវាចា ជាអ្នកនិយាយតែពាក្យដែលឥតទោស ពាក្យដែលជាសុខដល់ត្រចៀកគេ គួរឱ្យស្រឡាញ់ គួរឱ្យតាំងទុកក្នុងហឫទ័យ ជាសំដីអ្នកក្រុង ទាំងជាទីស្រឡាញ់នៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកសាងនូវកុសលកម្មនោះ ។ល។ លុះព្រះតថាគតនោះច្យុតចាកឋាននោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានអណ្តាតវែង ១ មានសូរស័ព្ទសំឡេងក្រាងក្រឪ ដូចជាសំឡេងព្រហ្ម កាលបើបញ្ចេញវាចាលាន់ឮពីរោះ ដូចជាសំឡេងសត្វករវិក ១”[១] ។

បទថា សុសណ្ឋានា បានដល់ ការមានទ្រង់ទ្រាយល្អ លោកអធិប្បាយថា ការស្ថិតនៅនៃអវយវៈតូចធំ ក្នុងទីដែលគួរពេញ និងមូល ដោយភាពជាអវយវៈដែលពេញ និងមូល ដូចដែលព្រះមានព្រះភាគត្រាស់ថា ៖

“ម្នាលភិក្ខុទាំងឡាយ កាលតថាគត(អាស្រ័យ)នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីសុខ ប្រាថ្នានូវសេចក្តីក្សេមក្សាន្តចាកយោគៈ ដល់ពួកជនច្រើន ធ្វើដូចម្តេចជនទាំងនេះ នឹងបានចម្រើនដោយសទ្ធា ចម្រើនដោយ-

១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ៥៥-៥៦ ។

សីល ចម្រើនដោយសុតៈ ចម្រើនដោយវុឌ្ឍិ ចម្រើនដោយចាគៈ ចម្រើនដោយលោកិយធម៌ ចម្រើនដោយប្រាជ្ញា ចម្រើនដោយទ្រព្យ និងធញ្ញាហារ ចម្រើនដោយស្រែ និងចម្ការ ចម្រើនដោយសត្វជើង ២ និងសត្វជើង ៤ ចម្រើនដោយកូននិងប្រពន្ធ ចម្រើនដោយពួកបុរសជាទាសៈនិងកម្មករ ចម្រើនដោយពួកញាតិ ចម្រើនដោយពួកមិត្ត ចម្រើនដោយពួកផៅពង្ស ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកុសលកម្ម ។ល។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះមកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំង ៣ នេះគឺ មានចំណែកកន្ទះកាយខាងលើ ស្រដៀងនឹងចំណែកកន្ទះកាយនៃរាជសីហ៍ ១ មានខ្នងពេញលើឥតមានចង្អូរខ្នងត្រង់កណ្តាល ១ មាន-កមូលសម ១”[១] ។

បទនៃព្រះសូត្រទាំងឡាយ ដែលធ្វើឱ្យការបានសម្រេចដោយ បុញ្ញនិធិនេះ សូម្បីក្នុងទីដទៃអំពីនេះ ក៏គប្បីនាំមកអំពីទីនោះៗ ពោលដោយន័យនេះ ។ តែព្រោះខ្លាចពិស្តារលើសទៅ ទើបបានជាសង្ខេប ឥឡូវនេះ ខ្ញុំនិងធ្វើការពណ៌នាបទដ៏សេស ។

ទូទាំងរាងកាយគប្បីជ្រាបថា **រូប** ក្នុងពាក្យថា **សុរូបតា** នេះ ។ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា “អាកាសមានរូបរួមជាមួយគ្នាហើយ ទើបហៅថា

---

១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ៣៩-៤០ ។

រូបបាន"ដូច្នេះឯង[១] ។ ភាពដែលរូបនោះល្អ ឈ្មោះថា ភាពដែលរូបស្អាត លោកអធិប្បាយថា មិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិនសពេក ។ បទថា អាធិបច្ចំ បានដល់ ភាពជាធំ អធិប្បាយថា ភាពជានាយ ដោយជាក្សត្រមហាសាលជាដើម ។ បទថា បរិវារោ បានដល់ សម្រាប់គ្រហស្ថ សម្បត្តិ គឺជនរបស់ខ្លួន និងជនដោយជុំវិញ សម្រាប់បព្វជិត សម្បត្តិគឺបរិស័ទ ។ ភាពជាធំ និងភាពមានបរិវារ ឈ្មោះថា ភាពជាធំ និងមានបរិវារ ។ ក៏បណ្ដាឥដ្ឋផលទាំងនោះ គប្បីជ្រាបថា សិរីសម្បត្តិ ត្រាស់ដោយភាពជាអ្នកមានសម្បុរស្អាតជាដើម សម្បត្តិ គឺភោគៈ ត្រាស់ដោយភាពជាធំ សម្បត្តិ គឺជនរបស់ខ្លួន និងជនដោយជុំវិញ ត្រាស់ដោយភាពជាអ្នកមានបរិវារ ។ ដោយបទថា សព្វមេតេន លព្ភតិ ព្រះដ៏មានព្រះភាគជាម្ចាស់រមែងទ្រង់ ត្រាស់សម្ដែងថា ពាក្យនោះបានត្រាស់ថា ទេវតា និងមនុស្សទាំងឡាយ ប្រាថ្នាផលណាៗ ផលនោះៗទាំងអស់ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ ក្នុងពាក្យនោះ ឥដ្ឋ-ផល ភាពជាអ្នកមានវណ្ណៈស្អាតជាដើម ដែលត្រាស់ទុកចំណែកដំបូងសូម្បីនេះ គប្បីជ្រាបថា ផលទាំងអស់នោះ បុគ្គលបានដោយបុញ្ញនិធិនេះ ។

---

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២១ ទំព័រ ២១១ ។

## ធ្វានសមគាថាវណ្ណនា

### ពណ៌នាគាថាទី ១២

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងសម្បត្តិរបស់ទេវតា និងមនុស្ស ដែលទាបជាងសម្បត្តិគឺភាពជាព្រះរាជា ដែលបុគ្គលគប្បីបានដោយបុញ្ញានុភាព ដោយគាថានេះយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងសម្បត្តិ គឺភាពជាព្រះរាជាទាំងពីរនោះ ទើបត្រាស់គាថានេះថា ៖

"បទេសរជ្ជំ ឥស្សរិយំ ចក្កវត្តិសុខំ បិយំ

ទេវរជ្ជម្បិ ទិព្វេសុ សព្វមេតេន លព្ភតិ ។

ភាពជាស្តេចប្រទេសរាជ ឥស្សរិយយស សេចក្តីសុខរបស់ស្តេចចក្រពត្តិជាទីស្រឡាញ់ ភាពជាស្តេចនៃទេវតា ក្នុងទេពនិកាយទាំងឡាយផលទាំងអស់រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ[១] ។

បណ្តាបទទាំងនោះ បទថា បទេសរជ្ជំ បានដល់ ភាពជាព្រះរាជានៃប្រទេសក្នុងប្រទេសមួយៗ សូម្បីតែទ្វីបមួយមិនដល់ទាំងអស់ ។ ភាពជាព្រះរាជាដែលជាធំ ឈ្មោះថា **ឥស្សរិយៈ** ។ ទ្រង់សម្តែងភាពជាស្តេចចក្រពត្តិ ដោយបទនេះ ។ សុខរបស់ស្តេចចក្រពត្តិ ឈ្មោះថា **ចក្កវត្តិសុខ** ។ បទថា បិយំ បានដល់

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទបាឋ លេខ ៥២ ទំព័រ ១៧ ។

គួរឱ្យប្រាថ្នា គួរឱ្យស្រឡាញ់ គួរឱ្យពេញចិត្ត ។ ទ្រង់សម្តែងភាពជាស្តេចចក្រពត្តិមានមហា សមុទ្រទាំងបួនជាព្រំប្រទល់ដោយបទនេះ ។ ភាពជាព្រះរាជា ក្នុងពួកទេវតា ឈ្មោះថា ភាពជាព្រះរាជាក្នុងពពួកទេព ។ កាលដែលទ្រង់សម្តែងភាពជាព្រះរាជារបស់ទេវតានៃមនុស្សទាំងឡាយ មានព្រះបាទមន្ធាតុរាជជាដើម ដោយបទនេះ ។ ដោយបទថា អបិ ទិព្វេសុ នេះ ទ្រង់សម្តែងភាពជាព្រះរាជារបស់ទេវតា និងមនុស្សទាំងឡាយ សូម្បីដែលកើតក្នុងពពួកទេពទាំងឡាយ ដែលហៅថា ទេព ព្រោះមានក្នុងទេពកត ។ ដោយបទថា សព្វមេតេន លព្ភតិ ទ្រង់សម្តែងថា ក្នុងពាក្យដែលត្រាស់ទុកថា យំ យំ ទេវាភិបត្ថេន្តិ សព្វមេតេន លព្ភតិ ឥដ្ឋផល មានភាពជាព្រះរាជាចំពោះប្រទេសដែលត្រាស់ជាចំណែកទីពីរនេះ គប្បីជ្រាបថា ឥដ្ឋផល ទាំងអស់នោះ ដែលបុគ្គលរមែងបានក៏ ដោយបុញ្ញ-និធិនេះ ។

## គេរសមគាថាវណ្ណនា

**ពណ៌នាគាថាទី ១៣**

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងសម្បត្តិ គឺភាពជាព្រះរាជានៃទេវតានិងមនុស្ស ដែលបុគ្គលគប្បីបានដោយបុញ្ញានុភាព ដោយគាថានេះយ៉ាង

នេះហើយ ឥឡូវនេះ កាលទ្រង់ធ្វើសម្បត្តិដែលត្រាស់ ដោយពីរគាថាទុក ខាងមុខដោយសង្ខេប នឹងទ្រង់សម្តែងសម្បត្តិគឺ ព្រះនិព្វាន ទើបត្រាស់គាថានេះថា ៖

"មានុស្សិកា ច សម្បត្តិ ទេវលោកេ ច យា រតិ

យា ច និព្វានសម្បត្តិ សព្វមេតេន លព្ភតិ ។

សម្បត្តិជារបស់មនុស្សណាផង សេចក្តីត្រេកអរក្នុងទេវលោកណាផង សម្បត្តិ គឺព្រះនិព្វានណាផង សម្បត្តិទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ" ១។

ពណ៌នាបទរបស់គាថានោះ មានដូច្នេះ ឈ្មោះថា មានុសី ព្រោះជារបស់មនុស្សទាំងឡាយ មានុសីនោះឯង ឈ្មោះថា មានុស្សិកា ។ ការដល់ព្រម ឈ្មោះថា សម្បត្តិ ។ លោករបស់ទេវតាទាំងឡាយ ឈ្មោះថា ទេវលោក ។ ក្នុងទេវលោកនោះ ។ បទថា យា ជាការកាន់យកមិនមានសេសសល់ ។ ឈ្មោះថា រតិ ព្រោះត្រេកអរដោយសម្បត្តិ ដែលកើតខាងក្នុង ឬជាគ្រឿងឧបករណ៍ខាងក្រៅ ។ ពាក្យនេះជាឈ្មោះ របស់សុខ និងវត្ថុជាហេតុឱ្យបានសេចក្តីសុខ ។ បទ

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៧ ។

ថា យា ជាបទ សំដែងសេចក្ដីដែលមិនពិតប្រាកដ ។ ច សទ្ទ មានសេចក្ដីថា រួមជាមួយសម្បត្តិទាំងពួង ។ ព្រះនិព្វាននោះឯងឈ្មោះថា និព្វានសម្បត្តិ ។

ក៏ការពណ៌នាសេចក្ដី មានដូច្នេះ ដោយបទថា **សុវណ្ណតា** ជាដើម សម្បត្តិនិងការត្រេកអរនោះ ត្រាស់ទុកថា **មានុស្សិកា ច សម្បត្តិ ទេវលោកេ ច យា រតិ** សម្បត្តិ របស់មនុស្ស និងសេចក្ដីត្រេកអរក្នុងទេវលោក ។ សម្បត្តិ និង សេចក្ដីត្រេកអរនោះទាំងអស់ និងនិព្វានសម្បត្តិ ដែលបុគ្គលគប្បីសម្រេច ជាព្រះអរិយបុគ្គល ដែលជាសទ្ធានុសារីជាដើមដទៃៗ ឥដ្ឋផលដូច ពោលមកនេះ ដែលទ្រង់ត្រាស់ជាទី ៣ ។ គប្បីជ្រាបថា ឥដ្ឋផល ភាពជាអ្នកមានវណ្ណៈល្អជាដើម និងផ្សេងដោយចំណោះដឹង ការឆ្លាតជាដើម ដែលលោកសំដែងទុកដោយន័យយ៉ាងនេះថា អ្នកអង់អាច មានសតិ ការរស់នៅ ប្រព្រឹត្តព្រហ្មចរិយៈ ក្នុងធម្មវិន័យនេះជាដើម សេចក្ដីត្រេកអរក្នុងឈានជាដើម ក្នុងទេវលោកយ៉ាងដទៃទៀត និងនិព្វានសម្បត្តិ តាមដែលពោលហើយយ៉ាងណា ឥដ្ឋផលដូចពោលមកនេះ ត្រាស់ទុកជាចំណែកទី ៣ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះ បុគ្គលរមែងបានដោយបុញ្ញនិធិនេះ ។

គប្បីជ្រាបការពណ៌នាសេចក្ដីក្នុងសេចក្ដីនេះ ដោយប្រការដូច្នេះ ។

ចុទ្ទសមគាថាវណ្ណនា

**ពណ៌នាគាថាទី ១៤**

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងនិព្វានសម្បត្តិ ដែលគប្បីបានដោយបុញ្ញានុភាព និងដែលគប្បីសម្រេចដោយភាពជាព្រះអរិយបុគ្គល មានសទ្ធានុសារីជាដើមដោយគាថានេះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងនិព្វាននោះ និងឧបាយនៃនិព្វាននោះ ដោយភាពជាអ្នកជំនាញក្នុងវិជ្ជា ៣ និងឧភតោភាគវិមុត្តិ ទើបត្រាស់គាថានេះថា ៖

"មិត្តសម្បទមាគម្ម យោនិសោ ចេ បយុញ្ជតោ
វិជ្ជាវិមុត្តិវសីភាវោ សព្វមេតេន លព្ភតិ ។

ភាពនៃបុគ្គលកាលអាស្រ័យមិត្តសម្បទា បើប្រកបដោយសេចក្តីព្យាយាម ដោយឧបាយដែលត្រូវ ជាអ្នកស្ទាត់ក្នុងវិជ្ជា និងវិមុត្តិ ឥដ្ឋផលទាំងអស់បានដោយកំណប់ទ្រព្យគឺបុណ្យនោះ"[១] ។

ពណ៌នាបទរបស់គាថានោះ មានដូច្នេះ ឈ្មោះថា **សម្បទា** ព្រោះជាគ្រឿងសម្រេចផលគឺដល់សេចក្តីចម្រើននៃគុណសម្បទា គឺមិត្ត ឈ្មោះថា **មិត្ត-**

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៧ ។

***សម្បទា*** ។ នូវមិត្តសម្បទានោះ ។ បទថា ***អាគម្ម*** ប្រែថា អាស្រ័យ ។ បទថា យោនិសោ បានដល់ ដោយឧបាយ ។ បទថា បយុញ្ជតោ បានដល់ ធ្វើសេចក្តីឧស្សាហ៍ ។ ឈ្មោះថា ***វិជ្ជា*** ព្រោះជាគ្រឿងដឹងច្បាស់ ។ ឈ្មោះថា ***វិមុត្តិ*** ព្រោះជាគ្រឿងរួចផុត ឬរួចផុតខ្លួនឯង ។ ទាំងវិជ្ជា ទាំងវិមុត្តិ ឈ្មោះថា វិជ្ជា និងវិមុត្តិ ។ ភាពជាអ្នកជំនាញក្នុងវិជ្ជានិងវិមុត្តិឈ្មោះថា ***វិជ្ជាវិមុត្តិវសីភាវៈ*** ។

ចំណែកការពណ៌នាសេចក្តី មានដូចតទៅនេះ ៖

ការដែលបុគ្គលអាស្រ័យមិត្តសម្បទា គឺអាស្រ័យព្រះសាស្តា ឬសព្រហ្មចារិយ ដែលជាទីតាំងនៃសេចក្តីគោរពអង្គណាមួយ ទទួលឱវាទ និងអនុសាសនីពីលោកហើយប្រកបដោយឧបាយដ៏ឆ្លាត ដោយការបដិបត្តិ តាមដែលលោកបង្រៀនជាអ្នកជំនាញក្នុងវិជ្ជា ៣ មាន បុព្វេនិវាសញ្ញាណជាដើម និងក្នុងវិមុត្តិដែលផ្សេងដោយសមាបត្តិ ៨ និងព្រះនិព្វាន ដែលមកយ៉ាងនេះថា ក្នុងធម៌ពួកនោះ វិមុត្តិគឺអ្វី? គឺការរួចផុតដ៏ក្រៃលែងនៃចិត្ត និងព្រះនិព្វាន ដោយអត្ថថា មិនបន្អែបន្អង់ដោយប្រការនោះៗ នេះជាផលដែលត្រាស់ជាចំណែកទី ៤ នេះ គប្បីជ្រាប ឥដ្ឋផលទាំងអស់នោះ បុគ្គលរមែងបានដោយបុញ្ញនិធិនេះ ។

## បណ្ណរសមគាថាវណ្ណនា

### ពណ៌នាគាថាទី ១៥

*ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងនិព្វានសម្បត្តិ ដែលគប្បីបានដោយអានុភាពនៃបុណ្យ ដែលជាចំណែកនៃភាពជាអ្នកជំនាញក្នុងវិជ្ជា និងវិមុត្តិដែលពោលមកពីមុនហើយ ដែលគប្បីសម្រេចដោយអំណាចនៃត្រៃវិជ្ជានិងឧភតោភាគវិមុត្តិ ដោយគាថានេះយ៉ាងនេះហើយ ឥឡូវនេះ ព្រោះហេតុ ដែលលោកដល់នូវភាពជាអ្នកដែលសម្រេចភាពជាអ្នកជំនាញក្នុងវិជ្ជា និងវិមុត្តិសូម្បីជាអ្នកមានវិជ្ជា ៣ និងរួចផុតហើយ ដោយចំណែក ២ (គឺចេតោវិមុត្តិ និងបញ្ញា-វិមុត្តិ) លោកទាំងអស់នោះ មិនមែនបានសេចក្ដីចម្រើននៃគុណមានបដិសម្ភិទាជាដើមទៅទាំងអស់ទេ ប៉ុន្តែសេចក្ដីចម្រើននៃគុណ បុគ្គលរមែងបានដោយបុញ្ញ-សម្បទានេះ សូម្បីដែលធ្វើហើយដោយប្រការនោះៗ ដោយជាបទដ្ឋាននៃវិមុត្តិនោះដូច្នោះ កាលទ្រង់សម្ដែងសេចក្ដីចម្រើននៃគុណនោះ ទើបត្រាស់គាថានេះថា ៖*

“បដិសម្ភិទា វិមោក្ខា ច យា ច សាវកបារមី

បច្ចេកពោធិ ពុទ្ធភូមិ សព្វមេតេន លព្ភតិ ។

*សម្រាប់ជាធម្មទាន*

*បដិសម្ភិទា វិមោក្ខ សាវកបារមីញាណ បច្ចេកពោធិញ្ញាណ និងពុទ្ធភូមិណា ៗ ឥដ្ឋផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ”*[១] ។

*ព្រោះហេតុថា បញ្ញានេះដែលដល់នូវភាពបែកធ្លាយក្នុងធម៌ អត្ថ និរុត្តិ និង បដិភាណ លោកហៅថា បដិសម្ភិទា វិមោក្ខ ៨ ពួកនេះដោយន័យថា អ្នកដែលមានរូបរមែងឃើញរូបជាដើម ។ សាវកបារមីនេះ ដែលឱ្យសម្រេចសាវក-សម្បត្តិ ដែលព្រះសាវកទាំងឡាយរបស់ព្រះដ៏មានព្រះភាគជាម្ចាស់ គប្បីសម្រេច ។ បច្ចេកពោធិណា ដែលឱ្យសម្រេចភាពជាព្រះសយម្ភូ និងពុទ្ធភូមិណា ដែលឱ្យសម្រេចភាពជាអ្នកដែលខ្ពង់ខ្ពស់ជាងសព្វសត្វ ឥដ្ឋផលដែលត្រាស់ជាចំណែកទី ៥ សូម្បីទាំងអស់នេះ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះបុគ្គលរមែងបាន ដោយបុញ្ញនិធិនេះ ដែលគេធ្វើហើយដោយប្រពៃ ។*

## សោឡសមគាថាវណ្ណនា

## ពណ៌នាគាថាទី ១៦

*ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងផលដែលត្រាស់ ទុកថាទេវតា និងមនុស្សទាំងឡាយ ប្រាថ្នាផលណា ឥដ្ឋផលទាំងអស់នោះ បុគ្គលរមែងបានដោយបុញ្ញនិធិនេះជាចំណែកៗ ទៅដោយគាថា ៥ គាថាទាំងអស់នេះ*

*១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៨ ។*

យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សរសើរបុញ្ញសម្បទា ដែលយល់ថាជានិធិដែលឱ្យផលដែលគួរឱ្យប្រាថ្នាគ្រប់យ៉ាងនេះទាំងអស់ ទើបទ្រង់បញ្ចប់ទេសនាដោយគាថានេះថា៖

"ឯវំ មហត្ថិកា ឯសា យទិទំ បុញ្ញសម្បទា
តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតំ ។

បុញ្ញសម្បទានេះ ឱ្យសម្រេចប្រយោជន៍ដ៏ធំ ដោយប្រការដូច្នេះ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ជាធីរជន ទើបសរសើរនូវភាពនៃបុគ្គលជាអ្នកមានបុណ្យធ្វើទុកហើយ"(១) ។

ការពណ៌នាបទនៃគាថានោះដូច្នេះ ៖ ពាក្យថា ឯវំ ជាពាក្យសម្តែងភាពដែលកន្លងទៅហើយ ។ ឈ្មោះថា មហត្ថិកា ព្រោះមានប្រយោជន៍ច្រើន ។ លោកអធិប្បាយថា ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍យ៉ាងធំ ។ បាលីថា មហិទ្ធិកា ដូច្នេះ ក៏មាន ។ បទថា ឯសា ជាពាក្យឧទ្ទេស (តែងសេចក្តី)លើកបុញ្ញសម្បទាដែលត្រាស់ពីដំបូងពីរបទនេះថា យស្ស ទានេន សីលេន រហូតដល់បទថា កយិរាថ ធីរោ បុញ្ញានិ ដោយពាក្យឧទ្ទេសនោះ ។ សព្ទថា យទិទំ ជានិបាត

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៨ ។

ចុះក្នុងអត្តធ្វើឱ្យគ្រប់សព្វ ។ ដើម្បីទ្រង់អធិប្បាយបទឧទ្ទេសដែលទ្រង់លើកឡើងថា ឯសា ទើបទ្រង់ធ្វើឱ្យគ្រប់សព្វថា យា ឯសា ដោយស័ព្ទថា យទិទំ នោះ ។ ការដល់ព្រមនៃបុណ្យទាំងឡាយឈ្មោះថា បុញ្ញសម្បទា ។ ពាក្យថា តស្មា ជាពាក្យ សម្តែងហេតុ ។ បទថា ធីរា បានដល់ អ្នកមានបញ្ញា ។ បទថា បសំសន្តិ ប្រែថា សរសើរ ។ បទថា បណ្ឌិតា បានដល់ អ្នកដល់ព្រមដោយបញ្ញា ។ បទថា កតបុញ្ញតំ ប្រែថា ភាពជាអ្នកធ្វើបុណ្យទុកហើយ ។

ចំណែកការពណ៌នាសេចក្តីមានដូច្នេះថា ព្រះដ៏មានព្រះភាគជាម្ចាស់កាលទ្រង់សរសើរបុញ្ញនិធិមានភាពជាអ្នកដែលមានវណ្ណៈល្អជាដើម មានពុទ្ធភូមិជាទីបំផុត ល្មមដែលបុគ្គលនឹងគប្បីសម្រេចបាន ដោយអានុភាពនៃបុញ្ញសម្បទា ដូច្នេះហើយ ឥឡូវនេះ កាលទ្រង់ប្រមូលសម្តែងតាមសេចក្តីនោះនុ៎ះឯង កាលទ្រង់លើកសេចក្តីនៃបុញ្ញសម្បទា តាមដែលពោលហើយមានប្រយោជន៍ច្រើន ដោយសេចក្តីនោះនុ៎ះឯង ទើបត្រាស់ថា ភាពនៃបុញ្ញសម្បទា ដែលតថាគតសម្តែងដោយន័យថា យស្ស ទានេន សីលេន យ៉ាងនេះ ព្រោះដូច្នោះ បណ្ឌិតដែលមានបញ្ញាដូចតថាគត ទើបសរសើរភាពជាអ្នកធ្វើបុណ្យហើយ ដែលមានអាការៈ និងវោហារៈ គឺខន្ធច្រើន ដោយពាក្យដែលពោលក្នុងទីនេះថា និធិមិនសាធារណៈដល់ជនដទៃៗ ចោរលួចទៅមិនបានជាដើម និងមិនបានពោលទុក

(ក្នុងទីនេះ)ថា "មា ភិក្ខវេ បុញ្ញានំ ភាយិត្ថ សុខស្សេតំ ភិក្ខវេ អធិវចនំ យទិទំ បុញ្ញានំ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំខ្លាចនូវបុណ្យឡើយ ម្នាលភិក្ខុទាំងឡាយពាក្យថាបុណ្យនេះជាឈ្មោះនៃសេចក្ដីសុខ"[១] ។ ដូច្នេះជាដើម ដោយគុណតាមដែលពិតនោះ ព្រោះមិនខ្វិលច្រអូសក្នុង ការសម្ដែងធម៌ ដែលនាំមកនូវប្រយោជន៍សុខដល់សត្វទាំងឡាយ មិនមែនសរសើរដោយកាន់ជើងបក្ខពួកខ្លួនឡើយ ។

ទីបញ្ចប់នៃទេសនា ឧបាសកនោះក៏តាំងនៅក្នុងសោតាបត្តិផលព្រមដោយជនជាច្រើន និងគាត់ក៏ចូលគាល់ព្រះបាទបសេនទិកោសល ក្រាបទូលសេចក្ដីនោះ ។ ព្រះរាជាទ្រង់ត្រេកអរយ៉ាងក្រៃលែង ទ្រង់សរសើរថា "ល្អមែន គហបតិ ល្អមែន គហបតិ លោកកប់កំណប់ទ្រព្យ ដែលសូម្បីយើងក៏នាំទៅមិនបាន" ទ្រង់ធ្វើការបូជាយ៉ាងច្រើនដល់ឧបាសកនោះឯង ។

បរមត្ថជោតិកាយ ខុទ្ទកបាឋដ្ឋកថាយ

និធិកណ្ឌសុត្តវណ្ណនា និដ្ឋិតា

**ចប់អដ្ឋកថានិធិកណ្ឌសូត្រ**

**នៃ**

**អដ្ឋកថា ខុទ្ទកបាឋៈ ឈ្មោះបរមត្ថជោតិកា ៗ**

---

១-សុត្តន្តបិដក អង្គុត្តរនិកាយ សត្តកនិបាត លេខ ៤៧ ទំព័រ ១៦៤ ។

## ៩-មេត្តសុត្តវណ្ណនា

## **ពណ៌នាអំពីមេត្តសូត្រ**

## និក្ខេបប្បយោជនំ

### **ប្រយោជន៍នៃការតាំងសូត្រ**

*ឥឡូវនេះ ដល់លំដាប់ការពណ៌នា សេចក្ដីរបស់មេត្តសូត្រ ដែលលើកមកសម្ដែងបន្ទាប់អំពី និធិកណ្ឌសូត្រ ។ ក្នុងទីនេះ ខ្ញុំនឹងពោល ប្រយោជន៍របស់ការតាំងមេត្តសូត្រនោះហើយ តអំពីនោះ គប្បីជ្រាបការចន្អុលបង្ហាញបទទាំងនោះថា មេត្តសូត្រនោះ អ្នកណាពោល ពោលកាលណា ពោលទីណា និងពោលព្រោះហេតុណាជម្រះនិទានហើយទើបនឹងធ្វើការពណ៌នាសេចក្ដីរបស់មេត្តសូត្រនោះ ។*

*ក្នុងមេត្តសូត្រនោះ ព្រោះហេតុដែលទ្រង់ត្រាស់ បុញ្ញសម្បទាមានទានសីលជាដើមដោយនិធិកណ្ឌសូត្រ ។ កាលបុគ្គលធ្វើមេត្តាក្នុងសត្វទាំងឡាយបុញ្ញសម្បទានោះ រមែងមានផលច្រើន រហូតដល់ប្រាថ្នាឱ្យបាក់ធ្លុះពុទ្ធភូមិបានដូច្នោះ ទើបខ្ញុំលើកមេត្តសូត្រ ឡើងតាំងទុកក្នុងទីនេះ ដើម្បីសម្ដែងថា មេត្តាជាឧបការៈដល់បុញ្ញសម្បទានោះ ឬព្រោះហេតុ ដែលខ្ញុំកាលសម្ដែងកម្មដ្ឋាន ដែលលះទោសៈដោយទ្វត្តិំសាការៈ សម្រាប់ជនទាំងឡាយអ្នកគោរពព្រះពុទ្ធសាសនា ដោយសរណៈ ហើយតាំងនៅក្នុងសីល ដោយសិក្ខាបទ ទាំងឡាយនឹងអាចលះមោហៈដោយកុមារបញ្ហា ទើបសម្ដែងថា ការប្រព្រឹត្តិសរណៈជាដើមនោះ ជាមង្គលនិងរក្សាខ្លួនឯង ដោយមង្គលសូត្រ សម្ដែងការរក្សាអ្នកដទៃដែលសមដល់មង្គលនោះ ដោយរតនសូត្រ សម្ដែងការឃើញភូតពួកខ្លះ បណ្ដាភូតទាំងឡាយ ដែល*

ពោលទុកក្នុងរតនសូត្រ និងសេចក្ដីវិបត្តិរបស់ពួកជន ដែលប្រមាទក្នុងបុញ្ញ-សម្បត្តិ ដូចដែលពោលហើយក្នុងតិរោកុឌ្ឌសូត្រ និងសម្ដែងសម្បត្តិ ដែលជាបដិបក្សចំពោះវិបត្តិ ដែលពោលទុកក្នុងតិរោកុឌ្ឌសូត្រ ដោយនិធិកណ្ឌសូត្រ តែនៅមិនបាន សម្ដែងកម្មដ្ឋាន ដែលអាចលះទោសៈនោះ ព្រោះដូច្នោះ ទើបខ្ញុំលើកមេត្តសូត្រនេះឡើងតាំងក្នុងទីនេះ ដើម្បីសម្ដែងកម្មដ្ឋាន ជាគ្រឿងលះបង់នូវទោសៈ ។ កាលបើដូច្នេះ ខុទ្ទកបាឋ ទើបនឹងបរិបូណ៌ដោយល្អ ។ សេចក្ដីដែលពោលមកដូច្នេះ ជាប្រយោជន៍នៃការតាំងមេត្តសូត្រនោះទុកក្នុងទីនេះ ។

## និទានសោធនំ

### ការជម្រះនិទាន

ឥឡូវនេះ ខ្ញុំលើកមាតិកាខាងចុងនេះទុកថា គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនេះថា ៖

មេត្តសូត្រនេះ អ្នកណាពោល ពោលកាលណា ពោលទីណានឹងពោលព្រោះហេតុណា ខ្ញុំជម្រះនិទានហើយ ទើបនឹងធ្វើការពណ៌នាសេចក្ដីនៃមេត្តសូត្រនោះដូច្នេះ ។

ក្នុងមាតិកាចុងសេចក្ដីនោះ គប្បីបង្ហាញបទទាំងនេះ នឹងការជម្រះនិទានដោយសង្ខេបយ៉ាងនេះមុនថា៖ មេត្តសូត្រនេះព្រះដ៏មានព្រះភាគមួយព្រះអង្គគត់

សម្រាប់ជាធម្មទាន

ប៉ុណ្ណោះ បានត្រាស់សម្តែង សាវ័កជាដើមមិនបានពោលទេ ។ តែថាកាលណា ភិក្ខុទាំងឡាយ ត្រូវទេវតាទាំឡាយនៅក្នុំហេមវន្តបន្ទាច ទើបនាំគ្នាមកគាល់ព្រះមានព្រះភាគ កាលនោះព្រះដ៏ព្រះភាគទើបត្រាស់មេត្តសូត្រនោះ ដើម្បីការពារ និងដើម្បីជាកម្មដ្ឋាន សម្រាប់ភិក្ខុទាំងនោះ ។ ចំណែកសេចក្តីពិស្តារគប្បីជ្រាបយ៉ាងនេះ ។

សម័យមួយ ជិតតិថីចូលចាំព្រះវស្សា ព្រះដ៏មានព្រះភាគប្រថាប់ក្នុងក្រុងសាវត្ថី ។ សម័យនោះ ភិក្ខុទាំងឡាយចេញចាកក្រុងផ្សេងៗមានចំនួនច្រើន ទទួលកម្មដ្ឋានក្នុងសំណាក់ព្រះដ៏មានព្រះភាគ ហើយមានបំណងនឹងចូលចាំវស្សាក្នុងទីនោះៗ ទើបចូលគាល់ព្រះដ៏មានព្រះភាគ ។ បានឮថា សម័យនោះឯងព្រះមានព្រះភាគត្រាស់កម្មដ្ឋានទាំងឡាយ ដែលអនុកូលដល់ចរិតចំនួន ៨៤,០០០ ប្រភេទ ដោយន័យនេះគឺ អសុភកម្មដ្ឋាន ១១ យ៉ាងគឺ អសុភៈមាន វិញ្ញាណ និងមិនមានវិញ្ញាណសម្រាប់មនុស្សរាគចរិត កម្មដ្ឋានមានមេត្តាកម្មដ្ឋានជាដើម ៤ យ៉ាងសម្រាប់មនុស្សទោសចរិត កម្មដ្ឋានមានមរណស្សតិកម្មដ្ឋានជាដើម សម្រាប់មនុស្សមោហៈចរិត កម្មដ្ឋានមានអនាបានស្សតិ និងបឋវីកសិណជាដើម សម្រាប់មនុស្សវិតក្កចរិត កម្មដ្ឋានមានពុទ្ធានុស្សតិកម្មដ្ឋានជាដើម សម្រាប់មនុស្សសទ្ធា-ចរិត កម្មដ្ឋានមានចតុធាតុវវត្ថានកម្មដ្ឋានជាដើម សម្រាប់មនុស្ស ពុទ្ធិចរិត ។

លំដាប់នោះ ភិក្ខុប្រមាណ ៥០០ រូប រៀនកម្មដ្ឋាន ក្នុងសំណាក់ព្រះមានព្រះភាគ កំពុងស្វែងរកសេនាសនៈ ជាទីសប្បាយ និងគោចរគ្រាម ដើរទៅតាមលំដាប់ បានជួបភ្នំផ្ទាំងសិលា ស្រដៀងមណីពណ៌ក្រហមប្រដាប់ ដោយដងព្រៃពណ៌ខៀវ មានម្លប់ត្រឈឹងត្រឈៃត្រជាក់ មានភូមិភាគពេញ ដោយដីខ្សាច់ហាក់បីដូចផែនកែវមុក្តា ព័ទ្ធដោយជលាស័យ ដែលបរិសុទ្ធល្អត្រជាក់ជាប់ជាមួយព្រៃហេមវន្ត ក្នុងបច្ចន្តប្រទេស ។ ភិក្ខុទាំងនោះ ស្នាក់នៅមួយយប់ក្នុងទីនោះ កាលរាត្រីកន្លងទៅហើយ ពេលព្រឹកធ្វើ សរីរៈកិច្ចហើយ ក៏នាំគ្នាចូលទៅបិណ្ឌបាត នៅភូមិមួយក្នែងជិតទីនុ៎ះឯង ។ ភូមិប្រកបដោយត្រកូល ១.០០០ ត្រកូល ដែលអាស្រ័យនៅកុះករក្នុងភូមិនោះ មនុស្សទាំងឡាយ អ្នកមានសទ្ធា មានសេចក្តីជ្រះថ្លា ពួកគេឃើញភិក្ខុទាំងឡាយប៉ុណ្ណោះ ក៏កើតបីតិសោមនស្ស ព្រោះការឃើញបព្វជិត ក្នុងបច្ចន្តប្រទេសរកបានដោយលំបាក និមន្តភិក្ខុទាំងនោះ ឱ្យឆាន់ហើយ ក៏អង្វរសូមថា "បពិត្រលោកម្ចាស់ សូមលោកម្ចាស់នៅក្នុងទីនេះ រហូតអស់ត្រីមាសចុះ" ហើយជួយគ្នាសាងកុដិ សម្រាប់ធ្វើសេចក្តីព្យាយាម ៥០០ ខ្នង ចាត់ចែងគ្រឿងឧបករណ៍គ្រប់យ៉ាង មានគ្រែ តាំង ក្អមទឹកឆាន់ ទឹកប្រើប្រាស់ជាដើមក្នុងទីនោះ ។

ថ្ងៃព្រឹកឡើង ភិក្ខុទាំងឡាយចូលទៅបិណ្ឌបាតនៅភូមិដទៃ ។ ក្នុងភូមិសូម្បីនោះ មនុស្សទាំងឡាយ ក៏និយាយ ដើម្បីទំនុកបម្រុងពួកភិក្ខុយ៉ាងនោះដូចគ្នា អង្វរ

ឱ្យនៅចាំវស្សា ។ ភិក្ខុទាំងឡាយ ទទួលនិមន្តដោយមានល័ក្ខខណ្ឌថា កាលមិនមានអន្តរាយ (អាត្មានឹងនៅ) ហើយនាំគ្នាចូលទៅនៅជងព្រៃនោះ ជាអ្នកប្រារព្ធសេចក្តីព្យាយាម រហូតអស់យប់ និងថ្ងៃ វាយរគាំង ប្រាប់យាម ជាអ្នកច្រើនទៅដោយយោនិសោមនសិការៈ ទើបចូលទៅអង្គុយត្រង់គល់ឈើ ។ រុក្ខទេវតាទាំងឡាយ ត្រូវតេជះរបស់ពួកភិក្ខុ អ្នកមានសីល កម្ចាត់តេជះរបស់ខ្លួនបាត់ហើយ ក៏ចុះអំពីវិមានរបស់ខ្លួនៗនាំពួកកូនៗ ធ្វើដំណើរអំពីទីនោះៗ ។ ប្រៀបដូចកាលព្រះរាជា ឬរាជមហាមាត្យ កាលទៅកាន់ទីនៅរបស់អ្នកភូមិ កាន់យកឱកាសទំនេរក្នុងផ្ទះទាំងឡាយរបស់អ្នកភូមិ អ្នកភូមិក៏ត្រូវចេញចាកភូមិទៅនៅកន្លែងដទៃ ក៏បានតែត្រឹមសម្លឹងមើលនៅឆ្ងាយៗ ដោយសង្ឃឹមថា "កាលណាហ្ន៎ ទើបលោកនឹងចេញទៅ? ទេវតាទាំងឡាយ ត្រូវលះចោលវិមានរបស់ខ្លួនៗ បែកខ្ញែកគ្នា បានតែត្រឹមសម្លឹងមើលពីទៅឆ្ងាយៗដោយសង្ឃឹមថា "កាលណាហ្ន៎ ទើបលោកម្ចាស់ទាំងឡាយនិមន្តទៅ" ក៏យ៉ាងនោះដូចគ្នា ។ តាំងតែពីនោះ ទេវតាទាំងឡាយ ក៏រួមគំនិតគិតគ្នាយ៉ាងនេះថា "ភិក្ខុទាំងឡាយចូលវស្សាដំបូងហើយនឹងនៅរហូតដល់ត្រីមាសពិតប្រាកដ តែពួកយើងមិនអាចនឹងនាំពួកក្មេង នៅយ៉ាងលំបាកបាន" ណ្ហើយចុះ ពួកយើងនឹងសម្តែងអារម្មណ៍ ដែលគួរខ្លាចដល់ភិក្ខុទាំងឡាយ ។ ទេវតាទាំងនោះ ទើបនិមិត្តរូបយក្ស ដែលគួរខ្លាចឈរនៅខាងមុខៗ វេលាភិក្ខុទាំងឡាយធ្វើសមណធម៌រហូតដល់កណ្តាលយប់ និងធ្វើសំឡេង

គួរឱ្យភ័យខ្លាច ។ ភិក្ខុទាំងឡាយ ព្រោះឃើញរូបទាំងនោះ ក៏មានសម្បុរស្លេកស្លាំង និងកើតជារោគស្គមលឿង ។ ព្រោះហេតុនោះ ភិក្ខុទាំងនោះ ទើបមិនអាចធ្វើចិត្តឱ្យមានអារម្មណ៍តែមួយបាន កាលចិត្តមិនមានអារម្មណ៍តែមួយ ស្លុតចិត្តរឿយៗ ព្រោះខ្លាចសតិរបស់ភិក្ខុពួកនោះ ក៏វង្វេងមិនច្បាស់ តាំងអំពីនោះ អារម្មណ៍ដែលស្អុយៗ ក៏ជួបជួនដល់ភិក្ខុពួកនោះ ដែលមានសតិវង្វេងវង្វាន់ ហើយ ។ ខួរក្បាលរបស់ភិក្ខុពួកនោះ ក៏ដូចត្រូវក្លិនស្អុយនោះកៀបសង្កត់រោគឈឺសីសៈក៏កើតឡើងយ៉ាងធ្ងន់ ។ ភិក្ខុទាំងនោះ ក៏មិនព្រមប្រាប់រឿងនោះដល់គ្នា នឹងគ្នា ។

តមកថ្ងៃមួយ កាលភិក្ខុគ្រប់រូបប្រជុំគ្នាក្នុងវេលា ទំនុកបម្រុងព្រះសង្ឃត្ថេរ ។ ព្រះសង្ឃត្ថេរក៏សួរថា អ្នកមានអាយុ កាលពួកលោកចូលទៅក្នុងដងព្រៃនោះ ស្បែកពណ៌សម្បុរបរិសុទ្ធផូរផង់យ៉ាងក្រៃលែង នៅ ២-៣ ថ្ងៃ ទាំងឥន្ទ្រិយក៏ស្រស់ថ្លា តែឥឡូវនេះ ក្នុងទីនេះ ពួកលោកស្គមស្បែកស្លេកស្លាំងកើតជារោគលឿង ក្នុងទីនេះពួកលោកមិន សប្បាយឬ ។ លំដាប់នោះ ភិក្ខុមួយរូបពោលថា បពិត្រលោកម្ចាស់ វេលាយប់មិញនេះ ខ្ញុំឃើញ និងបានឮអារម្មណ៍ដែលគួរខ្លាចយ៉ាងនេះៗ ស្រូបតែក្លិន ដូច្នេះ ព្រោះហេតុនោះ ចិត្តរបស់ខ្ញុំទើបមិនតាំងមាំជាសមាធិ ។ ភិក្ខុទាំងនោះគ្រប់រូប ទើបនាំគ្នាប្រាប់រឿងនោះ ដោយឧបាយនេះដូចគ្នា ។ ព្រះសង្ឃត្ថេរពោលថា អ្នកមានអាយុ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តការចូលចាំ

វស្សាទុក ២ យ៉ាង ក៏សេនាសនៈមិនជាទីសប្បាយដល់ពួកយើង មកចុះ អ្នកមានអាយុពួកយើងនឹងនាំគ្នាទៅគាល់ព្រះដ៏មានព្រះភាគ ទូលសួរនូវសេនាសនៈដែលជាទីសប្បាយដទៃៗ ភិក្ខុទាំងនោះ ទទួលពាក្យព្រះថេរៈថា ករុណាលោកម្ចាស់ គ្រប់រូបក៏ប្រមូល បិទបាំងសេនាសនៈ កាន់បាត្រចីវរ មិនប្រាប់ដល់នរណាៗ ក្នុងត្រកូលទាំងឡាយ នាំគ្នាចារិកទៅកាន់ក្រុងសាវត្ថី ក៏ដល់ក្រុង-សាវត្ថីតាមលំដាប់ហើយ ក៏នាំគ្នាចូលគាល់ព្រះដ៏មានព្រះភាគ ។

ព្រះដ៏មានព្រះភាគ ទ្រង់ឃើញភិក្ខុទាំងនោះទើបត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ តថាគតបញ្ញត្តសិក្ខាបទទុកថា ភិក្ខុមិនគប្បីត្រាច់ចារិកទៅខាងក្នុងវស្សា ហេតុអ្វីពួក លោកទើបចារិកទៅ ។ ភិក្ខុពួកនោះ ទើបក្រាប ទូលរឿងទាំងអស់ដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់នឹកគិត ក៏ទ្រង់មិនឃើញសេនាសនៈ ដែលជាទីសប្បាយដទៃសម្រាប់ភិក្ខុទាំងនោះ ទាំងជម្ពូទ្វីប ដោយទីបំផុត សូម្បីត្រឹមតែតាំងមានជើង ៤ ដូច្នេះ ទើបត្រាស់ប្រាប់ភិក្ខុទាំងនោះថា "ម្នាលភិក្ខុទាំងឡាយ សេនាសនៈដែលជាទីសប្បាយដទៃសម្រាប់អ្នកទាំងឡាយមិនមាន អ្នកទាំងឡាយនៅក្នុងទីនោះៗឯង នឹងបន្ទុះធម៌ជាទីអស់អាសវៈ ទៅចុះភិក្ខុទាំងឡាយ អ្នកទាំងឡាយទៅអាស្រ័យសេនាសនៈនោះនុ៎ះឯងនៅចុះ តែ

បើថាអ្នកទាំងឡាយប្រាថ្នាការមិនមានភ័យអំពីទេវតាទាំងឡាយ ក៏ចូរនាំគ្នារៀនព្រះបរិត្តនេះ" ។ ព្រោះថាព្រះបរិត្តនេះ នឹងបានជាគ្រឿងការពារ ហើយជាកម្មដ្ឋានសម្រាប់អ្នកទាំងឡាយ ដូច្នេះហើយទើបទ្រង់ត្រាស់ព្រះសូត្រនេះ ។

តែអាចារ្យពួកដទៃទៀតពោលថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "ទៅចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូលទៅអាស្រ័យសេនាសនៈនុ៎ះឯងនៅចុះ ហើយទើបត្រាស់ថា ភិក្ខុអ្នកនៅព្រៃគួរជីងនឹងការរក្សា" ។ រក្សាយ៉ាងណារក្សាយ៉ាងនេះគឺ ផ្សាយមេត្តា ២ ពេលគឺ ពេលល្ងាច និងពេលព្រឹក ចម្រើនព្រះបរិត្ត ២ ពេល ចម្រើនអសុភៈ ២ ពេល ចម្រើនមរណាសតិ ២ ពេល និងនឹកដល់មហាសង្វេគវត្ថុ ៨ ។ ឈ្មោះថា មហាសង្វេគវត្ថុ ៨ គឺ ជាតិ ជរា ព្យាធិ មរណៈ និងអបាយទុក្ខ ៤ ។ ន័យមួយទៀត ជាតិជរាព្យាធិមរណៈ ៤ អបាយទុក្ខជាទី ៥ ទុក្ខមានវដ្តជាមូលក្នុងអតីត ១ ទុក្ខមានវដ្តជាមូលក្នុងអនាគត ១ ទុក្ខមានការស្វែងរកអាហារជាមូលក្នុងបច្ចុប្បន្ន ១ ។ ព្រះដ៏មានព្រះភាគ កាលទ្រង់ប្រាប់ការរក្សាយ៉ាងនេះហើយ ទើបទ្រង់ត្រាស់ព្រះសូត្រនេះដើម្បីជាមេត្តា ដើម្បីជាព្រះបរិត្ត និងដើម្បីជាឈាន ដែលជាបាទនៃវិបស្សនាដល់ភិក្ខុទាំងនោះ ។ គប្បី

ជ្រាបការពន្យល់ បទទាំងនេះថា យេន វុត្តំ យទា យត្ថ យស្មា ចេ និងការជម្រះនិទានដោយពិស្ដារយ៉ាងនេះ ។

មាតិកាចុងសេចក្ដីនោះណា ខ្ញុំតាំងទុកថា យេន វុត្តំ យទា យត្ថ យស្មា ចេតេស ធីបនា និធានំ សោធយិត្វា មាតិកាចុងសេចក្ដីនោះ ដែលខ្ញុំពោលពិស្ដារហើយដោយអាការៈទាំងពួងដោយកថាប្រមាណត្រឹមនេះ ។

## បឋមគាថាវណ្ណនា

### ពណ៌នាគាថាទី ១

ឥឡូវនេះ នឹងផ្ដើមពណ៌នាសេចក្ដីនៃព្រះសូត្រនោះ ដែលធ្វើការជម្រះនិទានហើយយ៉ាងនេះ ។ ព្រោះពោលទុកថា ទើបនឹងធ្វើការពណ៌នា សេចក្ដីនៃព្រះសូត្រនោះដូច្នោះ ។ ក្នុងគាថានោះ នឹងផ្ដើមពណ៌នាបទនៃគាថានេះ ថា ករណីយមត្ថកុសលេន មុនដូច្នេះ ។ បទថា ករណីយំ ប្រែថា គប្បីធ្វើ អធិប្បាយថា គួរដល់ការធ្វើបដិបទា ។ ឈ្មោះថា អត្ថ ឬប្រយោជន៍គាំទ្រយ៉ាងណាមួយ ប្រយោជន៍គាំទ្រនោះទាំងអស់ លោកហៅថា អត្ថ ព្រោះមិនមានកិលេសដូចសត្រូវ ឈ្មោះថា **ករណីយៈ** ព្រោះដែលបុគ្គលគប្បីចូលដល់ ។ ជាអ្នកឆ្លាតក្នុងប្រយោជន៍ ឈ្មោះថា អត្ថកុសលេន លោកអធិប្បាយថា ជាអ្នកវាងវៃក្នុង

ប្រយោជន៍ ។ បទថា យំ ជាបឋមាវិភត្តិសម្តែងមិនជាក់លាក់ ។ បទថា តំ ជាទុតិយាវិភត្តិសម្តែងសេចក្តីជាក់លាក់ ។ ឬបទថា យំ តំ សូម្បីទាំងពីរ ជាបឋមា-វិភត្តិ ។ បទថា សន្តំ បទំ ជាទុតិយាវិភត្តិ ។ បណ្តាបទទាំងពីរនោះ ដែលឈ្មោះថា សន្តំ ព្រោះជាលក្ខណៈ បទំ ព្រោះបុគ្គលគប្បីដល់ ពាក្យនេះជា ឈ្មោះរបស់ព្រះនិព្វាន ។បទថា អភិសមេច្ច ប្រែថា បន្ទុះហើយ ។ អ្នកណារមែងអាចហេតុនោះ អ្នកនោះ ឈ្មោះថា សក្កោ អ្នកអាច លោកអធិប្បាយថា អ្នកប្រាថ្នាអ្នកអង់អាច ។ បទថា ឧជូ បានដល់ អ្នកប្រកបដោយសេចក្តីត្រង់ ។ អ្នកណាត្រង់ ដោយល្អ ហេតុនោះ អ្នកនោះឈ្មោះ សុហុជូ អ្នកត្រង់ដោយល្អ ។ សេចក្តីថា ងាយស្រួលមានក្នុងអ្នកនោះ ហេតុនោះ អ្នកនោះ ឈ្មោះថា សុវចោ អ្នកងាយស្រួល ។ បទថា អស្ស ប្រែថា គប្បីមានគប្បីកើត ។ បទថា មុទុ បានដល់ អ្នកប្រកបដោយការទន់ភ្លន់ ។ អ្នកណាមិនមានអតិមានៈ ហេតុនោះ អ្នកនោះ ឈ្មោះថា អនតិមានី មិនមានអតិមានៈ ។

ចំណែកការពណ៌នាសេចក្តីក្នុងគាថាទី ១ ដូច្នេះ ៖

វិនិច្ឆ័យក្នុងបទថា ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិសមេច្ច នេះមុន ករណីយក៏មាន អករណីយក៏មាន ។ បណ្តាពីរយ៉ាងនោះ ដោយសង្ខេប សិក្ខា ៣ ឈ្មោះថា ករណីយៈ ។ សីលវិបត្តិ ទិដ្ឋិវិបត្តិ អាចារវិបត្តិ

អាជីវវិបត្តិ ដូចពោលមកយ៉ាងនេះជាដើម ឈ្មោះថា **អករណីយៈ** ។ ម្យ៉ាងទៀត អត្ថកោសលក៏មាន អនត្ថកោសលក៏មាន ។ បណ្ដា ២ យ៉ាងនោះ កុលបុត្របួសក្នុងព្រះសាសនានេះ មិនប្រកបខ្លួនទុកដោយប្រពៃជាអ្នកមានសីលដាច់ អាស្រ័យ **អនេសនៈ**(ការស្វែងរកមិនសមគួរ) ២១ យ៉ាងដើម្បីចិញ្ចឹមជីវិត គឺ

១-វេឡុទានំ= ឱ្យឫស្សី

២-បត្តទានំ = ឱ្យស្លឹកឈើ

៣- បុប្ផទានំ = ឱ្យផ្កាឈើ

៤-ផលទានំ = ឱ្យផ្លែឈើ

៥- ទន្តកដ្ឋទានំ = ឱ្យឈើជម្រះធ្មេញ

៦- មុខោទកទានំ = ឱ្យទឹកលាងមុខ

៧- សិនានទានំ = ឱ្យទឹកងូត

៨- ចុណ្ណទានំ = ឱ្យម្សៅលាបខ្លួន

៩- មត្តិកាទានំ = ឱ្យដីដុសខ្លួន

១០- ចាដុកម្យតំ = ផ្គាប់ផ្គុន

១១-មុគ្គសូប្យតំ =និយាយពិតលាយកុហក(ដូចបបរសណ្ដែកបាយ)

១២-ចារិភជយតំ = ចិញ្ចឹមកូនឱ្យគេ

១៣-ជង្ឃបេសនិកំ =ទទួលបម្រើគ្រហស្ថ

១៤-វេជ្ជកម្មំ=ធ្វើខ្លួនជាពេទ្យព្យាបាល

១៥-ទូតកម្មំ =ធ្វើខ្លួនជាទូត

១៦-បហិណាគមនំ =ទទួលបញ្ជូនសារគ្រហស្ថ

១៧-បិណ្ឌបដិបិណ្ឌំ = ការឱ្យចង្ហាន់បិណ្ឌបាតដល់ត្រកូល

១៨-នានានុប្បទានំ=ឱ្យទៅឱ្យមក

១៩-វត្ថុវិជ្ជំ =ធ្វើជាហោរមើលផ្ទៃដី

២០-នក្ខត្តវិជ្ជំ =ធ្វើជាគ្រូមើលនក្ខត្តឫក្ស

២១-អង្គវិជ្ជនំ =ធ្វើជាគ្រូមើលលក្ខណៈ

និងប្រព្រឹត្តអគោចរៈ ៦ យ៉ាងគឺ

១-វេសិយាគោចរេ =ត្រាច់ទៅកាន់សម្នាក់ស្ត្រីពេស្យា

២-វិធវគោចរេ = ត្រាច់ទៅកាន់សម្នាក់ស្ត្រីមេម៉ាយ

សម្រាប់ជាធម្មទាន

៣-ថុល្លកុមារិកគោចរេ = ត្រាច់ទៅកាន់សម្នាក់ស្ត្រីក្រមុំចាស់

៤-បណ្ឌកគោចរេ = ត្រាច់ទៅកាន់សម្នាក់មនុស្សខ្ទើយ

៥-ភិក្ខុនីគោចរេ = ត្រាច់ទៅកាន់សម្នាក់នាងភិក្ខុនី

៦-បានាគារគោចរេ = ត្រាច់ទៅកាន់រោងស្រា ។

និងការសេពគប់ស្និទ្ធស្នាលជាមួយគ្រហស្ថផង ព្រះរាជាផង ព្រះរាជអាមាត្យរបស់ព្រះរាជាផង តិរ្ថិយផង សាវ័ករបស់តិរ្ថិយផង ដោយការសេពគប់ស្និទ្ធស្នាល ដែលមិនសមគួរ ។ ការសេពគប់ចូលចិត្តត្រកូលដែលមិនមានសទ្ធា មិនមានសេចក្ដីជ្រះថ្លា មិនដូចជាអណ្ដូងទឹក ជេរ និងស្ដីបន្ទោស សង្ឃឹមតែប្រយោជន៍ មិនគាំទ្រ មិនប្រព្រឹត្តិដើម្បីសេចក្ដីសុខសាន្ត មិនដើម្បីប្រាសចាកយោគៈ ដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា កុលបុត្រនោះឈ្មោះថា អ្នកឈ្លាសក្នុងវត្ថុដែលមិនមានប្រយោជន៍ ។

ម្យ៉ាងទៀត កុលបុត្រណា បួសក្នុងព្រះសាសនានេះ ប្រកបខ្លួនដោយពេញចិត្តលះអនេសនៈប្រាថ្នាតែនឹងតាំងនៅក្នុងចតុបារិសុទ្ធិសីល បំពេញបាតិមោក្ខសំវរសីល ដោយសទ្ធាជាសំខាន់ បំពេញឥន្ទ្រិយសំវរសីល ដោយសតិជាសំខាន់ បំពេញអាជីវបារិសុទ្ធិសីល ដោយសេចក្ដីព្យាយាមជាសំខាន់ បំពេញនូវបច្ចយសន្និស្សិតសីល ដោយបញ្ញាជាសំខាន់ កុលបុត្រនោះឈ្មោះថា អ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត កុលបុត្រណាជម្រះបាតិមោក្ខសំវរសីល ដោយជម្រះអាបត្តិ ៧ កង ជម្រះឥន្ទ្រិយសំវរសីល ដោយមិនឱ្យអភិជ្ឈាជាដើមកើតក្នុងអារម្មណ៍ ដែលប៉ះខ្ទប់ក្នុងទ្វារ ៦ ជម្រះអាជីវបារិសុទ្ធិសីល ដោយវៀរចាកអនេសនៈ និងប្រើប្រាស់បច្ច័យដែលវិញ្ញូជន ព្រះពុទ្ធ និងពុទ្ធសាវកសរសើរហើយ ជម្រះការប្រើប្រាស់បច្ច័យ ដោយការពិចារណាបច្ច័យតាមដែលពោលហើយ និងជម្រះការសម្បជញ្ញៈ ដោយការពិចារណានូវសាត្ថកសម្បជញ្ញៈជាដើម ក្នុងការផ្លាស់ប្តូរឥរិយាបថទាំង ៤ សូម្បីកុលបុត្រនោះ ក៏ឈ្មោះថា អ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត បុគ្គលណាដឹងថា សំពត់កខ្វក់អាស្រ័យទឹកអំបិល ក៏ធ្វើឱ្យស្អាតបាន កញ្ចក់អាស្រ័យផេះក៏ធ្វើឱ្យស្អាតបាន មាសអាស្រ័យឡសម្រាប់ដុតរម្លាយលោហធាតុធ្វើឱ្យបរិសុទ្ធបាន យ៉ាងណា សីលអាស្រ័យញាណ(បញ្ញា) ក៏ធ្វើឱ្យបរិសុទ្ធបានយ៉ាងនោះ ហើយជម្រះដោយទឹកគឺញាណ ក៏ធ្វើសីលឱ្យបរិសុទ្ធបាន ។ ប្រៀបដូចសត្វត្រដេវរ៉ិចរក្សាពង សត្វចាមរីរក្សារោមកន្ទុយ ស្ត្រីមានបុត្រតែមួយ រក្សាបុត្រតែមួយរបស់ខ្លួន បុរសអ្នកមានភ្នែកតែម្ខាងរក្សាភ្នែកតែម្ខាងនោះទុកយ៉ាងណា កុលបុត្រអ្នកមិនប្រមាទយ៉ាងក្រៃលែង ក៏រក្សាសីលក្ខន្ធរបស់ខ្លួនក៏យ៉ាងនោះ គេពិចារណាទាំងព្រឹកល្ងាច ក៏មិនឃើញទោសសូម្បីប្រមាណតិច សូម្បីកុលបុត្រនោះ ក៏ឈ្មោះថា អ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត កុលបុត្រណាតាំងនៅក្នុងសីល ដោយមិនធ្វើសេចក្តីក្តៅក្រហាយ

រមែងកាន់យកបដិបទា ជាគ្រឿងសង្កត់សង្កិនទូវកិលេស ។ ការកាន់យកបដិបទា នោះហើយរមែងធ្វើបរិកម្មក្នុងកសិណកាលធ្វើបរិកម្មហើយ រមែងញ៉ាំងសមាបត្តិ ទាំងឡាយឱ្យកើត ។ សូម្បីកុលបុត្រនោះ ក៏ឈ្មោះថា អ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត កុលបុត្រណាចេញចាកសមាបត្តិ ពិចារណាសង្ខារទាំងឡាយ រមែងចាក់ធ្លុះព្រះអរហត្ត កុលបុត្រនេះជាកំពូលអ្នកឈ្លាសក្នុងប្រយោជន៍ ។ កុលបុត្រនេះ ជាអ្នកឈ្លាសក្នុងប្រយោជន៍ ដែលលោកសរសើរហើយ ដោយត្រឹមតែការតាំងនៅក្នុងសីល ដែលមិនមានសេចក្ដីក្ដៅក្រហាយ ឬដោយត្រឹមតែការកាន់យកនូវបដិបទា ជាគ្រឿងសង្កត់សង្កិនទូវកិលេស កុលបុត្រនោះ លោកបំណងថា អ្នកឈ្លាសក្នុងប្រយោជន៍ក្នុងអត្ថនេះ ។ និងកុលបុត្រទាំងនោះ ក៏មានសភាពយ៉ាងនោះ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់សំដៅដល់កុលបុត្រទាំងនោះ ទើបត្រាស់សម្ដែងដោយទេសនាជាបុគ្គលាធិដ្ឋានប៉ុណ្ណោះ ហើយត្រាស់ទៀតថា ករណីយមត្ថកុសលេន អ្នកឈ្លាសក្នុងប្រយោជន៍គប្បីធ្វើដូច្នេះ ។

តអំពីនោះ កាលកុលបុត្រទាំងនោះ កើតសេចក្ដីសង្ស័យថា កិច្ចដែលត្រូវធ្វើអ្វីខ្លះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា យន្តំ សន្តំ បទំ អភិសមេច្ច ។ ក្នុងពាក្យ នេះមានអធិប្បាយដូច្នេះ៖ កិច្ចឯណា ដែលកុលបុត្រតែងប្រាថ្នាដើម្បីធ្លុះចំពោះ ដោយអំណាចនៃការសម្រេចនូវសន្តិបទ គឺព្រះនិព្វាន កិច្ចនោះ គឺព្រះពុទ្ធ

និងអនុពុទ្ធទាំងឡាយ តែងសរសើរ ។ ក៏ក្នុងពាក្យនេះ គប្បីជ្រាបថា បទថា យំ ខ្ញុំពោលទុកខាងដើមបទគាថានេះនោះហើយ រមែងប្រព្រឹត្តទៅដោយអធិការថា ករណីយំ គឺ តំ សន្តំ បទំ អភិសមេច្ច ។ ព្រោះហេតុតែសេចក្តីនេះ មានបាឋៈដែលនឹងត្រូវផ្តើមពាក្យដ៏សេស ដូច្នេះ ខ្ញុំទើបពោលថា វិហារិតុកាមេន ។

ម្យ៉ាងមួយទៀត ក្នុងពាក្យនេះគប្បីជ្រាបអធិប្បាយយ៉ាងនេះថា បទថា សន្តំ បទំ អភិសមេច្ច រមែងប្រព្រឹត្តទៅអធិការថា កិច្ចឯណា ដែលអ្នកបំណងនឹងដឹងបទ គឺព្រះនិព្វានថា សន្តៈ (ស្ងប់) ដោយលោកិយបញ្ញា ដោយការស្តាប់តគ្នាមកជាដើម និងចាក់ធ្លុះសន្តិបទ គឺព្រះនិព្វាននោះ កិច្ចនោះ គឺកុលបុត្រគប្បីធ្វើ ។ ន័យមួយទៀត កាលត្រាស់ថា ករណីយមត្ថកុសលេន កាលកុលបុត្រទាំងឡាយនាំគ្នាគិតថាអ្វី ទើបត្រាស់ថា យន្តំ សន្តំ បទំ អភិសមេច្ច ន័យនោះគប្បីជ្រាបអធិប្បាយយ៉ាងនេះ កិច្ចណា គឺកុលបុត្រដឹងបទដែលស្ងប់ ដោយលោកិយបញ្ញាហើយ គប្បីធ្វើ គប្បីប្រកប កិច្ចនោះ គឺកុលបុត្រគួរធ្វើ លោកអធិប្បាយថា កិច្ចនោះ គឺកុលបុត្រ គួរដល់ការធ្វើ ។

សួរថា កិច្ចនោះគឺអ្វី ? ឆ្លើយថា កិច្ចអ្វីដទៃក្រៅតែពីការប្រាស់ចាកឧបាយជាគ្រឿងចាក់ធ្លុះនិព្វានបទនោះ គប្បីមាន ។ កិច្ចនោះ ខ្ញុំពោលទុកហើយ

ដោយបទដើមដែលសម្ដែងសិក្ខា ៣ ព្រោះអត្ថថា គួរដល់ការធ្វើ ក៏ពិតមែនហើយ ក៏ប៉ុន្តែថា ក្នុងការពណ៌នាសេចក្ដីនៃពាក្យនោះ ខ្ញុំក៏បានពោលទុកហើយថា **ករណីយៈ**ក៏មាន **អករណីយៈ**ក៏មាន ។ បណ្ដាពាក្យពីរយ៉ាងនោះ ដោយសង្ខេប សិក្ខា ៣ ឈ្មោះថា **ករណីយៈ** ។ ព្រោះតែទ្រង់សម្ដែងទុកសង្ខេបពេក បណ្ដាភិក្ខុទាំងនោះ ភិក្ខុពួកខ្លះដឹង ភិក្ខុពួកខ្លះមិនដឹង ។ តែកាលត្រាស់កិច្ច ដោយចំពោះយ៉ាងក្រៃលែងដល់ភិក្ខុ អ្នកនៅក្នុងព្រៃគួរធ្វើឱ្យពិស្ដារ ដើម្បីឱ្យពួកភិក្ខុដែលមិនដឹងបាន ទើបត្រាស់កន្លះគាថានេះមុនថា សក្កោ ឧជូ ច សុហុជូ ច សុវចោ ចស្ស មុទុ អនតិមានី ។

លោកអធិប្បាយទុកថាយ៉ាងណា លោកអធិប្បាយថា ភិក្ខុអ្នកនៅព្រៃ បំណងចាក់ធ្លុះសន្តិបទ ឬចាក់ធ្លុះសន្តិបទនោះដោយលោកិយបញ្ញា ហើយបដិបត្តិដើម្បីចាក់ធ្លុះសន្តិបទនោះ មិនអាល័យក្នុងកាយ និងជីវិត ដោយប្រកបដោយបធានិយង្គនៈ ២ និង ៤ គប្បីជាអ្នកអាចបដិបត្តិដើម្បីចាក់ធ្លុះរហូតដល់សច្ចៈ ករណីយកិច្ចដដែលគួរធ្វើណានីមួយ មិនថាខ្ពស់ ឬទាបរបស់សព្រហ្មចារី ក្នុងការបរិកម្ម កសិណ សមាទានវត្តជាដើម និងការជួសជុលឱ្យល្អឡើងវិញនូវបាត្រចីវរជាដើមរបស់ខ្លួន ក៏គប្បីអង់អាច គប្បីឧស្សាហ៍ មិនខ្ជិលច្រអូស ប្រាជ្ញាក្នុង

ករណីយកិច្ចទាំងនោះ និងក្នុងកិច្ចដូចនោះយ៉ាងដទៃក៏ដូចគ្នា ។ សូម្បីកាលជាអ្នកអង់អាច ក៏គប្បីជាអ្នកត្រង់ដោយការប្រកបនូវបធានិយង្គទី ៣ ។ សូម្បីកាលជាអ្នកត្រង់ ក៏គប្បីជាអ្នកត្រង់ដោយល្អ ដោយជាអ្នកត្រង់គ្រាតែមួយ ឬដោយជាអ្នកត្រង់ក្នុងវេលានៅកម្លោះ ដោយមិនដល់នូវការសន្តោស តែធ្វើមិនឱ្យស្រោលធ្វើឱ្យរឿយៗ រហូតដល់អស់ជីវិត ឬថា ឈ្មោះថា ត្រង់(ឧជុ) ព្រោះធ្វើដោយការមិនអួតអាងថា ល្អ ឈ្មោះថា ត្រង់ដោយល្អ (សុហុជូ) ព្រោះមិនមានមាយា ។ ឬថា ឈ្មោះថា ត្រង់ ព្រោះលះភាពកោងនៃកាយ និងវាចា ឬថាត្រង់ដោយល្អព្រោះលះភាពកោងនៃចិត្ត ។ ឬឈ្មោះថា ត្រង់ ព្រោះមិនអួតនូវគុណដែលមិនមាន ។ ឈ្មោះថា ត្រង់ដោយល្អ ព្រោះមិនអត់ទ្រាំចំពោះលាភ ដែលកើតឡើងដោយគុណដែលមានមិន ។ ឈ្មោះថាជាអ្នកត្រង់ និងត្រង់ដោយល្អ ដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ដោយសិក្ខា ២-៣ ខាងដើម និងដោយបយោគសុទ្ធិ និងអាសយសុទ្ធិដោយប្រការដូច្នេះ ។

ភិក្ខុមិនត្រឹមតែជាអ្នកត្រង់ និងត្រង់ដោយល្អប៉ុណ្ណោះទេ ថែមទាំងជាអ្នកប្រដៅងាយទៀតផង ។ ក៏បុគ្គលណាត្រូវលោកពោលថា លោកមិនគួរធ្វើសេចក្តីនេះ ក៏ពោលថា លោកឃើញអ្វី លោកបានឮយ៉ាងណា លោកជាអ្វីជាមួយនឹង

យើង ទើបពោលតបយ៉ាងនេះថា ជាឧបជ្ឈាយ៍ អាចារ្យ មិត្តឃើញគ្នាម្ដងម្កាលឬ ឬមិត្រជិតស្និទ្ធ រមែងបៀតបៀនអ្នកដោយកុំឱ្យនិយាយ ឬមិនព្រមទទួលធ្វើ យ៉ាងនោះ អ្នកនោះឈ្មោះថា នៅឆ្ងាយចាកការចាក់ដុះគុណវិសេស ។ ចំណែក អ្នកណាត្រូវលោកឱ្យឱវាទ ក៏ពោលថា ប្រពៃហើយ លោកម្ចាស់ លោកពោលល្អ ហើយ ។ ឈ្មោះថា ទោសរបស់ខ្លួនជារបស់ គឺខ្លួនឃើញបានលំបាក លោក ឃើញខ្ញុំមានសភាពយ៉ាងនោះ អាស្រ័យមេត្តាសូមពោលទៀតចុះ ខ្ញុំមិនបាន ទទួលឱវាទអំពីសម្នាក់របស់លោកយូរណាស់មកហើយ និងបដិបត្តិតាមដែល លោកបង្រៀន បុគ្គលនោះឈ្មោះថា នៅជិតការចាក់ដុះគុណវិសេស ព្រោះដូច្នោះ បុគ្គលទទួលពាក្យរបស់អ្នកដទៃហើយធ្វើយ៉ាងនេះ ឈ្មោះថា ជាបុគ្គលអ្នក ប្រដៅងាយ ។

មួយទៀត ជាអ្នកប្រដៅងាយយ៉ាងណា ក៏គប្បីជាអ្នកទន់ភ្លន់ក៏យ៉ាងនោះ ដែរ ។ បទថា មុទុ សេចក្ដីថា ភិក្ខុត្រូវពួកគ្រហស្ថប្រើក្នុងការជាទូត ទៅទទួល បញ្ជូនសារជាដើម ក៏មិនធ្វើការទន់ជ្រាយក្នុងកិច្ចនោះ ជាអ្នកមាំទាំ គប្បីជាអ្នក ទន់ភ្លន់ក្នុងវត្តបដិបត្តិ និងព្រហ្មចារ្យទាំងអស់ ការមិនត្រូវទទួលប្រើក្នុងកិច្ចនោះ ដូចមាសដែលជាងគុបតែងដោយល្អ ។ ម្យ៉ាងទៀត បទថា មុទុ បានដល់

ជាអ្នកមិនមានមុខចងចិញ្ចើម គឺជាអ្នកមានមុខរីករាយ ចរចារតែពាក្យដែលឱ្យកើតតែសេចក្ដីសុខ ប្រៀបដូចកំពង់ទឹកល្អហើយងាយស្រួលចុះ ។ មិនត្រឹមតែជាអ្នកទន់ភ្លន់ប៉ុណ្ណោះទេ គប្បីជាអ្នកមិនមានអតិមានះផង ។ មិនគប្បីមើលងាយអ្នកដទៃ ដោយវត្ថុនៃការមើលងាយមានជាតិ និងគោត្រជាដើម គប្បីជាអ្នកមានចិត្តស្មើដោយក្មេងចណ្ឌាល ដូចព្រះសារីបុត្តត្ថេរដូច្នេះ ។

## ទុតិយាគាថាវណ្ណនា

### ពណ៌នាគាថាទី ២

ព្រះដ៏មានព្រះភាគត្រាត្រាស់ករណីយកិច្ច ដោយចំណែកមួយរបស់ភិក្ខុអ្នកនៅព្រៃ ដែលបំណងនូវការចាក់ធ្លុះសន្តិបទ ឬបដិបត្តិដើម្បីចាក់ធ្លុះសន្តិបទនោះយ៉ាងនោះហើយ មានពុទ្ធបំណងនឹងត្រាស់បន្តទៅទៀត ទើបត្រាស់គាថាទី ២ ថា សន្តុស្សកោ ច ជាដើម ។ ក្នុងគាថាទី ២ នោះ ភិក្ខុឈ្មោះថា សន្តោស ព្រោះសន្តោស ដោយសន្តោស ១២ យ៉ាង មានប្រការដូចពោលទុក ហើយក្នុងមង្គលសូត្រនោះថា សន្តុដ្ឋី ច កតញ្ញុតា នេះ ។ ន័យម្យ៉ាងទៀត ភិក្ខុណា រមែងត្រេកអរ ហេតុនោះ ភិក្ខុនោះ ឈ្មោះថា **តុស្សកះ** អ្នកត្រេកអរ ភិក្ខុ អ្នកត្រេកអរដោយរបស់ខ្លួនឯង អ្នកត្រេកអរនូវរបស់ដែលមាន អ្នកត្រេកអរដោយរបស់

ស្មើ ហេតុនោះ ទើបឈ្មោះថា **សន្តុស្សកៈ** អ្នកសន្តោស ។ បណ្តាលក្ខណៈ ៣ យ៉ាងនោះ បច្ច័យ ៤ ដែលលោកសម្តែងក្នុងពេលឧបសម្បទាយ៉ាង នេះថា បិណ្ឌិយាលោបភោជនំ និស្សាយ អាស្រ័យភោជន គឺបាយដែលរកមក ដោយស្មងជើងជាដើម និងខ្លួនទទួលទុកហើយ ឈ្មោះថា របស់ខ្លួន។ ភិក្ខុមិន សម្តែងអាការៈខុសប្រក្រតីក្នុងវេលាទទួល និងវេលាបរិភោគ ញ៉ាំងអត្តភាពឱ្យ ប្រព្រឹត្តទៅ ដោយបច្ច័យរបស់ខ្លួនល្អក្តី មិនល្អក្តី ដែលគេប្រគេនដោយគោរពក្តី ហៅថា អ្នកត្រេកអរដោយរបស់ខ្លួន ។ របស់ណាបានមកហើយ មានដល់ខ្លួន របស់នោះឈ្មោះថា មាននៅ ។ ភិក្ខុត្រេកអរដោយរបស់មាននោះទុំះឯង មិន ប្រាថ្នារបស់ក្រៅអំពីនោះ លះភាពជាអ្នកប្រាថ្នាកើនចំណែក (លាភច្រើន) ហៅថា អ្នកត្រេកអរដោយរបស់ដែលមាន ។ ការលះសេចក្តីត្រេកអរ មិនពេញចិត្តក្នុង ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ឈ្មោះថា ស្មើ ។ ភិក្ខុត្រេកអរក្នុងអារម្មណ៍ទាំងពួង ដោយអាការៈស្មើនោះ ហៅថា អ្នកត្រេកអរដោយអាការៈស្មើ។

ឈ្មោះថា សុភរៈ ព្រោះគេចិញ្ចឹមដោយងាយ ។ លោកអធិប្បាយថា អ្នក ដែលគេចិញ្ចឹមងាយ ។ ភិក្ខុណា កាលមនុស្ស បានយកបាត្រដាក់បាយ ស្រូវ-សាលី និងដុំសាច់ឱ្យពេញប្រគេនហើយ សម្តែងការៈជាអ្នកមានមុខស្ងួត និង

ខ្ទប់ចិត្តហើយមើលងាយនូវបិណ្ឌបាតនោះ ចំពោះមុខជនទាំងនោះដោយពាក្យថា “ពួកលោកឱ្យអ្វី?” ក៏ឱ្យដល់សាមណេរ និងគ្រហស្ថទាំងឡាយ ភិក្ខុនោះ ឈ្មោះថា **ទុព្ភរៈ** (អ្នកដែលគេប្រដៅលំបាក) ។ មនុស្សទាំងឡាយឃើញភិក្ខុនោះហើយក៏គេចចេញអំពីចម្ងាយភ្លាមៗដោយពោលថា ភិក្ខុចិញ្ចឹមលំបាក នរណាក៏មិនអាចចិញ្ចឹមលោកបាន ។ ចំណែកភិក្ខុណា បានរបស់ក្រខ្វក់ ឬប្រណីត តិចឬច្រើន មានចិត្តល្អ មុខមាត់ស្រស់ថ្លាញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ ភិក្ខុនោះ ឈ្មោះថា **សុភរៈ** (អ្នកដែលគេចិញ្ចឹមបានដោយងាយ)។ មនុស្សទាំងឡាយ ឃើញភិក្ខុនោះ ជាអ្នកស្និទ្ធិស្នាល ក៏ប្ដេជ្ញាទទួលចិញ្ចឹមថា ព្រះគុណម្ចាស់របស់យើងចិញ្ចឹមងាយ រមែងត្រេកអររបស់បន្តិចបន្តួច យើងទាំងឡាយនឹងចិញ្ចឹមលោក ។ ភិក្ខុបែបនេះ លោកបំណងថាជា **សុភរៈ** អ្នកចិញ្ចឹមបានដោយងាយក្នុងទីនេះ ។

កិច្ចរបស់ភិក្ខុនោះតិច ហេតុនោះ ភិក្ខុនោះឈ្មោះថា អប្បកិច្ចៈ អ្នកមានកិច្ចតិច មិនមែនអ្នកខ្វល់ខ្វាយដោយកិច្ចច្រើនយ៉ាង ដូចជាសប្បាយ និងការងារសប្បាយ និងជជែកគ្នា សប្បាយសេពគប់ស្និទ្ធិស្នាលជាដើម ម្យ៉ាងទៀត ជាអ្នកវៀរកិច្ច មានការងារកសាង ការប្រៀនប្រដៅសាមណេរ និងអារាមិកជននូវទាំងវត្ត ។ លោកអធិប្បាយថា ការកោរសក់បួស កាត់ក្រចក ដាក់ស្ងោកបាត្រ ជួសជុលចីវរជាដើមរបស់ខ្លួន ។ ក្រៅអំពីកិច្ចនោះ គឺធ្វើសមណធម៌ ។

ការប្រព្រឹត្តរបស់ភិក្ខុនោះស្រាល ហេតុនោះ ភិក្ខុនោះ ឈ្មោះថា សល្លហុកវុត្តិ អ្នកមានការប្រព្រឹត្តស្រាល ។ ភិក្ខុអ្នកមានបរិក្ខារច្រើនរូបខ្លះ វេលាចេញដើរផ្លូវក៏ឱ្យមហាជនលើកបាត្រ ចីវរ គ្រឿងក្រាល ប្រេង ទឹកអំពៅជាដើមដ៏ច្រើនទូល កណ្តៀតជាដើម យ៉ាងណា ភិក្ខុណាមិនមានសភាពដូច្នោះ រមែងជាអ្នកមានបរិក្ខារតិច រក្សាត្រឹមតែសមណបរិក្ខារ ៨ មានបាត្រចីវរជាដើម[១]ប៉ុណ្ណោះ វេលាដើរផ្លូវ ក៏ដើរទៅដូចបក្សាមានតែស្លាប ភិក្ខុបែបនោះ លោកបំណាងថា ជាអ្នកមានការប្រព្រឹត្តស្រាលក្នុងទីនេះ ។ ឥន្ទ្រិយទាំងឡាយរបស់ភិក្ខុនោះស្ងប់ ហេតុនោះ ភិក្ខុនោះ ឈ្មោះថា អ្នកមានឥន្ទ្រិយស្ងប់ ។ លោកអធិប្បាយថា អ្នកមានឥន្ទ្រិយមិនរាយមាយ ដោយអំណាចរាគៈជាដើមក្នុងឥដ្ឋារម្មណ៍ជាដើម ។ បទថា និបកោ បានដល់ អ្នកជាវិញ្ញូជន គឺដឹងច្បាស់ បានដល់ អ្នកមានបញ្ញា អធិប្បាយថា អ្នកប្រកបដោយបញ្ញាជាគ្រឿងតាមរក្សាសីល ដោយបញ្ញាកំណត់បច្ច័យ ៤ មាន

---

១-អដ្ឋបរិក្ខាររបស់សមណៈ មាន ប្រាំបី គឺ សង្ឃាដិ ឧត្តរាសង្គ(ចីពរ) អន្តរវាសក (ស្បង់) កាយពន្ធនៈ(វត្ថពន្ធចង្កេះ) បាត្រ (ព្រមទាំងស្លោក និងយោគផង) កាំបិតកោរ (ព្រមទាំងថ្មសំលៀងផង) ម្ជុល(ព្រមទាំងបំពង់ម្ជុល និងចេសផង) តម្រងទឹក (ទាំងតួ និងសំពត់សម្រាប់ត្រងផង) ។

ចីវរជាដើម និងដោយបញ្ញាជាគ្រឿងដឹងនូវសប្បាយ ៧ យ៉ាង[១] មានអាវាស-សប្បាយជាដើម ។

អ្នកមិនធ្វើឫក ហេតុនោះឈ្មោះថា **អប្បគព្ភ:** អ្នកមិនធ្វើឫក អធិប្បាយថា វៀរចាកការធ្វើឫកតាមផ្លូវកាយ ៨ ឋាន ចាកការធ្វើឫកតាមវាចា ៤ ឋាននិងចាកការធ្វើឫកផ្លូវចិត្តច្រើនឋាន ។

ការធ្វើមិនសមគួរតាមកាយ ក្នុងសង្ឃ គណៈ បុគ្គល រោងឆាន់ រោងភ្លើង កំពង់ងូតទឹក ផ្លូវបិណ្ឌបាត និងការចូលកាន់បរិវេណជិតៗភូមិ ឈ្មោះថា ការធ្វើឫកតាមកាយ ៨ ឋាន ។ មានយ៉ាងនេះថា ភិក្ខុរូបខ្លះក្នុងសាសនានេះអង្គុយត្របោមក្បាលជង្គង់ ឬយកជើងដាក់ជើងក្នុងកណ្តាលសង្ឃ ។ ក្នុងកណ្តាលគណៈ ក្នុងទីប្រជុំបរិស័ទទាំង ៤ ក៏ដូចគ្នា ក្នុងបុគ្គលអ្នកចាស់ជាងក៏ដូចគ្នា ។ ចំណែកក្នុងរោងឆាន់ ភិក្ខុមិនឱ្យអាសនៈដល់អ្នកមានវស្សាច្រើនជាង ហាមអាសនៈដល់ភិក្ខុថ្មីក្នុងរោងភ្លើងក៏ដូចគ្នា ។ ក៏ក្នុងរោងភ្លើងនោះ ភិក្ខុមិនសូមឱកាសដល់ភិក្ខុអ្នក

---

១-វិសុទ្ធមគ្គ ភាគ ១ ទំព័រ ២៤៩ លោកសំដែងថា សប្បាយ ៧ យ៉ាងគឺ អាវាសសប្បាយ ១ គោចរ-សប្បាយ ១ កថាជាគ្រឿងពោលសប្បាយ ១ បុគ្គលសប្បាយ ១ ភោជនសប្បាយ ១ ឧតុសប្បាយ ១ ឥរិយាបថសប្បាយ ១ ។

មានវស្សាច្រើនជាង ធ្វើការបង្អាត់ភ្លើងជាដើម ។ ចំណែកកំពង់ងូតទឹក លោកពោលនេះថា មិនត្រូវប្រកាន់ថា មានវស្សាចាស់ជាង ឬខ្ចីជាង គប្បីងូតទឹកតាមលំដាប់អ្នកមកដល់ ភិក្ខុមិនអើពើពាក្យនោះ មកក្រោយក៏ចុះទឹក បៀតបៀនភិក្ខុចាស់ ឬភិក្ខុថ្មី ។ ចំណែកផ្លូវបិណ្ឌបាត ភិក្ខុទៅខាងមុខៗ យកដៃប៉ះដៃភិក្ខុអ្នកមានវស្សាច្រើនជាង ដើម្បីបំណាំងអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ និងអាហារដ៏ប្រសើរ ។ ក្នុងការចូលទៅកាន់បរិវេណជិតៗភូមិ ក៏មានជាដើមយ៉ាងនេះថា ភិក្ខុចូលទៅមុខភិក្ខុអ្នកមានវស្សាចាស់ជាង ធ្វើការលេងផ្លូវកាយជាមួយភិក្ខុកម្លោះនោះ ។

ការបន្ទឹវាចាមិនសមគួរ ក្នុងសង្ឃ គណៈ បុគ្គល និងបរិវេណជិតៗ ឈ្មោះថា ធ្វើឫកតាមវាចា ៤ ឋាន គឺជាដើមយ៉ាងនេះថា ភិក្ខុរបខ្វះក្នុងសាសនានេះ មិនសូមឱកាសក្នុងកណ្ដាលសង្ឃពោលធម៌ ។ ក្នុងគណៈ ក្នុងបុគ្គលអ្នកចាស់ជាងដូចដែលពោលមកមុនហើយដូចគ្នា ។ ក្នុងទីនេះ ភិក្ខុត្រូវមនុស្សទាំងឡាយ សួរបញ្ហា មិនសូមឱកាសភិក្ខុអ្នកមានវស្សាចាស់ជាងក៏ឆ្លើយបញ្ហា ។ ចំណែកក្នុងបរិវេណជិតៗស្រុក ភិក្ខុពោលជាដើមយ៉ាងនេះថា មានអ្វីក្នុងស្រុកនោះ បបរ ឬរបស់គួរ ទំពាស៊ី លោកនឹងឱ្យអ្វីដល់យើង ថ្ងៃនេះយើង ទំពាស៊ីអ្វី បរិភោគអ្វី និងផឹកអ្វី ។

សូម្បីមិនដល់សេចក្ដីល្មើសតាមផ្លូវកាយវាចា ក្នុងឋានទុំះ ៗ តែក៏មាន

វិតក្កៈដែលមិនសមគួរប្រការផ្សេងៗ មានកាមវិតក្កៈជាដើម តាមផ្លូវចិត្តឈ្មោះថា ការធ្វើឫក តាមផ្លូវចិត្តមានច្រើនហ៊ាន ។

បទ កុលេសុ អននុគិទ្ធោ សេចក្តីថា ភិក្ខុចូលទៅរកត្រកូលទាំងនោះ មិនដោយសេចក្តីប្រាថ្នាបានបច្ច័យ ឬដោយការសេពគប់ស្និទ្ធិស្នាល ដែលមិនសមគួរក្នុងត្រកូលទាំងនោះ លោកអធិប្បាយថា មិនសោកសៅរួមគ្នា មិនរីករាយរួមគ្នា មិនសុខផង កាលត្រកូលទាំងនោះប្រកបសុខ មិនប្រកបទុក្ខផង កាលត្រកូលទាំងនោះប្រកបទុក្ខ ឬកាលករណីយកិច្ចទាំងឡាយកើតឡើង ក៏មិនចូលប្រកបដោយខ្លួនឯង ។ ក៏បទថា អស្ស ដែលត្រាស់ទុកក្នុងបទថា សុវចោ អស្ស នៃគាថានេះ គប្បីប្រកបចូលជាមួយបទយ៉ាងនេះថា សន្តុស្សកោ ច អស្ស សុភរោ ច អស្ស ។

តតិយគាថាវណ្ណនា

**ពណ៌នាគាថាទី ៣**

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលត្រាស់ប្រាប់ករណីយកិច្ច សូម្បីលើសនោះ ដោយចំពោះយ៉ាងច្រើនដល់ភិក្ខុអ្នកនៅព្រៃ ដែលបំណងនឹងចាក់ធ្លុះសន្តិបទ ហើយនៅ ឬបំណងនឹងបដិបត្តិដើម្បីចាក់ធ្លុះសន្តិបទនោះយ៉ាងនេះហើយ ឥឡូវ

នេះ មានព្រះបំណងនឹងត្រាស់ប្រាប់អករណីយៈ ទើបត្រាស់កន្លះគាថាយ៉ាងនេះថា

ន ច ខុទ្ទំ សមា ចរេ កិញ្ចិ យេន វិញ្ញូ បរេ ឧបវទេយ្យុំ ។

កន្លះគាថានោះ មានសេចក្តីដូច្នេះ ភិក្ខុកាលធ្វើករណីយកិច្ចយ៉ាងនេះ ក៏មិនគប្បីប្រព្រឹត្តកាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត ដែលហៅថា **ខុទ្ទៈ** គឺកាលមិនប្រព្រឹត្តដ៏លាមក មិនមែនមិនប្រព្រឹត្តតែកម្មអាក្រក់តែម្យ៉ាង សូម្បីកម្មតិចតួចអ្វី ៗ ក៏មិនប្រព្រឹត្ត លោកអធិប្បាយថា មិនប្រព្រឹត្តកម្មលាមក ទាំងចំនួនតិច ទាំងចំនួនច្រើន ។

អំពីនោះ ព្រះមានព្រះភាគទ្រង់សម្តែង ទោសដែលឃើញបានដោយខ្លួនឯង ក្នុងការប្រព្រឹត្តកម្មដ៏លាមកនោះថា យេន វិញ្ញូ បរេ ឧបវទេយ្យុំ ។ ក៏ក្នុងពាក្យនេះព្រោះហេតុដែលអ្នកមិនមែនជាវិញ្ញូជនពួកដទៃ មិនយកជាប្រមាណ ។ ព្រោះវិញ្ញូជនពួកនោះនៅធ្វើ កម្មមិនមានទោស ឬមានទោស មានទោសតិច ឬទោសច្រើន ។ ចំណែកវិញ្ញូជនទាំងឡាយប៉ុណ្ណោះ កាន់ជាប្រមាណបាន ។ ព្រោះថា វិញ្ញូជនទាំងនោះ គិតសញ្ជឹងសាឡើងវិញហើយ រមែងតិះដៀលអ្នកដែលគួរតិះដៀល សរសើរអ្នកដែលគួរសរសើរ ។ ដូច្នោះ ទើបត្រាស់ថា វិញ្ញូ បរេ ។

ព្រះមានព្រះភាគជាម្ចាស់ គ្រាត្រាស់ឧបចារៈនៃកម្មដ្ឋានផ្សេង ដោយករណីយកិច្ច និងអករណីយកិច្ច ដោយចំពោះតែម្យ៉ាងដល់ភិក្ខុអ្នកនៅព្រៃ ដែលបំណងនឹងចាក់ធ្លុះសន្តិបទហើយ ឬបំណងបដិបត្តិដើម្បីចាក់ធ្លុះសន្តិបទនោះ និងដល់ពួកភិក្ខុអ្នកបំណងនឹងទទួលយកកម្មដ្ឋានសូម្បីគ្រប់រូប ដោយលើកភិក្ខុអ្នកនៅព្រៃជាសម្គាល់ ដោយពីរគាថាកន្លះយ៉ាងនេះហើយ ឥឡូវនេះទើបទ្រង់ផ្តើមត្រាស់មេត្តាកថា ដោយន័យថា **សុខិនោ វា ខេមិនោ ហោន្តុ** ជាដើម ដើម្បីជាព្រះបរិត្តកម្ចាត់ភ័យអំពីទេវតានោះ និងដើម្បីជាកម្មដ្ឋាន ដោយមានឈានជាបាទនៃវិបស្សនាដល់ភិក្ខុទាំងនោះ ។

បណ្តាបទទាំងនោះ បទថា **សុខិនោ** បានដល់ អ្នកដល់ព្រមដោយសុខ ។ បទថា **ខេមិនោ** ប្រែថា អ្នកមានសេចក្តីក្សេម ។ លោកអធិប្បាយថា អ្នកមិនមានភ័យ មិនមានឧបទ្ទវៈ ។ បទថា **សព្វេ** បានដល់ មិនសេសសល់ ។ បទថា **សត្តា** បានដល់ សត្វមានជីវិត ។ បទថា **សុខិតត្តា** បានដល់ អ្នកមានចិត្តជាសុខ ។ ក៏ក្នុងពាក្យនេះ គប្បីជ្រាបថា ឈ្មោះថា អ្នកមានសេចក្តីសុខ គឺសុខផ្លូវកាយ ។ ឈ្មោះថា មានចិត្តជាសុខ គឺសេចក្តីសុខផ្លូវចិត្ត ។ ឈ្មោះថា មានសេចក្តីក្សេម សូម្បីដោយសុខទាំងពីរនោះ ឬដោយការទៅប្រាសចាកភ័យ និង

ឧបទ្រវៈទាំងពួង ។ ក៏ហេតុអ្វី ទើបទ្រង់ត្រាស់យ៉ាងនេះ ។ ដើម្បីសម្តែងអាការៈនៃមេត្តាភាវនា ។ ក៏កាលជាយ៉ាងនេះ ទើបគួរនឹង ចម្រើនមេត្តាថា សូមសត្វទាំងពួង ចូរមានសេចក្តីសុខដូច្នេះខ្លះ ចូរមានសេចក្តីក្សេមដូច្នេះខ្លះ ចូរជាអ្នកមានខ្លួនដល់សេចក្តីសុខដូច្នេះខ្លះ ។

## ចតុត្ថគាថាវណ្ណនា

### ពណ៌នាគាថា ទី ៤

ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងមេត្តាភាវនា ដោយសង្ខេបតាំងពីឧបចារៈដល់អប្បនាជាទីបំផុតយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងមេត្តាភាវនានោះសូម្បីដោយពិស្តារ ទើបទ្រង់ត្រាស់ ២ គាថាថា យេ កេចិ ជាដើម ។ ន័យម្យ៉ាងទៀត ព្រោះចិត្តដែលសន្សំនៅក្នុងអារម្មណ៍ច្រើនៗ រមែងមិនឈប់នៅក្នុងអារម្មណ៍តែមួយដោយគ្រាដំបូងប៉ុណ្ណោះ ដែលនឹងជាប់តាមអារម្មណ៍ដោយលំដាប់ដូច្នោះ ទើបត្រាស់ ២ គាថាថា យេ កេចិ ជាដើម ដើម្បីចិត្តដែលជាប់តាមទៅហើយឈប់ក្នុងអារម្មណ៍ដែលមានប្រភេទនៃទុកៈពួក ២ នៃសត្វ និងតិកៈពួក ៣ នៃសត្វមាន

*តសថាវរទុកៈ[១]ជាដើម ។ ន័យម្យ៉ាងទៀត អារម្មណ៍ណា របស់អ្នកណា ជាអារម្មណ៍ ដែលប្រាកដច្បាស់ហើយ ចិត្តរបស់អ្នកនោះ រមែងតាំងនៅជាសុខក្នុងអារម្មណ៍នោះ ដូច្នោះអារម្មណ៍របស់ភិក្ខុរូបណា បណ្តាភិក្ខុទាំងនោះ ប្រាកដច្បាស់ហើយ ព្រះមានព្រះភាគជាម្ចាស់ មានព្រះពុទ្ធបំណងនឹងឱ្យចិត្តរបស់ភិក្ខុរូបនោះ តាំងនៅក្នុងអារម្មណ៍នោះ ទើបត្រាស់ ២ គាថាថា យេ កេចិ ជាដើម ដើម្បីបំភ្លឺសេចក្តីផ្សេងគ្នានៃអារម្មណ៍ជាទុកៈ និងតិកៈ មានតសថាវរទុកៈជាដើម ។*

*សេចក្តីពិតក្នុង ២ គាថានោះ ព្រះមានព្រះភាគទ្រង់សម្តែង ទុកៈពួក ២ មានសត្វ ៤ ទុកៈ គឺ **តសថាវរទុកៈ** (ពួក ២ នៃសត្វអ្នកតក់ស្លុត និងមាំមួន គឺមិនតក់ស្លុត) **ទិដ្ឋាទិដ្ឋទុកៈ** (ពួក ២ នៃសត្វដែលខ្លួនឃើញហើយ និងសត្វដែលខ្លួនទៅមិនឃើញ) **ទូរសន្តិកទុកៈ** (ពួក ២ នៃសត្វនៅទីឆ្ងាយ និងអ្នកនៅទីជិត) ១ **ភូតសម្ភវេសីទុកៈ** (ពួក២ នៃសត្វអ្នកដែលកើតហើយ និងអ្នកដែលកំពុងស្វែងរកទីកើត) ១ ។ និងទ្រង់សម្តែងតិកៈ ពួក ៣ នៃសត្វ ៣ តិកៈ គឺ **ទីឃរស្ស-***

---

១-រក្ខេយ្យ តសថាវរេតិ តសា វុច្ចន្តិ សតណ្ហា ថាវរា និត្តណ្ហា ។ ឥទំ វុត្តំ ហោតិ យោ និព្វានំ ចាបុណាតិ សោ សព្វំ តសថាវរំ រក្ខិតុំ សមត្ថោ ហោតិ ។ បបញ្ចសូទនិយា មជ្ឈិមនិកាយដ្ឋកថាយ អង្គុលិមាលសុត្តវណ្ណនា ។

**មជ្ឈិមតិកៈ** (ពួក ៣ នៃសត្វ អ្នកមានអត្តភាពវែង ទាប និងកណ្តាល) ១ **មហន្តាណុកមជ្ឈិមតិកៈ**( ពួក ៣ នៃសត្វអ្នកមានអត្តភាពធំ តូច និង កណ្តាល) ១ **ថូលាណុកមជ្ឈិមតិកៈ** (ពួក ៣ នៃសត្វអ្នកមានអត្តភាព ធាត់ ស្គម និងកណ្តាល) ១ ដោយមជ្ឈិមបទជា ទីកើតប្រយោជន៍ក្នុង ៣ តិកៈ និង**អណុកថូលបទ**ជាទីកើតប្រយោជន៍ក្នុង ២ តិកៈ ដោយបទ ៦ បទមាន**ទីឃបទ**ជាដើម ។ បណ្តាបទទាំងនោះ បទថា យេ កេចិ ជាពាក្យសម្តែងថាមិនមានចំណែកសេសសល់ឡើយ ។ ពួកសត្វដែលកើតហើយ ឈ្មោះថា **បាណភូត** ។ ន័យម្យ៉ាងទៀត សត្វទាំងឡាយរមែងដកដង្ហើម ហេតុនោះ ទើបឈ្មោះថា **បាណៈ** ។ ទ្រង់កាន់យក**បញ្ចវោការសត្វ** ដែលអាស្រ័យដោយអស្សាសបស្សាសៈ(ខ្យល់ដកដង្ហើមចេញចូល) ដោយបទនេះ ។ សត្វទាំងឡាយ រមែងកើត ហេតុនោះ ទើបឈ្មោះថា **ភូត** ។ ទ្រង់កាន់យកឯកវោការសត្វ និង ចតុវោការសត្វដោយបទនេះ ។ បទថា អត្ថិ ប្រែថា មាន គឺមានព្រម ។

ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងសត្វទាំងពួង ដែលទ្រង់សង្គ្រោះដោយទុកៈ និងតិកៈរួមគ្នា ដោយបទថា យេ កេចិ ចាណភូតត្ថិ នោះ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សង្គ្រោះសត្វទាំងនោះសូម្បីទាំងអស់ សម្តែងដោយទុកៈនេះថា

តសា វា ថាវរា វា អនវសេសា ។

បណ្តាបទទាំងនោះ សត្វទាំងឡាយរមែងតក់ស្លុត ហេតុនោះ ទើបឈ្មោះថា តសា ពាក្យនេះជាឈ្មោះរបស់សត្វទាំងឡាយ អ្នកមានតណ្ហា និងមានភ័យ ។ សត្វទាំងឡាយ រមែងមាំមួន ហេតុនោះ ទើបឈ្មោះថា ថាវរា ពាក្យនេះជាឈ្មោះរបស់ព្រះអរហន្តទាំងឡាយ អ្នកលះតណ្ហា និងភ័យបានហើយ ។ ចំណែកសេសសល់របស់សត្វទាំងនោះមិនមាន ហេតុនោះ ទើបឈ្មោះថា អនវសេសា លោកអធិប្បាយថា សូម្បីគ្រប់សត្វ ។ ក៏ពាក្យណា ត្រាស់ទុកខាងចុងនៃគាថាទី ២ ពាក្យនោះ គប្បីភ្ជាប់ជាមួយគ្រប់ទុកៈ និងតិកៈ ។ បទថា យេ កេចិ ចាណភូតត្ថិ សេចក្តីថា សត្វទាំងឡាយតក់ស្លុតក្តី មាំមួនក្តី មិនសេសសល់ឡើយ សត្វទាំងនោះសូម្បីទាំងអស់ ចូរជាអ្នកមានខ្លួនដល់នូវសេចក្តីសុខចុះ។ ពួកសត្វដែលកើតហើយក្តី កំពុងស្វែងរកទីកើតក្តីត្រឹមណា សត្វទាំងអស់សូម្បីទាំងនោះត្រឹមនោះ ចូរជាអ្នកមានខ្លួនដល់នូវសេចក្តីសុខចុះ ដោយប្រការដូច្នេះ ។

ឥឡូវនេះ បណ្តាបទទាំង ៦ មាន ឱឃា វា ជាដើម ដែលសម្តែងតិកៈ ៣ ពួក មាន**ទីឃរស្សមជ្ឈិមតិកៈ**ជាដើម ។ បទថា ឱឃា បានដល់ សត្វដែលមានអត្តភាពវែងមាន នាគ ត្រី ទន្សង ជាដើម ។ មែនពិត អត្តភាពរបស់នាគទាំងឡាយ

ក្នុងមហាសមុទ្រ សូម្បីមានទំហំច្រើនរយព្យាម ។ អត្តភាគរបស់ត្រី ទន្សង ជាដើម ក៏មានទំហំច្រើនយោជន៍ ។ បទថា មហន្តា បានដល់ សត្វមានអត្តភាពធំ ក្នុងទឹក មានត្រី អណ្តើកជាដើម នៅលើគោកមានស្តេចដំរីជាដើម ក្នុងជំពូកអមនុស្ស ក៏មានអសុរជាដើម និងត្រាស់ថា រាហូជាកំពូលរបស់សត្វដែលមានអត្តភាពទាំងឡាយ ។ មែនពិត អត្តភាពរបស់រាហូនោះ មានកម្ពស់ ៤.៨០០ យោជន៍ ដៃប្រវែង ១.២០០ យោជន៍ ចន្លោះចិញ្ចើមម្ខាងទៅចិញ្ចើមម្ខាង ៥០ យោជន៍ ចន្លោះម្រាមដៃក៏ដូចគ្នា បាតដៃប្រវែង ២០០ យោជន៍ ។ បទថា មជ្ឈិមា បានដល់ អត្តភាពរបស់សេះ គោ ក្របី ជ្រូកជាដើម ។ បទថា រស្សកា បានដល់ សត្វទាំងឡាយមានទំហំទាប ត្រង់កណ្តាលវែង ត្រង់កណ្តាលធាត់ មានមនុស្សតឿជាដើម ក្នុងជាតិនោះៗ ។ បទថា អណុកា បានដល់ សត្វទាំងឡាយដែលមានអត្តភាពល្អិត ឬតូចជាដើម ដែលកើតក្នុងទឹកជាដើម មិនមែនជាវិស័យរបស់មំសចក្ខុទេ ប៉ុន្តែជាវិស័យរបស់ទិព្វចក្ខុ ។ម្យ៉ាងទៀត សត្វពួកណាមានទំហំទាប ត្រង់កណ្តាលធំ និងត្រង់កណ្តាលធាត់ ក្នុងជាតិនោះ ៗ សត្វទាំងនោះ គប្បីជ្រាបថា តូច ។ បទថា ថូលា បានដល់ សត្វទាំងឡាយ ដែលមានអត្តភាពមូលក្លំមាន ត្រី ខ្យងជាដើម ។

## បញ្ចមគាថាវណ្ណនា

### ពណ៌នាគាថា ទី ៥

*ព្រះមានព្រះភាគ ទ្រង់សម្ដែងសត្វទាំងឡាយ មិនឱ្យសេសសល់ដោយតិកៈយ៉ាងនេះហើយ ឥឡូវនេះទ្រង់សង្គ្រោះដោយទុកៈ ៣ ទុកៈថា ទិដ្ឋា វា យេ ច អទិដ្ឋា ជាដើម ។*

*បណ្ដាបទទាំងនោះ បទថា ទិដ្ឋា បានដល់ សត្វពួកណា ដែលឃើញប្រាកដដោយភ្នែករបស់ខ្លួន ។ បទថា អទិដ្ឋា បានដល់ សត្វពួកណា តាំងនៅក្នុងសមុទ្រដទៃ ភ្នំដទៃ និងចក្រវាឡដទៃជាដើម ។ តែព្រះមានព្រះភាគ ទ្រង់សម្ដែងសត្វដែលនៅឆ្ងាយ និងមិនឆ្ងាយអត្តភាពរបស់ខ្លួនដោយទុកៈនេះថា យេ ច ទូរេ វសន្តិ អវិទូរេ ។ សត្វទាំងនោះ គប្បីជ្រាប ដោយជាសត្វមិនមានជើង និងសត្វមានជើង ២ ។ ក៏ពួកសត្វដែលនៅក្នុងកាយរបស់ខ្លួន ហៅថា អវិទូរេ (នៅមិនឆ្ងាយ) ពួកសត្វនៅក្រៅកាយ ហៅថា ទូរេ (នៅឆ្ងាយ) ។ម្យ៉ាងទៀត ពួកសត្វដែលនៅក្នុងឧបចារៈ ហៅថា នៅមិនឆ្ងាយ ។ ដែលនៅខាងក្រៅឧបចារៈ ហៅថា នៅឆ្ងាយ ។ សត្វដែលនៅក្នុងវិហារ តាមស្រុក ជនបទ ទ្វីប ចក្រវាឡ ហៅថា នៅក្នុងទីមិនឆ្ងាយ សត្វនៅក្នុងចក្រវាឡដទៃ ហៅថា នៅក្នុងទីឆ្ងាយ ។*

បទថា ភូតា បានដល់ កើតហើយ ។ ព្រះខីណាស្រពអង្គណា កើតហើយទុំះឯង មិនរាប់ថានឹងកើតម្តងទៀតទេ ពាក្យនោះជាឈ្មោះ របស់ព្រះខីណាស្រពអង្គនោះ ។ សត្វពួកណា ស្វែងរកទីកើត ហេតុនោះ សត្វទាំងនោះឈ្មោះ **សម្ភវេសី** ។ ពាក្យនេះជាឈ្មោះ របស់ព្រះសេក្ខៈ និងបុថុជ្ជនទាំងឡាយ ដែលកំពុងស្វែងរកទីកើត សូម្បីក្នុងអនាគត ព្រោះភវសំយោជនៈនៅមិនទាន់លះ ។ ម្យ៉ាងទៀត បណ្តាកំណើតទាំង ៤ ពួក សត្វដែលជាអណ្ឌជៈ (កើតក្នុងពង) និងជលាពុជៈ (កើតក្នុងគភ៌) នៅមិនទម្លាយសំបកពង និងស្រោមសុកចេញមកដរាបណា ក៏ឈ្មោះថា **សម្ភវេសី** ។ ដែលទម្លាយសំបកពង និងស្រោមសុកចេញហើយមកខាងក្រៅ ឈ្មោះថា **ភូត** ពួកសត្វដែលជាសំសេទជៈ និងឱបបាតិកៈឈ្មោះថា **សម្ភវេសី** ក្នុងខណៈបឋមចិត្ត តាំងតែខណៈទុតិយចិត្តទៅ ឈ្មោះថា **ភូត** ។ ម្យ៉ាងទៀត សត្វទាំងឡាយ កើតដោយឥរិយាបថណា នៅមិនប្តូរឥរិយាបថទៅជាយ៉ាងដទៃទៅអំពីឥរិយាបថនោះ ដរាបណា ដរាបនោះ ឈ្មោះថា **សម្ភវេសី** ក្រៅអំពីនោះទៅ ឈ្មោះថា **ភូត** ។

## ចដ្ឋគាថាវណ្ណនា

## ពណ៌នាគាថា ទី ៦

ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនាក្នុងសត្វទាំងឡាយ ដោយប្រាថ្នាតែនឹងឱ្យចូលដល់ប្រយោជន៍សុខរបស់ភិក្ខុទាំងនោះ ដោយប្រការផ្សេងៗ

ដោយ ២ គាថា ថា **សុខិនោ វា** ជាដើម យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងមេត្តាភាវនានោះ សូម្បីដោយប្រាថ្នាមិនឱ្យនូវវត្ថុដែលមិនជាប្រយោជន៍ និងសេចក្តីទុក្ខ ទើបត្រាស់ថា ន បរោ បរំ និកុព្វេថ ។ នេះជាបាឋៈចាស់ តែបច្ចុប្បន្ន សូត្រថា បរំ ហិ ដូច្នេះក៏ មាន បាឋៈនេះមិនល្អ ។

បណ្តាបទទាំងនោះ បទ បរោ បានដល់ ជនដទៃ ។ បទថា បរំ នូវជនដទៃ ។ បទថា ន និកុព្វេថ បានដល់ មិនកំហែងបៀតបៀន ។ បទថា នាតិមញ្ញេថ បានដល់ មិនគប្បីមើលងាយ ។ បទថា កត្ថចិ បានដល់ ក្នុងឱកាសណាមួយ គឺស្រុក គាមខេត្ត កណ្តាលញាតិ ឬកណ្តាលបុគ្គល ដូច្នេះជាដើម ។ បទថា នំ ប្រែថា នោះ ។ បទថា កិញ្ចិ បានដល់ អ្នកណាម្នាក់ គឺក្សត្រ ឬ ព្រាហ្មណ៍ គ្រហស្ថ ឬបព្វជិត ដែលដល់នូវសេចក្តីសុខ ឬសេចក្តីទុក្ខដូច្នេះជាដើម ។ បទថា ព្យារោសនា បដិឃសញ្ញា បានដល់ ព្រោះសេចក្តីក្រេវក្រោធដោយកាយវិការ និងវចីវិការ និងព្រោះចងគំនុំដោយមនោវិការ ។ ព្រោះកាលគួរនឹងត្រាស់ថា ព្យារោសនាយ បដិឃសញ្ញាយ តែក៏ត្រាស់ថា ព្យារោសនា បដិឃសញ្ញា ឬកាលគួរនឹងត្រាស់ថា សម្មទញ្ញាយ វិមុត្តា ក៏ត្រាស់ថា សម្មទញ្ញា វិមុត្តា និងដូចកាលគួរនិងត្រាស់ថា អនុបុព្វសិក្ខាយ អនុបុព្វកិរិយាយ អនុបុព្វបដិបទាយ តែក៏ត្រាស់ថា អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា ដូច្នេះ ។ បទថា នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ សេចក្តីថា មិនគប្បីប្រាថ្នានូវសេចក្តី ទុក្ខដល់គ្នានឹង

គ្នា លោកអធិប្បាយទុកយ៉ាងណា? លោកអធិប្បាយទុកថា បុគ្គល មិនមែនត្រឹមតែចម្រើនមេត្តា ដោយធ្វើទុកក្នុងចិត្តជាដើមថា សូមសត្វទាំងឡាយ ចូរមានសេចក្ដីសុខ មានសេចក្ដីក្សេមប៉ុណ្ណោះទេ ប៉ុន្តែគប្បីធ្វើទុកក្នុងចិត្តយ៉ាងនេះ ថា ឱហ្ន៎ បុគ្គលដទៃទៀតណា មិនគប្បីកំហែងបៀតបៀនបុគ្គលដទៃ មិនថានរណាៗ ដោយកិរិយាកោងវៀច មានបោកបញ្ឆោតជាដើម មិនគប្បីមើលងាយបុគ្គលដទៃ មិនថានរណាម្នាក់ មិនថាក្នុងប្រទេសណាមួយដោយវត្ថុនៃមានះ ៩ យ៉ាង មាន ជាតិជាដើម និងមិនគប្បីប្រាថ្នាសេចក្ដីទុក្ខដល់គ្នានឹងគ្នា ព្រោះសេចក្ដីក្រេវក្រោធ ឬព្រោះការចងគំនុំ ដូច្នេះទៀតផង ។

## សត្តមគាថាវណ្ណនា

## ពណ៌នាគាថា ទី ៧

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងមេត្តាភាវនា ដោយអត្ថដោយប្រាថ្នាឱ្យគេចេញចាកវត្ថុមិនជាប្រយោជន៍ និងទុក្ខយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងមេត្តាភាវនានោះនុ៎ះឯង ដោយឧបមាទើបត្រាស់ថា មាតា យថា និយំ បុត្តំ ជាដើម ។

គាថានោះមានសេចក្ដីថា មាតាគប្បីរក្សាបុត្រក្នុងខ្លួន គឺបុត្រដែលកើតអំពីខ្លួន គប្បីបីបាច់ថែរក្សាបុត្រនោះ ដែលមានខ្លួនតែមួយប៉ុណ្ណោះដោយជីវិត គឺព្រមលះបង់សូម្បីជីវិតរបស់ខ្លួនថ្នាក់ថ្នមបុត្រនោះ ដើម្បីហាមការពារទុក្ខមកដល់បុត្រ

នោះ ថ្នមរក្សាបុត្រនោះយ៉ាងណា កុលបុត្រគប្បីចម្រើនមេត្តានេះឱ្យច្រើន គឺឱ្យកើតជារឿយៗ ឱ្យផ្សាយទៅ និងញ៉ាំងមេត្តាភាវនានោះឱ្យចម្រើន ដោយមានសត្វជាអារម្មណ៍មិនមានប្រមាណ ឬផ្សាយទៅមិនឱ្យសល់សូម្បីតែក្នុងសត្វមួយ ។

អដ្ឋមគាថាវណ្ណនា

**ពណ៌នាគាថាទី ៨**

ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនា ដោយអាការៈទាំងពួងយ៉ាងនេះ ឥឡូវនេះ កាលទ្រង់សម្តែងការចម្រើនមេត្តាភាវនានោះទុំះឯង ទើបត្រាស់ថា មេត្តញ្ច សព្វលោកស្មឹ ជាដើម ។

ក្នុងគាថានោះ ឈ្មោះថា មិត្ត ព្រោះស្រឡាញ់ និងរក្សា អធិប្បាយថា ព្រួយបារម្ភណ៍ ព្រោះមានអធ្យាស្រ័យក្នុងប្រយោជន៍ និងរក្សាឱ្យផុតចាកនូវវត្ថុមិនជាប្រយោជន៍ ។ សភាពនៃមិត្តនោះ ឈ្មោះថា មេត្តា ។ បទថា **សព្វលោកស្មឹ** បានដល់ ក្នុងសត្វលោកមិនមានសេសសល់ឡើយ ។ មានក្នុងចិត្ត ហេតុនោះទើបឈ្មោះថា **មានសៈ** ។ ក៏ពាក្យថា **មានសៈ** នោះ លោកពោលយ៉ាងនេះ ព្រោះប្រកបជាមួយចិត្ត ។ បទថា ភាវយេ ប្រែថា ឱ្យចម្រើន ។ មិនមានប្រមាណហេតុនោះ ទើបឈ្មោះថា **អបរិមាណៈ** ។ លោកពោលយ៉ាងនេះ ក៏ព្រោះមេត្តា

មានសត្វ មិនមានប្រមាណជាអារម្មណ៍ ។ បទថា ឧទ្ធំ ប្រែថា ខាងលើ ។ ទ្រង់កាន់យកអរូបភពដោយបទនេះ ។ បទថា អធោ ប្រែថា ខាងក្រោម ។ ទ្រង់កាន់យកកាមភពដោយបទនេះ ។ បទថា តិរិយំ បានដល់ ទទឹង ។ ទ្រង់កាន់យករូបភពដោយបទនេះ ។ បទថា អសម្ពាធំ វៀរចាកសេចក្ដីចង្អៀត ។ លោកអធិប្បាយថា មិនមានព្រំដែន ។ សត្រូវ លោកហៅថា ព្រំដែន អធិប្បាយថា ប្រព្រឹត្តទៅក្នុងទីមិនមានព្រំដែននោះ ។ បទថា អវេរំ បានដល់ វៀរចាកវេរា អធិប្បាយថា វៀរចាកសេចក្ដីប្រាកដនៃចេតនាបង្កវេរា សូម្បីក្នុងចន្លោះៗ ។ បទថា អសបត្តំ បានដល់ ប្រាសចាកសត្រូវ ។ មែនពិត បុគ្គលអ្នកនៅដោយមេត្តា រមែងជាទីស្រឡាញ់របស់មនុស្ស និងជាទីស្រឡាញ់របស់ពួកអមនុស្ស ។ សត្រូវ របស់គេរមែងមិនមាន ។ ព្រោះហេតុនោះ ការទាក់ទងក្នុងចិត្តរបស់គេនោះ លោកទើបពោលថា **អសបត្តៈ** ព្រោះប្រាសចាកសត្រូវ ។ ក៏ពាក្យដែលពោលថា សឹកសត្រូវៗ ជាពាក្យសម្រាប់បរិយាយ ។ ការពណ៌នា សេចក្ដីតាមបទមានប៉ុណ្ណោះ ចំណែកការសម្ដែងសេចក្ដីដែលបំណងក្នុងទីនេះមានដូច្នេះ ។

គប្បីចម្រើនផ្សាយមេត្តាដែលត្រាស់ទុកថា ឯវម្បិ សព្វភូតេសុ មានសំភាវយេ អបរិមាណំ ដូច្នេះ ផ្សាយមេត្តាមាននៅក្នុងចិត្តមិនមានប្រមាណ ឱ្យ

បន្ទុះដល់សេចក្តីចម្រើន រីកលូតលាស់ល្អចម្រើនក្នុងលោកទាំងពួង ។ តើផ្សាយមេត្តាចិត្តយ៉ាងណា គឺផ្សាយមេត្តានោះ ទៅមិនសល់ទាំងខាងលើ ខាងក្រោម ខាងទទឹង ខាងលើតាំងពីកវគ្គព្រហ្មចុះមក ខាងក្រោមតាំងតែអវចីនរកឡើងទៅ ខាងទទឹង បានដល់ទិសដ៏សេស ឬខាងលើ បានដល់ អរូបធាតុ ខាងក្រោម បានដល់ កាមធាតុ ខាងទទឹង បានដល់ រូបធាតុផ្សាយទៅមិនឱ្យសេសសល់ ។ ក៏ឯកាលចម្រើនមេត្តានៅយ៉ាងនេះ ធ្វើមិនឱ្យមានសេចក្តីតូចចង្អៀត ពៀរ និងសត្រូវ គប្បីចម្រើនមេត្តានោះ ដោយប្រការមិនចង្អៀត មិនមានពៀរ និងមិនមានសត្រូវ ។ ឬថាមេត្តានោះ បានដល់ ភាវនាសម្បទាជាគុណ ឈ្មោះថា មិនចង្អៀត ព្រោះជាឱកាសលោកទាំងពួង (គឺ៣១ភូមិ) ជាគុណ ឈ្មោះថា មិនមានពៀរ ព្រោះកម្ចាត់ការចងអាឃាតរបស់ខ្លួនក្នុងសត្វដទៃទៀត ជាគុណ ឈ្មោះថា មិនមានសត្រូវ ព្រោះកម្ចាត់ការចងអាឃាតរបស់សត្វដទៃក្នុងខ្លួនទៀត ។ ក៏គប្បីចម្រើនមេត្តា ដែលមានក្នុងចិត្តនោះ ដែលមិនចង្អៀត ដែលមិនមានពៀរ ដែលមិនមានសត្រូវ មិនមានប្រមាណទៅក្នុងលោកទាំងពួង ដោយកំណត់ទិសទាំង ៣ គឺខាងលើ ខាងក្រោម និងខាងទទឹង ។

## នវមគាថាវណ្ណនា

### ពណ៌នាគាថា ទី ៩

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងការចម្រើនមេត្តាភាវនាយ៉ាងនេះហើយ កាលទ្រង់សម្តែងការមិនមានឥរិយាបថជាក់លាក់របស់អ្នកប្រកបរឿយៗ នៅការចម្រើនមេត្តានោះ ទើបត្រាស់ថា តិដ្ឋញ្ចរំ ។បេ។អធិដ្ឋេយ្យដូច្នេះ ។

គាថានោះមានសេចក្តីថា អ្នកចម្រើនមេត្តាកាលចម្រើនមេត្តាមានក្នុងចិត្តនោះយ៉ាងនេះ មិនត្រូវកំណត់ឥរិយាបថ ដូចក្នុងព្រះបាលីថា អង្គុយសមាធិ តាំងកាយឱ្យត្រង់ដូច្នេះជាដើម កាលធ្វើឱ្យធូរស្រាល ដោយបន្ទោបង់ការឈឺចាប់អស់កម្លាំងដោយឥរិយាបថ យ៉ាងណាមួយ តាមសប្បាយ និងឈរ ឬដើរ អង្គុយ ឬដេកត្រឹមណា ក៏គប្បីតាំងសតិក្នុងមេត្តាឈាននោះទុកត្រឹមនោះ ។

ន័យម្យ៉ាងទៀត ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងការចម្រើនមេត្តាភាវនាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងភាពជាអ្នកជំនាញ ទើបត្រាស់ថា តិដ្ឋញ្ចរំ ជាដើម ។ មែនពិត អ្នកជំនាញហើយ ញ៉ាំងបំណងនឹងតាំងសតិក្នុងមេត្តាឈាន ដោយឥរិយាបថមានឈរ ឬដើរ និងអង្គុយ ឬដេកក៏បាន ។ ន័យម្យ៉ាងទៀត អ្នកជំនាញ នឹងឈរ ឬដើរ និងអង្គុយ ឬដេក ព្រោះហេតុនោះ

ការឈរជាដើម រមែងមិនធ្វើអន្តរាយដល់អ្នកនោះ ។ ម្យ៉ាងទៀត អ្នកជំនាញញ៉ាំងបំណង និងតាំងសតិនោះទុក ក្នុងមេត្តាឈាននេះត្រឹមណា ក៏ត្រូវជាអ្នកប្រាសចាកសេចក្តីងងុយដេក ទើបតាំងសតិទុកបានត្រឹមនោះ ។ សេចក្តីយឺតយូរក្នុងមេត្តាឈាននោះ របស់អ្នកនោះ រមែងមិនមាន ព្រោះហេតុនោះ ទើបត្រាស់ថា និងឈរ ឬដើរ អង្គុយ ឬដេក នៅជាអ្នកប្រាសចាកសេចក្តីងងុយដេកត្រឹមណា ក៏គប្បីតាំងសតិនោះទុកត្រឹមនោះ ។

គាថានោះ មានអធិប្បាយដូច្នេះ អ្នកជំនាញគប្បីចម្រើនមេត្តា ដែលត្រាស់ទុកថា មេតញ្ច សព្វលោកស្មឹ មានសំ ភាវយេ ដោយប្រការដែលអ្នកជំនាញមិនអើពើដោយឥរិយាបថ បណ្តាឥរិយាបថមានឈរជាដើម ឬដល់ឥរិយាបថមានឈរជាដើម ញ៉ាំងបំណង និងតាំងសតិក្នុងមេត្តាឈាននោះត្រឹមណា ជាអ្នកប្រាសចាកសេចក្តីងងុយដេក ហើយក៏គប្បីតាំងសតិនោះទុកត្រឹមនោះ ។

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងភាពជាអ្នកជំនាញ ក្នុងមេត្តាភាវនាយ៉ាងនេះ ទ្រង់ប្រកាសកិច្ចអ្នកប្រកបក្នុងមេត្តាវិហារធម៌ ការនៅដោយមេត្តានោះថា ឯតំ សតឹ អធិដ្ឋេយ្យ គប្បីតាំងសតិនោះទុក ឥឡូវនេះ កាលទ្រង់លើកសរសើរការនៅនោះ ទើបត្រាស់ថា ព្រហ្មមេតំ វិហារំ ឥធមាហុ ។

គាថានោះ មានសេចក្តីថា ការនៅដោយមេត្តានេះឯណា ទ្រង់សរសើរតាំងតែអំពីដើម មានព្រះពុទ្ធតម្រាស់ថា **សុខិនោ វា ខេមិនោ វា ហោន្តុ** ចូរជាអ្នកមានសេចក្តីសុខ ឬមានសេចក្តីក្សេម ហើយត្រាស់បន្ថែមទៀតថា **ឯតំ សតឹ** អធិដ្ឋេយ្យ គប្បីតាំងសតិនោះ អស់កាលត្រឹមនោះ ។ អ្នកប្រាជ្ញទាំងឡាយ ពោលការនៅនោះថា **ព្រហ្មវិហារ** គឺនៅដូចព្រហ្ម ពោលការនៅនោះថា **សេដ្ឋវិហារ** ការនៅយ៉ាងប្រសើរបំផុត ក្នុងព្រះសាសនា គឺក្នុងធម្មវិន័យរបស់ព្រះអរិយៈនេះ ព្រោះមិនមានទោសក្នុងការនៅ ៤ យ៉ាងគឺ នៅជាទិព្វ នៅដូចព្រហ្ម នៅដូចព្រះអរិយៈ និងនៅដោយឥរិយាបថ ឯការនៅដោយមេត្តានោះ ធ្វើប្រយោជន៍ដល់ខ្លួន និងដល់អ្នកដទៃ ។ ព្រោះហេតុ ដែលសេចក្តីស្ងប់ទាក់ទងគ្នាមិនត្រូវជ្រៀតជ្រែក ដូច្នេះ អ្នកចម្រើនមេត្តា ឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី នៅមិនងងុយដេក ត្រឹមណា ក៏គប្បីតាំងសតិនោះ ទុកត្រឹមនោះ ។

## ទសមគាថាវណ្ណនា

## ពណ៌នាគាថា ទី ១០

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងមេត្តាភាវនាប្រការផ្សេងៗ ដល់ភិក្ខុទាំងនោះយ៉ាងនេះហើយ ឥឡូវនេះ ព្រោះហេតុ ដែលមេត្តាជិត**អត្តទិដ្ឋិ**

(សេចក្តីឃើញថាជាខ្លួន) ព្រោះមានសត្វជាអារម្មណ៍ដូច្នោះ កាលទ្រង់សម្តែងចាក់ចុះនូវអរិយភូមិ ធ្វើមេត្តាឈាននោះនុ៎ះឯងឱ្យជាបាទដល់ភិក្ខុទាំងនោះ ដើម្បីហាមការប្រកាន់យកនូវទិដ្ឋិជាប្រមុខ ទើបទ្រង់បញ្ចប់ទេសនានេះថា ទិដ្ឋិញ្ច អនុបគម្ម ជាដើម ។

គាថានោះ មានសេចក្តីថា ការនៅដោយមេត្តាឈាននេះណា ទ្រង់សរសើរទុកថា ព្រហ្មមេតំ វិហារំ ឥធមាហុ អ្នកទាំងឡាយ ពោលការនៅនោះថា ព្រហ្មវិហារក្នុងធម្មវិន័យនេះ អ្នកចម្រើនចេញចាកទៅនៅដោយមេត្តាឈាននោះហើយ កំណត់(នាម)ធម៌មានវិតក្កវិចារៈជាដើម ហើយកំណត់រូបធម៌ និង ដោយការកំណត់នាមរូបនេះ ក៏មិនចាប់ទុកទិដ្ឋិយ៉ាងនេះថា នេះកងសង្ខារដ៏បរិសុទ្ធ បុគ្គលរមែងកាន់មិនបានថា សត្វក្នុងសង្ខារនេះដូច្នេះ ជាអ្នកមានសីលដោយលោកុត្តរសីល តាមលំដាប់ដល់ព្រមដោយទស្សនៈ ព្រោះសម្គាល់ថា សម្មាទិដ្ឋិ ក្នុងសោតាបត្តិមគ្គ ដែលប្រកបដោយលោកុត្តរសីល តអំពីនោះ ក៏នាំចេញកម្ចាត់រម្ងាប់សេចក្តីជំពាក់ចិត្តក្នុងកាមទាំងឡាយ គឺកិលេសកាមដែលលះមិនបាន ដោយការធ្វើឱ្យស្តួចស្តើងដោយសកទាគាមិមគ្គ និងអនាគាមិមគ្គ និងការមិនឱ្យសល់ឡើយ ក៏រមែងមិនចូលដល់ការដេកក្នុងគភ៌មាតាទៀត គឺមិនត្រូវដេកក្នុងគភ៌

ទៀតយ៉ាងពិតប្រាកដ បានដល់ កើតក្នុងពពួកទេវតាក្នុងសុទ្ធាវាសទាំងឡាយ ចាក់ធ្លុះព្រះអរហត្តហើយបរិនិព្វានក្នុងជាន់សុទ្ធាវាសនោះនុ៎ះឯង ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់បញ្ចប់ទេសនាយ៉ាងនេះ ហើយត្រាស់នឹងភិក្ខុទាំងនោះថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយទៅចុះ អ្នកទាំងឡាយ ចូលនៅជងព្រៃនោះនុ៎ះឯង នឹងចូរគោះរគាំងក្នុងថ្ងៃធម្មសវនៈ(ថ្ងៃសន្ទនាធម៌) ទាំង ៨ ថ្ងៃ ក្នុង១ខែ ហើយចូរតាំងព្រះសូត្រនេះ ចូរធ្វើធម្មកថា ពោលធម៌សន្ទនាធម៌ អនុមោទនាគ្នា ចូរសេពគប់ ចូរចម្រើន ចូរធ្វើឱ្យច្រើននូវកម្មដ្ឋាននេះឯង ពួកអមនុស្សសូម្បីទាំងនោះ នឹងមិនសម្តែងអារម្មណ៍មិនជាទីភ័យខ្លាចនោះ និងប្រាថ្នាប្រយោជន៍ដល់ពួកលោកដោយពិត ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធតម្រាស់ថា សាធុ ដូច្នេះ ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំហើយ ធ្វើប្រទក្សិណទៅកាន់ជងព្រៃនោះ ហើយធ្វើតាមដែលទ្រង់បង្រៀនគ្រប់ប្រការ ។ ទេវតាទាំងឡាយ កើតបីតិសោមនស្សថាព្រះគុណម្ចាស់ទាំងឡាយ ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីចម្រើនដល់ពួកយើង ។ ទេវតាទាំងនោះ ក៏នាំគ្នាប្រមូលសម្អាតសេនាសនៈផ្ទាល់ខ្លួន ចាត់ចែងទឹកក្តៅប្របាច់ជើង គក់ខ្នង រៀបចំរក្សាទុក ភិក្ខុសូម្បីពួកនោះក៏នាំគ្នាចម្រើនមេត្តា ធ្វើមេត្តានោះឱ្យជាបាទ ផ្តើមវិបស្សនាក៏ចាក់ធ្លុះព្រះអរហត្តដែលជាផលដ៏ប្រសើរ

ខាងក្នុងត្រីមាសនោះទុំះឯងទាំងអស់អង្គ បវារណាដោយបរិសុទ្ធិបវារណា ក្នុងថ្ងៃមហាបវារណាចេញវស្សា ។

ឯវម្បិ អត្តកុសលេន តថាគតេន
ធម្មិស្សរេន កថិតំ ករណីយមត្តំ
កត្វានុភុយ្យ បរមំ ហទយស្ស សន្តឹ
សន្តំ បទំ អភិសមេន្តិ សមត្តបញ្ញា។
តស្មា ហិ តំ អមតមព្ភុតមរិយកន្តំ
សន្តំ បទំ អភិសមេច្ចវិហារិតុកាមោ
វិញ្ញូ ជនោ វិមលសីលសមាធិបញ្ញាភេទំ
ករេយ្យ សតតំ ករណីយមត្តន្តិ ។

ព្រះតថាគតជាម្ចាស់នៃធម៌ ទ្រង់ឆ្លាតក្នុងប្រយោជន៍ ត្រាស់
ករណីយមេត្តសូត្រដែលមានប្រយោជន៍ ដោយប្រការដូច្នេះ ។
ភិក្ខុទាំងឡាយ អ្នកមានបញ្ញាបរិបូណ៌ បានធ្វើនូវសេចក្តី
ស្ងប់ នៃហឫទ័យដ៏ប្រសើរ ក៏ចាក់ធ្លុះសន្តិបទ ។
ព្រោះដូច្នោះឯង វិញ្ញូជនអ្នកបំណងនឹងចាក់ធ្លុះសន្តិបទ

*ដែលជាអមតៈគួរអស្ចារ្យ ដែលព្រះអរិយៈជាម្ចាស់រក្សាហើយ ក៏គប្បីធ្វើករណីយដែលមានប្រយោជន៍ ផ្សេងដោយសីល សមាធិ បញ្ញា គ្មានមន្ទិលអ្វីឡើយ ។*

បរមត្ថជោតិកាយ ខុទ្ទកបាឋដ្ឋកថាយ

មេត្តសុត្តវណ្ណនា និដ្ឋិតា

**ចប់អដ្ឋកថាមេត្តសូត្រ**

**នៃ**

**អដ្ឋកថា ខុទ្ទកបាឋៈ ឈ្មោះថា បរមត្ថជោតិកា ។**

# និគមនកថា

*ដោយកថាមានប្រមាណប៉ុណ្ណេះ ខ្ញុំពោលពាក្យទុកថា ខ្ញុំសូមក្រាបថ្វាយបង្គំព្រះរតនត្រ័យដ៏ខ្ពង់ខ្ពស់បំផុត ជាវត្ថុដែលគួរក្រាបថ្វាយបង្គំ នឹងតែងអដ្ឋកថានៃខុទ្ទកបាឋៈ ។*

*ក្នុងគម្ពីរ**បរមត្ថជោតិកា**នេះ ខ្ញុំជាអ្នកតែងអដ្ឋកថានៃខុទ្ទកបាឋៈ ៩ ប្រការ គឺ ៖*

**១-ត្រៃសរណគមន៍**

**២-សិក្ខាបទ**

**៣-ទ្វត្តិំសាការៈ**

**៤-កុមារបញ្ហា**

**៥-មង្គលសូត្រ**

**៦-រតនសូត្រ**

**៧-តិរោកុឌ្ឌសូត្រ**

**៨-និធិកណ្ឌសូត្រ**

**៩-មេត្តសូត្រ**

*ព្រោះហេតុនោះ ខ្ញុំទើបពោលពាក្យនេះថា ខ្ញុំមានបំណង នឹងឱ្យព្រះសទ្ធម្មតាំងមាំ ទើបតែងអដ្ឋកថា នៃខុទ្ទកបាឋៈនេះ ជាកុសលយ៉ាងណា ។ សូមជនពួកនេះ ធាប់ចាក់ធ្លុះសេចក្តីចម្រើនរីកលូតលាស់ល្អ ចម្រើនក្នុងធម៌ ដែលព្រះអរិយៈជាម្ចាស់ លោកបានប្រកាសហើយ ព្រោះអានុភាពនៃកុសលមួយនេះ ។*

*អដ្ឋកថានៃខុទ្ទកបាឋៈឈ្មោះថា បរមត្ថជោតិកានេះ រចនាដោយព្រះថេរៈដែលគ្រូទាំងឡាយថ្វាយព្រះនាមថា ពុទ្ធឃោសៈ ប្រដាប់ដោយសទ្ធាពុទ្ធិ*

*(ការបេះដឹង) និងវីរិយៈដ៏បរិសុទ្ធដ៏ក្រៃលែង បានញុំាងហេតុនៃសីល អាចារៈ អាជ្ជវៈ (សេចក្តីស្មោះត្រង់) និងមទ្ទវៈ (ភាពទន់ភ្លន់) ជាដើម ឱ្យតាំងឡើងហើយ អាចក្នុងការដោះស្រាយសេចក្តីសាំញុំា (គឺវិនិច្ឆ័យសេចក្តីដែលស្មុគស្មាញ) ក្នុងសេចក្តីផ្សេងគ្នានៃលទ្ធិរបស់ខ្លួន និងអ្នកដទៃ ប្រកបដោយភាពភ្លឺស្វាងនៃបញ្ញា មានកម្លាំងនៃញាណ ដែលមិនទើសទាក់ក្នុងសត្ថុសាសន៍ អាចវែកញែកការសិក្សាព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា ជាមហាវេយ្យាករណ៍ (គឺជាអ្នកអធិប្បាយដ៏ទូលាយ) ប្រកបដោយលម្អនៃពាក្យពេចន៍ដ៏ពីរោះឯក ទាំងពោលចេញទៅបានស្រួល ដែលកើតអំពីករណសម្បត្តិ ជាអ្នកនិយាយថ្នាក់កំពូល ដោយនិយាយបាន ទាំងចង និងស្រាយ (សួរឆ្លើយ) ជាកវីថ្មី ជាអលង្ការនៃវង្សរបស់ព្រះថេរៈទាំងឡាយ អ្នកនៅក្នុងមហាវិហារ ដែលជាប្រទីបនៃថេរវង្ស មានសេចក្តីដឹងមុតមាំល្អ ក្នុងឧត្តរិមនុស្សធម៌ ដែលប្រដាប់ដោយគុណមាន អភិញ្ញា ៦ និងបដិសម្ភិទាជាដើម ដែលខ្លួនចាក់ធ្លុះហើយ ជាអ្នកមានការដឹងដ៏បរិសុទ្ធទូលំទូលាយ ជាអ្នកធ្វើបករណ៍នេះទុក ។*

តាវ តិដ្ឋតុ លោកស្មឹ លោកនិត្ថរណេសិនំ
ទស្សេន្តី កុលបុត្តានំ នយំ សីលាទិវិសុទ្ធិយា ។

*សម្រាប់ជាធម្មទាន*

យាវ ពុទ្ធោតិ នាមម្បិ សុទ្ធចិត្តស្ស តាទិនោ
លោកម្ហិ លោកជេដ្ឋស្ស បវត្តតិ មហេសិនោ ។

*(គម្ពីរបរមត្ថជោតិកា) ដែលសម្តែងន័យនៃវិសុទ្ធិ មានសីលវិសុទ្ធិជាដើម ចូរតាំងនៅក្នុងលោក ដើម្បីកុលបុត្រទាំងឡាយអ្នកស្វែងរកធម៌ ជាគ្រឿងរលាស់ខ្លួនចេញចាកលោក ។ ដរាបដល់ព្រះនាមថា* **ពុទ្ធោ** *របស់អង្គព្រះលោកជេដ្ឋៈ ជាអ្នកស្វែងរកគុណដ៏ធំ ដែលមានចិត្តបរិសុទ្ធ ជាអ្នកនឹងធឹង ប្រព្រឹត្តទៅក្នុងលោកចុះ ។*

បរមត្ថជោតិកាយ ខុទ្ទកដ្ឋកថាយ
ខុទ្ទកបាឋវណ្ណនា និដ្ឋិតា

**ការពណ៌នានូវខុទ្ទកបាឋៈ**

**ក្នុង**

**អដ្ឋកថា ខុទ្ទកបាឋៈ ឈ្មោះថា បរមត្ថជោតិកា ចប់ ។**

# ឯកសារយោង

១-គម្ពីរ បរមត្ថជោតិកា ភាសាបាលី, ច្បាប់ឆដ្ឋសង្គាយនា
២-គម្ពីរ បរមត្ថជោតិកាភាសាបាលី, ច្បាប់មហាមកុដរាជវិទ្យាល័យ
៣-គម្ពីរ បរមត្ថជោតិកា, ច្បាប់ប្រែរបស់មហាមកុដរាជវិទ្យាល័យ
៤-ព្រះត្រៃបិដកភាសាខ្មែរ, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ
៥-គម្ពីរ អដ្ឋកថា ដីកា, ច្បាប់ឆដ្ឋសង្គាយនា
៦-បទានុក្រមបាលី អភិធានប្បទីបិកា,ព្រះឧបាលិវង្ស ម៉ឹង សែស, ព.ស ២៥៣៩
៧-បទានុក្រមធម្មបទ(បីភាគ), ព្រះសាសនមុនី កិម តួរ, ព.ស ២៥៣៨
៨-ធាតុសង្គ្រោះ,ពុទ្ធសាសនបណ្ឌិត្យ,
៩-វចនានុក្រមខ្មែរ អេឡិចត្រូនិចកំណែទី ២,ពុទ្ធសាសនបណ្ឌិត្យ, ២០០៩
១០-វចនានុក្រមបាលី-ថៃ, ច្បាប់ភូមិពលោភិក្ខុ, ព.ស ២៥៣៥
១១-វចនានុក្រម អង់គ្លេស-ខ្មែរ, បណ្ឌិត ម៉ក់ បេន, ភ្នំពេញ ២០០៤
១២-វចនានុក្រម ថៃ-ខ្មែរ, យន់ វណ្ណាវង្ស និង រស់ សារ៉ាវុធ.ភ្នំពេញ ២០០៦
១៣-វចនានុក្រមអភិធម្មប្រាំពីរគម្ពីរ, លោក ស. បុញ្ញអារក្ស៍
១៤-វចនានុក្រមថៃ, ច្បាប់រាជបណ្ឌិត្យស្ថាន, ព.ស ២៥២៥
១៥-DICTIONARY of PALI PROPER NAMES VoL.1-2, C.P MALALASEKERA,LONDON, 1974.
16-PALI-ENGLISH DICTIONARY, T.W. Rhys Davids and William Stede, OXFORD, 1999
17-www.accesstoinsight.org
18-http://www.tipitaka.org/khmr
19-ឯកសារផ្សេងៗទៀតៗ

**<u>កំណត់សម្គាល់:</u>** ឯកសារព្រះពុទ្ធសាសនាទាំងឡាយ ជាភាសាបាលី អាចរកអាន បានក្នុងគេហទំព័រ: <u>http://www.tipitaka.org/khmr</u>